# សិក្សាពុទ្ធប្រវត្តិ

## ភាគ ២




វត្តនិគ្រោធវ័ន

រៀបរៀងដោយ ព្រះមហាសទ្ធម្មធរជោតិកៈ

សុវណ្ណជោតោ តួច-សុវណ្ណ

ពុទ្ធសករាជ ២៥៥៩

(សម្រាប់ជាធម្មទាន)

# សិក្សាពុទ្ធប្រវត្តិ

## ភាគ ២

វត្តនិគ្រោធវ័ន

រៀបរៀងដោយ

ព្រះមហាសទ្ធម្មធរជោតិកៈ

សុវណ្ណជោតោ ភួង-សុវណ្ណ

ពុទ្ធសករាជ ២៥៥៩

(សម្រាប់ជាធម្មទាន)

-សៀវភៅ **សិក្ខាពុទ្ធប្បវត្តិ ភាគ ២**

-រៀបរៀងដោយ **ភិក្ខុ សុវណ្ណជោតោ ឈួន-សុវណ្ណ**

**អាចារ្យបង្រៀនព្រះវិន័យ ឧត្តមសិក្សានៃវត្តនិគ្រោធវ័ន**

-អ្នកជួយពិនិត្យ

- **ភិក្ខុ វិនយធរោ គុន-ប៊ុនសាយ**
- **ភិក្ខុ សុមេធបណ្ឌិតោ ស៊ិន-ផល្លា**
- **សាមណេរ មុនីកោសល្យ នៅ-ហៃឡុន**

-គម្ពីរជាឧបករណ៍ សម្រាប់រៀបរៀងសៀវភៅនេះ

| | |
|---|---|
| -ព្រះត្រៃបិដក | -អដ្ឋកថា សមន្តប្បាសាទិកា |
| -អដ្ឋកថា សុមង្គលវិលាសិនី | -អដ្ឋកថា បបញ្ចសូទនី |
| -អដ្ឋកថា ជាតក | -អដ្ឋកថា មធុរត្ថវិលាសិនី |
| -អដ្ឋកថា សីហសូត្រ | -អដ្ឋកថា ពហុធាតុកសូត្រ |
| -អដ្ឋកថា ធម្មបទ | -សារត្ថទីបនីដីកា ជាដើម ។ |

-ស្ថានទីធ្វើ វត្តនិគ្រោធវ័ន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-ពុទ្ធសករាជ ២៥៥៩

-ធម្មទានដោយ ពុទ្ធបរិស័ទទូទៅ

# <u>អារម្ភកថា</u>

សៀវភៅ **សិក្សាពុទ្ធប្រវត្តិ** ភាគ ២ នេះ ខ្ញុំព្រះករុណារចនាបន្តពីភាគ ១ ដែលបានបោះពុម្ពចែកជាធម្មទានរួចមកហើយ ។

ក្នុងសៀវភៅនេះ ខ្ញុំព្រះករុណារៀបរាប់ចាប់ផ្តើមតាំងពី **សន្តិកេនិទាន** គឺព្រះសម្ពុទ្ធទ្រង់គង់ក្នុងទីណា តាំងពីព្រះអង្គត្រាស់ជាព្រះពុទ្ធ រហូតដល់ទ្រង់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និងរឿងខាងក្រោយពីព្រះអង្គបរិនិព្វានខ្លះ ។ តែការលើកឡើងមកសរសេរក៏មិនបានពិស្តារទេ គ្រាន់តែជាសេចក្តីសង្ខេបប៉ុណ្ណោះ ។ ដើម្បីពុទ្ធបរិស័ទសិក្សា បានយល់ដឹងពីពុទ្ធកិច្ចរបស់ព្រះអង្គ និងបាននូវសេចក្តីជ្រះថ្លាក្នុងគុណរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលព្រះ-អង្គទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន, ដូចដែលទ្រង់ត្រាស់ទុកថា

**ពុទ្ធោបិ ពុទ្ធស្ស ភណេយ្យ វណ្ណំ កប្បម្បិ ចេ អញ្ញមភាសមានោ**
**ខីយេថ កប្បោ ចិរទីឃមន្តរេ វណ្ណោ ន ខីយេថ តថាគតស្ស ។**

បើសូម្បីថា ព្រះពុទ្ធ គប្បីត្រាស់សរសើរព្រះគុណរបស់ព្រះពុទ្ធដោយមិនត្រាស់រឿងអ្វីដទៃទៀយ សូម្បីរហូតអស់ទាំងកប្ប, កប្បដែលមានក្នុងចន្លោះកាលដ៏យូរអង្វែង ក៏នឹងគប្បីអស់ទៅ តែការ

សរសើរព្រះគុណរបស់ព្រះតថាគត នៅមិនទាន់អស់ទៅឡើយ ។

ដោយមហាកុសលចេតនាណា ដែលខ្ញុំមានសេចក្ដីជ្រះថ្លាក្នុងព្រះសទ្ធម្ម ហើយរចនានេះ សូមឧទ្ទិសសៀវភៅនេះ ជាសក្ការៈបូជាថ្វាយចំពោះព្រះរតនត្រ័យ សូមព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធ ឋិតនៅអស់កាលយូរ ដោយអានុភាពនៃបុណ្យទាំងពួងនេះ សូមពួកញាតិនិងសព្វសត្តនិករ មួយអន្លើដោយពុទ្ធបរិស័ទទាំងឡាយ ចូរបានសេចក្ដីសុខ ឱ្យមានសេចក្ដីក្សេម ចូរជាអ្នកសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ ។ ម្យ៉ាងទៀត ដោយអំណាចមហា-កុសលនេះ សូមបានជាឧបនិស្ស័យនៃបញ្ញាសម្មាទិដ្ឋិ ការត្រាស់ដឹងនូវធម៌ ដល់ព្រមដោយបដិសម្ភិទា ក្នុងសាសនារបស់ព្រះមាន-ព្រះភាគ ក្នុងកាលជាអនាគត ។

សូមអនុមោទនា !

វត្តនិគ្រោធវ័ន ថ្ងៃ ១១ កើត ខែផល្គុន ព.ស.២៥៥៩

**ភិក្ខុ សុវណ្ណជោតោ ភួង~សុវណ្ណ**

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

អារម្ភកថា .......................................................... គ

សន្លឹកប្រាប់មាតិកា ............................................. ង

ពាហិរនិទាន ..................................................... ១

## I. សន្តិកេនិទាន

១- ៧ សប្តាហ៍និង ១១ ថ្ងៃក្រោយការត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ

១.១ ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្សលើមង្គលបល្ល័ង្ក ... ៣

១.២ អនិមិ្មសចេតិយ ............................................ ២៣

១.៣ រតនចង្រ្កមចេតិយ ....................................... ២៤

១.៤ រតនឃរចេតិយ ............................................ ២៦

១.៥ អជបាលនិគ្រោធ ......................................... ២៧

រស្មី ៦ ពណ៌របស់ព្រះមានព្រះភាគ ................. ៣១

រឿងមារ .................................................... ៣៤

១.៦ មុចលិន្ទ ...................................................... ៤០

១.៧ រាជាយតន ................................................... ៤៤

១.៨ សប្ដាហ៍ទី ៨ ក្រោយការត្រាស់ដឹង .................... ៥៣
ក-ទ្រង់យាងចូលកាន់ដើមអជបាលនិគ្រោធវិញ .... ៥៣
ខ-ព្រហ្មយាចនកថា ....................................... ៥៤
គ-សេចក្ដីប្រៀបផ្កាឈូកនឹងបុគ្គល ៤ ពួក .......... ៦២
ឃ-ពុទ្ធបរិវិតក្កៈ .......................................... ៦៧
ង-ព្រះមានព្រះភាគទ្រង់យាងទៅកាន់ក្រុងពារាណសី
ដើម្បីសម្ដែងធម្មចក្ក ................................. ៧៣
ច-ឥសិបតនមិគទាយវ័ន ................................ ៧៥
ឆ-ទ្រង់យាងដល់ឥសិបតនមិគទាយវ័ន ............. ៧៧
២-ទ្រង់សម្ដែងធម្មចក្កប្បវត្តនសូត្រ .............................. ៨៣
ញាណទស្សនៈមានបរិវដ្ដ ៣ អាការ ១២ ........... ១០៥
ពាក្យថាធម្មចក្ក .......................................... ១០៦
៣-ឧបសម្បទារបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ...................... ១១០
៤-បញ្ចវគ្គិយភិក្ខុត្រាស់ដឹងធមិតាមលំដាប់ .................... ១១១
៥-អនត្តលក្ខណសូត្រ ................................................ ១១៣
ឈ្មោះថាជាអនត្តា ដោយហេតុ ៤ យ៉ាង .................... ១៣១
ឈ្មោះថាមិនទៀង ដោយហេតុ ៤ យ៉ាង .................... ១៣៤

ឈ្មោះថាជាទុក្ខ ដោយហេតុ ៤ យ៉ាង ........................ ១៣៦
៦-នាឡកសូត្រ ........................................................... ១៤២
៧-មោនេយ្យសូត្រ ...................................................... ១៥១
៨-យសវត្ថុកថា .......................................................... ១៥៥
បិតារបស់ព្រះយសបានសម្រេចធម៌ ........................ ១៥៩
ឧបសម្បទារបស់ព្រះយស .................................... ១៦៦
ហេតុនៃឯហិភិក្ខុឧបសម្បទា .................................. ១៦៧
មាតានិងបុរាណទុតិយិកានៃព្រះយស ...................... ១៦៩
បព្វជ្ជារបស់គ្រហស្ថជាសម្លាញ់គ្នា ៤ នាក់ ................. ១៧២
បព្វជ្ជារបស់គ្រហស្ថជាសម្លាញ់គ្នា ៥០ នាក់ ............. ១៧៦
៩-ការប្រកាសនូវព្រហ្មចរិយធម៌ ................................. ១៨១
ដីកាពន្យល់ពីលំអ ៣ យ៉ាង ................................ ១៨៦
១០-មារកថា ........................................................... ១៩៣
១១-បព្វជ្ជាកថា ....................................................... ១៩៥
១២-ភទ្ទវគ្គិយកុមារ ៣០ អង្គ ..................................... ២០០
១៣-រឿងជដិលជាបងប្អូននឹងគ្នា ............................... ២០៥
១៤-អាទិត្តបរិយាយ ................................................ ២១៣

ចក្ខុ ២ យ៉ាង ........................................................ ២២៣
ញាណចក្ខុ ៥ យ៉ាង ........................................... ២២៣
មំសចក្ខុមាន ២ យ៉ាង ...................................... ២២៤
១៥-ការជួបជុំរបស់ព្រះបាទពិម្ពិសារ ............................ ២៣០
១៦-បព្វជ្ជារបស់ព្រះសារីបុត្តនិងព្រះមោគ្គល្លាន ............. ២៣៦
១៧-កុលបុត្រអ្នកដែនមគធៈបួស ................................. ២៥៨
១៨-ទីឃនខសូត្រ ...................................................... ២៦១
១៩-ឱវាទបាតិមោក្ខ ................................................. ២៧១
២០-រឿងព្រះបាទសុទ្ធោទនសក្យរាជ ........................... ២៧៥
២១-មហាធម្មបាលជាតក ........................................... ២៩៩
២២-ពួកជដិលច្រើនរូប ............................................ ២៩៩
២៣-ពាហិយទារុចីរិយ ............................................. ៣១០
២៤-ព្រះមានព្រះភាគចូលទៅកាន់បាវាលចេតិយ .......... ៣១៩
២៥-ទ្រង់ដាក់អាយុសង្ខារ ........................................ ៣២៦
២៦-បច្ច័យដែលនាំឱ្យកក្រើកផែនដីមាន ៨ យ៉ាង ......... ៣៣២
២៧-ទ្រង់ធ្វើនិមិត្ត ១៦ កន្លែង .................................. ៣៤៤
២៨-ទ្រង់ឱ្យប្រជុំភិក្ខុសង្ឃ ........................................ ៣៤៧

២៩-ការទ្រង់ទតក្រុងវេសាលីជាបច្ឆិមទស្សនៈ ................ ៣៥៣
៣០-មហាបទេស ៤ ................................................ ៣៥៥
៣១-ទ្រង់ទៅកាន់ក្រុងបាវា ........................................ ៣៦៧
៣២-ព្រះតថាគតទ្រង់ល្ងិតល្ហៃ .................................... ៣៧៣
៣៣-ឆវីវណ្ណបរិសុទ្ធផូរផង់ក្រៃពេកក្នុងកាលទាំងពីរ ........ ៣៧៧
៣៤-ទ្រង់ស្តេចចុះកាន់ស្ទឹងកកុធៈ ................................ ៣៧៩
៣៥-ចង្ហាន់បិណ្ឌបាត ២ មានផលស្មើគ្នា ........................ ៣៨១
៣៦-ទ្រង់ចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ...... ៣៨៦
៣៧-ការបូជាចំពោះព្រះតថាគត ................................ ៣៩៤
៣៨-រឿងព្រះឧបវាណ ............................................ ៤០៦
៣៩-សំវេជនីយដ្ឋាន ៤ កន្លែង .................................. ៤១៤
៤០-ការប្រតិបត្តិក្នុងមាតុគ្រាម .................................. ៤១៧
៤១-ការប្រតិបត្តិក្នុងព្រះសរីរៈ .................................... ៤២១
៤២-ថូបារហបុគ្គល ៤ ពួក ......................................... ៤២៣
៤៣-អច្ឆរិយព្ភូតធម៌មាននៅក្នុងព្រះអានន្ទ .................. ៤៣០
៤៤-រាជធានីឈ្មោះកុសាវតី ...................................... ៤៣២
៤៥-ការថ្វាយដំណឹងដល់ពួកមល្លក្សត្រ ........................ ៤៣៦

៤៦-រឿងសុភទ្ទបរិព្វាជក .......................................... ៤៣៨
៤៧-ទ្រង់ប្រទានព្រះឱវាទដល់ភិក្ខុសង្ឃ ........................ ៤៤៦
៤៨-ពោលអំពីសិក្ខាបទតូចនិងតូច ............................... ៤៥០
៤៩-ទ្រង់ឱ្យភិក្ខុសាកសួរ ....................................... ... ៤៥៤
៥០-បច្ឆិមវាចារបស់ព្រះមានព្រះភាគ ......................... ៤៥៦
៥១-ការបរិនិព្វាននៃព្រះមានព្រះភាគ ......................... ៤៥៧
៥២-ហេតុកើតព្រមនឹងការបរិនិព្វាន .......................... ៤៦២

## II. កាលជាខាងក្រោយពីការបរិនិព្វាន

១-ការកន្ទក់កន្ទេញនៃបរិស័ទ ..................................... ៤៦៧
២-ការថ្វាយដំណឹងបរិនិព្វាន ....................................... ៤៧០
៣-មល្លក្សត្រិយ៍ ៨ អង្គ ........................................... ៤៧៣
៤-រឿងព្រះមហាកស្សប .......................................... ៤៨០
៥-ព្រះសរីរធាតុរបស់ព្រះមានព្រះភាគ ........................ ៤៩៥
៦-ពណ៌ព្រះបរមធាតុ ............................................... ៤៩៦
៧-ខ្នាតព្រះបរមធាតុ ............................................... ៤៩៧
៨-ការរំលត់ជើងថ្ករជាដើម ....................................... ៤៩៨

៩-រឿងព្រះបាទអជាតសត្តុជាដើម ............................... ៥០២
១០-ការចែកព្រះសរីរធាតុនៃព្រះមានព្រះភាគ .............. ៥១៥
១១-ព្រះស្តូប ១០ ស្ថាន ............................................ ៥១៩
១២-ព្រះសរីរធាតុ ................................................... ៥២១
១៣-ការបូជារបស់ព្រះបាទអជាតសត្តុ ......................... ៥២៣

## III. វេមត្តកថា

១-វេមត្តៈ ៨ ប្រការ ................................................ ៥២៩
១.១ អាយុវេមត្តៈ ..................................................... ៥២៩
១.២ បមាណវេមត្តៈ ................................................. ៥៣១
១.៣ កុលវេមត្តៈ ....................................................... ៥៣២
១.៤ បធានវេមត្តៈ ..................................................... ៥៣២
១.៥ រស្មីវេមត្តៈ ....................................................... ៥៣៤
១.៦ យានវេមត្តៈ ..................................................... ៥៣៤
១.៧ ពោធិរុក្ខវេមត្តៈ ................................................ ៥៣៦
១.៨ បល្លង្កវេមត្តៈ ..................................................... ៥៣៨

# IV. ផ្សេងៗ

១-ស្ថានទីព្រះពុទ្ធទ្រង់មិនលះ ..................................... ៥៣៩
២-ការកំណត់សហជាតនិងកំណត់នក្ខត្តឫក្ស .................... ៥៣៩
៣-រឿងធម្មតារបស់ព្រះពុទ្ធ .......................................... ៥៤១
៤-រឿងអនន្តរាយិកធម៌ ............................................... ៥៤៤
៥-ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ......................... ៥៤៥

# V. អត្ថបទកំណាព្យ

(១) ដំណើរយាត្រានមស្ការពុទ្ធស្ថាន ............................. ៥៤៩
(២) វត្តជេតពនជាទីរីករាយ .......................................... ៥៤៩
(៣) ទីក្រុងកបិលពស្ដុ .................................................. ៥៥០
(៤) និគ្រោធារាម ........................................................ ៥៥១
(៥) កុសិនារាគួរឲ្យអាឡោះ ......................................... ៥៥១
(៦) មកុដពន្ធនចេតីយ៍ ................................................ ៥៥២
(៧) ក្រុងវេសាលី ....................................................... ៥៥២
(៨) ទ្រង់ប្រាប់ការបរិនិព្វាន ........................................... ៥៥៣
(៩) បាតលិបុត្តអសោការាម ......................................... ៥៥៤
(១០) ទីក្រុងរាជគ្រឹះ ..................................................... ៥៥៤

(១១) វត្តអម្ពវ័នជាដើម ................................................ ៥៥៥
(១២) ឥន្ទសាលគុហាជាដើម ...................................... ៥៥៦
(១៣) ភ្នំបណ្ឌវៈ ........................................................ ៥៥៦
(១៤) ទុក្ករកិរិយាជាផ្លូវអម ........................................ ៥៥៧
(១៥) ៧ សប្តាហ៍ក្រោយការត្រាស់ដឹង ......................... ៥៥៨
(១៦) ស្ថានទីត្រាស់ដឹងពោធិព្រឹក្ស ................................ ៥៥៩
(១៧) សួនធម្មចក្ក ...................................................... ៥៦០
(១៨) ហែព្រះបរមសារីរិកធាតុនៅពារាណសី ................ ៥៦១
(១៩) អាទិត្តបរិយាយសូត្រ ........................................ ៥៦១
(២០) ឥន្ទសាលគុហា ................................................ ៥៦២
(២១) សេនាបតីសារីបុត្ត ............................................ ៥៦៣
(២២) អង្គុលិមាល ...................................................... ៥៦៣
(២៣) ក្រុងកោសម្ពីឃោសិតារាម ................................ ៥៦៤
(២៤) វាំងចាស់ព្រះបាទស្តេចឧទេន ............................ ៥៦៤
(២៥) ព្រះពាកុលៈ ...................................................... ៥៦៥
(២៦) ដែនសង្កស្សអចលចេតីយ៍ ................................ ៥៦៦
(២៧) សតិប្បដ្ឋានព្រះធម្មី ........................................ ៥៦៦
(២៨) ស្ថានទីព្រះពុទ្ធមិនលះបង់ ................................ ៥៦៧
(២៩) ព្រះធាតុព្រះសម្មាសម្ពុទ្ធ .................................... ៥៦៨

(៣០) បូជាព្រះបរមសារីរិកធាតុ ...................................... ៥៦៩
(៣១) សាធុសាធុ ចិត្តត្រេកអរ ...................................... ៥៦៩
(៣២) ព្រះពុទ្ធសម្តែងជយបរិត្ត ...................................... ៥៧០
(៣៣) វិហារផ្កាឈូក ...................................... ៥៧១
(៣៤) ឯករាជសព្វសត្វតែងប្រាថ្នា ...................................... ៥៧១
(៣៥) ចូលវិហារ ...................................... ៥៧២
(៣៦) វដ្តសង្សារជាផ្លូវឆ្ងាយ ...................................... ៥៧២
(៣៧) មគ្គអង្គប្រាំបីដ៏ប្រពៃ ...................................... ៥៧៣
(៣៨) ឆ្លងសង្សារ ...................................... ៥៧៤
(៣៩) បុណ្យបូកនិងបុណ្យ ...................................... ៥៧៤
(៤០) មានទ្រព្យត្រូវប្រើដោយបញ្ញា ...................................... ៥៧៥
(៤១) សូមជូនបុណ្យ ...................................... ៥៧៥
(៤២) ប្រពៃណាស់ ...................................... ៥៧៦
៤៣ ថ្ងៃទ្រង់បរិនិព្វាន ...................................... ៥៧៦

# នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
# សូមនមស្ការ ចំពោះព្រះមានព្រះភាគ
# ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## ពាហិរនិទាន

*ឥឡូវនេះ នឹងពណ៌នាសេចក្ដីនៃពុទ្ធប្រវត្តិនោះ ដែលនាំបន្ដមកយ៉ាងនេះ ក៏ព្រោះហេតុការពណ៌នាសេចក្ដីនេះ ត្រូវសម្ដែងនិទានទាំង ៣ នេះគឺ* ***ទូរេនិទាន អវិទូរេនិទាន*** *និង* ***សន្តិកេនិទាន*** *នឹងពណ៌នា ទើបឈ្មោះថាជាការពណ៌នាដោយល្អ និងឈ្មោះថាអ្នកស្ដាប់និទាននោះដឹងរឿងបាន ព្រោះដឹងតាំងពីដើមហេតុដែលកើត ដូច្នោះខ្ញុំនឹងសម្ដែងនិទានទាំងនោះហើយ ទើបពណ៌នា ។*

*ក្នុងនិទាននោះ គប្បីជ្រាបកាលបរិច្ឆេទរបស់និទានទាំងនោះចាប់ដើមតាំងពីដើមមុន ការសម្ដែងសេចក្ដីដោយសង្ខេបក្នុងនិទាននោះដូច្នេះ តាំងពីព្រះមហាសត្វបំពេញបារមី ទៀបព្រះបាទរបស់ព្រះទសពលសម្ពុទ្ធព្រះនាមថា* ***ទីបង្ករ*** *រហូតដល់ចុតិចាកអត្តភាព*

ជាព្រះវេស្សន្តរ ហើយកើតក្នុងភពតុសិត កថាដែលប្រព្រឹត្តទៅត្រឹមតែប៉ុណ្ណោះ ឈ្មោះថា **ទូរេនិទាន** (និទានក្នុងកាលឆ្ងាយ) ។

តាំងពីចុតិចាកភពតុសិត ដរាបកើតព្រះសព្វញ្ញុតញ្ញាណទៀបពោធិមណ្ឌស្ថាន កថាដែលប្រព្រឹត្តទៅត្រឹមតែប៉ុណ្ណោះ ឈ្មោះថា **អវិទូរេនិទាន** (និទានក្នុងកាលមិនឆ្ងាយ) ។

តាំងពីទ្រង់ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ទៀបគល់មហាពោធិមណ្ឌស្ថាន ដរាបដល់គ្រែជាទីបរិនិព្វាន ក្នុងចន្លោះនេះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីណាៗ ទីនោះៗ ដូចជា “សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវន ជាអារាមរបស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី”, ថា “ទ្រង់គង់នៅក្នុងវត្តវេឡុវន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ”, និងថា “ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវន ទៀបក្រុងវេសាលី”, ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា **សន្តិកេនិទាន** ។

បណ្ដានិទានទាំង ៣ នេះ **ទូរេនិទាន អវិទូរេនិទាន** ខ្ញុំបានពោលហើយ ក្នុងសៀវភៅសិក្សាពុទ្ធប្រវត្តិ ភាគ ១ ។ ក្នុងសៀវភៅភាគ ២ នេះ នឹងពោល**សន្តិកេនិទាន** ល្មមសមគួរតទៅ ។

# សន្តិកេនិទាន

## ១_៧សប្តាហ៍និង ១១ ថ្ងៃក្រោយការត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ

### ១.១ ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្សលើមង្គលបល្ល័ង្ក

*សន្តិកេនិទាន រមែងមានក្នុងទីនោះៗឯង, លោកពោលទុកយ៉ាងនោះក៏ពិត សូម្បីយ៉ាងនោះ សន្តិកេនិទាននោះ គប្បីជ្រាបយ៉ាងនេះ ចាប់ផ្តើមតាំងពីដើមទៅ ។*

*ព្រះមានព្រះភាគ កាលទ្រង់មានព្រះតម្រិះថា យើងត្រាច់រង្គាត់អន្ទោលមកអស់ ៤ អសង្ខ្យេយ្យ ១ សែនកប្ប ក៏ព្រោះហេតុនៃបល្ល័ង្កនេះ បល្ល័ង្កនេះជាវិជ័យបល្ល័ង្ក មង្គលបល្ល័ង្ករបស់យើង យើងគង់លើបល្ល័ង្កនេះ សេចក្តីត្រិះរិះ នៅមិនទាន់បរិបូរណ៍ដរាបណា យើងក៏នឹងមិនទាន់ក្រោកឡើងចាកបល្ល័ង្កនេះដរាបនោះ ទ្រង់ចូលសមាបត្តិរាប់បានច្រើនសែនកោដិ ទ្រង់គង់លើបល្ល័ង្កនោះអស់ ៧ ថ្ងៃ ដែលលោកពោលទុកថា ៖*

*"កាលព្រះមានជោគ បានត្រាស់ដឹងជាដម្បូង ទ្រង់គង់នៅក្រោមម្លប់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរាក្នុងឧរុវេលាប្រទេស ។*

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយព្រះភ្លែនតែមួយអស់ ៧ ថ្ងៃ ក្រោមម្លប់ពោធិព្រឹក្ស ទ្រង់សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ)” ។

ក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះសមន្តបាសាទិកា ពន្យល់ត្រង់ពាក្យថា **ពោធិ** និង **ពោធិព្រឹក្ស** ថា ៖

ពាក្យថា **ពោធិរុក្ខមូលេ** សេចក្តីថា ញាណ ក្នុងមគ្គ ៤ ហៅថា **ពោធិញាណ** ព្រះមានព្រះភាគ ទ្រង់បានត្រាស់ដឹងពោធិញាណនោះ ក្រោមម្លប់ដើមឈើនេះ ព្រោះហេតុនោះ ដើមឈើទើបបានឈ្មោះថា **ពោធិព្រឹក្សផង** ក្រោមម្លប់ពោធិព្រឹក្សនោះ ឈ្មោះថា **ពោធិរុក្ខមូល** ។

ក្នុងគម្ពីរសារត្ថទីបនីដីកា លោកពោលទុកថា **មគ្គញ្ញាណ** លោកហៅថា **ពោធិ** ក្នុងពាក្យថា ញាណក្នុងមគ្គ ៤ ហៅថា ពោធិញាណ ។ សព្វញ្ញុតញ្ញាណ ហៅថា **ពោធិ** ក្នុងពាក្យថា ព្រះមានព្រះភាគ មានបញ្ញាដូចផែនដីដ៏ប្រសើរ សម្រេចព្រះ-ពោធិញាណ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់សម្រេចពោធិញាណទាំងពីរនោះ ក្រោមដើមឈើនេះ ហេតុនោះ សូម្បីដើមឈើ ក៏ត្រឡប់បានឈ្មោះថា **ពោធិព្រឹក្ស** ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ

ឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹងពោជ្ឈង្គ ៧ ។ ដើមឈើនោះ ឈ្មោះថា **ពោធិព្រឹក្ស** ព្រោះព្រះមានព្រះភាគអង្គនោះ ព្រះអង្គទ្រង់ត្រាស់ដឹង ទ្រង់អាស្រ័យហើយ ។

## សេចក្តីរំពឹងរបស់ព្រះមានព្រះភាគ

វេលានោះ ព្រះមានព្រះភាគ ទ្រង់រំពឹងនូវបដិច្ចសមុប្បាទធម៌ ជាអនុលោមប្បដិលោម គឺបណ្តោយចុះ និងច្រាសឡើង អស់បឋមយាមនៃរាត្រី ដោយន័យថា ៖

សង្ខារទាំងឡាយកើតមាន ព្រោះមានអវិជ្ជាជាហេតុ
វិញ្ញាណកើតមាន ព្រោះមានសង្ខារជាហេតុ
នាមរូបកើតមាន ព្រោះមានវិញ្ញាណជាហេតុ
សឡាយតនៈកើតមាន ព្រោះមាននាមរូបជាហេតុ
ផស្សៈកើតមាន ព្រោះមានសឡាយតនៈជាហេតុ
វេទនាកើតមាន ព្រោះមានផស្សៈជាហេតុ
តណ្ហាកើតមាន ព្រោះមានវេទនាជាហេតុ
ឧបាទានកើតមាន ព្រោះមានតណ្ហាជាហេតុ
ភពកើតមាន ព្រោះមានឧបាទានជាហេតុ

ជាតិកើតមាន ព្រោះមានភពជាហេតុ

សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ទាំងឡាយកើតមាន ព្រោះមានជាតិជាហេតុ, សេចក្ដីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។

ម្យ៉ាងទៀត សេចក្ដីរលត់សង្ខារកើតមាន ព្រោះវិនាស និងរលត់មិនមានសេសសល់នៃអវិជ្ជា សេចក្ដីរលត់វិញ្ញាណ កើតមាន ព្រោះរលត់សង្ខារ សេចក្ដីរលត់នាមរូបកើតមាន ព្រោះរលត់វិញ្ញាណ សេចក្ដីរលត់សឡាយតនៈកើតមាន ព្រោះរលត់នាមរូប សេចក្ដីរលត់ផស្សៈកើតមាន ព្រោះរលត់សឡាយតនៈ សេចក្ដីរលត់វេទនាកើតមាន ព្រោះរលត់ផស្សៈ សេចក្ដីរលត់តណ្ហាកើតមាន ព្រោះរលត់វេទនា សេចក្ដីរលត់ឧបាទានកើតមាន ព្រោះរលត់តណ្ហា សេចក្ដីរលត់ភពកើតមាន ព្រោះរលត់ឧបាទាន សេចក្ដីរលត់ជាតិកើតមាន ព្រោះរលត់ភព សេចក្ដីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀត

ចន្លុលទាំងឡាយ ក៏សឹងតែរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្ដីរលត់កងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះ ។

គ្រានោះ (ក្នុងបឋមយាមនៃរាត្រី) ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនេះ ហើយទើបបន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា ៖

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឲ្យក្ដៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្ដីសង្ស័យទាំងឡាយទាំងពួងរបស់ខីណាសវព្រាហ្មណ៍នោះ ក៏សឹងតែរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។

ក្នុងមជ្ឈិមយាមនៃរាត្រី ព្រះអង្គទ្រង់បន្លឺនូវឧទានគាថានេះថា

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ ខយំ បច្ចយានំ អវេទិ ។

*ធម៌ទាំងឡាយ រមែងប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួង របស់ខីណាសវព្រាហ្មណ៍នោះ តែងរម្ងាប់អស់ទៅក្នុងកាលនោះ ព្រោះថា ខីណាសវព្រាហ្មណ៍នោះ បានដឹងច្បាស់នូវព្រះនិព្វាន ជាទីអស់ទៅនៃបច្ច័យ ។*

ក្នុងបច្ឆិមយាមនៃរាត្រី ព្រះអង្គទ្រង់បន្លឺនូវឧទានគាថានេះថា

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ

សុរិយោវ ឱភាសយមន្តលិក្ខំ ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាម ញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេសក្នុងកាលណា ខីណាសវព្រាហ្មណ៍នោះ រមែងកំចាត់បង់នូវមារ ព្រមទាំងសេនាមារ ហើយឋិតនៅក្នុងកាលនោះ បីដូចព្រះអាទិត្យរះឡើង ធ្វើអាកាសឲ្យរុងរឿងដោយរស្មីរបស់ខ្លួន កំចាត់បង់នូវងងឹតឋិតនៅ ដូច្នោះឯង ។

## អដ្ឋកថា

ក្នុងអដ្ឋកថាសមន្តប្បាសាទិកា លោកពោលទុកថា ៖

បទថា **ឯកបល្លង្កេន** (ទ្រង់គង់ដោយព្រះភ្លេនតែមួយ) មានសេចក្តីថា ទ្រង់គង់ដោយបល្ល័ង្កតែមួយ ដែលទ្រង់ពែនហើយប៉ុណ្ណោះ ទ្រង់មិនក្រោកឡើងសូម្បីតែម្តង ។

បទថា **វិមុត្តិសុខប្បដិសំវេទី** (ទ្រង់សោយវិមុត្តិសុខ) មានសេចក្តីថា សោយវិមុត្តិសុខ គឺសុខដែលកើតអំពីផលសមាបត្តិ ។

បទថា បដិច្ចសមុប្បាទំ បានដល់ បច្ចយាការៈ ។

មែនពិត បច្ចយាការៈ លោកហៅថា បដិច្ចសមុប្បាទ ព្រោះអត្ថ វិគ្រោះថា អាស្រ័យគ្នានិងគ្នា ញុាំងធម៌ដែលជាប់តគ្នា ឲ្យកើតឡើង ។ បទថា អនុលោមប្បដិលោមំ មានវិគ្រោះថា បណ្ដាយលំដាប់ផង ច្រាសលំដាប់ផង ឈ្មោះថា ទាំងបណ្ដាយលំដាប់ ទាំងច្រាសលំដាប់ ។

អ្នកសិក្សាគប្បីឃើញសេចក្ដីក្នុងបទនោះ យ៉ាងនេះឯងថា បណ្ដាអនុលោម និងបដិលោមទាំងពីរនោះ **បច្ចយាការៈ** មានអវិជ្ជាជាដើម ដែលលោកពោលដោយន័យមានជាដើមថា **អវិជ្ជា-បច្ចយា សង្ខារា** ដូច្នេះ ហៅថា អនុលោម ព្រោះធ្វើកិច្ចដែលខ្លួនគប្បីធ្វើ ។

បច្ចយាការៈនោះឯង ដែលលោកពោលដោយន័យមានជាដើមថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ដូច្នេះ កាលរលត់ព្រោះនិរោធ គឺមិនកើតឡើង រមែងមិនធ្វើកិច្ចនោះ ព្រោះហេតុដូច្នោះ ទើបហៅថា **បដិលោម** ព្រោះមិនធ្វើកិច្ចនោះ ។ មយ៉ាងទៀត បច្ចយាការៈដែលលោកពោលហើយតាមន័យមុននោះឯង ប្រព្រឹត្តទៅតាមហេតុ ក្រៅពីនេះ ប្រព្រឹត្តទៅត្រឡប់

ប្រាសចាកហេតុ ។ ឯសេចក្ដីអនុលោម និងបដិលោមក្នុងបច្ចយាការៈនេះ នៅមិនទាន់ត្រូវដោយសេចក្ដីដទៃអំពីនេះ ព្រោះលោកមិនបានពោលតាំងអំពីដើមដរាបដល់ចុង និងតាំងអំពីចុងដរាបដល់ដើម ។

បទថា មនសាកាសិ បានដល់ បានធ្វើទុកក្នុងព្រះហឫទ័យ ។ បណ្ដាអនុលោម និងបដិលោមទាំងពីរនោះ ព្រះមានព្រះភាគ ទ្រង់បានធ្វើទុកក្នុងព្រះហឫទ័យជាអនុលោម ដោយប្រការឯណា ដើម្បីសម្ដែងប្រការនោះមុន ព្រះធម្មសង្គាហកាចារ្យទើបពោលពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម ។ ក្នុងពាក្យនោះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីក្នុងបទទាំងពួង ដោយន័យនេះថា អវិជ្ជានោះផង ជាបច្ច័យផង ព្រោះហេតុដូច្នោះ ឈ្មោះថា អវិជ្ជាជាបច្ច័យ, សង្ខារទាំងឡាយរមែងកើតព្រម ព្រោះអវិជ្ជាដែលជាបច្ច័យនោះ ។ ឯព្រះមានព្រះភាគ ទ្រង់បានធ្វើទុកក្នុងព្រះហឫទ័យជាបដិលោមដោយប្រការឯណា, ដើម្បីសម្ដែងប្រការនេះ លោកទើបពោលពាក្យថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ជាដើម ។

ក្នុងពាក្យនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បទថា **អវិជ្ជាយ ត្វេវ** កាត់បទថា **អវិជ្ជាយ តុ ឯវ** ។

បទថា **អសេសវិរាគនិរោធា** (ព្រោះរលត់មិនមានសេសសល់) មានសេចក្តីថា ព្រោះរលត់មិនមានសេសសល់ដោយមគ្គ ពោលគឺ វិរាគៈ ។

បទថា **សង្ខារនិរោធោ** (សេចក្តីរលត់សង្ខារ) បានដល់សេចក្តីរលត់ គឺសេចក្តីមិនកើតឡើងនៃសង្ខារទាំងឡាយ ។ ក៏ឯដើម្បីសម្តែងថា សេចក្តីរលត់នៃវិញ្ញាណកើតមាន ក៏ព្រោះរលត់សង្ខារទាំងឡាយ ដែលរលត់ទៅហើយយ៉ាងនោះ និងធម៌ទាំងឡាយមាននាមរូបជាដើម នឹងបានជាធម៌ដែលរលត់ល្អហើយតែម្តង ក៏ព្រោះរលត់នៃធម៌ទាំងឡាយ មានវិញ្ញាណជាដើម លោកទើបពោលពាក្យថា **សង្ខារនិរោធា វិញ្ញាណនិរោធោ** ជាដើម ហើយពោលពាក្យថា កងទុក្ខទាំងអស់នេះជាការរលត់ទៅដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កេវលស្ស** (ទាំងអស់នេះ) បានដល់ទាំងមូល សេចក្តីថា ប្រាសចាកសត្វ ។

បទថា **ទុក្ខក្ខន្ធស្ស** (នៃគំនរទុក្ខ) បានដល់ កងទុក្ខ ។

ពីរបទថា **និរោធោ ហោតិ** (សេចក្ដីរលត់កើតមាន) មានសេចក្ដីថា សេចក្ដីមិនកើត រមែងមាន ។

ពីរបទថា **ឯតមត្ថំ វិទិត្វា** (ទ្រង់ជ្រាបច្បាស់សេចក្ដីនេះហើយ) មានសេចក្ដីថា សេចក្ដីនេះណាដែលព្រះធម្មសង្គាហកាចារ្យពោលថា កងទុក្ខមានសង្ខារជាដើម ជាការកើតឡើងដោយអំណាចនៃបច្ច័យមានអវិជ្ជាជាដើម និងជាការរលត់ទៅ ដោយអំណាចរលត់នៃបច្ច័យ មានអវិជ្ជាជាដើមដូច្នេះ ទ្រង់ជ្រាបសេចក្ដីនោះ ដោយអាការទាំងពួង ។

ពីរបទថា **តាយំ វេលាយំ** (ក្នុងវេលានោះ) បានដល់ ក្នុងវេលាដែលទ្រង់ជ្រាបសេចក្ដីនោះៗ ។

បទថា **ឥមំ ឧទានំ ឧទានេសិ** (ទើបបន្លឺនូវឧទានគាថា) សេចក្ដីថា ទ្រង់បន្លឺឧទានដែលកើតឡើងព្រមដោយសោមនស្សប្រកបដោយបញ្ញា មានពាក្យថា **យទា ហវេ បាតុភវន្តិ** (ធម៌ទាំងឡាយរមែងប្រាកដក្នុងកាលណា) ជាដើមនេះ ដែលសម្ដែងអានុភាពដែលទ្រង់ជ្រាបហេតុ និងធម៌ដែលកើតអំពីហេតុ ក្នុងសេចក្ដីដែល

ទ្រង់ជ្រាបហើយនោះ មានពាក្យអធិប្បាយថា ទ្រង់បន្លឺព្រះវាចាសម្តែងសេចក្តីរីករាយព្រះហឫទ័យ ។

សេចក្តីនៃឧទាននោះថា បទថា **យទា ហវេ** (ក្នុងកាលណា) បានដល់ ក្នុងកាលឯណា ។ បទថា **បាតុភវន្តិ** (រមែងប្រាកដ) បានដល់ រមែងកើត ។ ពោធិបក្ខិយធម៌ ដែលឲ្យសម្រេចនូវការត្រាស់ដឹងបច្ចយាការៈដោយអនុលោម ឈ្មោះថា ធម៌ ។

ម្យ៉ាងទៀត បទថា **បាតុភវន្តិ** មានសេចក្តីថា ជាក់ច្បាស់ គឺជារបស់ច្បាស់លាស់ ប្រាកដដោយអំណាចការត្រាស់ដឹង ។ ធម៌គឺអរិយសច្ចៈ ៤ ឈ្មោះថា **ធម៌** ។ សេចក្តីព្យាយាម ហៅថា **អាតាបៈ** ព្រោះអត្ថថា ដុតកំដៅកិលេសឲ្យក្តៅ ។ បទថា **អាតាបិនោ** (អ្នកមានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ) បានដល់ អ្នកមានសេចក្តីព្យាយាមដែលបុគ្គលគប្បីតាំងទុកដោយប្រពៃ ។

បទថា **ឈាយតោ** (អ្នកដុតបង់នូវកិលេស) មានសេចក្តីថា អ្នកសំឡឹងដោយឈាន ២ គឺដោយការកំណត់ គឺអារម្មណូបនិជ្ឈាន ១ ដោយការកំណត់ គឺលក្ខណូបនិជ្ឈាន ១ ។

បទថា **ព្រាហ្មណស្ស** (ដល់ព្រះខីណាសវព្រាហ្មណ៍)

បានដល់ ព្រះទីណាស្រេពដែលបណ្តេតបាបហើយ ។

ប្រើនបទថា **អថស្ស កង្ខា វបយន្តិ** (សេចក្តីសង្ស័យទាំងឡាយរបស់ព្រះទីណាសវព្រាហ្មណ៍នោះ រមែងរម្ងាប់ទៅ) មានសេចក្តីថា កាលនោះសេចក្តីសង្ស័យរបស់ព្រាហ្មណ៍នោះ គឺអ្នកមានធម៌ប្រាកដហើយយ៉ាងនោះ រមែងអស់ទៅ ។

បទថា **សព្វា** (ទាំងពួង) មានសេចក្តីថា សេចក្តីសង្ស័យក្នុងបច្ចយាការដែលលោកបានពោលទុក ដោយន័យជាដើមថា កាលគេសួរថា "បពិត្រព្រះអង្គដ៏ចម្រើន នណាហ្ន៎ តែងពាល់ត្រូវ ព្រះមានព្រះភាគ ត្រាស់តបថា ប្រស្នានេះមិនត្រូវទេ" ដូច្នេះ និងដោយន័យជាដើមថា កាលគេសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ជរា និងមរណៈ តើដូចម្តេចហ្ន៎ មួយទៀត ជរា និងមរណៈនេះ ជារបស់អ្នកណា ។ ព្រះមានព្រះភាគ ត្រាស់តបថា ប្រស្នានេះមិនត្រូវទេ" ដូច្នេះ ។ ក៏សេចក្តីសង្ស័យ ១៦ យ៉ាងជាដើមថា ក្នុងអតីតកាលយើងបានមានហើយឬហ្ន៎ ? ដែលមកហើយ ព្រោះមិនទាន់បានត្រាស់ដឹងបច្ចយាការៈនុ៎ះឯង ទាំងអស់នេះ រមែងអស់ទៅ គឺរមែងប្រាសចាកទៅ រមែងរលត់ទៅ ។ ព្រោះហេតុអ្វី ? ព្រោះ

ហេតុដែលដឹងធម៌ព្រមទាំងហេតុ ។ មានអធិប្បាយថា ព្រោះជ្រាប គឺជ្រាបច្បាស់ ត្រាស់ដឹងធម៌ គឺកងទុក្ខទាំងអស់មានសង្ខារជាដើម នេះ ព្រមទាំងហេតុ ដោយហេតុមានអវិជ្ជាជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយវារៈ ៖

បីបទថា **ឥមំ ឧទានំ ឧទានេសិ** (ទើបបន្លឺនូវឧទានគាថា នេះ) មានសេចក្តីថា ទ្រង់បន្លឺឧទាន មានប្រការដូចពោលហើយ នេះ ដែលសម្តែងអានុភាពនៃការត្រាស់ដឹង ការអស់បច្ច័យ ពោល គឺនិព្វានដែលប្រាកដហើយយ៉ាងនេះថា **អវិជ្ជាយ ត្វេវ អសេស-វិរាគនិរោធា សង្ខារនិរោធោ** ក្នុងសេចក្តីដែលទ្រង់ជ្រាបហើយ នោះ ។

សេចក្តីសង្ខេបក្នុងឧទាននោះ ដូចតទៅនេះ ៖

ព្រោះបានដឹង គឺបានជ្រាបច្បាស់បានត្រាស់ដឹងនិព្វាន ពោលគឺសេចក្តីអស់បច្ច័យទាំងឡាយ កាលណាធម៌ទាំងឡាយ មានប្រការដូចពោលហើយ ប្រាកដដល់ព្រាហ្មណ៍នោះ ដែលមាន ព្យាយាម កាលនោះសេចក្តីសង្ស័យគ្រប់យ៉ាង ដែលនឹងគប្បីកើត ឡើង ព្រោះមិនដឹងនិព្វាន រមែងអស់ទៅ ។

*គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយវារៈ តទៅ ៖*

*បីបទថា* ***ឥមំ ឧទានំ ឧទានេសិ*** *មានសេចក្តីថា ទ្រង់បន្លឺឧទានមានប្រការដូចពោលហើយនេះ ដែលសម្តែងអានុភាពនៃអរិយមគ្គ ដែលជាហេតុ ទ្រង់ជ្រាបសេចក្តីពោលគឺការកើត និងការរលត់នៃកងទុក្ខនោះ ដោយអំណាចកិច្ច និងដោយធ្វើឲ្យជាអារម្មណ៍ ។*

*<u>សេចក្តីសង្ខេបក្នុងឧទាននោះ ដូចតទៅនេះ</u> ៖*

*ធម៌ទាំងឡាយ ប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានសេចក្តីព្យាយាមញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា, ក្នុងកាលនោះ ខីណាសវព្រាហ្មណ៍នោះ រមែងកម្ចាត់បង់នូវមារព្រមទាំងសេនាមារ ដោយពោធិបក្ខិយធម៌ដែលកើតហើយទាំងនោះ ឬដោយអរិយមគ្គជាគ្រឿងប្រាកដនៃចតុសច្ចធម៌ឋិតនៅ ។ ពាក្យថា* ***វិធូបយំ តិដ្ឋតិ មារសេនំ*** *សេចក្តីថា រមែងកម្ចាត់ គឺផ្ចាញ់ បង្ក្រាបសេនាមារ មានប្រការដូចពោលហើយ ដោយន័យជាដើមថា "កាមទាំងឡាយជាសេនាទី ១ របស់អ្នក"[១]*

---

១. ខុទ្ទ. សុត្ត. ៥៤. ៤១ / ១៣៧ ។

ដូច្នេះ តាំងនៅ ។

សួរថា កម្ចាត់យ៉ាងណា ?

ឆ្លើយថា ដូចព្រះអាទិត្យបំភ្លឺអាកាសឲ្យភ្លឺដូច្នោះ ។

អធិប្បាយថា ព្រះអាទិត្យរះឡើងទៅហើយ កាលបំភ្លឺអាកាសឲ្យភ្លឺដោយរស្មីរបស់ខ្លួនឯង ឈ្មោះថា កម្ចាត់ងងឹតចេញសេចក្ដីនេះយ៉ាងណា ។ ព្រាហ្មណ៍សូម្បីនោះ កាលត្រាស់ដឹងសច្ចៈទាំងឡាយ ដោយធម៌ទាំងនោះ ឬដោយមគ្គនោះឯង ឈ្មោះថាកម្ចាត់សេនាមារចេញបាន សេចក្ដីនេះក៏យ៉ាងនោះ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបសន្និដ្ឋានថា ក្នុងឧទានទាំង ៣ នេះ ឧទានទី ១ កើតឡើងដោយអំណាចការពិចារណាបច្ចយការៈ ឧទានទី ២ កើតឡើងដោយអំណាចការពិចារណាព្រះនិព្វាន ឧទានទី ៣ កើតឡើងដោយអំណាចការពិចារណាមគ្គ ដោយប្រការដូច្នេះ ។

ចំណែកក្នុងឧទាន លោកពោលថា "ទ្រង់រំពឹងក្នុងព្រះហឫទ័យចំពោះបដិច្ចសមុប្បាទធម៌ជាអនុលោម គឺពិចារណាបណ្ដោយអស់រាត្រីបឋមយាម, ជាបដិលោម គឺពិចារណាច្រាសឡើង អស់មជ្ឈិមយាមនៃរាត្រី, ជាអនុលោម និងបដិលោម អស់រាត្រីបច្ឆិម-

យាម” ពាក្យនោះ លោកពោលសំដៅយកមនសិការដែលព្រះមានព្រះភាគ ទ្រង់ឲ្យកើតឡើងរហូតអស់រាត្រី ដោយទ្រង់តាំងព្រះហឫទ័យថា “ក្នុងថ្ងៃស្អែកគប្បីគតនឹងក្រោកអំពីអាសនៈ ព្រោះគ្រប់ ៧ ថ្ងៃ” ។ ពិតមែន គ្រានោះ ព្រះមានព្រះភាគ ទ្រង់បានពិចារណាចំណែកមួយៗ ប៉ុណ្ណោះ រហូតអស់បឋមយាម និងមជ្ឈិមយាម ដោយអំណាចនៃការជ្រាបច្បាស់នូវបច្ចយាការៈ និងការសម្រេចការអស់ទៅនៃបច្ច័យ ដែលមានអានុភាពដែលឧទានគាថា ២ ខាងដើមសម្តែងទុក តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់បានពិចារណាយ៉ាងនោះ ក្នុងរាត្រីថ្ងៃបាដិបទ (១រោច) ។ ពិតមែន ក្នុងរាត្រីពេញបូណ៌មីខែវិសាខ ព្រះមានព្រះភាគ ទ្រង់រលឹកបុព្វេនិវាសក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងមជ្ឈិមយាម ទ្រង់ពិចារណាបដិច្ចសមុប្បាទដោយអនុលោម និងបដិលោម ក្នុងបច្ឆិមយាម ទ្រង់សម្រេចភាពជាព្រះសព្វញ្ញូ ក្នុងខណៈដែលនឹងគប្បីពោលថា អរុណនឹងរះឡើងឥឡូវនេះ ។ អរុណរះឡើងក្នុងវេលាបន្ទាប់ពីវេលា ដែលទ្រង់បានសម្រេចភាពជាព្រះសព្វញ្ញូតែម្តង ។ តពីនោះ ទ្រង់ញុំាងថ្ងៃនោះឲ្យកន្លងផុតទៅដោយការ

អង្គុយចម្រើនសមាធិនោះឯង ហើយទ្រង់ពិចារណាយ៉ាងនោះ បន្ទឹឧទានទាំងនេះ ក្នុងយាមទាំង ៣ នៃរាត្រីថ្ងៃបាដិបទ ដែលដល់ព្រមហើយ ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាយ៉ាងនោះ ក្នុងរាត្រីថ្ងៃបាដិបទ ឲ្យ ៧ ថ្ងៃដែលលោកពោលយ៉ាងនេះថា "ទ្រង់គង់នៅដោយភ្នែនតែមួយអស់ ៧ ថ្ងៃ ក្រោមម្លប់ពោធិព្រឹក្ស" នោះកន្លងផុតទៅ ក្រោមម្លប់ពោធិព្រឹក្សនោះឯង ដោយប្រការដូច្នេះ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា</u> លោកអធិប្បាយទុកថា ៖

ឥឡូវនេះ លោកអាចារ្យបានផ្តើមពាក្យថា ចំណែកក្នុងឧទានជាដើម ដើម្បីនឹងសម្តែងសេចក្តីមិនខុសគ្នានៃព្រះបាលី ក្នុងឧទាន ដែលព្រះធម្មសង្គាហកាចារ្យបានពោលទុកយ៉ាងនេះថា ក៏ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ប្រថាប់នៅសោយវិមុត្តិសុខដោយបល្ល័ង្កតែមួយរហូតអស់ ៧ ថ្ងៃ គ្រានោះឯង លុះសប្តាហ៍នោះកន្លងទៅ ព្រះមានព្រះភាគ ស្តេចចេញចាកសមាធិនោះ ទ្រង់បានធ្វើមនសិការបដិច្ចសមុប្បាទ ដែលជាអនុលោមដោយល្អ រហូតដល់អស់បឋមយាមនៃរាត្រី ទ្រង់បានធ្វើមនសិការបដិច្ចសមុប្បាទ ដែលជាបដិលោមដោយល្អ រហូតដល់អស់មជ្ឈិម

យាមនៃរាត្រី ទ្រង់បានធ្វើមនសិការបដិច្ចសមុប្បាទ ដែលជាអនុលោម និងបដិលោមដោយល្អ រហូតដល់អស់បច្ឆិមយាមនៃរាត្រី និងក្នុងព្រះបាលីនៃខន្ធកៈនេះ ។

ពីរបទថា តស្ស វសេន សេចក្ដីថា ដោយអំណាចនៃសេចក្ដីដឹងច្បាស់បច្ចយាការៈ និងសេចក្ដីសម្រេចការអស់ទៅនៃបច្ច័យនោះ ។ ពីរបទថា ឯកេកកមេវ កោដ្ឋាសំ សេចក្ដីថា ចំណែកមួយៗ ប៉ុណ្ណោះ បណ្ដាបដិច្ចសមុប្បាទ ដែលជាអនុលោម និងបដិលោមទាំងឡាយ ។ ពាក្យថា ទ្រង់មនសិការយ៉ាងនេះ ក្នុងរាត្រីថ្ងៃបាដិបទ សេចក្ដីថា ទ្រង់មនសិការបដិច្ច-សមុប្បាទដែលជាអនុលោម និងបដិលោមក្នុងយាមទាំង ៣ នៃរាត្រី ។ បានឮថា ព្រះមានព្រះភាគ ទ្រង់ពិចារណាធម៌ក្នុងចន្លោះៗ ប្រថាប់សោយវិមុត្តិសុខដោយច្រើន ក្នុងសប្ដាហ៍ទាំង ៦ ដ៏សេស វៀរសប្ដាហ៍ត្រង់រតនឃរចេតិយ ។ ក៏ក្នុងសប្ដាហ៍ នៃរតនឃរចេតិយ ប្រថាប់នៅដោយអំណាចទ្រង់ពិចារណាព្រះ-អភិធម្មតែម្យ៉ាង ព្រោះហេតុនោះ ទើបមានអធិប្បាយថា ព្រះធម្ម-សង្គាហកាចារ្យទាំងឡាយពោលទុកយ៉ាងនេះ ក្នុងព្រះបាលីក្នុង

*ខន្ធក: សំដៅដល់ការដែលទ្រង់មនសិការដែលព្រះមានព្រះភាគឲ្យកើតឡើងក្នុងរាត្រីថ្ងៃបាដិបទ បណ្តាមនសិការដែលទ្រង់ឲ្យកើតឡើង ដោយទ្រង់ពិចារណាធម៌ក្នុងចន្លោះៗ ។*

*( ចាកសារត្ថទីបនីដីកា )*

## ពោធិព្រឹក្ស កន្លែងព្រះអង្គត្រាស់ដឹង





# ១.២ អនិមិ្មសចេតិយ

*ទេវតាពួកខ្លះកើតសេចក្ដីសង្ស័យឡើងថា ព្រះមានព្រះភាគទ្រង់មិនក្រោកឡើង ធម៌ដែលធ្វើភាវៈជាព្រះពុទ្ធសូម្បីដទៃ នឹងមានទៀតទេដឹង ? លំដាប់នោះ ព្រះមានព្រះភាគ ចេញចាកសមាបត្តិក្នុងថ្ងៃទី ៨ ទ្រង់ជ្រាបសេចក្ដីសង្ស័យរបស់ពួកទេវតា ដើម្បីកាត់សេចក្ដីសង្ស័យ ទើបទ្រង់ហោះឡើងពួដ៏អាកាស សម្ដែងយមក-បាដិហារ្យ កំចាត់បង់សេចក្ដីសង្ស័យរបស់ពួកទេវតាទាំងនោះ*

ហើយទ្រង់ឈរសំឡឹងមើល ដោយព្រះនេត្រមិនបានប៉ព្រិច នូវព្រះបល្ល័ង្ក និងពោធិព្រឹក្សដែលជាស្ថានទីបានសម្រេចផលនៃព្រះ-បារមី ដែលទ្រង់កសាងមកអស់ ៤ អសង្ខេយ្យ កម្រៃ ១ សែនកប្ប ឲ្យមួយសប្តាហ៍កន្លងផុតទៅ ។ ក្នុងទិសឧត្តរ ផ្ទៀងទៅខាងទិសបូព៌បន្តិច (ទិសឦសាន) អំពីព្រះបល្ល័ង្ក ស្ថានទីនោះឈ្មោះថា **អនិម្មិសចេតិយ** ។

## ១.៣ រតនចង្រ្កមចេតិយ

លំដាប់ពីនោះមក ស្តេចចង្រ្កមលើរតនចង្រ្កមដ៏វែងឆ្ងាយទៅខាងមុខនិងខាងក្រោយ ចន្លោះព្រះបល្ល័ង្ក និងទីដែលស្តេចទ្រង់ឈរ (អនិម្មិសចេតិយ) ឲ្យមួយសប្តាហ៍កន្លងផុតទៅ ។ ស្ថានទីនោះ ឈ្មោះថា **រតនចង្រ្កមចេតិយ** ។

ពាក្យថា **រតនចង្រ្កម** បានដល់ ទីចង្រ្កមដែលសម្រេចដោយរតនៈ ដែលទេវតាទាំងឡាយនិម្មិតថ្វាយ ។


រតនចង្ក្រមចេតិយ


រតនចង្ក្រមចេតិយ

## ១.៤ រតនឃរចេតិយ

*តអំពីនោះមក ទេវតាទាំងឡាយ និម្មិតផ្ទះកែវឡើង ក្នុងបស្ចិមទិស, ព្រះមានព្រះភាគ ទ្រង់គង់ពែនព្រះភ្លែនសមាធិ ក្នុងផ្ទះកែវនោះ ទ្រង់ពិចារណាអភិធម្មបិដក និងសមន្តប្បដ្ឋាន ដែលមានន័យមិនមានទីបំផុត ក្នុងអភិធម្មបិដកនេះ ដោយពិស្តារឲ្យមួយសប្តាហ៍កន្លងផុតទៅ ។ ស្ថានទីនោះ ឈ្មោះថា* ***រតនឃរ-ចេតិយ*** *។ អាចារ្យទាំងឡាយពោលថា ស្ថានទីនោះ មានឈ្មោះថា* ***រតនឃរចេតិយ*** *ព្រោះទ្រង់ពិចារណាបករណ៍ទាំង ៧ ដែលជារតនៈ និងព្រោះទ្រង់ពិចារណាព្រះធម្មរតនៈដ៏កំពូល បណ្តាបករណ៍ទាំង ៧ នោះដូច្នេះក៏មាន ។ ដោយហេតុនោះឯង ក្នុងអដ្ឋសាលិនី លោកអាចារ្យទើបពោលទុកថា ដែលឈ្មោះថា* ***រតនឃរ*** *មិនមែនជាផ្ទះដែលសម្រេចដោយរតនៈ តែជាស្ថានទីពិចារណាបករណ៍ទាំង ៧ ។ គប្បីជ្រាបថា ឈ្មោះថា* ***រតនឃរ*** *ប្រែថា ផ្ទះកែវ ។*

# ១.៥ អជបាលនិគ្រោធ

ព្រះមានព្រះភាគ ឲ្យបួនសប្តាហ៍កន្លងផុតទៅ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាធិនោះហើយ ទ្រង់ចេញពីម្លប់ពោធិព្រឹក្ស យាងចូលទៅកាន់ដើមអជបាលនិគ្រោធ លុះចូលទៅដល់ហើយ ទ្រង់គង់ពែនភ្នែនតែមួយ ។ អង្គុយអស់មួយសប្តាហ៍ ក្រោមម្លប់អជបាលនិគ្រោធព្រឹក្ស សោយវិមុត្តិសុខ (គឺសុខក្នុងផលសមាបត្តិ) ។

ពាក្យថា **សោយវិមុត្តិសុខ** គឺទ្រង់ពិចារណាព្រះធម៌នោះឯង ទ្រង់សោយវិមុត្តិសុខក្នុងចន្លោះៗ ។ ម្យ៉ាងទៀត គប្បីកាន់យកបាលីក្នុងពាក្យនេះយ៉ាងនេះថា **ធម្មំ វិចិនតោ វិមុត្តិសុខញ្ច បដិសំវេទេន្តោ** ដែលប្រែថា ទ្រង់ពិចារណាព្រះធម៌ និងទ្រង់សោយវិមុត្តិសុខ ។ ក៏សូម្បីក្នុងអដ្ឋកថានៃគម្ពីរឧទាន ក៏មានបាលីដូច្នេះ ដូចគ្នា ។

ក៏ព្រះមានព្រះភាគ កាលទ្រង់ពិចារណាព្រះធម៌ត្រង់អជ-បាលនិគ្រោធនេះ ទ្រង់ពិចារណាន័យដ៏ក្រៃលែងក្នុងអភិធម្ម យ៉ាងនេះ គឺគម្ពីរដំបូងឈ្មោះថា ធម្មសង្គណីបករណ៍ តអំពីធម្ម-

សង្គណីបករណ៍នោះ ទ្រង់ពិចារណា វិភង្គបករណ៍ ធាតុកថា-បករណ៍ បុគ្គលប្បញ្ញត្តិបករណ៍ កថាវត្ថុបករណ៍ យមកបករណ៍ៗ តអំពីបករណ៍យមកនោះ ទ្រង់ពិចារណា មហាបករណ៍ ឈ្មោះថា **បដ្ឋាន** ។ បណ្តាបករណ៍ទាំង ៧ នោះ កាលព្រះទ័យបានឈានចុះក្នុងគម្ពីរបដ្ឋាន ដែលល្អិតសុខុម ព្រះបីតិក៏កើតឡើងដល់ព្រះមានព្រះភាគនោះ ។ កាលព្រះបីតិកើតឡើងហើយ ព្រះលោហិតក៏ថ្លាៗ កាលព្រះលោហិតថ្លាបរិសុទ្ធហើយ ព្រះឆវីវណ្ណក៏ផូរផង់ ។ កាលព្រះឆវីវណ្ណផូរផង់ហើយ ព្រះរស្មី មានប្រមាណប៉ុនផ្ទះកំពូលជាដើម ក៏ផុសឡើងអំពីព្រះកាយខាងមុខ ស្ទុះទៅកាន់អនន្ត-ចក្កវាឡ ក្នុងបាចីនទិស (ទិសខាងកើត) ដូចត្រកូលនៃស្ដេចដំរីឆទ្ទន្តស្ទុះទៅក្នុងអាកាស ។ ព្រះរស្មីផុសឡើង អំពីព្រះកាយខាងក្រោយ ស្ទុះទៅកាន់អនន្តចក្កវាឡក្នុងបច្ឆិមទិស (ទិសខាងលិច) ។ ព្រះរស្មីផុសឡើងអំពីចង្កេះស្មាខាងស្តាំ ស្ទុះទៅកាន់អនន្តចក្កវាឡក្នុងទក្ខិណទិស(ទិសខាងត្បូង) ។ ព្រះរស្មី ផុសឡើងអំពីចង្កេះ-ស្មាខាងឆ្វេង ស្ទុះទៅកាន់អនន្តចក្កវាឡក្នុង ទិសឧត្តរ (ទិសខាងជើង) ។ ព្រះរស្មីពណ៌ដូចកែវបវាឡចេញអំពីផ្ទៃព្រះបាទ

ទំលុះមហាប្រថពី ទំលាយទឹកពីរចំណែក ទំលុះខ្យល់ ស្ទុះទៅកាន់អជដាកាស ។ ព្រះរស្មីពណ៌ខៀវ ដូចកម្រងកែវមណី ដែលវិលជុំវិញតាំងអំពីព្រះសិរ្ស ផ្សាយទៅកាន់អជដាកាស ឆ្លងកាត់ទេវលោក ៦ ជាន់ កន្លងផុតព្រហ្មលោក ៩ ជាន់ ។ ក្នុងថ្ងៃនោះ សត្វទាំងឡាយ មិនមានប្រមាណ ក្នុងចក្រវាឡទាំងឡាយមិនមានប្រមាណ ក៏មានសម្បុរដូចជាសម្បុរនៃមាសទាំងអស់ ។ ក៏ឯក្នុងថ្ងៃនោះ បានឮថា ព្រះរស្មីទាំងនោះចេញអំពីព្រះសរីរៈរបស់ព្រះមានព្រះភាគ ទៅកាន់លោកធាតុមិនមានទីបំផុតតែម្តងរហូតថ្ងៃនេះ ។ ក៏កាលព្រះមានព្រះភាគ ទ្រង់ពិចារណា ព្រះធម៌ក្នុងសប្តាហ៍នេះប៉ុណ្ណោះ ព្រះរស្មីបានផ្សាយចេញអំពីព្រះសរីរៈនៅមិនទាន់អស់ដោយពិត គប្បីជ្រាបថា កាលទ្រង់ពិចារណាគម្ពីរបដ្ឋាន សូម្បីក្នុងសប្តាហ៍ត្រង់រតនឃរចេតិយ ព្រះរស្មីបានផ្សាយចេញអំពីព្រះសរីរៈយ៉ាងនេះដូចគ្នា ។

សេចក្តីនេះ សមដូចពាក្យដែលលោកបានពោលទុកក្នុងគម្ពីរអដ្ឋសាលិនី ដូច្នេះថា ៖

ក៏បណ្តា ២១ ថ្ងៃទាំងនេះ ព្រះរស្មីមិនបានផ្សាយចេញអំពី

ព្រះសរីរៈរបស់ព្រះសាស្ដាសូម្បីក្នុងមួយថ្ងៃ ប៉ុន្តែក្នុងសប្ដាហ៍ទី ៤ ព្រះមានព្រះភាគ ទ្រង់គង់នៅរតនឃរចេតិយក្នុងទិសពាយ័ព្យ ។ ទ្រង់គង់ទីនោះ សូម្បីកាលទ្រង់ពិចារណា ធម្មសង្គណីបករណ៍ ព្រះរស្មីក៏មិនបានចេញអំពីព្រះសរីរៈ សូម្បីកាលទ្រង់ពិចារណា វិភង្គបករណ៍ ធាតុកថា បុគ្គលប្បញ្ញត្តិ កថាវត្ថុបករណ៍ យមកបករណ៍ ព្រះរស្មីក៏មិនបានចេញអំពីព្រះសរីរៈ ។ តែកាលណាព្រះមានព្រះភាគ ទ្រង់ឈានចុះកាន់មហាបករណ៍ ចាប់ផ្តើមការពិចារណាថា ហេតុប្បច្ច័យ អារម្មណប្បច្ច័យ ។ល។ អវិគតប្បច្ច័យ កាលនោះព្រះអង្គពិចារណាហើយ ពិចារណាទៀតនូវសមន្តប្បដ្ឋាន ២៤ ដែលព្រះសព្វញ្ញុតញ្ញាណ បានឱកាសក្នុងមហាបករណ៍ ដោយចំណែកមួយ ។ ឧបមាដូចមហាមច្ឆាឈ្មោះតិមិតិមង្គល បានឱកាសក្នុងមហាសមុទ្រដ៏ជ្រៅ ៨៤,០០០ យោជន៍ យ៉ាងណា ព្រះសព្វញ្ញុតញ្ញាណ ក៏បានឱកាសក្នុងមហាបករណ៍ ដោយចំណែកមួយយ៉ាងនោះដូចគ្នា ។

កាលព្រះសាស្ដា ទ្រង់ពិចារណាព្រះធម៌ដែលល្អិតសុខុម តាមដែលទ្រង់បានហើយ ដោយព្រះសព្វញ្ញុតញ្ញាណ ដែលបាន

ឱកាសយ៉ាងនេះ ព្រះរស្មីដែលមានពណ៌ ៦ គឺពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស រស្មីពណ៌ហង្សបាទ ពណ៌ផ្លេក ក៏បានចេញអំពីព្រះសរីរៈ ។

## រស្មី ៦ ពណ៌របស់ព្រះមានព្រះភាគ

*រស្មីពណ៌ខៀវ : ផ្សាយចេញអំពីព្រះកេសា (សក់) និងព្រះមស្សុ (ពុកមាត់ពុកចង្កា), និងអំពីឋានដែលមានពណ៌ខៀវនៃព្រះនេត្រ ។*

*រស្មីពណ៌លឿង : ផ្សាយចេញអំពីព្រះឆវីវណ្ណ (សម្បុរស្បែក) និងអំពីឋានដែលមានពណ៌លឿងនៃព្រះនេត្រ ។*

*រស្មីពណ៌ក្រហម : ផ្សាយចេញអំពីព្រះមំស (សាច់) និងព្រះលោហិត (ឈាម) និងអំពីឋានដែលមានពណ៌ក្រហមនៃព្រះនេត្រ ។*

*រស្មីពណ៌ស : ផ្សាយចេញអំពីព្រះអដ្ឋិ (ឆ្អឹង) ទាំងឡាយ និងព្រះទន្ត (ធ្មេញ) ទាំងឡាយ និងអំពីឋានដែលមានពណ៌សនៃព្រះនេត្រ,*

*រស្មីពណ៌ហង្សបាទ និង រស្មីពណ៌ផ្លេក : ផ្សាយចេញអំពីចំណែកនៃព្រះសរីរៈនោះៗ ។*

*ព្រះឆព្វណ្ណរង្សីទាំងឡាយនោះ ផ្សាយចេញទៅទំលុះផែនដីទៅដល់ទឹកខាងក្រោម, ទំលុះទឹកចុះទៅដល់ខ្យល់, ទំលុះខ្យល់ហើយស្ទុះទៅកាន់អជដាកាសខាងក្រោម ។ ពោលដោយចំណែកខាងលើ ព្រះរស្មីទាំងឡាយសូម្បីផ្សាយឡើងទៅហើយ ឆ្លងកាត់ទេវលោក ៦ ជាន់ កន្លងផុតព្រហ្មលោក ៩ ជាន់ តអំពីនោះទំលុះជាន់វេហប្ផលៈ តអំពីនោះទំលុះជាន់សុទ្ធាវាសទាំង ៥ ទៅកាន់ជាន់អរូបព្រហ្មទាំង ៤ ជាន់ ហើយទំលុះជាន់អរូបព្រហ្មទាំង ៤ ជាន់ ហើយស្ទុះទៅកាន់អជដាកាស (អាកាសទទេ) ។ ពោលដោយចំណែកខាងទទឹង រស្មីទាំងឡាយផ្សាយចេញទៅកាន់លោកធាតុដែលមិនមានទីបំផុត ។ ក្នុងស្ថានទីមានប្រមាណប៉ុណ្ណោះ មិនមានពន្លឺព្រះចន្ទ្រ ក្នុងព្រះចន្ទ្រ មិនមានពន្លឺព្រះអាទិត្យ ក្នុងព្រះអាទិត្យ មិនមានដួងតារាក្នុងដួងតារាទាំងឡាយ មិនមានពន្លឺរបស់ទេវតាទាំងឡាយក្នុងទីទាំងពួង គឺត្រង់ឧទ្យានវិមានដើមកប្បព្រឹក្ស ត្រង់សរីរៈ និងអាករណៈទាំងឡាយ ។ សូម្បីស្តេចមហា-*

ព្រហ្មអ្នកមានពន្លឺផ្សាយទៅកាន់លោកជាតុតិសហស្សី និងមហាសហស្សី ក៏ដូចអំពិលអំពែកក្នុងពេលព្រះអាទិត្យរះឡើង ។ ព្រះចន្ទ្រ ព្រះអាទិត្យ ផ្កាយ ឧទ្យាន ដើមកប្បព្រឹក្សរបស់ទេវតា ក៏ប្រាកដត្រឹមតែដែនកំណត់ប៉ុណ្ណោះ ។ ស្ថានទីមានប្រមាណប៉ុណ្ណោះ បានត្រូវស្មើព្រះពុទ្ធគ្របសង្កត់ហើយ ។ ក៏ឫទ្ធិនេះមិនមែនឫទ្ធិកើតពីការអធិដ្ឋានរបស់ព្រះពុទ្ធទាំងឡាយ មិនមែនជាឫទ្ធិកើតពីការភាវនា របស់ព្រះពុទ្ធទាំងឡាយ តែកាលព្រះលោកនាថបានពិចារណាព្រះធម៌ដ៏ល្អិតសុខុម ព្រះលោហិតក៏ភ្លឺថ្លា វត្ថុរូបក៏ភ្លឺថ្លា ព្រះឆវីវណ្ណក៏ភ្លឺថ្លា ។ វណ្ណធាតុដែលមានចិត្តជាសមុដ្ឋានតាំងនៅ មិនញាប់ញ័រក្នុងប្រទេសប្រមាណ ៨០ ហត្ថដោយជុំវិញ។

(ចាកសារត្ថទីបនីដីកា ភាគ៣ ទំព័រ១៧៧)

# រឿង មារ

ព្រះសាស្ដា ទ្រង់គង់នៅក្នុងទីជិតពោធិព្រឹក្សនុ៎ះឯង រហូតដល់អស់ ៤ សប្ដាហ៍ ដោយអាការយ៉ាងនេះ ក្នុងសប្ដាហ៍ទី ៥ ទើបស្ដេចចេញពីគល់ពោធិព្រឹក្ស ចូលទៅដើមអជបាលនិគ្រោធ ទ្រង់គង់ពិចារណាព្រះធម៌ និងសោយវិមុត្តិសុខនៅទៀបដើម

អជបាលនិគ្រោធសូម្បីនោះ ។

សម័យនោះ ទេវបុត្តមារជាប់តាមរហូតអស់កាលជានិច្ច មានប្រមាណប៉ុណ្ណោះ សូម្បីនឹងសម្លឹងមើលរកចន្លោះ ក៏មិនបាន ឃើញសេចក្ដីភ្លាំងភ្លាត់អ្វីតិចតួចរបស់ព្រះសិទ្ធត្ថៈនេះ ទើបដល់សេចក្ដីទោមនស្សថា ឥឡូវនេះ សិទ្ធត្ថៈនេះកន្លងផុតវិស័យរបស់យើងហើយ ទើបអង្គុយក្នុងផ្លូវធំគិតដល់ហេតុ ១៦ ប្រការ ទើបគូសគំនូស ១៦ គំនូស ចុះលើផែនដី គឺគិតថា យើងមិនបាន បំពេញទានបារមីដូចសិទ្ធត្ថៈនេះ ហើយគូសចុះទៅមួយគំនូស ។ មួយទៀត គិតថា យើងមិនបានបំពេញសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី ដូចសិទ្ធត្ថៈនេះ ដោយហេតុនោះ យើងទើបមិនដូចជាសិទ្ធត្ថៈនេះ ហើយគូសគំនូស (ទី២ ដល់) ទី១០ ។ មួយទៀត គិតថា យើងមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យដល់ការចាក់ធ្លុះអាសយានុសយញ្ញាណ ឥន្រ្ទិយបរោបរិយត្តញ្ញាណ មហាករុណាសមាបត្តិញ្ញាណ យមកបាដិហារិយញ្ញាណ អនាវរណញ្ញាណ និងសព្វញ្ញុតញ្ញាណ ដែលមិនទូទៅ

ដល់អ្នកដទៃ ដូចជាសិទ្ធត្ថៈនេះ ដោយហេតុនោះ យើងទើបមិនដូចជាសិទ្ធត្ថៈនេះ ហើយគូសគំនូស (ទី១១ ដល់) ទី១៦ ។ កាលទេវបុត្តមារនោះអង្គុយគូសគំនូស ១៦ គំនូស នៅលើផ្លូវធំព្រោះហេតុទាំងនេះ ដោយប្រការយ៉ាងនេះហើយ ។

សម័យនោះ ធីតាមារទាំង ៣ គឺ នាងតណ្ហា នាងអរតី និងនាងរាគា ពោលនឹងគ្នាថា បិតារបស់ពួកយើងមិនប្រាកដ ឥឡូវនេះ នៅទីណាហ្ន៎ ទើបក្រឡេកមើល បានឃើញទេវបុត្តមារនោះបានទទួលសេចក្តីទោមនស្សគូសផែនដី ទើបនាំគ្នាទៅកាន់សំណាក់របស់បិតា សួរថា បពិត្របិតា ព្រោះហេតុអ្វី បិតាទើបជាទុក្ខមានចិត្តអាក់អន់ ។ ទេវបុត្តមារពោលថា កូនអើយ មហាសមណៈនេះកន្លងផុតអំណាចរបស់យើងហើយ បិតាធ្លាប់មើលរហូតអស់កាលជានិច្ចមានប្រមាណប៉ុណ្ណេះ មិនទាន់អាចឃើញចន្លោះឱកាសរបស់មហាសមណៈនេះ ដោយហេតុនោះ បិតាទើបជាទុក្ខ មានចិត្តអាក់អន់ ។ មារធីតាពោលថា បើកាលជាយ៉ាងនោះ បិតាកុំខ្វល់ចិត្តឡើយ ពួកខ្ញុំនឹងធ្វើមហាសមណៈនោះ ឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយនឹងនាំមក ។ ទេវបុត្តមារពោលថា កូនអើយ

អ្នកណាៗ មិនអាចធ្វើមហាសមណៈនេះ ឲ្យនៅក្នុងអំណាច បុរសនេះតាំងនៅក្នុងសទ្ធាដែលមិនញាប់ញ័រ ។ ធីតាមារពោលថា បពិត្របិតា ពួកខ្ញុំឈ្មោះថាជាស្ត្រី ពួកខ្ញុំនឹងយកអន្ទាក់គឺរាគៈជាដើម ចងមហាសមណៈឲ្យមាំ ហើយនាំមកឲ្យឥឡូវនេះ បិតាកុំគិតឡើយៗ លុះពោលហើយធីតាមារទាំង ៣ នោះ ទើបចេញពីទីនេះចូលទៅរកព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះសមណៈ ពួកខ្ញុំនឹងបម្រើព្រះបាទារបស់ព្រះអង្គ ។ ព្រះមានព្រះភាគ មិនបានដាក់ព្រះនេត្រក្រឡេកមើល មានព្រះសោមនស្ស បង្អោនទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិដ៏កំពូល និងគង់សោយសុខដែលកើតពីវិវេកប៉ុណ្ណោះ ។

ធីតាមារគិតគ្នាទៀតថា សេចក្ដីប្រាថ្នារបស់បុរសទាំងឡាយផ្សេងៗគ្នា បុរសខ្លះស្រឡាញ់ស្រីកុមារី អ្នកខ្លះស្រឡាញ់ស្រីដែលនៅក្នុងបឋមវ័យ អ្នកខ្លះស្រឡាញ់ស្រីដែលតាំងនៅក្នុងមជ្ឈិមវ័យ អ្នកខ្លះស្រឡាញ់ស្រីដែលតាំងនៅក្នុងបច្ឆិមវ័យ បើដូច្នោះ គួរពួកយើងប្រលោមដោយរូបនានា ទើបនាំគ្នានិម្មិតនូវភេទនៃនាង-កុមារីមួយរយ ក្នុងមួយៗ ធ្វើឲ្យបែកទៅជាមានភេទមួយរយៗ

នាក់ ដោយជារូបស្រីកុមារីជាដើម ជាស្រីមិនទាន់សម្រាល ជាស្រីទើបសម្រាលម្តង ជាស្រីសម្រាល ២ ដង ជាស្រីមានវ័យជាកណ្តាល និងជាស្រីចាស់ ចូលទៅរកព្រះមានព្រះភាគ ដល់ទៅ ៦ គ្រា ហើយពោលថា "បពិត្រសមណៈ យើងទាំងឡាយសូមបម្រើព្រះបាទាព្រះអង្គ" ។ ព្រះមានព្រះភាគ មិនបានធ្វើទុកក្នុងព្រះហឫទ័យនឹងពាក្យនោះឡើយ ព្រោះព្រះអង្គមានព្រះហឫទ័យចុះស៊ុបក្នុងព្រះនិព្វានដ៏ប្រសើរ ជាទីអស់ទៅនៃឧបធិហើយ ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគ គ្រាទ្រង់ឃើញធីតាទាំងនោះ ចូលមកដោយការៈជាស្រីអ្នកធំ ទើបទ្រង់អធិដ្ឋានថា ស្រីទាំងនេះចូរជាអ្នកមានធ្មេញកាច់បំបាក់ សក់ស្កូវ យ៉ាងនេះៗ ។ ពាក្យរបស់អាចារ្យពួកខ្លះនោះ មិនគួរកាន់យក ។ ព្រោះព្រះសាស្តា ទ្រង់មិនធ្វើការអធិដ្ឋានបែបនោះ ។ ក៏ព្រះមានព្រះភាគ ត្រាស់ថា ពួកនាងចូរជៀសចេញទៅ ពួកនាងដូចអ្វី ទើបនាំគ្នាព្យាយាមយ៉ាងនេះ ឈ្មោះថា កម្មបែបនេះ គួរធ្វើខាងមុខរបស់អ្នកដែលមិនទាន់ប្រាសចាករាគៈជាដើម តែតថាគតលះរាគៈ ទោសៈ មោហៈបានហើយ ទើបទ្រង់ប្រារព្ធដល់ការលះកិលេស

របស់ព្រះអង្គ ។ ទ្រង់សម្តែងធម៌ត្រាស់ព្រះគាថា ២ គាថា ក្នុង ព្រះធម្មបទ ពុទ្ធវគ្គ ដូច្នេះថា ៖

ជ័យជំនះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេស ណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជំនះរបស់ព្រះពុទ្ធ អង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែល មានគោចរកេទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេចកើត ។ តណ្ហាដែលមាន បណ្តាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិនមានដល់ព្រះពុទ្ធ អង្គណា ដើម្បីនឹងនាំទៅក្នុងកពណាមួយ នាងទាំងឡាយនឹង ប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរកេទីបំផុតគ្មាន មិន មានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើងម្តេច កើត ។

ធីតាមារទាំងនោះពោលពាក្យជាដើមថា បានឮថា បិតា របស់ពួកយើងនិយាយពិត ព្រះអរហន្តសុគតជាម្ចាស់ ជាអ្នក ដែលនឹងនាំទៅមិនបានងាយៗ ក្នុងលោកដោយរាគៈ ហើយបាន នាំគ្នាទៅកាន់សំណាក់របស់បិតា ។ (ចាកអដ្ឋកថា ជាតក)




*សប្តាហ៍នេះ ព្រះអង្គបានជួបនឹងព្រាហ្មណ៍ម្នាក់ ឈ្មោះ **ហុំហុំកជាតិកៈ** ផងដែរ ។*

*<u>ទ្រង់បន្លឺនូវឧទានគាថា</u> ថា ៖*

យោ ព្រាហ្មណោ ពាហិតបាបធម្មោ
និហុំហុកោ និក្កសាវោ យតត្តោ
វេទន្តគូ វុសិតព្រហ្មចរិយោ
ធម្មេន សោ ព្រហ្មវាទំ វទេយ្យ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ ។

ព្រាហ្មណ៍ណា មានបាបធម៌បណ្តែតចោលហើយ មានសំឡេងគម្រាមថា **ហុំហុំ** លះចោលហើយ មានទឹកម្ចត់ គឺរាគាទិក្កិលេសលះចោលហើយ មានចិត្តសង្រួម ចេះចប់នូវវេទ (គឺមគ្គញាណទាំង៤) មានមគ្គព្រហ្មចរិយៈនៅរួចហើយ ម្យ៉ាងទៀត ព្រាហ្មណ៍ណាមិនមានគំនរ គឺរាគាទិក្កិលេសក្នុងអារម្មណ៍បន្តិចបន្តួច ក្នុងលោកសន្និវាស ព្រាហ្មណ៍នោះ គួរនឹងហៅខ្លួនថា ជាព្រាហ្មណ៍ដោយធម៌បាន ។ (ចាកវិនយបិដក)

## ១.៦ មុចលិន្ទ

លុះថ្ងៃ ៧ កន្លងទៅហើយ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ក្រោកចាកសមាធិនោះ ហើយទ្រង់ចេញអំពីម្លប់អជបាលនិគ្រោធព្រឹក្ស យាងចូលទៅកាន់ដើមរាំង លុះចូលទៅដល់ហើយទ្រង់គង់ដោយព្រះភ្លែនតែមួយអង្គុយ អស់ ៧ ថ្ងៃ ក្រោមម្លប់រាំងសោយវិមុត្តិសុខ ។

សម័យនោះឯង មហាមេឃពុំជួកាល ក៏បណ្តាលកើតឡើងជាភ្លៀង ៗ មានភ្លៀងរលឹមអស់ ៧ ថ្ងៃ បណ្តាលឲ្យអាប់ពន្លឺព្រះ-

អាទិត្យ ដោយអំណាចខ្យល់ត្រជាក់ ។ គ្រានោះ មុចលិន្ទនាគរាជចេញអំពីលំនៅរបស់ខ្លួនហើយ ពេនព័ទ្ធព្រះកាយព្រះមានព្រះភាគ ៧ ជុំដោយភ្នែន (របស់ខ្លួន) ហើយលើកពពារដ៏ធំបាំងពីខាងលើព្រះសិរព្រះមានព្រះភាគ ហើយឋិតនៅ ដោយគិតថា រងាកុំបៀតបៀនព្រះមានព្រះភាគ ក្តៅកុំបៀតបៀនព្រះមានព្រះភាគ សម្ផស្សរបោមមូសខ្យល់ កំដៅថ្ងៃ ពស់តូចពស់ធំ ក៏កុំបៀតបៀនព្រះមានព្រះភាគឡើយ ។ លុះថ្ងៃ ៧ កន្លងទៅហើយ លំដាប់នោះ មុចលិន្ទនាគរាជដឹងថា ភ្លៀងរាំងហើយ មេឃស្រឡះហើយ ក៏រំសាយភ្នែនចេញពីព្រះកាយព្រះមានព្រះភាគ ហើយប្រែភេទរបស់ខ្លួន និម្មិតជាភេទមាណព ឈរប្រណមអញ្ជលី នមស្ការព្រះមានព្រះភាគ ពីខាងទីចំពោះព្រះភក្ត្រព្រះអង្គ ។

ក្នុងអដ្ឋកថាសមន្តប្បាសាទិកា លោកពោលទុកថា ៖

ត្រើនបទថា **សត្តក្ខត្តុំ ភោគេហិ បរិក្ខិបិត្វា** មានសេចក្តីថា កាលស្តេចនាគនោះ ពេនព័ទ្ធជុំវិញព្រះកាយដោយពេនព័ទ្ធ ៧ ជុំ បើកពពារធំបាំងនៅខាងលើព្រះសិរយ៉ាងនោះ រួមក្នុងរង្វង់ភ្នែនរបស់ស្តេចនាគនោះ មានប្រមាណប៉ុនបន្ទប់ឃ្លាំងក្នុងលោហ-

ប្រាសាទ, ព្រោះហេតុនោះ ព្រះមានព្រះភាគ ហាក់ដូចជាទ្រង់គង់ក្នុងប្រាសាទដែលហាប់ខ្យល់ មានទ្វារបង្អួចបិទ ។

ពាក្យថា **មា ភគវន្តំ សីតំ** ជាដើម សម្ដែងហេតុដែលស្ដេចនាគនោះធ្វើយ៉ាងនោះ ។ ពិតមែន ស្ដេចនាគបានធ្វើយ៉ាងនោះ ក៏ដោយតាំងចិត្តថា រងាកុំបៀតបៀនព្រះមានព្រះភាគ ។ ក្ដៅកុំបៀតបៀនព្រះមានព្រះភាគ និងសម្ផស្ស របោមជាដើម កុំបៀតបៀនព្រះមានព្រះភាគ ការពិត កាលមានភ្លៀងបង្អុរចុះរហូតអស់ ៧ ថ្ងៃ ក្នុងទីនោះ មិនមានក្ដៅឡើយ ។ ទោះជាយ៉ាងនោះ ក៏សមគួរដល់ស្ដេចនាគនោះគិតយ៉ាងនេះថា "បើមេឃនឹងស្រឡះទៅក្នុងចន្លោះៗ កំដៅគង់នឹងមាន សូម្បីកំដៅនោះកុំបៀតបៀនព្រះអង្គឡើយ" ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្ដីនេះហើយក៏បន្លឺនូវឧទានគាថា ក្នុងវេលានោះថា ៖

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ ។
សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ

អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ ។

សេចក្តីស្ងាត់ចាកកិលេស របស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញាណ) មានធម៌ប្រាកដហើយ បានឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឲ្យកើតសេចក្តីសុខ សេចក្តីមិនព្យាបាទ និងសេចក្តីសង្រួម មិនបៀតបៀនសត្វទាំងឡាយ ក៏ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក សេចក្តីណាយចាករាគៈ និងការប្រព្រឹត្តិកន្លងកាមទាំងឡាយ ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក កិរិយាកំចាត់បង់នូវអស្មិមានះ កិរិយាកំចាត់បង់នូវអស្មិមានះនុ៎ះ ជាសុខយ៉ាងក្រៃលែង ។ (បិដក ភាគ៦ ទំព័រ១០)

<u>អដ្ឋកថា</u> : អព្យាបជ្ឈន្តិ អកុប្បនភាវោ ការមិនប្រទូសរ៉ាយគ្នា ឈ្មោះថា សេចក្តីមិនបៀតបៀនគ្នា ។

ធម៌ជាចំណែកខាងដើមនៃមេត្តា ព្រះមានព្រះភាគ ទ្រង់សម្តែងដោយបទថា សេចក្តីមិនបៀតបៀនគ្នា ។

ធម៌ជាចំណែកខាងដើមនៃករុណា ព្រះមានព្រះភាគ ទ្រង់សម្តែងដោយបទថា សេចក្តីសង្រួមនោះ ។ សេចក្តីប្រាសចាក

តម្រេកឯណា ដែលលោកហៅថា សេចក្តីកន្លងកាមទាំងឡាយចេញ សូម្បីសេចក្តីប្រាសចាកតម្រេកនោះ ក៏ចាត់ជាសេចក្តីសុខ ។ **អនាគាមិមគ្គ** ព្រះមានព្រះភាគ ត្រាស់ដោយបទថា សេចក្តីប្រាសចាកតម្រេកនោះ ។ ចំណែក**ព្រះអរហត្ត** ព្រះមានព្រះភាគ ត្រាស់ដោយពាក្យនេះថា សេចក្តីកំចាត់អស្មិមានះចេញ ។ មែនពិត ព្រះអរហត្តលោកពោលថា វិន័យសម្រាប់កំចាត់បង់អស្មិមានះ ។ ក៏ឈ្មោះថា សុខដទៃក្រៅអំពីព្រះអរហត្តនេះមិនមាន ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា "សេចក្តីនេះឯងជាសុខយ៉ាងក្រៃលែង" ។

## ១.៧ រាជាយតន

លុះ ៧ ថ្ងៃកន្លងទៅហើយ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ក្រោកចាកសមាធិនោះ ហើយយាងចេញពីម្លប់ដើមពំង ហើយយាងចូលទៅកាន់ដើមរាជាយតនៈ (ដើមកែស) លុះចូលទៅដល់ហើយ ទ្រង់គង់ដោយព្រះភ្លែនតែមួយអង្គុយ អស់ ៧ ថ្ងៃ ក្រោមម្លប់ដើមរាជាយតនៈ ទ្រង់សោយវិមុត្តិសុខ ។

សម័យនោះឯង មានពាណិជពីរនាក់ (ជាបងប្អូននឹងគ្នាបង្កើត) ឈ្មោះតបុស្សៈ ១ ភល្លិកៈ ១ ជាអ្នកដើរផ្លូវឆ្ងាយ ចេញពីឧក្កលជនបទ សំដៅទៅកាន់ប្រទេសនោះ។ គ្រានោះ មានទេវតាជាញាតិសាលោហិត របស់តបុស្សៈនិងភល្លិកៈពាណិជ បាននិយាយពាក្យនេះនឹងតបុស្សៈនិងភល្លិកៈពាណិជថា ម្នាលគ្នាយើង ព្រះមានព្រះភាគអង្គនេះ ទើបនឹងបានត្រាស់ដឹងជាដំបូង ឥឡូវព្រះអង្គគង់នៅក្រោមម្ចប់រាជាយតនៈ (ឯណោះ) អ្នកទាំងឡាយ គួរចូលទៅបូជាព្រះមានព្រះភាគអង្គនោះ ដោយសដូវផង់និងសដូវដុំចុះ ការបូជានោះនឹងបានជាប្រយោជន៍ និងសេចក្ដីសុខដល់អ្នកទាំងឡាយអស់កាលជាយូរអង្វែង ។ គ្រានោះ តបុស្សៈនិងភល្លិកៈ ពាណិជក៏នាំយកនូវសដូវផង់និងសដូវដុំ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងកន្លែងដ៏សមគួរ ។ លុះតបុស្សៈនិងភល្លិកៈពាណិជ ឋិតនៅក្នុងកន្លែងដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះមានព្រះភាគ ថាបពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលនូវសដូវផង់និងសដូវដុំរបស់យើងខ្ញុំ ព្រោះថា ការទទួលនឹងបានជាប្រយោជន៍

និងសេចក្ដីសុខដល់យើងខ្ញុំទាំងឡាយ អស់កាលយូរអង្វែង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា ធម្មតាព្រះតថាគតទាំងឡាយមិនដែលទទួល (អាមិសៈ) ផ្ទាល់នឹងដៃឡើយ បើដូច្នោះ តើតថាគតគួរទទួលនូវសដូវផង់ និងសដូវដុំដោយវត្ថុអ្វីហ្ន៎ ។ គ្រានោះ មហារាជទាំង ៤ ទ្រង់ជ្រាបព្រះតម្រិះរបស់ព្រះមានព្រះភាគ (ដោយចិត្តរបស់ខ្លួន) ទើបនាំនូវបាត្រថ្មកែវទាំងឡាយ ៤ អំពីទិសទាំង ៤ បង្អោនចូលមកថ្វាយព្រះមានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលនូវសដូវផង់និងសដូវដុំដោយបាត្រនេះចុះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនូវសដូវផង់និងសដូវដុំ ដោយបាត្រថ្មកែវទាំងឡាយដ៏មានតម្លៃថ្លៃ លុះទទួលស្រេចហើយក៏ទ្រង់សោយ (ក្នុងពេលនោះ) ។

គ្រានោះឯង តបុស្សៈនិងភល្លិកៈពាណិជ បាននិយាយពាក្យនេះនឹងព្រះមានព្រះភាគ ថា ៖

“ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ឧបាសកេ នោ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេ ។ បពិត្រព្រះមានព្រះភាគ

ដ៏ចម្រើន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះមានព្រះភាគ និង ព្រះធម៌ជាទីរឭក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថា ជាឧបាសក បានដល់នូវ(ព្រះមានព្រះភាគ និងព្រះធម៌) ជាទីរឭក ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមតរៀងទៅ" ។

តេ ច លោកេ បឋមំ ឧបាសកា អហេសុំ ទ្វេវាចិកា : ក៏ឯពាណិជទាំងពីរនាក់នោះ បាននាមបញ្ញត្តិថា **ទ្វេវាចិកឧបាសក** ជាដំបូងក្នុងលោក ។

## អដ្ឋកថា ពន្យល់ថា

បទថា **មុចលិន្ទមូលា** (មូប់ដើមរាំង) បានដល់ ចាកគល់ ដើមរាំងដែលឋិតនៅក្នុងទិសបស្ចឹមជិតមហាពោធិព្រឹក្ស ។

បទថា **រាជាយតនំ** (ដើមរាជាយតនៈ) មានសេចក្តីថា ស្តេចចូលទៅកាន់គល់នៃដើមកែសដែលឋិតនៅទិសទក្សិណ ។

ពាក្យថា **តេន ខោ បន សមយេន** (សម័យនោះឯង) មានពាក្យសួរថា ក្នុងសម័យណា ?

ឆ្លើយថា ក្នុងសម័យដែលព្រះមានព្រះភាគ ទ្រង់គង់ដោយ

ក្អែនតែមួយចម្រើនសមាធិរហូតអស់ ៧ ថ្ងៃ ក្រោមម្លប់ដើមកែស សក្កទេវរាជទ្រង់ជ្រាបថា ត្រូវមានកិច្ចជាប់ដោយព្រះក្រយាហារ ទើបទ្រង់បង្អោនផ្លែសម៉ជាព្រះឱសថថ្វាយ ក្នុងពេលអរុណរះឡើង ក្នុងថ្ងៃដែលទ្រង់ចេញចាកសមាធិតែម្តង ។ ព្រះមានព្រះភាគសោយផ្លែសម៉ព្រះឱសថនោះ ល្មមសោយស្រេចប៉ុណ្ណោះ ក៏បានមានកិច្ចជាប់ដោយព្រះសរីរៈ ស្តេចសក្កៈបានថ្វាយទឹកខ្ពុរព្រះឱស្ឋហើយ ។ ព្រះមានព្រះភាគ ទ្រង់ខ្ពុរព្រះឱស្ឋ ហើយទ្រង់គង់ក្រោមម្លប់ឈើនោះឯង ។ កាលព្រះមានព្រះភាគ គង់ប្រថាប់ក្នុងកាលអរុណរះហើយ ដោយប្រការយ៉ាងនោះ ។

ពីរបទថា **តបុស្សភល្លិកា វាណិជា** (មានពាណិជឈ្មោះ-តបុស្សៈ ១ ភល្លិកៈ ១) បានដល់ ពាណិជពីរនាក់បងប្អូន គឺ តបុស្សៈ និងភល្លិកៈ ។

បទថា **ឧក្កលា** បានដល់ ចាកឧក្កលជនបទ ។

ពីរបទថា **តំ ទេសំ** (ប្រទេសនោះ) មានសេចក្តីថា កាន់ប្រទេសជាទីនៅរបស់ព្រះមានព្រះភាគ ។

សួរថា ក៏ព្រះមានព្រះភាគ ស្តេចនៅក្នុងប្រទេសណាហ្ន៎ ?

ឆ្លើយថា ក្នុងមជ្ឈិមប្រទេស ។ ព្រោះដូច្នោះ ក្នុងពាក្យនេះ ទើបមានសេចក្តីដូច្នេះ ពាណិជពីរនាក់នោះ ជាអ្នកធ្វើដំណើរផ្លូវឆ្ងាយ ដើម្បីទៅកាន់មជ្ឈិមប្រទេស ។

ពីរបទថា **ញាតិសាលោហិតា ទេវតា** (មានទេវតាជាញាតិសាលោហិត) បានដល់ ទេវតាដែលធ្លាប់ជាញាតិរបស់ពាណិជពីរនាក់នោះ ។

ពីរបទថា **ឯតទវោច** (បាននិយាយពាក្យនេះ) មានសេចក្តីថា បានឮថា ទេវតានោះបានបណ្តាលឲ្យរទេះទាំងអស់ របស់ពាណិជនោះឈប់ ។ លំដាប់នោះ អ្នកទាំងពីរមកពិចារណាមើលថា "នេះជាហេតុអ្វី ?" ទើបបានធ្វើពលីកម្មដល់ទេវតា ដែលជា-ម្ចាស់ផ្លូវទាំងឡាយ ។ ក្នុងវេលាធ្វើពលីកម្មរបស់គេ ទេវតានោះសម្តែងកាយឲ្យឃើញ បានពោលពាក្យនេះ ។

ពីរបទថា **មន្ថេន ច មធុបិណ្ឌិកាយ ច** (សដូវផង់ និងសដូវដុំ) បានដល់ សដូវផង់និងសដូវដុំ ផ្សំហើយដោយទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅជាដើម ។

បទថា **បដិមានេថ** បានដល់ ចូរទំនុកបម្រុង ។

ពីរបទថា **តំ វោ** មានសេចក្ដីថា សេចក្ដីទំនុកបម្រុងនោះ នឹងមានដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់លោកទាំងឡាយ រហូតអស់កាលយូរអង្វែង ។

ពីរបទថា **យំ អម្ហាកំ** មានសេចក្ដីថា ការទទួលយ៉ាងណា នឹងគប្បីមាន ដើម្បីប្រយោជន៍សេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ដល់ពួកខ្ញុំព្រះអង្គរហូតអស់កាលយូរអង្វែង ។

ពីរបទថា **ភគវតោ ឯតទហោសិ** (ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា) មានសេចក្ដីថា បានឮថា បាត្រណារបស់ព្រះអង្គ បានមានក្នុងវេលាទ្រង់ប្រកបសេចក្ដីព្យាយាម បាត្រនោះបានបាត់ទៅ តាំងពីកាលនាងសុជាតា មកថ្វាយបាយបាយាស ។ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់បានមានព្រះរំពឹងនេះថា បាត្ររបស់តថាគតមិនមាន ក៏ឯព្រះតថាគតទាំងឡាយអង្គមុនៗ ទ្រង់មិនទទួលដោយព្រះហស្តឡើយ ។ តថាគតនឹងគប្បីទទួលសដូវផង់និងសដូវជុំផ្សំទឹកឃ្មុំដោយអ្វីហ្ន៎ ?

បទថា **បរិវិតក្កមញ្ញាយ** (ជ្រាបព្រះតម្រិះ) មានសេចក្ដីថា ក្រយាហារដែលនាងសុជាតា ថ្វាយចំពោះព្រះមានព្រះភាគ ក្នុង

កាលមុននោះ តាំងនៅដោយអំណាចដែលផ្សំឱជះទុក សេចក្ដីស្រេកសេចក្ដីឃ្លាន ភាពជាអ្នកមិនលំបាកកាយ អស់កាលប៉ុណ្ណោះក៏ឥឡូវនេះ ព្រះអង្គរំពឹងដោយន័យជាដើមថា **ន ខោ តថាគតា** បានកើតឡើង ក៏ព្រោះព្រះអង្គប្រាថ្នានឹងទ្រង់ទទួលព្រះក្រយាហារ ។ ជ្រាបព្រះតម្រិះក្នុងព្រះហឫទ័យរបស់ព្រះមានព្រះភាគ ដែលកើតឡើងយ៉ាងនោះដោយចិត្តរបស់ខ្លួន ។

ពីរបទថា **សេលមយេ បត្តេ** (បាត្រថ្មកែវទាំងឡាយ) បានដល់ បាត្រដែលធ្វើដោយថ្មមានពណ៌ដូចសណ្ដែកបាយ ។ ព្រះមានព្រះភាគ ទ្រង់ទទួលបាត្រនេះឯង ។ ពាក្យថា បាត្រដែលសម្រេចដោយថ្ម លោកពោលសំដៅយកបាត្រទាំងនោះ ។ ក៏ស្ដេចមហារាជទាំង ៤ បានបង្អោនថ្វាយបាត្រដែលសម្រេចដោយកែវឥន្ទនិលជាដំបូង ។ ព្រះមានព្រះភាគ ទ្រង់មិនទទួលបាត្រទាំងនោះ ក្រោយពីនោះ ទើបបង្អោនថ្វាយបាត្រដែលសម្រេចដោយថ្មមានពណ៌ដូចសណ្ដែកបាយទាំង ៤ នេះ ។ ព្រះមានព្រះភាគ ទ្រង់បានទទួលបាត្រទាំង ៤ ដើម្បីរក្សាសេចក្ដីជ្រះថ្លារបស់ស្ដេចមហារាជទាំង ៤ នោះ មិនមែនព្រោះសេចក្ដីប្រាថ្នាច្រើនទេ ។

ក៏ក្រាទ្រង់ទទួលហើយ ទ្រង់បានអធិដ្ឋានបាត្រទាំង ៤ ឲ្យជាបាត្រតែមួយ ផលបុណ្យនៃស្តេចទាំង ៤ បានដូចគ្នា ព្រះមានព្រះភាគទ្រង់ទទួលសដូវផង់និងសដូវដុំ ផ្សំទឹកឃ្មុំ ដោយបាត្រថ្មមានតម្លៃច្រើន ដែលទ្រង់អធិដ្ឋានឲ្យជាបាត្រតែមួយ ដោយប្រការដូច្នេះ ។

ពាណិជ្ជទាំងពីរនាក់នោះ ឈ្មោះថា មានវាចាពីរ ព្រោះអត្ថវិគ្រោះថា បានជាអ្នកមានវាចាពីរ ។ ម្យ៉ាងទៀត សេចក្តីថា ពាណិជពីរនាក់នោះ ដល់ភាពជាឧបាសកដោយវាចាពីរ ។ ពាណិជទាំងពីរនាក់នោះ កាលប្រកាសភាពជាឧបាសកយ៉ាងនោះហើយ បានក្រាបទូលព្រះមានព្រះភាគថា “បពិត្រព្រះអង្គដ៏ចម្រើន តាំងពីថ្ងៃនេះទៅ តើខ្ញុំព្រះអង្គគប្បីធ្វើការអភិវាទនិងឈរទទួលបុគ្គលណាហ្ន៎ ព្រះអង្គ” ព្រះមានព្រះភាគ ទ្រង់ស្ទាបព្រះសិរសា ។ ព្រះកេសាជាប់ព្រះហស្ត បានប្រទានព្រះកេសាទាំងនោះ ដល់អ្នកទាំងពីរដោយត្រាស់ថា “លោកចូររក្សាសក់ទាំងនេះទុក” ។ ពាណិជពីរនាក់នោះ បានព្រះកេសធាតុ ហាក់ដូចជាបានអភិសេកដោយអមតធម៌ រីករាយត្រេកអរ ថ្វាយបង្គំព្រះមានព្រះភាគ ហើយជៀសចេញទៅ ។

ក្នុងសប្តាហ៍នេះ ទ្រង់ជួបសក្កទេវរាជ, តបុស្សៈនិងភល្លិកៈ, មហារាជទាំង ៤ ។ សក្កទេវរាជ ទ្រង់បង្អោនថ្វាយផ្លែសម៉ ជាព្រះឱសថ ថ្វាយឈើជម្រះព្រះទន្ត និងទឹកខ្ពុរព្រះឱស្ឋផង ។ មហារាជទាំង ៤ បង្អោនថ្វាយបាត្រសម្រេចដោយថ្មកែវ មានពណ៌ដូចសណ្តែកបាយទាំង ៤ បង្អោនថ្វាយព្រះមានព្រះភាគ ។ តបុស្សៈនិងភល្លិកៈ ថ្វាយសដូវផង់និងសដូវដុំ ។

## ១.៨ សប្តាហ៍ទី ៨ ក្រោយការត្រាស់ដឹង

### ក. ទ្រង់យាងចូលកាន់ដើមអជបាលនិគ្រោធវិញ

លុះ ៧ ថ្ងៃកន្លងទៅហើយ លំដាប់នោះ ព្រះមានជោគ ទ្រង់ក្រោកចាកសមាធិនោះ ហើយយាងចេញអំពីរាជាយតនៈ ហើយយាងចូលទៅកាន់ដើមអជបាលនិគ្រោធវិញ ។

លំដាប់នោះ មារមានចិត្តបាប ក៏ចូលទៅគាល់ព្រះមានព្រះភាគ ហើយបានពោលពាក្យសូមឲ្យព្រះមានព្រះភាគបរិនិព្វាន ដូចសេចក្តីដែលមានសម្តែងក្នុងអដ្ឋកថា សុមង្គលវិលាសិនី ថា ក៏មារនេះ ជាប់តាមមកតាំងពីពោធិមណ្ឌលស្ថាន ក្នុងសប្តាហ៍ទី ៨

រាប់តាំងពីព្រះមានព្រះភាគ ទ្រង់សម្រេចសម្ពោធិញាណ ពោលថា ព្រះមានព្រះភាគ ទ្រង់សម្រេចប្រយោជន៍របស់ព្រះអង្គ ដែលព្រះអង្គទ្រង់បំពេញព្រះបារមីមកដោយលំដាប់ហើយ ទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណហើយ ព្រះអង្គនឹងទ្រង់ត្រួតមើលលោកដោយហេតុអ្វី ? ទើបទូលអង្វរថា ឥឡូវនេះ សូមព្រះមានព្រះភាគទ្រង់បរិនិព្វានទៅក្នុងថ្ងៃនេះចុះព្រះអង្គ ។ តែព្រះមានព្រះភាគត្រាស់បដិសេធដល់មារនោះថា យើងនឹងមិនទាន់បរិនិព្វានទេ ដូច្នេះជាដើម ។

## ៦.ព្រហ្មយាចនកថា

បានឮថា ព្រះមានព្រះភាគ ក៏គង់នៅក្រោមម្លប់អជបាលនិគ្រោធនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ គង់សម្ងំនៅក្នុងទីស្ងាត់តែមួយព្រះអង្គ ទើបទ្រង់ព្រះតម្រិះយ៉ាងនេះថា ក៏ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌គឺសត្វឃើញបានដោយកម្រ ជាធម៌គឺសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ដ៏ឧត្តម ជាធម៌ដែលសត្វមិនគប្បីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត ជាធម៌លុះតែ

អ្នកប្រាជ្ញទើបត្រាស់ដឹងបាន ក៏ឯពពួកសត្វនេះ សុទ្ធតែនៅកំពុងរីករាយក្នុងសេចក្ដីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្ដីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្ដីអាល័យ (ចំពោះកាមទាំងឡាយនៅឡើយ) ក៏បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ជាហេតុនាំឲ្យពពួកសត្វនៅរីករាយក្នុងសេចក្ដីអាល័យ នៅត្រេកត្រអាលក្នុងសេចក្ដីអាល័យ នៅស្រើប-ស្រាលក្នុងសេចក្ដីអាល័យ ឃើញបានដោយកម្រ,

<u>ម្យ៉ាងទៀត</u> ធម៌ណាសម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះបោលនូវឧបធិ គឺខន្ធនិងកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីណាយចាករាគៈ ជាទីរលត់នៃទុក្ខ គឺនិព្វានធម៌ទាំងអម្បាលនេះ ជាហេតុដែលពួកសត្វឃើញបានដោយកម្រក្រៃ-ពេក បើទុកជាតថាគតសម្ដែងធម៌ទៅ ក៏គង់សត្វទាំងឡាយដទៃមិនអាចនឹងត្រាស់ដឹងធម៌របស់តថាគតបានឡើយ ព្រោះហេតុនោះសេចក្ដីលំបាក សេចក្ដីនឿយព្រួយ មុខជានឹងមានដល់តថាគតមិនខាន ។ ម្យ៉ាងទៀត ព្រះគាថាទាំងឡាយជាហេតុអស្ចារ្យ សម

គួរនេះ ព្រះមានព្រះភាគ មិនដែលបានឮក្នុងកាលមុនឡើយ ក៏កើតប្រាកដដល់ព្រះអង្គថា ៖

ឥឡូវនេះ តថាគតគួរសម្តែងនូវធម៌ដែលតថាគតបាន ត្រាស់ដឹងហើយដោយកម្រ (ទុំះទៅចុះ) ។ ប៉ុន្តែសត្វទាំង ឡាយដែលរាគៈទោសៈគ្របសង្កត់ ក៏មិនអាចនឹងត្រាស់ ដឹងនូវធម៌នេះបានដោយងាយទេ ។ សត្វទាំងឡាយដែល កំពុងត្រេកត្រអាលដោយរាគៈ ដែលគំនរងងឹត(គឺអវិជ្ជា) កំពុងបិទបាំង (យ៉ាងនេះ) មុខជានឹងមិនឃើញនូវធម៌ដែល នាំសត្វឲ្យដល់នូវព្រះនិព្វាន ជាធម៌ល្អិតឆ្មារ ជ្រាលជ្រៅ សត្វឃើញបានដោយកម្រ (ទុំះទេ) ។

កាលព្រះមានព្រះភាគ ពិចារណាឃើញដោយន័យ ដែល ត្រិះរិះដូច្នេះហើយ ព្រះហឫទ័យក៏ឱនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសម្តែងធម៌ឡើយ ។

លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះ ហឫទ័យរបស់ព្រះមានព្រះភាគ ដោយចិត្តរបស់ខ្លួនហើយ ទើប រំពឹងត្រិះរិះដូច្នេះថា អើហ្ន៎ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ មាន

ព្រះហឫទ័យឱនទៅដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសម្ដែងធម៌ (យ៉ាងនេះ) ។ ឱសត្វលោកវិនាសតើហ្ន៎ ឱសត្វលោកវិនាសតើហ្ន៎ ។

គ្រានោះ សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ (ដោយឆាប់ភ្លាម) ប្រៀបដូចបុរសអ្នកមានកម្លាំង លាចេញនូវដើមដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដើមដៃដែលខ្លួនលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្មធ្វើសំពត់ឆៀងស្មាម្ខាង ហើយលុតចុះនូវមណ្ឌលជង្គង់ខាងស្ដាំលើផែនដី ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះត្រង់ព្រះមានព្រះភាគទើបពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះមានព្រះភាគ សម្ដែងធម៌ សូមព្រះសុគតសម្ដែងធម៌ (ដ្បិត) សត្វដែលមានរាគាទិក្កិលេសដ៏ស្រាលស្ដើងក្នុងភ្នែក គឺបញ្ញា តែខានស្ដាប់ធម៌ក៏មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយអ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ក៏គង់មានដែរ ។ សហម្បតិព្រហ្ម បានពោលពាក្យនេះ (ប៉ុណ្ណោះ) លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃតទៅទៀតថា

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយអ្នកប្រកបដោយមន្ទិលតែងគិត ជាធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយ ក្នុងដែនមគធៈ ។ សូមព្រះអង្គបើកនូវទ្វារនៃព្រះនិព្វានចុះ សត្វទាំងឡាយដែលប្រុងចាំស្តាប់ធម៌ដែលព្រះអង្គ ជាអ្នកប្រាសចាកមន្ទិល ទ្រង់ត្រាស់ដឹងតាម (លំអានព្រះពុទ្ធអំពីបូរាណ) ។ ប្រៀបដូចជាបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយថ្មសុទ្ធ ក្រឡេកមើលប្រជុំជនដោយជុំវិញយ៉ាងណាមិញ បពិត្រព្រះអង្គមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទ ដ៏ហើយដោយធម៌ ពិចារណាមើលនូវប្រជុំជនអ្នកច្រឡំដោយសេចក្តីសោក ដែលជាតិជរាកំពុងគ្របសង្កត់ មានឧបមាដូច្នោះដែរ ។ បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម ហើយជានាយកនៃពួកសត្វ អ្នកមិនជាប់បំណុលគឺកាម សូមព្រះអង្គក្រោកឡើង សូមទ្រង់ស្តេចទៅក្នុងលោក ។ សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ សត្វទាំងឡាយអ្នកបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីអារាធនារបស់សហម្បតិព្រហ្មផង ទ្រង់អាស្រ័យនូវសេចក្តីករុណាចំពោះសត្វទាំងឡាយផង ទើបទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ។ ព្រះមានព្រះភាគ កាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយ មានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែក(ខ្លះ) មានធូលីគឺរាគាទិក្កិលេស ច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយចាស់ក្លា (ខ្លះ) មានឥន្ទ្រិយទន់ខ្សោយ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការអាក្រក់(ខ្លះ) ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ (ខ្លះ) ជាអ្នកឃើញបរលោក និងទោសដោយសភាពគួរខ្លាច (ខ្លះ) ។

(សេចក្តីប្រៀបថា) មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹកនៅឡើយ, មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ស្ថិតនៅ

ត្រឹមស្មើនឹងទឹក, មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះខ្ពស់ឡើងជាងទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ព្រះមានព្រះភាគ កាលទ្រង់រមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញសត្វទាំងឡាយ មានធូលីគឺរាគាទិ-ក្កិលេសតិចក្នុងភ្នែក(ខ្លះ) មានធូលីគឺរាគាទិក្កិលេសច្រើនក្នុងភ្នែក (ខ្លះ) មានឥន្ទ្រិយចាស់ក្លា (ខ្លះ) មានឥន្ទ្រិយទន់ខ្សោយ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការមិនល្អ(ខ្លះ) ជាសត្វដែលព្រះអង្គគួរឲ្យត្រាស់ដឹងបានដោយងាយ(ខ្លះ) ឲ្យត្រាស់ដឹងបានដោយកម្រ (ខ្លះ) សត្វចំពូកខ្លះ ឃើញបរលោកនិងទោសដោយសភាពគួរខ្លាច មានឧបមេយ្យ ដូច្នោះឯង លុះទ្រង់ឃើញហើយ ទើបទ្រង់សម្តែងជាបទគាថា នឹងសហម្បតិព្រហ្មថា ៖

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ ។
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណា មានសោតប្បសាទ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ ។ ម្នាលមហាព្រហ្ម តថាគតមានសេចក្ដីសម្គាល់ក្នុងការលំបាក បានជាមិនសម្ដែងធម៌ដ៏ឧត្ដម ដែលស្ទាត់ក្នុងសំណាក់មនុស្សទាំងឡាយ ។

គ្រានោះ សហម្បតិព្រហ្មគិតថា ខ្លួនអញជាបុគ្គល គឺព្រះដ៏មានព្រះភាគ ទ្រង់យល់ព្រមដើម្បីនឹងសម្ដែងធម៌ហើយ (លុះគិតដូច្នេះហើយ) ក៏ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយក៏បាត់អំពីទីនោះមួយរំពេចទៅ ។ (វិនយបិដក ៦,១៣-១៩)

ក្នុងអដ្ឋកថាវិន័យពន្យល់ថា : ពីរបទថា បរិវិតក្កោ ឧទបាទិ សេចក្ដីថា សេចក្ដីរំពឹងនៃចិត្តនេះ ដែលព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់ប្រព្រឹត្តមកជាអាចិណ្ណៈ កើតឡើងដល់ព្រះមានព្រះភាគ ល្មមបានទ្រង់គង់ក្រោមម្លប់ដើមអជបាលនិគ្រោធប៉ុណ្ណោះ ។ សួរថា ក៏ព្រោះហេតុអ្វីសេចក្ដីរំពឹងនៃចិត្តនេះ ទើបកើតឡើងដល់ព្រះពុទ្ធគ្រប់ព្រះអង្គ ?

ធម្មស្ស មហគ្ឃតាយ គរុតាយ ភារិយតាយ បច្ចវេក្ខណាយ ព្រហ្មុនា យាចិតោ ទេសេតុកាមតាយ ច ៖ ឆ្លើយថា "ព្រោះទ្រង់ពិចារណានូវភាវៈនៃព្រះធម៌ជាគុណធំ ជាគុណដ៏លើសលប់ ជារបស់ធ្ងន់ និងព្រោះជាអ្នកប្រាថ្នា នឹងទ្រង់សម្ដែងតាមពាក្យដែលព្រហ្មទូលអារាធនា" ។

មែនពិត ព្រះពុទ្ធទាំងឡាយ រមែងទ្រង់ជ្រាបថា កាលព្រះអង្គទ្រង់រំពឹងយ៉ាងនោះ ព្រហ្មនឹងមកទូលនិមន្តឲ្យសម្ដែងធម៌ គ្រានោះ សត្វទាំងឡាយនឹងកើតសេចក្ដីគោរពក្នុងធម៌ ព្រោះថា លោកសន្និវាសគោរពព្រហ្ម ។ សេចក្ដីរំពឹងនេះ កើតឡើងព្រោះហេតុ ២ ប្រការនេះ ដោយប្រការដូច្នេះឯង ។

## គ-សេចក្ដីប្រៀបផ្កាឈូកនឹងបុគ្គល ៤ ពួក

បណ្ដាផ្កាឈូកទាំងនោះ ផ្កាឈូកណា តាំងនៅផុតពីទឹក កាលសម្លស្សស្មើព្រះអាទិត្យពាល់ត្រូវ ផ្កាឈូកទាំងនោះ នឹងរីកក្នុងថ្ងៃនេះ ។ ផ្កាឈូកណាតាំងនៅស្មើទឹក ផ្កាឈូកទាំងនោះ នឹង

រីកក្នុងថ្ងៃស្អែក ។ ផ្កាឈូកណានៅមិនទាន់ឡើងផុតអំពីទឹក លិចនៅក្នុងទឹក ដែលទឹកផ្សើមទុក ផ្កាឈូកទាំងនោះនឹងរីកក្នុងថ្ងៃទី ៣ ។

ម្យ៉ាងទៀត សូម្បីផ្កាឈូកដទៃទៀត ដែលមិនទាន់ឡើងផុតអំពីទឹក ដែលឈ្មោះថា ជាឈូកមានរោគជាដើមក៏នៅមាន ឈូកពួកណាដែលមិនទាន់រីក នឹងបានជាចំណីនៃត្រី និងអណ្តើកតែម្យ៉ាង ឈូកទាំងនោះ មិនឡើងកាន់ព្រះបាលី តែក៏គួរនាំមកសម្តែងទុកផង ព្រោះហេតុនោះ លោកទើបមិនប្រកាសទុកក្នុងអដ្ឋកថា ក៏បុគ្គលមាន ៤ ពួក គឺ

**១-ឧគ្ឃដិតញ្ញូ** អ្នកត្រាស់ដឹងបានឆាប់
**២-វិបចិតញ្ញូ** អ្នកដឹងធម៌ក្នុងកាលដែលអធិប្បាយ
**៣-នេយ្យ** អ្នកដឹងធម៌ដែលគួរនឹងណែនាំបាន
**៤-បទបរម** អ្នកមានបទធម៌យ៉ាងក្រៃលែង

ដូចផ្កាឈូកទាំង ៤ យ៉ាងនោះឯង ។

បណ្តាបុគ្គល ៤ ពួកនោះ បុគ្គលណារមែងមានការត្រាស់-ដឹងធម៌បាន ព្រមជាមួយនឹងវេលាដែលលើកធម៌ឡើងសម្តែងបុគ្គលនេះ កាលតាំងមាតិកាដោយសង្ខេប ដោយន័យថា នេះគឺ

សតិប្បដ្ឋាន ៤ ដូច្នេះជាដើម ក៏បញ្ជូនញាណទៅតាមក្រសែនៃព្រះធម៌ អាចនឹងចាក់ធ្លុះព្រះអរហត្តបាន បុគ្គលនេះឈ្មោះថា **ឧគ្ឃដិតញ្ញូ** អ្នកត្រាស់ដឹងបានឆាប់ ។ បុគ្គលណា កាលបានចែកនៃកាសិតដែល បានពោលទុកដោយសង្ខេបឲ្យពិស្តារ ទើបត្រាស់ដឹងធម៌ បុគ្គលនេះ ហៅថា **វិបចិតញ្ញូ** អ្នកដឹងធម៌ក្នុងកាលដែលអធិប្បាយ ។ បុគ្គលណាកាលសាកសួរដោយឧទ្ទេស ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា សេពគប់រក ចូលទៅអង្គុយជិតកល្យាណមិត្តទាំងឡាយ ទើបមានការត្រាស់ដឹងធម៌បានដោយលំដាប់ បុគ្គលនេះហៅថា **នេយ្យបុគ្គល** អ្នកដឹងធម៌ដែលគួរនឹងណែនាំបាន ។ បុគ្គលណា សូម្បីកាលស្តាប់ច្រើន សូម្បីកាលពោលច្រើន សូម្បីកាលចាំទុកច្រើន សូម្បីកាលរៀនច្រើន ក៏មិនមានការត្រាស់ដឹងធម៌បានក្នុងជាតិនេះ មិនអាចនឹងញ៉ាំងមគ្គ ឬផល ដោយហោចទៅញ៉ាំងឈាន ឬវិបស្សនាឲ្យកើតដោយអត្តភាពនោះបាន បុគ្គលនេះហៅថា **បទបរម** អ្នកមានបទធម៌យ៉ាងក្រៃលែង ។ ក្នុងបុគ្គល ៤ ពួកនោះ ព្រះមានព្រះភាគ កាលទ្រង់រមិលមើលម៉ឺនលោកធាតុ ដែលដូចជាគុម្ពផ្កាឈូកជាដើម បានទ្រង់ឃើញ**ឧគ្ឃដិតញ្ញូបុគ្គល** ដែលប្រៀប

ដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃនេះ, **វិបចិតញ្ញូ** ដែលប្រៀបដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃស្អែក, **នេយ្យបុគ្គល** ដែលប្រៀបដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃទី ៣ និង**បទបរមបុគ្គល** ដែលប្រៀបដូចផ្កាឈូកដែលនឹងបានជាចំណីនៃត្រីនិងអណ្តើក, កាលទ្រង់ឃើញក៏បានទ្រង់ឃើញដោយអាការទូទៅយ៉ាងនេះថា បុគ្គលនេះមានធូលីក្នុងចក្ខុតិច មានចំនួនប៉ុណ្ណេះ បុគ្គលនេះមានធូលីក្នុងចក្ខុច្រើន មានចំនួនប៉ុណ្ណេះ សូម្បីក្នុងបុគ្គលពួកនោះ បុគ្គលដែលជាឧគ្ឃដិតញ្ញូមានចំនួនប៉ុណ្ណេះ ។

បណ្តាបុគ្គល ៤ ពួកនោះ ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគ រមែងញុំាងប្រយោជន៍ឲ្យសម្រេចក្នុងអត្តភាពនេះឯង ដល់បុគ្គល ៣ ពួក ។ សម្រាប់ពួកបទបរមបុគ្គល រមែងជាវាសនាដើម្បីប្រយោជន៍ក្នុងអនាគត ។ គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់ជ្រាបការសម្តែងធម៌ទេសនា ដែលនាំប្រយោជន៍មកឲ្យដល់បុគ្គល ៤ ពួកទាំងនេះ បានទ្រង់ញុំាងសេចក្តីប្រាថ្នានឹងទ្រង់សម្តែងឲ្យកើតឡើងហើយទ្រង់ចែកសត្វក្នុងភពទាំង ៣ ទាំងអស់ជាពីរចំណែកគឺ ជាភព្វសត្វ ១ អភព្វសត្វ ១ ដែលទ្រង់សំដៅដល់

ត្រាស់ទុកថា សត្វពួកណាប្រកបដោយគ្រឿងរារាំងគឺ កម្ម ប្រកបដោយគ្រឿងរារាំងគឺ វិបាក ប្រកបដោយគ្រឿងរារាំងគឺ កិលេស មិនមានសទ្ធា មិនមានឆន្ទះ អប្បឥតប្រាជ្ញា មិនគួរដើម្បីនឹងឈានចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយបាន សត្វទាំងនេះនោះ ឈ្មោះថាជា**អភព្វសត្វ** អ្នកមិនគួរដល់ការត្រាស់ដឹង ។ សត្វទាំងឡាយដែលជាភព្វសត្វ គួរដល់ការត្រាស់ដឹងយ៉ាងណា ? សត្វទាំងនោះណា មិនប្រកបដោយគ្រឿងរារាំងគឺ កម្ម ។ល។ សត្វពួកនោះ ឈ្មោះថា **ភព្វសត្វ** អ្នកគួរដល់ការត្រាស់ដឹង ។ ក្នុងភព្វបុគ្គលនិងអភព្វបុគ្គលទាំងនោះ ព្រះមានព្រះភាគ ទ្រង់លះអភព្វបុគ្គលចេញទាំងអស់ ទ្រង់កំណត់យកភព្វបុគ្គលតែម្យ៉ាងដោយញាណ ទ្រង់ចែកជា ៦ ចំណែក គឺពួកដែលជារាគចរិតចំនួនប៉ុណ្ណោះ ពួកដែលជាទោសចរិត ចំនួនប៉ុណ្ណោះ ពួកដែលជាមោហចរិតចំនួនប៉ុណ្ណោះ ពួកដែលជាវិតក្កចរិត ចំនួនប៉ុណ្ណោះ ពួកដែលជាសទ្ធាចរិត ចំនួនប៉ុណ្ណោះ ពួកដែលជាពុទ្ធិចរិតចំនួនប៉ុណ្ណោះ ។ កាលទ្រង់ចែកយ៉ាងនេះហើយ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្ដែងធម៌ ។ ក៏ក្នុងអធិការនេះ គប្បីឃើញថា សត្វទាំងនោះរមែង

ប្រាកដជាពួកៗ ដល់ព្រះមានព្រះភាគ ទ្រង់រំពឹងដោយជាបុគ្គល ដែលមានធូលីក្នុងចក្ខុតិចជាដើម និងជាភព្វបុគ្គលជាដើម មិនប្រាកដជាម្នាក់ៗ ទេ ។ (ចាកសារត្ថទីបនីដីកា )

## ឃ. ពុទ្ធបរិវិតក្កៈ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះទៀតថា **អាឡារតាបសកាឡាមគោត្រ** នេះជាបណ្ឌិត ជាអ្នកឈ្លៀវឈ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកយូរមកហើយ បើដូច្នោះតថាគតគួរសម្តែងធម៌ដល់អាឡារតាបសកាឡាមគោត្រជាមុនចុះ តាបសនោះ នឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។

គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូលព្រះមានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន

អាឡារតាបសកាឡាមគោត្រ ធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃហើយ ។

ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបថា អាឡារតាបសកាឡាម-គោត្រ ធ្វើកាលកិរិយាស្លាប់ទៅ ៧ ថ្ងៃហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះយ៉ាងនេះថា អាឡារតាបសកាឡាមគោត្រ (នុ៎ះ) មានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះ បានស្តាប់ធម៌នេះ ក៏គប្បីត្រាស់ដឹងធម៌បានមួយរំពេច ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះទៀតថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនអេះ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ព្រះមានព្រះភាគ ក៏ទ្រង់ព្រះតម្រិះក្នុងលំដាប់នោះទៀតថា **ឧទ្ទកតាបសរាមបុត្រ**នេះឯង ជាបណ្ឌិត ជាអ្នកឈ្លៀវឈ្លាសវាងវៃ ជាអ្នកមានបញ្ញា មានធូលី គឺរាគាទិ-ក្កិលេសតិចក្នុងភ្នែកយូរមកហើយ បើដូច្នោះ តថាគតគួរសម្តែងធម៌ដល់ឧទ្ទកតាបសរាមបុត្រជាមុនចុះ តាបសនោះ នឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។

គ្រានោះ មានទេវតា (អង្គមួយ) មានរូបមិនប្រាកដ ក្រាបទូលព្រះមានព្រះភាគ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ឧទ្ទកតាបសរាមបុត្រ ធ្វើកាលកិរិយាស្លាប់អំពីពេលព្រលប់ទៅហើយ ។

ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបថា ឧទ្ទកតាបសរាមបុត្រ ធ្វើកាលកិរិយាស្លាប់អំពីពេលព្រលប់ទៅហើយដែរ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះយ៉ាងដូច្នេះថា ឧទ្ទកតាបសរាមបុត្រ (នុ៎ះ) មានសេចក្តីសាបសូន្យធំ ប្រសិនបើតាបសនោះ បានស្តាប់ធម៌នេះ ក៏គប្បីត្រាស់ដឹងធម៌បានមួយរំពេច ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះ ក្នុងលំដាប់នោះទៀតថា បញ្ចវគ្គិយភិក្ខុទាំងឡាយមានឧបការគុណច្រើនដល់តថាគត ព្រោះថាបានបម្រើតថាគតកាលដែលកំពុងបញ្ជូនចិត្តទៅក្នុងព្យាយាម បើដូច្នោះ គួរតថាគតសម្តែងធម៌ដល់បញ្ចវគ្គិយភិក្ខុទាំងឡាយជាមុនចុះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះ

*តម្រិះដូច្នេះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងឡាយនៅឯណា ។ លុះព្រះមានព្រះភាគ ទ្រង់ឃើញបញ្ចវគ្គិយភិក្ខុទាំងឡាយ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធ ស្អាតកន្លងលើសចក្ខុរបស់មនុស្ស ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ទើបទ្រង់យាងទៅកាន់ចារិក សំដៅទៅក្រុងពារាណសី ។*

## *ក្នុងគម្ពីរអដ្ឋកថាសីហសូត្រ លោកពោលទុកថា ៖*

សីហស្ស ចតុទិសាវិលោកនំ វិយ បដិវិទ្ធសព្វញ្ញុ-តញ្ញាណស្ស សត្តសត្តាហំ ពោធិមណ្ឌេ វិហរិត្វា បរិភុត្ត-មធុបិណ្ឌិកាហារស្ស អជបាលនិគ្រោធមូលេ មហាព្រហ្មុនោ ធម្មទេសនាយាចនំ បដិគ្គហេត្វា តត្ថ វិហរន្តស្ស ឯកាទស-មេ ទិវសេ "ស្វេ អាសាឡ្ហិបុណ្ណមា ភវិស្សតី"តិ បច្ចូស-សមយេ "កស្ស នុ ខោ អហំ បឋមំ ធម្មំ ទេសេយ្យ"ន្តិ អាឡារុទកានំ កាលកតភាវំ ញត្វា ធម្មទេសនត្ថាយ បញ្ចវគ្គិយានំ ឱលោកនំ ឧជ្ជុតំ ។

កាលព្រះតថាគត ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ទ្រង់គង់នៅជិតពោធិមណ្ឌស្ថាន ៧ សប្ដាហ៍ សោយមធុបាយាសជាព្រះក្រយាហារ ទ្រង់ទទួល(ការ)អារាធនាសម្ដែងធម៌របស់ស្ដេចមហាព្រហ្ម ទៀបគល់អជបាលនិគ្រោធ ទ្រង់គង់នៅក្នុងទីនោះ ក្នុងថ្ងៃទី ១១ ទ្រង់រលឹកថា ថ្ងៃស្អែកនេះជាថ្ងៃ ១៥ កើត ខែអាសាឍ (អាសាឡ្ហបុណ្ណមី) ក្នុងវេលាជិតភ្លឺទ្រង់ពិចារណាមើលថា តថាគតគួរសម្ដែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសអស់ជីវិតហើយ ក៏ទ្រង់ឃើញភិក្ខុបញ្ចវគ្គិយ សមគួរទទួលព្រះធម៌ទេសនាមុន, គប្បីឃើញដូចការក្រឡេកមើលទិសទាំង ៤ របស់រាជសីហ៍ ។

សីហស្ស គោចរត្ថាយ តិយោជនំ គមនកាលោ វិយ អត្តនោ បត្តចីវរំ អាទាយ "បញ្ចវគ្គិយានំ ធម្មចក្កំ បវត្តេស្សាមី"តិ បច្ឆាភត្តេ អជបាលនិគ្រោធតោ វុដ្ឋិតស្ស អដ្ឋារសយោជនមគ្គំ គមនកាលោ ។

វេលាដែលព្រះតថាគតទ្រង់កាន់យកបាត្រ និងចីវររបស់ព្រះអង្គស្ដេចក្រោកអំពីដើមអជបាលនិគ្រោធ ស្ដេចទៅអស់ផ្លូវ

១៨ យោជន៍ វេលាខាងក្រោយភត្ត ដោយប្រាថ្នាព្រះហឫទ័យនឹងប្រកាសធម្មចក្កដល់ភិក្ខុបញ្ចវគ្គិយ គប្បីឃើញដូចវេលារាជសីហ៍ចេញរកចំណីទៅបានបីយោជន៍ ។

វេលាដែលព្រះតថាគតស្តេចទៅអស់ផ្លូវ ១៨ យោជន៍ ទ្រង់ធ្វើភិក្ខុបញ្ចវគ្គិយឲ្យយល់ហើយ ទ្រង់គង់លើអចលបល្ល័ង្ក ចម្រើនសមាធិ ដែលពួកទេវតាបានប្រជុំព្រមគ្នាមួយម៉ឺនចក្រវាឡហែហមហើយទើបប្រកាសព្រះធម្មចក្ក ដោយន័យជាអាទិថា **អន្តៈ** ផ្លូវប្រតិបត្តិអមខាងដ៏លាមកបំផុត ២ ប្រការនេះ ដែលបព្វជិត មិនគួរសេពដូច្នេះ, គប្បីជ្រាបដូចជាវេលាដែលរាជសីហ៍បន្លឺសីហនាទ ។

ក៏ឯកាលព្រះតថាគតទ្រង់សម្តែងព្រះធម្មចក្កនេះ សំឡេងធម៌របស់រាជសីហ៍ គឺព្រះតថាគត ក៏គ្របដណ្តប់ម៉ឺនលោកធាតុ ខាងក្រោមដល់អវីចិ ខាងលើរហូតដល់ភវគ្គព្រហ្ម ។ វេលាដែលព្រះតថាគតសម្តែងលក្ខណៈ ៣ ត្រាស់ធម៌ចែកសច្ចៈ ៤ ព្រមដោយអាការ ១៦ ជរាបដល់ពាន់ន័យ ពួកទេវតាដែលមានអាយុវែងក៏កើតសេចក្តីតក់ស្លុតដោយញាណ គប្បីជ្រាបដូចវេលាពួកសត្វតូចៗ តក់ស្លុតព្រោះសំឡេងរបស់រាជសីហ៍ ។

## ខ. ព្រះមានព្រះភាគទ្រង់យាងទៅកាន់ក្រុងពារាណសី ដើម្បីសម្តែងធម្មចក្ក

មានអាជីវកម្នាក់ ឈ្មោះឧបកៈ បានឃើញព្រះមានព្រះភាគស្តេចទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះគយាសីសប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង លុះឃើញហើយក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវិវណ្ណ (សម្បុរស្បែក) របស់អ្នកដ៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា ។

កាលឧបកាជីវកសួរយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ឆ្លើយតបដោយពាក្យជាគាថាទៅរកឧបកាជីវកថា ៖

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេស ក្នុងតេភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ ដោយខ្លួនឯង (ចាំបាច់) ចំពោះ

បុគ្គលណា ៗ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគតឡើយ ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ៗ ព្រោះថាតថាគតជាអរហន្តក្នុងលោក ជាសាស្ដាខ្ពស់ផុត ជាអ្នកត្រាស់ដឹងដោយប្រពៃចំពោះខ្លួនឯង តថាគតមានសេចក្ដីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ៗ ឥឡូវតថាគតទៅកាន់ក្រុងនៃពួកជនអ្នកកាសី ដើម្បីនឹងសម្ដែងធម្មចក្ក (ដោយបំណងថា) តថាគតនឹងទូងនូវស្គរ គឺអមតនិព្វានចំពោះសត្វលោកដែលងងឹត គឺអវិជ្ជា កំពុងគ្របសង្កត់ ៗ

ឧបកាជីវកក៏តបថា ម្នាលអាវុសោ អ្នកប្ដេជ្ញាខ្លួនថាយ៉ាងណា អ្នក(គួរដើម្បីបាននូវឈ្មោះ)ថា **អនន្តជិនៈ** (យ៉ាងនោះឯង),

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះពុទ្ធដីកាទៀតថា ៖

ជនទាំងឡាយណា បានដល់នូវធម៌សម្រាប់ធ្វើអាសវៈឲ្យអស់ទៅ ជនទាំងឡាយនោះ ឈ្មោះថា **ជិនៈ** (ជាអ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ ៗ តថាគតបានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតបាន

នូវឈ្មោះថា **ជិនៈ** (ជាអ្នកឈ្នះបាបធម៌) ។

កាលព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ឧបកាជីវកពោលពាក្យថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹងពិតមែនហើយ (ថាហើយ) ក៏ផ្ទក់ក្បាលហើយ កាន់យកផ្លូវខុស (គឺដើរបែកផ្លូវគ្នា) ចៀសចេញទៅ ។ (វិនយបិដក ៦, ២២)

## ច.ឥសិបតនមិគទាយវ័ន

ពាក្យថា **ក្នុងព្រៃឥសិបតនមិគទាយវ័ន** មានសេចក្ដីថា បានឮថា ប្រទេសនោះ កាលព្រះសម្មាសម្ពុទ្ធនៅមិនទាន់កើតឡើង ព្រះបច្ចេកពុទ្ធទាំងឡាយបានគង់នៅដោយនិរោធសមាបត្តិអស់ ៧ ថ្ងៃ លើភ្នំគន្ធមាទ ទំពាឈើស្ទន់ ឈ្មោះថា នាគលតាហើយ លុបលាងព្រះភក្ត្រត្រង់ស្រះអនោតត្ត កាន់បាត្រនិងចីវរ ស្ដេចមកតាមផ្លូវអាកាសហើយចុះឃុំចីវរក្នុងទីនោះហើយ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុង ធ្វើភត្តកិច្ចស្រេចហើយ សូម្បីក្នុងវេលាទៅ ក៏ហោះឡើងអំពីស្ថានទីនោះៗ ឯងទៅ ។ ពួកឥសីរមែងចុះ ហោះឡើងអំពីស្ថានទីនេះដូច្នេះ, ហេតុនោះ ស្ថានទីនោះទើបមានឈ្មោះថា

**ឥសិបតនៈ ។**

ចំណែកដែលហៅថា **មិគទាយ** ព្រោះជាស្ថានទីដែលព្រះរាជាប្រទានដល់ម្រឹគទាំងឡាយ ដើម្បីប្រយោជន៍ដល់ការមិនមានភ័យ ។ ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ក្នុងព្រៃឥសិបតនមិគទាយវ័ន ។

ព្រះពុទ្ធទាំងឡាយអន្លដទៃៗ កាលនឹងស្តេចទៅដើម្បីប្រយោជន៍ដល់ការសម្តែងធម៌ជាដំបូង ក៏ស្តេចទៅតាមផ្លូវអាកាសហើយចុះក្នុងស្ថានទីនោះៗឯង ។ ចំណែកព្រះមានព្រះភាគ របស់យើងទាំងឡាយ ទ្រង់ឃើញឧបនិស្ស័យរបស់អាជីវក ឈ្មោះថា **ឧបកៈ** ទ្រង់ជ្រាបថា ឧបកៈដើរតាមផ្លូវនេះ លោកឃើញតថាគតហើយ សន្ទនាជាមួយតថាគតហើយនឹងទៅ កាលខាងក្រោយត្រឡប់នឿយណាយ ក៏នឹងមកធ្វើឲ្យជាក់ច្បាស់អរហត្តផល ដូច្នេះទើបបានស្តេចពុទ្ធដំណើរដោយព្រះបាទ រហូតផ្លូវចម្ងាយ ១៨ យោជន៍ ។ ដោយហេតុនោះ ព្រះធម្មសង្គីតិកាចារ្យទើបពោលថា ទ្រង់យាងទៅកាន់ចារិកសំដៅទៅក្រុងពារាណសី ។

ពាក្យថា អន្តរា ច គយំ អន្តរា ច ពោធឹ ប្រែថា ក្នុងចន្លោះគយាសីសប្រទេសផង ក្នុងចន្លោះពោធិព្រឹក្សផង គឺក្នុងចន្លោះ ៣ គាវុត ។ ពិតមែន ស្រុកគយាអំពីពោធិមណ្ឌលប្រវែង ៣ គាវុត, នគរពារាណសីមានប្រវែង ១៨ យោជន៍ ។ ឧបកៈបានជួបព្រះមានព្រះភាគ ក្នុងចន្លោះពោធិមណ្ឌលស្ថាន និងស្រុកគយា ។ ក៏ស្រុកគយាអំពីពោធិមណ្ឌលស្ថាន ជាចន្លោះផ្លូវ ៣ គាវុត ។

(បាកសារត្ថទីបនីដីកា ៤, ៤៥)

## ៦_ ទ្រង់យាងដល់ឥសិបតនមិគទាយវ័ន

គ្រានោះ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់ចារិក តាមលំដាប់ហើយ ក៏យាងចូលទៅកាន់ក្រុងពារាណសី រួចហើយ ទ្រង់យាងទៅឯឥសិបតនមិគទាយវ័ន សំដៅទៅរកកន្លែងដែលបញ្ច-វគ្គិយភិក្ខុនៅ ។ បញ្ចវគ្គិយភិក្ខុឃើញព្រះមានព្រះភាគ យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ធ្វើប្តេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះ ជាអ្នកប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកសេចក្តីព្យាយាមហើយ វិលត្រឡប់ដើម្បីការៈជាអ្នកល្មោភច្រើន

ឥឡូវនេះ លោកនិមន្តមក យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលយកបាត្រចីវររបស់លោកឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបម្រុងទុក បើលោកចង់គង់ក៏គង់ចុះ ។ ព្រះមានព្រះភាគ យាងចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណាៗ បញ្ចវគ្គិយភិក្ខុទាំងនោះ ក៏មិនអាចឋិតនៅក្នុងពាក្យប្តេជ្ញារបស់ខ្លួន ដោយប្រការនោះៗ បានឡើយ ក៏ស្រោបតែក្រោកទទួលព្រះមានព្រះភាគ ខ្លះទទួលយកបាត្រចីវររបស់ព្រះមានព្រះភាគ ខ្លះក្រាលអាសនៈថ្វាយ ខ្លះតម្កល់ទឹកលាងព្រះបាទ យកតាំងសម្រាប់រងព្រះបាទ និងឈ្នាន់ព្រះបាទមកថ្វាយ ។ ព្រះមានព្រះភាគ គង់លើអាសនៈដែលបញ្ចវគ្គិយភិក្ខុទាំងឡាយ រៀបចំទុកហើយ ។ លុះព្រះមានព្រះភាគ គង់ហើយក៏ទ្រង់លាងព្រះបាទទាំងពីរ ។ ទើបបញ្ចវគ្គិយភិក្ខុហៅព្រះមានព្រះភាគ ដោយចំព្រះនាមផង ដោយពាក្យថា អាវុសោផង ។ កាលបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យហៅយ៉ាងនេះហើយ ព្រះភគវន្តមុនីទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នាកុំហៅតថាគតដោយចំឈ្មោះ និង

ពាក្យថា អាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្ត ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្ដែងធម៌ ក៏កុលបុត្រទាំងឡាយដែលចេញចាកផ្ទះហើយ បួសក្នុងភាពនៃបុគ្គលគ្មានការផ្ទះជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយកាលបើបានប្រតិបត្តិគួរតាមពាក្យប្រដៅ របស់តថាគតហើយពុំយូរឡើយនឹងបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាខ្លួនឯងក្នុងបច្ចុប្បន្នេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយឥរិយាបថទាំងបួន ។

កាលព្រះមានព្រះភាគ ទ្រង់មានពុទ្ធដីកាយ៉ាងនេះហើយ បញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្ស-ធម្ម ជាធម៌វិសេសដោយញាណ និងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេស ដោយការប្រព្រឹត្តនោះផង ដោយការប្រតិបត្តិនោះផង ដោយអំពើដែលអ្នកដទៃ ធ្វើតាមបានដោយកម្រផង ឥឡូវនេះ

ព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើនហើយ ក៏នឹងបានត្រាស់ដឹងឧត្តរិ-មនុស្សធម៌ដ៏វិសេស ដោយញាណនិងទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេសដូចម្ដេចបាន ។

លុះបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ ទើបព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលយ៉ាងនេះនឹងបញ្ចវគ្គិយ-ភិក្ខុថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាកសេចក្តីព្យាយាមទេ មិនវិលត្រឡប់ដើម្បីល្មោភច្រើនដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្ត-សម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ តថាគតនឹងប្រៀនប្រដៅនូវព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្ដែងធម៌ ក៏កុលបុត្រទាំងឡាយចេញចាកផ្ទះហើយ បួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិ គួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់

ច្បាស់ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ នឹងសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

បញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យនេះនឹងព្រះមានព្រះភាគ ជាគម្រប់ពីរដងផង ។បេ។ ព្រះមានព្រះភាគ ទ្រង់មានព្រះ-ពុទ្ធដីកានេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយ ជាគម្រប់ពីរដងផង។បេ។

បញ្ចវគ្គិយភិក្ខុទាំងឡាយពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគ ជាគម្រប់បីដងទៀតថា បពិត្រព្រះគោតមដ៏មានអាយុ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណទិនទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេស ដូចម្តេចបាន ។ កាលបើបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ នឹងបញ្ចវគ្គិយភិក្ខុ-ទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពិចារណាមើលនូវពាក្យរបស់តថាគតឥឡូវនេះ ដូចគ្នានឹងកាលមុនអំពីកាលឥឡូវនេះដែរឬទេ ។

បញ្ចវគ្គិយភិក្ខុទាំងឡាយតបថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យហ្នឹង ព្រះអង្គមិនដែលពោលទេ ។

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្បសាទចុះ ។ តថាគតនឹងប្រៀនប្រដៅព្រះនិព្វាន ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងព្រះធម៌ ក៏កុលបុត្រទាំងឡាយចេញចាកផ្ទះបួស ក្នុងភាពនៃបុគ្គលមិនមានការផ្ទះជាប្រយោជន៍ដល់ផ្ទះដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយ ប្រតិបត្តិគួរតាមពាក្យរបស់តថាគត ពុំយូរឡើយមុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រះមានព្រះភាគ បានញុំាងបញ្ចវគ្គិយភិក្ខុទាំងឡាយឲ្យយល់ច្បាស់ (ក្នុងពេលនោះ) ។ លុះគ្រាជាខាងក្រោយបញ្ចវគ្គិយភិក្ខុទាំងឡាយ តាំងចិត្តស្តាប់ព្រះមានព្រះភាគ ផ្ទៀងនូវសោតប្បសាទ ហើយផ្ចង់ចិត្តដើម្បីដឹងច្បាស់ ។

## ២-ទ្រង់សម្ដែងធម្មចក្កប្បវត្តនសូត្រ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយមកហើយត្រាស់ថា ៖

ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ម្នាលភិក្ខុទាំងឡាយ អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថាមិនគួរប្រព្រឹត្តឡើយ ។

កតមេ ទ្វេ អន្តធម៌ពីរយ៉ាងនោះដូចម្ដេច ?

យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ ធម៌ណា ដែលប្រកបខ្វល់ខ្វាយឲ្យជាប់ជំពាក់ដោយកាម ក្នុងកាមទាំងឡាយ ហីនោ ជាធម៌ថោកទាប គម្មោ ជាធម៌របស់អ្នកស្រុក ពោថុជ្ជនិកោ ជាធម៌របស់បុថុជ្ជន អនរិយោ មិនមែនជារបស់អរិយបុគ្គលទេ អនត្ថសំហិតោ មិនប្រកបដោយប្រយោជន៍ឡើយ ។

យោ ចាយំ អត្តកិលមថានុយោគោ ធម៌ណាដែល

*ប្រកបដោយសេចក្តីលំបាកដល់ខ្លួន ។*

ទុក្ខោ *ជាហេតុនាំឲ្យលំបាកកាយទទេ*

អនរិយោ *មិនមែនជារបស់អរិយបុគ្គលទេ*

អនត្ថសំហិតោ *មិនប្រកបដោយប្រយោជន៍ឡើយ ។*

ឯតេ តេ ឧភោ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ : *ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាល មិនលាយច្រឡំដោយអន្តធម៌ ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ (ភ្នែកគឺប្រាជ្ញា) ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដរមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ ។*

កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី

ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ម្នាលភិក្ខុទាំងឡាយ ក៏សេចក្ដីប្រតិបត្តិជាកណ្ដាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ដើម្បីសេចក្ដីដឹងចំពោះ ដើម្បីសេចក្ដីដឹងដោយប្រពៃ ដើម្បីសេចក្ដីរំលត់ទុក្ខនោះ តើដូចម្ដេច ?

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ *អដ្ឋង្គិកមគ្គ គឺធម៌ដូចជាផ្លូវមានអង្គ ៨ ដ៏ប្រសើរនេះឯង (ហៅថាសេចក្ដីប្រតិបត្តិជាកណ្ដាល)*

| | |
|---|---|
| សេយ្យថីទំ | *អដ្ឋង្គិកមគ្គនោះ ដូចម្ដេច ?* |
| សម្មាទិដ្ឋិ | *ប្រាជ្ញាយល់ឃើញត្រូវ* |
| សម្មាសង្កប្បោ | *សេចក្ដីត្រិះរិះត្រូវ* |
| សម្មាវាចា | *សម្ដីត្រូវ* |
| សម្មាកម្មន្តោ | *ការងារត្រូវ* |
| សម្មាអាជីវោ | *កិរិយាចិញ្ចឹមជីវិតត្រូវ* |

សម្មាវាយាមោ *ព្យាយាមត្រូវ*

សម្មាសតិ *សេចក្ដីរឭកត្រូវ*

សម្មាសមាធិ *កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ ។*

អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គនេះឯង ដែលហៅថា សេចក្ដីប្រតិបត្តិជាកណ្ដាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងចំពោះ ដើម្បីសេចក្ដីដឹងដោយប្រពៃ ដើម្បីសេចក្ដីរំលត់ទុក្ខ ។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ

ទុក្ខា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា : ម្នាលភិក្ខុទាំងឡាយ **ជាតិ** គឺ កិរិយាកកើតនៃខន្ធជាហេតុនាំមកនូវទុក្ខ **ជរា** គឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ **ព្យាធិ** គឺជំងឺដំកាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ **មរណៈ** គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាប្រកបដោយសត្វ និងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កាលបើចង់បាននូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ ឧបាទានក្ខន្ធទាំងឡាយ ៥ ដែលតថាគតសម្តែងហើយដោយបំព្រួញ ក៏ជាហេតុនាំមកនូវទុក្ខ កងទុក្ខមានជាតិជាដើមនេះ ឈ្មោះថា ទុក្ខអរិយសច្ចៈ ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ[១] អរិយសច្ចំ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគ-សហគតា តត្រ តត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា : *ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែងនូវភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតី តណ្ហានោះដូចម្តេចខ្លះ ? (តណ្ហានោះ) គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហាទាំង ៣ នេះឈ្មោះថា* ***ទុក្ខ-សមុទយអរិយសច្ចៈ*** ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ[២] អរិយសច្ចំ

---

១- សព្វត្ថ ទុក្ខសមុទយំ អរិយសច្ចំ ទុក្ខនិរោធំ អរិយសច្ចំ ទិស្សតិ ។ តម្បន ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ បាលិយា ន សមេតិ ។ តេនាហំ អម្ហាកំ អនុមតិយា សោធិតោតិ វេទិតព្វោ ។ ២- សព្វត្ថ ទុក្ខសមុទយំ អរិយសច្ចំ ទុក្ខនិរោធំ អរិយសច្ចំ ទិស្សតិ ។ តម្បន ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ បាលិយា ន សមេតិ ។ តេនាហំ អម្ហាកំ អនុមតិយា សោធិតោតិ វេទិតព្វោ ។

យោ តស្សា យេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ *ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គ មិនឲ្យមានសេសសល់ កិរិយាលះបង់នូវតណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាកតណ្ហានោះ កិរិយាមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហា ដោយអរិយមគ្គ មិនឲ្យមានសេសសល់ជាដើមនេះឯង ឈ្មោះថា* ***ទុក្ខនិរោធអរិយសច្ចៈ*** ។

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ *ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ដូចម្តេចខ្លះ គឺប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សម្តីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្តីរលឹកត្រូវ*

*កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ឈ្មោះថា* ***ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ*** ។

ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជា****ទុក្ខអរិយសច្ចៈ*** *ដូច្នេះឡើយ* ។

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំង*

ឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខ-អរិយសច្ចនេះឯង គួរតែកំណត់ដឹងដោយបញ្ញា ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខ-អរិយសច្ចនេះឯង តថាគតកំណត់ដឹងបានហើយ ដូច្នេះឡើយ ។

ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺ

ភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខសមុទយអរិយ-សច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខសមុទយំ អរិយសច្ចំ បហា-តព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខ-សមុទយអរិយសច្ច នេះឯង គួរតែលះបង់ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខសមុទយំ អរិយសច្ចំ បហីនន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើង

ហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង តថាគតលះបង់បានហើយ ដូច្នេះឡើយ ។

ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើម តថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ

អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង គួរតែធ្វើឲ្យជាក់ច្បាស់ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធអរិយសច្ច នេះឯង តថាគតធ្វើឲ្យជាក់ច្បាស់បានហើយដូច្នេះឡើយ ។

ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ

ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ។*

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ : *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង គួរតែចម្រើនឲ្យកើត*

ឡើង ដូច្នេះឡើយ ។

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ ៖ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ក្នុងធម៌ទាំងឡាយដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង តថាគតចម្រើនឲ្យកើតឡើងបានហើយ ដូច្នេះឡើយ ។

**យាវកីវញ្ច** មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ ៖ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដែលដឹងច្បាស់ឃើញច្បាស់តាមពិត មានបរិវដ្ដៈ ៣ មានអាការៈ ១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិយសច្ច

ទាំងឡាយ ៤ នេះ នៅមិនទាន់បរិសុទ្ធល្អ មានដល់តថាគតអស់កាលត្រឹមណា ។

នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ : ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលត្រឹមណោះនៅឡើយទេ ។

យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុវិសុទ្ធំ អហោសិ ម្នាលភិក្ខុទាំងឡាយ ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មានបរិវដ្ដៈ ៣ មាន

*អាការៈ ១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ បរិសុទ្ធល្អ មានដល់តថាគត ក្នុងកាលឯណា ។*

អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ : *ម្នាលភិក្ខុទាំងឡាយ តថាគតប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសក្នុងកាលណោះឯង ។*

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ[១] អយមន្តិមា ជាតិ នត្ថិ ទានិ បុនព្ភវោតិ *ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់ កើតឡើងហើយដល់តថាគត*

---

១- អម្ហាកំ បោត្ថកំ ឋបេត្វា សព្វត្ថ ចេតោវិមុត្តីតិ បាឋោ ទិស្សតិ ។ សោ ន យុជ្ជតិ ។ កស្មា ។ ន កេវលំ ចេតោវិមុត្តិ ឥធ អធិប្បេតា បញ្ញាវិមុត្តិបិ ឥធ គហិតា ។

ដូច្នេះថា សេចក្ដីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះភពថ្មី គឺការត្រឡប់កើតទៀតក៏មិនមានឡើយ ។

ឥទមវោច ភគវា ព្រះមានព្រះភាគ បានត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រនេះ (ចប់ហើយ)

អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ : បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគដោយក្រៃពេក ។

ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ : នាកាលវេយ្យាករណ៍ គឺព្រះសូត្រដែលឥតមានគាថានេះ ដែលព្រះមានព្រះភាគ កំពុងត្រាស់ទេសនា ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលីគឺរាគៈ ប្រាសចាកមន្ទិល គឺអកុសលកើតឡើងហើយ ដល់ព្រះកោណ្ឌញ្ញៈដ៏មានអាយុថា

យំ កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ

*ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតនោះទាំងអស់មានកិរិយារលត់ទៅជាធម្មតា ។*

**បវត្តិតេ** ច ភគវតា ធម្មចក្កេ : *ក៏នាកាលព្រះធម្មចក្កប្បវត្តនសូត្រ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ទេសនាចប់ហើយ*

ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតំ ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ : *ភុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ចក្កគឺធម៌នេះ ឥតមានចក្កឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណាទីមួយក្តី ក្នុងលោកសម្តែងពុំបានឡើយ មានតែព្រះមានព្រះភាគ ព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័នជិតក្រុងពារាណសី ។*

ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយក្នុងជាន់ចាតុម្ម-ហារាជិកៈ បានឮសំឡេងនៃភុម្មទេវតាទាំងឡាយហើយ ក៏ញ៉ាំងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)* ។

ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវត្តឹសា ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយ ក្នុងជាន់តាវត្តិង្ស បានឮសំឡេងនៃទេវតា ក្នុងជាន់ចាតុម្មហារាជិកៈហើយ ក៏ញ៉ាំងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)* ។

តាវត្តឹសានំ ទេវានំ សទ្ទំ សុត្វា យាមា ទេវា សទ្ទមនុស្សាវេសុំ : *ទេវតាទាំងឡាយក្នុងជាន់យាមា បានឮសំឡេងនៃទេវតាជាន់តាវត្តិង្សហើយ ក៏ញ៉ាំងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)* ។

យាមានំ ទេវានំ សទ្ទំ សុត្វា តុសិតា ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយក្នុងជាន់តុសិត បានឮសំឡេង*

*នៃទេវតាក្នុងជាន់យាមាហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា)* ។

តុសិតានំ ទេវានំ សទ្ទំ សុត្វា និម្មានរតី ទេវា សទ្ទមនុស្សាវេសុំ ៖ *ទេវតាទាំងឡាយក្នុងជាន់និម្មានរតី បានឮសំឡេងនៃទេវតាក្នុងជាន់តុសិតហើយ ក៏ញុំាងសំឡេង ឲ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា)* ។

និម្មានរតីនំ ទេវានំ សទ្ទំ សុត្វា បរនិម្មិតវសវត្តី ទេវា សទ្ទមនុស្សាវេសុំ ៖ *ទេវតាទាំងឡាយ ក្នុងជាន់បរនិម្មិតវសវត្តី បានឮសំឡេងនៃទេវតាក្នុងជាន់និម្មានរតីហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើង (ដោយសេចក្ដីសរសើរដូចគ្នា)* ។

បរនិម្មិតវសវត្តីនំ ទេវានំ សទ្ទំ សុត្វា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ ។ "ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា

លោកស្មិន្តិ : *ទេវតាទាំងឡាយក្នុងពួកព្រហ្ម បានឮសំឡេងនៃទេវតាក្នុងជាន់បរនិម្មិតវសវត្តីហើយ ក៏ញុំាងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ចក្កគឺធម៌នេះ ឥតមានចក្កឯណាមួយក្រៃលែងជាងគឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តី ក្នុងលោកសម្តែងពុំបានឡើយ មានតែព្រះមានព្រះភាគព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។*

ឥតិហ តេន ខណេន[១] តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ : *សំឡេងសាធុការលាន់ឮឡើងទៅដរាបដល់ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយអាការលាន់ឮតៗគ្នា ដូច្នេះ ។*

អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ : *ទាំងម៉ឺនលោកធាតុនេះ ក៏កក្រើកញាប់ញ័រទាំងខាងលើទាំងខាងក្រោម និងញាប់ញ័រក្នុងទិសទាំងពួង*

១- ឥតោ បរំ ឱ. ម. បោត្ថកេសុ តេន លយេនាតិ អត្ថិ ។

អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុរហោសិ អតិក្កម្ម ទេវានំ ទេវានុភាវំ[១] : *ទាំងរស្មីដ៏រុងរឿងក្រៃពេក នឹងប្រមាណមិនបាន កន្លងលើសទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតឡើងប្រាកដក្នុងលោក ។*

អថ ខោ ភគវា ឧទានំ[២] ឧទានេសិ "អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ"តិ : *លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បន្លឺនូវឧទានវាចាថា ឱ ! កោណ្ឌញ្ញៈបានចេះដឹងហើយហ្ន៎ ឱ ! កោណ្ឌញ្ញៈបានចេះដឹងហើយហ្ន៎ ។*

ឥតិហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញា-កោណ្ឌញ្ញោ ត្វេវ នាមំ អហោសីតិ : *ព្រោះហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញៈនេះឯង បានមកជាឈ្មោះនៃព្រះកោណ្ឌញ្ញៈដ៏មានអាយុ ។*

*ព្រះធម្មចក្កប្បវត្តនសូត្រ ចប់ ។* ៚

---

១ យេភុយ្យេន ឥតិសទ្ទោ បក្ខិត្តោ ។ សោ សមាបន្នោ ទដ្ឋព្វោ ។ ២ ឱ. ម. ឥមំ ឧទានំ ។

## ញាណទស្សនៈមានបរិវដ្ដៈ ៣ អាការៈ ១២

ញាណទស្សនៈ(ការដឹងការឃើញ) តាមពិត មានបរិវដ្ដៈ ៣ អាការៈ ១២ យ៉ាងនេះ ក្នុងអរិយសច្ចទាំងឡាយ ៤ ... ។

**សច្ចញ្ញាណ** : សេចក្ដីដឹងតាមពិតក្នុងសច្ចទាំង ៤ យ៉ាងនេះថា នេះទុក្ខអរិយសច្ច នេះទុក្ខសមុទយអរិយសច្ច នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ឈ្មោះថា សច្ចញ្ញាណ ។

**កិច្ចញ្ញាណ** : ញាណ គឺសេចក្ដីដឹងកិច្ចដែលគួរធ្វើ យ៉ាងនេះថា គួរកំណត់ដឹង គួរលះ គួរធ្វើឲ្យជាក់ច្បាស់ គួរចម្រើន ឈ្មោះថា កិច្ចញ្ញាណ ។

**កតញ្ញាណ** : ញាណ គឺការដឹងសេចក្ដីដែលសច្ចៈនោះបានធ្វើហើយ យ៉ាងនេះថា បានកំណត់ដឹងហើយ បានលះហើយ បានធ្វើឲ្យជាក់ច្បាស់ហើយ បានចម្រើនហើយ ឈ្មោះថា កតញ្ញាណ ។

បទថា ទ្វាទសាការំ ប្រែថា មានអាការៈ ១២ គឺ អាការក្នុងសច្ចៈតែម្យ៉ាងៗ អាការៈមួយៗ មាន ៣ ទាំងនោះឯង ។

*បទថា ញាណទស្សនំ បានដល់ ការឃើញ ពោលគឺ ញាណដែលកើតឡើងដោយអំណាចជុំវិញទាំង ៣ អាការៈ ១២ ទាំងនេះ ។ (សារត្ថទីបនីដីកា ភាគ៣; អដ្ឋកថា សារត្ថបកាសិនី)*

## ពាក្យថាធម្មចក្ក

ធម្មចក្កេតិ បដិវេធញាណញ្ច ទេសនាញា-

ណញ្ច បវត្តនដ្ឋេន ចក្កន្តិ ធម្មចក្កំ ៖

*ពាក្យថា **ធម្មចក្ក** អធិប្បាយថា បដិវេធញាណ និង ទេសនាញាណ ឈ្មោះថា ជាចក្ក ព្រោះអត្ថថា ឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មចក្ក** ។*

*ពិតមែន សូម្បីបដិវេធញាណ ដែលមានអាការៈ ១២ ដែលកើតឡើងក្នុងសច្ចទាំង ៤ ដល់ព្រះមានព្រះភាគ ដែលទ្រង់គង់នៅលើពោធិបល្ល័ង្ក សូម្បីទេសនាញាណដែលប្រព្រឹត្តទៅដោយការសម្តែងសច្ចទេសនា ដែលមានអាការៈ ១២ របស់ព្រះ-មានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនៈ ក៏ឈ្មោះថា **ធម្មចក្ក** ។*

ក៏ញាណទាំង ២ នេះ ជាញាណដែលប្រព្រឹត្តទៅក្នុងព្រះហឫទ័យរបស់ព្រះទសពលនោះតែម្តង ។

ព្រះមានព្រះភាគ ទ្រង់ប្រកាសញាណទាំង ២ នោះ ដោយទេសនានេះ ឈ្មោះថា ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅហើយ ។ ក៏ធម្មចក្កនេះ ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់កំពុងឲ្យប្រព្រឹត្តទៅដរាបព្រះអញ្ញាកោណ្ឌញ្ញថេរៈ នៅមិនទាន់បានតាំងនៅក្នុងសោតាបត្តិផល ព្រមទាំងព្រហ្ម ១៨ កោដិ ព្រោះកិច្ច គឺការឲ្យប្រព្រឹត្តទៅនៅមិនទាន់សម្រេច កាលព្រះអញ្ញាកោណ្ឌញ្ញថេរៈតាំងនៅក្នុងសោតាបត្តិផលហើយ ទើបឈ្មោះថា ទ្រង់ឲ្យប្រព្រឹត្តទៅហើយ ព្រោះទ្រង់បានញ៉ាំងធម្មចក្ក ដែលនៅមិនទាន់ធ្លាប់ប្រព្រឹត្ត ឲ្យប្រព្រឹត្តទៅហើយ ចាប់ដើមតាំងអំពីសាសនាព្រះកស្សបសម្មាសម្ពុទ្ធអន្តរធានទៅ រហូតដល់ពុទ្ធុប្បាទកាល អស់កាលមានប្រមាណប៉ុណ្ណោះ ព្រះធម្មសង្គាហកាចារ្យសំដៅសេចក្តីនោះ ទើបបានពោលពាក្យមានជាដើមថា ក៏ឯព្រះមានព្រះភាគ ទ្រង់ប្រកាសធម្មចក្កឲ្យប្រព្រឹត្តទៅហើយ ពួកភុម្មទេវតាទាំងឡាយបានបន្លឺសំឡេងដូចនេះ ជាដើម ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **ពួកកុម្មទេវតា** បានដល់ពួកទេវតាដែលនៅលើផែនដី ។ ពាក្យថា **បានបន្លឺសំឡេង** សេចក្ដីថា បានឲ្យសាធុការដោយព្រមគ្នាតែម្ដង ពោលពាក្យជាដើមថា ធម្មចក្កនេះ ព្រះមានព្រះភាគ ទ្រង់ប្រកាសឲ្យប្រព្រឹត្តទៅហើយ ដូចនេះជាដើម ឲ្យបានឮតៗគ្នាទៅ ។ ពាក្យថា **ពន្លឺភ្លឺស្វាង** បានដល់ពន្លឺភ្លឺស្វាងដែលមានចិត្តជាបច្ច័យ មានឧតុជាសមុដ្ឋាន បានប្រព្រឹត្តទៅហើយ ដោយអានុភាពនៃព្រះសព្វញ្ញុតញ្ញាណ ។ ក៏ពន្លឺភ្លឺស្វាងនោះ រុងរឿងកន្លងនូវទេវានុភាពរបស់ទេវតាទាំងឡាយ ក្នុងកាលនោះឯង ។ សំឡេងបន្លឺព្រះឧទានសូម្បីនេះថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** បានផ្សាយទៅរហូត ១ ម៉ឺនលោកធាតុ ។ ពិតមែនព្រះបីតិសោមនស្សដ៏ឱឡារិកក្រៃលែង ដែលកើតឡើងប្រៀបមិនបាន បានកើតឡើងដល់ព្រះមានព្រះភាគ សូម្បីក្នុងវេលាចប់ ដូចក្នុងកាលចាប់ផ្ដើមប្រកាសព្រះធម្មចក្ក ។

(សារត្ថទីបនីដីកា ភាគ៣; អដ្ឋកថា សារត្ថបកាសិនី)


ឥសិបតនមិគទាយវ័ន កន្លែងព្រះអង្គសម្តែងធម្មចក្ក


ឥសិបតនមិគទាយវ័ន កន្លែងព្រះអង្គសម្តែងធម្មចក្ក

## ៣-ឧបសម្បទារបស់ព្រះអញ្ញាកោណ្ឌញ្ញៈ

*គ្រានោះ ព្រះអញ្ញាកោណ្ឌញ្ញៈដ៏មានអាយុ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានត្រាស់ដឹងអរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿង ឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនបាច់ជឿស្តាប់បុគ្គល ដទៃក្នុងសាសនានៃព្រះសាស្តា ទើបក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា* "លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទំ : *សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ"* ។

"ឯហិ ភិក្ខូតិ ភគវា អវោច ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយ : *ព្រះមានជោគ ទ្រង់ត្រាស់ហៅថា* ***អ្នកចូរមកជាភិក្ខុចុះ*** *ហើយមានព្រះពុទ្ធដីកាថា* ***សាសនធម៌តថាគតពោលល្អហើយ អ្នកចូរប្រព្រឹត្ត***

ព្រហ្មចរិយធម៌ ដើម្បីនឹងធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ ដោយប្រពៃចុះ ។

សា ច តស្ស អាយស្មតោ ឧបសម្បទា អហោសិ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់អញ្ញាកោណ្ឌញ្ញៈដ៏មានអាយុនោះ ។

បទថា សា ច តស្ស អាយស្មតោ ឧបសម្បទា អហោសិ បានសេចក្តីថា ថ្ងៃពេញបូណ៌មីខែអាសាឍ កាលព្រះអញ្ញាកោណ្ឌញ្ញៈដ៏មានអាយុ និងទេវតា ១៨ កោដិ តាំងនៅក្នុងសោតាបត្តិផលហើយ, ព្រះវាចានេះឯងដែលសម្រេចដោយព្រះពុទ្ធវចនៈរបស់ព្រះមានព្រះភាគថា "អ្នកចូរមកជាភិក្ខុចុះ" ដូច្នេះ បានជាឯហិភិក្ខុឧបសម្បទារបស់ (ព្រះអញ្ញាកោណ្ឌញ្ញៈ) ដ៏មានអាយុនោះ ។ (វិនយបិដក ៦, ៣៧ ; សមន្ត. ៣,១៨)

## ៤-បញ្ចវគ្គិយភិក្ខុត្រាស់ដឹងធម៌តាមលំដាប់

លំដាប់តទៅ ព្រះមានព្រះភាគ ទ្រង់ពោលទូន្មានប្រៀនប្រដៅភិក្ខុដ៏សេសក្រៅអំពីអញ្ញាកោណ្ឌញ្ញៈភិក្ខុនោះ ដោយធម្មីកថា ។

- ថ្ងៃ ១ រោច ធម្មចក្ខុ ភ្នែកឃើញធម៌ បានកើតឡើង ដល់ព្រះវប្បត្ថេរ

- ក្នុងថ្ងៃ ២ រោច បានកើតឡើងដល់ព្រះភទ្ទិយត្ថេរ

- ក្នុងថ្ងៃ ៣ រោច បានកើតឡើងដល់ព្រះមហានាមត្ថេរ

- ក្នុងថ្ងៃ ៤ រោច បានកើតឡើងដល់ព្រះអស្សជិត្ថេរ

☆ ក្នុងថ្ងៃទី ៥ រោច ព្រះអង្គឲ្យភិក្ខុទាំងអស់ប្រជុំព្រមគ្នា ហើយត្រាស់ទូន្មានដោយអនត្តលក្ខណសូត្រ ព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ។ បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មាន ចិត្តត្រេកអររីករាយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។ ក៏កាល ដែលព្រះមានព្រះភាគជាម្ចាស់ កំពុងត្រាស់សម្តែងនូវវេយ្យាករណ៍ នេះ ចិត្តរបស់ភិក្ខុទាំង ៥ រូប បានរួចស្រឡះហើយ ចាកអាសវៈ ទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញ ថាយើង) ឡើយ ។

ក្នុងសម័យនោះឯង មានព្រះអរហន្ត ៦ អង្គក្នុងលោក ជាដំបូង (រាប់ទាំងព្រះមានព្រះភាគផង) ។

(វិនយបិដក ៦, ៤៧ ; សមន្ត. ៣, ១៨)

ក៏ពាក្យនេះ ព្រះធម្មសង្គាហកាចារ្យ ពោលសំដៅដល់ព្រះអរហន្តដែលជាមនុស្សប៉ុណ្ណោះ ព្រោះការសម្រេចអរហត្តផលសម្បីរបស់ទេវតានិងព្រហ្មដទៃទៀត ក៏មាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ព្រះអរហន្តដែលជាមនុស្ស ៦ អង្គ ។

(សារត្ថ. ភាគ៣ ទំព័រ២៣២)

## ៥_អនត្តលក្ខណសូត្រ

ឯវម្មេ សុតំ សូត្រនេះ (ឈ្មោះអនត្តលក្ខណសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្ដាប់មកហើយយ៉ាងនេះថា

ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។

តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុទាំងឡាយក្នុងទីនោះឯង (ឲ្យតាំងចិត្តស្ដាប់នូវភាសិតនេះថា)

រូបំ ភិក្ខវេ អនត្តា ម្នាលភិក្ខុទាំងឡាយ រូប គឺ

រាងកាយជាអនត្តា មិនមែនជារបស់ខ្លួនឡើយ ។

រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើរូបនេះ ជារបស់ខ្លួនពិតមែន

ន យិទំ រូបំ អាពាធាយ សំវត្តេយ្យ រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជម្ងឺដំកាត់ឡើយ

លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ : ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងរូបថា សូមឲ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឲ្យរូបរបស់អញយ៉ាងនេះឡើយ ។

យស្មា ច ខោ ភិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តាពិតមែន ព្រោះហេតុនោះ បានជារូបចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។

ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងរូបថាសូមឲ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឲ្យរូបរបស់អញ

*យ៉ាងនេះឡើយ ។*

វេទនា អនត្តា *វេទនាមិនមែនជារបស់ខ្លួនឡើយ*

វេទនា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវេទនានេះ ជារបស់ខ្លួនពិតមែន*

ន យិទំ វេទនា អាពាធាយ សំវត្តេយ្យ *វេទនានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ ។*

លព្ភេថ ច វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវេទនាថា សូមឲ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឲ្យវេទនារបស់អញយ៉ាងនេះឡើយ ។*

យស្មា ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពាធាយ សំវត្តតិ : *ម្នាលភិក្ខុទាំងឡាយ វេទនាជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវេទនាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ ។*

ន ច លព្ភតិ វេទនាយ ឯវំ មេ វេទនា ហោតុ

ឯវំ មេ វេទនា មា អហោសីតិ ម្យ៉ាងទៀត បុគ្គល មិនបាន(នូវអំណាច) ក្នុងវេទនាថា សូមឲ្យវេទនារបស់អញយ៉ាង នេះទៅ សូមកុំឲ្យវេទនារបស់អញយ៉ាងនេះឡើយ ។

សញ្ញា អនត្តា សញ្ញាមិនមែនជារបស់ខ្លួនឡើយ

សញ្ញា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស ម្នាលភិក្ខុ ទាំងឡាយ ប្រសិនណាបើសញ្ញានេះ ជារបស់ខ្លួនពិតមែន

ន យិទំ សញ្ញា អាពាធាយ សំវត្តេយ្យ សញ្ញានេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ

លព្ភេថ ច សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឲ្យសញ្ញារបស់អញយ៉ាងនេះឡើយ

យស្មា ច ខោ ភិក្ខវេ សញ្ញា អនត្តា តស្មា សញ្ញា អាពាធាយ សំវត្តតិ ម្នាលភិក្ខុទាំងឡាយ សញ្ញាជា អនត្តាពិតមែន ព្រោះហេតុនោះ បានជាសញ្ញាចេះតែប្រព្រឹត្តទៅ

ដើម្បីអាពាធ

ន ច លព្ភតិ សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឲ្យសញ្ញារបស់អញយ៉ាងនេះឡើយ ។*

សង្ខារា អនត្តា *សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួនឡើយ*

សង្ខារា ច ហិទំ ភិក្ខវេ អត្តា អភវិស្សំសុ *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសង្ខារទាំងឡាយនេះ ជារបស់ខ្លួនពិតមែន*

ន យិទំ សង្ខារា អាពាធាយ សំវត្តេយ្យុំ *សង្ខារទាំងឡាយនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ*

លព្ភេថ ច សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ : *ម្យ៉ាងទៀត បុគ្គលគប្បីបាន(នូវអំណាច)ក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខាររបស់អញ*

*យ៉ាងនេះទៅ សូមកុំឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ ភិក្ខវេ សង្ខារា អនត្តា តស្មា សង្ខារា អាពាធាយ សំវត្តន្តិ : *ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ ជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាសង្ខារទាំងឡាយ ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ*

ន ច លព្ភតិ សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឲ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ ។*

វិញ្ញាណំ អនត្តា *វិញ្ញាណមិនមែនជារបស់ខ្លួនឡើយ*

វិញ្ញាណញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវិញ្ញាណនេះ ជារបស់ខ្លួនពិតមែន*

ន យិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ

*វិញ្ញាណនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ*

លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ : *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឲ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ អាពាធាយ សំវត្តតិ : *ម្នាលភិក្ខុទាំងឡាយ វិញ្ញាណជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវិញ្ញាណចេះតែប្រព្រឹត្តទៅដើម្បីអាពាធ*

ន ច លព្ភតិ វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ, ឯវំ មេ វិញ្ញាណំ មា អហោសីតិ : *ម្យ៉ាងទៀត បុគ្គលមិនបាន(នូវអំណាច) ក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឲ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ ។*

**តំ កឹ មញ្ញថ** ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច រូបទៀង ឬមិនទៀង ?

អនិច្ចំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន រូបមិនទៀងទេ

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

ទុក្ខំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ,

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ : ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

នោ ហេតំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

តំ កឹ មញ្ញថ ភិក្ខវេ វេទនា និច្ចា វា អនិច្ចា វាតិ : ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តី

នោះជាដូចម្តេច វេទនាទៀង ឬមិនទៀង ?

អនិច្ចា ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន វេទនាមិនទៀងទេ,

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ : របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

ទុក្ខំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើនរបស់នោះជាទុក្ខ

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

នោ ហេតំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនោះទេ ។

តំ កឹ មញ្ញថ ភិក្ខវេ សញ្ញា និច្ចា វា អនិច្ចា វាតិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច សញ្ញាទៀង ឬមិនទៀង ?

អនិច្ចា ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាមិនទៀងទេ*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?*

ទុក្ខំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?*

នោ ហេតំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។*

តំ កឹ មញ្ញថ ភិក្ខវេ សង្ខារា និច្ចា វា អនិច្ចា វាតិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច សង្ខារទាំងឡាយទៀង ឬមិនទៀង ?*

អនិច្ចា ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន សង្ខារទាំងឡាយមិនទៀងទេ ។*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?*

ទុក្ខំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬ ដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?*

នោ ហេតំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។*

តំ កឹ មញ្ញថ ភិក្ខវេ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះជាដូចម្តេច វិញ្ញាណទៀង ឬមិនទៀង ?*

អនិច្ចំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណមិនទៀងទេ

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ក៏របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?

ទុក្ខំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ក៏របស់ឯណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?

នោ ហេតំ ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។

**តស្មាតិហ** ភិក្ខវេ យំ កិញ្ចិ រូបំ អតីតា-នាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ : ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូប

ឯណាមួយដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ ក៏គ្រាន់តែជារូប (ប៉ុណ្ណោះឯង) ។

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ អ្នកទាំងឡាយគួរឃើញនូវសេចក្តីនោះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។

យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា វេទនា វេទនាឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី

*ជោកទាបក្តី ឧត្តមក្តី វេទនាឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វេទនាទាំងអស់នោះ ក៏គ្រាន់តែជាវេទនា (ប៉ុណ្ណោះឯង)* ។

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ *អ្នកទាំងឡាយគួរឃើញនូវសេចក្តីនោះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះ ដូច្នេះថានុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ* ។

យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា សញ្ញា *សញ្ញាឯណាមួយដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោក-ទាបក្តី ឧត្តមក្តី សញ្ញាឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សញ្ញាទាំងអស់នោះ ក៏គ្រាន់តែជាសញ្ញា (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ

ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ *អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។*

យេ កេចិ សង្ខារា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា សព្វេ សង្ខារា *សង្ខារទាំងឡាយឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី សង្ខារទាំងឡាយទាំងអស់នោះ ក៏គ្រាន់តែជាសង្ខារ (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ *អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះ*

*ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។*

យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ *វិញ្ញាណឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ ក៏គ្រាន់តែជាវិញ្ញាណ (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ *អ្នកទាំងឡាយគួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។*

**ឯវំ បស្សំ** ភិក្ខវេ សុតវា អរិយសាវកោ

រូបស្មិម្បិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ *ម្នាលភិក្ខុទាំងឡាយ អរិយសាវកបានស្ដាប់ហើយ យល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង*

និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ *កាលបើនឿយណាយ (យ៉ាងនេះហើយ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះកិរិយាប្រាសចាកតម្រេក*

វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ *កាលដែលចិត្តផុតស្រឡះ (ចាកអាសវៈ)ហើយ ញាណ(របស់អរិយសាវកនោះ) ក៏កើតឡើងប្រាកដថា ចិត្ត (របស់អញ) ផុតស្រឡះ (ចាកអាសវៈ)ហើយ*

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ *(អរិយសាវកនោះ) ក៏*

ដឹងច្បាស់ដូច្នេះថា ជាតិ (របស់អញ) អស់ហើយ មគ្គព្រហ្ម-
ចរិយធម៌ អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើ
រួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន(ដល់អញ)ឡើយ ។

ឥទមវោច ភគវា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បាន
ត្រាស់សម្តែងនូវព្រះសូត្រនេះចប់ហើយ

អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ
អភិនន្ទុំ បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអររីករាយ
ចំពោះភាសិតនៃព្រះមានព្រះភាគជាម្ចាស់ ។

ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ
បញ្ចវគ្គិយានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ
វិមុច្ចឹសូតិ ក៏កាលដែលព្រះមានព្រះភាគជាម្ចាស់ កំពុងត្រាស់
សម្តែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ៥ រូប បានរួច
ស្រឡះហើយ ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថា
អញ ថាយើងទៀតឡើយ) ។

អនត្តលក្ខណសូត្រ ចប់ ។

## ឈ្មោះថាជាអនត្តា ដោយហេតុ ៤ យ៉ាង

១-អវសវត្តនដ្ឋេន ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច

២-អសាមិកដ្ឋេន ដោយអត្ថថា មិនជាម្ចាស់

៣-សុញ្ញតដ្ឋេន ដោយអត្ថថា ជារបស់សោះសូន្យទទេ

៤-អត្តបដិក្ខេបដ្ឋេន ដោយអត្ថថា បដិសេធអត្តា ។

បណ្តាហេតុ ៤ យ៉ាងនោះ អ្នកណាៗ ក៏ជាអ្នកមិនមានអំណាចក្នុងរូបនេះថា សូមរូបដែលកើតឡើងហើយ ចូរដល់ការតាំងនៅ សូមរូបដែលដល់ការតាំងនៅ ចូរកុំចាស់ សូមរូបដែលដល់ការចាស់ហើយ ចូរកុំបែកធ្លាយ សូមកុំលំបាកដោយការកើតឡើង និងការសូន្យទៅឡើយ ។ សេចក្តីនេះជាអត្ថថា មិននៅក្នុងអំណាចរបស់រូបនោះ ។ សេចក្តីមិនមានអ្នកណាៗ ជាម្ចាស់ដោយអត្ថថា មិនមានម្ចាស់ ។ សេចក្តីដែលរូបនោះសោះសូន្យទទេ ចាកភាវៈនោះ ដោយវៀរចាកអ្នកនៅអាស្រ័យ អ្នកកសាងអ្នកគ្រប់គ្រង ឈ្មោះថាអត្ថថា សោះសូន្យទទេ ។ ភាពមិនមាន

*សភាវៈដែលជាអត្តា ដែលពួកលទ្ធិដទៃគិតទុកជាមុន ឬគិតទុកហើយនោះឯង ឈ្មោះថា អត្តថា* ***បដិសេធអត្តា*** *។*

*ឥឡូវនេះ ដើម្បីនឹងញ៉ាំងភាពជាអនត្តានោះឯងឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា* ***រូបញ្ច ហិទំ ភិក្ខវេ*** *ដូច្នេះជាដើម ។ បណ្តាពាក្យទាំងនោះ ពីរបទថា* ***អត្តា អភវិស្ស*** *អធិប្បាយថា នឹងបានជាអត្តា យ៉ាងនេះថា អ្នកសាង អ្នកសោយ អ្នកមានអំណាចខ្លួនឯង ។ ព្រោះកាលជាយ៉ាងនេះ ការញ៉ាំងអាពាធឲ្យប្រព្រឹត្តទៅដល់រូប ក៏នឹងគប្បីជាការមិនសមគួរ ក៏ក្នុងសេចក្តីនេះ ព្រោះហេតុដែលរូបជាអនត្តា ដោយព្រះពុទ្ធវចនៈថា "ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះរូបជាអនត្តា ដូច្នេះ រូបទើបប្រព្រឹត្តទៅដើម្បីអាពាធដូច្នេះ ។ ភាវៈដែលរូបជាទុក្ខ ក៏ប្រាកដដូចធ្វើឲ្យជាក់ច្បាស់ហើយ ក៏ពិតមែន សូម្បីយ៉ាងនោះ ភាពមិនមានសារៈ គឺអត្តានៃរូប ព្រះមានព្រះភាគ ក៏ទ្រង់បានធ្វើឲ្យជាក់ច្បាស់ហើយ ដោយសេចក្តីដែលរូបជារបស់អាពាធ ដែលប្រាកដថា ព្រោះរូបប្រព្រឹត្តទៅដើម្បីអាពាធ ដូច្នោះ រូបទើបជាអនត្តា ។ ក៏ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទ្រង់បានសម្តែងសេចក្តីដែលអ្នកណាៗ*

មិនប្រព្រឹត្តទៅក្នុងរូប និងអាការដែលរូបនោះ មិនធ្លាក់ចុះនៅក្នុងអំណាចថា ក៏អ្នកណាៗ រមែងមិនបានអំណាចក្នុងរូបថា សូមឲ្យរូបរបស់អញចូរជាយ៉ាងនេះ សូមកុំឲ្យរូបរបស់អញយ៉ាងនេះឡើយ ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យយ៉ាងនេះឯង ។

ព្រះពុទ្ធវចនៈនេះថា តំ កឹ មញ្ញថ ភិក្ខវេ នេះ ព្រះមានព្រះភាគ ទ្រង់ផ្ដើមទុក ព្រោះហេតុអ្វី ? ព្រះអង្គបានត្រាស់អនត្តលក្ខណៈម្យ៉ាង ដោយហានត្រឹមប៉ុណ្ណោះ មិនបានត្រាស់អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈជាដើម ។

ឥឡូវនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ប្រាថ្នានឹងសម្ដែងរួបរួមអនិច្ចលក្ខណៈ និង ទុក្ខលក្ខណៈទាំងនោះ ហើយទ្រង់សម្ដែងលក្ខណៈទាំង ៣ ។ ទើបទ្រង់បានផ្ដើមពាក្យនេះ ។

ពីរបទថា អនិច្ចំ ភន្តេ សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះរូបមានហើយ ត្រឡប់ជាមិនមាន ដូច្នោះ ទើបឈ្មោះថា មិនទៀង ។

ព្រោះមិនមានមក(ពី)មុន មានឡើង កើតឡើងដោយការប្រជុំរបស់បច្ច័យហើយ ត្រឡប់មិនមាន ដោយការចូលដល់ការ

បែកធ្លាយដូច្នេះ ទើបមិនទៀង ហេតុនោះ ទើបឈ្មោះថា អនិច្ចំ ប្រែថា មិនទៀង អធិប្បាយថា មិនយូរយា ។

###ម្យ៉ាងទៀត មិនទៀងដោយហេតុសូម្បីទាំង៤នេះគឺ

១-ឧប្បាទវយវន្តតាយ ព្រោះមានការកើតឡើង និងការសាបសូន្យទៅជាទីបំផុត ។

២-តាវកាលិកតាយ ព្រោះជារបស់បណ្តោះអាសន្ន

៣-វិបរិណាមកោដិយា ព្រោះមានការប្រែប្រួលជាទីបំផុត,

៤-និច្ចប្បដិក្ខេបតោ ព្រោះជំទាស់ចំពោះសេចក្តីទៀង ។

ក៏បណ្តាហេតុទាំង ៤ យ៉ាងនេះ ដែលឈ្មោះថា ភាវៈដែលរូបមានការកើត និងការសូន្យទៅជាទីបំផុត, ព្រោះប្រព្រឹត្តទៅដោយអំណាចការកើតឡើង និង ដោយអំណាចការរលត់ទៅគ្រប់ៗខណៈ ។ សេចក្តីជារបស់បណ្តោះអាសន្ន ឬមួយរំពេចៗ ព្រោះជារបស់មាននៅក្នុងខណៈនោះ ។ ដែលឈ្មោះថា មាន

សេចក្តីប្រែប្រួលជាទីបំផុត ព្រោះភាវៈជារបស់មានការប្រែប្រួល ។ ពិតមែន រូបកាលប្រែប្រួលទៅដោយការដល់នូវភាពវិការ មានការកើតឡើងជាដើម រមែងដល់សេចក្តីវិនាស ។ សេចក្តីដែលរូបមិនមានសភាពដែលទៀងនោះឯង ឈ្មោះថា ការបដិសេធសេចក្តីទៀង ។ ពិតមែន ធម៌ទាំងឡាយដែលមិនទៀង ឈ្មោះថា រមែងបដិសេធភាពជាសភាពទៀង ដោយអត្ថថា ព្រោះភាវៈដែលខ្លួនជាសភាពមិនទៀងនោះៗឯង ។

ពីរបទថា ទុក្ខំ ភន្តេ សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើនជាទុក្ខ ដោយអាការៈ គឺការបៀតបៀន ។ ពិតមែន ទុក្ខរមែងបៀតបៀន ជានិច្ចដល់រូប ដោយអំណាចការកើត ការចាស់ និងការបែកធ្លាយ ព្រោះហេតុនោះ ការដែលរូបនោះ ជាទុក្ខក៏ដោយអាការៈដែលបៀតបៀន ។

###ម្យ៉ាងទៀតឈ្មោះថាទុក្ខដោយហេតុ ៤ យ៉ាងគឺ

១–សន្តាបដ្ឋេន ដោយអត្ថថា ជារបស់ក្តៅក្រហាយ

២–ទុក្ខមដ្ឋេន ដោយអត្ថថា ទ្រាំបានដោយលំបាក

៣-ទុក្ខវត្ថុកដ្ឋេន *ដោយអត្ថថា ជាទីតាំងនៃទុក្ខ*

៤-សុខបដិក្ខេបដ្ឋេន *ដោយអត្ថថា បដិសេធសេចក្តីសុខ ។*

*ក៏បណ្តាហេតុទាំង ៤ យ៉ាងនេះ ដែលឈ្មោះថា សេចក្តីក្តៅក្រហាយ បានដល់ ការដុតរោល គឺសេចក្តីក្តៅក្រហាយ ដោយអំណាចភាវៈជាទុក្ខពិតៗ ជាដើម ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា ទ្រាំបានដោយលំបាក ។ ឈ្មោះថា ជាទីតាំងនៃទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ៣ យ៉ាង និងនៃសង្ខារទុក្ខ ។*

*ភាវៈមិនមានទូវសភាពដែលជាសុខនោះឯង ឈ្មោះថា ការបដិសេធសេចក្តីសុខ ។*

*បទថា វិបរិណាមធម្មំ សេចក្តីថា មានសភាពប្រែប្រួលដោយការចាស់និងការស្លាប់ ។*

*ការប្រកាន់ គឺតណ្ហាថា* **ឯតំ មម** *ទុ៎ះរបស់អញ ព្រោះភាវៈជា* **មមង្ការ** *។ ការប្រកាន់គឺមានះថា* **ឯសោហមស្មិ** *ទុ៎ះជាអញ ព្រោះភាវៈជា* **អហង្ការ** *។ ការប្រកាន់គឺទិដ្ឋិ ថា* **ឯសោ មេ អត្តា** *ទុ៎ះជាខ្លួនរបស់អញ ព្រោះភាវៈប្រកាន់វិបល្លាសថាជាតួខ្លួន ។*

ក៏ក្នុងការប្រកាន់ទាំង ៣ នេះ ការប្រកាន់គឺតណ្ហា គប្បីជ្រាបដោយអំណាចតណ្ហាវិចរិត ១០៨ ប្រការ, ការប្រកាន់គឺមានះ គប្បីជ្រាបដោយអំណាចមានះ ៩ យ៉ាង, ការប្រកាន់គឺទិដ្ឋិ គប្បីជ្រាបដោយអំណាចទិដ្ឋិ ៦២ ។ មានអធិប្បាយថា គួរឬហ្ន៎ ដើម្បីនឹងពិចារណាឃើញរូបនោះ ដោយអំណាចសេចក្ដីប្រកាន់ តណ្ហា មានះ និងទិដ្ឋិទាំង ៣ ពួកនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងអនត្តលក្ខណៈនោះឯង ដោយអំណាចការមិនទៀង និងការៈជាទុក្ខ ដោយប្រការដូច្នេះ ។

ពិតមែន ក្នុងទីកន្លែងខ្លះ ព្រះមានព្រះភាគ ទ្រង់សម្ដែងការៈជាអនត្តា ដោយអំណាចការមិនទៀង ត្រង់ទីកន្លែងខ្លះ ទ្រង់សម្ដែងដោយអំណាចការៈជាទុក្ខ ត្រង់ទីកន្លែងខ្លះ ទ្រង់សម្ដែងដោយអំណាចទាំងពីរយ៉ាង ។ ពិតយ៉ាងនោះ ព្រះមានព្រះភាគទ្រង់សម្ដែងការៈដែលរូបជាអនត្តា ដោយអំណាចជារបស់មិនទៀង ។

ទ្រង់សម្ដែងដោយរូបជាអនត្តា ដោយអំណាចការមិនទៀង និងភាពជាទុក្ខ ទាំងពីរយ៉ាង ក្នុងអរហន្តសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ

របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះក៏គួរឃើញដោយបញ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះថា ទុំះមិនមែនរបស់អញ ទុំះមិនមែនជាអញ ទុំះមិនមែនជាខ្លួនរបស់អញឡើយ” ដូច្នេះ ។

ព្រោះហេតុអ្វី ? ព្រោះរបស់ដែលមិនទៀង និងជាទុក្ខជាក់ច្បាស់ របស់ដែលជាអនត្តា មិនជាក់ច្បាស់ ។ ព្រោះថា កាលភាជនៈ គ្រឿងប្រើប្រាស់ជាដើម បែកហើយ មនុស្សទាំងឡាយតែងនិយាយថា ឱ ! មិនទៀង ។ តែអ្នកដែលពោលថា ឱ ! ជាអនត្តា ដូច្នេះមិនមាន ។ កាលកើតជម្ងឺ បូស ដំបៅកើតឡើងក្នុងរាងកាយ ឬត្រូវបន្ទាមុត តែងនិយាយថា ឱ ! ឈឺពិត តែនឹងរកអ្នកដែលនិយាយថា ឱ ! ជាអនត្តា ដូច្នេះ មិនមាន ។

ព្រោះហេតុអ្វី ? ព្រោះធម្មតាអនត្តលក្ខណៈនេះ មិនជាក់ច្បាស់ ឃើញបានលំបាក រកបញ្ញត្តិបានលំបាក ។ ពិតមែនសាស្តាទាំងឡាយ មានសរភង្គតាបសជាដើម ក៏មិនបានឃើញការបញ្ញត្តិនឹងមានមកពីណា ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបទ្រង់សម្តែងអនត្តលក្ខណៈ ដោយអំណាចការមិនទៀងខ្លះ

ដោយអំណាចភាពជាទុក្ខ ១ ដោយអំណាចទាំង ២ យ៉ាងចូលគ្នា ១ ។ អនត្តលក្ខណៈនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងស្ងួ្ប្បី ក្នុងអនត្តលក្ខណសូត្រនេះ ដែលមានជុំវិញ ៣ ដោយអំណាចការមិនទៀង និងភាពជាទុក្ខនោះឯង ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យនេះឯង ។

បទថា វុសិតំ សេចក្ដីថា នៅហើយ គឺអប់រំហើយ អធិប្បាយថា ធ្វើហើយ ប្រព្រឹត្តទៅហើយ សម្រេចហើយ ។ បទថា ព្រហ្មចរិយំ បានដល់ ព្រហ្មចរិយធម៌ គឺមគ្គ ។ ក៏សេក្ខបុគ្គលទាំង ៧ ពួក ព្រមទាំងកល្យាណបុថុជ្ជន ឈ្មោះថា កំពុងប្រព្រឹត្តមគ្គព្រហ្មចរិយធម៌ ។ ព្រះខីណាស្រព ឈ្មោះថា មានការនៅព្រហ្មចរិយធម៌ចប់ហើយ ព្រោះហេតុនោះ អរិយសាវ័ក កាលពិចារណាឃើញការនៅចប់ព្រហ្មចរិយធម៌របស់ខ្លួន រមែងដឹងច្បាស់ថាព្រហ្មចរិយ យើងបាននៅចប់ហើយ ។ ពីរបទថា កតំ ករណីយំ សេចក្ដីថា កិច្ចទាំង ១៦ យ៉ាង គឺបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ច ដែលមគ្គទាំង ៤ ធ្វើឲ្យចប់ហើយក្នុងសច្ចៈទាំង ៤ ។ ពិតមែន បុគ្គលទាំងឡាយមាន

កល្យាណបុថុជ្ជនជាដើម ឈ្មោះថា រមែងធ្វើកិច្ចនោះៗ ព្រះខីណាស្រព ឈ្មោះថា មានកិច្ចដែលគួរធ្វើបានធ្វើស្រេចហើយ ព្រោះហេតុនោះ ព្រះអរិយសាវកកាលពិចារណាកិច្ចដែលគួរធ្វើរបស់ខ្លួន ឈ្មោះថា រមែងដឹងច្បាស់កិច្ចដែលគួរធ្វើ បានធ្វើស្រេចហើយ ព្រោះហេតុនោះ ព្រះអរិយសាវក កាលពិចារណាកិច្ចដែលគួរធ្វើរបស់ខ្លួន ឈ្មោះថា រមែងដឹងច្បាស់កិច្ចដែលគួរធ្វើ បានធ្វើហើយ ។

ពីរបទថា ឆាបរំ ឥត្ថត្តាយ សេចក្តីថា រមែងដឹងច្បាស់ថា ឥឡូវនេះកិច្ច គឺមគ្គភាវនាដើម្បីភាវៈជាយ៉ាងនេះ គឺដើម្បីភាវៈជាកិច្ច ១៦ យ៉ាងនេះ ឬដើម្បីការអស់កិលេស របស់យើងមិនមានទៀត ។

ម្យ៉ាងទៀត បទថា ឥត្ថត្តាយ សេចក្តីថា ខន្ធសន្តានដទៃក្រៅពីខន្ធសន្តានដែលប្រព្រឹត្តទៅនៅក្នុងឥឡូវនេះ ដែលមានភាវៈយ៉ាងនេះ គឺមានប្រការយ៉ាងនេះ នេះរបស់អញ មិនមាន ។ ក៏ខន្ធទាំង ៥ នេះ យើងបានកំណត់ដឹងហើយ រមែងតាំងនៅដូចដើមឈើដែលមានឫសដាច់ហើយ រមែងដឹងច្បាស់ថា ខន្ធទាំង ៥

នេះ នឹងរលត់ទៅដោយការរលត់នៃវិញ្ញាណចុងក្រោយ ដូចភ្លើងកើតឯង មិនមានពូជរលត់ទៅដូច្នោះ ។

ពាក្យថា អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ សេចក្តីថា មានចិត្តផុតស្រឡះហើយ ព្រោះមិនប្រកាន់មាំ គឺមិនប្រកាន់មាំ ដោយអាសវៈទាំងឡាយដែលរលត់ទៅ ដោយការរលត់ទៅដោយមិនកើតឡើង គឺព្រោះមិនប្រកាន់មាំនូវធម៌ណាៗ ថាអញ ថារបស់អញ ។

ពីរបទថា ឆ អរហន្តោ សេចក្តីថា មានព្រះអរហន្ត ៦ អង្គ រួមទាំងព្រះមានព្រះភាគ ។ ក៏ពាក្យនេះ ព្រះធម្មសង្គាហកាចារ្យ ពោលសំដៅដល់ព្រះអរហន្តដែលជាមនុស្សប៉ុណ្ណោះ ព្រោះការសម្រេចអរហត្តផល សូម្បីរបស់ទេវតា និងព្រហ្មដទៃទៀតក៏មាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ព្រះអរហន្តដែលជាមនុស្ស ៦ អង្គ ។ (ចាកសារត្ថទីបនីដីកា ៣ / ២៣២)

# ៦_នាឡកសូត្រ

*អសិតឥសី* សម្រាកនៅក្នុងទិវាវិហារ បានឃើញនូវពួកទេវតាជាន់តាវត្តិង្ស មានសេចក្ដីសោមនស្សរីករាយផង នូវសក្កទេវរាជ ជាធំជាងទេវតាផង នូវពួកទេវតាដែលស្លៀកសំពត់ស្អាតផង កាន់នូវសំពត់ហើយសរសើរក្រៃពេក ។ លុះឃើញទេវតា (ទាំងនោះ) មានចិត្តរីករាយ មានចិត្តខ្ពស់ឡើង ក៏ធ្វើនូវសេចក្ដីអើពើ សួរដូច្នេះថា ពួកទេវតាក្នុងជាន់តាវត្តិង្សនោះ មានសភាពរីករាយក្រៃពេក ព្រោះហេតុអ្វី អ្នកទាំងឡាយកាន់សំពត់ត្រេកអរ ព្រោះអាស្រ័យហេតុអ្វី ។ (អសិតឥសីដឹងថា) ក្នុងវេលាណា មានសង្គ្រាមជាមួយពួកអសុរ ជ័យជំនះមានដល់ពួកទេវតា ពួកអសុរបាញ់ ក្នុងវេលានោះ ពួកទេវតាក៏មិនមានការព្រឺរោមប្រាកដដូច្នោះឡើយ ពួកទេវតាត្រេកអររីករាយ ព្រោះឃើញនូវហេតុចំឡែកដូចម្ដេច ។ ពួកទេវតាហួចផង ច្រៀងផង ប្រគំផង ទះដៃទាំងសងខាងផង រាំផងថា នៃទេវតាទាំងឡាយ ជាបុគ្គលនិរទុក្ខ ខ្ញុំសួរអ្នកទាំងឡាយ ដែលនៅលើកំពូលភ្នំមេរុ គឺជាន់តាវត្តិង្ស (នេះ) សូមអ្នកទាំងឡាយ បន្ទោបង់សេចក្ដីសង្ស័យរបស់ខ្ញុំដោយ

ឆាប់ ។ (ពួកទេវតាតបថា) ពោធិសត្វនោះ ដូចជាកែវដ៏ប្រសើរ ឥតមានអ្វីទឹងផ្ទឹមបាន ទ្រង់កើតក្នុងព្រៃលុម្ពិនីវ័ន ក្នុងជនបទ ជាស្រុករបស់ពួកសក្យៈ ក្នុងមនុស្សលោក ដើម្បីជាប្រយោជន៍និងសេចក្ដីសុខ ព្រោះហេតុនោះ បានជាយើងខ្ញុំមានសេចក្ដីត្រេកអរ មានសភាពរីករាយក្រៃពេក ។ ពោធិសត្វនោះ ប្រសើរជាងសព្វសត្វ (ទេវតា និងមនុស្ស) ជាអគ្គបុគ្គល ជានរអង់អាច ឧត្ដម ជាងពួកសត្វទាំងអស់ អាចញុំាងចក្រឲ្យប្រព្រឹត្តទៅក្នុងព្រៃឥសិបតនមិគទាយវ័ន ដូចសត្វសីហៈ ជាសត្វមានកម្លាំងគ្របសង្កត់នូវពួកម្រឹគ បន្លឺសីហនាទដែរ ។ អសិតឥសីនោះ លុះឮសំឡេងនោះហើយ ទើបចុះមកដោយរួសរាន់ ចូលសំដៅទៅកាន់ព្រះដំណាក់របស់ព្រះបាទសុទ្ធោទនៈ ក្នុងកាលណោះ លុះអង្គុយនៅក្នុងព្រះដំណាក់ហើយ ក៏សួរពួកសក្យៈ ដូច្នេះថា ព្រះរាជកុមារនៅឯណា អាត្មាត្រូវការចង់ឃើញ ។ គ្រានោះ ពួកសក្យៈបង្ហាញព្រះរាជកុមារ ជារាជឱរសមានសម្បុររុងរឿង ដូចមាសត្រង់មុខបាវដែលជាងមាសអ្នកឈ្លាសវៃ ឲ្យដីហើយថ្មីៗ មានសម្បុរសដ៏រុងរឿងដោយសិរី មានសម្បុរមិនអន់ថយ ដល់អសិតឥសី ។ អសិតឥសី

លុះឃើញព្រះរាជកុមារ មានសម្បុររុងរឿងដូចអណ្តាតភ្លើង ដូចព្រះចន្ទ្រដ៏រុងរឿង ក្នុងកណ្តាលហ្វូងផ្កាយ ឋិតនៅឰដ៏អាកាសបរិសុទ្ធ ដូចព្រះអាទិត្យ ផុតអំពីពពក រុងរឿងក្នុងសរទៈរដូវ មានសេចក្តីរីករាយ បាននូវបីតិធំទូលាយ ។ ពួកទេវតាបាំងឆត្រមានឆ្អឹងច្រើន មានមណ្ឌលមួយពាន់ (សម្រេចពីមាសឆ្អិន) នាកណ្តាលអាកាស ចាមរទាំងឡាយមានដងជាវិការៈនៃមាស សំយុងចុះពួកទេវតាអ្នកកាន់ចាមរនិងឆត្រក៏មិនប្រាកដឡើង ។ ជដិល ជាឥសីឈ្មោះកណ្ហសិរី លុះឃើញព្រះរាជាកុមារមានរស្មីរុងរឿងដូចដុំមាស លើកម្រាលសំពត់បណ្ឌុកម្ពល ដែលពួកទេវតាបាំងស្វេតឆត្រលើព្រះសិរ្សហើយ ក៏មានចិត្តអណ្តែតខ្ពស់ឡើង មានចិត្តរីករាយហើយទទួលយក (ព្រះរាជកុមារនោះ) ។ តាបសនោះ ជាអ្នកត្រិះរិះរំពឹងនូវកាលជាអនាគត ជាអ្នកចេះចប់នូវមន្តសម្រាប់ស្គាល់នូវលក្ខណៈ លុះទទួលព្រះរាជកុមារដ៏ប្រសើររបស់ពួកសក្យៈហើយ មានចិត្តរីករាយ បញ្ចេញសំណើចថា ព្រះរាជកុមារនេះប្រសើរឧត្តមជាងពួកសត្វមានជើងពីរ គឺទេវតានិងមនុស្ស ។ លំដាប់នោះ កណ្ហសិរី រឭកឃើញដំណើររបស់ខ្លួន ក៏មានសភាព

មិនរីករាយ ទើបឃំសម្រក់ទឹកភ្នែកវិញ ពួកសក្យៈឃើញហើយ ក៏សួរឥសីដែលកំពុងយំថា សេចក្តីអន្តរាយនឹងមានដល់ព្រះរាជ-កុមារនៃយើងឬ ។ ឥសីលុះឃើញពួកសក្យៈមិនរីករាយហើយ ទើបពោលថា អាត្មាមិនបានរឭកនូវអំពើមិនមែនជាប្រយោជន៍ចំពោះព្រះរាជកុមារឡើយ មួយទៀត សេចក្តីអន្តរាយនឹងមិនមានដល់ព្រះរាជកុមារទេ ព្រះរាជកុមារនេះ មិនថោកថយឡើយ សូមអ្នកទាំងឡាយមានចិត្តរីករាយចុះ ។ ព្រះរាជកុមារនេះ នឹងបានត្រាស់ដឹងនូវសម្មោធិញ្ញាណដ៏ប្រសើរ ព្រះរាជកុមារនេះ ជាអ្នកឃើញនូវព្រះនិព្វានដ៏បរិសុទ្ធក្រៃលែង ព្រះរាជកុមារនេះ ជាអ្នកអនុគ្រោះនូវប្រយោជន៍ដល់ជនច្រើន នឹងញ៉ាំងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ ព្រហ្មចរិយៈ គឺសាសនារបស់ព្រះរាជកុមារនេះ នឹងសាយភាយទៅ ។ ឯអាយុរបស់អាត្មាមិនបានតាំងនៅយូរ ក្នុងមនុស្សនេះទេ កាលកិរិយារបស់អាត្មានឹងមានក្នុងរវាង(នេះ)ឯងអាត្មានឹងមិនបានស្តាប់ ធម៌របស់ព្រះរាជកុមារ អ្នកមានព្យាយាមមិនមានអ្នកណាស្មើឡើយ ។ ព្រោះហេតុនោះ បានជាអាត្មាស្តាយក្រោយ ព្រួយចិត្ត កើតទុក្ខ ។

តាបសអ្នកមានព្រហ្មចរិយធម៌នោះ ញុំាងបីតិដ៏ធំទូលាយឲ្យកើតឡើងដល់ពួកសក្យៈហើយ ក៏ចៀសចេញអំពីបរមរាជវាំងទៅ តាបសនោះ មានសេចក្តីអនុគ្រោះចំពោះក្មួយរបស់ខ្លួន ក៏បបួលឲ្យកាន់យកធម៌របស់មហាបុរស អ្នកមានព្យាយាម មិនមានអ្នកណាស្មើ ថាបើអ្នកបានឮសំឡេងថា **ពុទ្ធោ** អំពីសំណាក់បុគ្គលដទៃហើយ (ត្រូវដឹងថា) មហាបុរសដល់នូវការត្រាស់ដឹងហើយ បើកផ្លូវទៅកាន់ព្រះនិព្វានហើយ អ្នកគប្បីសាកសួរនូវលទ្ធិក្នុងសំណាក់នៃមហាបុរសនោះ ហើយប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគនោះចុះ ។ នាឡកកុមារនោះ ជាបុគ្គលមានបុណ្យសន្សំទុកហើយ ដែលឥសីនោះ មានចិត្តប្រកបដោយប្រយោជន៍មិនញាប់ញ័រ ឃើញថាព្រះនិព្វានបរិសុទ្ធក្រៃលែង ក្នុងអនាគត ប្រៀនប្រដៅហើយ ក៏នៅរង់ចាំព្រះជិនស្រី រក្សាសោតិន្ទ្រិយ បួសដោយភេទនៃខ្លួនជាតាបស ។ នាឡកតាបសលុះឮសំឡេងគឹកកង (ដែលទេវតាទាំងឡាយធ្វើហើយ) ក្នុងកាលដែលព្រះជិនស្រីញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ក៏ទៅ(កាន់ទីនោះ) លុះទៅដល់ហើយ ឃើញព្រះមានព្រះភាគ ដូចឥសី ក៏មានចិត្ត

ជ្រះថ្លា បានសាកសួរនូវមោនេយ្យវត្ត គឺមគ្គញ្ញាណដ៏ប្រសើរនឹងព្រះពុទ្ធជាមុនីវិសេស តាមពាក្យប្រៀនប្រដៅរបស់អសិតឥសីទូន្មានហើយ ។ (សុត្តន្តបិដក ៥៤ ទំព័រ២៣៥)

ចប់ វត្ថុកថា ។

សេចក្ដីក្នុងសូត្រនេះ នៅមានសេចក្ដីច្រើនទៀត តែក្នុងទីនេះ សូមពោលតែវត្ថុកថាប៉ុណ្ណោះ នឹងស្រង់យកសេចក្ដីអដ្ឋកថាដោយសង្ខេបតទៅ :

អដ្ឋកថា ៖

ព្រះសូត្រនេះ មានការកើតឡើងយ៉ាងណា ? មានរឿងដំណាលថា តាបសឈ្មោះថា **នាលកៈ** ជាក្មួយរបស់**អសិតឥសី** ឃើញសាវករបស់ព្រះមានព្រះភាគ ព្រះនាមថា **បទុមុត្តរៈ** បដិបត្តិមោនេយ្យបដិបទា (បដិបត្តិដើម្បីភាពជាមុនី) ទើបប្រាថ្នាជាយ៉ាងក្រៃលែងដែលនឹងបានជាយ៉ាងនោះ ចាប់ផ្ដើមតាំងអំពីនោះមក បានបំពេញបារមីមួយសែនកប្ប បានទូលសួរមោនេយ្យបដិបទាចំពោះព្រះមានព្រះភាគ ដោយគាថាពីរគាថា មានជាដើមថា **អញ្ញាតមេតំ** ខ្ញុំព្រះអង្គបានដឹងតាមពាក្យរបស់អសិតឥសី ដូច្នេះ ។ ក្នុងថ្ងៃទី ៧

អំពីថ្ងៃដែលព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅហើយ ។

ព្រះមានព្រះភាគ ទ្រង់ព្យាករណ៍មោនេយ្យបដិបទានោះដល់នាលកតាបសដោយន័យមានជាដើមថា **មោនេយ្យន្តេ ឧបញ្ញិស្សំ** យើងនឹងបញ្ញត្តបដិបទារបស់មុនីដល់លោកដូច្នេះ ។ កំកាលព្រះមានព្រះភាគ ស្តេចរំលត់ខន្ធបរិនិព្វានហើយ ព្រះអានន្ទដែលព្រះមហាកស្សប ធ្វើសង្គាយនា សួរមោនេយ្យបដិបទានោះប្រាប្ថានឹងសម្តែងធ្វើរឿងរ៉ាវទាំងអស់ ក្នុងខណៈដែលនាលកតាបសត្រូវទូលសួរព្រះមានព្រះភាគ ឲ្យប្រាកដ ទើបពោលវត្ថុគាថា ២០ គាថា មានជាដើមថា **អានន្ទជាតេ** ដូច្នេះ ។ លោកហៅរឿងសូម្បីទាំងអស់នោះថា **នាលកសូត្រ** ។

បទទាំងនោះមានសេចក្តីដូចតទៅនេះ សមណៈដឹងនូវធម៌នោះ ជាអ្នកសង្រួមខ្លួនហើយ យុំគ្រងចិត្តហើយ ដឹងពាក្យដែលមិននាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់សត្វទាំងឡាយ រមែងមិនពោលច្រើន សមណៈយ៉ាងនេះ រមែងគួរដល់ភាពជាមុនី មុនីនោះជាអ្នកបដិបត្តិដើម្បីភាពជាមុនី រមែងគួរដល់បដិបទារបស់មុនី

បានដល់មោនេយ្យបដិបទា ។ មិនមែនរមែងគួរតែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត មុនីនោះ គប្បីជ្រាបថា បានដល់ធម៌ជាគ្រឿងធ្វើឲ្យបាននូវភាពជាមុនី ដែលបានដល់អរហត្តមគ្គញាណ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ជាកំពូល គឺព្រះ-អរហត្ត ។

ព្រះនាលកត្ថេរ ក្រាស្តាប់ដូចនោះហើយ បានជាអ្នកមានសេចក្តីប្រាថ្នាតិចក្នុងឋាន ៣ គឺ ក្នុងការឃើញ ១ ក្នុងការស្តាប់ ១ ក្នុងការសាកសួរ ១ ព្រោះកាលចប់ទេសនា ព្រះនាលកត្ថេរនោះ មានចិត្តជ្រះថ្លាថ្វាយបង្គំព្រះមានព្រះភាគ ចូលទៅកាន់ព្រៃ មិនកើតសេចក្តីស្ទាក់ស្ទើរថា ធ្វើយ៉ាងណាល្អហ្ន៎ យើងនឹងគប្បីបានគាល់ព្រះមានព្រះភាគទៀត នេះគឺភាពជាអ្នកមានសេចក្តីប្រាថ្នាតិចក្នុងការឃើញរបស់ព្រះនាលកត្ថេរនោះ ។ មួយទៀត មិនកើតសេចក្តីស្ទាក់ស្ទើរថា ធ្វើយ៉ាងណាល្អហ្ន៎ យើងនឹងគប្បីបានស្តាប់ព្រះធម៌ទេសនាទៀត នេះគឺភាពជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងការស្តាប់របស់ព្រះនាលកត្ថេរនោះ ។ មួយទៀត មិនកើតសេចក្តីស្ទាក់ស្ទើរថា ធ្វើយ៉ាងណាល្អហ្ន៎ យើងនឹងគប្បីបានសាកសួរ

បដិបទាទៀត នេះគឺភាពជាអ្នកប្រាថ្នាតិច ក្នុងការសួររបស់ព្រះនាលកត្ថេរនោះ ។ ព្រះនាលកត្ថេរនោះ ជាអ្នកមានសេចក្ដីប្រាថ្នាតិច យ៉ាងនេះ ទើបចូលទៅកាន់ជើងភ្នំ មិននៅរហូតដល់អស់ពីរថ្ងៃ ក្នុងព្រៃស្រោងមួយកន្លែង មិនអង្គុយរហូតដល់អស់ពីរថ្ងៃ ក្នុងគល់ឈើមួយកន្លែង មិនចូលទៅបិណ្ឌបាតរហូតដល់អស់ពីរថ្ងៃ ក្នុងស្រុកមួយកន្លែង ។

ព្រះនាលកត្ថេរ ត្រាច់អំពីព្រៃកាន់ព្រៃ អំពីដើមឈើកាន់ដើមឈើ អំពីស្រុកកាន់ស្រុក បដិបត្តិបដិបទាដែលសមគួរ ហើយតាំងនៅក្នុងផលដ៏ប្រសើរ ។ ព្រោះភិក្ខុអ្នកបំពេញមោនេយ្យបដិបទាយ៉ាងឧក្រិដ្ឋ នឹងមានជីវិតនៅបាន ៧ ខែ ប៉ុណ្ណោះ បំពេញយ៉ាងកណ្ដាល នឹងមានជីវិតនៅបាន ៧ ឆ្នាំ បំពេញយ៉ាងខ្សោយ នឹងមានជីវិតនៅបាន ១៦ ឆ្នាំ ព្រះនាលកត្ថេរនេះ បំពេញយ៉ាងឧក្រិដ្ឋ ដូច្នោះនឹងនៅបាន ៧ ខែ ដឹងថា ខ្លួននឹងអស់អាយុ ទើបស្រង់ទឹក ស្លៀកសំពត់(ស្បង់) ចងកាយពន្ធ ដណ្ដប់សង្ឃាដីពីរជាន់ បែរមុខទៅផ្លូវព្រះទសពល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ផ្គងអញ្ជលីឈរផ្អែកភ្នំ**ហិង្គុលិកៈ** បរិនិព្វានដោយអនុ-

បាទិសេសនិព្វានធាតុ ។ ព្រះមានព្រះភាគ កាលទ្រង់ជ្រាបថា ព្រះនាលកត្ថេរបរិនិព្វានហើយ ទើបស្តេចទៅកាន់ភ្នំនោះ ព្រមដោយភិក្ខុសង្ឃ ធ្វើឈាបនកិច្ចឲ្យរក្សាព្រះធាតុទៅបញ្ចុះនៅចេតិយ ហើយស្តេចត្រឡប់វិញ ដោយប្រការដូច្នេះ ។

ចប់ អដ្ឋកថានាលកសូត្រ ដោយសង្ខេប
នៃអដ្ឋកថាខុទ្ទកនិកាយ ឈ្មោះបរមត្ថជោតិកា ។

## ៧-មោនេយ្យសូត្រ

នៅក្នុងសុត្តន្តបិដក តិកនិបាត ព្រះមានព្រះភាគ ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញនេះមាន ៣ យ៉ាង ។ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺភាពជាអ្នកប្រាជ្ញផ្លូវកាយ ១ ភាពជាអ្នកប្រាជ្ញផ្លូវវាចា ១ ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ១ ។

ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវកាយតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តិមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវ

កាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកបាជ្ជផ្ទវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្ទវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្ទវចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្ទវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញ មាន ៣ យ៉ាងប៉ុណ្ណេះ ។

អ្នកប្រាជ្ញទាំងឡាយ ពោលចំពោះបុគ្គលដែលជាអ្នកប្រាជ្ញ
ផ្ទវកាយ ផ្ទវវាចា ផ្ទវចិត្ត មិនមានអាសវៈ ជាអ្នកប្រាជ្ញ
បរិបូរណ៍ដោយភាពជាអ្នកប្រាជ្ញ ថាជាអ្នកមានបាបលះបង់
អស់ហើយ ។

## អដ្ឋកថាមោនេយ្យសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងមោនេយ្យសូត្រ ដូចតទៅនេះ ៖

ភាពជាមុនី ឈ្មោះថា មោនេយ្យៈ ។ ភាពជាមុនី គឺភាពជាសាធុជន បានដល់ ភាពជាបណ្ឌិតក្នុងកាយទ្វារ ឈ្មោះថា **កាយមោនេយ្យៈ** ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **ឥទំ វុច្ចតិ ភិក្ខវេ កាយមោនេយ្យំ** សេចក្ដីថា ពិតមែន ការលះកាយទុច្ចរិត ៣ យ៉ាងនេះ ឈ្មោះថា **កាយមោនេយ្យៈ** ។ មួយទៀត សូម្បីកាយសុចរិត ៣ យ៉ាង ក៏ឈ្មោះថា **កាយមោនេយ្យៈ** ។ ញាណដែលមានកាយជាអារម្មណ៍ ក៏ឈ្មោះថា **កាយមោនេយ្យៈ** ដូចគ្នា ។ ការកំណត់ដឹងកាយ ក៏ឈ្មោះថា **កាយមោនេយ្យៈ** ។ មគ្គដែលសហគតដោយបរិញ្ញា ក៏ឈ្មោះថា **កាយមោនេយ្យៈ** ។ ការលះឆន្ទរាគៈផ្សំកាយ ក៏ឈ្មោះថា **កាយមោនេយ្យៈ** ។ ការរលត់កាយសង្ខារ និងការចូលចតុត្ថជ្ឈាន ក៏ឈ្មោះថា **កាយមោនេយ្យៈ** ។ សូម្បីក្នុងវចីមោនេយ្យៈ ក៏មានន័យនេះដូចគ្នា ។

ចំណែកក្នុងវចីមោនេយ្យៈ និងមនោមោនេយ្យៈ នេះ មានសេចក្ដីផ្សេងគ្នា ដូចតទៅនេះ ៖

ក្នុងទីនោះ គប្បីជ្រាបការចូលទុតិយជ្ឈាន គឺការលេត់វចីសង្ខារ ថា ឈ្មោះថា វចីមោនេយ្យៈ ដូចការចូលចតុត្ថជ្ឈានក្នុងទីនេះ ។ កាលជ្រាបសេចក្ដីក្នុងមនោមោនេយ្យៈ ដោយន័យសូម្បីនេះហើយ ក៏គួរជ្រាបការចូលសញ្ញាវេទយិតនិរោធ គឺការលេត់ចិត្តសង្ខារថា ឈ្មោះថា **មនោមោនេយ្យៈ** ។

បទថា **កាយមុនី** បានដល់ អ្នកដឹង គឺ អ្នកខ្ពស់បំផុត បានដល់ អ្នកបរិសុទ្ធក្នុងកាយទ្វារ ឬអ្នកដឹងផ្លូវកាយ ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សព្វប្បហាយិនំ** បានដល់ ព្រះខីណាស្រព ។ ព្រោះថា ព្រះខីណាស្រព ឈ្មោះថា **សព្វបហាយី** (អ្នកលះបានទាំងអស់) ដូច្នេះឯង ។

ចប់ អដ្ឋកថាមោនេយ្យសូត្រ ។

# ៨-យសវត្ថុកថា

សម័យនោះឯង ក្នុងក្រុងពារាណសី មានកុលបុត្រ (ម្នាក់) ឈ្មោះយស ជាកូនសេដ្ឋី ជាបុគ្គលចម្រើនដោយសេចក្ដីសុខ ។ យសកុលបុត្រនោះ មានប្រាសាទ ៣ ប្រាសាទមួយសម្រាប់នៅក្នុងរដូវរងា ប្រាសាទមួយសម្រាប់នៅក្នុងរដូវក្ដៅ ប្រាសាទមួយសម្រាប់នៅក្នុងរដូវភ្លៀង ។

យសកុលបុត្រនោះ មាតាបិតាឲ្យអ្នកភ្លេង តូរ្យតន្ត្រី សុទ្ធសឹងតែស្រី ឥតមានបុរសឡើយ ចាំបម្រើអស់កំណត់ ៤ ខែ ក្នុងប្រាសាទសម្រាប់នៅក្នុងរដូវភ្លៀង មិនដែលចុះមកកាន់ផ្ទៃប្រាសាទខាងក្រោមទេ ។ គ្រានោះ យសកុលបុត្រ ឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ កាលពួកស្រីកំពុងបម្រើ ក៏ដេកលក់ទៅជាមុនឯជនជាបរិស័ទ ក៏ដេកលក់ជាខាងក្រោយ ។ រីឯប្រទីបដែលគេអុជទុកដោយប្រេង តែងឆេះបំភ្លឺទាល់ព្រឹករាល់ៗ យប់ ។ គ្រានោះ យសកុលបុត្រ ភ្ញាក់ពីនិទ្រាមុនគេ បានឃើញជនជាបរិស័ទរបស់ខ្លួនកំពុងដេកលក់ ស្រីខ្លះមានពិណានៅត្រង់ក្លៀក ស្រីខ្លះមានស្គរសម្ភោរនៅត្រង់ក ស្រីខ្លះមានស្គរធំនៅត្រង់ទ្រូង ស្រីខ្លះមានសក់

*រំសាយ ស្រីខ្លះមានទឹកមាត់ហូរហៀរ ស្រីខ្លះកំពុងមមើ (យសកុលបុត្រ បានឃើញជនជាបរិស័ទរបស់ខ្លួន) ហាក់ដូចជាព្រៃស្មសាន មកប្រាកដក្នុងកណ្ដាប់ដៃ ។ យសកុលបុត្រនោះ លុះបានឃើញហើយ កើតសេចក្ដីជិនឆ្អន់ចិត្ត ក៏បិតនៅស៊ប់ ក្នុងសេចក្ដីនឿយណាយ ។*

អថខោ យសោ កុលបុត្តោ ឧទានំ ឧទានេសិ ឧបទ្ទុតំ វត ភោ ឧបស្សដ្ឋំ វត ភោតិ *ទើបយសកុលបុត្រ បន្លឺនូវឧទានវាចា (ដោយសេចក្ដីសង្វេគ)ថា ឱហ្ន៎ (ទីនេះ) ប្រឫកប្រឫលណាស់តើ ឱហ្ន៎ (ទីនេះ) ជំពាក់វាក់វិនណាស់តើ ។*

*គ្រានោះ យសកុលបុត្រ ពាក់ទ្រនាប់ជើងមាសដើរសំដៅទៅកាន់មាត់ទ្វារផ្ទះ ។ អមនុស្សទាំងឡាយបើកទ្វារទុកដោយបំណងថា អ្នកណាមួយកុំធ្វើអន្តរាយក្នុងការចេញចាកផ្ទះ ហើយបួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះ របស់យសកុលបុត្រឡើយ ។ គ្រានោះ យសកុលបុត្រ ក៏ដើរតម្រង់ទៅកាន់ទ្វារព្រះនគរ ។ អមនុស្សទាំងឡាយបើកទ្វារទុក ដោយបំណងថា អ្នកណាមួយកុំធ្វើអន្តរាយក្នុងការចេញចាកផ្ទះ ហើយ*

បួសក្នុងកាលនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះ របស់យសកុលបុត្រឡើយ ។ គ្រានោះ យសកុលបុត្រ ក៏ដើរតម្រង់ទៅកាន់ឥសិបតនមិគទាយវ័ន ។

សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងសម័យព្រឹកព្រាងស្វាងរាត្រី ហើយទ្រង់ចង្ក្រមក្នុងទីវាល ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញយសកុលបុត្រ ដើរមកអំពីចម្ងាយ លុះទតឃើញហើយ ក៏យាងចេញអំពីកន្លែងចង្ក្រម ហើយគង់លើអាសនៈដែលគេក្រាលទុកស្រាប់ ។

គ្រានោះ យសកុលបុត្រ បន្លឺឧទានវាចា (ដោយសេចក្តីសង្វេគ) ក្នុងទីជិតព្រះមានព្រះភាគថា ឱហ្ន៎ (ទីទុំៈ) ប្របូកប្របល់ណាស់តើ ឱហ្ន៎ (ទីទុំៈ) ជំពាក់វាក់វិនណាស់តើ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ នឹងយសកុលបុត្រថា ម្នាលយស ទីនេះឯងមិនប្របូកប្របល់ ទីនេះមិនជំពាក់វាក់វិនទេ ម្នាលយសមកណោះ មកអង្គុយ(ឯណោះ) តថាគតនឹងសម្តែងធម៌ដល់អ្នក ។

គ្រានោះ យសកុលបុត្រក៏រីករាយ អណ្តែតចិត្ត ដោយគិតឃើញថា ឮថា ទីនេះមិនប្របូកប្របល់ ទីនេះមិនជំពាក់វាក់វិន

(គិតដូច្នេះហើយ) ក៏ដោះទ្រនាប់ជើងមាសចេញ ដើរតម្រង់ទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះយសកុលបុត្រអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងអនុបុព្វីកថា, ព្រះអង្គសម្តែងអនុបុព្វីកថាដូចម្តេច ? គឺទ្រង់ប្រកាស “**ទានកថា** (សម្តែងអំពីទាន), **សីលកថា** (សម្តែងអំពីសីល), **សគ្គកថា** (សម្តែងអំពីឋានសួគ៌), កាមានំ អាទីនវំ ឱការំ សង្កិលេសំ (សម្តែងអំពីទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង), នេក្ខម្មេ អានិសំសំ (សម្តែងអំពីអានិសង្សក្នុងការចេញចាកកាម ហើយបួស ក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ដល់ផ្ទះ)” ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបយសកុលបុត្រថា **មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា** ក្នុងកាលណាហើយ កាលនោះ ព្រះអង្គក៏ទ្រង់សម្តែងធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ។ ធម្មតាសំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមាន

*ពណ៌ខ្មៅ គឺចង្រៃ ឬល័ក្ខខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អ បាន មានឧបមាដូចម្ដេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គ ដ៏ប្រាស ចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់យសកុលបុត្រ ក្នុងកន្លែងអង្គុយនោះឯងថា ៖*

*យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ធម្មជាត ណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏រលត់ ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។*

*(វិនយបិដក ៦, ៤៧-៥១)*

*ព្រះមានព្រះភាគ ត្រាស់សំដៅដល់ព្រះនិព្វានថា ម្នាលយស ទីនេះឯង ។ មែនពិត និព្វាននោះ មិនប្រឬកប្រឬល់ មិនជំពាក់ វាក់វិនដោយកិលេស មានតណ្ហាជាដើម ។*

## បិតារបស់ព្រះយសបានសម្រេចធម៌

*គ្រានោះ មាតារបស់ព្រះយសកុលបុត្រ ឡើងទៅកាន់ ប្រាសាទ មិនបានឃើញយសកុលបុត្រ ក៏ដើរតម្រង់ទៅរកសេដ្ឋី គហបតី (ជាស្វាមី) លុះចូលទៅដល់ហើយក៏ប្រាប់សេដ្ឋីគហបតី*

ថា បពិត្រគហបតី យសកុមារជាកូនរបស់អ្នកមិនឃើញទេ ។ គ្រានោះ សេដ្ឋីគហបតីបញ្ជូនបម្រើទៅដោយសេះ ក្នុងទិសទាំង ៤ ខ្លួនឯងក៏ដើរសំដៅទៅកាន់ឥសិបតនមិគទាយវ័ន សេដ្ឋីគហបតីបានឃើញដានទ្រនាប់ជើងមាស លុះឃើញហើយ ក៏ដើរទៅតាមដានទ្រនាប់ជើងមាសនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញច្បាស់នូវសេដ្ឋីគហបតីដើរមកអំពីចម្ងាយ ។ លុះព្រះមានព្រះភាគទ្រង់ទតឃើញហើយ ក៏ទ្រង់ពុទ្ធបរិវិតក្កថា តថាគតគួរធ្វើឥទ្ធា-កិសង្ខារ (សម្តែងឫទ្ធិមិនឲ្យឃើញ) មិនឲ្យសេដ្ឋីគហបតីដែលអង្គុយនៅក្នុងទីនេះឃើញយសកុលបុត្រ ដែលអង្គុយនៅក្នុងទីនេះឯង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់តាក់តែងនូវឥទ្ធាកិសង្ខារមានសភាពដូច្នោះហើយ ។ កាលនោះ សេដ្ឋីគហបតី ក៏ដើរចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បានឃើញយសកុលបុត្រដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី បើដូច្នោះ ចូរអ្នកអង្គុយសិនចុះ បើអ្នកអង្គុយក្នុងទីនេះ មុខជានឹងឃើញយសកុលបុត្រអង្គុយនៅក្នុងទីនេះដែរ ។ គ្រានោះ សេដ្ឋីគហបតីនឹកសង្ឃឹមថា ឮថា បើអ្នកអង្គុយ

នៅក្នុងទីនេះឯង គង់នឹងឃើញយសកុលបុត្រអង្គុយនៅក្នុងទីនេះដែរ ហើយក៏ត្រេកអររីករាយ ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះសេដ្ឋីគហបតីអង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងអនុបុព្វីកថា គឺទ្រង់ប្រកាសទានកថា ១ **សីលកថា** ១ **សគ្គកថា** ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុងការចេញចាកកាម (បួស) ១ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថាសេដ្ឋីគហបតី មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លាក្នុងកាលណា ធម្មទេសនាណាដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសម្តែងដោយព្រះអង្គឯង ទ្រង់ក៏ប្រកាសនូវធម្មទេសនានោះ គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលនោះឯង ។ ធម្មតាសំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ឯធម្មចក្ខុគឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សេដ្ឋីគហបតី ក្នុងទីអង្គុយនោះថា

“ធម្មជាតណាមួយ ដែលកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង” ។

គ្រានោះ សេដ្ឋីគហបតី បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានជ្រៀតជ្រាបនូវអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវការៈជាអ្នកក្លាហាន មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបបង្គំទូលព្រះ-ដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន (ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ) ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុរសដែលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះ ឬបើកចេញនូវរបស់ដែលគេបិទបាំងទុក ឬប្រាប់ផ្លូវដល់បុរសដែលវង្វេងផ្លូវ ឬទ្រោលបំភ្លឺនូវប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុទាំងឡាយ នឹងឃើញរូបបានដោយងាយ មានឧបមាយ៉ាងណាមិញ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសហើយ ដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរលឹក សូមព្រះមានព្រះភាគ

ទ្រង់ជ្រាបខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមទៅ ។

សោ ច លោកេ បឋមំ ឧបាសកោ អហោសិ តេវាចិកោ : ឯសេដ្ឋីគហបតីនោះ បានទាមបញ្ញត្តិថា តេវាចិកឧបាសក (គឺជាឧបាសកដល់តេវាចិកសរណគមន៍) ជាដំបូងក្នុងលោក ។

គ្រានោះ យសកុលបុត្រ កាលដែលព្រះមានព្រះភាគកំពុងសម្តែងធម៌ដល់បិតា (របស់ខ្លួន) ក៏ពិចារណានូវភូមិធម៌ដែលខ្លួនឃើញហើយ ដែលខ្លួនត្រាស់ដឹងហើយ ចិត្តក៏រួចផុតស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជំពាក់ដោយឧបាទានឡើយ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា យសកុលបុត្រ កាលដែលតថាគតកំពុងសម្តែងធម៌ដល់បិតា (របស់ខ្លួន) ក៏ពិចារណានូវថ្នាក់នៃធម៌ដែលខ្លួនឃើញហើយ ត្រាស់ដឹងហើយ ចិត្តក៏រួចផុតស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជាប់ចំពាក់ដោយឧបាទាន ឯយសកុលបុត្រ(នេះ) មិនគួរវិលត្រឡប់ទៅដើម្បីភាវៈថោកទាប ហើយបរិភោគកាមទាំងឡាយដូចកាលនៅ

យកវាសក្នុងកាលពីមុនទេ បើដូច្នោះ គួរតែជាគតរម្ងាប់នូវឥទ្ធាភិសង្ខារ (រំសាយឫទ្ធិ)នោះចេញ ។ គ្រានោះ ព្រះមានព្រះភាគបានរំសាយឥទ្ធាភិសង្ខារនោះហើយ ។ សេដ្ឋីគហបតីបានឃើញយសកុលបុត្រអង្គុយនៅ (ក្នុងទីនោះ) លុះឃើញហើយក៏និយាយពាក្យនេះនឹងយសកុលបុត្រថា នែយស មាតារបស់អ្នកមានសេចក្តីសោកខ្សឹកខ្សួល ចូរអ្នកឲ្យជីវិតដល់មាតារបស់អ្នកផង ។ គ្រានោះយសកុលបុត្រ ក៏ងើបមើលព្រះមានព្រះភាគ ។ ឯព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានេះ នឹងសេដ្ឋីគហបតីថា ម្នាលគហបតីអ្នកឯងសម្គាល់យសកុលបុត្រនោះថាដូចម្តេចទៅ ឯយសកុលបុត្រ(នេះ) ឈ្មោះថា ឃើញធម៌ហើយដោយសេក្ខញាណ និងសេក្ខទស្សនៈ ព្រោះថា យសកុលបុត្រនោះ ពិចារណានូវភូមិធម៌ ដូចជាធម៌ដែលអ្នកឃើញហើយ អ្នកដឹងហើយ ចិត្ត(របស់យសកុលបុត្រនោះ) ក៏រួចចាកអាសវៈធម៌ទាំងឡាយហើយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ម្នាលគហបតី យស(នេះ) គួរនឹងវិលត្រឡប់ទៅដើម្បីការៈបោកទាប ហើយបរិភោគកាមទាំងឡាយ ដូចកាល

នៅជាយរាវាសក្នុងកាលពីមុនដែរឬទេ ។ សេដ្ឋីគហបតី ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ហេតុនេះមិនគួរទេ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី យសកុលបុត្រ(នេះឯង) ឈ្មោះថាឃើញធម៌ហើយ ដោយសេក្ខញ្ញាណ និងសេក្ខទស្សនៈ ព្រោះថា យសកុលបុត្រនោះ ពិចារណានូវភូមិធម៌ដូចជាធម៌ដែលអ្នកឃើញហើយ អ្នកត្រាស់ដឹងហើយ ចិត្តក៏រួចចាកអាសវៈធម៌ទាំងឡាយហើយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ម្នាលគហបតី យសកុលបុត្រមិនគួរនឹងវិលត្រឡប់ទៅដើម្បីការៈថោកទាប ហើយបរិភោគកាមទាំងឡាយ ដូចនៅជាយរាវាសក្នុងកាលពីមុនទេ ។

សេដ្ឋីគហបតី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន យសកុលបុត្រមានលាភហើយ បពិត្រព្រះអង្គដ៏ចម្រើន (អត្តភាពជាមនុស្ស) យសកុលបុត្របានល្អហើយ ព្រោះចិត្តរបស់យសកុលបុត្រ រួចចាកអាសវធម៌ទាំងឡាយហើយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃនេះ ព្រមទាំង

យសកុលបុត្រជាបច្ឆាសមណៈផង ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយភាវៈស្ងៀមនៅ ។ គ្រានោះ សេដ្ឋីគហបតីដឹងថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយដើរចេញទៅ ។

## ឧបសម្បទារបស់ព្រះយស

កាលបើសេដ្ឋីគហបតី ចេញទៅមិនយូរប៉ុន្មាន ក៏យសកុលបុត្រ ក្រាបបង្គំទូលព្រះមានព្រះភាគ ក្នុងពេលនោះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។

ឯហិ ភិក្ខុតិ ភគវា អវោច ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ, ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកចូរមកជាភិក្ខុចុះ ហើយទ្រង់ត្រាស់ថា សាសនធម៌ តថាគតពោលល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ចុះ ។

ឯព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ថា អ្នកចូរមកជាភិក្ខុនោះឯង ជាឧបសម្បទារបស់យសកុលបុត្រដ៏មានអាយុនោះ ។ ព្រះអរហន្ត ទាំងឡាយ ៧ អង្គ កើតមានក្នុងលោកក្នុងគ្រានោះឯង ។

## ហេតុនៃឯហិភិក្ខុឧបសម្បទា

ឯហិ ភិក្ខូតិ ភគវា អវោចាតិ តស្ស កិរ ឥទ្ធិមយបត្តចីវរស្ស ឧបនិស្សយំ ឱលោកេន្តោ អនេកាសុ ជាតីសុ ចីវរាទិអដ្ឋបរិក្ខារទានំ ទិស្វា ឯហិ ភិក្ខូតិ អវោច : ពាក្យថា **ព្រះមានព្រះភាគ ត្រាស់ថា "លោកចូរមក ជាភិក្ខុចុះ"** ដូច្នេះ សេចក្តីថា បានឮថា ព្រះមានព្រះភាគ ទ្រង់ រមិលមើលឧបនិស្ស័យនៃបាត្រនិងចីវរ ដែលសម្រេចដោយឫទ្ធិ របស់យសកុលបុត្រនោះ ទ្រង់ឃើញការប្រគេនអដ្ឋបរិក្ខារ មាន ចីវរជាដើមក្នុងជាតិជាអនេក ហើយទើបទ្រង់ត្រាស់ថា **ចូរមកជា ភិក្ខុចុះ** ។

ក្នុងខណៈនោះឯង យសកុលបុត្រនោះ ក៏មានសក់ដាច់ ហើយ និងគ្រងសំពត់កាសាវពស្ត្រ មានបរិក្ខាររបស់ភិក្ខុ ៨ យ៉ាង

*ស្បៀកដណ្តប់លើរាងកាយតែម្តង ដូចជាព្រះថេរៈ ៦០ វស្សា អង្គុយនមស្ការព្រះមានព្រះភាគ ។*

យោ ហិ ចីវរាទិកេ អដ្ឋ បរិក្ខារេ បត្តចីវរមេវ វា សោតាបន្នាទិអរិយស្ស បុថុជ្ជនស្សេវ វា សីលសម្បន្នស្ស ទត្វា ឥទំ បរិក្ខារទានំ អនាគតេ ឯហិភិក្ខុភាវាយ បច្ចយោ ហោតូតិ បត្ថនំ បដ្ឋបេតិ, តស្ស តំ សតិ អធិការសម្បត្តិយំ ពុទ្ធានំ សម្មុខីភាវេ ឥទ្ធិមយបរិក្ខារលាភាយ សំវត្តតីតិ វេទិតព្វំ ។

*ក៏បុគ្គលណាថ្វាយអដ្ឋបរិក្ខារមានចីវរជាដើម ឬត្រឹមតែបាត្រ និងចីវរប៉ុណ្ណោះ ដល់ព្រះអរិយៈ មានព្រះសោតាបន្នជាដើម ឬដល់បុថុជ្ជនទោះឯង ដែលដល់ព្រមដោយសីល ហើយតាំងសេចក្តីប្រាថ្នាទុកថា “រីការថ្វាយបរិក្ខារនេះ សូមជាបច្ច័យដើម្បីភាពជាឯហិភិក្ខុ ក្នុងអនាគតកាលចុះ” ។ កាលការដល់ព្រមនៃបុញ្ញាធិការមានតាមប្រាថ្នានោះ គប្បីជ្រាបថា រមែងប្រព្រឹត្តទៅ*

ដើម្បីការបានបរិក្ខារដែលសម្រេចដោយឫទ្ធិ ចំពោះព្រះភក្ត្រនៃព្រះពុទ្ធជាម្ចាស់ទាំងឡាយដល់បុគ្គលនោះ ។ (សារត្ថទីបនីដីកា ៣,)

ឥត្ថីនំ ហិ ចីវរទានំ មហាលតាបសាធនេន មត្ថកំ បប្បោតិ បុរិសានំ ឥទ្ធិមយបត្តចីវរេន : ក៏ចីវរទានរបស់ស្ត្រីទាំងឡាយ រមែងដល់ទីបំផុត ដោយគ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍, ចីវរទានរបស់បុរសទាំងឡាយ រមែងដល់ទីបំផុតដោយបាត្រនិងចីវរ ដែលសម្រេចហើយដោយឫទ្ធិ ។

(ធម្មបទដ្ឋកថា. ៣, ៩២ ; ៨៦)

## មាតានិងបុរាណទុតិយិកានៃព្រះយស

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ មានព្រះយសដ៏មានអាយុ ជាបច្ឆាសមណៈ យាងចូលទៅកាន់លំនៅរបស់សេដ្ឋីគហបតី លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលសេដ្ឋីក្រាលបម្រុងទុកហើយ ។ គ្រានោះ មាតានិងស្រីជាបុរាណទុតិយិកា របស់ព្រះយសដ៏មានអាយុ នាំគ្នាដើរចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុង

ទីដ៏សមគួរ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងអនុបុព្វីកថាដល់ស្រី ទាំងនោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុងការ ចេញចាកកាម (បួស) ១ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ស្រីទាំងឡាយនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាស ចាកនីវរណធម៌ មានចិត្តរីករាយ មានចិត្តជ្រះថ្លាក្នុងកាល ណា ធម្មទេសនាណា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើង សម្តែងដោយព្រះអង្គឯង ទ្រង់ក៏ប្រកាសនូវធម្មទេសនានោះ គឺ ទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាល នោះ ។ សំពត់ស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មាន ឧបមាដូចម្តេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ស្រីទាំងឡាយនោះ ក្នុងទី អង្គុយនោះឯងថា "ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យ ដូច្នោះឯង" ។ ស្រីទាំងអម្បាលនោះ បានឃើញអរិយសច្ចធម៌ ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌

ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្ដីក្លៀវក្លា មិនបាច់ជឿស្ដាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្ដា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ ពីរោះណាស់ បុរសដែលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះ ឬបើកចេញនូវរបស់ដែលគេបិទបាំងទុក ឬប្រាប់ផ្លូវដល់បុរសដែលវង្វេងផ្លូវ ឬទ្រោលបំភ្លឺនូវប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុនឹងឃើញរូបបានដោយងាយ មានឧបមាយ៉ាងណាមិញ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសហើយដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុ-សង្ឃផង ជាទីរលឹក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំព្រះអង្គទាំងឡាយថាជាឧបាសិកា ដល់នូវទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមទៅ" ។

ឯស្រីទាំងអម្បាលនោះ បានទាមបញ្ញត្តិថា ឧបាសិកាដល់នូវតេវាចិកាសរណគមន៍ជាដំបូងក្នុងលោក ។

គ្រានោះ បិតាមាតានិងស្រីជាបុរាណទុតិយិកា របស់ព្រះ-យសដ៏មានអាយុ អង្គាសព្រះមានព្រះភាគ និងព្រះយសដ៏មានអាយុ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯងឲ្យឆ្អែតស្កប់ស្កល់ហើយ (សំគាល់) នូវព្រះមានព្រះភាគដែលឆាន់ហើយ មានព្រះហស្តលែងលូកចុះក្នុងបាត្រហើយ ទើបអង្គុយចុះក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់បិតាមាតានិងស្រីជាបុរាណទុតិយិកា របស់ព្រះយសដ៏មានអាយុឲ្យយល់ច្បាស់ ឲ្យកាន់យក ឲ្យឧស្សាហ៍មាំ ឲ្យរីករាយដោយធម្មី-កថា ហើយទើបទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

## បព្វជ្ជារបស់គ្រហស្ថជាសម្លាញ់គ្នា ៤ នាក់

(លំដាប់នោះ) មានគ្រហស្ថ ៤ នាក់ ជាសម្លាញ់របស់ព្រះយសដ៏មានអាយុ គឺឈ្មោះវិមលៈ ១ សុពាហុ ១ បុណ្ណជិ ១ គវម្បតិ ១ ជាបុត្រពួកត្រកូលសេដ្ឋីនិងអនុសេដ្ឋី ក្នុងក្រុងពារា-ណសី បានឮដំណឹងថា យសកុលបុត្រកោរសក់ និងពុកមាត់

ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញអំពីផ្ទះហើយ បួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យណា ធម្មវិន័យនោះមិនមែនជារបស់ថោកទាបដោយពិត ទាំងបព្វជ្ជានោះសោត ក៏មិនមែនជារបស់ថោកទាបឡើង ។

សំឡាញ់ទាំងនោះ នាំគ្នាចូលទៅរកព្រះយសដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះយសដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះយសដ៏មានអាយុ នាំសំឡាញ់គ្រហស្ថទាំង ៤ នាក់នោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ លុះព្រះយសដ៏មានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក្រាបទូលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំឡាញ់របស់ខ្ញុំព្រះអង្គជាគ្រហស្ថទាំង ៤ នាក់នេះ ឈ្មោះវិមលៈ ១ សុពាហុ ១ បុណ្ណជិ ១ គវម្បតិ ១ ជាបុត្រពួកត្រកូលសេដ្ឋីនិងអនុសេដ្ឋី ក្នុងក្រុងពារាណសី (ជាមួយគ្នា) សូមព្រះមានព្រះភាគ ឲ្យឱវាទប្រៀនប្រដៅសំឡាញ់អម្បាលនេះឲ្យទាន ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងអនុបុព្វីកថាដល់បុរសទាំងឡាយនោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុងការចេញចាកកាម (បួស) ១ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថាបុរសទាំងឡាយនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តអណ្ដែតឡើង មានចិត្តជ្រះថ្លាក្នុងកាលណា ព្រះអង្គទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្ដែងដោយព្រះអង្គឯង ទ្រង់ក៏ប្រកាសនូវធម្មទេសនានោះគឺ ទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលនោះ ។ ធម្មតាសំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្ដេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់បុរសទាំងអម្បាលនោះ ក្នុងទីអង្គុយនោះឯងថា "ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង" ។ បុរសទាំងអម្បាលនោះ បាន

ឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្ដីក្លៀវក្លា មិនបាច់ជឿស្ដាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្ដា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យនេះថា "បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងអម្បាលនេះ គួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌តថាគតពោលល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយល្អចុះ" ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ឲ្យឱវាទប្រៀនប្រដៅដោយធម្មីកថា ក៏មានចិត្តផុតចាកអាសវធម៌ទាំងឡាយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ។ ព្រះអរហន្តទាំងឡាយ ១១ អង្គ កើតឡើងក្នុងលោក ក្នុងកាលនោះឯង ។

## បព្វជ្ជារបស់គ្រហស្ថជាសម្លាញ់គ្នា ៥០ នាក់

មានគ្រហស្ថ ជាសម្លាញ់របស់ព្រះយសដ៏មានអាយុ ៥០ នាក់ (ទៀត) ជាអ្នកនៅក្នុងជនបទ (ស្រុកក្រៅ) ជាកូននៃពួកត្រកូលទាំងឡាយមានបុព្វបុរសជាលំដាប់នៃបុព្វបុរស (គឺត្រកូលមានជីដូនជីតាជាលំដាប់តៗគ្នាមកច្រើនជួរ) បានឮដំណឹងច្បាស់ថា យសកុលបុត្រកោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញអំពីផ្ទះ ហើយបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ។ លុះជនទាំងនោះបានឮដំណឹង (យ៉ាងនេះ) ក៏ត្រិះរិះដូច្នេះថា "យសកុលបុត្រ កោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញអំពីផ្ទះហើយបួសក្នុងភេទនៃបុគ្គលមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យណា ធម្មវិន័យនោះ មិនមែនជារបស់ថោកទាបដោយពិត ទាំងបព្វជ្ជានោះសោត ក៏មិនមែនជារបស់ថោកទាបឡើយ"។

បុរសទាំង ៥០ នាក់នោះ នាំគ្នាចូលទៅរកព្រះយសដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះយសដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះយស

ដ៏មានអាយុ នាំសំឡាញ់ទាំង ៥០ នាក់នោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមាន-ព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ លុះព្រះយសដ៏មានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលដូច្នេះថា "បពិត្រព្រះអង្គដ៏ចម្រើន គ្រហស្ថជាសំឡាញ់របស់ខ្ញុំព្រះអង្គមានប្រ-មាណ ៥០ នាក់ ទាំងនេះ ជាអ្នកនៅក្នុងជនបទ ជាកូននៃពួកត្រកូលទាំងឡាយ មានបុព្វបុរសជាលំដាប់នៃបុព្វបុរស សូមព្រះមានព្រះភាគ ទ្រង់ឲ្យឱវាទ ប្រៀនប្រដៅសំឡាញ់អម្បាលនេះឲ្យទាន ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងអនុបុព្វីកថាដល់បុរសទាំងអម្បាលនោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុងការចេញចាកកាម (បួស) ១ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថាបុរសទាំង ៥០ នាក់នោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តអណ្ដែតឡើង មានចិត្តជ្រះថ្លាក្នុងកាលណា ព្រះអង្គទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្ដែងដោយព្រះអង្គឯង គឺ ទុក្ខសច្ច ១

សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលនោះ ។ ធម្មតាសំពត់សស្អាត មិនប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គឺធ្យូង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់បុរសទាំងអម្បាលនោះ ក្នុងទីអង្គុយនោះឯងថា "ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង" ។ បុរសទាំង ៥០ នាក់នោះ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវការៈជាអ្នកក្លាហាន មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា, ក៏ក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យនេះថា "បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ គួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា "អ្នកទាំងឡាយចូរមកជាភិក្ខុចុះ" ហើយត្រាស់ថា សាសនធម៌តថាគតពោលល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្ត

ព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយល្អចុះ" ។ ព្រះពុទ្ធដីកានេះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងអម្បាលនោះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទូន្មាន ប្រៀនប្រដៅភិក្ខុទាំងអម្បាលនោះ ដោយធម្មីកថា ។ ភិក្ខុទាំងអម្បាលនោះ កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទូន្មានប្រៀនប្រដៅដោយធម្មីកថា ចិត្តក៏រួចផុតចាកអាសវធម៌ទាំងឡាយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ។ (ក្នុងវស្សាទី ១ ប៉ុណ្ណោះ មានមនុស្សជា) ព្រះអរហន្តទាំងឡាយ ៦១ អង្គ កើតឡើងក្នុងលោកក្នុងកាលនោះឯង ។ (វិនយបិដក ៦, ៥៧-៦៥)

ក្នុងអដ្ឋកថា ពន្យល់ថា ៖

ពាក្យថា តេន ខោ បន សមយេន ឯកសដ្ឋិ លោកេ អរហន្តោ ហោន្តិ មានសេចក្តីថា ខាងក្នុងវស្សាប៉ុណ្ណោះ មានមនុស្សជាព្រះអរហន្ត ៦១ អង្គ គឺ ពួកមុន ៦ អង្គ និងពួកនេះ ៥៥ អង្គទៀត ។ បណ្តាមនុស្សទាំងនោះ យសកុលបុត្រជាដើម មានបុព្វប្រយោគដូចតទៅនេះ ៖

បានឮមកថា ក្នុងអតីតកាល សម្លាញ់ ៥៥ នាក់ ធ្វើបុណ្យរួមគ្នាជាពួក ទើបដើរជួយគ្នាចាត់ចែងសាកសពមនុស្សអនាថាទាំងឡាយ ។ ថ្ងៃមួយពួកគេជួបស្រីមានគភ៌ធ្វើកាលកិរិយា គិតថានឹងដុត ទើបនាំទៅកាន់ព្រៃជាទីចោលសាកសព ។ បណ្ដាពួកជនទាំងនោះ រៀវជនប្រាំនាក់ទុកត្រង់ព្រៃជាទីចោលសាកសព បង្គាប់ថា ចូរជួយគ្នាដុត ជនដ៏សេសនាំគ្នាចូលទៅកាន់ស្រុក ។ យសអ្នកមានវ័យក្មេង ចាក់ប្រែត្រឡប់សាកសពនោះឲ្យឆេះ ក៏បានអសុភសញ្ញា ។ យសបានបង្ហាញដល់សំឡាញ់ ៤ នាក់ថា អ្នកដ៏ចម្រើនចូរមើលរបស់មិនស្អាត គួរខ្ពើមនេះ ។ ជន ៤ នាក់ទៀតក៏បានអសុភសញ្ញាក្នុងសាកសពនោះផង ។ ជនទាំង ៥ នាក់នាំគ្នាទៅស្រុកហើយប្រាប់ដល់សម្លាញ់ដ៏សេស ។ ចំណែកយសដែលនៅវ័យក្មេង ទៅផ្ទះហើយបានប្រាប់ដល់មាតាបិតានិងភរិយា ។ ជនទាំងអស់នោះ បានចម្រើនអសុភសញ្ញាផងដែរ ។ បុព្វប្រយោគរបស់ជនទាំងនេះប៉ុណ្ណេះ ។ ព្រោះហេតុនោះ សេចក្ដីសម្គាល់ក្នុងពួកជនអ្នករបាំថា ជាព្រៃខ្មោចទុំះឯង ទើបបានកើតឡើងដល់

ព្រះយសដ៏មានអាយុ ។ និងដោយឧបនិស្ស័យសម្បត្តិនោះ ការសម្រេចធម៌ពិសេស បានកើតដល់សំឡាញ់គ្រប់ៗគ្នាដែរ ។




## ៩-ការប្រកាសនូវព្រហ្មចរិយធម៌

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយ អំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោត ក៏បានរួចហើយអំពីអន្ទាក់ទាំងអស់ដែរ ទោះបីជារបស់ទេវតាក្តី ទោះបីជា

របស់មនុស្សក្តី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក (គឺស្រុក និងនិគម និងរាជធានី ហើយសម្តែងធម៌) ដើម្បីជាប្រយោជន៍និងសេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវមួយជាមួយគ្នាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ ឲ្យពីរោះបទដើមបទកណ្តាលនិងបទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូរណ៍ទាំងអស់ សត្វទាំងឡាយដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងឡាយនឹងសាបសូន្យ (ចាកមគ្គផល) ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយអ្នកបំរុងត្រាស់ដឹងធម៌គង់នឹងមាន ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតក៏នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ដើម្បីសម្តែងធម៌ដែរ ។ (វិនយបិដក ៦, ៦៦)

## អដ្ឋកថា ពន្យល់ថា

ពាក្យថា សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិយោសានកល្យាណំ មានអធិប្បាយថា ព្រះមានព្រះភាគអង្គនោះ សូម្បីត្រូវលះបង់សុខដែលកើតពីវិវេកដ៏ប្រសើរ ហើយទ្រង់សម្តែងធម៌ ក៏ព្រោះទ្រង់អាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយ ។ ក៏ឯព្រះអង្គកាលទ្រង់សម្តែងធម៌នោះ ទោះបីតិចឬច្រើនក៏ដោយ ទ្រង់សម្តែងគ្រប់ទាំង ៣ ប្រការ មានលំអបទខាងដើមជាដើមប៉ុណ្ណោះ ។ គឺយ៉ាងណា ? គឺយ៉ាងនេះ សេចក្តីពិស្តារថា សូម្បីតែមួយព្រះគាថា ក៏មានលំអបទដើម ដោយបាទ-ដំបូង មានលំអបទកណ្តាល ដោយបាទទីពីរ និងទីបី មានលំអបទខាងចុង ដោយបាទទីបំផុត ព្រោះព្រះធម៌មានលំអជុំវិញ ។

ព្រះសូត្រមានអនុសន្ធិតែមួយ មានលំអបទដើម ដោយពាក្យនិទាន, មានលំអបទទីបំផុត ដោយពាក្យនិគម, មានលំអបទកណ្តាលដោយពាក្យដ៏សេស ។ ព្រះសូត្រដែលមានអនុសន្ធិផ្សេងៗ មានលំអបទដើម ដោយអនុសន្ធិដំបូង, មានលំអបទទីបំផុត ដោយអនុសន្ធិក្នុងទីបំផុត, មានលំអបទកណ្តាល ដោយ

អនុសន្ធិដ៏សេស ។

<u>សាសនធម៌</u> សូម្បីទាំងអស់ មានលំអបទដើម ដោយសីល ដែលជាអត្ថរបស់ខ្លួនខ្លះ, មានលំអបទកណ្តាល ដោយសមថៈ និងវិបស្សនា មគ្គនិងផលខ្លះ, មានលំអបទទីបំផុត ដោយព្រះនិព្វានខ្លះ ។

ម្យ៉ាងទៀត មានលំអបទខាងដើម ដោយសីល និងសមាធិ, មានលំអបទកណ្តាល ដោយវិបស្សនានិងមគ្គ, មានលំអបទចុង ដោយផលនិងព្រះនិព្វាន ។

ម្យ៉ាងទៀត មានលំអបទដើម ដោយការត្រាស់ដឹងដ៏ប្រពៃរបស់ព្រះពុទ្ធ មានលំអផ្នែកកណ្តាល ដោយភាពជាធម៌ដ៏ល្អនៃព្រះធម៌ មានលំអបទទីបំផុត ដោយការបដិបត្តិល្អនៃព្រះសង្ឃ ។

ម្យ៉ាងទៀត មានលំអខាងដើម ដោយព្រះអភិសម្ពោធិញ្ញាណ ដែលអ្នកស្តាប់សាសនធម៌នោះ ហើយបដិបត្តិតាមដូច្នោះ នឹងគប្បីសម្រេច មានលំអបទកណ្តាល ដោយបច្ចេកពោធិញ្ញាណ មានលំអបទទីបំផុត ដោយសាវកពោធិញ្ញាណ ។

មួយទៀត សាសនធម៌នោះ កាលសាធុជនស្តាប់ រមែងនាំ

មកនូវសេចក្ដីល្អតែម្យ៉ាង សូម្បីដោយការស្ដាប់ ព្រោះនឹងគ្របសង្កត់នីវរណធម៌បាន ព្រោះដូច្នោះ ទើបឈ្មោះថា មានលំអបទដើម, កាលសាធុជនបដិបត្តិ ក៏រមែងនាំមកនូវសេចក្ដីល្អតែម្យ៉ាង សូម្បីដោយការបដិបត្តិ ព្រោះនឹងនាំមកនូវសេចក្ដីសុខដែលកើតពីសមថៈនិងវិបស្សនា ព្រោះដូច្នោះ ទើបឈ្មោះថា មានលំអបទកណ្ដាល ។ ក៏កាលសាធុជនបដិបត្តិហើយ ដោយប្រការនោះ ក៏រមែងនាំមកតែសេចក្ដីល្អដូចគ្នា សូម្បីដោយផលនៃការបដិបត្តិ ព្រោះនឹងនាំមកតែសេចក្ដីល្អ ក្នុងកាលបានសម្រេចផលនៃការបដិបត្តិហើយ ព្រោះដូច្នោះ ទើបឈ្មោះថា មានលំអបទទីបំផុត ។

មួយទៀត មានលំអបទដើម ដោយសេចក្ដីបរិសុទ្ធិនៃដែនកើត ព្រោះសាសនធម៌មានទីពឹងជាដែនកើត មានលំអបទកណ្ដាល ដោយសេចក្ដីបរិសុទ្ធិនៃអត្ថ មានលំអបទទីបំផុត ដោយសេចក្ដីបរិសុទ្ធិនៃកិច្ច ។ ព្រោះដូច្នោះ ព្រះមានព្រះភាគអង្គនោះ កាលទ្រង់សម្ដែងធម៌ ទោះបីតិច ឬច្រើនក៏ដោយ គប្បីជ្រាបថា ទ្រង់សម្ដែងគ្រប់ទាំង ៣ ប្រការ មានលំអបទខាងដើមជាដើម ។

*(ចាក សមន្តបាសាទិកា អដ្ឋកព្រះវិន័យ វេរញ្ជកណ្ឌ)*

## ដីកាពន្យល់ពីលំអ ៣ យ៉ាង

១-អាទិកល្យាណំ *លំអបទខាងដើម*

២-មជ្ឈេកល្យាណំ *លំអបទកណ្តាល*

៣-បរិយោសានកល្យាណំ *លំអបទខាងចុង*

*បទថា* អាទិកល្យាណំ *សេចក្តីថា ស្អាត គឺល្អ ។ ពិតមែន បទខាងដើមកណ្តាលនិងខាងចុងក៏ដូចគ្នា ។ ក៏ឈ្មោះថា ខាងដើម កណ្តាលនិងខាងចុងនេះ មាន ២ យ៉ាង ជាប់ទាក់ទងនឹងព្រះសាសនា និងទេសនា ។*

តត្ថ សាសនស្ស សីលំ អាទិ សមថវិបស្សនា-មគ្គា មជ្ឈំ ផលនិព្វានានិ បរិយោសានំ : *បណ្តា ២ យ៉ាងនោះ, សាសនា មានសីលជាខាងដើម មានសមថវិបស្សនានិងមគ្គ ជាកណ្តាល មានផលនិងព្រះនិព្វានជាទីបំផុត ។*

សីលសមាធយោ វា អាទិ វិបស្សនាមគ្គា មជ្ឈំ ផលនិព្វានានិ បរិយោសានំ, *ម្យ៉ាងទៀត មានសីល សមាធិ*

*ជាខាងដើម មានវិបស្សនានិងមគ្គជាកណ្ដាល មានផល និងព្រះ-និព្វានជាទីបំផុត ។*

សីលសមាធិវិបស្សនា វា អាទិ មគ្គោ មជ្ឈំ ផលនិព្វានានិ បរិយោសានំ, *ម្យ៉ាងទៀត មានសីល សមាធិ វិបស្សនាជាខាងដើម មានមគ្គជាកណ្ដាល មានផលនិងព្រះនិព្វាន ជាទីបំផុត ។*

ទេសនាយ បន ចតុប្បទិកគាថាយ តាវ បឋម-បាទោ អាទិ ទុតិយតតិយា មជ្ឈំ ចតុត្ថោ បរិយោ-សានំ, *ចំណែក**ទេសនា** ខាងដើមគាថាដែលមាន ៤ បាទ មានបាទទី ១ ជាបទខាងដើម មានបាទ ទី ២ និងទី ៣ ជាបទកណ្ដាល មានបាទទី ៤ ជាបទខាងចុង ។*

បញ្ចបទឆប្បទានំ បឋមបាទោ អាទិ អវសាន-បាទោ បរិយោសានំ សេសា មជ្ឈំ, *សម្រាប់គាថា ដែលមាន ៥ បាទ ៦ បាទ មានបាទទី ១ ជាបទខាងដើម មានបាទខាងចុងជាទីបំផុត មានបាទដ៏សេសជាកណ្ដាល ។*

ឯកានុសន្ធិកស្ស សុត្តស្ស និទានំ អាទិ ឥទមវោចាតិ បរិយោសានំ សេសំ មជ្ឈំ , *ព្រះសូត្រដែលមានអនុសន្ធិ ១ មានពាក្យនិទានជាខាងដើម មានពាក្យពោលចុងក្រោយថា* ឥទមវោច *ជាទីបំផុត មានពាក្យដ៏សេសជាកណ្តាល ។*

អនេកានុសន្ធិកស្ស សុត្តស្ស មជ្ឈេ ពហុកម្បិ អនុសន្ធិ មជ្ឈមេវ និទានំ អាទិ ឥទមវោចាតិ បរិយោសានំ, *សម្រាប់ព្រះសូត្រដែលមានអនុសន្ធិច្រើន មានអនុសន្ធិសូម្បីច្រើន ត្រង់កណ្តាល ជាកណ្តាលនោះឯង មានពាក្យនិទានជាបទខាងដើម មានពាក្យចុងក្រោយថា* ឥទមវោច *ជាបទទីបំផុត ។ (ចាក សារត្ថទីបនីដីកា ភាគ ៣ )*

### *<u>អដ្ឋកថា</u> ពន្យល់ស័ព្ទថា សាត្ថំ សព្យញ្ជនំ ជាដើម*

*ក៏ក្នុងពាក្យជាដើមយ៉ាងនេះថា* សាត្ថំ សព្យញ្ជនំ *(ប្រកបដោយអត្ថនិងព្យញ្ជនៈ) ដូច្នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖*

ព្រោះព្រះមានព្រះភាគអង្គនោះ កាលទ្រង់សម្តែងព្រះធម៌នេះ ឈ្មោះថា ទ្រង់ប្រកាស គឺទ្រង់សម្តែងសាសនព្រហ្មចរិយ និងមគ្គព្រហ្មចរិយ ដោយន័យផ្សេងៗ ។ ក៏សាសនព្រហ្មចរិយ និងមគ្គព្រហ្មចរិយនោះ ឈ្មោះថា ប្រកបដោយអត្ថ ព្រោះដល់ព្រមដោយអត្ថ, ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយព្យញ្ជនៈ តាមសមគួរ ។

សង្កាសនបកាសន-វិវរណ-វិភជន-ឧត្តានីករណ-បញ្ញត្តិអត្ថបទសមាយោគតោ សាត្ថំ,

ឈ្មោះថា ប្រកបដោយអត្ថ ព្រោះប្រកបព្រមទាំងអត្ថបទដែលសម្តែង ប្រកាស បើក បែក ធ្វើឲ្យងាយ និងបញ្ញត្តិ ;

អក្ខរបទ- ព្យញ្ជនាការនិរុត្តិនិទ្ទេស- សម្បត្តិយា សព្យញ្ជនំ ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយអក្សរ បទ ព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេស ។

អត្ថគម្ភីរតាបដិវេធគម្ភីរតាហិ សាត្ថំ,

ឈ្មោះថា ប្រកបដោយអត្ថ ព្រោះសេចក្តីដែលសាសនព្រហ្មចរិយជាដើមនោះ ជ្រៅដោយអត្ថ និងជ្រៅដោយបដិវេធ,

ធម្មគម្ភីរតោទេសនាគម្ភីរតាហិ សព្យញ្ជនំ ។

*ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះសេចក្តីដែលសាសនព្រហ្មចរិយនោះ ជ្រៅដោយធម៌ និងជ្រៅដោយទេសនា ។*

អត្ថបដិភាណបដិសម្ភិទាវិសយតោ សាត្ថំ,

*ឈ្មោះថា ប្រកបដោយអត្ថ ព្រោះភាពជាវិស័យ (គឺជាអារម្មណ៍) នៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា,*

ធម្មនិរុត្តិបដិសម្ភិទាវិសយតោ សព្យញ្ជនំ ។

*ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះភាពជាវិស័យ (គឺជាអារម្មណ៍) នៃធម្មប្បដិសម្ភិទា និង និរុត្តិប្បដិសម្ភិទា ។*

បណ្ឌិតវេទនីយតោ បរិក្ខកជនប្បសាទកន្តិ សាត្ថំ, *ព្រហ្មចរិយនោះ ឈ្មោះថា ប្រកបដោយអត្ថ ព្រោះហេតុថា ជាទីជ្រះថ្លានៃជនជាអ្នកប្រាជ្ញ ព្រោះជាវត្ថុដែលបណ្ឌិតគប្បីដឹង ;*

សទ្ធេយ្យតោ លោកិយជនប្បសាទកន្តិ សព្យញ្ជនំ *ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះហេតុថា ជាទីជ្រះថ្លានៃ*

*លោកិយជន ព្រោះជាវត្ថុគួរជឿ ;*

គម្ភីរាធិប្បាយតោ សាត្ថំ, *ឈ្មោះថា ប្រកបដោយអត្ថ ព្រោះមានសេចក្ដីអធិប្បាយជ្រៅ,*

ឧត្តានបទតោ សព្យញ្ជនំ *ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះមានបទងាយយល់,*

ឧបនេតព្វស្ស អភាវតោ សកលបរិបុណ្ណភាវេន កេវលបរិបុណ្ណំ: *ឈ្មោះថា ពេញបរិបូរណ៍ទាំងអស់ ព្រោះមានសេចក្ដីដ៏ពេញបរិបូរណ៍ ព្រោះមិនមានវត្ថុដែលត្រូវបន្ថែមចូល ;*

អបនេតព្វស្ស អភាវតោ និទ្ទោសភាវេន បរិសុទ្ធំ *ឈ្មោះថា* ***បរិសុទ្ធ*** *ព្រោះជារបស់រកទោសមិនបាន ព្រោះមិនមានវត្ថុដែលនឹងត្រូវនាំចេញ ;*

សិក្ខត្តយបរិគ្គហិតត្តា ព្រហ្មភូតេហិ សេដ្ឋេហិ ចរិតព្វតោ តេសញ្ច ចរិយភាវតោ ព្រហ្មចរិយំ ។

*ឈ្មោះថា* ***ព្រហ្មចរិយ*** *ព្រោះដែលបុគ្គលជាធំ គឺអ្នកប្រសើរគប្បីបដិបត្តិ ហេតុដែលព្រហ្មចរិយនោះ ដែលលោកកំណត់*

ដោយត្រៃសិក្ខា និងព្រោះជាចរិយារបស់លោកទាំងនោះ,

ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបពោលថា ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ប្រកាសព្រហ្មចរិយ ប្រកបដោយអត្ថ និងព្យញ្ជនៈ បរិសុទ្ធ បរិបូរណ៍ទាំងអស់ ។

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ មានហេតុនិងរឿងដែលកើតឡើង ឈ្មោះថា ទ្រង់សម្តែង(ធម៌នោះ) មានលំអបទខាងដើម និងឈ្មោះថា ទ្រង់សម្តែង(ធម៌នោះ) មានលំអបទកណ្តាល ព្រោះសេចក្តីមិនវិបរិត និងព្រោះប្រកបដោយហេតុ និងឧទាហរណ៍ ដោយសមគួរដល់វេនេយ្យសត្វ និងឈ្មោះថា ទ្រង់សម្តែង (ធម៌នោះ) មានលំអបទទីបំផុត ព្រោះធ្វើឲ្យអ្នកស្តាប់ទាំងឡាយ បានសទ្ធា និងសេចក្តីទុកចិត្ត ។ ក៏កាលទ្រង់សម្តែងធម៌យ៉ាងនោះ ឈ្មោះថា ទ្រង់ប្រកាសព្រហ្មចរិយ ។

ក៏ព្រហ្មចរិយ ឈ្មោះថា ប្រកបដោយអត្ថ ព្រោះជ្រាបច្បាស់ក្នុងធម៌ដែលគួរសម្រេចបាន ក៏ដោយការបដិបត្តិ,

ឈ្មោះថា ប្រកបដោយព្យញ្ជនៈ ព្រោះស្ទាត់ជំនាញក្នុងគម្ពីរ ក៏ដោយបរិយត្តិ, ឈ្មោះថា បរិបូរណ៍ទាំងអស់ ព្រោះប្រកប

ដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម, ឈ្មោះថា **បរិសុទ្ធ** ព្រោះមិនមានគ្រឿងសៅហ្មង ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍លះបង់ទុក្ខក្នុងវដ្ដៈ និងព្រោះមិនមានសេចក្ដីប្រាថ្នាលោកាមិសៈ, ហៅថា **ព្រហ្មចរិយ** ព្រោះជាចរិយារបស់លោកអ្នកធំ ដោយអត្ថថា ជាអ្នកប្រសើរ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវក ។ សូម្បីព្រោះដូច្នោះ ព្រះមានព្រះភាគអង្គនោះ ទើបពោលបានថា ទ្រង់សម្ដែងធម៌ មានលំអបទខាងដើម មានលំអបទកណ្ដាល មានលំអបទចុង ទ្រង់ប្រកាសព្រហ្មចរិយដ៏បរិសុទ្ធ បរិបូរណ៍ទាំងអស់ប្រកបដោយអត្ថ និងព្យញ្ជនៈ ។

(ចាក សមន្តបាសាទិកា អដ្ឋកព្រះវិន័យ វេរញ្ជកណ្ឌ)

## ១០_មារកថា

គ្រានោះ ក្រុងមារជាអ្នកមានចិត្តអាក្រក់ ចូលទៅរកព្រះ-ដ៏មានព្រះភាគ លុះចូលទៅដល់ហើយទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយគាថា ថា ៖

បពិត្រព្រះសមណៈ ព្រះអង្គជាប់ជំពាក់ហើយដោយអន្ទាក់

ទាំងពួង ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី គឺព្រះអង្គជាបុគ្គលជាប់ជំពាក់ដោយចំណងដ៏មាំ ព្រះអង្គមិនរួចអំពីវិស័យរបស់ខ្ញុំព្រះអង្គឡើយ ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា នែក្រុងមារ អ្នកជាសត្វដ៏ថោកទាប តថាគតរួចហើយចាកអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី គឺតថាគតជាបុគ្គលរួចស្រឡះហើយចាកចំណងដ៏មាំ អ្នកឯងសោត ក៏តថាគតនាំចេញអំពីពុតកំណាច (គឺតថាគតឲ្យបាលបាញ់ហើយ) ។

ក្រុងមារ ក្រាបទូលថា បពិត្រព្រះសមណៈ អន្ទាក់ណាដែលត្រាច់ទៅក្នុងអាស អន្ទាក់នោះឯងគឺឆន្ទរាគដែលត្រាច់ទៅក្នុងចិត្ត (របស់សត្វ) ខ្ញុំនឹងទាក់ព្រះអង្គដោយអន្ទាក់គឺឆន្ទរាគនោះ ព្រះ-អង្គគង់មិនរួច (អំពីវិស័យ) របស់ខ្ញុំព្រះអង្គទេ ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលមារជាសត្វដ៏ថោកទាប រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ជាគ្រឿងតម្រេកក្នុងចិត្តនៃសត្វ ចំណង់របស់តថាគតក្នុងអារម្មណ៍មានរូបជាដើមនេះ ប្រាសចាក

អស់ហើយ អ្នកឯងសោត ក៏តថាគតនាំចេញអំពីពុតកំណាច (គឺតថាគតឲ្យចាលចាញ់ហើយ) ។

លំដាប់នោះ ក្រុងមារជាអ្នកមានចិត្តអាក្រក់ កើតទុក្ខតូចចិត្តថា ព្រះមានព្រះភាគ ស្គាល់អញ ព្រះសុគតស្គាល់អញ រូបក៏អន្តរធានបាត់ទៅអំពីកន្លែងនោះឯង ។

## ១១~បព្វជ្ជាកថា

សម័យនោះឯង ភិក្ខុទាំងឡាយតែងនាំមកនូវពួកបព្វជ្ជាបេក្ខបុគ្គលផង (អ្នកសម្ងំយកនូវបព្វជ្ជា គឺអ្នកដែលប្រាថ្នាបួសជាសាមណេរ) នូវពួកឧបសម្បទាបេក្ខបុគ្គលផង (អ្នកសម្ងំយកនូវឧបសម្បទា គឺអ្នកដែលប្រាថ្នាបួសជាភិក្ខុ) អំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ ដោយគិតថា ព្រះមានព្រះភាគ នឹងបំបួស នឹងឲ្យឧបសម្បទាដល់កុលបុត្រទាំងនោះ (ចំពោះព្រះអង្គ) ។ ឯភិក្ខុទាំងឡាយក្តី បព្វជ្ជាបេក្ខបុគ្គលទាំងឡាយក្តី ឧបសម្បទាបេក្ខបុគ្គលទាំងឡាយក្តី ក៏រមែងលំបាកក្នុងដំណើរនោះ ។

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ ទ្រង់សម្ងំនៅក្នុងកម្មដ្ឋាន មានព្រះតម្រិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ឥឡូវនេះ ភិក្ខុទាំងឡាយតែងនាំមកនូវពួកបព្វជ្ជាបេក្ខបុគ្គលផង នូវពួកឧបសម្បទាបេក្ខបុគ្គលផង អំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ (មកកាន់សំណាក់តថាគត) ដោយគិតថា ព្រះមានព្រះភាគ នឹងបំបួស នឹងឲ្យឧបសម្បទាដល់កុលបុត្រទាំងនោះ ចំណែកភិក្ខុទាំងឡាយក្តី បព្វជ្ជាបេក្ខបុគ្គលទាំងឡាយក្តី ឧបសម្បទាបេក្ខបុគ្គលទាំងឡាយក្តី ក៏រមែងលំបាកក្នុងដំណើរនោះ បើដូច្នោះ គួរតថាគតអនុញ្ញាតដល់ភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយត្រូវឲ្យបព្វជ្ជា ឲ្យឧបសម្បទា (ដល់កុលបុត្រ) ក្នុងទិសនោះៗ ក្នុងជនបទនោះៗ ចុះ ។

ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ចេញចាកការសម្ងំនៅក្នុងកម្មដ្ឋាន ក្នុងវេលាថ្ងៃរសៀល ហើយព្រះអង្គឲ្យប្រជុំភិក្ខុសង្ឃ រួចធ្វើធម្មីកថា ត្រាស់ចំពោះភិក្ខុទាំងឡាយក្នុងកាលនោះថា, ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅក្នុងទីស្ងាត់សម្ងំនៅក្នុងកម្មដ្ឋាន ក្នុងទីនេះ ក៏មានសេចក្តីរិះគិតក្នុងចិត្តកើត

ឡើងយ៉ាងនេះថា ឥឡូវនេះឯង ភិក្ខុទាំងឡាយតែងនាំមកនូវពួកបព្វជ្ជាបេក្ខបុគ្គលទាំងឡាយផង នូវពួកឧបសម្បទាបេក្ខបុគ្គលទាំងឡាយផង អំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ ដោយគិតថា ព្រះមានព្រះភាគ នឹងបំបួស នឹងឲ្យឧបសម្បទាដល់កុលបុត្រទាំងនោះ ភិក្ខុទាំងឡាយក្តី បព្វជ្ជាបេក្ខបុគ្គលទាំងឡាយក្តី ឧបសម្ប-ទាបេក្ខបុគ្គលទាំងឡាយក្តី ក៏រមែងលំបាកក្នុងដំណើរនោះ បើដូច្នោះគួរតថាគតអនុញ្ញាតដល់ភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយចូរឲ្យបព្វជ្ជា ឲ្យឧបសម្បទា (ដល់កុលបុត្រ) ក្នុងទិសនោះៗ ក្នុងជនបទនោះៗ ចុះ ។

អនុជានាមិ ភិក្ខវេ តុម្ហេវទានិ តាសុ តាសុ ទិសាសុ តេសុ តេសុ ជនបទេសុ បព្វាជេថ ឧបសម្បាទេថ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថា អ្នកទាំងឡាយចូរឲ្យបព្វជ្ជា ឲ្យឧបសម្បទា (ដល់កុលបុត្រ) ក្នុងទិសនោះៗ ក្នុងជនបទនោះៗ ក្នុងកាលឥឡូវនេះចុះ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវឲ្យបព្វជ្ជា ឲ្យឧប-សម្បទាយ៉ាងនេះ ។

បឋមំ កេសមស្សុំ ឱហារាបេត្វា *កុលបុត្រនោះ ភិក្ខុគប្បីកោរសក់និងពុកមាត់ឲ្យជាដំបូង*

កាសាយានិ វត្ថានិ អច្ឆាទាបេត្វា *ហើយឲ្យស្លៀកសំពត់កាសាយៈទាំងឡាយ*

ឯកំសំ ឧត្តរាសង្គំ ការាបេត្វា ភិក្ខូនំ បាទេ វន្ទាបេត្វា ឧក្កុដិកំ និសីទាបេត្វា អញ្ជលឹ បគ្គណ្ហាបេត្វា ឯវំ វទេហីតិ វត្តព្វោ *រូបឲ្យពាក់ចីវរឆៀងស្មាម្ខាង ឲ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ, ហើយអង្គុយប្រហោងផ្គងអញ្ជលីឡើង រូបប្រាប់ថា អ្នកចូរពោលពាក្យយ៉ាងនេះថា ៖*

ពុទ្ធំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក*

ធម្មំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីរលឹក*

សង្ឃំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់*

*នូវព្រះសង្ឃ ជាទីរលឹក*

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់ពីរដងផង*

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរលឹក ជាគំរប់ពីរដងផង*

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់ពីរដងផង*

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់បីដងផង*

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរលឹកជាគំរប់បីដងផង*

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់បីដងផង ។*

អនុជានាមិ ភិក្ខវេ ឥមេហិ តីហិ សរណាគមនេហិ បព្វជ្ជំ ឧបសម្បទំ : *ម្នាលភិក្ខុទាំងឡាយ*

តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍ទាំងឡាយនេះ ។

## ១២_ភទ្ទវគ្គិយកុមារ ៣០ អង្គ

គ្រានោះ ព្រះមានព្រះភាគ នៅចាំវស្សារួចហើយ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អរហត្តផលវិមុត្តិដ៏ប្រសើរ តថាគតបានសម្រេចហើយ អរហត្តផលវិមុត្តិដ៏ប្រសើរ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ដោយបានធ្វើទុកក្នុងចិត្តជាឧបាយ ដោយមានព្យាយាមដ៏ល្អជាឧបាយ, ម្នាលភិក្ខុទាំងឡាយ ចំណែកអ្នកទាំងឡាយ ក៏បានសម្រេចនូវអរហត្តផលវិមុត្តិដ៏ប្រសើរ ក៏បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលវិមុត្តិដ៏ប្រសើរហើយ ដោយបានធ្វើទុកក្នុងចិត្តជាឧបាយ ដោយមានព្យាយាមដ៏ល្អជាឧបាយ ។ល។

ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងក្រុងពារាណសី គួរដល់ពុទ្ធអធ្យាស្រ័យ រួចទ្រង់យាងចេញទៅកាន់ចារិកក្នុងឧរុវេលាប្រទេស ។ កាលនោះ ព្រះអង្គទ្រង់យាងចុះចាកផ្លូវ សំដៅទៅ

កាន់ដងព្រៃមួយ លុះយាងទៅដល់ហើយ ទ្រង់ចូលទៅកាន់ដងព្រៃនោះហើយ គង់នៅទៀបគល់ឈើមួយ ។

សម័យនោះឯង ពួកភទ្ទវគ្គិយកុមារប្រមាណ ៣០ នាក់ ជាសម្លាញ់នឹងគ្នាព្រមទាំងភរិយា កំពុងឲ្យភរិយាបម្រើ (ដោយកាម) ក្នុងដងព្រៃនោះ មានកុមារម្នាក់ឥតមានភរិយានឹងគេ ។ ទើបកុមារទាំងនោះ ទៅនាំយកស្រីពេស្យា (ស្រីផ្កាមាស) ម្នាក់មក ដើម្បីប្រយោជន៍ដល់កុមារដែលឥតមានភរិយានោះ ។ លំដាប់នោះឯងកាលដែលកុមារទាំងនោះប្រហែសធ្វេស កំពុងឲ្យភរិយារបស់ខ្លួនបម្រើ ស្រីពេស្យានោះបានលួចយកភណ្ឌៈ (ទ្រព្យ) រត់បាត់ទៅ ។ កាលនោះកុមារជាសម្លាញ់នឹងគ្នាទាំងនោះ ខ្វល់ខ្វាយដល់កុមារជាសម្លាញ់ ជួយស្វែងរកស្រីពេស្យានោះ ក៏បានដើរទៅកាន់ដងព្រៃនោះ បានឃើញព្រះមានព្រះភាគ គង់នៅទៀបគល់ឈើមួយ លុះឃើញហើយទើបនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បានឃើញស្រី (ម្នាក់) ដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកុមារទាំងឡាយ

ចុះអ្នកត្រូវការអ្វី ដោយស្រី(នោះ) ។ កុមារទាំងអម្បាលនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងអស់គ្នាប្រមាណ ៣០ នាក់ ជាពួកដ៏ចម្រើន ជាសម្លាញ់នឹងគ្នានៅក្នុងឧរុវេលាប្រទេសនេះ មានកិរិយាគ្រប់ៗ គ្នា បានឲ្យកិរិយាបម្រើក្នុងដងព្រៃនេះ ឯកុមារជាសម្លាញ់ម្នាក់មិនមានកិរិយានឹងគេឡើយ យើងខ្ញុំបាននាំយកស្រីពេស្យាម្នាក់មក ដើម្បីប្រយោជន៍ដល់កុមារជាសម្លាញ់នោះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំប្រហែសធ្វេស កំពុងឲ្យកិរិយារបស់ខ្លួនបម្រើ ស្រីពេស្យានោះ ក៏លួចយកកណ្ដុះរត់បាត់ទៅ ក្នុងពេលនោះ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះយើងខ្ញុំជាសម្លាញ់នឹងគ្នាខ្វល់ខ្វាយ ដល់កុមារជាសម្លាញ់ជួយស្វែងរកស្រីពេស្យានោះ ក៏បានដើរទៅកាន់ដងព្រៃនេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា "ម្នាលកុមារទាំងឡាយ អ្នកទាំងឡាយសម្គាល់រឿងនោះដូម្ដេច អ្នកទាំងឡាយគួរស្វែងរកស្រី ប្រសើរជាង ឬគួរស្វែងរកខ្លួនឯងប្រសើរជាង" ។ កុមារទាំងអម្បាលនោះក្រាបបង្គំទូលថា "បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំគួរស្វែងរកខ្លួនប្រសើរជាង" ។ ទើបព្រះអង្គត្រាស់ថា ម្នាលកុមារទាំងឡាយ

បើដូច្នោះ អ្នកទាំងឡាយអង្គុយមកសិនចុះ តថាគតនឹងសម្ដែងធម៌ ដល់អ្នកទាំងឡាយ ។ ភទ្ទវគ្គិយកុមារជាសម្លាញ់នឹងគ្នាទាំងនោះ ទទួលព្រះពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចម្រើនយ៉ាងហ្នឹងហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងនូវអនុបុព្វីកថាដល់ពួកភទ្ទ-វគ្គិយកុមារជាសម្លាញ់នឹងគ្នាទាំងនោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុងការចេញចាកកាម (បួស) ១ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ពួកភទ្ទវគ្គិយកុមារទាំងនោះ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តអណ្ដែតឡើង មានចិត្តជ្រះថ្លាក្នុងកាលណា ព្រះអង្គក៏ទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសម្ដែងចំពោះព្រះអង្គ គឺទ្រង់សម្ដែងទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលនោះ ។ ធម្មតាសំពត់ស្អាតមិនប្រឡាក់ដោយវត្ថុ មានពណ៌ខ្មៅ គឺជ្យួង ឬល័ក្តខ្មៅជាដើម គួរទទួលទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្ដេចមិញ ឯធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង

ដល់ពួកកទ្ទវគ្គិយកុមារទាំងនោះ ក្នុងទីអង្គុយនោះឯងថា "ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង" ។ ពួកកទ្ទ-វគ្គិយកុមារទាំងនោះ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបបង្គំទូលព្រះដ៏មានព្រះ-ភាគ យ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះ-ភាគ ទ្រង់ត្រាស់ហៅកទ្ទវគ្គិយកុមារទាំងនោះថា "អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ" ហើយទ្រង់ត្រាស់ថា "សាសនធម៌ តថាគតបានសម្តែងល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយល្អចុះ ។ ព្រះពុទ្ធដីកានេះឯងជាឧបសម្បទារបស់កទ្ទវគ្គិយភិក្ខុដ៏មានអាយុទាំងនោះ ។

(វិនយបិដក ៦, ៧១-៧៣)

<u>អដ្ឋកថា</u> **:** ពីរបទថា ធម្មចក្ខុំ ឧទបាទិ បានសេចក្តីថា សោតាបត្តិមគ្គ បានកើតឡើងដល់ពួកខ្លះ សកទាគាមិមគ្គ បានកើតឡើងដល់ពួកខ្លះ អនាគាមិមគ្គ បានកើតឡើងដល់ពួកខ្លះ មែនពិត មគ្គទាំង ៣ នេះ លោកហៅថា **ធម្មចក្ខុ** ។

## ១៣-រឿងជដិលជាបងប្អូននឹងគ្នា

គ្រានោះ ព្រះមានព្រះភាគ ត្រាច់ទៅកាន់ចារិកតាមលំដាប់ ក៏ទ្រង់ពុទ្ធដំណើរសំដៅទៅកាន់ឧរុវេលាប្រទេស ។ សម័យនោះឯង ជដិល ៣ នាក់ (ជាបងប្អូននឹងគ្នា) គឺ ឧរុវេលកស្សប ១ នទីកស្សប ១ គយាកស្សប ១ អាស្រ័យនៅក្នុងឧរុវេលាប្រទេសនោះ ។ បណ្តាជដិលទាំងនោះ មានជដិលឈ្មោះឧរុវេលកស្សប ជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាងជដិល ៥០០ នាក់ ។ ជដិលឈ្មោះនទីកស្សប ជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាងជដិល ៣០០ នាក់ ។ ជដិលឈ្មោះគយាកស្សប ជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាង

ជដិល ២០០ នាក់ ។ កាលនោះ ព្រះមានព្រះភាគ ទ្រង់យាងចូលទៅកាន់អាស្រមរបស់ជដិលឈ្មោះឧរុវេលកស្សប លុះចូលទៅដល់ហើយ ទ្រង់មានព្រះពុទ្ធដីកានឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប បើអ្នកមិនចង្អៀតចង្អល់ទេ យើងសូមនៅក្នុងរោងភ្លើងបាន ១ រាត្រី។ ឧរុវេលកស្សប ពោលតបថា បពិត្រមហាសមណៈ ខ្ញុំមិនមានសេចក្តីចង្អៀតចង្អល់អ្វីទេ តែថាក្នុងរោងភ្លើងនេះ មាននាគរាជមួយជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក កុំឲ្យតែនាគរាជនោះវាបៀតបៀនព្រះអង្គ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងជដិលឈ្មោះឧរុវេលកស្សបជាគម្រប់ពីរដងទៀត ។ល។ ជាគម្រប់បីដងទៀត ។ល។

ឧរុវេលកស្សប ពោលតបថា បពិត្រមហាសមណៈ ខ្ញុំមិនមានសេចក្តីចង្អៀតចង្អល់អ្វីទេ តែថាក្នុងរោងភ្លើងនេះ មាននាគរាជមួយជាសត្វកាច មានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក កុំឲ្យតែនាគរាជនោះវាបៀតបៀនព្រះអង្គ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែកស្សប នាគរាជនោះបៀតបៀនយើងមិនបានទេ ណ្ហើយចុះ អ្នកចូរព្រមឲ្យរោងភ្លើង

(ដល់យើងចុះ) ។ ឧរុវេលកស្សប តបថា បពិត្រមហាសមណៈ ព្រះអង្គចូរនៅតាមសប្បាយចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់រោងភ្លើង ហើយក្រាលនូវកម្រាលស្មៅ គង់ផ្គត់ភ្នែន តាំងកាយដ៏ត្រង់តម្កល់សតិឆ្ពោះមុខទៅកាន់កម្មដ្ឋាន ។

គ្រានោះ នាគនោះបានឃើញព្រះមានព្រះភាគ យាងចូលទៅ លុះឃើញហើយ កើតទុក្ខ តូចចិត្ត ក៏បណ្ដាលផ្សែងឲ្យហុយចេញ ។ ឯព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា ការនេះគួរតថាគត កុំបៀតបៀនស្បែកសម្បុរថ្ងៃ ស្បែកបន្ទាប់ សាច់សរសៃឆ្អឹង និងខួរក្នុងឆ្អឹង របស់នាគរាជនេះឲ្យសោះ ហើយគ្រាន់តែគ្របសង្កត់តេជះ (របស់នាគរាជ) ដោយតេជះរបស់តថាគតចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ សម្ដែងឥទ្ធាភិសង្ខារមានសភាពដូច្នោះហើយ ក៏បណ្ដាលផ្សែងឲ្យហុយតបទៅវិញ ។ ចំណែកនាគនោះ អត់ទ្រាំសេចក្ដីក្រោធមិនបាន ក៏បណ្ដាលភ្លើងឲ្យឆេះឡើង ។ ឯព្រះមានព្រះភាគ ព្រះអង្គទ្រង់ចូលឈាន មានតេជោធាតុជាអារម្មណ៍ហើយ ទ្រង់បណ្ដាលភ្លើងឲ្យឆេះឡើងដែរ ។ កាលបើអ្នកមានឫទ្ធិទាំងពីរ បណ្ដាលពន្លឺភ្លើងឲ្យភ្លឺព្រោងព្រាយ

ឡើងហើយ ឯភេងភ្លើងក៏រុងរឿងភ្លឺសន្ធោសន្ធៅឡើង ហាក់ដូចជាភ្លើងឆេះ ។ លំដាប់នោះ ជដិលទាំងអម្បាលនោះ នាំគ្នាចោមរោមភេងភ្លើង ហើយពោលយ៉ាងនេះថា ឱសមណៈមានរូបល្អម៉្លេះ ឥឡូវត្រូវនាគរាជបៀតបៀន ។ ឯព្រះមានព្រះភាគ លុះរាត្រីនោះកន្លងទៅហើយ ទ្រង់មិនបានប៉ះពាល់ស្បែកក្រៅ ស្បែកបន្ទាប់សាច់សរសៃឆ្អឹង និងខួរក្នុងឆ្អឹងរបស់នាគរាជនោះ ទ្រង់គ្របសង្កត់តេជះដោយតេជះហើយ ទ្រង់ចាប់នាគប្រកក្នុងបាត្រ (នាំយកទៅ) បង្ហាញដល់ជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប នេះនាគរបស់អ្នកឯង តថាគតបានគ្របសង្កត់តេជះរបស់វា ដោយតេជះតថាគតហើយ ។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សបត្រិះរិះដូច្នេះថា មហាសមណៈ(នេះ) មានឫទ្ធិខ្លាំង មានអានុភាពធំមែន ព្រោះហេតុថា (ព្រះអង្គ) អាចគ្របសង្កត់ តេជះរបស់នាគ ជាសត្វកាចមានឫទ្ធិ មានពិសក្នុងចង្កូម មានពិសដ៏ពន្លឹក ដោយតេជះ (របស់ព្រះអង្គបាន) តែបើទុកជាយ៉ាងនោះ ក៏គង់មិនមែនជាព្រះអរហន្តដូចអញទេ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងបាដិហារ្យ ៣,៥១៦ វិធី តាំងពីគ្រប់សន្តត់តែជះរបស់នាគ រហូតដល់ព្រះអង្គធ្វើទឹក ឲ្យញែកចេញដោយជុំវិញ ហើយដើរចង្ក្រមលើផែនដី ដ៏មានធូលីហុយឡើងដេរជាសក្ដុងទឹកណ្ដាលទឹក ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះបរិវិតក្កៈដូច្នេះថា មោឃបុរសនេះត្រិះរិះយ៉ាងនេះយូរណាស់មកហើយថា មហាសមណៈនេះ មានឫទ្ធិខ្លាំង មានអានុភាពធំមែន តែបើទុកជាយ៉ាងនោះក៏គង់មិនមែនជាព្រះអរហន្តដូចអញទេ បើដូច្នោះ គួរតថាគតធ្វើជដិលនេះ ឲ្យកើតសេចក្ដីសង្វេគ (ស្លុតចិត្ត) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះ នឹងជដិលឈ្មោះឧរុវេលកស្សបថា នែកស្សប អ្នកឯងមិនមែនជាព្រះអរហន្តទេ អ្នកមិនទាន់បានដល់អរហត្តមគ្គទេ ម្យ៉ាងទៀត អ្នកឯងនឹងបានជាអរហន្តឬៗ ថាជាបុគ្គលដល់ហើយនូវអរហត្តមគ្គ ដោយបដិបទាណាបដិបទានោះមិនមានដល់អ្នកទេ ។ គ្រានោះ ជដិលឈ្មោះឧរុវេលកស្សប ក្រាបសិរសាចុះទៀបព្រះបាទារបស់ព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមាន

ព្រះភាគ ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ (ក្នុងកាលឥឡូវនេះ) ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា នែកស្សប អ្នកឯងជានាយក ជាអ្នកដឹកនាំ ជាកំពូល ជាប្រធាន ជាបុគ្គលដ៏ឧត្តម ប្រសើរជាងជដិល ៥០០ រូប អ្នកត្រូវប្រាប់ជដិលទាំងអម្បាលនោះជាមុនសិន បើជដិលទាំងអម្បាលនោះគេយល់យ៉ាងណា គេក៏នឹងធ្វើយ៉ាងនោះដែរ ។ កាលនោះ ជដិលឈ្មោះឧរុវេលកស្សប ចូលទៅរកជដិលជាកូនសិស្សទាំងអម្បាលនោះ លុះចូលទៅដល់ហើយ ទើបប្រាប់ជដិលទាំងនោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំចង់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈ (នុ៎ះ) អ្នកទាំងឡាយយល់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ ។ ជដិលទាំងអម្បាលនោះតបថា បពិត្រលោកដ៏ចម្រើន ខ្ញុំទាំងអស់គ្នាជាអ្នកជ្រះថ្លាហើយក្នុងសំណាក់ព្រះមហាសមណៈ (នុ៎ះ) យូរណាស់មកហើយ បើលោកម្ចាស់នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈ យើងទាំងអស់គ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈ(នុ៎ះ)ដែរ ។ កាលនោះ ជដិលទាំងអម្បាលនោះ

បណ្តែតចោលនូវគ្រឿងបរិក្ខារព្រមទាំងសក់ ទាំងជដាទាំងអម្រែក ទាំងគ្រឿងបូជាភ្លើងក្នុងទឹក ហើយនាំគ្នាចូលទៅកាន់ទីដែលព្រះ-មានព្រះភាគគង់នៅ លុះចូលទៅហើយ ក្រាបសិរសាចុះទៀបព្រះបាទារបស់ព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមាន-ព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ហើយត្រាស់ថា សាសនធម៌តថាគតពោលល្អហើយ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីនឹងធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខដោយល្អចុះ ។ ព្រះពុទ្ធដីកានេះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងឡាយនោះ ។

ឯជដិលឈ្មោះនទីកស្សប និងគយាកស្សប បានឃើញគ្រឿងបរិក្ខារព្រមទាំងសក់ ទាំងជដា ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើងអណ្តែតទៅតាមទឹកច្បាស់លាស់ លុះបានឃើញហើយ គិតដូច្នេះថា សេចក្តីអន្តរាយកុំគប្បីមានដល់ជដិលជាបងអញឡើយ ។ គិតហើយក៏ប្រើជដិលទាំងឡាយឲ្យទៅដោយពាក្យថា អ្នកទាំង

*ឡាយចូរទៅស្តាប់ដំណឹងបងខ្ញុំមើល ជាហើយ ទើបខ្ទួនឯងក៏ទៅជាមួយនឹងជដិលទាំង ៣០០ រូប និង២០០ រូប ដើរតម្រង់ទៅកាន់ទីដែលឧរុវេលកស្សបដ៏មានអាយុនៅ លុះចូលទៅដល់ហើយនិយាយពាក្យនេះនឹងឧរុវេលកស្សបដ៏មានអាយុថា បពិត្រកស្សបអំពើនេះប្រសើរហើយឬអ្វីហ្ន៎ ។ ឧរុវេលកស្សបប្រាប់ថា អើអ្នកដ៏មានអាយុទាំងឡាយ អំពើនេះប្រសើរហើយ ។ កាលនោះ ជដិលទាំងអម្បាលនោះ ក៏បណ្តែតចោលនូវគ្រឿងបរិក្ខារព្រមទាំងសក់ទាំងជដា ទាំងអម្រែក ទាំងគ្រឿងបូជាភ្លើងទៅក្នុងទឹក ហើយនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅហើយក្រាបសិរសាចុះទៀបព្រះបាទារបស់ព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ ។ល។ (វិនយបិកដ ភាគ៦ ទំព័រ៧៦-១០៣)*

# ១៤-អាទិត្តបរិយាយសូត្រ

គ្រានោះ ព្រះមានព្រះភាគ គង់នៅក្នុងឧរុវេលាប្រទេស តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅ ក្នុងគយាសីសប្រទេស មួយអន្លើដោយភិក្ខុសង្ឃដ៏ច្រើនចំនួន ១.០០០ អង្គ គឺពួកភិក្ខុដែលជាជដិលក្នុងកាលមុននោះឯង ។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគ ទ្រង់គង់នៅលើខ្នងថ្ម ឈ្មោះគយា-សីសៈ ទៀបប្រទេសនោះ មួយអន្លើដោយភិក្ខុ ១,០០០ អង្គ ។

តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា

សព្វំ ភិក្ខវេ អាទិត្តំ ម្នាលភិក្ខុទាំងឡាយ ធម្មជាតទាំងអស់ជារបស់ក្តៅ

កិញ្ច ភិក្ខវេ សព្វំ អាទិត្តំ ម្នាលភិក្ខុទាំងឡាយ ធម្មជាតទាំងអស់ជារបស់ក្តៅ (នោះ) តើគឺអ្វី ?

ចក្ខុំ ភិក្ខវេ អាទិត្តំ ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ក្តៅ

រូបា អាទិត្តា *រូបទាំងឡាយជារបស់ក្តៅ*

ចក្ខុវិញ្ញាណំ អាទិត្តំ *ចក្ខុវិញ្ញាណជារបស់ក្តៅ*

ចក្ខុសម្ផស្សោ អាទិត្តោ *ចក្ខុសម្ផស្សជារបស់ក្តៅ*

យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា : *ការសោយអារម្មណ៍ណានេះ ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងអំពីបច្ច័យ គឺចក្ខុសម្ផស្ស*

តម្បិ អាទិត្តំ *ការសោយអារម្មណ៍នោះឯង ក៏ជារបស់ក្តៅ ។*

កេន អាទិត្តំ *ចុះក្តៅដោយហេតុអ្វី ?*

អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ : *តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ ក្តៅ(ដោយភ្លើង) គឺជាតិ ជរា មរណៈ ក្តៅដោយ(ភ្លើងគឺ)*

*សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីតូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត ។*

សោតំ អាទិត្តំ *ត្រចៀកជារបស់ក្ដៅ*

សទ្ទា អាទិត្តា *សំឡេងទាំងឡាយជារបស់ក្ដៅ ។បេ។*

ឃានំ អាទិត្តំ *ច្រមុះជារបស់ក្ដៅ*

គន្ធា អាទិត្តា *ក្លិនទាំងឡាយជារបស់ក្ដៅ ។បេ។*

ជិវ្ហា អាទិត្តា *អណ្ដាតជារបស់ក្ដៅ*

រសា អាទិត្តា *រសទាំងឡាយជារបស់ក្ដៅ ។បេ។*

កាយោ អាទិត្តោ *កាយជារបស់ក្ដៅ*

ផោដ្ឋព្វា អាទិត្តា *ផោដ្ឋព្វៈទាំងឡាយជារបស់ក្ដៅ។បេ។*

មនោ អាទិត្តោ *ចិត្តជារបស់ក្ដៅ*

ធម្មា អាទិត្តា *ធម្មារម្មណ៍ទាំងឡាយជារបស់ក្ដៅ*

មនោវិញ្ញាណំ អាទិត្តំ *មនោវិញ្ញាណជារបស់ក្ដៅ*

មនោសម្ផស្សោ អាទិត្តោ *មនោសម្ផស្សជារបស់ក្ដៅ*

យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា *សេចក្តីសោយអារម្មណ៍ណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី តែងកើតឡើងព្រោះបច្ច័យ គឺមនោសម្ផស្ស*

តម្បិ អាទិត្តំ *សេចក្តីសោយអារម្មណ៍នោះឯង ក៏ជារបស់ក្តៅ*

កេន អាទិត្តំ *ចុះក្តៅដោយហេតុអ្វី ?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ : *តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ ក្តៅដោយសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ។*

ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មិម្បិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ : *ម្នាលភិក្ខុទាំងឡាយ អរិយសាវកប្រកបដោយសុតៈ (គឺជាអ្នកចេះដឹង) កាលឃើញយ៉ាងនេះ ក៏នឿយណាយក្នុងចក្ខុផង ក្នុងរូបទាំងឡាយផង ក្នុងចក្ខុវិញ្ញាណផង ក្នុងចក្ខុសម្ផស្សផង*

យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មិម្បិ និព្វិន្ទតិ *សេចក្តីសោយអារម្មណ៍ណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី តែងកើតឡើងអំពីបច្ច័យ គឺចក្ខុសម្ផស្ស អរិយសាវករមែងនឿយណាយ ក្នុងសេចក្តីសោយអារម្មណ៍នោះឯងផង ។*

សោតស្មឹបិ និព្វិន្ទតិ *ក្នុងត្រចៀកផង*

សទ្ទេសុបិ និព្វិន្ទតិ *ក្នុងសំឡេងទាំងឡាយផង ។បេ។*

ឃានស្មឹបិ និព្វិន្ទតិ *ក្នុងច្រមុះផង*

គន្ធេសុបិ និព្វិន្ទតិ *ក្នុងក្លិនទាំងឡាយផង ។បេ។*

ជិវ្ហាយបិ និព្វិន្ទតិ *ក្នុងអណ្តាតផង*

រសេសុបិ និព្វិន្ទតិ *ក្នុងរសទាំងឡាយផង ។បេ។*

កាយស្មឹបិ និព្វិន្ទតិ *ក្នុងកាយផង*

ផោដ្ឋព្វេសុបិ និព្វិន្ទតិ *ក្នុងផោដ្ឋព្វៈទាំងឡាយផង ។បេ។*

មនស្មឹបិ និព្វិន្ទតិ *ក្នុងចិត្តផង*

ធម្មេសុបិ និព្វិន្ទតិ *ក្នុងធម្មារម្មណ៍ទាំងឡាយផង*

មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ *នឿយណាយក្នុងមនោវិញ្ញាណផង នឿយណាយក្នុងមនោ-សម្ផស្សផង*

យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ *សេចក្តីសោយអារម្មណ៍ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី រមែងកើតឡើងអំពីបច្ច័យ គឺមនោសម្ផស្ស អរិយសាវករមែងនឿយណាយក្នុងសេចក្តីសោយអារម្មណ៍នោះឯងផង ។*

និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ *កាលបើនឿយណាយហើយ ក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក (នោះឯង) ចិត្តក៏ផុតស្រឡះចាកសេចក្តីប្រកាន់មាំ*

វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ *កាលបើចិត្តរួចស្រឡះហើយ ក៏មានញាណដឹងថា ចិត្តរបស់អញរួចស្រឡះហើយ*

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ *អរិយសាវកនោះ ដឹងច្បាស់ថា កំណើតអស់ហើយ ព្រហ្មចរិយធម៌បាននៅរួចហើយ សោឡសកិច្ចបានធ្វើរួចហើយ កិច្ចដទៃក្រៅពីសោឡសកិច្ចនេះមិនមានឡើយ ។*

ឥមស្មឹ ច បន វេយ្យាករណស្មឹ ភញ្ញមានេ តស្ស ភិក្ខុសហស្សស្ស អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ ។ *កាលព្រះមានព្រះភាគ កំពុងសម្តែងវេយ្យាករណ៍*

នេះ ចិត្តរបស់ភិក្ខុចំនួន ១.០០០ រូបនោះ ក៏ផុតចាកអាសវធម៌ទាំងឡាយ ឥតមានជាប់ចំពាក់ដោយឧបាទានឡើយ ។

ចប់ អាទិត្តបរិយាយសូត្រ ។

ក្នុងគម្ពីរសារត្ថទីបនីដីកា មានពន្យល់ក្នុងអាទិត្តបរិយាសូត្រច្រើន តែសូមស្រង់យកតែសេចក្តីខ្លះមកអធិប្បាយតទៅ :

ក្នុងអាទិត្តបរិយាយសូត្រនោះដែលឈ្មោះថា សព្វំ គ្រប់វត្ថុមាន ៤ យ៉ាងគឺ

១-សព្វសព្វំ គ្រប់វត្ថុគឺធម៌ទាំងពួង

២-អាយតនសព្វំ គ្រប់វត្ថុគឺអាយតនៈ

៣-សក្កាយសព្វំ គ្រប់វត្ថុគឺកាយរបស់ខ្លួន

៤-បទេសសព្វំ គ្រប់វត្ថុគឺចំណែកខ្លះ ។

បណ្តាគ្រប់វត្ថុទាំងពួង ៤ យ៉ាងនោះ គ្រប់វត្ថុដែលមកដូច្នេះថា :

ន តស្ស អទ្ទិដ្ឋមិធត្ថិ កិញ្ចិ អថោ អវិញ្ញាតម-ជានិតព្វំ សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ តថាគតោ

តេន សមន្តចក្ខុ ។

ហេតុនីមួយក្នុងលោកនេះ ដែលព្រះមានព្រះភាគនោះ ទ្រង់មិនឃើញ ឬថាមិនជ្រាប មិនយល់ មិនមានទេ ហេតុណាដែលត្រូវដឹង ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវហេតុ (នោះ) ទាំងអស់ ព្រោះហេតុនោះ ព្រះតថាគត ទើបឈ្មោះថា សមន្តចក្ខុ ដូច្នេះ ។ ឈ្មោះថាគ្រប់វត្ថុ គឺធម៌ទាំងពួង ។

គ្រប់វត្ថុដែលមកដូច្នេះថា សព្វំ វោ ភិក្ខវេ ទេសេស្សាមិ តំ សុណាថ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងគ្រប់វត្ថុដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់គ្រប់វត្ថុនោះ ដូច្នេះ ឈ្មោះថា គ្រប់វត្ថុគឺអាយតនៈ ។

គ្រប់វត្ថុដែលមកដូច្នេះថា សព្វធម្មមូលបរិយាយំ វោ ភិក្ខវេ ទេសេស្សាមិ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ ដែលជាបរិយាយនៃមូលរបស់ធម៌គ្រប់វត្ថុ ដូច្នេះ ឈ្មោះថា គ្រប់វត្ថុគឺកាយរបស់ខ្លួន ។

*គ្រប់វត្ថុដែលមកដូច្នេះថា សព្វធម្មេសុ វា បឋម-សមន្នាហារោ ឧប្បជ្ជតិ ចិត្តំ មនោ មានសំ តជ្ជា មនោវិញ្ញាណធាតុ : ម្យ៉ាងទៀត ការនឹកគ្រាដំបូង គឺ* ***ចិត្ត មនោ មានស មនោវិញ្ញាណធាតុ*** *ដែលកើតអំពីធម៌នោះ រមែងកើតឡើងក្នុងធម៌ គ្រប់វត្ថុដូច្នេះឈ្មោះថា គ្រប់វត្ថុគឺចំណែកខ្លះ ។*

*គ្រប់វត្ថុគឺចំណែកខ្លះត្រឹមតែជាអារម្មណ៍ ៥ ប៉ុណ្ណោះដូច្នេះ ។ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា គ្រប់វត្ថុគឺកាយរបស់ខ្លួន ។ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា គ្រប់វត្ថុគឺអាយតនៈ ។*

*ធម៌ដែលគួរដឹងយ៉ាងណាមួយ ឈ្មោះថា គ្រប់វត្ថុគឺធម៌ទាំងពួង ។*

*គ្រប់វត្ថុគឺចំណែកខ្លះមិនដល់គ្រប់វត្ថុគឺកាយរបស់ខ្លួន ព្រោះគ្រប់វត្ថុ គឺចំណែកខ្លះនោះ មិនបានរួមយកចំណែកមួយសូម្បីក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ គ្រប់វត្ថុគឺកាយរបស់ខ្លួនមិនដល់គ្រប់វត្ថុគឺអាយតនៈ ព្រោះមិនបានរួមយកលោកុត្តរធម៌ទាំងឡាយ ។ គ្រប់វត្ថុគឺអាយតនៈ មិនដល់គ្រប់វត្ថុគឺធម៌ទាំងពួង ។*

ព្រោះហេតុអ្វី ? ព្រោះលោកកំណត់កាន់យកធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ដោយគ្រប់វត្ថុគឺអាយតនៈ មិនមែនកំណត់យកលក្ខណៈនិងបញ្ញត្តិ ។ ក៏ក្នុងសូត្រនេះ ទ្រង់ប្រាថ្នាយកគ្រប់វត្ថុគឺអាយតនៈ សូម្បីយ៉ាងនោះ ក្នុងទីនេះក៏គួរកាន់យកធម៌ដែលគួរជាវិបស្សនាបានប៉ុណ្ណោះ ។

## ចក្ខុ ២ យ៉ាង

ចក្ខូតិ ទ្វេ ចក្ខូនិ ញាណចក្ខុ ចេវ មំសចក្ខុ ច

ពាក្យថា **ចក្ខុ** បានដល់ ចក្ខុ **២ យ៉ាង** គឺ ញាណចក្ខុ ១ មំសចក្ខុ ១ ។

## ញាណចក្ខុ ៥ យ៉ាង

**១-ពុទ្ធចក្ខុ** បានដល់ អាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិយត្តញ្ញាណ ដែលមកហើយថា ព្រះមានព្រះភាគទ្រង់រមិលមើលលោកដោយ **ពុទ្ធចក្ខុ** ។

**២-ធម្មចក្ខុ** បានដល់ មគ្គ ៣ និងផល ៣ ខាងក្រោម

ដែលមកហើយថា ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងហើយ ។

៣-សមន្តចក្ខុ បានដល់ ព្រះសព្វញ្ញុតញ្ញាណ ដែលមកហើយថា ទ្រង់មានព្រះសមន្តចក្ខុឡើងកាន់ប្រាសាទ ។

៤-ទិព្វចក្ខុ បានដល់ ញាណដែលកើតឡើង ដែលមកហើយថា ដោយចក្ខុដែលជាទិព្វបរិសុទ្ធ ។

៥-បញ្ញាចក្ខុ បានដល់ ញាណដែលកំណត់សច្ចៈទាំង ៤ បានដែលមកហើយថា ចក្ខុកើតឡើងហើយ ។

## មំសចក្ខុមាន ២ យ៉ាង

១- សសម្ភារចក្ខុ ២- បសាទចក្ខុ ។

បណ្ដាមំសចក្ខុទាំង ២ យ៉ាងនោះ ដុំសាច់ដែលត្របកភ្នែកព័ន្ធព័ទ្ធទុក ក្នុងរណ្ដៅភ្នែកនេះណា ដែលមានអង្គប្រកបដោយសង្ខេប ១៣ គឺ ធាតុ ៤ វណ្ណៈ ១ គន្ធៈ ១ រសៈ ១ ឱជា ១ សម្ភវៈ ១ ជីវិតរូប ១ ភាវៈ ១ ចក្ខុបសាទ ១ កាយបសាទ ១ ។ តែដោយពិស្ដារមានអង្គប្រកបដល់ ៤០ បានដល់ អង្គប្រកប ៩ ចំណែកទាំងនេះគឺ ធាតុទាំង ៤ វណ្ណៈ ១ គន្ធៈ ១ រសៈ ១ ឱជា១

*សម្ភារៈ ១ រួមជា ៣៦ ដោយអំណាចសមុដ្ឋានទាំង ៤ និងអគ្គប្រកបដទៃ ៤ មុន ដែលមានកម្មជាសមុដ្ឋានទាំងនេះគឺ ជីវិតរូប១ កាវៈ ១ ចក្ខុបសាទ ១ កាយបសាទ ១ ។ នេះឈ្មោះថា* ***សសម្ភារចក្ខុ*** *។*

*មួយទៀត ក្នុងសសម្ភារចក្ខុនោះ វត្ថុណាដែលត្រឹមតែជាសេចក្ដីថ្លា តាំងនៅក្នុងរង្វង់ដែលនឹងឃើញបាននូវរង្វង់ភ្នែកខ្មៅដែលកំណត់ដោយរង្វង់ភ្នែកសព័ទ្ធទុក អាចនឹងឃើញរូបបាន នេះឈ្មោះថា* ***បសាទចក្ខុ*** *។*

*បណ្ដាមំសចក្ខុទាំងពីរនោះ ព្រះមានព្រះភាគ ទ្រង់កាន់យកបសាទចក្ខុនេះនោះ ត្រាស់សំដៅព្រះពុទ្ធវចនៈនេះថា ចក្ខុជារបស់ក្ដៅ ដូច្នេះជាដើម ។*

*ក្នុងពាក្យទាំងឡាយមានពាក្យថា រាគគ្គិនា ជាដើម មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា អគ្គិ ដោយអត្ថថា តាមដុត ព្រោះហេតុនោះ ឈ្មោះថា រាគគ្គិ ។ ពិតមែន រាគជាធម្មជាតក្ដៅខ្លាំងក្លាកើតឡើងរមែងតាមដុតសត្វទាំងឡាយ គឺធ្វើឲ្យឆេះ ព្រោះហេតុ*

នោះទើបហៅថា អគ្គិ ។ សូម្បីក្នុងពីរបទក្រៅនេះ ក៏មានន័យដូចគ្នា ។

បណ្តាភ្លើងមានរាគៈជាដើមនោះ មានរឿងដូចតទៅនេះ ។

ភិក្ខុនីក្រមុំមួយរូបទៅកាន់ឧបោសថាគារ ឯចិត្តលបព្វតវិហារ ឈរសម្លឹងមើលរូបនាយទ្វារបាល ។ គ្រានោះ រាគៈខាងក្នុងរបស់នាងជាធម្មជាតិក្តៀវក្លាកើតឡើង, ព្រោះហេតុនោះ តេជោធាតុដែលមានរាគៈនោះជាសមុដ្ឋាន ទើបបានដុតបេះដូងព្រមជាមួយធម្មជាតិដែលកើតរួមជាមួយខ្លួន ដោយភាពជាធម្មជាតិក្តៀវក្លា ដែលទឹងប្រៀបបានដូចជាតេជោធាតុខាងក្រៅដុតទីអាស្រ័យ ។ ដោយហេតុនោះ ភិក្ខុនីនោះទើបត្រូវរាគៈដុតស្លាប់ ។ ភិក្ខុនីទាំងឡាយដើរទៅនិយាយថា "ភិក្ខុនីក្រមុំនេះឈរនៅ ទើបហៅនាងមក" ភិក្ខុនីមួយរូបទៅចាប់ត្រង់ដៃ និយាយថា "នាងឈរនៅធ្វើអ្វី" ។ គ្រាន់តែចាប់ប៉ុណ្ណោះ ភិក្ខុនីនោះក៏ដួលទៅ ។ នេះជារឿងរបស់រាគៈដែលតាមដុតមុន ។

ចំណែកក្នុងសេចក្តីដែលទោសៈតាមដុត គប្បីជ្រាបពួកមនោបទោសិកាទេវតា ។ (ពួកទេវតាទាំងនោះ រមែងចុតិ ដោយ

*អំណាចសេចក្តីក្រោធទៅវិញទៅមក) ។*

*កាលទេវបុត្រទាំង ២ ក្រោធ សេចក្តីក្រោធរបស់ទេវ-បុត្រខ្លួនឯងមួយ រមែងជាបច្ច័យដល់ទេវបុត្រក្រៅនេះ, សេចក្តីក្រោធរបស់ទេវបុត្រសូម្បីនោះ ក៏រមែងជាបច្ច័យដល់ទេវបុត្រក្រៅនេះ ព្រោះហេតុនោះ ទេវបុត្រទាំងពីរកាលផ្សំកម្លាំងសោយសោកនោះឯង ក៏រមែងចុតិ ។ ក៏ព្រោះថា កាលទេវបុត្រទាំងពីរក្រោធ សេចក្តីក្រោធដែលផ្សាយឡើងយ៉ាងក្លៀវក្លា ដោយអំណាចសេចក្តីពង្រីកទៅជុំវិញ ក្នុងគ្នានឹងគ្នា មានការដុតទីអាស្រ័យជាកិច្ច កាលកើតឡើងដុតហទយវត្ថុ រមែងញាំងករជកាយដែលល្អិតបំផុតឲ្យវិនាសទៅបាន ។ លំដាប់នោះ អត្តភាពសូម្បីទាំងអស់ រមែងអន្តរធាន ។ នេះជារឿងរាវរបស់សភាពដែលទោសៈតាមដុត ។*

*ចំណែកក្នុងសេចក្តីដែលមោហៈតាមដុត គប្បីឃើញពួកទេវតា ពួកខិឌ្ឌាបទោសិកានោះឯង ព្រោះថាការវង្វេងភ្លេចសតិនៃទេវតាខិឌ្ឌាបទោសិកាទាំងនោះ រមែងមានដោយអំណាចមោហៈ ។*

ព្រោះហេតុនោះ ទេវតាខិឌ្ឌាបទោសិកាទាំងឡាយ ញុំាងវេលាអាហារឲ្យកន្លងទៅដោយការលេង ហើយធ្វើកាលកិរិយា ។

សួរថា ទេវតាពួកណា ជាទេវតាឈ្មោះ ខិឌ្ឌាបទោសិកា ?

ឆ្លើយថា អាចារ្យពួកខ្លះពោលថា ទេវតាពួកណាមួយអាស្រ័យកពឡីការាហារចិញ្ចឹមជីវិត ។

អាចារ្យពួកខ្លះពោលថា ទេវតាទាំងនោះ ជាទេវតាជាន់និម្មានរតី និងជាន់បរនិម្មិតវសវត្តី ព្រោះទេវតាជាន់និម្មានរតីនិងជាន់បរនិម្មិតវសវត្តីទាំងនេះ លោកហៅថា **ខិឌ្ឌាបទោសិកា** ព្រោះត្រឹមតែប្រទូសរ៉ាយ ដោយការលេងប៉ុណ្ណោះ ។

ក្នុងអដ្ឋកថានោះឯង លោកពោលទុកថា ចំណែកទេវតាឈ្មោះថា មនោបទោសិកា បានដល់ ទេវតាជាន់ចាតុម្មហារាជិកា ។

ចំណែកអាចារ្យពួកខ្លះពោលថា សូម្បីទេវតា**ខិឌ្ឌាបទោ-សិកា** ក៏គឺទេវតាជាន់ចាតុម្មហារាជិកានោះឯង ។

កិលេសទាំង ៣ មានរាគៈជាដើម គប្បីជ្រាបថា ឈ្មោះថា **អគ្គិ** ភ្លើង យ៉ាងនេះមុន ដោយអត្ថថា តាមដុត ។ ចំណែកធម្មជាតិ ៣ យ៉ាង មានជាតិជាដើម ឈ្មោះថា **អគ្គិ** ភ្លើង ព្រោះ

តាមដុត ដោយជាទីតាំងនៃទុក្ខមានប្រការផ្សេងៗ ។ សេចក្តីទុក្ខមានសោកជាដើម ជាកិរិយាតាមដុត ជាក់ច្បាស់ហើយតែម្តង ។

ព្រះមានព្រះភាគ ត្រាស់ទុក្ខលក្ខណៈ ទុកក្នុងព្រះសូត្រនេះ ព្រោះបានត្រាស់សេចក្តីដែលធម្មជាតមានចក្ខុជាដើមជាទុក្ខ ដោយភាវៈជាវត្ថុដែលទ្រាំបានលំបាក ដោយភាវៈជារបស់ក្តៅក្រហាយ ដោយភ្លើង ១១ កង ដោយប្រការដូច្នេះ ។






## ១៥_ការជួបជុំរបស់ព្រះបាទពិម្ពិសារ

លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់ក្រុងរាជគ្រឹះ ។ មានសេចក្ដីដំណាលថា ព្រះមានព្រះភាគ គង់នៅក្នុងសុប្បតិដ្ឋចេតិយ ក្នុងលដ្ឋិវនឧទ្យាន (សួនច្បារត្នោត) ទៀបក្រុងរាជគ្រឹះនោះ ។

គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ បានទ្រង់ព្រះ-សណ្ដាប់ដំណឹងច្បាស់ថា ព្រះសមណគោតមដ៏ចម្រើន ជាសក្យ-បុត្រ ចេញចាកសក្យត្រកូលហើយបួស ឥឡូវយាងមកកាន់ក្រុង

រាជគ្រឹះ គង់នៅក្នុងសុប្បតិដ្ឋចេតិយ ក្នុងលដ្ឋិវនឧទ្យាន ទៀប ក្រុងរាជគ្រឹះ កិត្តិសព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ។ល។

គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ មានទាំងព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរម៉ឺនជាបរិវារ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ឯពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរម៉ឺននោះ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគ រួចហើយគង់នៅក្នុងទីដ៏សមគួរ ពួកខ្លះក៏ពោលពាក្យរីករាយជាមួយនឹងព្រះមានព្រះភាគ លុះធ្វើពាក្យគួររីករាយ គួររលឹកឲ្យសម្រេចហើយក៏អង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះក៏ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះប្រកាសនាមនិងគោត្តរបស់ខ្លួនក្នុងសំណាក់ព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ពួកខ្លះក៏ស្ងៀមអង្គុយនៅក្នុងទីដ៏សមគួរ ។

ទើបពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរម៉ឺននោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា មហាសមណៈ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ឧរុវេលកស្សបឬហ្ន៎ ឬឧរុវេ-លកស្សប ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់មហាសមណៈ ។ ឯព្រះមានព្រះភាគ ក៏ជ្រាបសេចក្តីត្រិះរិះនៃចិត្តរបស់ពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរម៉ឺននោះ ដោយព្រះហឫទ័យព្រះអង្គ ហើយទ្រង់ត្រាស់នឹងឧរុវេលកស្សបដ៏មាន-អាយុ ដោយព្រះគាថា ថា ៖

អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស តើអ្នកឃើញអ្វីបានជាលះបង់ការបូជាភ្លើងចោលចេញ ។ ម្នាលកស្សប តថាគតសួរសេចក្តីនេះនឹងអ្នក ការបូជាភ្លើងដែលអ្នកលះបង់ហើយ តើព្រោះហេតុអ្វី ។

ឧរុវេលកស្សប ក្រាបបង្គំទូលថា ជនទាំងឡាយតែងពោលសរសើរចំពោះនូវកាមទាំងឡាយ គឺរូបសំឡេងព្រមទាំងរសផងនូវស្រីទាំងឡាយផង ព្រោះការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណមានរូបជាដើមនេះ ជាគ្រឿងសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះ

ហេតុដូច្នោះខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងការបូជាតូច (គឺការគោរពភ្លើងរាល់ថ្ងៃ) ។

ព្រះមានព្រះភាគ ត្រាស់ថា ម្នាលកស្សប ចិត្តរបស់អ្នកមិនត្រេកអរហើយក្នុងកាមគុណទាំងឡាយនោះ គឺរូប សំឡេង ព្រមទាំងរស ម្នាលកស្សប ម្យ៉ាងទៀត ចិត្តរបស់អ្នកត្រេកអរក្នុងមនុស្សលោក និងទេវលោកខ្លះដែរឬ ចូរអ្នកពោលហេតុនោះមកតថាគតមើល ។

ព្រះឧរុវេលកស្សប ក្រាបបង្គំទូលថា ខ្ញុំព្រះអង្គឃើញនូវព្រះនិព្វានជារបស់ល្អិត ឥតមានឧបធិ ឥតមានសេចក្ដីខ្វល់ មិនជាប់ជំពាក់នៅក្នុងកាមភព ជាធម្មជាតពិត មិនប្រែប្រួល ជាធម្មជាត គឺបុគ្គលមិនគប្បីបានដោយហេតុដទៃ (ក្រៅពីមគ្គ) ព្រោះហេតុដូច្នោះ បានជាខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំនិងការបូជាតូច ។

លំដាប់នោះ ព្រះឧរុវេលកស្សបដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈលើស្មាម្ខាង ហើយក្រាបសិរសាទៀបព្រះបាទារបស់ព្រះមានព្រះភាគ រួចក៏បានបង្គំទូលពាក្យនេះ

នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន "ព្រះមានព្រះ-ភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក" ។

គ្រានោះ ពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរម៉ឺននោះ មានសេចក្តីត្រិះរិះដូច្នេះថា ឱរុវេលកស្សប ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់មហាសមណៈទេតើ ។

ពេលនោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីត្រិះរិះក្នុងចិត្តនៃពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់ពីរម៉ឺននោះ ដោយព្រះហឫទ័យរបស់ព្រះអង្គ រួចហើយក៏ទ្រង់សម្តែងអនុបុព្វីកថា និងទ្រង់ប្រកាសធម្មទេសនា គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលនោះ ។ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងដែនមគធៈ ចំនួនដប់មួយម៉ឺន មានព្រះបាទពិម្ពិសារជាប្រធាន លើអាសនៈនោះថា ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំង

អស់នោះ ក៏រលត់ទៅជាធម្មតាដែរ មានឧបមេយ្យដូច្នោះឯង ។ ចំណែកព្រាហ្មណ៍និងគហបតីចំនួនមួយម៉ឺនរូប ក៏ថ្វាយខ្លួនជាឧបាសក ។

ព្រះបាទមាគធសេនិយពិម្ពិសារ បានប្រកាសខ្លួន សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹកថា សូមព្រះមានព្រះភាគជាម្ចាស់ ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត ចាប់តាំងតែអំពីថ្ងៃនេះជាដើមតទៅ មិនតែប៉ុណ្ណោះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។

គ្រានោះ ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ជ្រាបថាព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ទើបក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅ ។

លំដាប់នោះ ព្រះបាទមាគធសេនិយពិម្ពិសារ លុះរាត្រីនោះកន្លងទៅហើយ ព្រះអង្គក៏ទ្រង់ឲ្យចាត់ចែងខាទនីយភោជនីយាហារ

ដ៏ឧត្តម សម្រាប់ព្រះមានព្រះភាគជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃ ។ ព្រះបាទមាគធសេនិយពិម្ពិសារ អង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តម ដោយព្រះហស្តព្រះអង្គឯង ។ រួចក៏ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយនូវឧទ្យានវេឡុវ័ននេះ ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។

ព្រះមានព្រះភាគ ក៏ទ្រង់ទទួលអារាមនោះ ។

## ១៦-បព្វជ្ជារបស់ព្រះសារីបុត្តនិងព្រះមោគ្គល្លាន

សម័យនោះឯង សញ្ជយបរិព្វាជកនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ មួយអន្លើដោយបរិព្វាជកជាបរិស័ទ គឺបរិព្វាជកចំនួន ២៥០ រូប ។ សម័យនោះឯង ព្រះសារីបុត្តនិងព្រះមោគ្គល្លាន ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់បរិព្វាជកឈ្មោះសញ្ជយ ។ ព្រះសារីបុត្តនិងព្រះមោគ្គល្លាននោះ បានធ្វើប្តេជ្ញានឹងគ្នាថា អ្នកណាបានដឹងអមតធម៌មុន អ្នកនោះគប្បីប្រាប់ដល់ម្នាក់ទៀត ។ កាលនោះ ព្រះអស្សជិដ៏មានអាយុ ស្លៀកស្បង់ប្រដាប់ដោយ

បាត្រនិងចីវរអំពីព្រឹក លោកប្រកបដោយឥរិយាបទ គឺដើរទៅដើរមក ក្រឡេកមើលទៅ ក្រឡេកមើលផ្សេងៗ បត់ដៃជើងនិងលាដៃជើង មានក្អែកសម្រួមគួរជាទីជ្រះថ្លា ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ បរិព្វាជកឈ្មោះសារីបុត្ត បានឃើញនូវព្រះអស្សជិដ៏មានអាយុ កំពុងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជ-គ្រឹះ បរិបូណ៌ដោយឥរិយាបថ គឺដើរទៅដើរមក ក្រឡេកមើលទៅក្រឡេកមើលផ្សេងៗ បត់ដៃជើងនិងលាដៃជើង មានក្អែកសម្រួមគួរជាទីជ្រះថ្លា លុះឃើញហើយក៏មានសេចក្ដីត្រិះរិះដូច្នេះថា "ឱហ្ន៎ ជនទាំងឡាយណា ជាអរហន្តក្ដី បានដល់ហើយនូវអរហត្តមគ្គក្ដីក្នុងលោក ភិក្ខុនេះក៏ប្រហែលជាពួកនៃជនទាំងនោះដែរ បើដូច្នោះគួរតែអញចូលទៅរកភិក្ខុនេះហើយសួរថា ម្នាលលោកដ៏មានអាយុលោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក ឬលោកនេះឯងគាប់ចិត្តធម៌របស់អ្នកណា" ។ លំដាប់នោះសារីបុត្តបរិព្វាជក មានសេចក្ដីត្រិះរិះដូច្នេះថា "កាលនេះជាកាលមិនគួរដើម្បីសួរនូវភិក្ខុនេះឡើយ (ព្រោះ) ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះផ្ទះត្រាច់ទៅដើម្បីបិណ្ឌបាត" បើដូច្នោះ គួរតែអញទៅ

តាមភិក្ខុនេះអំពីក្រោយៗ ទៅចុះ ក៏ការដែលជាប់តាមភិក្ខុនេះឯង គង់ដឹងនូវមគ្គញាណដែលជនទាំងឡាយគេត្រូវការដឹង ឬភិក្ខុនេះ ឯង ជាអ្នកស្វែងរកនូវព្រះនិព្វានដែលជនទាំងឡាយគេត្រូវការដឹងៗ ឯព្រះអស្សជិដ៏មានអាយុ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជ-គ្រឹះ ទទួលបិណ្ឌបាតហើយក៏ត្រឡប់មកវិញ ។ បរិព្វាជកឈ្មោះ សារីបុត្ត ក៏ចូលទៅកាន់សំណាក់ព្រះអស្សជិដ៏មានអាយុ ក្នុងកាល នោះ លុះចូលទៅជិតហើយ ធ្វើសេចក្តីរីករាយជាមួយនឹងព្រះ-អស្សជិដ៏មានអាយុ ហើយពោលនូវពាក្យជាទីត្រេកអរ ជាទីរលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលគ្នាបាន លុះសម្រេចកិច្ចនោះហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ។ លុះបរិព្វាជកឈ្មោះសារីបុត្ត ឋិតនៅក្នុង ទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងព្រះអស្សជិដ៏មានអាយុ ថា ម្នាលលោកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់លោកក៏ ស្រស់បស់ សម្បុរស្បែករបស់លោកក៏ស្អាតផូរផង់ ម្នាលលោក ដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូ របស់លោក ឬនលោកនេះឯង ពេញចិត្តធម៌របស់អ្នកណា ។ ព្រះអស្សជិឆ្លើយថា ម្នាលអាវុសោ មានមហាសមណៈ (មួយ

ព្រះអង្គ) ជាសក្យបុត្រ ចេញចាកសក្យត្រកូលហើយទ្រង់ព្រះផ្នួស ខ្ញុំឯងក៏បួសតាមព្រះមហាសមណៈដ៏មានព្រះភាគនោះ ឯព្រះដ៏មានព្រះភាគនោះឯង ជាគ្រូរបស់អាត្មា ចំណែកអាត្មាក៏គាប់ចិត្តនូវធម៌អាថ៌របស់ព្រះមានព្រះភាគនោះ ។ បរិព្វាជកឈ្មោះសារីបុត្តសួរថា ចុះគ្រូរបស់លោកម្ចាស់ពោលពាក្យដូចម្ដេច សម្ដែងធម៌ដូចម្ដេច ? ព្រះអស្សជិឆ្លើយថា នៃអ្នកដ៏មានអាយុ អាត្មាឯងជាភិក្ខុថ្មី ទើបនឹងបួស មកកាន់ធម្មវិន័យនេះថ្មីៗ អាត្មាមិនអាចដើម្បីនឹងសម្ដែងធម៌ដោយពិស្ដារបានទេ តែថាអាត្មា នឹងពោលនូវសេចក្ដីដល់អ្នកដោយសង្ខេបបាន ។

បរិព្វាជកឈ្មោះសារីបុត្ត ឆ្លើយថា សូមលោកម្ចាស់សម្ដែងធម៌តិចក្ដី ច្រើនក្ដី សូមសម្ដែងតែទំនងសេចក្ដីម្យ៉ាងដល់ខ្ញុំៗ ត្រូវការដោយទំនងសេចក្ដីតែម្យ៉ាងទេ លោកម្ចាស់មិនបាច់ពោលព្យញ្ជនៈឲ្យច្រើនឡើយ ។

គ្រានោះ ព្រះអស្សជិដ៏មានអាយុ បានពោលនូវធម្មបរិយាយនេះ ដល់បរិព្វាជកឈ្មោះសារីបុត្ត ថា ៖

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ

តេសញ្ច យោ និរោធោ ឯវំវាទី មហាសមណោតិ

*ធម៌ទាំងឡាយ គឺខន្ធ ៥ តែងកើតអំពីហេតុ ព្រះតថាគត ពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀត សេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយណា ព្រះតថាគតពោលនូវសេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះ ព្រះមហាសមណៈ មានប្រក្រតីពោលពាក្យយ៉ាងនេះ ។*

*កាលនោះ បរិព្វាជកឈ្មោះសារីបុត្ត លុះបានស្តាប់ធម្មបរិយាយនេះហើយក៏មានធម្មចក្ខុ គឺសោតាបត្តិមគ្គញ្ញាណ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ។*

*<u>ក្នុងដីកា</u> ភាគ៣ លោកពោលក្នុងពាក្យនេះថា* ***កាលបានស្តាប់ធម្មបរិយាយនេះ ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិលបានកើតឡើង*** *មានសេចក្តីថា បរិព្វាជកបានស្តាប់ពីរបាទដំបូងប៉ុណ្ណោះ ក៏បានតាំងនៅក្នុងសោតាបត្តិផល ដល់ព្រមដោយន័យ*

១,០០០ ។ ពីរបាទក្រៅនេះគប្បីជ្រាបថា ចុះក្នុងកាលដែលជាព្រះសោតាបន្ន ។ (ចាក សារត្ថទីបនីដីកា)

ក្នុងព្រះវិន័យបិដក ៖

ឯសេវ ធម្មោ យទិ តាវទេវ បច្ចព្យថា បទមសោកំ

អទិដ្ឋំ អព្ភតីតំ ពហុកេហិ កប្បនហុតេហីតិ ។

សារីបុត្តបរិព្វាជក ពោលថា និព្វានធម៌នេះមានប្រាកដមែន លោកម្ចាស់បានត្រាស់ដឹងនិព្វាន ដែលគ្មានសេចក្ដីសោក ព្រះនិព្វាននោះខ្ញុំមិនដែលបានឃើញ មិនដែលបានជួបប្រទះឡើយ ដោយម៉ឺននៃកប្បទាំងឡាយដ៏ច្រើន ។

គ្រានោះ បរិព្វាជកឈ្មោះសារីបុត្ត ចូលទៅរកបរិព្វាជកឈ្មោះមោគ្គល្លាន ។ បរិព្វាជកឈ្មោះមោគ្គល្លាន បានឃើញបរិព្វាជកឈ្មោះសារីបុត្តកំពុងដើរមកពីចម្ងាយ លុះឃើញហើយក៏បានពោលពាក្យនេះនឹងបរិព្វាជកឈ្មោះសារីបុត្តថា ម្នាលអ្នកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់អ្នកស្រស់បស់អីម្ល៉េះ សម្បុរស្បែករបស់អ្នកក៏ស្អាតផូរផង់ ម្នាលអ្នកដ៏មានអាយុ អ្នកបានដឹងនូវអមតធម៌ហើយឬ ? បរិព្វាជកឈ្មោះសារីបុត្ត ឆ្លើយថា អើ

អ្នកដ៏មានអាយុ ខ្ញុំបានដឹងអមតធម៌ហើយ ។ បរិព្វាជកឈ្មោះមោគ្គល្លាន សួរថា អ្នកបានដឹងអមតធម៌ដូចម្តេច ? បរិព្វាជកឈ្មោះសារីបុត្ត ឆ្លើយថា នែអាវុសោ ខ្ញុំបានឃើញភិក្ខុឈ្មោះអស្សជិ កំពុងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ប្រកបដោយឥរិយាបថ គឺដើរទៅដើរមក ក្រឡេកមើលទៅ ក្រឡេកមើលផ្សេងៗ បត់ដៃជើងនិងលាដៃជើង មានភ្នែកសង្រួម គួរជាទីជ្រះថ្លា លុះឃើញហើយក៏មានសេចក្តីត្រិះរិះដូច្នេះថា "ឱហ្ន៎ ជនទាំងឡាយណាជាអរហន្តក្តី បានដល់ហើយនូវអរហត្តមគ្គក្តី ក្នុងលោក ភិក្ខុនេះក៏ប្រហែលជាពួកនៃជនទាំងនោះដែរ បើដូច្នោះគួរតែអញចូលទៅរកភិក្ខុនេះហើយសួរថា ម្នាលលោកដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក លោកគាប់ចិត្តធម៌របស់អ្នកណា", នែអ្នកដ៏មានអាយុ ខ្ញុំឯងក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា "កាលនេះជាកាលមិនគួរដើម្បីសួរនូវភិក្ខុនេះទេ (ព្រោះ) ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះផ្ទះត្រាច់ទៅដើម្បីបិណ្ឌបាត" បើដូច្នោះគួរតែអញទៅតាមភិក្ខុនេះអំពីក្រោយៗទៅចុះ ក៏ការដែលជាប់តាមភិក្ខុនេះឯង គង់ដឹងនូវមគ្គញាណ

ដែលជនទាំងឡាយគេត្រូវការដឹង ឬភិក្ខុនេះឯងជាអ្នកស្វែងរកនូវព្រះនិព្វានដែលជនទាំងឡាយគេត្រូវការដឹង, នែអ្នកដ៏មានអាយុ ពេលនោះអស្សជិភិក្ខុ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ហើយកាន់យកបិណ្ឌបាតត្រឡប់មកវិញ, នែអ្នកដ៏មានអាយុ ខ្ញុំក៏ចូលទៅកាន់សំណាក់អស្សជិភិក្ខុនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរីករាយជាមួយនឹងអស្សជិភិក្ខុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធ-ស្នាលគ្នាហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ, នែអ្នកដ៏មានអាយុ លុះខ្ញុំឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងអស្សជិភិក្ខុថា "ម្នាលលោកដ៏មានអាយុ ឥន្ទ្រិយទាំងឡាយរបស់លោកក៏ស្រស់បស់ សម្បុរស្បែករបស់លោកក៏បរិសុទ្ធផូរផង់ ម្នាលលោកដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀត អ្នកណាជាគ្រូរបស់លោក លោកពេញចិត្តធម៌របស់អ្នកណា" ? អស្សជិភិក្ខុឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មានមហាសមណៈ (មួយព្រះអង្គ) ជាសក្យបុត្ត ចេញចាកសក្យត្រកូលហើយទ្រង់ព្រះផ្នួស អាត្មាក៏បួសតាមព្រះមហាសមណៈដ៏មានព្រះភាគនោះ ឯព្រះដ៏មាន-

ព្រះភាគនោះឯង ជាគ្រូរបស់អាត្មា ចំណែកអាត្មា ក៏គាប់ចិត្តនូវធម៌អាថ៌របស់ព្រះដ៏មានព្រះភាគនោះ, (ហើយខ្ញុំសួរទៀត) ថា ចុះគ្រូរបស់លោកម្ចាស់មានប្រក្រតីពោលពាក្យដូចម្តេច សម្តែងធម៌ដូចម្តេច ? ទើបអស្សជិភិក្ខុ ឆ្លើយថា នែអ្នកដ៏មានអាយុ អាត្មាឯងជាភិក្ខុថ្មី ទើបនឹងបួស មកកាន់ធម្មវិន័យនេះថ្មីៗ អាត្មាមិនអាចដើម្បីនឹងសម្តែងធម៌ដោយពិស្តារបានទេ តែថាអាត្មានឹងពោលនូវទំនងសេចក្តីដល់អ្នក ដោយសង្ខេបបាន, (ខ្ញុំក៏និយាយទៅនឹងអស្សជិភិក្ខុនោះ) ថា សូមលោកម្ចាស់សម្តែងធម៌តិចក្តី ច្រើនក្តី សូមសម្តែងតែទំនងសេចក្តីម្យ៉ាងដល់ខ្ញុំៗ ត្រូវការដោយទំនងសេចក្តីតែម្យ៉ាងទេ លោកម្ចាស់មិនបាច់ពោលព្យញ្ជនៈឲ្យច្រើនឡើយ ។

ម្នាលអ្នកដ៏មានអាយុ អស្សជិភិក្ខុ ក៏បានពោលនូវធម្មបរិយាយនេះ ក្នុងកាលនោះ ថា ៖

ធម៌ទាំងឡាយ គឺខន្ធ ៥ តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀត សេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយណា ព្រះ

តថាគតពោលនូវសេចក្ដីរលត់ និងឧបាយជាគ្រឿងរលត់ នៃធម៌ទាំងឡាយនោះ ព្រះមហាសមណៈ មានប្រក្រតីពោលពាក្យយ៉ាងនេះ ។

កាលនោះ បរិព្វាជកឈ្មោះមោគ្គល្លាន លុះបានស្ដាប់ធម្មបរិយាយនេះហើយ ក៏មានធម្មចក្ខុ គឺសោតាបត្តិមគ្គញ្ញាណ, ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងក្នុងចិត្តថា ធម្មជាតណាមួយ ដែលមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។

ទើបបរិព្វាជកឈ្មោះមោគ្គល្លាន ពោលថា និព្វានធម៌នេះ មានប្រាកដមែន លោកម្ចាស់បានត្រាស់ដឹងព្រះនិព្វាន ដែលគ្មានសេចក្ដីសោក ព្រះនិព្វាននោះខ្ញុំមិនដែលបានឃើញ មិនដែលបានជួបប្រទះឡើយ ដោយម៉ឺននៃកប្បទាំងឡាយដ៏ច្រើន ។

បរិព្វាជកឈ្មោះមោគ្គល្លាន បានពោលពាក្យនេះទៅនឹងបរិព្វាជកឈ្មោះសារីបុត្ត ក្នុងកាលនោះថា ម្នាលអ្នកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះមានព្រះភាគៗ នោះជាគ្រូរបស់យើង ។ បរិព្វាជកឈ្មោះសារីបុត្ត ឆ្លើយថា ម្នាលអ្នកដ៏មាន

អាយុ បរិព្វាជកចំនួន ២៥០ រូបនេះឯង អាស្រ័យយើងទាំងឡាយ បានឃើញនូវយើងទាំងឡាយ ទើបនៅក្នុងទីនេះបាន យើងទាំងឡាយត្រូវលាពួកបរិព្វាជកទាំងនោះសិន ពួកបរិព្វាជកទាំងនោះនឹងយល់យ៉ាងណា គេក៏ធ្វើយ៉ាងនោះចុះ ។ កាលនោះ សារីបុត្តនិងមោគ្គល្លាន ក៏ចូលទៅរកពួកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយក៏បានពោលពាក្យនេះ ទៅនឹងពួកបរិព្វាជកទាំងនោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះមានព្រះភាគៗ នោះជាគ្រូរបស់យើងទាំងឡាយ ។ ពួកបរិព្វាជកទាំងនោះ ឆ្លើយថា យើងទាំងឡាយអាស្រ័យនូវលោកទាំងឡាយដ៏មានអាយុ បានឃើញនូវលោកទាំងឡាយដ៏មានអាយុ ទើបនៅក្នុងទីនេះបាន បើលោកទាំងឡាយដ៏មានអាយុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈ យើងទាំងឡាយទាំងអស់គ្នា ក៏នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមហាសមណៈដែរ ។ លំដាប់នោះ សារីបុត្តនិងមោគ្គល្លាន ក៏ចូលទៅរកបរិព្វាជកឈ្មោះសញ្ជ័យ លុះចូលទៅដល់ហើយក៏បានពោលនូវពាក្យនេះនឹងបរិព្វាជកឈ្មោះសញ្ជ័យថា ម្នាលលោក

ដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះមានព្រះ-ភាគៗ នោះជាគ្រូរបស់យើងទាំងឡាយ ។ បរិព្វាជកឈ្មោះសញ្ជ័យ ឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មិនគួរទេ អ្នកទាំងឡាយកុំទៅឡើយ ពួកយើងទាំង ៣ នាក់នឹងគ្រប់គ្រងរក្សាគណៈនេះ ។ សារីបុត្តនិងមោគ្គល្លាន បានពោលពាក្យនេះនឹងបរិព្វាជកឈ្មោះសញ្ជ័យអស់វារៈពីរដងផង ។បេ។ អស់វារៈបីដងផងថា ម្នាលលោកដ៏មានអាយុ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះ-មានព្រះភាគៗ នោះជាគ្រូរបស់យើងទាំងឡាយ ។ បរិព្វាជកឈ្មោះសញ្ជ័យ ឆ្លើយថា ម្នាលអ្នកដ៏មានអាយុ មិនគួរទេ អ្នកទាំងឡាយ កុំទៅឡើយ ពួកយើងទាំង ៣ នាក់នឹងគ្រប់គ្រងរក្សាគណៈនេះ ។ គ្រានោះ សារីបុត្តនិងមោគ្គល្លាន ក៏នាំបរិព្វាជកចំនួន ២៥០ រូបនោះ ចូលទៅកាន់វត្តវេឡុវ័ន ។ ចំណែកខាងបរិព្វាជកឈ្មោះសញ្ជ័យ ក៏ (មានសេចក្តីទោមនស្សជុតឡើង) បណ្តាលឲ្យក្តៅក្រហាយ រហូតដល់ក្អួតឈាមចេញអំពីមាត់ ក្នុងទីនោះ ។

ព្រះមានព្រះភាគ បានទតឃើញសារីបុត្ត និងមោគ្គល្លាន កំពុងដើរមកអំពីចម្ងាយ លុះទតឃើញហើយ ក៏ទ្រង់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជនជាសម្លាញ់នឹងគ្នាទាំងពីរនាក់នុ៎ះ ឈ្មោះកោលិតៈ ១ ឈ្មោះឧបតិស្សៈ ១ នឹងមកដល់ឥឡូវហើយ ហ្នឹងហើយជាគូនៃសាវករបស់តថាគតដែលជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ។

គម្ភីរេ ញាណវិសយេ អនុត្តរេ ឧបធិសង្ខយេ
វិមុត្តេ អប្បត្តេ វេឡុវនំ អថ នេ សត្ថា ព្យាកាសិ ។
ឯតេ ទ្វេ សហាយកា អាគច្ឆន្តិ កោលិតោ ឧបតិស្សោ ច
ឯតំ មេ សាវកយុគំ ភវិស្សតិ អគ្គំ ភទ្ទយុគន្តិ ។

ពេលនោះ ព្រះសាស្តាទ្រង់ព្យាករនូវជនទាំងពីរនោះ ដែលមានចិត្តយាងចុះក្នុងធម៌ដ៏ជ្រាលជ្រៅ ក្នុងញាណវិស័យ ក្នុងធម៌ជាគ្រឿងអស់ទៅនៃឧបធិដ៏ប្រសើរ (ព្រះនិព្វាន) តាំងតែពីមិនទាន់មកដល់វត្តវេឡុវនថា ជនទាំងពីរនាក់ជាសម្លាញ់នឹងគ្នានុ៎ះ ឈ្មោះកោលិតៈ ១ ឈ្មោះឧបតិស្សៈ ១ នឹងមក

ដល់ឥឡូវហើយ ហ្នឹងហើយជាគូនៃសាវ័ករបស់តថាគត ដែលជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ។

គ្រានោះ ព្រះសារីបុត្តនិងព្រះមោគ្គលាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបសិរសាទៀបព្រះបាទទាំងគូនៃព្រះមានព្រះភាគ ហើយបានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យើងទាំងឡាយគប្បីបានបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគបានត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមកចុះ" ហើយទ្រង់ត្រាស់ថា "ធម៌តថាគតសម្តែងហើយដោយប្រពៃ អ្នកទាំងឡាយចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះ-និព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ" ។ ព្រះពុទ្ធដីកានោះឯង ជាឧបសម្បទារបស់លោកដ៏មានអាយុទាំងនោះ ។

(ចាក ព្រះវិនយបិដក ៦, ១២០-១៣១)

## អដ្ឋកថា ពន្យល់ថា

បទថា **សារីបុត្តមោគ្គល្លានា** បានដល់ ព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ លោកទាំង ២ បានធ្វើកតិកាគ្នាទុកថា អ្នកណា

ដឹងនូវអមតធម៌មុន អ្នកនោះចូរប្រាប់ដល់អ្នកម្នាក់ទៀត ។

បានឮថា លោកទាំង ២ នោះ ក្នុងកាលនៅជាគ្រហស្ថ មានឈ្មោះប្រាកដយ៉ាងនេះថា ឧបតិស្សៈ កោលិតៈ មានមាណព ២៥០ ជាបរិវារ បានទៅមើលមហោស្រពដែលមាននៅលើកំពូលភ្នំ ។ សម្លាញ់ទាំងពីរឃើញមហាជនក្នុងទីនោះ ហើយបានពិចារណាថា ដែលឈ្មោះថា ពួកមហាជនយ៉ាងនេះៗ មិនទាន់ដល់ ១០០ ឆ្នាំផង ក៏នឹងធ្លាក់នៅក្នុងមាត់នៃសេចក្ដីស្លាប់ ។

លំដាប់នោះ សម្លាញ់ទាំង ២ កាលបរិស័ទក្រោកឡើងហើយ បានសាកសួរគ្នានឹងគ្នាមានអធ្យាស្រ័យរួមគ្នា មានសេចក្ដីសម្គាល់ថា សេចក្ដីស្លាប់ប្រាកដចំពោះមុខ ប្រឹក្សាគ្នាថា "ម្នាលសម្លាញ់ កាលសេចក្ដីស្លាប់មាន ធម៌ដែលមិនស្លាប់ ក៏មានដែរ ។ ណ្ហើយចុះ យើងស្វែងរកធម៌ដែលមិនស្លាប់ចុះ" ដូច្នេះ ។

ដើម្បីស្វែងរកធម៌ដែលមិនស្លាប់ ទើបបួសក្នុងសំណាក់សញ្ជយបរិព្វាជក ជាអ្នកស្លៀកសំពត់ព្រមដោយបរិស័ទ មិនប៉ុន្មានថ្ងៃ ក៏ដល់ត្រើយក្នុងលទ្ធិសម័យ ដែលជាវិស័យនៃញាណ

របស់សញ្ជ័យនោះ ។ កាលមើលមិនឃើញអមតធម៌ ទើបសួរថា "លោកអាចារ្យ ខ្ញុំសូមសួរខ្លឹមសារសូម្បីដទៃក្នុងបព្វជ្ជានេះ តើនឹងនៅមានតទៅទៀតឬ ?"

បានស្ដាប់ពាក្យឆ្លើយតបរបស់លោកថា "មិនមានទេ អ្នកមានអាយុ" និងថា "លទ្ធិនេះមានប៉ុណ្ណេះឯង" ។

ទើបធ្វើកតិកាទុកថា អ្នកមានអាយុ លទ្ធិនេះទទេ មិនមានខ្លឹមសារ ពេលនេះ បណ្ដាពួកយើង អ្នកណាដឹងនូវអមតធម៌មុន អ្នកនោះចូរប្រាប់ដល់ម្នាក់ទៀត ។

ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលពាក្យជាដើមថា លោកទាំង ២ បានធ្វើកតិកាគ្នាទុក ។

ពាក្យនេះថា **អត្ថិកេហិ ឧបញ្ញាតំ មគ្គំ** ជាពាក្យសម្ដែងហេតុការជាប់តាម ។ ពិតមែន មានពាក្យដែលលោកអធិប្បាយទុកដូច្នេះថា បើដូច្នោះ យើងគប្បីតាមកិច្ចនេះទៅខាងក្រោយៗ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ធម្មតាការជាប់តាមទៅខាងក្រោយៗ នេះជាផ្លូវដែលអ្នកមានសេចក្ដីត្រូវការទាំងឡាយដឹង

ច្បាស់ហើយ អធិប្បាយថា ជាផ្លូវដែលជនទាំងឡាយ អ្នកមានសេចក្តីត្រូវការដឹងហើយ នឹងដើរចូលទៅរកហើយ ។

ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងពាក្យនេះ យ៉ាងនេះថា ដែលឈ្មោះថា និព្វានដែលយើងទាំងឡាយ អ្នកមានសេចក្តីត្រូវការដឹងច្បាស់ហើយថា មានពិតប្រាកដដោយអនុមតិ យ៉ាងនេះថា "កាលសេចក្តីស្លាប់មាន ធម៌ដែលមិនស្លាប់ក៏ត្រូវមានដែរ" បើដូច្នោះ យើងកាលស្វែងរក គឺកាលស្រាវជ្រាវរកនិព្វាននោះ គប្បីជាប់តាមកិក្ខុនេះទៅខាងក្រោយៗ ។

ប្រែបទថា **បិណ្ឌបាតំ អាទាយ បដិក្កមិ** មានសេចក្តីថា ព្រះអស្សជិដ៏មានអាយុ ចូលទៅអង្គុយប្របជញ្ជាំងសាលាមួយ ដែលមានសេចក្តីដូចពោលហើយក្នុងសុទិន្នកណ្ឌ ។ សូម្បីសារីបុត្តក៏ឈររង់ចាំវេលាថា មិនមែនជាវេលាដែលត្រូវសួរបញ្ហាទេ ដើម្បីនឹងបំពេញវត្តបដិបត្តិ ទើបថ្វាយទឹកអំពីកំសៀវរបស់ខ្លួន ដល់ព្រះថេរៈដែលសម្រេចភត្តកិច្ចហើយ ធ្វើបដិសណ្ឋារៈ នឹងព្រះថេរៈដែលលាងដៃនិងជើងហើយ ទើបសួរបញ្ហា ។ ព្រោះហេតុនោះ

ទើបព្រះធម្មសង្គាហកាចារ្យពោលថា **អថ ខោ សារីបុត្តោ បរិព្វាជកោ** ជាដើម ។

ពីរបទថា **ន តាហំ សក្កោមិ** កាត់បទថា **ន តេ អហំ សក្កោមិ** : សម្រាប់លោក អាត្មាមិនអាច (សម្តែងឲ្យពិស្តារទេ) ។

ប៉ុន្តែថា ព្រះថេរៈដល់បដិសម្ភិទាញាណក្នុងធម្មវិន័យនេះ នឹងមិនអាចសម្តែងធម៌ត្រឹមតែប៉ុណ្ណោះក៏ទេ តាមការពិត លោកគិតថា យើងនឹងបណ្តុះសេចក្តីគោរពក្នុងធម៌ដល់អ្នកនេះ បានកាន់យកសេចក្តីដែលជាការសម្តែងធម៌ ក្នុងពុទ្ធវិស័យដោយអាការទាំងពួងមិនមែនវិស័យរបស់លោក ទើបពោលយ៉ាងនោះ ។

បាទគាថាថា **យេ ធម្មា ហេតុប្បភវា** បានសេចក្តីថា បញ្ចក្ខន្ធ ឈ្មោះថា ធម៌មានហេតុជាដែនកើត ។ ព្រះថេរៈសម្តែងទុក្ខសច្ចៈដល់សារីបុត្តនោះ ដោយពាក្យនេះ ។

បាទគាថាថា **តេសំ ហេតុំ តថាគតោ (អាហ)** បានសេចក្តីថា សមុទយសច្ចៈ ឈ្មោះថា ជាហេតុនៃបញ្ចក្ខន្ធនោះ ព្រះថេរៈសម្តែងថា ព្រះតថាគតត្រាស់សមុទយសច្ចៈនោះឯង ។

បាទគាថា ថា **តេសញ្ច យោ និរោធោ** បានសេចក្ដីថា ព្រះតថាគតត្រាស់សេចក្ដីរលត់ គឺសេចក្ដីមិនប្រព្រឹត្តទៅនៃសច្ចៈសូម្បីទាំងពីរនោះផង ។ ព្រះថេរៈសម្ដែងនិរោធសច្ចៈ ដល់សារីបុត្តនោះ ដោយពាក្យនោះ ។ ចំណែកមគ្គសច្ចៈ សូម្បីលោកមិនបានសម្ដែងរួមទុកក្នុងគាថានេះ ក៏ឈ្មោះថា សម្ដែងហើយដោយន័យ។ ព្រោះថា ការពោលនិរោធ មគ្គដែលជាហេតុឲ្យដល់និរោធនោះ ក៏ឈ្មោះថា ពោលហើយដែរ ។

ម្យ៉ាងទៀត ក្នុងបាទគាថាថា **តេសញ្ច យោ និរោធោ** នេះសូម្បីសច្ចៈទាំងពីរ ឈ្មោះថា ព្រះថេរៈសម្ដែងហើយយ៉ាងនេះថា សេចក្ដីរលត់នៃសច្ចៈទាំងពីរនោះ និងឧបាយនៃសេចក្ដីរលត់នៃសច្ចៈទាំងពីរនោះដូច្នេះឯង ។ (អដ្ឋកថា)

ឥឡូវនេះ ព្រះថេរៈកាលនឹងញ៉ាំងសេចក្ដីនោះឯងឲ្យជាប់តគ្នា ទើបពោលថា ព្រះមហាសមណៈមានប្រក្រតីត្រាស់យ៉ាងនេះ ។

បាទគាថាថា **ឯសេវ ធម្មោ យទិ តាវទេវ** មានសេចក្ដីថា ប្រសិនបើធម៌ដ៏ក្រៃលែងជាងនេះមិនមាន ធម៌ត្រឹមតែប៉ុណ្ណេះ គឺគុណប៉ុណ្ណេះ កំណត់ប្រមាណថា សោតាបត្តិផលនេះប៉ុណ្ណោះ

ដែលខ្ញុំព្រះករុណាគប្បីសម្រេចយ៉ាងនោះ ធម៌នេះឯង ដែលខ្ញុំព្រះករុណាស្វែងរកហើយ ។

បាទគាថាថា **បច្ចព្យថា បទមសោកំ** មានសេចក្ដីថា ពួកខ្ញុំព្រះករុណា ត្រាច់ស្វែងរកផ្លូវដែលមិនមានសេចក្ដីសោកណា លោកទាំងឡាយនុ៎ះឯង រមែងត្រាស់ដឹងផ្លូវដែលមិនមានសេចក្ដីសោកនោះ អធិប្បាយថា ផ្លូវនោះដែលលោកទាំងឡាយសម្រេចហើយ ។

កន្លះគាថាថា **អទិដ្ឋំ អព្ភតីតំ ពហុកេហិ កប្បនហុតេហិ** មានសេចក្ដីថា ផ្លូវដែលមិនមានសេចក្ដីសោកនេះ ឈ្មោះថា ដែលខ្ញុំព្រះករុណាទាំងឡាយ មិនដែលបានឃើញហើយ មិនដែលបានជួបប្រទះ អស់ម៉ឺននៃកប្បច្រើន សារីបុត្តបរិព្វាជក សម្ដែងនូវភាវៈនៃខ្លួនមានសេចក្ដីសាបសូន្យធំ របូតដល់អស់កាលយូរ ព្រោះហេតុដែលមិនបានឃើញផ្លូវនោះ ដោយប្រការដូច្នេះ ។

បាទគាថាថា **គម្ភីរេ ញាណវិសយេ** មានសេចក្ដីថា ជាធម៌ដែលជ្រាលជ្រៅផង ជាវិស័យនៃញាណដ៏ជ្រាលជ្រៅផង ។

*បាទគាថាថា **អនុត្តរេ ឧបធិសង្ខយេ** បានដល់ ព្រះនិព្វាន។*

*បទថា **វិមុត្តេ** មានសេចក្តីថា អ្នកនោះផុតហើយដោយវិមុត្តិ មានព្រះនិព្វាននោះជាអារម្មណ៍ ។*

*បទថា **ព្យាកាសិ** មានសេចក្តីថា ព្រះសាស្តាកាលត្រាស់ថា "**ឯតំ មេ សាវកយុគំ ភវិស្សតិ អគ្គំ ភទ្ទយុគំ :** ហ្នឹងហើយជាគូនៃសាវករបស់តថាគត ដែលជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន" ដូច្នេះ ឈ្មោះថា ទ្រង់ព្យាករណ៍ហើយនូវគូនៃសាវក-បារមីញាណ ។*

*ពាក្យថា **សា វ តេសំ អាយស្មន្តានំ ឧបសម្បទា អហោសិ** មានសេចក្តីថា ឯហិភិក្ខុឧបសម្បទានោះឯង បានជាឧបសម្បទារបស់អ្នកទាំង ២ ព្រមទាំងបរិស័ទ ។*

*ក៏ឯបណ្តាព្រះថេរៈទាំង ២ ដែលឧបសម្បទាហើយយ៉ាងនោះ ព្រះមហាមោគ្គល្លានត្ថេរ ៧ ថ្ងៃ ទើបបានសម្រេចព្រះអរហត្ត ព្រះសារីបុត្តត្ថេរ កន្លះខែ ទើបបានសម្រេចព្រះអរហត្ត ។*

បានឮថា ក្នុងអតីតកាល ព្រះពុទ្ធព្រះនាមអនោមទស្សី ស្តេចឧប្បត្តិឡើងក្នុងលោក ។ តាបសឈ្មោះសារទៈ ធ្វើមណ្ឌប ដោយផ្កាឈើផ្សេងៗ ក្នុងអាស្រមរបស់ខ្លួន ដើម្បីព្រះពុទ្ធអង្គនោះ យាងព្រះមានព្រះភាគ ឲ្យប្រថាប់លើអាសនៈផ្កាឈើនោះ ធ្វើមណ្ឌបយ៉ាងនោះឯង តាក់តែងអាសនៈផ្កាឈើ សម្រាប់ភិក្ខុសង្ឃផង ហើយប្រាថ្នាជាអគ្គសាវក ក៏ឯគ្រាប្រាថ្នាហើយ ទើបបញ្ជូនដំណឹងទៅប្រាប់ដល់សេដ្ឋីឈ្មោះសិរីវឌ្ឍនៈថា "ខ្ញុំបានប្រាថ្នាតំណែងអគ្គសាវកហើយ សូម្បីលោកក៏ចូរមកប្រាថ្នាតំណែងមួយ" ។ សេដ្ឋីធ្វើមណ្ឌបផ្កាឧប្បលខៀវ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឆាន់ក្នុងមណ្ឌបនោះ កាលនិមន្តឆាន់រួចស្រេចហើយ បានប្រាថ្នាជាសាវកទី ២, បណ្តាជនទាំង ២ នោះ សារទតាបសបានជាព្រះសារីបុត្តត្ថេរ សិរីវឌ្ឍនសេដ្ឋី បានជាព្រះមហាមោគ្គល្លានត្ថេរ ដូច្នេះឯង បុព្វកម្មរបស់ព្រះអគ្គសាវកទាំង ២ នោះប៉ុណ្ណោះ ។

## ១៧.កុលបុត្រអ្នកដែនមគធៈបួស

សម័យមួយ កុលបុត្រទាំងឡាយនៅក្នុងដែនមគធៈ ដែលមានកេរ្តិ៍ឈ្មោះ គេដឹងឮគ្រប់គ្នា ក៏តែងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ ។ មនុស្សទាំងឡាយពោលទោសតិះដៀល បន្ទុះបង្អាប់ថា សមណគោតមប្រតិបត្តិដើម្បីធ្វើមនុស្សមិនឲ្យមានកូន សមណគោតមប្រតិបត្តិដើម្បីធ្វើឲ្យស្រីទៅជាមេម៉ាយ សមណគោតមប្រតិបត្តិដើម្បីផ្តាច់បង់ត្រកូល ឥឡូវគាត់បំបួសជដិលចំនួនមួយពាន់នាក់ ហើយបំបួសទាំងបរិព្វាជកចំនួន ២៥០ នាក់ជាពួកសញ្ជ័យនោះទៀត ទាំងកុលបុត្រទាំងឡាយដែលនៅក្នុងដែនមគធៈ ដែលមានកេរ្តិ៍ឈ្មោះ គេដឹងឮគ្រប់គ្នានេះទៀត ក៏ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះសមណគោតមដែរ ។ ឯមនុស្សទាំងឡាយឃើញពួកភិក្ខុហើយ ក៏នាំគ្នាចោទដោយគាថានេះថា

មហាសមណៈ យាងមកហើយកាន់ក្រុងគិរិព្វជៈ (ភ្នំមានសណ្ឋានដូចក្រោល) របស់ពួកជននៅក្នុងដែនមគធៈ ព្រះអង្គនាំអស់ពួកបរិវាររបស់សញ្ជ័យទៅហើយ ឥឡូវនឹងនាំ

យកអ្នកណាទៅទៀតអេះ ។

ពួកភិក្ខុបានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបពួកភិក្ខុនោះ ក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំឡេងនោះនឹងមិនមាននៅអស់កាលដ៏យូរទេ សំឡេងនោះនឹងមាននៅត្រឹមតែ ៧ ថ្ងៃ លុះកន្លង ៧ ថ្ងៃទៅ នឹងអន្តរធានបាត់ទៅឯង ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា ចោទអ្នកទាំងឡាយដោយគាថានេះថា :

មហាសមណៈ យាងមកហើយកាន់ក្រុងគិរិព្វជៈ របស់ពួកជននៅក្នុងដែនមគធៈ ព្រះអង្គនាំអស់ពួកបរិវាររបស់សញ្ជ័យទៅហើយ ឥឡូវនឹងនាំយកអ្នកណាទៅទៀតអេះ ។

(បើដូច្នោះ) អ្នកទាំងឡាយ ចូរចោទជនទាំងនោះដោយគាថានេះវិញថា ព្រះតថាគតទាំងឡាយ មានសេចក្តីព្យាយាមដ៏មាំ ណែនាំសត្វដោយព្រះសទ្ធម្មដ៏ប្រពៃពិត ហេតុដូចម្តេច

*ក៏មានសេចក្តីប្រណែននឹងពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំសត្វដោយធម៌ (នោះឯង) ។*

*សម័យនោះឯង ពួកមនុស្សឃើញពួកភិក្ខុហើយ ចោទដោយគាថានេះថា*

*មហាសមណៈ យាងមកហើយកាន់ក្រុងគិរិព្វជៈ របស់ពួកជននៅក្នុងដែនមគធៈ ព្រះអង្គនាំអស់ពួកបរិវាររបស់សញ្ជ័យទៅហើយ ឥឡូវនឹងនាំយកអ្នកណាទៅទៀតហ្ន៎ ។*

*ភិក្ខុទាំងឡាយ ចោទតបនឹងមនុស្សទាំងនោះ ដោយគាថានេះថា ព្រះតថាគតទាំងឡាយ មានសេចក្តីព្យាយាមដ៏មាំ ណែនាំសត្វដោយព្រះសទ្ធម្មដ៏ប្រពៃពិត ហេតុដូចម្តេចក៏មានសេចក្តីប្រណែននឹងពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំសត្វដោយធម៌ (នោះឯង) ។*

*ពួកមនុស្ស ពោលពាក្យយ៉ាងនេះថា បានឮថា សមណទាំងឡាយជាសក្យបុត្រ ណែនាំសត្វដោយធម៌ មិនមែនណែនាំដោយសភាវៈមិនមែនធម៌ទេ ។ សំឡេងនោះ ក៏មានត្រឹមតែ ៧ ថ្ងៃ លុះកន្លង ៧ ថ្ងៃ ក៏អន្តរធានបាត់ទៅឯង ។ (ចាកវិនយបិដក)*

## ១៨_ទីឃនខសូត្រ

*សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងគុហាឈ្មោះសូករខាតា នាភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ មានបរិព្វាជកម្នាក់ឈ្មោះទីឃនខៈ (ជាអគ្គិវេស្សនគោត្ត) ចូលទៅគាល់ព្រះមានព្រះភាគ ។ល។*

អយំ ខោ បន អគ្គិវេស្សន, កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសូបចយោ អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ, *ម្នាលអគ្គិវេសនៈ ក៏ឯកាយនេះ មានរូបជាទីប្រជុំនៃមហាភូតរូប ទាំង ៤ (ដី ទឹក ភ្លើង ខ្យល់) កើតមកអំពីមាតាបិតា ចម្រើនឡើង ដោយបាយ និងនំកុម្មាស មានការមិនទៀង មានការគក់ប្រឫាច់ ការដុសខាត់ មន្ទិលក្លិនស្អុយ ការបែកធ្លាយ និងការរាត់រាយទៅជាធម្មតា,*

អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សិតព្វោ, *បុគ្គលគួរពិចារណាឃើញច្បាស់*

*ដោយសភាពជារបស់មិនទៀង ជាទុក្ខ ជារោគ ថាបីដូចជាបូស ថាបីដូចជាកូនសរ ជាសេចក្ដីលំបាក ជាជម្ងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ ។*

តស្មិំ កាយំ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតោ យោ កាយស្មឹ កាយឆន្ទោ កាយស្នេហោ កាយន្វយតា សា បហីយតិ ។ *កាលបុគ្គលនោះ ពិចារណាឃើញច្បាស់នូវកាយនេះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ថាបីដូចជាបូស ថាបីដូចជាកូនសរ ជាសេចក្ដីលំបាក ជាជម្ងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ សេចក្ដីប្រាថ្នាក្នុងកាយ និងសេចក្ដីអាល័យកាយ ទាំងកិលេសដែលប្រព្រឹត្តទៅតាមកាយណា កិលេសតណ្ហានោះ គេក៏លះបង់បាន ។*

*ម្នាលអគ្គិវេស្សនៈ វេទនានេះមាន ៣ ប្រការ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។*

ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ ក្នុងសម័យនោះទទួលចំពោះតែសុខវេទនា ។

ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលទុក្ខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ ទទួលចំពោះតែទុក្ខវេទនា ។

ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះទទួលចំពោះតែអទុក្ខមសុខវេទនា ។

ម្នាលអគ្គិវេស្សនៈ សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្សាយទៅទាំងមានកិរិយារលត់ទៅវិញជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ ទុក្ខវេទនា ក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ តែងអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្សាយទៅ ទាំងមានកិរិយារលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខមសុខវេទនា ក៏ជា

របស់មិនទៀង ជារបស់ដែលសង្ខារ តាក់តែងកើតឡើងហើយ តែងអស់ទៅសូន្យទៅជាធម្មតា មានកិរិយាក្ស័យទៅ និងវលត់ទៅជាធម្មតា ។

ម្នាលអគ្គិវេស្សនៈ អរិយសាវកអ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខវេទនាផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេស កាលចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថាជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើបានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះ មិនមានឡើយ ។

ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តផុតស្រឡះយ៉ាងនេះ រមែងមិននិយាយផ្សំនឹងអ្នកណាៗ មិននិយាយទទឹងទាស់នឹងអ្នកណាៗ វាចាណាដែលគេនិយាយហើយក្នុងលោក ក៏ពោលទៅតាមវាចានោះ តែមិនបានស្ទាបអង្អែល (ដោយទិដ្ឋិ) ។

សម័យនោះឯង ព្រះសារីបុត្តមានអាយុ គង់ខាងប្រឹស្ពាង្គ (អវយវៈខាងក្រោយគឺខ្នង) នៃព្រះមានព្រះភាគ បក់ថ្វាយព្រះមានព្រះភាគ ។ ក្នុងលំដាប់នោះ ព្រះសារីបុត្តមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា បានឮថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ការលះបង់នូវពួកធម៌នោះៗ ដោយប្រាជ្ញាដ៏ក្រៃលែងដល់យើងទាំងឡាយ បានឮថា ព្រះសុគតទ្រង់ត្រាស់ការរលាស់ចោលនូវពួកធម៌នោះៗ ដោយប្រាជ្ញាដ៏ក្រៃលែងដល់យើងទាំងឡាយ ។ កាលព្រះសារីបុត្តមានអាយុ កំពុងពិចារណាហេតុនេះ ស្រាប់តែចិត្តលោកក៏ផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ដោយប្រការដូច្នេះ ។ ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិល បានកើតឡើងហើយដល់ទីឃនខបរិព្វាជកថា ធម្មជាតិអ្វីមួយមានសេចក្តីកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ។

គ្រានោះ ទីឃនខបរិព្វាជក បានឃើញធម៌ហើយ បានដល់ធម៌ហើយ បានដឹងច្បាស់នូវធម៌ហើយ មានចិត្តចុះស៊ប់ក្នុងធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ជាហេតុពោលថាអ្វីៗ ដល់នូវសេចក្តីក្លៀវក្លា មិនជឿស្តាប់បុគ្គល

ដទៃ ក្នុងសាសនារបស់ព្រះសាស្តា បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនទ្រង់ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញវត្ថុដែលបិទបាំងទុក ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោត ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក (ភ្លឺ) មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណគមន៍ ស្មើដោយជីវិតចាប់ដើមតាំងពីថ្ងៃនេះតទៅ ។

ចប់ ទីឃនខសូត្រ ។

(សុត្តន្ត. ភាគ២៤ ទំព័រ៩៥)

# អដ្ឋកថានិយនខសូត្រ

បណ្ដាបទទាំងនោះ បទថា សូករខាតាយំ ក្នុងល្អាងដែលមានឈ្មោះយ៉ាងនេះថា **សូករខាតា** ។

មានរឿងពោលទុកថា កាលសាសនាព្រះកស្សបសម្ពុទ្ធ ល្អាងនោះកើតខាងក្នុងផ្ទៃផែនដីដែលដុះឡើង ក្នុងមួយពុទ្ធន្តរ ។ កាលជាខាងក្រោយមក ថ្ងៃមួយ ជ្រូកមួយកកាយដីក្នុងទីជិតខេត្តបិទល្អាងនោះ ។ កាលភ្លៀងធ្លាក់បានប្រាកដខេត្តបិទ ព្រោះត្រូវភ្លៀងជម្រះ ព្រានព្រៃម្នាក់ឃើញ ចូលទៅទើបគិតថា កាលមុនមិនមានអ្នកមានសីលនៅក្នុងល្អាង ។ យើងនឹងកែលំអល្អាងនោះ។ ទើបជញ្ជូនដីចេញ បោសល្អាងឲ្យស្អាត ហើយធ្វើជញ្ជាំងជុំវិញ ប្រកបទ្វារបង្អួច ធ្វើល្អាងឲ្យមានបរិវេណ ក្រាលដោយខ្សាច់ដូចប្រាក់ ធ្វើយ៉ាងវិចិត្រ លាបកំបោរស រហូតសម្រេចរៀបរយយ៉ាងល្អ ហើយចាត់ចែងគ្រែ និងតាំង បានថ្វាយជាទីប្រថាប់របស់ព្រះមានព្រះភាគ ។ ល្អាងជ្រៅ ឡើងចុះសប្បាយ ។ បទថា សូករខាតាយំ នេះ លោកពោលសំដៅដល់ល្អាងនោះ ។ បទថា

ឱឃនសោ ជាឈ្មោះរបស់បរិព្វាជកនោះ ។ បទថា ឧបសង្កមិ ចូលទៅគាល់ ព្រោះហេតុអ្វី ទីឃនខបរិព្វាជកទើបចូលទៅគាល់ ។ ដំណាលមកថា ទីឃនខបរិព្វាជកនោះ កាលព្រះថេរៈបួសបាន កន្លះខែ គិតថា លោកអ៊ំរបស់យើងទៅកាន់លទ្ធិដទៃ ដែលខុស ហើយបិតនៅជាវេលាយូរ ។ តែឥឡូវនេះ កាលលោកអ៊ំទៅគាល់ ព្រះសមណគោតមបានកន្លះខែ ហើយប្រាថ្នានឹងទៅដោយប្រាថ្នាថា យើងនឹងស្តាប់ដំណឹងរបស់លោកអ៊ំនោះ ។ យើងនឹងដឹងពាក្យ ទូន្មានដែលរុងរឿងនោះហ្ន៎ ។ ព្រោះដូច្នោះ ទីឃនខៈទើបចូលទៅ គាល់ ។ បទថា ឯកមន្តំ ឋិតោ បានឈរក្នុងទីសមគួរមួយ, បានឮថា ក្នុងខណៈនោះ ព្រះថេរៈឈរបក់ផ្លិតថ្វាយព្រះមាន-ព្រះភាគ ។ បរិព្វាជក ដោយមានហិរិឱត្តប្បៈក្នុងលោកអ៊ំ ទើប ឈរទូលសួរបញ្ហា ដោយហេតុនោះ លោកទើបពោលថា ឯកមន្តំ ឋិតោ ដូច្នេះ ។

បទថា អភិញ្ញា បហានមាហ ព្រះមានព្រះភាគ ត្រាស់ ការលះធម៌ទាំងនោះដោយបញ្ញាដ៏ក្រៃលែង សេចក្តីថា ព្រះមាន

ព្រះភាគ ទ្រង់ដឹងសេចក្តីទៀងនៃធម៌ទាំងនោះ ក្នុងបណ្តាសេចក្តីទៀងជាដើមដោយបញ្ញាដ៏ក្រៃលែង ហើយទើបត្រាស់ដល់ការលះសេចក្តីទៀង ។ ទ្រង់ដឹងសេចក្តីដាច់សូន្យ សេចក្តីទៀងខ្លះដោយបញ្ញាដ៏ក្រៃលែងហើយ ទើបត្រាស់ដល់ការលះសេចក្តីទៀងខ្លះ ។ ទ្រង់ដឹងរូបដោយបញ្ញាដ៏ក្រៃលែងហើយ ទើបត្រាស់ដល់ការលះរូប គប្បីជ្រាបសេចក្តីក្នុងបទនេះដោយន័យមានជាដើមដូច្នេះឯង ។

បទថា បដិសញ្ចិក្ខតោ កាលព្រះសារីបុត្ត កំណត់គឺយល់ឃើញច្បាស់ ។ បទថា អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ចិត្តផុតស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់មាំ គឺចិត្តផុតស្រឡះហើយចាកអាសវៈទាំងឡាយ ដែលរលត់ហើយ ដោយសេចក្តីរលត់ស្និទ្ធ គឺមិនកើតទៀតព្រោះមិនប្រកាន់មាំ ។

ដោយហេតុប្រមាណប៉ុណ្ណេះ ព្រះសារីបុត្តដូចបុគ្គលបរិភោគអាហារដែលគេដួសឲ្យអ្នកដទៃហើយ បន្ទោបង់សេចក្តីឃ្លានបានកាលបញ្ជូនញាណទៅក្នុងធម៌ទេសនា ដែលប្រារព្ធអ្នកដទៃ ទើបចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ចាក់ធ្លុះរហូតដល់ទីបំផុតនៃសាវកបារមីញាណ និងបញ្ញា ១៦ ហើយតាំងនៅ ។

ចំណែកទីឃនខៈ បានសម្រេចសោតាបត្តិផលហើយតាំងនៅក្នុងសរណៈទាំងឡាយ ។

## ព្រះសាវកសន្និបាត

ចំណែកព្រះមានព្រះភាគ កាលព្រះអាទិត្យនៅប្រាកដ ទ្រង់បញ្ចប់ទេសនានេះហើយ ស្តេចចុះពីភ្នំគិជ្ឈកូដ ទ្រង់ទៅព្រះវិហារវេឡុវ័ន ទ្រង់បានប្រជុំព្រះសាវ័ក ។ បានមានសន្និបាតប្រកបដោយអង្គ ៤ ។ អង្គ ៤ ទាំងនេះ គឺថ្ងៃនោះជាថ្ងៃឧបោសថ ១៥ កើត ប្រកបដោយមាឃនក្ខត្តឫក្ស ១ ភិក្ខុ ១,២៥០ រូប ប្រជុំគ្នាតាមធម្មតារបស់ខ្លួនៗ មិនមានអ្នកណានិមន្ត ១ ភិក្ខុទាំងនោះមិនមានសូម្បីត្រឹមតែមួយរូបដែលជាបុថុជ្ជន ឬព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្តសុក្ខវិបស្សក ភិក្ខុទាំងអស់នោះជាអ្នកបានអភិញ្ញាប្រាំមួយ ១ មិនបានកោរសក់ដោយកាំបិតកោរបួស សូម្បីត្រឹមតែមួយរូប ភិក្ខុទាំងអស់ជា**ឯហិភិក្ខុ** ១ ។

ចប់ អដ្ឋកថា ទីឃនខសូត្រ ។

*វត្តវេឡុវ័ន កន្លែងព្រះអង្គសម្តែងឱវាទបាតិមោក្ខ*



## ១៩_ឱវាទបាតិមោក្ខ

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។

*ការមិនធ្វើបាបទាំងពួង ការញុំាងកុសលឲ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។*

ខន្តិ បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
ន សមណោ ហោតិ បរំ វិហេឋយន្តោ ។

*ខន្តិ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែង ពោលថា ព្រះនិព្វានជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ ក៏មិនឈ្មោះថា សមណៈឡើយ ។*

អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

*ការមិនតិះដៀល ១ ការមិនបៀតបៀន ១ ការសង្រួមក្នុងបាតិមោក្ខ ១ ភាពជាអ្នកដឹងប្រមាណក្នុងភត្ត ១ ការដេក និងអង្គុយក្នុងទីស្ងាត់ ១ ការព្យាយាមក្នុងអធិចិត្ត ១ នុ៎ះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។*

## អដ្ឋកថា

បទថា សព្វបាបស្ស បានដល់ អកុសលកម្មគ្រប់ប្រភេទ ។ ការញុំាងកុសលឲ្យកើតឡើង តាំងពីចេញបួស ដរាបដល់ព្រះអរហត្តមគ្គ និងការញុំាងកុសលដែលខ្លួនឲ្យកើតឡើងហើយឲ្យចម្រើន ឈ្មោះថា **ឧបសម្បទា** ។

ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ចាកនីវរណៈទាំង ៥ ឈ្មោះថា **សចិត្តបរិយោទបនំ** ។

បាទព្រះគាថាថា ឯតំ ពុទ្ធាន សាសនំ ដោយអត្ថថា នេះជាវាចា ពាក្យទូន្មានរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ។

បទថា ខន្តិ សេចក្ដីថា ដែលឈ្មោះថា សេចក្ដីអត់ធន់ ពោលគឺសេចក្ដីសង្កត់ចិត្តនេះ ជាតបៈដ៏កំពូលក្រៃលែង គឺយ៉ាងខ្ពស់បំផុតក្នុងព្រះសាសនានេះ ។

បាទព្រះគាថាថា និព្វានំ បរមំ វទន្តិ ពុទ្ធា សេចក្ដីថា ពុទ្ធបុគ្គលទាំង ៣ ប្រភេទនេះ គឺ ព្រះពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ព្រះអនុពុទ្ធ ១ រមែងពោលព្រះនិព្វានថា “ជាធម្មជាតដ៏ឧត្ដម” ។

បទថា ន ហិ បព្វជិតោ ដោយសេចក្ដីថា បុគ្គលអ្នកបំផ្លាញឲ្យហិនហោច បៀតបៀនសត្វដទៃ ដោយគ្រឿងប្រហារផ្សេងៗ មានបាតដៃជាដើម ឈ្មោះថា អ្នកប្រទូសរ៉ាយអ្នកដទៃ មិនឈ្មោះថា ជាបព្វជិត ។

បទថា សមណោ សេចក្ដីថា បុគ្គលដែលនៅបៀតបៀនសត្វដទៃដោយន័យដែលពោលហើយនុ៎ះឯង មិនឈ្មោះថា ជាសមណៈផងដូចគ្នា ។ ការមិនតិះដៀលដោយខ្លួនឯង និងការមិនញុំាងអ្នកដទៃឲ្យតិះដៀល ឈ្មោះថា **អនូបវាទោ** ។

ការមិនប្រទូសរ៉ាយខ្លួនឯង និងការមិនប្រើអ្នកដទៃឲ្យប្រទូសរ៉ាយ ឈ្មោះថា **អនូបឃាតោ** ។

បទថា បាតិមោក្ខេ បានដល់ សីលដែលជាប្រធាន, ការបិទ ឈ្មោះថា **សំវរោ** ។ ភាពជាអ្នកដឹងប្រមាណ គឺសេចក្ដីស្គាល់ប្រមាណ ឈ្មោះថា **មត្តញ្ញុតា** ។

បទថា បន្តំ បានដល់ ស្ងាត់ ។ បទថា អធិចិត្តេ សេចក្ដីថា ក្នុងចិត្តដែលក្រៃលែង ពោលគឺចិត្តដែលប្រកបព្រមដោយសមាបត្តិប្រាំបី ។ ការធ្វើសេចក្ដីព្យាយាម ឈ្មោះថា **អាយោគោ** ។

បទថា ឯតំ សេចក្តីថា នេះជាពាក្យទូន្មានរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ។ ក៏ក្នុងព្រះគាថានេះ ព្រះមានព្រះភាគ ត្រាស់សីលដែល ប្រព្រឹត្តទៅតាមផ្លូវវាចា ដោយពាក្យថា **អនូបវាទ**, ត្រាស់សីល ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ដោយពាក្យថា **អនូបឃាត** ។ ត្រាស់បាតិមោក្ខសំវរសីល និង ឥន្ទ្រិយសំវរសីល ដោយពាក្យ នេះថា **បាតិមោក្ខេ ច សំវរោ** ។

ត្រាស់អាជីវបារិសុទ្ធិសីលនិងបច្ចយសន្និស្សិតសីល ដោយ ពាក្យថា **មត្តញ្ញុតា**, ត្រាស់សេនាសនៈដែលសប្បាយ ដោយ ពាក្យថា **បន្តសេនាសនៈ**, ត្រាស់សមាបត្តិ ៨ ដោយពាក្យថា **អធិចិត្ត** ។ ដោយប្រការដូច្នេះ សិក្ខាសូម្បីទាំង ៣ រមែងជាសិក្ខា គឺព្រះអង្គត្រាស់ហើយដោយព្រះគាថានេះមែនពិត ដូច្នេះឯង ។

ឱវាទបាតិមោក្ខ ចប់ ។

## ២០. រឿងព្រះបាទសុទ្ធោទនសក្យរាជ

បានឮមកថា ចាប់ដើមអំពីថ្ងៃដែលព្រះពោធិសត្វ ស្តេច ចេញសាងអភិនេស្ក្រមន៍ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ផ្ញើង

ព្រះសោតៈ ចាំស្តាប់ដំណឹងថា បុត្ររបស់យើងចេញទៅ ដោយកំណត់ទុកក្នុងចិត្តថា នឹងបានត្រាស់ដឹងជាព្រះពុទ្ធ បានត្រាស់ដឹងជាព្រះពុទ្ធហើយឬនៅហ្ន៎”, ស្តេចទ្រង់ព្រះសណ្តាប់ការបំពេញព្យាយាម ការត្រាស់ដឹងឯង និងពុទ្ធកិច្ចទាំងឡាយ មានញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅជាដើម របស់ព្រះមានព្រះភាគ ទ្រង់បានព្រះសណ្តាប់ថា បានឮមកថា ឥឡូវនេះ បុត្ររបស់យើងអាស្រ័យនៅក្នុងក្រុងរាជគ្រឹះ” ទើបទ្រង់ត្រាស់បង្គាប់អមាត្យម្នាក់ថា នែអ្នក យើងជាបុគ្គលចាស់ មានវ័យចម្រើនហើយ, ល្អហើយអ្នក ចូរអ្នកទៅនិមន្តបុត្រមកឲ្យដល់យើង ទាន់យើងនៅរស់” អមាត្យទទួលថា សាធុ ហើយមានបុរស ១ ពាន់នាក់ជាបរិវារទៅកាន់ក្រុងរាជគ្រឹះ ថ្វាយបង្គំព្រះបាទព្រះមានព្រះភាគ ហើយទើបអង្គុយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ធម្មីកថាដល់អមាត្យ អមាត្យជ្រះថ្លាទូលសូមបព្វជ្ជា និងឧបសម្បទាក្នុងទីនោះ ព្រះមានព្រះភាគឲ្យអមាត្យឧបសម្បទា ដោយឯហិភិក្ខុឧបសម្បទា, ភិក្ខុនោះព្រមទាំងបរិស័ទ បានសម្រេចព្រះអរហត្ត ហើយបាននៅសោយសុខដែលកើតអំពីផលសមាបត្តិ ក្នុងទីនោះឯង ។

ព្រះរាជា ទ្រង់បញ្ជូនទូតសូម្បីដទៃទៅទៀត ៨ នាក់ ដោយឧបាយនោះដែរ ។ សូម្បីទូតទាំងអស់នោះ ព្រមទាំងបរិស័ទ បានសម្រេចព្រះអរហន្តហើយ នៅក្នុងទីនោះដូចគ្នា ។ មិនមានអ្នកណាៗ ទូលសូម្បីត្រឹមតែដំណឹងដល់ព្រះរាជាថា ទូតទាំងនោះមិនត្រឡប់មក ព្រោះហេតុឈ្មោះនេះ” ។

គ្រានោះ ព្រះរាជាមានព្រះបំណងនឹងទ្រង់បញ្ជូនអមាត្យឈ្មោះកាឡុទាយី ដែលកើតក្នុងថ្ងៃជាមួយនឹងព្រះពោធិសត្វ ទើបទ្រង់អង្វរដោយន័យមុននុ៎ះដែរ ។ អមាត្យក្រាបទូលថា បើខ្ញុំព្រះ-អង្គទៅនឹងបានបួស ខ្ញុំព្រះអង្គនឹងនិមន្ត” ។ ព្រះរាជាទ្រង់បញ្ជូនអមាត្យទៅថា សូម្បីអ្នកបួសហើយ ក៏ចូរនិមន្តបុត្រមកឲ្យដល់យើង” ។ សូម្បីអមាត្យមានបុរស ១ ពាន់នាក់ជាបរិវារបានទៅហើយ ព្រមទាំងបរិស័ទ បានសម្រេចជាព្រះអរហន្តយ៉ាងនោះដូចគ្នា ។ ក្នុងថ្ងៃមួយ កាឡុទាយីនោះ កាលសន្ទូងទាំងឡាយទាំងពួងសម្រេចរៀបរយហើយ មនុស្សក្នុងជនបទទាំងឡាយសម្រាកការងារហើយ ផ្កាឈើដែលកើតលើគោកនិងកើតក្នុងទឹករីកហើយទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយពណ៌នាគុណនៃការស្ដេច

យាងទៅ តាមផ្លូវដែលសមគួរទ្រង់ព្រះដំណើរដោយគាថាប្រមាណ ៦០ គត់ ព្រះមានព្រះភាគ ត្រាស់សួរថា នេះជាអ្វី ? លោកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនមហារាជ ជាបិតារបស់ព្រះអង្គ ទ្រង់បង្គាប់ខ្ញុំព្រះអង្គមកថា "យើងចាស់ហើយ អ្នកចូរទៅនិមន្តបុត្រមកឲ្យដល់យើង ទាន់យើងនៅរស់មែនពិត" ដូច្នេះ ល្អហើយព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ធ្វើសេចក្តីអនុគ្រោះដល់ព្រះញាតិទាំងឡាយ ឥឡូវនេះ ជាវេលាដែលស្តេចនឹងទ្រង់ចៀសចេញទៅកាន់ចារិកបាន ។ ព្រះមានព្រះភាគ ត្រាស់ថា បើដូច្នោះ អ្នកចូរប្រាប់ដល់សង្ឃ ភិក្ខុទាំងឡាយនឹងញ៉ាំងគមិកវត្តឲ្យពេញបរិបូរណ៍ ។

ព្រះថេរៈទទួលថា សាធុ ភន្តេ ហើយបានធ្វើតាមបង្គាប់ ។

ព្រះមានព្រះភាគ ទ្រង់ហែហមដោយព្រះខីណាស្រពទាំងអស់នោះ ២ ម៉ឺនរូប គឺកុលបុត្រអ្នកដែនអង្គៈនិងមគធៈ ១ ម៉ឺនរូប, កុលបុត្រអ្នកដែនកបិលវត្ថុ ១ ម៉ឺនរូប, ស្តេចទ្រង់ចេញចាកក្រុងរាជគ្រឹះ ចៀសចេញទៅកាន់ចារិក ទ្រង់យាងទៅមិនប្រញាប់

ប្រញាប់ ដោយទ្រង់ធ្វើទុកក្នុងព្រះហឫទ័យថា តថាគតកាលដើរផ្លូវមួយថ្ងៃៗ មួយយោជន៍ ពីរខែនឹងដល់ក្រុងកបិលវត្ថុ ដែលមានរយៈផ្លូវ ៦០ យោជន៍ អំពីក្រុងរាជគ្រឹះ ។

ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា យេន កបិលវត្ថុ តេន ចារិកំ បក្កាមិ ដូច្នេះ ។

ក៏ឯនាកាលព្រះមានព្រះភាគ ស្តេចចៀសចេញទៅហើយយ៉ាងនោះ ព្រះឧទាយិត្ថេរ ធ្វើភត្តកិច្ចក្នុងព្រះរាជនិវេសន៍ របស់ព្រះបាទសុទ្ធោទនមហារាជ ចាប់ដើមអំពីថ្ងៃដែលព្រះមានព្រះភាគស្តេចយាងទៅ ។ ព្រះរាជាទ្រង់អង្គាសព្រះថេរៈហើយ ទ្រង់អប់បាត្រដោយលំអិតគ្រឿងក្រអូប ដាក់ព្រះក្រយាហារដ៏ឧត្តម ដរាបដល់ពេញបង្អោនថ្វាយក្នុងដៃព្រះថេរៈថា "លោកម្ចាស់ចូរថ្វាយដល់ព្រះមានព្រះភាគ" ។ សូម្បីព្រះថេរៈ រមែងធ្វើតាមបង្គាប់ទាំងនោះ ។ ព្រះមានព្រះភាគ សោយបិណ្ឌបាតរបស់ព្រះរាជាតែប៉ុណ្ណោះ ក្នុងចន្លោះផ្លូវដោយប្រការដូច្នេះ ។ ចំណែកព្រះថេរៈ ក្នុងវេលា សម្រេចភត្តកិច្ចរាល់ថ្ងៃបានទូលព្រះរាជាថា ថ្ងៃនេះ ព្រះមានព្រះភាគ ស្តេចមកដល់ទីត្រឹមប៉ុណ្ណេះ" នឹងបានបណ្តុះសេចក្តី

ជ្រះថ្លាក្នុងព្រះមានព្រះភាគ ឲ្យកើតឡើងដល់ស្តេចសក្យៈទាំងឡាយ ដោយកថាដែលប្រកបដោយពុទ្ធគុណ ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងឯតទគ្គៈ (គឺអ្នកមានដំណែងដ៏ឆ្នើម) ថា "ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុទាំងឡាយ អ្នកញុំាងត្រកូលឲ្យជ្រះថ្លា ដែលជាសាវ័ករបស់តថាគត កាឡុទាយីជាអ្នកឆ្នើម" ដូច្នេះ ។

ចំណែកស្តេចសក្យៈសោត កាលព្រះមានព្រះភាគ ស្តេចយាងទៅមិនទាន់ដល់ ទើបមានបំណងក្នុងព្រះហឫទ័យថា "យើងទាំងឡាយ នឹងគាល់ព្រះញាតិដ៏ប្រសើររបស់ពួកយើង" ទើបប្រជុំគ្នា កាលជ្រើសរើសរកទីកន្លែង សម្រាប់ព្រះមានព្រះភាគ ស្តេចគង់នៅ ទ្រង់កំណត់ថា អារាមរបស់សក្កៈ ឈ្មោះនិគ្រោធគួរជាទីរីករាយ ទើបឲ្យធ្វើការចាត់ចែងជួសជុល វិធីទាំងពួងក្នុងអារាមនោះ មានរបស់ក្រអូប និងផ្កាឈើក្នុងដៃ កាលនឹងធ្វើការក្រោកទទួល បានបញ្ជូនក្មេងប្រុស និងក្មេងស្រី អ្នកនគរកំលោះក្រមុំ ប្រដាប់ដោយអលង្ការគ្រប់យ៉ាង ឲ្យទៅមុខ បន្ទាប់អំពីនោះបញ្ជូនរាជកុមារ និងរាជកុមារីទាំងឡាយទៅ, ហើយទើបទៅខ្លួនឯង

ក្នុងលំដាប់នៃពួករាជកុមា និងរាជកុមារីទាំងនោះ, បូជាដោយគ្រឿងសក្ការៈ មានផ្កាឈើនិងគ្រឿងលំអិតជាដើម បានទិមន្តព្រះមានព្រះភាគ ស្តេចទៅកាន់និគ្រោធារាមតែម្តង ។

ព្រះមានព្រះភាគ មានព្រះខីណាស្រពពីរម៉ឺនអង្គចោមរោមទ្រង់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេចាត់ចែងទុក ក្នុងនិគ្រោធារាមនោះ ។ ពួកសក្យរាជ ជាអ្នកប្រកបដោយជាតិនៃមានះ គឺប្រកាន់ខ្លួនរឹងត្អឹង ។ ពួកស្តេចសក្យៈទាំងពួងនោះ ទ្រង់មានសេចក្តីត្រិះរិះថា "សិទ្ធត្ថកុមារនៅក្មេងកំលោះជាងពួកយើង ជាប្អូន ជាក្មួយ ជាបុត្រ ជាចៅនៃពួកយើង" ទើបបង្គាប់ដល់រាជកុមារកំលោះថា "ពួកអ្នកចូរថ្វាយបង្គំ ពួកយើងនឹងអង្គុយខាងក្រោយពួកអ្នក" ។ នាកាលសក្យរាជទាំងនោះ ទ្រង់គង់យ៉ាងនោះហើយ, ព្រះមាន ព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ពួកស្តេចសក្យៈហើយ ទ្រង់រំពឹងថា ពួកព្រះញាតិ មិនព្រមថ្វាយបង្គំតថាគត, ណ្ហើយចុះ ឥឡូវនេះ តថាគតនឹងឲ្យព្រះញាតិទាំងនោះថ្វាយបង្គំ" ដូច្នេះហើយ ទ្រង់ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទទ្រង់យាងហើយហោះ ឡើងកាន់អាកាសដោយឫទ្ធិ ទ្រង់បានធ្វើ

បាដិហារិយ៍ ស្រដៀងយមកបាដិហារិយ៍ ទៀបគល់គណ្ឌម្ពព្រឹក្ស (គឺដើមស្វាយ) ហាក់ដូចជាទ្រង់រោយធូលីអំពីព្រះបាទ ចុះលើសិរសានៃព្រះញាតិទាំងនោះ ។

ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យយ៉ាងនោះ ទើបទ្រង់ត្រាស់ថា បពិត្រ ព្រះមានព្រះភាគ កាលព្រះអង្គដែលនាងកិលៀងនាំចូលទៅដើម្បីថ្វាយបង្គំព្រាហ្មណ៍ក្នុងថ្ងៃជាមង្គល សូម្បីខ្ញុំព្រះអង្គ បានឃើញព្រះបាទរបស់ព្រះអង្គ ទៅប្រតិស្ឋានលើសីសៈរបស់ព្រាហ្មណ៍ ទើបខ្ញុំព្រះអង្គថ្វាយបង្គំព្រះអង្គ នេះជាការថ្វាយបង្គំមុនដំបូងរបស់ខ្ញុំព្រះអង្គ ។ ក្នុងថ្ងៃវប្បមង្គល (ជាថ្ងៃច្រត់ព្រះនង្គ័ល) កាលព្រះអង្គផ្ទំលើព្រះបន្ទំដ៏មានសិរី ក្រោមដើមព្រីង ខ្ញុំព្រះអង្គឃើញម្លប់ ដើមព្រីងមិនបានបែរជ្រេរទៅតាម(ព្រះអាទិត្យ) ទើបខ្ញុំព្រះអង្គថ្វាយបង្គំព្រះបាទ នេះជាការថ្វាយបង្គំលើកទី ២ របស់ខ្ញុំព្រះអង្គ, ឥឡូវ នេះ សូម្បីខ្ញុំព្រះអង្គបានឃើញបាដិហារិយ៍ ដែលមិនធ្លាប់បានឃើញនេះ ខ្ញុំព្រះអង្គសូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ, នេះជាការថ្វាយបង្គំលើកទី ៣ របស់ខ្ញុំព្រះអង្គ" ។ ក៏ឯកាលព្រះមានព្រះភាគ ដែលព្រះបាទសុទ្ធោទនមហារាជ

ថ្វាយបង្គំហើយ សូម្បីស្តេចសក្យៈតែមួយអង្គ ដែលឈ្មោះថាមិនថ្វាយបង្គំមិនមានសោះឡើយ, ថ្វាយបង្គំគ្រប់គ្នាទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់ញុំាងព្រះញាតិទាំងឡាយឲ្យថ្វាយបង្គំហើយ ស្តេចចុះពីអាកាស ទ្រង់គង់លើអាសនៈ ដែលគេចាត់ចែងទុក ។ កាលព្រះមានព្រះភាគ ទ្រង់គង់ហើយ ព្រះញាតិសមាគមបានជាអ្នកដល់ទីបំផុត (គឺអស់មានះ) ។ ព្រះញាតិទាំងពួង មានព្រះហឫទ័យមាំមួន អង្គុយប្រជុំគ្នាហើយ ។ លំដាប់នោះ មហាមេឃបណ្តាភ្លៀងបោក្ខរព័ស៌ (ភ្លៀងមានអាការដូចជាទឹកធ្លាក់លើស្លឹកឈូក) ឲ្យធ្លាក់ចុះមក ។ ទឹកមានពណ៌ក្រហម ហូរចុះទៅខាងក្រោម សូម្បីទឹកតែមួយដំណក់នឹងធ្លាក់ចុះមកលើសរីរៈរបស់អ្នកណាៗ ក៏មិនមាន ។ ព្រះញាតិទាំងពួងទ្រង់ឃើញហេតុនោះហើយ បានជាអ្នកកើតសេចក្តីអស្ចារ្យក្នុងចិត្ត ។ ព្រះមានព្រះភាគ ត្រាស់ថា ភ្លៀងបោក្ខរព័ស៌ធ្លាប់ធ្លាក់ចុះមកក្នុងញាតិសមាគមរបស់តថាគតក្នុងកាលនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងអតីតកាល ក៏បានធ្លាក់ចុះមកហើយ ដូច្នេះ ហើយទ្រង់ត្រាស់វេស្សន្តរជាតក ព្រោះកើតហេតុនេះឡើង ។ ព្រះញាតិទាំងពួងបានស្តាប់ព្រះធម៌-

ទេសនាហើយ ស្តេចទ្រង់ក្រោកឡើង ថ្វាយបង្គំធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ សូម្បីបុគ្គលតែម្នាក់ គឺព្រះរាជា ឬរាជ-មហាមាត្យដែលនឹងទូលថា ក្នុងថ្ងៃស្អែក សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ" ហើយទើបទៅ ក៏មិនមានសោះឡើយ ។ ក្នុងថ្ងៃទី ២ ព្រះមានព្រះភាគ មានភិក្ខុ ២ ម៉ឺនអង្គជាបរិវារ ស្តេចចូលទៅបិណ្ឌបាត ក្នុងក្រុងកបិលវត្ថុ ។ អ្នកណាៗ នឹងក្រោកទទួលហើយនិមន្ត ឬបានទទួលបាត្រ ក៏មិនមានសោះ ។ ព្រះមានព្រះភាគ ទ្រង់ឈរនៅទៀបសសរឥន្ទខីលៈ ទ្រង់នឹកថា ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ស្តេចយាងបិណ្ឌបាតក្នុងនគរនៃត្រកូលយ៉ាងណាហ្ន៎ ស្តេចបានចូលទៅកាន់ផ្ទះរបស់ឥស្សរៈជន ដោយខុសលំដាប់ឬ ឬថាស្តេចទ្រង់យាងចារិកទៅតាមលំដាប់ច្រក ។ លំដាប់នោះ មិនបានទ្រង់ឃើញការទៅខុសលំដាប់ សូម្បីនៃព្រះពុទ្ធតែមួយអង្គ ទើបទ្រង់រំពឹងថា ឥឡូវនេះ វង្សនេះ និងប្រវេណីនេះ សូម្បីតថាគតគួរលើកតម្កើង និងតទៅសាវកទាំងឡាយរបស់តថាគត កាលយកតម្រាប់តាមតថាគត នឹងញុំាងបិណ្ឌចារិកវត្ត

ឲ្យពេញបរិបូរណ៍បានហើយ ស្ដេចទ្រង់យាងបិណ្ឌបាតតាមលំដាប់ប្រក ចាប់ដើមអំពីផ្ទះដែលស្ដេចចូលទៅមុនដំបូង ។

មហាជនបានឮដំណឹងថា បានឮថា ព្រះអង្គម្ចាស់សិទ្ធត្ថកុមារ ស្ដេចទ្រង់យាងបិណ្ឌបាត ទើបបើកបង្អួចក្នុងប្រាសាទ ៤ ជាន់ជាដើម បានជាអ្នកខ្វល់ខ្វាយដើម្បីនឹងឃើញ ។

ចំណែកព្រះទេវីជាមាតាព្រះរាហុល ទ្រង់ព្រះចិន្ដាថា បានឮមកថា ព្រះអយ្យបុត្ត ស្ដេចទ្រង់យាងទៅដោយព្រះយាន មានសុវណ្ណសិវិកាជាដើម ដោយព្រះតេជានុភាពដ៏ធំក្នុងនគរនេះឯងឥឡូវនេះ ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុចេញ ហើយទ្រទ្រង់សំពត់កាសាវពស្ដ្រ មានអម្បែងក្នុងព្រះហស្ដ ស្ដេចទ្រង់យាងបិណ្ឌបាត ព្រះអង្គនឹងទ្រង់សមល្អដូចម្ដេចហ្ន៎, ឬថា មិនទ្រង់សមល្អ ។ ទើបទ្រង់បើកបង្អួចទតព្រះនេត្រមើល, ទ្រង់ឃើញព្រះមានព្រះភាគ ដែលល្អរុងរឿងដោយព្រះពុទ្ធសិរី ទ្រង់ញុំាងនគរវិថីទាំងឡាយឲ្យភ្លឺស្វាង ដោយព្រះសរីរៈរស្មីដ៏រុងរឿងឥតមានរាគៈផ្សេងៗ ទើបទ្រង់សរសើរព្រះរូបឆោម ចាប់ដើមអំពីព្រះកេសាដរាបដល់ព្រះបាទដោយព្រះគាថា ៨ ដែលមាននាមថា នរសីហ

គាថា ហើយស្តេចទៅគាល់ព្រះរាជា ក្រាបបង្គំទូលចំពោះព្រះរាជាថា "ព្រះអយ្យបុត្ររបស់ព្រះអង្គ ស្តេចទ្រង់យាងបិណ្ឌបាត" ។ ព្រះរាជា ទ្រង់ព្រះសណ្តាប់ដំណឹងនោះ ទ្រង់ស្លុតព្រះហឫទ័យ ទ្រង់ចាប់ព្រះភូសា (សំពត់សម្រាប់ស្លៀកពាក់ ឬគ្រឿងតែងខ្លួន) បណ្តើរឲ្យរៀបរយដោយព្រះហស្ត ស្តេចប្រញាប់ប្រញាល់ ចេញទៅដោយរហ័ស ទ្រង់ប្រថាប់ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច ទើបទ្រង់ញុំាងខ្ញុំព្រះ-អង្គឲ្យបានសេចក្តីខ្មាស, ព្រះអង្គទ្រង់យាងបិណ្ឌបាតដើម្បីប្រ-យោជន៍អ្វី, ព្រះអង្គមានសេចក្តីសំគាល់យ៉ាងនេះថា ភិក្ខុមានប្រមាណប៉ុណ្ណោះមិនអាចបាន ភត្តទេឬ", ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ ការត្រាច់បិណ្ឌបាតនេះ ជាចារិតសម្រាប់វង្សរបស់តថាគត ។

ព្រះរាជាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថាមហាសម្មតិខត្តិយវង្ស ជាវង្សរបស់ពួកយើងមិនមែនឬ, ក៏ឯខត្តិយ-វង្សនេះ សូម្បីក្សត្រិយ៍តែមួយអង្គ ឈ្មោះថា ជាអ្នកត្រាច់រកភិក្ខារមែងមិនមាន" ។

ព្រះមានព្រះភាគ ត្រាស់តបថា បពិត្រមហារាជ ឈ្មោះថា រាជវង្សនេះ ជាវង្សរបស់មហាបពិត្រ តែឈ្មោះថា ពុទ្ធវង្ស ជាវង្សរបស់តថាគត ព្រះពុទ្ធៗគ្រប់ព្រះអង្គមែនពិត ទ្រង់តែងយាងបិណ្ឌបាត ដូច្នេះ ទ្រង់ប្រថាប់ក្នុងផ្លូវថ្នល់ភូមិ បានត្រាស់ព្រះ-គាថានេះថា ៖

ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ

ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។

បុគ្គលមិនគួរប្រមាទ ក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

ព្រះរាជា ទ្រង់បានធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលក្នុងកាលដែលចប់នៃព្រះគាថា, និងបានស្តាប់ព្រះគាថានេះថា៖

ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ

ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។

*បុគ្គលគួរប្រព្រឹត្តធម៌ឲ្យជាសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។*

ដូច្នេះហើយ ទ្រង់តាំងនៅក្នុងសកទាគាមិផល, បានទ្រង់បានព្រះសណ្ដាប់ធម្មបាលជាតកហើយ ទ្រង់តាំងនៅក្នុងអនាគាមិ-ផល, ក្នុងមរណសម័យ ស្ដេចផ្ទុំលើក្រឡាព្រះបន្ទំដ៏មានសិរី <u>ខាងក្រោមនៃស្វេតច្ឆត្រនុ៎ះឯង</u> ទើបទ្រង់សម្រេចព្រះអរហន្ត ។ កិច្ចដែលត្រូវឧស្សាហ៍ ប្រកបព្យាយាមក្នុងព្រៃមិនមានដល់ព្រះរាជា ។

ក៏ឯទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលនុ៎ះឯង ទើបទ្រង់ទទួលបាត្ររបស់ព្រះមានព្រះភាគ ហើយនិមន្តព្រះមានព្រះភាគព្រមទាំងបរិស័ទឡើងកាន់មហាប្រាសាទ ទ្រង់អង្គាសដោយខាទ-នីយភោជនីយៈដ៏ប្រណីតថ្លៃថ្លា ។

ក្នុងវេលាចប់ភត្តកិច្ច ស្រីស្នំទាំងពួងវៀរតែព្រះមាតានៃព្រះរាហុលចេញ បានមកថ្វាយបង្គំព្រះមានព្រះភាគ ។ ចំណែកព្រះមាតាព្រះរាហុលនោះ សូម្បីដែលជនជាបរិវារទូលថា "សូម

ព្រះនាងជាម្ចាស់ស្តេចទៅថ្វាយបង្គំព្រះអយ្យបុត្រ” បានបង្គាប់ថា “បើសេចក្តីល្អរបស់យើងមាន ព្រះអយ្យបុត្រនឹងស្តេចមកដោយព្រះអង្គឯងតែម្តង យើងនឹងថ្វាយបង្គំព្រះអង្គ កាលស្តេចមកហើយ” ដូច្នេះ ស្តេចក៏មិនបានទៅ ។

ព្រះមានព្រះភាគ ទ្រង់ញុំាងព្រះរាជាឲ្យកាន់យកបាត្រហើយ ព្រមដោយព្រះអគ្គសាវកទាំងពីរ ស្តេចចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះរាជធីតា ត្រាស់ថា “ព្រះរាជធីតាចូរថ្វាយបង្គំតាមគាប់ចិត្តកុំគប្បីពោលថាយ៉ាងណាឡើយ” ហើយទ្រង់គង់លើអាសនៈដែលគេតាក់តែងទុក ។ ព្រះនាងស្តេចមកដោយរហ័សទ្រង់ចាប់ត្រង់កព្រះបាទបម្រះននៀលព្រះសិរសា លើខ្នងព្រះបាទថ្វាយបង្គំតាមព្រះអធ្យាស្រ័យ ។ ព្រះរាជាទូលដល់គុណសម្បត្តិមានព្រះសិនេហា និងសេចក្តីរាប់អានច្រើន ជាដើមក្នុងព្រះមានព្រះភាគ របស់ព្រះរាជធីតា ។

ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ នៅមិនទាន់ជាអស្ចារ្យទេ, ព្រះរាជធីតាដែលព្រះបរមបពិត្រទ្រង់នៅគ្រប់គ្រងបាន ក្នុងកាលព្រះញាណចាស់ក្លាហើយ ក្នុងកាលឥឡូវនេះ, កាល

អំពីមុននាងមិនមានអ្នកណាគ្រប់គ្រង ត្រាច់ទៅទៀបជើងភ្នំ រក្សាព្រះនាងទុកបាន ក្នុងកាលព្រះញាណនៅមិនទាន់ចាស់ក្លា" ដូច្នេះហើយ ទើបត្រាស់ចន្ទកិន្នរីជាតក ។

ថ្ងៃនោះឯង ព្រះនន្ទរាជកុមារ មានព្រះមហាមង្គល ៥ យ៉ាង គឺស្រោយព្រះកេសា ចងព្រះសុពណ្ណបដយរមង្គល អាវាហមង្គល ឆត្តមង្គល ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះនន្ទកុមារឲ្យកាន់យកបាត្រហើយ ទើបត្រាស់នូវមង្គល ស្តេចក្រោកចាកអាសនៈចៀសចេញទៅ ។

គ្រានោះ នាងជនបទកល្យាណី ឃើញព្រះកុមារកំពុងស្តេចចេញទៅ ទើបទូលថា "បពិត្រព្រះអយ្យបុត្ត ព្រះអង្គប្រញាប់ប្រញាល់ស្តេចត្រឡប់មកវិញ" ហើយអើតករមើលមើល ។ សូម្បីព្រះនន្ទកុមារនោះ កាលមិនអាចទូលព្រះមានព្រះភាគ ថា "សូមព្រះអង្គទ្រង់ទទួលបាត្រចុះ" ទើបត្រូវស្តេចទៅដល់វត្តតែម្តង ។

ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះនន្ទកុមារនោះ អ្នកមិនប្រាថ្នាឡើយឲ្យបួសហើយ ។ ព្រះមានព្រះភាគ ស្តេចមកកាន់កបិលបុរី ញ៉ាំងព្រះនន្ទកុមារឲ្យបួសក្នុងថ្ងៃទី ២ ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃទី ៧ ព្រះមាតាព្រះរាហុល ទ្រង់តាក់តែងព្រះកុមារ បញ្ជូនទៅកាន់សំណាក់ព្រះមានព្រះភាគ ដោយទ្រង់បង្គាប់ថា "បាអើ ! អ្នកចូរមើលសមណៈនុ៎ះ ដែលមានសម្បុរដូចជាពណ៌នៃមាស មានព្រះរូបពណ៌ដូចពណ៌នៃព្រហ្ម មានសមណៈ ២ ម៉ឺនចោមរោម, ព្រះសមណៈនេះជាព្រះបិតានៃអ្នក ព្រះសមណៈនោះមានកំណប់ទ្រព្យដ៏ធំ, ចាប់ដើមអំពីវេលាដែលព្រះអង្គស្តេចចេញទៅ មាតាក៏មិនបានឃើញ, អ្នកចូរទៅសូមទ្រព្យមត៌កនឹងព្រះអង្គថា "បពិត្រព្រះបិតាជាម្ចាស់ ទូលព្រះបង្គំជាខ្ញុំនៅជាកុមារនឹងលើកឆត្រឡើងហើយជាស្តេចចក្រពត្តិ, ទូលព្រះបង្គំជាខ្ញុំត្រូវការទ្រព្យ សូមព្រះអង្គប្រោសប្រទានទ្រព្យដល់ទូលព្រះបង្គំជាខ្ញុំចុះ ព្រោះថាបុត្តរមែងជាម្ចាស់នៃទ្រព្យរបស់បិតា" ។

ព្រះកុមារ លុះទៅកាន់សំណាក់ព្រះមានព្រះភាគ ក៏ត្រឡប់បានសេចក្តីស្រឡាញ់ព្រះបិតា មានព្រះហឫទ័យត្រេកអរទូលថា "បពិត្រព្រះសមណៈជាម្ចាស់ ម្លប់បុណ្យរបស់ព្រះអង្គសុខស្រួលណាស់" ហើយបានឈរទូលនូវពាក្យដ៏សមគួរដល់ខ្លួនយ៉ាងច្រើនសូម្បីដទៃ ។

ព្រះមានព្រះភាគ ទ្រង់សម្រេចភត្តកិច្ចហើយ ទ្រង់ធ្វើអនុមោទនា ស្ដេចក្រោកចាកអាសនៈចៀសចេញទៅ ។ ចំណែកព្រះកុមារ ទ្រង់បានជាប់តាមទូលព្រះមានព្រះភាគថា "បពិត្រព្រះសមណៈ សូមព្រះអង្គទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំព្រះអង្គ" ។

ព្រះមានព្រះភាគ ទ្រង់មិនញ៉ាំងព្រះកុមារឲ្យត្រឡប់វិញឡើយ ទាំងជនជាបរិវារ ក៏មិនអាចដើម្បីញ៉ាំងព្រះរាជកុមារ កាលស្ដេចទៅជាមួយនឹងព្រះមានព្រះភាគ ឲ្យស្ដេចត្រឡប់មកវិញឡើយ ។ គ្រានោះ ព្រះមានព្រះភាគ ស្ដេចយាងទៅដល់អារាមហើយទ្រង់ព្រះតម្រិះថា "រាហុលនេះ ប្រាថ្នាទ្រព្យជារបស់បិតាណា, ទ្រព្យនោះជាប់ដោយវដ្ដៈ ប្រព្រឹត្តទៅមួយអន្លើដោយសេចក្ដីចង្អៀតចង្អល់, ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការដែលតថាគតបានហើយ ក្រោមម្លប់ពោធិព្រឹក្សដល់រាហុលកុមារ, នឹងធ្វើរាហុលកុមារឲ្យជាម្ចាស់នៃមត៌កដែលជាលោកុត្តរៈ" ដូច្នេះហើយទើបទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុមក ។

លុះទ្រង់ហៅមកហើយត្រាស់ថា "ម្នាលសារីបុត្ត បើដូច្នោះអ្នកចូរបំបួសរាហុលកុមារចុះ" អធិប្បាយថា រាហុលកុមារនេះ

សូមនូវទ្រព្យមត៌ក, ព្រោះហេតុនោះ អ្នកចូរញ៉ាំងរាហុលកុមារនោះ ឲ្យបួសដើម្បីបានចំពោះនូវទ្រព្យមត៌កជាលោកុត្តរៈ ។

(ចាកសមន្ត. ៣, ៦៧-៧៣ )

## ២១_មហាធម្មបាលជាតក

សេចក្ដីដូចរឿងដែលបានពោលខាងដើមហើយថា ៖

ព្រះសាស្ដា កាលស្ដេចយាងមកកាន់ព្រះនគរកបិលវត្ថុជាដំបូង គង់នៅនិគ្រោធារាម ទ្រង់ប្រារព្ធការមិនជឿរបស់ព្រះពុទ្ធបិតា ក្នុងព្រះរាជនិវេសន៍ ទើបត្រាស់រឿងនេះ មានពាក្យចាប់ផ្ដើមថា **កិន្តេ វតំ** ដូច្នេះ ។

សេចក្ដីសង្ខេបថា គ្រានោះព្រះបាទសុទ្ធោទនមហារាជ ថ្វាយបាយយាគូ និងខាទនីយៈចំពោះព្រះមានព្រះភាគ ព្រមទាំងភិក្ខុ ២០,០០០ រូប ជាបរិវារក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ កាលទ្រង់ធ្វើសម្មោទនីយកថាក្នុងចន្លោះភត្ត បានត្រាស់ថា ព្រះអង្គ វេលាដែលព្រះអង្គធ្វើសេចក្ដីព្យាយាម មានពួកទេវតាមកឈរក្នុងអាកាសប្រាប់ដល់ខ្ញុំព្រះអង្គថា សិទ្ធត្ថកុមារឱរសរបស់ព្រះអង្គ

អស់ព្រះជន្មហើយ ព្រោះសោយព្រះក្រយាហារតិច, កាលព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រះអង្គទ្រង់ជឿឬ ? ទើបទ្រង់ត្រាស់ថា ខ្ញុំព្រះអង្គមិនជឿទេព្រះអង្គ ទាំងហាមទេវតាដែលឈរពោលនៅក្នុងអាកាសទៀតថា ព្រះឱរសរបស់យើងមិនទាន់បានត្រាស់ជាព្រះពុទ្ធ ទៀបគល់ពោធិព្រឹក្សហើយ នឹងមិនទាន់បរិនិព្វាន ព្រះសាស្តាត្រាស់ថា មហាបពិត្រ ក្នុងឥឡូវនេះ ព្រះអង្គនឹងទ្រង់មិនបានជឿយ៉ាងណា សូម្បីក្នុងកាលមុន កាលតថាគតកើតជាមហាធម្មបាលកុមារ កាលអាចារ្យទិសាបាមោក្ខ យកឆ្អឹងពពែមកសម្តែងប្រាប់ថា បុត្ររបស់លោកស្លាប់ហើយ នេះឆ្អឹងបុត្ររបស់លោក ព្រះអង្គក៏ទ្រង់មិនបានជឿ ពោលនឹងអាចារ្យថា ក្នុងត្រកូលរបស់យើងនេះនឹងស្លាប់កំពុងនៅកំលោះនោះ មិនមានទេ, ក៏ហេតុអ្វីក្នុងកាលឥឡូវនេះ ព្រះអង្គនឹងទ្រង់ជឿហ្ន៎ ? ព្រះពុទ្ធបិតាទូលអារាធនាឲ្យត្រាស់រឿងរ៉ាវ ទើបទ្រង់នាំយកអតីតនិទានមកសាធកដូចតទៅនេះ ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី មានស្រុកធម្មបាលគ្រាម ក្នុងដែនកាសី

ស្រុកនោះ ដែលបានឈ្មោះយ៉ាងនោះ ព្រោះជាទីនៅរបស់ត្រកូលធម្មបាលព្រាហ្មណ៍ ដែលនៅអាស្រ័យក្នុងស្រុកនោះ ប្រាកដឈ្មោះថា **ធម្មបាល** ព្រោះហេតុដែលរក្សាធម៌ គឺកុសលកម្មបថ ១០ ក្នុងត្រកូលរបស់គេ ដោយហោចទៅសូម្បីទាសៈ និងកម្មករក៏ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្មដែរ ។

គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលនោះ បាននាមថាធម្មបាលកុមារ គ្រាចម្រើនវ័យហើយ បិតាបានឲ្យទ្រព្យ ១ ពាន់បញ្ជូនឲ្យទៅរៀនសិល្បៈក្នុងក្រុងតក្កសិលា ធម្មបាលកុមារ ទៅក្នុងទីនោះហើយ រៀនសិល្បៈក្នុងសំណាក់របស់អាចារ្យទិសាបាមោក្ខ បានជាប្រធានមាណពពួកអន្តេវាសិក ៥០០ នាក់ គ្រានោះបុត្រដ៏ប្រសើររបស់អាចារ្យស្លាប់ អាចារ្យមានសិស្សមាណពហែហម ព្រមដោយពួកញាតិស្រែកយំ ខ្សឹកខ្សួល ធ្វើឈាបនកិច្ចសាកសព បុត្រក្នុងព្រៃជាទីចោលសាកសព ទាំងអាចារ្យទាំងសិស្ស និងពួកញាតិស្រែកយំ ខ្សឹកខ្សួលនៅក្នុងទីនោះ ធម្មបាលម្នាក់ប៉ុណ្ណោះ មិនស្រែកយំ មិនខ្សឹកខ្សួល កាលមាណព ៥០០នាក់នោះ មកពីព្រៃជាទីចោលសាកសពហើយ បាននាំគ្នាទៅ

*អន្វ័យរៀបរាប់ ក្នុងសំណាក់អាចារ្យថា “**អហោ ឯវរូបោ នាម អាចារសម្បន្នោ តរុណមាណវោ តរុណកាលេយេវ មាតាបិតូហិ វិប្បយុត្តោ មរណប្បត្តោ** ឱហ្ន៎ មិនគួរបើសោះ មាណពកំលោះបរិបូណ៌ដោយមារយាទបែបនេះ ព្រាត់ប្រាសចាកមាតាបិតា ដល់នូវសេចក្ដីស្លាប់តាំងពីនៅក្មេងនៅឡើយ” ធម្មបាលកុមារពោលថា “**សម្មា, តុម្ហេ តរុណោ”តិ ភណថ, អថ កស្មា តរុណកាលេយេវ មរតិ, ននុ អយុត្តំ តរុណកាលេ មរិតុំ** : នែសម្លាញ់ លោកទាំងឡាយ ពោលថានៅកំលោះ ចុះហេតុដូចម្ដេច ទើបបានស្លាប់តាំងពីនៅក្មេង វេលាក្មេងនៅមិនទាន់គួរស្លាប់មិនមែនទេឬ ?” ។*

*មាណពទាំងនោះ ពោលនឹងធម្មបាលកុមារថា នែសម្លាញ់ លោកមិនដឹងសេចក្ដីស្លាប់របស់សត្វទាំងនេះទេឬ ?*

*ធម្មបាលកុមារ : យើងដឹង តែមិនមានអ្នកណាស្លាប់តាំងពីនៅក្មេងទេ ដល់ពេលចាស់ទើបស្លាប់ ។*

*មាណពទាំងឡាយ : សង្ខារទាំងពួង មិនទៀង មានហើយត្រឡប់ជាមិនមាន មិនមែនឬ ?*

*ធម្មបាលកុមារ : ពិតមែន សង្ខារទាំងពួងមិនទៀងទេ តែ*

សត្វទាំងឡាយមិនមែនស្លាប់តាំងពីនៅកំលោះទេ ដល់ពេលចាស់ទើបស្លាប់ ហើយដល់នូវសេចក្ដីមិនទៀង ។

មាណពទាំងឡាយ : នៃសម្លាញ់ធម្មបាល ក្នុងផ្ទះរបស់លោកមិនមានអ្នកណាស្លាប់ទេឬ ?

ធម្មបាលកុមារ : ដែលស្លាប់ពីកំលោះមិនមានទេ មានតែស្លាប់ក្នុងកាលដែលចាស់ហើយប៉ុណ្ណោះ ។

មាណពទាំងឡាយ : ហេតុនេះជាប្រពៃណីនៃត្រកូលរបស់លោកឬ ? ធម្មបាលកុមារ : ត្រូវហើយ ជាប្រពៃណីនៃត្រកូលរបស់យើង ។

មាណពទាំងឡាយ បានស្ដាប់ពាក្យរបស់ធម្មបាលកុមារដូច្នោះហើយ ទើបនាំគ្នាប្រាប់ដល់អាចារ្យ អាចារ្យហៅធម្មបាលកុមារមកសួរថា នែធម្មបាល បានឮថា ក្នុងត្រកូលរបស់អ្នកមិនមានអ្នកស្លាប់ពីកំលោះពិតមែនឬ ? ធម្មបាលកុមារ ឆ្លើយថាពិតមែន លោកអាចារ្យស្ដាប់ពាក្យរបស់គេហើយគិតថា កុមារនេះនិយាយអស្ចារ្យហួសប្រមាណ យើងនឹងទៅកាន់សំណាក់បិតារបស់កុមារនេះសួរមើល បើពិតដូច្នោះមែន យើងនឹងបំពេញធម៌

ដូច្នោះខ្ញុំះ អាចារ្យនោះ កាលធ្វើឈាបនកិច្ចសាកសពបុត្រស្រេច ហើយកន្ទងមកបាន ៧-៨ ថ្ងៃ បានហៅធម្មបាលកុមារមក បង្គាប់ថា នែបា យើងនឹងទៅ អ្នកឯងចូរប្រាប់សិល្បៈដល់មាណពទាំងនេះ ដរាបយើងនឹងត្រឡប់មក បង្គាប់ហើយក៏ដាក់ឆ្អឹងពពែ ១ មកលាង យកដាក់កញ្ចប់ ឲ្យអ្នកបម្រើម្នាក់កាន់តាមទៅ ចេញពីក្រុងតក្កសិលា ទៅដោយលំដាប់ដល់ស្រុកនោះ ត្រាច់សួររកផ្ទះរបស់មហាធម្មបាលថា ផ្ទះខ្នងណា ដឹងហើយក៏ទៅឈរទៀបទ្វារ ។

ពួកទាសៈរបស់ព្រាហ្មណ៍ដែលឃើញមុន ក៏ទទួលឆត្រ ទទួលស្បែកជើងពីដៃរបស់អាចារ្យ និងទទួលកញ្ចប់ពីដៃរបស់អ្នកបម្រើ កាលអាចារ្យពោលថា ពួកលោកចូរទៅប្រាប់បិតារបស់កុមារថា អាចារ្យរបស់ធម្មបាលកុមារ ដែលជាបុត្ររបស់លោកមកឈរទៀបទ្វារ ពួកទាសៈទទួលពាក្យថា ល្អហើយ ហើយនាំគ្នាទៅប្រាប់, ព្រាហ្មណ៍នោះទៅជិតទ្វារដោយប្រញាប់អញ្ជើញថា ចូរមកខាងនេះចុះលោក ហើយនាំអាចារ្យឡើងផ្ទះ ឲ្យអង្គុយលើបល្ល័ង្ក ធ្វើកិច្ចគ្រប់យ៉ាងមានលាងជើងជាដើម អាចារ្យបរិភោគអាហារហើយ វេលាអង្គុយសន្ទនាគ្នាតាមសប្បាយ ទើបពោលថា

ម្នាលព្រាហ្មណ៍ ធម្មបាលកុមារបុត្ររបស់លោកជាអ្នកមានសតិបញ្ញារៀនចប់ត្រៃវេទ និងសិល្បៈ ១៨ ប្រការហើយ តែបានស្លាប់ហើយ ដោយរោគម្យ៉ាង សង្ខារទាំងឡាយមិនទៀងមែនពិត លោកកុំសោយសោកឡើយ ។

ព្រាហ្មណ៍ទះដៃសើចលាន់ឮឡើង, កាលអាចារ្យសួរថា ម្នាលព្រាហ្មណ៍ លោកសើចអ្វី ? ក៏ឆ្លើយថា កូនខ្ញុំមិនទាន់ស្លាប់ទេ ដែលស្លាប់នោះនឹងជាអ្នកដទៃ ។ អាចារ្យពោលថា ម្នាលព្រាហ្មណ៍ លោកបានឃើញឆ្អឹងបុត្ររបស់លោកហើយ ចូរជឿចុះ ហើយនាំឆ្អឹងចេញមកពោលថា នេះឆ្អឹងបុត្ររបស់លោក, ព្រាហ្មណ៍ពោលថា នេះនឹងបានជាឆ្អឹងពពែ ឬឆ្អឹងសុនខ តែកូនខ្ញុំមិនទាន់ស្លាប់ទេ ព្រោះក្នុងត្រកូលរបស់យើង ៧ ជំនាន់មកហើយ មិនមានអ្នកណាធ្លាប់ស្លាប់តាំងពីកំលោះឡើយ លោកនិយាយកុហក ។ ខណៈនោះ អ្នកទាំងអស់បានទះដៃ សើចដ៏ខ្លាំង ។ អាចារ្យឃើញសេចក្តីអស្ចារ្យនោះហើយ មានសេចក្តីសោមនស្ស កាលនឹងសួរថា ម្នាលព្រាហ្មណ៍ ក្នុងប្រពៃណីត្រកូលរបស់លោកដែលមនុស្សកំលោះៗ

មិនស្លាប់ បើមិនមានហេតុគង់មិនអាចប្រព្រឹត្តទៅបានទេ ព្រោះអ្វីមនុស្សក្រកំលោះៗ ទើបមិនស្លាប់ ដូច្នេះ បានពោលគាថាទី ១ ថា ៖

អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយរបស់អ្នក នេះជាផលសុចរិតធម៌ដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនោះដល់ខ្ញុំ ព្រោះហេតុអ្វីទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់អ្នកមិនស្លាប់ ។

បណ្តាបទទាំងនោះ បទថា **វតំ** គឺ ជាវត្តសមាទាន ។

បទថា **ព្រហ្មចរិយំ** គឺ ជាព្រហ្មចរិយដ៏ប្រសើរបំផុត ។

បទថា **កិស្ស សុចិណ្ណស្ស** សេចក្តីថា ការដែលមនុស្សនៅកំលោះៗ ក្នុងត្រកូលរបស់ពួកលោក មិនស្លាប់ជាផលនៃសុចរិតធម៌យ៉ាងណា ?

ព្រាហ្មណ៍បានស្តាប់ដូច្នោះហើយ កាលនឹងពណ៌នាគុណានុភាពដែលជាហេតុឲ្យមនុស្សកំលោះ ក្នុងត្រកូលនោះ មិនស្លាប់ ទើបពោលគាថាទាំងនេះថា ៖

ពួកយើងប្រព្រឹត្តធម៌ មិននិយាយកុហក វៀរនូវអំពើដ៏លាមក វៀរនូវអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង

ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

ពួកយើងស្តាប់ធម៌របស់អសប្បុរសផង សប្បុរសផង ប៉ុន្តែពួកយើង មិនពេញចិត្តនឹងធម៌របស់ពួកអសប្បុរសទេ ពួកយើងលះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

ពួកយើងមានចិត្តល្អ ក្នុងកាលមុនឲ្យ កាលកំពុងឲ្យ ក៏មានចិត្តត្រេកអរ លុះឲ្យហើយ ក៏មិនក្តៅក្រហាយក្នុងកាលជាក្រោយ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើង មិនស្លាប់ ។

ពួកយើងបានញុំាងសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូមយាចក និងអ្នកកំសត់ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់យើងមិនស្លាប់ ។

ពួកយើងមិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយាក៏មិនប្រព្រឹត្តកន្លងចិត្តពួកយើងដែរ ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌

លើកលែងតែកិរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទានក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយកុហក ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

កូនទាំងឡាយ (របស់យើង) កើតក្នុងពួកស្ត្រីដ៏ឧត្តម រមែងជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សុត ដឹងនូវវេទ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

មាតាបិតា បងប្អូនស្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើងគ្រប់គ្នាប្រព្រឹត្តធម៌ ដើម្បីជាប្រយោជន៍ ក្នុងលោកខាងមុខ ព្រោះហេតុនោះឯងទើបពួកជនទៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

ពួកខ្ញុំប្រុស ពួកខ្ញុំស្រី អ្នកចិញ្ចឹមជីវិតដោយសារអ្នកបម្រើ និងអ្នកធ្វើការងារទាំងអស់ ប្រព្រឹត្តធម៌ដើម្បីប្រយោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជនទៅក្មេង

(ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់ ។

បណ្ដាបទទាំងនោះ បទថា **ធម្មញ្ចរាម** បានដល់ ប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ប្រការ កុសលកម្មគ្រប់យ៉ាងជាដើមថា ពួកយើងមិនសម្លាប់សត្វដោយហោចទៅ សូម្បីស្រមោចខ្មៅចាកជីវិត ព្រោះហេតុនៃជីវិតខ្លួន និងមិនសម្លឹងមើលវត្ថុរបស់អ្នកដទៃដោយលោភចិត្ត ដែលបណ្ឌិតគប្បីពណ៌នាឲ្យពិស្ដារ ក៏ក្នុងគាថានេះ ព្រាហ្មណ៍ពោលដល់ការនិយាយមុសា តែពោលទុកដោយអំណាចនៃអកុសលកម្មដ៏ខ្ពស់ឡើងថា ដែលឈ្មោះថា បាបដែលបុគ្គលអ្នកនិយាយកុហកនឹងមិនធ្វើរមែងមិនមាន បានឮថា បុគ្គលទាំងនោះ មិននិយាយកុហក សូម្បីដោយប្រាថ្នានឹងឲ្យសើច ។

បទថា **បាបានិ** បានដល់ កម្មដ៏លាមកដែលជាហេតុឲ្យចូលដល់នរកសូម្បីគ្រប់យ៉ាង ។ បទថា **អនរិយំ** បានដល់ វៀរចាកកម្មដែលវៀរចាកភាពជាកម្មដ៏ប្រសើរ គឺកម្មដែលមិនល្អ បានដល់កម្មដែលមិនបរិសុទ្ធទាំងអស់ ។ **ហិ** អក្សរ ក្នុងពាក្យថា **តស្មា ហិ អម្ហំ** នេះត្រឹមតែជានិបាត អធិប្បាយថា ព្រោះហេតុនេះ ជននៅក្មេងៗ របស់ពួកយើងទើបមិនស្លាប់ គឺដែលឈ្មោះថា អកាល-

មរណៈ ក្នុងចន្ទោះ រមែងមិនមានដល់ពួកយើង, បាលីថា **តស្មា ហិ អម្ហំ** ដូច្នេះក៏មាន ។ បទថា **សុណោម** ជាដើម សេចក្ដីថា បានឮថា ពួកយើង ធម៌ដែលសម្ដែង(ពី)កុសលរបស់សប្បុរស ក៏ស្ដាប់ ធម៌ដែលសម្ដែង(ពី)អកុសលរបស់អសប្បុរស ក៏ស្ដាប់ ទាំងអស់ តែពួកយើងក៏ត្រឹមតែស្ដាប់ធម៌នោះហើយប៉ុណ្ណោះ មិនពេញចិត្តធម៌របស់អសប្បុរសនោះឡើយ; តែមិនឲ្យមានការឈ្លោះ ឬវិវាទនឹងអសប្បុរសទាំងនោះ, សូម្បីស្ដាប់ហើយ បានហើយ ក៏ប្រព្រឹត្តតាមសប្បុរស មិនលះបង់សប្បុរស សូម្បីតែមួយខណៈ, លះបង់អសប្បុរស គឺបាបមិត្តចេញហើយ ជាអ្នកសេពគប់តែកល្យាណមិត្តប៉ុណ្ណោះ ។

បទថា **សមណេ មយំ ព្រាហ្មណេ** សេចក្ដីថា ម្នាលព្រាហ្មណ៍ពួកយើងចិញ្ចឹមរក្សាសមណព្រាហ្មណ៍ គឺព្រះបច្ចេកពុទ្ធ ដែលមានបាបស្ងប់ហើយ មានបាបបណ្ដេតចោលហើយផង សមណព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌ដ៏សេសផង ជនដ៏សេស មាន អទ្ធិក (អ្នកដំណើរ) យាចក (អ្នកសូមទាន) ជាដើមផង ឲ្យឆ្អែតស្កប់ស្កល់សប្បាយដោយបាយ និងទឹក ។ ក៏ក្នុងព្រះបាលី គាថា

នេះ ក៏មកតាមក្រោយគាថាថា **បុព្វេ ទានា** ដូចគ្នា ។ បទថា **នាតិក្កមាម** សេចក្តីថា ពួកយើងមិនប្រព្រឹត្តកន្លងចិត្តភរិយារបស់ខ្លួន ធ្វើមិច្ឆាចារក្នុងស្រីដទៃក្នុងខាងក្រៅ ។ បទថា **អញ្ញត្រ តាហិ** សេចក្តីថា ពួកយើងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងស្ត្រីដ៏សេសក្រៅពីភរិយារបស់ខ្លួន សូម្បីភរិយារបស់ពួកយើង ក៏ប្រព្រឹត្ត ព្រហ្មចរិយធម៌ ក្នុងប្រុសដ៏សេសយ៉ាងនេះដូចគ្នា ។ បទថា **ជាយរេ** ប្រែថា រមែងកើត ។ បទថា **សុត្តមាសុ** គឺស្ត្រី ដ៏ខ្ពស់បំផុតអ្នកមានសីលល្អទាំងឡាយ ។

សេចក្តីនេះ អធិប្បាយថា បុត្រពួកណារបស់ពួកយើង កើតក្នុងស្ត្រីដ៏ឧត្តម អ្នកមានសីលបរិបូណ៌ទាំងនោះ បុត្រទាំងនោះ រមែងជាអ្នកមានប្រការយ៉ាងនេះ គឺជាអ្នកឆ្លាតជាដើម, សេចក្តីស្លាប់ក្នុងចន្លោះនឹងមានដល់បុត្រទាំងនោះ អំពីទីណាហ្ន៎ សូម្បីព្រោះហេតុនោះ ពួកជននៅក្មេង ក្នុងត្រកូលរបស់ពួកយើងទើបមិនស្លាប់ ។

បទថា **ធម្មញ្ចរាម** បានដល់ ប្រព្រឹត្តសុចរិតធម៌ ៣ ប្រការ ដើម្បីប្រយោជន៍ដល់បរលោក ។ ស្រីអ្នកបម្រើទាំងឡាយ ឈ្មោះថា ទាសី ។

ក្នុងទីបំផុត ព្រាហ្មណ៍ក៏បានសម្តែងគុណរបស់អ្នកប្រព្រឹត្តធម៌ ដោយគាថា ២ គាថាទាំងនេះថា ៖

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំមកនូវសេចក្តីសុខ នោះជាអានិសង្សក្នុងធម៌ ដែលបុគ្គលប្រព្រឹត្តល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ។

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ឆត្តំ មហន្តំ វិយ វស្សកាលេ
ធម្មេន គុត្តោ មម ធម្មបាលោ
អញ្ញស្ស អដ្ឋីនិ សុខី កុមាកោតិ ។

ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ដោយពិត ដូចឆត្រធំ (ការពារ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្តរបស់យើង ធម៌គ្រប់

គ្រងហើយ ឆ្អឹង(ដែលអ្នកនាំមកនេះ) ជាឆ្អឹងសត្វដទៃ កុមារ (ជាបុត្តរបស់យើង) មានសេចក្ដីសុខនៅឡើយ ។

បណ្ដាបទទាំងនោះ បទថា **រក្ខតិ** សេចក្ដីថា ធម្មតាថា ធម៌ដែលបុគ្គលរក្សាហើយនោះ រមែងត្រឡប់រក្សានូវបុគ្គលអ្នកមានធម៌ដែលខ្លួនរក្សាហើយ ។ បទថា **សុខមាវហាតិ** គឺ រមែងនាំសេចក្ដីសុខក្នុងទេវតា និងមនុស្សទាំងឡាយ និងនិព្វានសុខមកឲ្យ ។ បទថា **ន ទុគ្គតឹ** គឺ រមែងមិនទៅកាន់ទុគ្គតិ ដែលផ្សេងដោយទុគ្គតិមាននរកជាដើម ។

ព្រាហ្មណ៍នោះសម្ដែងថា ម្នាលព្រាហ្មណ៍ ពួកយើងរក្សាធម៌យ៉ាងនេះ សូម្បីធម៌ក៏រក្សាពួកយើងដូចគ្នា ។ បទថា **ធម្មេន គុត្តោ** គឺ ធម៌ដែលខ្លួនរក្សាដែលដូចជាឆត្រធំការពារហើយ ។ បទថា **អញ្ញស្ស អដ្ឋីនិ** សេចក្ដីថា ក៏ឆ្អឹងដែលលោកនាំមកនេះ ជាឆ្អឹងរបស់សត្វដទៃ គឺរបស់ពពែក៏ដោយ របស់សុនខក៏ដោយ លោកចូរចោលឆ្អឹងទាំងនោះចេញ បុត្ររបស់យើងនៅមានសេចក្ដីសុខ ។

អាចារ្យបានស្ដាប់ដូចនោះ ទើបពោលថា ការមករបស់ខ្ញុំ

ជាការមកល្អ មានផល មិនមែនគ្មានផលទេ ហើយមានសេចក្ដីត្រេកអរ សូមខមាទោសចំពោះបិតាធម្មបាលហើយ ពោលថា នេះជាឆ្អឹងពពែ ខ្ញុំនាំមកដើម្បីល្បងលោកមើល បុត្ររបស់លោកមិនមានរោគ (មានសេចក្ដីសុខសប្បាយ), លោកចូរឲ្យធម៌ដែលលោករក្សាដល់ខ្ញុំខ្លះ ដូច្នេះហើយសរសេរសេចក្ដីចុះក្នុងក្រាំង នៅក្នុងទីនោះ ២-៣ ថ្ងៃហើយ ទៅកាន់ក្រុងតក្កសិលាឲ្យធម្មបាលកុមារសិក្សាសិល្បៈគ្រប់យ៉ាង ហើយបញ្ជូនទៅដោយបរិវារធំ ។

ព្រះសាស្ដា គ្រាទ្រង់នាំព្រះធម៌ទេសនានេះមកសម្ដែងដល់ព្រះបាទសុទ្ធោទនមហារាជហើយ ទ្រង់ប្រកាសសច្ចធម៌ ក្នុងវេលាចប់សច្ចៈ ព្រះបាទសុទ្ធោទនមហារាជបានតាំងនៅក្នុងអនាគាមិ-ផល ។ ព្រះទសពលទ្រង់ប្រជុំជាតកថា មាតាបិតា ក្នុងគ្រានោះបានមកជាពុទ្ធមាតាពុទ្ធបិតាក្នុងឥឡូវនេះ, អាចារ្យ ក្នុងគ្រានោះបានមកជាព្រះសារីបុត្រ ក្នុងកាលឥឡូវនេះ, បរិស័ទក្នុងគ្រានោះបាន មកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ, ចំណែកធម្មបាលកុមារបានមក ជាយើងតថាគត ដូច្នេះឯង ។ (អដ្ឋកថា)

ចប់ មហាធម្មបាលជាតក ។

## ២២_ពួកជដិលច្រើនរូប

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងគយាសីសប្រទេសទៀបទន្លេគយា ។ សម័យនោះឯង ពួកជដិលច្រើនរូប នាំគ្នាងើបខ្លះ មុជខ្លះ ងើបមុជៗខ្លះ ស្រោចខ្ទនខ្លះ បំពក់ភ្លើងខ្លះ ទៀបកំពង់ឈ្មោះគយា ក្នុងសម័យនោះជាទីធ្លាក់ចុះនៃទឹកសន្សើម រវាង ៨ ថ្ងៃ ក្នុងវេលារាត្រីដ៏ត្រជាក់នៃហេមន្តរដូវ ដោយសេចក្តីគិតឃើញថា សេចក្តីបរិសុទ្ធិដោយអំពើនេះ ។ ព្រះមានព្រះភាគ ក៏បានឃើញពួកជដិលជាច្រើនទាំងនោះ ដែលកំពុងងើបខ្លះ មុជខ្លះ ងើបមុជៗខ្លះ ស្រោចខ្ទនខ្លះ បំពក់ភ្លើងខ្លះ ទៀបកំពង់ឈ្មោះគយា ។ ក្នុងសម័យជាទីធ្លាក់ចុះនៃទឹកសន្សើម រវាង ៨ ថ្ងៃ ក្នុងវេលារាត្រីដ៏ត្រជាក់នៃហេមន្តរដូវ ដោយសេចក្តីគិតឃើញថា សេចក្តីបរិសុទ្ធិដោយអំពើនេះ ។ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា ៖

ន ឧទកេន សុចិ ហោតិ ពហ្វេត្ថ ន្ហាយតី ជនោ

យម្ហិ សច្ចញ្ច ធម្មោ ច សោ សុចី សោ ច

ព្រាហ្មណោ ។

*បុគ្គលមិនមែនស្អាត ព្រោះទឹកទេ អ្នកផងច្រើនគ្នា រមែង ងូតទឹកនុ៎ះដែរ សច្ចៈ ១ ធម្មៈ ១ (មាននៅ) ក្នុងបុគ្គលណា បុគ្គលនោះទើបឈ្មោះថា ជាអ្នកស្អាតផង ឈ្មោះថាជា ព្រាហ្មណ៍ផង ។* *(សុត្តន្តបិដក ៥២, ១២៥)*

## ២៣. ពាហិយទារុចីរិយ

*ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ សម័យ នោះឯង ពាហិយទារុចីរិយបុរស (អ្នកស្លៀកដណ្តប់សំពត់សម្បក- ឈើ ឈ្មោះពាហិយៈ) អាស្រ័យនៅទៀបឆ្នេរសមុទ្រ ឈ្មោះ សុប្បារកៈ ជាអ្នកដែលគេធ្វើសក្ការៈ គោរពរាប់អាន បូជាកោត ក្រែង បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជ- បរិក្ខារ ។ កាលពាហិយទារុចីរិយបុរស ពួនសម្ងំនៅក្នុងទីស្ងាត់ ស្រាប់តែមានសេចក្តីត្រិះរិះកើតឡើងក្នុងចិត្តយ៉ាងនេះថា ពួកជន ណាមួយក្នុងលោក ជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គ បណ្តា*

អរហន្តទាំងនេះ ខ្ញុំនឹងអញជាព្រះអរហន្តមួយដែរ ។ លំដាប់នោះ ទេវតា ដែលជាសាលោហិត អំពីដើមរបស់ពាហិយទារុចីរិយ-បុរស ជាអ្នកអនុគ្រោះ ប្រាថ្នាប្រយោជន៍ បានដឹងច្បាស់នូវសេចក្ដីត្រិះរិះក្នុងចិត្ត ដោយចិត្តរបស់ពាហិយទារុចីរិយបុរស បានចូលទៅរកពាហិយទារុចីរិយបុរស លុះចូលទៅដល់ហើយ ក៏និយាយនឹងពាហិយទារុចីរិយបុរសយ៉ាងនេះថា នែពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ ទាំងមិនទាន់សម្រេចអរហត្តមគ្គទេ ខ្ញុំនឹងអ្នកមិនមានបដិបទាដែលនាំឲ្យបានជាព្រះអរហន្ត ឬសម្រេចអរហត្ត-មគ្គទេ ។ ពាហិយទារុចីរិយៈ សួរថា បើដូច្នោះក្នុងកាលឥឡូវនេះ ក្នុងលោក ព្រមទាំងទេវលោក តើជនណាជាអរហន្ត ឬបានសម្រេចអរហត្តមគ្គ មានដែរឬ ។ ទេវតាឆ្លើយថា ម្នាលពាហិយៈ មាន, ខាងជនបទឯជើង មានក្រុងមួយឈ្មោះសាវត្ថី ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគអង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សម្ដែងធម៌ដើម្បីអរហត្តផង ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ដែលទេវតានោះ ធ្វើឲ្យតក់ស្លុត ក៏ស្រាប់

តែគេចចេញអំពីឆ្នេរសមុទ្រឈ្មោះសុប្បារកៈ ក្នុងខណៈនោះភ្លាម ដោយការនៅតែក្នុងផ្លូវទាំងពួងអស់ ១ យប់ ក៏បានទៅដល់ព្រះមានព្រះភាគ ដែលកំពុងគង់ ក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

សម័យនោះ គាប់ចួនភិក្ខុច្រើនរូប កំពុងដើរចង្ក្រមក្នុងទីវាល ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏ឆៀងចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ហើយ ក៏បានសួរភិក្ខុទាំងនោះដូច្នេះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ គង់នៅទីណា យើងមានបំណងនឹងចូលទៅដើម្បីជួបព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ពួកភិក្ខុតបថា ម្នាលពាហិយៈ ព្រះមានព្រះភាគ ចូលកាន់ចន្លោះភូមិដើម្បីបិណ្ឌបាតទៅហើយ ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏មានដំណើរម្ទើម្ទាចេញពីវត្តជេតពនចូលទៅនគរសាវត្ថី បានឃើញព្រះមានព្រះភាគ កំពុងនិមន្តបិណ្ឌបាតក្នុងក្រុងសាវត្ថី ជាទីនាំមកនូវសេចក្តីជ្រះថ្លា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះទ័យស្ងប់ ទ្រង់បានដល់នូវការហាត់ពត់ និងការស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បាន

ទូន្មាន គ្រប់គ្រង សង្រួមឥន្ទ្រិយ ជាពុទ្ធនាគ គឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ មានសិរ្សៈឱនចុះទៀបព្រះបាទនៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។

កាលពាហិយទារុចីរិយបុរស អារាធនាយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយទារុចីរិយបុរសដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដ្បិតតថាគតចូលទៅកាន់ចន្លោះភូមិបិណ្ឌបាត ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តិទៅនៃជីវិតន្តរាយរបស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏វែងដល់ខ្ញុំព្រះអង្គ ឲ្យទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់

នឹងពាហិយទារុចីរិយបុរសអស់វារៈពីរដង យ៉ាងនេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដ្បិតតថាគតចូលកាន់ចន្លោះ ភូមិបិណ្ឌបាត្រសិន ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ អស់វារៈ ៣ ដង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយរបស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះ-អង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្ដែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្ដែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់រាត្រីវែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។

តស្មាតិហ តេ ពាហិយ ឯវំ សិក្ខិតព្វំ : ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតីតិ ។ ឯវញ្ហិ តេ ពាហិយ សិក្ខិតព្វំ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលអ្នកឮ

ហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ៗ

យតោ ខោ តេ ពាហិយ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ តតោ ត្វំ ពាហិយ ន តេន យតោ ត្វំ ពាហិយ ន តេន តតោ ត្វំ ពាហិយ ន តត្ថ យតោ ត្វំ ពាហិយ នេវត្ថ តតោ ត្វំ ពាហិយ នេវិធ ន ហុរំ ន ឧភយមន្តរេ ឯសេវន្តោ ទុក្ខស្សាតិ ។ ម្នាលពាហិយៈ រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ

អ្នកនឹងលែងមាន ម្នាលពាហិយៈ អ្នកនឹងលែងមាន ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងមិនមានក្នុងភពនេះ និងភពមុខ និងមិនមានក្នុងចន្លោះនៃលោកទាំងពីរ នេះឯងជាទីបំផុតនៃទុក្ខ ។

គ្រានោះ ចិត្តនៃពាហិយទារុចីរិយបុរស ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេប របស់ព្រះមានព្រះភាគនេះ ។

លុះព្រះមានព្រះភាគ ទ្រង់ទូន្មានពាហិយទារុចីរិយបុរស ដោយឱវាទសង្ខេបនេះហើយ ស្តេចចៀសចេញទៅ ។

កាលដែលព្រះមានព្រះភាគ ស្តេចចេញទៅផុតមិនយូរប៉ុន្មាន មេគោមានកូនខ្ចី ជល់ផ្តួលពាហិយទារុចីរិយបុរស ឲ្យដាច់ចាកជីវិតទៅ ។

លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់បិណ្ឌបាត ក្នុងនគរសាវត្ថី រួចត្រឡប់អំពីបិណ្ឌបាតវេលាខាងក្រោយភត្ត ចេញអំពីនគរជាមួយភិក្ខុច្រើនរូប បានទតឃើញពាហិយទារុចីរិយបុរស ធ្វើមរណកាល លុះទតឃើញហើយ ទើបត្រាស់ប្រាប់ពួកភិក្ខុថា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកសរីរៈពាហិយទារុចីរិយបុរស លើកដាក់លើគ្រែហើយនាំទៅដុតផង ធ្វើស្តូបដល់សរីរៈនោះផង ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) សព្រហ្មចារីរបស់អ្នកទាំងឡាយ ធ្វើមរណកាលហើយ ។

ពួកភិក្ខុទាំងនោះ ទទួលពុទ្ធដីការបស់ព្រះមានព្រះភាគ ថាព្រះករុណាព្រះអង្គ ហើយលើកសរីរៈពាហិយទារុចីរិបុរសដាក់លើគ្រែតូច នាំទៅរំលាយ ទាំងធ្វើស្តូបដល់សរីរៈនោះហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សរីរៈពាហិយ-ទារុចីរិយបុរស រំលាយហើយ ទាំងស្តូបសម្រាប់បញ្ចុះសរីរៈនោះក៏ធ្វើហើយ គតិរបស់គាត់តើដូចម្តេច ដំណើរក្នុងលោកខាងមុខតើដូចម្តេច ។

ព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយ-ទារុចីរិយបុរស ជាបណ្ឌិត បានប្រតិបត្តិធម៌គួរដល់ព្រះនិព្វានហើយ មិនបៀតបៀនតថាគត ព្រោះហេតុសម្តែងធម៌ទេ ម្នាល

ភិក្ខុទាំងឡាយ ពាហិយទារុចីរិយបុរសបរិនិព្វានហើយ ។

លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនោះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា ៖

យត្ថ អាបោ ច បឋវី តេជោ វាយោ ន គាធតិ
ន តត្ថ សុក្កា ជោតន្តិ អាទិច្ចោ នប្បកាសតិ
ន តត្ថ ចន្ទិមា ភាតិ តមោ តត្ថ ន វិជ្ជតិ ។
យទា ច អត្តនាវេទិ មុនិ មោនេន ព្រាហ្មណោ
អថ រូបា អរូបា ច សុខទុក្ខា បមុច្ចតិ ។

ទឹក ដី ភ្លើង ខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានធាតុណា ពួកផ្កាយមាននាមថា សុក្កៈ (មានពន្លឺ) រមែងមិនភ្លឺ ទាំងព្រះអាទិត្យ ក៏មិនរុងរឿងក្នុងនិព្វានធាតុនោះ ព្រះចន្ទ្រ ក៏មិនមានពន្លឺក្នុងនិព្វានធាតុនោះ ទាំងងងឹត ក៏មិនមានក្នុងនិព្វានធាតុនោះទេ ។ ព្រាហ្មណ៍មាននាមថា មុនី ព្រោះមោនប្បដិបត្តិ ដឹងច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ក្នុងកាលណា រមែងរួចចាករូបផង អរូបផង សុខទុក្ខផង ក្នុងកាលនោះ ។ (សុត្តន្តបិដក ខុទ្ទកនិកាយ ៥២,១២៦-១៣២) ។

បន្ទាប់ពីនេះទៅ នឹងពណ៌នាពីការបរិនិព្វានរបស់ព្រះមានព្រះភាគ ចាប់ដើមតាំងពីការដាក់អាយុសង្ខារតទៅ ៖

## ២៤-ព្រះមានព្រះភាគចូលទៅកាន់បាវាលចេតិយ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្ដេចចូលទៅទ្រង់បិណ្ឌបាត ក្នុងក្រុងវេសាលី លុះទ្រង់ត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងវេសាលី ហើយត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្ត ហើយទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈទៅ យើងនឹងចូលទៅសម្រាកក្នុងវេលាថ្ងៃឯបាវាលចេតិយ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាមៗ ខាងក្រោយព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ស្ដេចចូលទៅកាន់បាវាលចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ ចំណែកខាងព្រះអានន្ទមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះ

មានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលអានន្ទ ក្រុង វេសាលីជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមក ចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្ត-ចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ បាវាល-ចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គល ណាមួយបានចម្រើនហើយ បានធ្វើរឿយៗ ហើយ ធ្វើឲ្យដូចជា យានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គល នោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬ លើសជាងមួយអាយុកប្ប ក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយៗហើយ បានធ្វើឲ្យដូច ជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះ តថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។

ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើ

ឱកាសជាឱឡារិកយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏មិនអាចនឹងយល់សេចក្ដីច្បាស់លាស់បាន មិនបានអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ពួកទេវតា និងមនុស្សដូច្នេះសោះ ព្រោះមារចូលមកជ្រែកគំនិត ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលជាគំរប់ពីរដងផង ។បេ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទ ជាគំរប់បីដងផង ម្នាលអានន្ទ ក្រុងវេសាលីជាទីគួរត្រេកអរ ។ល។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយៗហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះបើប្រាថ្នានឹងឋិតនៅគប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។

ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏មិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកទេវតា និងមនុស្សទាំងឡាយដូច្នេះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ អ្នកចូរដឹងនូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយអង្គុយទៀបគល់ឈើមួយ ក្នុងទីមិនឆ្ងាយ ។

កាលបើព្រះអានន្ទមានអាយុ ចេញទៅហើយមិនយូរប៉ុន្មាន

គ្រានោះ ក្រុងមារមានចិត្តបាប ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ លុះក្រុងមារមានចិត្តបាប ឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប **ពួកភិក្ខុជាសាវករបស់តថាគត** ដែលឈ្លាសវាងវៃក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួនហើយប្រាប់ សម្ដែង បញ្ញត្ត តាំងទុក បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួន បានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្ដែងធម៌ប្រកបដោយបាដិហារ្យ ដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏

ចម្រើន ឥឡូវនេះ ពួកភិក្ខុជាសាវករបស់ព្រះមានព្រះភាគ បាន ឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ទាំងបានរៀន នូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិន បរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយ បាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះ មានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រ ព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមាន ព្រះភាគហើយ ; បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប **ពួកភិក្ខុនី ជា សាវិការបស់តថាគត** ដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ។ល។

បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បាន ត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប **ពួកឧបាសក ជា**

**សាវ័ករបស់តថាគត** ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ។ល។

បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បាន ត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប **ពួកឧបាសិកា ជាសាវិការបស់តថាគត** ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ។ល។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ ព្រះមានព្រះភាគហើយ ,

បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បាន ត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប **ព្រហ្មចារ្យ** របស់ តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយ ទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា នឹងមិនទាន់ពេញបរិបូរណ៍ ដរាបណា មួយទៀត ពួកទេវតានិងមនុស្ស មិនទាន់ចេះសម្តែង បានដោយប្រពៃដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ **ព្រហ្មចារ្យ**របស់ព្រះមាន ព្រះភាគនេះ ខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅ

សព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូរណ៍ហើយ ពួកទេវតា និងមនុស្ស បានបេះសម្តែងដោយល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ ។

## ២៥~ទ្រង់ដាក់អាយុសង្ខារ

កាលបើក្រុងមារ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ភាសិតនេះ ទៅនឹងក្រុងមារមានចិត្តបាប ថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ ឰដ៏បាវាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កក្រើកផែនដីដ៏ធំ គួរឲ្យភ្ញាក់ភ្ញើក ព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវដំណើរនោះហើយ ក៏បន្លឺនូវឧទាននេះ ក្នុង

វេលានោះថា ៖

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វាន ដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់ នូវសង្ខារដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរនូវ អារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះ ហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ)ផង ទ្រង់ បានទម្លាយនូវបណ្តាញ គឺកិលេសដែលកើតមាននៅក្នុង ខ្លួន ដូចជាក្រោះ ។

អដ្ឋកថាទីឃនិកាយ មហាវគ្គវណ្ណនា ពន្យល់ថា ៖

បទថា អប្បោស្សុក្កោ (មានសេចក្ដីខ្វល់ខ្វាយតិចចុះ) បានដល់ ប្រាសចាកសេចក្ដីអាល័យ ។ ព្រះមានព្រះភាគ ត្រាស់ ថា ម្នាលមារមានចិត្តបាប តាំងពីសប្តាហ៍ទី ៨ អ្នកត្រាច់ទៅ មកស្រែកអង្វរថា “សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូម ព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូម ព្រះអង្គបរិនិព្វានទៅ” ។ ឥឡូវនេះ តាំងពីថ្ងៃនេះទៅ អ្នកចូរ វៀរឧស្សាហ៍ កុំព្យាយាមឲ្យយើងបរិនិព្វានឡើយ ។

ពាក្យថា **ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារហើយ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ធ្វើសតិតាំងមាំដោយល្អ កំណត់ដោយព្រះញាណ ដាក់អាយុសង្ខារ ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់មិនបានដាក់អាយុសង្ខារ ដូចយកដៃចោលដុំដី ។ ទ្រង់កើតចិត្តគិតថា ទ្រង់នឹងចូលសមាបត្តិមិនដាច់រយៈត្រឹមតែ ៣ ខែប៉ុណ្ណោះ តអំពីនោះនឹងមិនចូល ។ លោកសំដៅយកសេចក្តីនោះ ទើបពោលថា ឱស្សជ្ជិ បាលីថា ឧស្សជ្ជិ ដូច្នេះក៏មាន ។

បទថា **កក្រើកផែនដីយ៉ាងធំ** បានដល់ មហាប្រថពីញាប់ញ័រ ។ បានឮថា គ្រានោះម៉ឺនលោកធាតុក៏ញាប់ញ័រ ។ ពាក្យថា **គួរឲ្យភ្ញាក់ភ្ញើក** បានដល់ កើតសេចក្តីគួរខ្លាច ។ បទថា **ទាំងស្គរក៏លាន់ឮឡើង** បានដល់ ពួកស្គរទិព្វក៏បន្លឺសំឡេងលាន់ឮ ផ្គរក៏គ្រហឹមលាន់ឮខុសរដូវកាលហើយ ផ្លេកបន្ទោរ រន្ទះ មិនមែនរដូវកាលក៏បញ្ចេញភ្លើងឆេតឆាត់ ។ លោកអធិប្បាយថា ភ្លៀងធ្លាក់មួយស្របក់ ។

ក្នុងពាក្យថា **បន្លឺនូវឧទាននេះ** សួរថា ទ្រង់ឧទានព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបានឮថា ឈ្មោះថា អ្នកណាៗ នឹងគប្បី

និយាយថា ព្រះមានព្រះភាគ ត្រូវមារជាប់តាមខាងក្រោយៗ អង្វររកកួនថា មេត្តាបរិនិព្វានចុះព្រះអង្គៗ ទ្រង់ដាក់អាយុសង្ខារ មិនមែនព្រោះខ្លាច ទើបទ្រង់បន្លឺឧទាន ដែលបន្លឺដោយកម្លាំងបីតិ ដើម្បីសម្តែងសេចក្តីនេះថា ឈ្មោះថា ពាក្យឧទាន រមែងមិនមានដល់អ្នកខ្លាចថា សូមមារកុំមានឱកាសឡើយ ។

ក្នុងឧទាននោះ ឈ្មោះថា **តុលៈ** ព្រោះថ្លឹងកំណត់ដោយការៈដែលប្រចក្សរបស់សត្វមានភ្នែក ភ្នែកចចកជាដើមទាំងអស់ ។ កម្មដែលថ្លឹងបាននោះជាយ៉ាងណា, បានដល់ កម្មផ្នែកកាមាវចរ ។ ឈ្មោះថា **អតុលៈ** ព្រោះថ្លឹងមិនបាន ។ ឬលោកិយកម្មយ៉ាងដទៃដែលប្រៀបដូចជាកាមាវចកម្មនោះមិនមាន ។ កម្មដែលថ្លឹងមិនបាននោះជាយ៉ាងណា បានដល់ កម្មផ្នែកមហគ្គតៈ ។ ម្យ៉ាងទៀត កាមាវចរកម្ម រូបាវចរកម្ម ចាត់ជាតុលៈ អរូបាវចរកម្ម ចាត់ជាអតុលៈ ។ ម្យ៉ាងទៀត កម្មដែលមានវិបាកតិច ឈ្មោះថា តុលៈ ដែលមានវិបាកច្រើន ឈ្មោះថា អតុលៈ ។ បទថា **សម្ភវំ** (ភព) បានដល់ កម្មដែលធ្វើជាដុំ អធិប្បាយថា ធ្វើជាកងដែលជាហេតុកើត ។ បទថា **ភវសង្ខារំ** (សង្ខារដែលនាំសត្វទៅកាន់ភព)

*បានដល់ កម្មដែលតាក់តែងភពថ្មី ។ បទថា* ***អវស្សជ្ជិ*** *(ទ្រង់លះបង់) បានដល់ ដាក់ ។ បទថា* ***មុនី*** *(អ្នកប្រាជ្ញ) បានដល់ អ្នកប្រាជ្ញ គឺព្រះពុទ្ធ ។ បទថា* ***អជ្ឈត្តរតោ*** *(ត្រេកអរនូវអារម្មណ៍ខាងក្នុង គឺត្រេកអរខាងក្នុងពិតប្រាកដ ។ បទថា* ***សមាហិតោ*** *(តាំងមាំហើយ គឺតាំងមាំហើយ ដោយឧបចារសមាធិនិងអប្បនាសមាធិ ។ បទថា* ***អភិន្ទិ កវចមិវ*** *(ទម្លាយនូវបណ្តាញដូចក្រោះ) បានដល់ ទម្លាយកិលេស ដូចក្រោះ ។ បទថា* ***អត្តសម្ភវំ*** *(ដែលកើតមាននៅក្នុងខ្លួន) បានដល់ កិលេសដែលកើតហើយក្នុងខ្លួន ។ លោកអធិប្បាយទុកថា ព្រះមុនីទ្រង់ដោះផុតពីលោកិយកម្ម ពោលគឺតុលកម្ម និងអតុលកម្ម ដែលបានឈ្មោះថា* ***សម្ភវៈ*** *ព្រោះអត្ថថា មានវិបាក ថា***ភវសង្ខារ** *ព្រោះអត្ថថា តាក់តែងភព និងទ្រង់ត្រេកអរខាងក្នុងតាំងមាំហើយ ទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចជាអ្នកចម្បាំងធំ ក្នុងសមរភូមិទម្លាយក្រោះ ដូច្នោះ ។*

*ន័យមួយទៀត បទថា* ***តុលំ*** *(ថ្លឹង) បានដល់ ថ្លឹងថ្លែង គឺពិចារណា ។ បទថា* ***អតុលញ្ច សម្ភវំ*** *(នូវគុណដែលថ្លឹងមិនបានផង) នូវការកើតផង បានដល់ ព្រះនិព្វាននិងភព ។ បទថា*

***ភវសង្ខារំ*** (ការតាក់តែងភព) បានដល់ កម្មដែលទៅកាន់ភព ។ បទថា ***អវស្សជ្ជិ មុនី*** (អ្នកប្រាជ្ញទ្រង់លះបង់) សេចក្តីថា ព្រះមុនីគឺព្រះពុទ្ធទ្រង់ពិចារណាដោយន័យជាដើមថា “ខន្ធ ៥ មិនទៀង, ការរលត់ខន្ធ ៥ គឺ និព្វានដ៏ទៀង” ទ្រង់ឃើញទោសក្នុងភព និងអានិសង្សក្នុងនិព្វានហើយ ទ្រង់រួចផុតដោយអរិយមគ្គ ដែលធ្វើការអស់កម្មដែលលោកពោលទុកយ៉ាងនេះថា កម្មគ្រឿងតាក់តែងភព ដែលជាមូលនៃខន្ធទាំងឡាយនោះ តែងប្រព្រឹត្តទៅដើម្បីអស់ទៅនៃកម្ម ដូច្នេះ ។ ព្រះអង្គទ្រង់ត្រេកអរខាងក្នុងតាំងមាំហើយទ្រង់ទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចក្រោះបានយ៉ាងណា ។ សេចក្តីពិត ព្រះមុនីនោះ ទ្រង់ត្រេកអរខាងក្នុងដោយអំណាចវិបស្សនា ទ្រង់តាំងមាំដោយអំណាចសមថៈ រួមសេចក្តីថា ព្រះអង្គទ្រង់ទម្លាយសំណាញ់គឺកិលេសទាំងអស់ ដែលតាំងនៅរួបរឹតអត្តភាពដូចក្រោះ ដែលបានឈ្មោះថា ***អត្តសម្ភវៈ*** ព្រោះកើតក្នុងខ្លួន ដោយកម្លាំងសមថៈនិងវិបស្សនា តាំងពីខាងដើម និងលះកម្មដោយការលះកិលេសយ៉ាងនេះថា កម្មដែលធ្វើដោយមិនមានកិលេស ឈ្មោះថា នៅសល់ ព្រោះមិនមានបដិសន្ធិ ។ គប្បី

ជ្រាបថា ឈ្មោះថា សេចក្តីខ្លាចរបស់អ្នកលះកិលេសបានហើយមិនមាន ព្រោះដូច្នោះ ព្រះមុនីទ្រង់មិនខ្លាចហើយ ទើបទ្រង់ដាក់អាយុសង្ខារ ព្រោះហេតុនោះ ទើបទ្រង់បន្លឺឧទាន ដើម្បីឲ្យដឹងថាទ្រង់មិនខ្លាច ។

## ២៦_បច្ច័យដែលនាំឱ្យកក្រើកផែនដីមាន ៨ យ៉ាង

លំដាប់នោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុជាអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចំឡែកពេកណាស់ ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ គួរឲ្យក្ខុកក្អឹក ឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង មានហេតុដូចម្តេច មានបច្ច័យដូចម្តេចហ្ន៎ នាំឲ្យកក្រើកផែនដីជាយ៉ាងធំម្ល៉េះ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុជាអស្ចារ្យ មានហេតុដ៏ប្លែក

បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះធំពេកណាស់ គួរឲ្យភ្លូកភ្លឹកឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំម៉្លេះ ។

ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ឯហេតុបច្ច័យដែលនាំឲ្យកក្រើកផែនដីនេះមាន ៨ យ៉ាង ។

ហេតុបច្ច័យទាំង ៨ យ៉ាង តើដូចម្តេចខ្លះ ។

ម្នាលអានន្ទ មហាប្រឹថពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់ធំបក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដីឲ្យកក្រើកដែរ នេះជាហេតុ ជាបច្ច័យទី ១ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាព

ធំ បុគ្គលនោះបានចម្រើនបបវីសញ្ញា ឲ្យមានកម្លាំងតិច ចម្រើនអាបោសញ្ញាឲ្យមានកម្លាំងច្រើន បុគ្គលនោះ រមែងធ្វើផែនដីនេះឲ្យកក្រើករំពើករំភើបញាប់ញ័របាន នេះជាហេតុ ជាបច្ច័យទី ២ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ ច្យុតចាកពួកទេវតា ដែលឋិតនៅក្នុងឋានតុសិតមានសតិ និងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៣ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ មានសតិនិងសម្បជញ្ញៈ ទ្រង់ប្រសូតចាកព្រះមាតុឧទរ ក្នុងកាលនោះផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៤ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះតែង

កក្រើករំពើក រំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៥ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគតញ៉ាំងអនុត្តរធម្មចក្កឲ្យប្រព្រឹត្តទៅ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៦ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត មានសតិនិងសម្បជញ្ញៈ ដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំពើក រំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៧ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគតបរិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំពើក រំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៨ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។

ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំមាន ៨ យ៉ាងនេះឯង ។

ក្នុងអដ្ឋកថា អធិប្បាយថា ៖

បទថា យំ មហាវាតា (ខ្យល់ធំណា) សេចក្ដីថា ព្រោះសម័យណា ឬក្នុងសម័យណា ខ្យល់ធំរមែងបក់ ។ បទថា **ខ្យល់ធំដែលបក់** បានដល់ ធម្មតាថា ខ្យល់ឧក្ខេបកៈ កាលកើតឡើង ក៏បក់កាត់ខ្យល់ដែលទ្រទឹកកម្រាស់ ៩៦០,០០០ យោជន៍ អណ្ដែតដាច់ចេញ តពីនោះទឹកក៏ធ្លាក់ចុះក្នុងអាកាស កាលទឹកធ្លាក់ចុះ ផែនដីក៏ធ្លាក់ចុះ ។ ខ្យល់ក៏ទ្រទឹកទុកទៀត ដោយកម្លាំងរបស់ខ្លួនដូចជាទឹកខាងក្នុងធម្មក្រក ។ តែទឹកនោះក៏បាញ់ឡើង ។ កាលទឹកបាញ់ឡើងផែនដីក៏ប៉ោងឡើង ទឹកកម្រើកហើយ ក៏ធ្វើឲ្យផែនដីកម្រើកយ៉ាងនេះ ។ ការកម្រើករបស់ទឹកនិងផែនដី រមែងមានមកដរាបដល់រាល់ថ្ងៃនេះ ដោយប្រការដូច្នេះ ។ តែសេចក្ដីផតចុះ និងប៉ោងឡើង រមែងមិនប្រាកដព្រោះជារបស់ក្រាស់ ។

ក្នុងហេតុកម្រើកផែនដី ៨ ប្រការនេះ ដូចពោលមកនេះ ហេតុទី ១ ញាប់ញ័រដោយធាតុកម្រើក ហេតុទី ២ ញ័រដោយអានុភាពរបស់អ្នកមានឫទ្ធិ ហេតុទី ៣ និងហេតុទី ៤ ញ័រដោយ

តេជនៃបុណ្យ ហេតុទី ៥ ញ័រដោយអំណាចនៃញាណ ហេតុទី ៦ ញ័រដោយអំណាចសាធុការ ហេតុទី ៧ ញ័រដោយអំណាចភាពជាអ្នកមានករុណា ហេតុទី ៨ ញ័រដោយការស្រែកយំ ។

កាលព្រះមហាសត្វចុះកាន់ព្រះគភ៌ព្រះមាតា និងប្រសូតចាកព្រះគភ៌នោះ ផែនដីញ័រដោយអំណាចនៃបុណ្យរបស់ព្រះអង្គ ។ គ្រាត្រាស់ដឹងអភិសម្ពោធិញាណ ផែនដីញ័រដោយអំណាចព្រះញាណ គ្រាប្រកាសព្រះធម្មចក្រ ផែនដីក៏កក្រើកឡើង ឲ្យសាធុការ គ្រាដាក់អាយុសង្ខារ ផែនដីកក្រើកញ័រឡើងដោយសេចក្តីករុណា អត់ទ្រាំសេចក្តីញាប់ញ័រនៃចិត្តមិនបានក៏កម្រើក ។ គ្រាបរិនិព្វាន ផែនដីក៏ត្រូវបន្ថែមដោយកម្លាំងការស្រែកយំ ក៏កម្រើក ។

ក៏សេចក្តីនេះ គប្បីជ្រាបដោយអំណាចទេវតាដែលឋិតនៅលើផែនដី ។ តែហេតុនេះ មិនមានដល់បឋវីធាតុ ដែលជាមហាភូតរូប ព្រោះមិនមានចេតនានោះឯង ។ (អដ្ឋកថា)

- ម្នាលអានន្ទ បរិស័ទនេះមាន ៨ ពួក ។ បរិស័ទ ៨ ពួក តើដូចម្តេច ? គឺ ខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហបតិបរិស័ទ

សមណបរិស័ទ ចាតុម្មហារាជិកបរិស័ទ តាវត្តិង្សបរិស័ទ មារបរិស័ទ ព្រហ្មបរិស័ទ ។

- ម្នាលអានន្ទ អភិភាយតនៈ (ហេតុជាគ្រឿងគ្របសង្កត់នូវបច្ចនិកធម៌) នេះមាន ៨ ប្រការ ។

- ម្នាលអានន្ទ វិមោក្ខ (ធម៌ជាគ្រឿងរួចចាកអាសវៈ) នេះមាន ៨ ប្រការ ។

- ម្នាលអានន្ទ សម័យមួយ តថាគតបានត្រាស់ដឹងជាដំបូង បានគង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេសឯណោះ ។ ម្នាលអានន្ទ គ្រានោះឯង ក្រុងមារមានចិត្តបាប បានចូលទៅរកតថាគត លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះក្រុងមារមានចិត្ត-បាប ឋិតនៅក្នុងទីដ៏សមគួរហើយ បាននិយាយយ៉ាងនេះនឹងតថា-គតថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ បរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ, ម្នាលអានន្ទ កាលបើក្រុងមារ បាននិយាយយ៉ាងនេះហើយ

តថាគតបានពោលពាក្យនេះនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប **ពួកភិក្ខុជាសាវ័ករបស់តថាគត** ដែលឈ្លាស វាងវៃក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្តតាំងទុក បើក បែក ធ្វើឲ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួន បានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។

ម្នាលមារមានចិត្តបាប **ពួកភិក្ខុនី** ។ល។

ម្នាលមារមានចិត្តបាប **ពួកឧបាសក** ។ល។

ម្នាលមារមានចិត្តបាប **ពួកឧបាសិកា** ។ល។

ម្នាលមារមានចិត្តបាប **ព្រហ្មចារ្យ** របស់តថាគតនេះនៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិសគេមិនទាន់ដឹងច្រើនគ្នា នឹងមិនទាន់ពេញបរិបូរណ៍ដរាបណា មួយ

ទៀត ពួកទេវតានិងមនុស្ស មិនទាន់ចេះសម្តែងបានដោយប្រពៃ ដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។

ម្នាលអានន្ទ ថ្ងៃនេះ ក្រុងមារមានចិត្តបាប បានចូលមករកតថាគត ក្នុងបាវាលចេតិយ អម្បាញ់មិញនេះឯង បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះមារមានចិត្តបាប បានឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះ-អង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ បានត្រាស់វាចានេះថា ម្នាលមារមានចិត្តបាប **ពួកភិក្ខុជាសាវ័ករបស់តថាគត** នៅមិនទាន់មាន ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ ។

**ពួកភិក្ខុនី ជាសាវិការបស់តថាគត** ។បេ។

ម្នាលអានន្ទ កាលបើក្រុងមារមានចិត្តបាប បាននិយាយយ៉ាងនេះហើយ តថាគតក៏បានពោលពាក្យនេះទៅនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប

ចូរអ្នកមានសេចក្ដីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ, ម្នាលអានន្ទ ក្នុងថ្ងៃនេះ តថាគតមានសតិសម្បជញ្ញៈ បានដាក់អាយុសង្ខារ ក្នុងបាវាលចេតិយ អម្បាញ់មិញនេះឯង ។

កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធតម្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បានក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគតឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

ម្នាលអានន្ទ ឥឡូវនេះ កុំឡើយ អ្នកកុំអង្វរតថាគតឡើយ ម្នាលអានន្ទ ឥឡូវនេះ មិនមែនជាកាលគួរអារាធនាតថាគតទេ ។

ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលជាគំរប់ពីរដងផង ។ល។ ជាគំរប់បីដងផង ។ល។

ម្នាលអានន្ទ អ្នកជឿពោធិញ្ញាណរបស់តថាគតដែរឬ ?

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។

ម្នាលអានន្ទ បើអ្នកជឿដែរ ហេតុអ្វីក៏អ្នកនៅតែទទូចតថាគតដល់ទៅ ៣ ដង ។

បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកានេះ ខ្ញុំព្រះអង្គបានស្ដាប់ក្នុងទីចំពោះព្រះភក្ត្រ បានត្រងរងក្នុងទីចំពោះព្រះភក្ត្រថា ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយ-អាយុកប្បក៏បាន, ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំ

ទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគត ប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាង មួយអាយុកប្ប ក៏បាន ។

ម្នាលអានន្ទ អ្នកជឿឬទេ ?

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។

ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ព្រោះតថាគត បានធ្វើនិមិត្តជាឱឡារិក បានធ្វើឱកាស ជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនយល់សេចក្តីច្បាស់លាស់បាន មិនអារាធនាតថាគតថា សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគតឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដូច្នេះសោះ, ម្នាលអានន្ទ បើអ្នកអារាធនាតថាគត តថាគតគប្បីឃាត់វាចារបស់អ្នកត្រឹមតែពីរលើក តែដល់ទៅបីលើក តថាគតគប្បីទទួល ម្នាលអានន្ទ

ព្រោះហេតុនោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

## ២៧. ទ្រង់ធ្វើនិមិត្ត ១៦ កន្លែង

### ទៀបក្រុងរាជគ្រឹះ ១០ កន្លែង

១- ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ

២- ទ្រង់គង់នៅគោតមនិគ្រោធ

៣- ទ្រង់គង់នៅជិតជ្រោះជាទីទម្លាក់នូវចោរ

៤- ទ្រង់គង់នៅក្នុងសត្តបណ្ណគុហា (គុហាដែលគេសន្មតដោយដើមសត្តបណ្ណព្រឹក្ស) ខាងភ្នំវេភារៈ

៥- ទ្រង់គង់នៅក្នុងកាឡសិលា ខាងភ្នំឥសិគិលិ

៦- ទ្រង់គង់នៅក្នុងសប្បសោណ្ឌិកបព្ភារៈ (ញកមានត្រពាំងទឹកជាទីនៅនៃពស់) ក្នុងសីតវន (ព្រៃត្រជាក់)

៧- ទ្រង់គង់នៅក្នុងតបោទារាម

៨- ទ្រង់គង់នៅក្នុងវេឡុវនកលន្ទកនិវាបស្ថាន

៩- ទ្រង់គង់នៅក្នុងជីវកម្ពវន

*១០- ទ្រង់គង់នៅក្នុងមទ្ទកុច្ឆិមិគទាយវ័ន ។*

## ទៀបក្រុងវេសាលី ៦ កន្លែង

*១- ទ្រង់គង់នៅក្នុងឧទេនចេតិយ*

*២- ទ្រង់គង់នៅក្នុងគោតមកចេតិយ*

*៣- ទ្រង់គង់នៅក្នុងសត្តម្ពចេតិយ*

*៤- ទ្រង់គង់នៅក្នុងពហុបុត្តចេតិយ*

*៥- ទ្រង់គង់នៅក្នុងសារន្ទទចេតិយ*

*៦- ទ្រង់គង់នៅក្នុងបាវាលចេតិយ ។*

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតប្រាប់អ្នកជាមុនហើយយ៉ាងនេះថា សេចក្តីព្រាត់ប្រាស សេចក្តីវិនាស សេចក្តីប្រែប្រួលចាកសត្វនិងសង្ខារ ជាទីស្រឡាញ់ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ មិនព្រាត់ប្រាសក្នុងខន្ធប្រវត្តិនេះអំពីណា ធម្មជាតិណា កើតឡើងហើយ មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្តីវិនាសទៅជាធម្មតា ធម្មជាតិនោះឯងបុគ្គល*

នឹងពោលឃាត់ថា កុំវិនាសដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ។

ម្នាលអានន្ទ មួយទៀត ធម្មជាតណា ដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្ទាត់ចោលហើយ អាយុសង្ខារតថាគតដាក់ចុះហើយ វាចាតថាគតពោលដោយពិតថា បរិនិព្វានៃតថាគតមិនយូរឡើយ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ តថាគតនឹងត្រឡប់មកកាន់ធម្មជាតនោះវិញទៀត ព្រោះហេតុនៃជីវិតប៉ុណ្ណោះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ, ម្នាលអានន្ទមកយើងនឹងទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

<u>អដ្ឋកថាថា</u> ពាក្យថា តំ ក្នុងពាក្យថា តំ កុតេត្ថ លព្ភា (ព្រោះហេតុនោះ បុគ្គលគប្បីបានអំពីទីណា) ត្រូវប្រែថា ព្រោះហេតុនោះ ។ អធិប្បាយថា ព្រោះនឹងត្រូវព្រាត់ប្រាសចាកសត្វនិងសង្ខារដែលជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់

នោះឯង ដូច្នោះ តថាគតបំពេញបារមី ១០ ក្តី សម្រេចសម្ពោធិ-ញ្ញាណក្តី ប្រកាសធម្មចក្រក្តី សម្តែងយមកបាដិហារ្យក្តី ចុះអំពីទេវលោកក្តី សរីរៈនោះណាដែលកើតហើយ មានហើយ ត្រូវសង្ខារតាក់តែងហើយ មានសេចក្តីវិនាសទៅជាធម្មតារបស់សរីរៈសូម្បីនៃព្រះតថាគតនោះកុំវិនាសទៅឡើយ ។ នោះមិនមែនឋានៈដែលនឹងមានបានទេ ទាំងអ្នកស្រែកយំ ទាំងអ្នកត្អូញត្អែរ ក៏អាចនឹងបានឋានៈយ៉ាងនោះ ។

## ២៨-ទ្រង់ឱ្យប្រជុំភិក្ខុសង្ឃ

លំដាប់នោះ ព្រះមានព្រះភាគ ក៏ស្តេចយាងចូលទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន មួយអន្លើយដោយព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋាន-សាលា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ, ហើយក៏ឲ្យពួកភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុង

ឧបដ្ឋានសាលា, ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ជ្រាបនូវកាលគួរ ក្នុងកាលឥឡូវនេះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលជាអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញា

ដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេពចម្រើន ធ្វើរឿយៗ ដោយប្រការដូច្នោះ ។

ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលយូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេពចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ តើដូចម្តេច ។ អ្វីខ្លះ ។ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។

ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលយូរ, មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជន

ច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្ដែងហើយដោយបញ្ញាដ៏ឧត្ដម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។

<u>អដ្ឋកថាថា</u> : បទថា យថយិទំ ព្រហ្មចរិយំ (ព្រហ្មចរិយៈនេះ) សេចក្ដីថា គឺសាសនព្រហ្មចរិយដែលសង្គ្រោះដោយសិក្ខា ៣ ។ បទថា អទ្ធនិយំ (គប្បីតាំងនៅអស់កាលអង្វែង) គឺតាំងនៅជាអង្វែង ។ បទថា ចិរដ្ឋិតិកំ (គប្បីតម្កល់នៅអស់កាលយូរ) បានដល់ តម្កល់នៅយូរដោយអំណាចប្រព្រឹត្តទៅអស់កាលយូរ ។ បទថា ចត្តារោ សតិប្បដ្ឋានា (សតិប្បដ្ឋាន ៤) ជាដើម ទាំងអស់លោកពោលដោយអំណាចជាលោកិយៈ និងលោកុត្តរៈ ។ ចំណែកការវិនិច្ឆ័យក្នុងពោធិបក្ខិយធម៌ទាំងនេះ លោកពោលទុកក្នុងបដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស ក្នុងវិសុទ្ធិមគ្គដោយអាការទាំងពួង ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងជាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយ មានសេចក្ដីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ បរិនិព្វានទឹងមានដល់តថាគត មិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏មានព្រះបន្ទូលដូច្នេះ តទៅទៀតថា ៖

ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។
យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទនបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។

ពួកជនណាៗ ទោះបីក្មេងក្ដី ចាស់ក្ដី ពាលក្ដី បណ្ឌិតក្ដី អ្នកមានក្ដី អ្នកក្រក្ដី ជនទាំងអស់នោះ តែងមានសេចក្ដីស្លាប់នៅពីខាងមុខ ។ ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបី តូចក្ដី ធំក្ដី ឆ្អិនក្ដី ឆៅក្ដី

*កាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។*

*ព្រះសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះតទៅទៀតថា ៖*

បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ
បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ,

*វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។*

អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។

*ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយៗ ចុះ ។*

យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។ (សុត្តន្តបិដក ១៦, ២៥៣-២៥៧)

## ២៩. ការទ្រង់ទតក្រុងវេសាលីជាបច្ឆិមទស្សនៈ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី លុះស្តេចទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ទ្រង់ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយកត្ត ទ្រង់ងាកក្រឡេកមើលនូវក្រុងវេសាលី ដូចជាដំរីដែលក្រឡេកបែរមើល (នូវទីខាងក្រោយ) ហើយត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ តថាគតឃើញក្រុងវេសាលីម្តងនេះ ជាបច្ឆិមទស្សនៈ ការឃើញជាទីបំផុត, ម្នាលអានន្ទ មកយើងនឹងទៅកាន់ភណ្ឌគ្រាម ។ល។

ក្នុងទីនោះឯងព្រះមានព្រះភាគ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរ

អង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវធម៌ទាំង ៤ យ៉ាង ។ល។ ចាក់ធ្លុះនូវអរិយសីល, អរិយសមាធិ, អរិយបញ្ញា, អរិយវិមុត្តិ ។ល។

បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅកណ្ឌគ្រាមនោះ ទ្រង់ធ្វើនូវធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ, សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន, បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន, ចិត្តដែលអប់រំ ដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃចាកអាសវៈទាំងឡាយ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅកណ្ឌគ្រាម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និងភោគនគរ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

## ៣០-មហាបទេស ៤

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់កោគនគរ ព្រមដោយភិក្ខុសង្ឃជាច្រើនអង្គ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតកោគនគរនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងមហាបទេសទាំង ៤ នេះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា :

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ ត្រូវរៀនទូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទាបស្ទង់មើល ក្នុងព្រះ

សូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិនប្រជុំចុះ គឺមិនមានក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគទេ ជាពាក្យដែលភិក្ខុនេះ រៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយត្រូវបោលពាក្យនុ៎ះចេញ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទាបស្ទង់មើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិន័យផង ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះ ដែលភិក្ខុនេះរៀនត្រូវល្អហើយដោយពិត, ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេស ជាបឋមនេះចុះ ។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មាន

ទាំងភិក្ខុជាប្រធាន ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះសង្ឃនោះ ថា នេះជាធម៌ នេះជាវិន័យ ។ល។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈ ទាំងនោះថា នេះជាធម៌ នេះជាវិន័យ ។ល។

-ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈនៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា ។ល។

បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអានន្ទចេតិយជិតភោគនគរនោះឯង ទ្រង់ធ្វើនូវធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្ស

ច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃចាកអាសវៈទាំងឡាយ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

អដ្ឋកថាថា : ពាក្យថា **កុំអាលត្រេកអរ** គឺដែលអ្នករីករាយ ត្រេកអរឲ្យសាធុការ គួរស្តាប់មុនក៏ទេ ។ ពិតមែន កាលធ្វើយ៉ាងនេះ សូម្បីខាងក្រោយត្រូវតបថា រឿងនេះមិនសមរម្យ ក៏ឆ្លើយឆ្លងបានថា កាលមុនរឿងនេះជាធម៌ ឥឡូវនេះ មិនជាធម៌ឬ ឈ្មោះថា មិនលះបង់លទ្ធិ ។ ពាក្យថា **កុំអាលឃាត់** សេចក្តីថា មិនគប្បីពោលមុនយ៉ាងនេះថា ជនពាលនេះនិយាយអ្វី ។ ក៏កាលត្រូវចំពោះថា នឹងមិននិយាយសូម្បីតែពាក្យដែលគួរនឹងនិយាយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **អនភិនន្ទិត្វា អប្បដិក្កោសិត្វា** (មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ) ។ ពាក្យថា **បទនិងព្យញ្ជនៈ** បានដល់ ព្យញ្ជនៈពោលគឺបទ ។ ពាក្យថា **ត្រូវរៀនឲ្យចាំល្អ** បានដល់ កាន់យកដោយល្អថា លោកពោលបាលីទុកក្នុងទីនេះ ពោលសេចក្តីទុកក្នុងទីនេះ ពោលខាងដើម

និងខាងចុងទុកក្នុងទីនេះ ។ ពាក្យថា **ស្ទាបស្ទង់មើលក្នុងសូត្រ** បានដល់ គប្បីដេញដោលសួរក្នុងព្រះសូត្រ ។ ពាក្យថា **ប្រៀបធៀបមើលក្នុងព្រះវិន័យ** បានដល់ ប្រៀបផ្ទឹមក្នុងព្រះវិន័យ ។

ក៏ក្នុងទីនេះ ដែលឈ្មោះថា **សូត្រ** បានដល់ វិន័យ ។ ដូចដែលលោកពោលទុកថា "ចុះព្រះមានព្រះភាគ ទ្រង់ឃាត់ក្នុងទីណា ។ ព្រះមានព្រះភាគ ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី ។" (សុត គឺវិន័យ) ដែលឈ្មោះវិន័យ បានដល់ ខន្ធកៈ ដូចដែលលោកពោលទុកថា **កោសម្ពិយំ វិនយាតិសារេ** ក្នុងរឿងប្រព្រឹត្តកន្លងខន្ធកៈ ក្នុងក្រុងកោសម្ពី ។ កាលជាដូច្នេះឈ្មោះថា មិនកាន់យកវិនយបិដក ។ ឈ្មោះថា កាន់យកព្រះវិន័យយ៉ាងនេះ គឺ ឧភតោវិភង្គ ឈ្មោះថា **សុត្ត**, ខន្ធកបរិវារ ឈ្មោះថា **វិន័យ** ។ ន័យមួយទៀត កាន់យកបិដកទាំង ២ យ៉ាងនេះគឺ សុត្តន្តបិដក ឈ្មោះថា ព្រះសូត្រ វិនយបិដក ឈ្មោះថា វិន័យ ។ ម្យ៉ាងវិញទៀត មិនកាន់យកបិដកទាំង ៣ សូម្បីយ៉ាងនេះមុន សុត្តន្តបិដក អភិធម្មបិដក ឈ្មោះថា **សុត្ត**, វិនយបិដក ឈ្មោះថា វិន័យ ។ ធម្មតាពុទ្ធវចនៈណាៗ ដែលឈ្មោះថា មិនមែនសូត្រក៏មាន គឺ

ជាតក បដិសម្ភិទា និទ្ទេស សុត្តនិបាត ធម្មបទ ឧទាន ឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា អបទាន ។

ក៏ព្រះសុទិន្នត្ថេរ ជំទាស់ពាក្យនេះទាំងអស់ថា ព្រះពុទ្ធវចនៈឈ្មោះថា មិនមែនសូត្រមិនមានឬ ដូច្នេះហើយពោលថា បិដក ៣ ឈ្មោះថា **សូត្រ** ចំណែកវិន័យឈ្មោះថា **ហេតុ** ។ តពីនោះកាលនឹងសម្តែងហេតុនោះ ទើបនាំសូត្រនេះមកអាងថា "ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងធម៌ទាំងឡាយណាថា ធម៌ទាំងនេះប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក, ប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្តៈ, ប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការ ប្រាសចាកការសន្សំកិលេសវដ្តៈ, ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច, ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស, ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក, ប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធ

សេចក្តីព្យាយាម, ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅដើម្បី ឲ្យគេចិញ្ចឹមបានដោយងាយ, ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រដៅ របស់ព្រះសាស្តារទេ ។ ម្នាលព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក, ប្រព្រឹត្តទៅដើម្បីការប្រាសចាកវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្តៈ, ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ, ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន, ប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស, ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីការប្រឡូកប្រឡំដោយពួក, ប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស, ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ,

ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្ដាហើយ” ។ ព្រោះដូច្នោះ គប្បីដេញដោលសួរក្នុងព្រះត្រៃបិដកពុទ្ធវចនៈ ដែលឈ្មោះថាសូត្រ គប្បីប្រៀបផ្ទឹមក្នុងហេតុគឺ វិន័យមានរាគៈជាដើម ដែលឈ្មោះថា វិន័យ សេចក្ដីក្នុងរឿងនេះមានដូចពោលមកដូច្នេះ ។

ពាក្យថា **មិនប្រជុំចុះក្នុងសូត្រ** សេចក្ដីថា បទព្យញ្ជនៈទាំងនោះ មិនមកក្នុងទីណាៗ តាមលំដាប់សូត្រ លើកតែដែលមកពីគុឡ្ហវេស្សន្តរៈ គុឡ្ហឧម្មគ្គៈ គុឡ្ហវិន័យ វេទល្លៈ និងបិដកនៅមានប្រាកដ ។ ពិតមែន បទព្យញ្ជនៈដែលមកយ៉ាងនេះ តែមិនប្រាកដក្នុងការកម្ចាត់កិលេសមានរាគៈជាដើម ក៏គប្បីចោលចេញ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវចោលពាក្យនេះ ដោយទំនងដូច្នេះចេញ” ។ គប្បីជ្រាបសេចក្ដីក្នុងទីគ្រប់កន្លែងដោយឧបាយនេះ ។ ពាក្យថា **ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីចាំទុក**

នូវមហាបទេស ជាគម្រប់ ៤ នេះចុះ សេចក្តីថា អ្នកគប្បីទ្រង់ចាំឱកាសជាទីប្រតិស្ឋាននៃធម៌ទី ៤ នេះទុក ។

ក៏ក្នុងទីនេះគប្បីជ្រាបបកិណ្ណកៈដូច្នេះថា ក្នុងព្រះសូត្រ មានមហាបទេស ៤ ក្នុងខន្ធកៈ មានមហាប្រទេស ៤ បញ្ហាព្យាករណ៍ ៤ សុត្តៈ ១ សុត្តានុលោម ១ អាចរិយវាទ ១ អត្តនោមតិ ១ សង្គីតិ ៣ ។

ក្នុងបកិណ្ណកៈទាំងនោះ កាលដល់ការវិនិច្ឆ័យធម៌ថា នេះធម៌ នេះវិន័យ មហាបទេស ៤ ទាំងនេះកាន់យកជាប្រមាណ សេចក្តីណាសមក្នុងមហាបទេស ៤ ទាំងនេះ សេចក្តីនោះគួរកាន់យក សេចក្តីក្រៅនេះសូម្បីរបស់អ្នកកាន់ខុស ក៏មិនគួរកាន់យក ។ កាលដល់ការវិនិច្ឆ័យសេចក្តីដែលគួរនិងមិនគួរថា វត្ថុនេះគួរ វត្ថុនេះមិនគួរ មហាបទេស ៤ ដែលត្រាស់ទុកក្នុងខន្ធកៈដោយន័យថា "ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ" ដូច្នេះជាដើម កាន់យកជាប្រមាណ ។ កថាវិនិច្ឆ័យមហាបទេសទាំងនោះពោល

ទុក ក្នុងអដ្ឋកថា ព្រះវិន័យឈ្មោះសមន្តប្បាសាទិកាដោយន័យដែលពោលទុកក្នុងទីនោះ គប្បីធ្វើសន្និដ្ឋានយ៉ាងនេះថា វត្ថុណាដែលអនុលោមចូលគ្នាបាននឹងវត្ថុដែលគួរ វត្ថុនោះគួរ ក្រៅនោះមិនគួរ ។

ឯកំសព្យាករណីយបញ្ហា ១ វិភជ្ជព្យាករណីយបញ្ហា ១ បដិបុច្ឆាព្យាករណីយបញ្ហា ១ ឋបនីយបញ្ហា ១ ទាំងនេះឈ្មោះថាបញ្ហាព្យាករណ៍ ៤ ។ ក្នុងបញ្ហាព្យាករណ៍ ៤ នោះ កាលត្រូវគេសួរថា ចក្ខុ មិនទៀងឬ គប្បីព្យាករណ៍មុនដោយចំណែកតែមួយថា មិនទៀងទេ ព្រះករុណា ។ ក្នុងសោតៈ ជាដើមក៏មានន័យនេះ ។ នេះឈ្មោះថា ឯកំសព្យាករណីយបញ្ហា ។ កាលត្រូវគេសួរថា ចក្ខុប៉ុណ្ណោះឬ ឈ្មោះថាមិនទៀង ។ គប្បីចែកហើយព្យាករណ៍យ៉ាងនេះថា មិនមែនចក្ខុប៉ុណ្ណោះទេ សូម្បីតែសោតៈ ក៏មិនទៀង សូម្បីឃានៈ ក៏មិនទៀង ។ នេះឈ្មោះថា វិភជ្ជព្យាករណីយបញ្ហា ។ កាលត្រូវគេសួរថា ចក្ខុយ៉ាងណា សោតៈ ក៏ដូច្នោះ សោតៈយ៉ាងណា ចក្ខុក៏ដូច្នោះឬ ជាដើម ។ ទើបសាកសួរថា លោកសួរដោយអត្ថថា អ្វី កាលគេឆ្លើយថា សួរដោយអត្ថថា ឃើញ

ទើបព្យាករណ៍ថា មិនមែន ។ កាលគេឆ្លើយថា សួរដោយអត្តថា មិនទៀង ទើបព្យាករណ៍ថា មែន ។ នេះឈ្មោះថា បដិបុច្ឆា-ព្យាករណីយបញ្ហា ។ តែកាលត្រូវគេសួរថា នោះក៏ជីវៈ នោះក៏សរីរៈជាដើម គប្បីឈប់ហើយដោយពោលថា សេចក្តីនេះព្រះ-មានព្រះភាគ មិនបានព្យាករណ៍ទេ។ បញ្ហានេះមិនគប្បីព្យាករណ៍។ នេះឈ្មោះថា ឋបនីយបញ្ហា ។ ដូច្នោះ កាលបញ្ហាមកដល់ដោយអាការនោះ បញ្ហាព្យាករណ៍ទាំង៤នេះ កាន់យកជាប្រមាណបាន ។ គប្បីព្យាករណ៍បញ្ហានោះដោយអំណាចបញ្ហាព្យាករណ៍ ៤ នេះ ។

ក៏បិដក ៣ ដែលលើកឡើងកាន់សង្គីតិ ៣ គ្រា ឈ្មោះថា សុត្តៈ, ក្នុងបកិណ្ណកៈ មានសុត្តៈជាដើម ។ វត្ថុដែលចូលគ្នាបាននឹងកប្បិយឈ្មោះថា សុត្តានុលោម ។ អដ្ឋកថា ឈ្មោះថា អាចរិយវាទ ។ បដិភាណរបស់ខ្លួន តាមសេចក្តីកាត់ន័យតាមការយល់ឃើញ ឈ្មោះថា អត្តនោមតិ ។ ក្នុងបកិណ្ណកៈទាំងនោះ សុត្តៈ អ្នកណាៗ ជំទាស់មិនបាន កាលជំទាស់សុត្តៈនោះ ក៏ស្មើនឹងជំទាស់ព្រះពុទ្ធនោះឯង ។ ចំណែកវត្ថុដែលអនុលោមចូលជាមួយនឹងកប្បិយបាន គួរកាន់យកចំពោះវត្ថុដែលសមនឹងសុត្តៈ

ប៉ុណ្ណោះ ក្រៅនោះមិនគួរកាន់យក ។ សូម្បីអាចរិយវាទ ក៏គួរកាន់យកតែវត្ថុដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅនោះមិនគួរកាន់យក ។ ចំណែកអត្តនោមតិ អន់ជាងគេទាំងអស់ ។ សូម្បីអត្ត-នោមតិនោះ ក៏គួរកាន់យកតែវត្ថុដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅនោះមិនគួរកាន់យក ។

ក៏សង្គីតិមាន ៣ ទាំងនេះគឺ បញ្ចសតិកសង្គីតិ (គ្រាទី ១) សត្តសតិកសង្គីតិ (គ្រាទី ២) សហស្សិកសង្គីតិ (គ្រាទី ៣) ។ សូម្បីសុត្តៈ ចំពោះដែលមកក្នុងសង្គីតិ ៣ នោះ គួរកាន់យកជាប្រមាណ ។ ក្រៅនោះជាខដែលលោកតិះដៀល មិនគួរកាន់យក ។ ពិតមែន បទព្យញ្ជនៈសូម្បីដែលចុះសម្រុងគ្នាបាន ក្នុងសុត្តៈនោះ គប្បីជ្រាបថា ចុះសម្រុងគ្នាមិនបានក្នុងព្រះសូត្រ និងផ្ទៀបគ្នាមិនបានក្នុងព្រះវិន័យ ។

# ៣១-ស្ដេចយាងទៅកាន់ក្រុងបាវា

គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភោគនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ក្រុងបាវា ។

ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់ក្រុងបាវា ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពវ័ន ព្រៃស្វាយរបស់នាយចុន្ទកម្មារបុត្ត (បុត្ររបស់ជាងមាស ជាកុដុម្ពីធំ ជាអ្នកស្តុកស្តម្ភ ជាសោតាបន្ន) ទៀបក្រុងបាវានោះ ។

នាយចុន្ទកម្មារបុត្ត បានឮដំណឹងថា ព្រះមានព្រះភាគ ស្តេចមកដល់ក្រុងបាវា ឥឡូវនេះ ទ្រង់គង់នៅក្នុងអម្ពវ័នរបស់អាត្មាអញ ទៀបក្រុងបាវា ។ គ្រានោះ នាយចុន្ទកម្មារបុត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ឲ្យឃើញច្បាស់

ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាយចុន្ទកម្មារបុត្ត កាលដែលព្រះមានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព ។ លុះនាយចុន្ទកម្មារបុត្ត បានដឹងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ទើបនាយចុន្ទកម្មារបុត្ត ក៏ឲ្យគេចាត់ចែងខាទនីយភោជនីយាហារមានរសដ៏ពីសា ព្រមទាំងសូករមទ្ទវៈដ៏ច្រើន ក្នុងផ្ទះរបស់ខ្លួនហើយ ឲ្យគេទៅក្រាបទូលភត្តកាលចំពោះ ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយស្ដេចចូលទៅកាន់លំនៅរបស់នាយ

ចុន្ទកម្មារបុត្ត ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់រួចហើយ ក៏ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទ សូករមទ្ទវៈណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគតដោយសូករមទ្ទវៈនោះចុះ ឯខាទនីយភោជនីយាហារដទៃណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសភិក្ខុសង្ឃដោយខាទនីយភោជនីយាហារនោះចុះ ។ នាយចុន្ទកម្មារបុត្ត ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏អង្គាសព្រះមានព្រះភាគ ដោយសូករមទ្ទវៈដែលខ្លួនតាក់តែងហើយ អង្គាសភិក្ខុសង្ឃដោយខាទនីយភោជនីយាហារ ដែលខ្លួនតាក់តែងហើយ។

ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទ សូករមទ្ទវៈណារបស់អ្នកដែលនៅសល់ អ្នកចូរកប់នូវសូករមទ្ទវៈនោះក្នុងរណ្តៅទៅ ម្នាលនាយចុន្ទ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញបុគ្គលណាមួយ ដែលបរិភោគនូវ

*សូករមទ្ទវៈនោះ ហើយសូករមទ្ទវៈនោះគប្បីដល់នូវកិរិយារលួយទៅដោយល្អឡើយ វៀរលែងតែតថាគតចេញ ។ នាយចុន្ទកម្មារបុត្តទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កប់សូករមទ្ទវៈដែលនៅសល់នោះក្នុងរណ្តៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាយចុន្ទកម្មារបុត្តអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈស្តេចចេញទៅ ។*

*លុះព្រះមានព្រះភាគ ទ្រង់ឆាន់ភត្តរបស់នាយចុន្ទកម្មារបុត្តរួចហើយ ព្រះអាពាធដ៏ខ្លាំងក៏កើតឡើង វេទនាដ៏ក្លៀវក្លា កើតអំពីលោហិតបក្ខន្ទិកាពាធ (អាពាធចុះព្រះលោហិត) ជិតដល់នូវមរណៈក៏ប្រព្រឹត្តទៅ ។ បានឮថា ព្រះមានព្រះភាគ មានព្រះសតិនិងសម្បជញ្ញៈមិនបានលំបាក ទ្រង់អត់សង្កត់នូវវេទនានោះបាន ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ក្រុងកុសិនារា ។ ព្រះអានន្ទ*

មានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់សោយភត្ត របស់នាយចុន្ទកម្មារបុត្ត ហើយមានព្រះអាពាធជាទម្ងន់ ជិតនឹងមរណៈ ។ ព្យាធិដ៏ក្លាកើតដល់ព្រះសាស្តាដែលសោយភត្តដោយសូករមទ្ទវៈ ព្រះមានព្រះភាគ ទ្រង់មានអាពាធចុះព្រះលោហិតរឿយៗ ទើបមានព្រះពុទ្ធតម្រាស់ថា តថាគតនឹងទៅក្រុងកុសិនារា ។

(គាថាទាំងនេះ ព្រះសង្គីតិកាចារ្យទាំងឡាយ សម្ដែងហើយក្នុងកាលធ្វើសង្គីតិ) ។

<u>អដ្ឋកថាថា</u> : បទថា **សូករមទ្ទវំ** (សាច់ជ្រូកល្អិតម៉ដ្ឋ) បានដល់ **បវត្តមំសៈ** របស់ជ្រូកមួយដែលធំបំផុត មិនក្មេងពេក មិនចាស់ពេក ។ បានឮថា បវត្តមំសៈនោះទន់ល្អិត ។ អធិប្បាយថា ឲ្យចាត់ចែងបវត្តមំសៈនោះ ធ្វើឲ្យឆ្អិនយ៉ាងល្អ ។ អាចារ្យពួកមួយ ពោលថា ក៏ពាក្យថា សូករមទ្ទវៈនេះ ជាឈ្មោះរបស់បាយទន់ ដែលផ្សំដោយបញ្ចគោរសេ (**ខីរ** ទឹកដោះស្រស់ **ទធិ**

ទឹកដោះជូរ **យតំ** ទឹកដោះថ្លា **តក្កំ** ទឹកដោះជូរឡើងពពុះ និង **នោទីតំ** ទឹកដោះ ខាប់) និងសណ្តែក ដូចរបស់ឆ្អិនឈ្មោះថា **គវបាន:** នំផ្សំទឹក ដោះគោ ។ អាចារ្យពួកខ្លះពោលថា វិធីផ្សំរស ឈ្មោះថា សូករមទ្ទវៈ ក៏សូករមទ្ទវៈនោះមកក្នុងសោយតនសា-ស្ត្រ ។ សូករមទ្ទវៈនោះ នាយចុន្ទៈ តាក់តែងតាមសោយនវិធី ដោយប្រាថ្នាថា ការបរិនិព្វានទឹងមិនទាន់មានដល់ព្រះមានព្រះ-ភាគ ។ តែពួកទេវតា ក្នុងមហាទ្វីបទាំង ៤ ដែលមានទ្វីបតូច ២,០០០ ទ្វីបជាបរិវារ ដាក់ឱជៈចុះក្នុងសូករមទ្ទវៈនោះ ។ ព្រះមានព្រះភាគ ទ្រង់បន្លឺសីហនាទនេះថា **នាហន្តំ** ដើម្បីអ្វី ។ ដើម្បីទ្រង់ដោះពាក្យស្តីបន្ទោសរបស់អ្នកដទៃ ។ ពិតមែន ព្រះ-មានព្រះភាគ ស្តាប់ពាក្យរបស់ពួកដែលត្រូវការនឹងពោលថា ព្រះមានព្រះភាគ មិនប្រទានសូករមទ្ទវៈ ដែលព្រះអង្គសោយនៅសល់ ទាំងដល់ភិក្ខុ ទាំងដល់មនុស្សទាំងឡាយ បន្តាប់ឲ្យកប់ចោលក្នុងរណ្តៅ ធ្វើឲ្យវិនាសអស់ដូច្នេះ ទើបទ្រង់បន្លឺសីហនាទ ដើម្បីដោះពាក្យស្តីបន្ទោសរបស់ជនពួកដទៃ ដោយព្រះប្រាថ្នាថា នឹងមិនមានឱកាសពោលស្តីបន្ទោសបាន ។

ពាក្យថា *ដែលសោយកត្តដោយសូករមទ្ទវៈ* សេចក្ដីថា ការអាពាធយ៉ាងខ្លាំងក្លាកើតឡើងដល់ព្រះអង្គអ្នកសោយ តែមិនមែនកើតព្រោះសូករមទ្ទវៈដែលសោយជាបច្ច័យទេ ។ ក៏ប្រសិនបើថា ព្រះអង្គមិនសោយក៏នឹងកើតអាពាធបាន និងជាអាពាធដែលខ្លាំងក្លាជាងផង ។ តែព្រោះសោយភោជនដ៏ស្និទ្ធ ព្រះអង្គទើបមានទុក្ខវេទនាស្រាលខ្លះ ។ ដោយហេតុនោះឯង ព្រះអង្គទើបស្ដេចពុទ្ធដំណើរទៅបាន ។ ពាក្យថា **ចុះព្រះលោហិតរឿយៗ** បានដល់ព្រះអង្គទ្រង់ចេញព្រះលោហិតរឿយៗ ។ លោកពោលយ៉ាងនេះថា **អរោច** (មានព្រះតម្រាស់) ក៏ដើម្បីប្រយោជន៍ដល់បរិនិព្វាន ក្នុងស្ថានទីដែលព្រះអង្គមានព្រះពុទ្ធប្រាថ្នា ។ គប្បីជ្រាបសេចក្ដីថា ក៏ព្រះធម្មសង្គាហកត្ថេរតាំងគាថាទាំងនេះទុក ។ (អដ្ឋកថា)

## ៣២-ព្រះតថាគតទ្រង់ល្ហិតល្ហៃ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចៀសចេញអំពីផ្លូវហើយ ទ្រង់ចូលទៅកាន់ម្លប់ឈើ ១ ដើម លុះចូលដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដី

មានជាន់ ៤ ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតល្ហិតល្ហៃណាស់ តថាគតអង្គុយសិន ។

ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ក្រាលសង្ឃាដីមានជាន់ ៤ ថ្វាយ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់រួចហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះរទេះចំនួន ៥០០ គេបរឆ្លងទៅហើយ ទឹកនោះតិច កង់រទេះក៏កិន ល្អក់វឹកវរហូរមក បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងកកុធៈនៅជិតនេះ មានទឹកថ្លា មានទឹកមានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករងៃ មានកំពង់ក៏ស្រួលជាទីគួរត្រេកអរ ក្នុងស្ទឹងនុ៎ះ ព្រះមានព្រះភាគ នឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ស្រួល ក៏បាន ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ជាគម្រប់ពីរដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។

ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ រទេះចំនួន ៥០០ គេបរឆ្លងទៅហើយ ។បេ។ នឹងស្រង់ព្រះកាយឲ្យត្រជាក់ស្រួលក៏បាន ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុ ជាគម្រប់បីដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។

ព្រះអានន្ទមានអាយុ ក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់បាត្រដើរតម្រង់ទៅស្ទឹងនោះ ។ លំដាប់នោះ ស្ទឹងតូចដែលកង់កិនល្អក់វឹកវរ ហូរមកនោះ កាលព្រះអានន្ទមានអាយុ ចូលទៅដល់ហើយ ក៏ត្រឡប់ទៅជារងថ្លា

មិនល្អក់ហូរមកវិញ ។ ទើបព្រះអានន្ទ មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ហេតុនេះជាអស្ចារ្យពេកណាស់ ឱហ្ន៎ ហេតុនេះចំឡែកពេកណាស់ ស្ទឹងតូចនេះឯងដែលកង់កិនល្អក់រីករវរហូរមក កាលបើអាត្មាអញ ចូលមកដល់ក៏ត្រឡប់ទៅជាទឹករងថ្លាស្អាត មិនល្អក់ ហូរមកវិញ ព្រោះព្រះតថាគតមានឫទ្ធិធំ មានអានុភាពធំ ។ ព្រះអានន្ទ ក៏ដងទឹកដោយបាត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ស្ទឹងតូចដែលកង់កិនល្អក់ រីករវរកំពុងហូរមកនោះ កាលដែលខ្ញុំព្រះអង្គចូលទៅដល់ហើយ ក៏ត្រឡប់ទៅជាទឹករងថ្លាស្អាត មិនល្អក់ហូរមកវិញ ព្រោះព្រះអង្គមានឫទ្ធិធំ មានអានុភាពធំ សូមព្រះមានព្រះភាគ ទ្រង់សោយព្រះសុទ្ធរស សូមព្រះសុគតទ្រង់សោយព្រះសុទ្ធរស ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏ទ្រង់សោយព្រះសុទ្ធរស ។

## ៣៣-ឆវីវណ្ណបរិសុទ្ធផូរផង់ក្រៃពេកក្នុងកាលទាំងពីរ

*សម័យនោះឯង មល្លបុត្ត (ព្រះរាជបុត្តនៃមល្លក្សត្រិយ៍) នាមបុក្កុសៈ ជាសាវ័ករបស់អាឡារតាបស កាលាមគោត្ត ចេញអំពីក្រុងកុសិនារា ដើរទៅតាមផ្លូវឆ្ងាយ សំដៅទៅកាន់ក្រុងបាវា ។ល។ ជ្រះថ្លានឹងកាសិតរបស់ព្រះអង្គ ប្រកាសខ្លួន សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ, បានបង្អោននូវសំពត់ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសង្កី ដែលគួរប្រើប្រាស់ (ម្តងៗ) នោះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលបុក្កុសៈ បើដូច្នោះ អ្នកចូរឲ្យសំពត់ ១ មកតថាគត ឲ្យសំពត់ ១ ទៅអានន្ទចុះ ។ល។*

*លុះបុក្កុសមល្លបុត្ត ចេញទៅមិនយូរប៉ុន្មាន ព្រះអានន្ទដ៏មានអាយុ ក៏យកសំពត់ដែលមានសាច់ម៉ដ្ឋ ១ គូ មានសម្បុរដូចមាសសង្កី ដែលគួរប្រើប្រាស់ (ម្តងៗ) នោះ ទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគ ។ ឯសំពត់ដែលព្រះអានន្ទ យកទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគនោះ (ក៏អាប់សម្បុរ) ប្រាកដដូចជារងើកភ្លើងដែលប្រាសចាកអណ្តាតភ្លើង ។ល។*

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុនេះយ៉ាងនេះឯង ម្នាលអានន្ទ កាយតថាគតស្អាត ឆវីវណ្ណក៏បរិសុទ្ធផូរផង់ក្រៃពេក ក្នុងកាលទាំងពីរ កាលទាំងពីរតើដូចម្តេច ម្នាលអានន្ទ កាលតថាគតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងរាត្រីណា ១ កាលតថាគតបរិនិព្វានដោយអនុបាទិសេស-និព្វានធាតុ ក្នុងរាត្រីណា ១ ។ល។

ក្នុងសុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ ថា ៖

សួរថា ក្នុងពាក្យថា **ឥមេសុ ខោ អានន្ទ ទ្វីសុ កាលេសុ** (ម្នាលអានន្ទ ក្នុងកាលទាំងពីរនេះឯង) តើហេតុដូចម្តេច កាយរបស់ព្រះតថាគត ទើបបរិសុទ្ធយ៉ាងក្រៃលែងយ៉ាងនេះ ក្នុងកាលទាំងពីរនេះ ។ ឆ្លើយថា ព្រោះសេចក្តីវិសេសនៃអាហារម្យ៉ាងព្រោះសោមនស្សមានកម្លាំងម្យ៉ាង ។ ក្នុងកាលទាំង ២ នេះ ពួកទេវតាក្នុងសាកលចក្រវាឡ ដាក់ឱជៈចុះក្នុងអាហារ ។ ក៏ភោជននោះធ្លាក់ដល់ផ្ទៃក៏បង្កើតបសន្នរូប (រូបថ្លា) ។ ឥន្ទ្រិយដែលមានចិត្តជាគម្រប់ ៦ ក៏រុងរឿងក្រៃលែងណាស់ ព្រោះមានរូបដែលមានអាហារជាសមុដ្ឋានស្រស់ថ្លា ។ ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹង

ទ្រង់រលឹកថា កងកិលេសដែលយើងសន្សំមកច្រើនសែនកោដិកប្ប ថ្ងៃនេះយើងលះបង់បានហើយហ្ន៎ ទើបកើតសោមនស្សមានកម្លាំងឡើង ។ ចិត្តក៏ថ្លា ។ កាលចិត្តថ្លា លោហិតក៏ថ្លា ។ កាលលោហិតថ្លា ឥន្ទ្រិយមានចិត្តជាគម្រប់ ៦ ក៏រុងរឿងក្រៃលែង ។ ក្នុងថ្ងៃបរិនិព្វាន ទ្រង់រលឹកថា ថ្ងៃនេះឥឡូវនេះ យើងនឹងចូលទៅកាន់នគរអមតមហាបរិនិព្វាន ដែលព្រះពុទ្ធច្រើនសែនព្រះអង្គចូលទៅហើយ ដូច្នេះ ទើបកើតសោមនស្សមានកម្លាំងឡើង ។ ចិត្តក៏ថ្លា កាលចិត្តថ្លា លោហិតក៏ថ្លា កាលលោហិតថ្លា ឥន្ទ្រិយមានចិត្តជាគម្រប់ ៦ ក៏រុងរឿងយ៉ាងក្រៃលែង ។ គប្បីជ្រាបថា ព្រះវរកាយរបស់ព្រះតថាគតបរិសុទ្ធយ៉ាងក្រៃលែង មានក្នុងកាលទាំង ២ នេះ ដោយអាហារនិងសោមនស្សមានកម្លាំងដោយប្រការដូច្នេះ ។

## ៣៤~ទ្រង់ស្តេចចុះកាន់ស្ទឹងកកុធៈ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ស្ទឹងកកុធៈ ព្រមទាំងភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ស្តេចចុះកាន់ស្ទឹងកកុធៈ ស្រង់ផង ទ្រង់សោយផងហើយ ស្តេចត្រឡប់

ឡើងវិញ ក៏ចូលទៅរកអម្ពវ័ន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់ហៅព្រះចុន្ទកៈមានអាយុមកថា ម្នាលចុន្ទកៈ ចូលក្រាលសង្ឃាដីមានជាន់ ៤ ឲ្យតថាគតដោយឆាប់ ម្នាលចុន្ទកៈ តថាគតល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ទើបព្រះមានព្រះភាគ ទ្រង់សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំ ទ្រង់មានព្រះសតិសម្បជញ្ញៈ ធ្វើទុកក្នុងព្រះទ័យនូវឧដ្ឋានសញ្ញា (សេចក្តីសម្គាល់ថានឹងក្រោកឡើងវិញ) ។ ឯព្រះ-ចុន្ទកៈមានអាយុ ក៏អង្គុយចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះឯង ។

ព្រះពុទ្ធទ្រង់ស្តេចទៅកាន់ស្ទឹងកកុធៈ ដែលមានទឹកថ្លា មានទឹកមានរសជាតិ មានទឹកស្អាត ព្រះតថាគតជាសាស្តា ឥតមានបុគ្គលប្រៀបផ្ទឹមក្នុងលោក ទ្រង់មិនលំបាកព្រះកាយស្តេចចុះ(កាន់ស្ទឹង) ព្រះសាស្តា ទ្រង់ស្រង់ផង ទ្រង់សោយផង នូវទឹកនោះ ហើយគង់ក្នុងទឹកណ្តាលនៃពួកភិក្ខុ ដែលគាល់ព្រះមានព្រះភាគ ជាសាស្តា ជាមហេសី អ្នកស្វែងរក

គុណធំ) ព្រះអង្គញុំាងធម៌ឲ្យប្រព្រឹត្តទៅក្នុងសាសនានេះ ទ្រង់ស្តេចចូលទៅកាន់អម្ពវ៉ន ។

ទ្រង់ត្រាស់ហៅចុន្ទកភិក្ខុមកថា អ្នកចូរក្រាលសង្ឃាដី មានជាន់ ៤ ឲ្យតថាគតដោយឆាប់ តថាគតនឹងសិង ព្រះ-ចុន្ទកភិក្ខុនោះ កាលព្រះសាស្តា មានព្រះអង្គចម្រើនហើយ ទ្រង់ត្រាស់បង្គាប់ហើយ ក៏ក្រាលសង្ឃាដីមានជាន់ ៤ ថ្វាយដោយប្រញាប់ ព្រះសាស្តាមិនលំបាកព្រះកាយ ទ្រង់ផ្ទំហើយ ឯព្រះចុន្ទកភិក្ខុ ក៏អង្គុយគាល់ចំពោះព្រះភក្ត្រក្នុងទីនោះ ។

<u>អដ្ឋកថា</u> បានពួថា ក្នុងកាលនោះ កាលព្រះមានព្រះភាគចុះស្រង់ អណ្តើក ត្រី ខាងក្នុងស្ទឹង និងជួរព្រៃមាត់ច្រាំងទាំង ២ ខាង ទាំងអស់ក៏មានពណ៌ដូចជាមាសដែរ ។

## ៣៥-ចង្ហាន់បិណ្ឌបាត ២ មានផលស្មើគ្នា

គ្រានោះ ព្រះមានព្រះភាគ បានត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ បើមានបុគ្គលណាមួយ ញុំាងសេចក្តីក្តៅ

ក្រហាយ ស្តាយក្រោយ ឲ្យកើតឡើងដល់ចុន្ទកម្មារបុត្តថា ម្នាល អាវុសោចុន្ទៈ អ្នកពេញហៅជាមនុស្ស ឥតលាភ អត្តភាពជាមនុស្ស ក៏អ្នកបានដោយអាក្រក់ ព្រោះព្រះតថាគត សោយបច្ឆិមបិណ្ឌបាត របស់អ្នកហើយទ្រង់បរិនិព្វាន ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់ សេចក្តីក្តៅក្រហាយ ស្តាយក្រោយរបស់ចុន្ទកម្មារបុត្តយ៉ាងនេះថា ម្នាលអាវុសោចុន្ទៈ អ្នកពេញហៅជាមនុស្សមានលាភ អត្តភាពជាមនុស្សអ្នកបានដោយប្រពៃហើយ ព្រោះថាព្រះតថាគត ទ្រង់សោយបច្ឆិមបិណ្ឌបាតរបស់អ្នកហើយ ទ្រង់បរិនិព្វាន ម្នាលអាវុសោចុន្ទៈ ពាក្យនេះ យើងបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដូច្នេះថា ចង្ហាន់បិណ្ឌបាតទាំងពីរនេះ មានផលស្មើៗគ្នា មានវិបាកស្មើៗគ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ ចង្ហាន់បិណ្ឌបាតទាំងពីរ តើដូចម្តេច ។ គឺ ព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណា ហើយទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ១ ព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណា ហើយទ្រង់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ១ ចង្ហាន់បិណ្ឌបាតទាំងពីរនេះឯង

មានផលស្មើៗគ្នា មានវិបាកស្មើៗគ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ល។

ទ្រង់បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា

ទទតោ បុញ្ញំ បវឌ្ឍតិ

សំយមតោ វេរំ ន ចីយតិ

កុសលោ ច ជហាតិ ចាបកំ

រាគទោសមោហក្ខយា និព្វុតោ ។

បុណ្យ រមែងចម្រើនដល់អ្នកឲ្យទាន វេរាមិនចម្រើន ដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស (បរិបូរណ៍ដោយញាណ) រមែងលះបង់នូវអំពើលាមកបាន បុគ្គលនោះក៏បរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

(សុត្តន្ត. ភាគ១៦ ទំព័រ២៨៧)

នៅក្នុងសុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ ថា ៖

<u>សួរថា</u> ព្រះតថាគតសរសើរបិណ្ឌបាតណា ដែលនាងសុជាតាថ្វាយហើយត្រាស់ដឹង បិណ្ឌបាតនោះព្រះអង្គសោយ ក្នុង

វេលាដែលនៅមានរាគៈ ទោសៈ មោហៈ តែបិណ្ឌបាតនេះ ដែលចុន្ទកម្មារបុត្តថ្វាយហើយ ព្រះអង្គសោយក្នុងវេលាដែលប្រាសចាករាគៈ ទោសៈ មោហៈ មិនមែនឬ តែព្រោះហេតុអ្វី បិណ្ឌបាតទាំងពីរនេះ ទើបមានផលស្មើៗ គ្នា ?

ឆ្លើយថា ព្រោះស្មើគ្នាដោយការបរិនិព្វាន ស្មើគ្នាដោយការចូលសមាបត្តិ និងស្មើគ្នាដោយការរលឹក ។ មែនពិត ព្រះមានព្រះភាគ ទ្រង់សោយចង្ហាន់បិណ្ឌបាតដែលនាងសុជាតា ថ្វាយហើយ ស្តេចបរិនិព្វានដោយសឧបាទិសេសនិព្វាន និងសោយចង្ហាន់បិណ្ឌបាតដែលចុន្ទកម្មារបុត្តថ្វាយហើយ ស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ រួមសេចក្តីថា មានផលស្មើគ្នាដោយការបរិនិព្វាន ។

ក៏ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹង ព្រះអង្គទ្រង់ចូលសមាបត្តិចំនួនពីរលានបួនសែនកោដិ សូម្បីក្នុងថ្ងៃទ្រង់បរិនិព្វាន ព្រះអង្គទ្រង់ចូលសមាបត្តិនោះទាំងអស់ ។ រួមសេចក្តីថា មានផលស្មើគ្នាដោយការចូលសមាបត្តិស្មើគ្នា ។

ក្នុងកាលក្រោយមក នាងសុជាតា បានជ្រាបថា ពួថា អ្នកដែលយើងឃើញនោះ មិនមែនរុក្ខទេវតា ជាព្រះពោធិសត្វ បានឮថា ព្រះពោធិសត្វនោះ ឆាន់បិណ្ឌបាតនោះហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រះអង្គស្ថិតនៅបានដោយបិណ្ឌបាតនោះអស់ ៧ សប្តាហ៍ ។ កាលនាងបានស្តាប់ដូច្នោះ ក៏រលឹកបានថា ជាលាភរបស់យើងហ្ន៎ ទើបកើតបីតិសោមនស្សយ៉ាងខ្លាំង ។ ក្នុងកាលក្រោយមក ចុន្ទកម្មារបុត្តមានអាយុ បានស្តាប់ថា បិណ្ឌ-បាតចុងក្រោយដែលយើងថ្វាយ យើងបានកំពូលធម៌ហើយ បានឮថា ព្រះសាស្តាសោយចង្ហាន់បិណ្ឌបាតរបស់យើង ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ត្រឡប់រលឹកបានថា ជាលាភរបស់យើងហ្ន៎ ទើបកើតសោមនស្សយ៉ាងខ្លាំង គប្បីជ្រាបថា មានផលស្មើគ្នាសូម្បីដោយការស្មើគ្នានៃការរលឹកដល់ យ៉ាងនេះដោយប្រការដូច្នេះ ។

## ៣៦-ទ្រង់ចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមាន-អាយុមកថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី និងចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះ-បន្ទូល ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមាន-ព្រះភាគ ស្តេចទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី និងចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ព្រមទាំងភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹង ព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែឲ្យមានក្បាលដំណេក បែរទៅទិសខាងជើងក្នុងចន្លោះនៃដើម-សាលព្រឹក្សទាំងគូ ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ព្រះអានន្ទមានអាយុទទួលព្រះ បន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គហើយរៀបចំគ្រែ ឲ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូថ្វាយ គ្រានោះ ព្រះមានព្រះភាគ

មានព្រះសតិសម្បជញ្ញៈ ទ្រង់សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំ ។

អដ្ឋកថា : ក្នុងពាក្យថា មហតា ភិក្ខុសង្ឃេន សទ្ធឹ (ព្រមទាំងភិក្ខុសង្ឃជាច្រើន) នេះ ចំនួនរបស់ភិក្ខុទាំងឡាយកំណត់មិនបាន ។ លុះមបានជ្រាបថា ចាប់ផ្តើមតាំងពីព្រះអង្គទ្រង់គ្របសង្កត់វេទនា ក្នុងវេឡុវគ្រាម មិនយូរឡើយព្រះមានព្រះភាគ ក៏នឹងបរិនិព្វាន បណ្តាភិក្ខុដែលមកអំពីទីនោះៗ មិនមានសូម្បីតែភិក្ខុមួយរូបដែលឈ្មោះថាជៀសចេញទៅ ព្រោះដូច្នោះ ព្រះសង្ឃទើបមានចំនួនរាប់មិនបាន ។

បទថា មញ្ចកំ បញ្ញាបេហិ (ចូររៀបចំគ្រែ) លោកពោលថា បានឮថា ព្រះទេនផ្ទំក្នុងព្រះរាជឧទ្យាននោះមាន ទ្រង់សំដៅដល់ព្រះទេននោះ ទ្រង់ត្រាស់ឲ្យក្រាល ។ សូម្បីព្រះថេរៈក៏ចាត់ចែងព្រះទេននោះថ្វាយ ។ បទថា កិលន្តោស្មិ អានន្ទ និបជ្ជិស្សាមិ (ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង) សេចក្តីថា សេចក្តីពិត ក្នុងពាក្យនេះថា

ត្រកូលដំរីឈ្មោះ គោចរី កលាបៈ គង្គេយ្យៈ បិង្គលៈ បព្វតេយ្យកៈ ហេមវតៈ តម្ពៈ មន្ទាកិនី ឧបោសថ ឆទ្ទន្តៈ ជាគម្រប់ ១០ ទាំងនេះ ជាកំពូលរបស់ដំរីទាំងឡាយ កម្លាំងយ៉ាងណារបស់ព្រះតថាគត ជាកម្លាំងស្មើនឹងកម្លាំងរបស់ដំរីប្រក្រតី ១ ពាន់កោដិ ដោយន័យដែលគុណបន្ថែម ១០ យ៉ាងនេះ គឺ កម្លាំងរបស់ដំរីប្រក្រតីដែលហៅថា ដំរីគោចរី ១០ ស្មើនឹងកម្លាំងរបស់ដំរីកលាបៈ ១ ជាដើម កម្លាំងនោះទាំងអស់ ក៏អស់ទៅដូចទឹកដែលដាក់ចុះក្នុងតម្រងទឹក តាំងពីវេលាដែលសោយបិណ្ឌបាតរបស់នាយចុន្ទៈ ។ តាំងពីនគរបាវាដល់នគរកុសិនារា រយៈផ្លូវ ៣ គាវុត ។ ក្នុងចន្លោះនេះ ព្រះមានព្រះភាគ ត្រូវប្រថាប់សម្រាកដល់ទៅ ២៥ កន្លែង ស្ដេចមកដោយឧស្សាហ៍ធំ ស្ដេចចូលកាន់សាលវ័នក្នុងវេលាល្ងាចព្រះអាទិត្យលិច ។ ព្រះរោគក៏មកលុប-លាងភាពមិនមានរោគចេញអស់ដោយប្រការដូច្នេះ ។ ដូចដែលទ្រង់សម្ដែងសេចក្ដីនេះ កាលត្រាស់ព្រះវាចាឲ្យកើតសេចក្ដីសង្វេគដល់សត្វលោកទាំងពួង ទើបត្រាស់ថា ឥិលន្តោស្មិ អានន្ទ

និបជ្ជិស្សាមិ (ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង) ដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបស្ដេចមកក្នុងទីនេះ ដោយឧស្សាហ៍ធំ មិនអាចទៅបរិនិព្វានក្នុងទីដទៃឬ ។ ឆ្លើយថា មិនអាចទៅបរិព្វានក្នុងទីដទៃក៏ទេ តែស្ដេចមកក្នុងទីនេះ ដោយហេតុ ៣ ប្រការ ។ ពិតមែន ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្ដីនេះថា កាលយើងតថាគតបរិនិព្វានក្នុងទីដទៃអត្ថុប្បត្តិ ហេតុកើតរឿងរបស់មហាសុទស្សនសូត្រនឹងមិនមាន តែកាលបរិនិព្វានក្នុងនគរកុសិនារា រហូតដល់បានសម្ដែងសម្បត្តិដែលតថាគតគប្បីសោយក្នុងទេវលោក ដែលសោយហើយក្នុងមនុស្សលោក ប្រដាប់ដោយកាណ្ឌវារ ២ កាណ្ឌវារ ជនជាច្រើនស្ដាប់ធម៌របស់តថាគតហើយ នឹងសម្គាល់កុសលថា គួរនឹងធ្វើ ។ មួយទៀត ទ្រង់ឃើញសេចក្ដីដទៃទៀតថា កាលតថាគតបរិនិព្វានក្នុងទីដទៃ សុភទ្ទៈនឹងមិនបានចូលគាល់ ដោយសុភទ្ទៈនោះជាវេនេយ្យរបស់ព្រះពុទ្ធ មិនមែនជាវេនេយ្យរបស់ព្រះសាវ័ក សាវ័កទាំងឡាយមិនអាចណែនាំសុភទ្ទៈនោះបាន ។ តែតថាគតបរិនិព្វានក្នុងនគរ

កុសិនារា សុភទ្ទៈនោះក៏នឹងចូលគាល់សួរបញ្ហាបាន និងទីបំផុតការឆ្លើយតបបញ្ហា គេក៏នឹងតាំងនៅក្នុងសរណៈ បានបព្វជ្ជាឧបសម្បទាក្នុងសំណាក់យើង ទទួលកម្មដ្ឋានហើយនឹងសម្រេចព្រះអរហត្តជាបច្ឆិមសាវ័ក ចំពោះកាលយើងនៅមានជីវិត ។ ទ្រង់ឃើញសេចក្ដីដទៃទៀតថា កាលយើងតថាគតបរិនិព្វានក្នុងទីដទៃ នឹងកើតឈ្លោះវិវាទគ្នាយ៉ាងធំក្នុងវេលាចែកព្រះធាតុ ទន្លេក៏នឹងហូរហៀរជាខ្សែឈាម តែកាលយើងតថាគតបរិនិព្វានក្នុងនគរកុសិនារា ទោណព្រាហ្មណ៍នឹងរម្ងាប់ការវិវាទនោះ ហើយចែកព្រះធាតុទាំងឡាយ ។ គប្បីជ្រាបថា ព្រះមានព្រះភាគ ស្ដេចមកក្នុងទីនេះដោយព្រះឧស្សាហ៍ធំយ៉ាងនេះ ក៏ដោយហេតុ ៣ ប្រការនេះ ។

ពាក្យថា សីហសេយ្យំ មានសេយ្យា ការដេក ៤ គឺ កាមភោគិសេយ្យា បេតសេយ្យា សីហសេយ្យា តថាគតសេយ្យា ។

ក្នុងសេយ្យាទាំង ៤ នោះ សេយ្យាដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សត្វអ្នកបរិភោគកាម ដោយច្រើនដេកផ្អៀងឆ្វេង

នេះឈ្មោះថា **កាមភោគិសេយ្យា** ។ ព្រោះថា សត្វអ្នកបរិភោគ-កាម ឈ្មោះថា ដេកផ្អៀងស្ដាំដោយច្រើនមិនមាន ។

**សេយ្យា** ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ដោយច្រើនពួកប្រេតដេកផ្ងារ នេះឈ្មោះថា **បេតសេយ្យា** ។ ព្រោះថាពួកប្រេតមានសាច់និងឈាមតិច និងព្រោះត្រូវរាងឆ្អឹងបញ្ឈប់ទុក មិនអាចដេកផ្អៀងតែម្ខាងបាន ទើបដេកផ្ងារតែម្យ៉ាង ។

**សេយ្យា** ដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ សីហ-មិគរាជ សម្រេចការដេកដោយផ្អៀងខាងស្ដាំ យកជើងតម្រួតលើជើង ស៊កកន្ទុយក្នុងចន្លោះភ្លៅ សីហមិគរាជនោះ លុះភ្ញាក់ឡើង ងើបកាយខាងមុខ គឺងើបក្បាល សម្លឹងមើលរាងកាយខាងក្រោម។ ម្នាលភិក្ខុទាំងឡាយ បើសីហមិគរាជ ឃើញសេចក្ដីភ្លាំងភ្លាត់ ឬឃ្លៀងឃ្លាតកាយណាមួយសោត ម្នាលភិក្ខុទាំងឡាយ សីហមិគ-រាជ រមែងតូចចិត្តព្រោះការភ្លាំងភ្លាត់និងឃ្លៀងឃ្លាតនៃកាយនោះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសីហមិគរាជ មិនឃើញសេចក្ដីភ្លាំងភ្លាត់ឬឃ្លៀងឃ្លាតនៃកាយណាមួយទេ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ រមែងត្រេកអរ ដោយការមិនភ្លាំងភ្លាត់ និងឃ្លៀង-

ឃ្នាតនៃកាយនេះ” ។ នេះឈ្មោះថា **សីហសេយ្យា** ។ ព្រោះថា ព្រោះជាសត្វមានអំណាចច្រើន ទើបសីហមិគរាជ ដេកដាក់ជើង ២ មុខទុកក្នុងទីមួយដាក់ជើង ២ ក្រោយទុកក្នុងទីមួយ ស៊កកន្ទុយទុកត្រង់ចន្លោះភ្លៅ កំណត់ទីដាក់ជើងមុខក្រោយ និង កន្ទុយទុកដាក់សីសៈទុកលើជើង ២ ខាងមុខ សូម្បីដេកពេលថ្ងៃ កាលភ្ញាក់ក៏ភ្ញាក់ដោយមិនតក់ស្លុត តែងងើយសីសៈកំណត់ទីដែលដាក់ជើងមុខជាដើម បើដាក់ខុសកន្លែងបន្តិច ក៏ខូចចិត្តថា នេះមិនសមគួរដល់ជាតិ និងសេចក្តីក្លៀវក្លារបស់អ្នកឯង ក៏ដេកក្នុងទីនោះទៀតមិនចេញទៅចាប់ចំណី តែកាលដាក់មិនខុសកន្លែងក៏នឹងសប្បាយចិត្តថា នេះសមគួរដល់ជាតិនិងសេចក្តីក្លៀវក្លារបស់អ្នកឯង ហើយក្រោកឡើងរលាស់បែបរាជសីហ៍ រលាស់សក់ក បន្លឺសីហនាទ ៣ ដង ហើយចេញទៅចាប់ចំណី ។

ចំណែកសេយ្យាក្នុងឈានទី ៤ លោកហៅថា តថាគតសេយ្យា ក្នុងសេយ្យាទាំងនោះ ក្នុងទីនេះមកពីសីហសេយ្យា ដោយថា សីហសេយ្យានេះ ជាកំពូលសេយ្យា ព្រោះជាឥរិយាបថច្រើនដោយអំណាច ។

បទថា ចាទេន ចាទំ (ព្រះបាទលើព្រះបាទ) បានដល់យកជើងឆ្វេងត្រួតលើជើងស្តាំ ។ បទថា ឧច្ចាធាយ (តម្រួត) បានដល់ បង្ខិតខុសគ្នាគឺ ដាក់ហួសគ្នាទៅបន្តិចបន្តួច ។ កាលយកថ្នាំងជើងត្រួតលើថ្នាំងជើង ឬយកជង្គង់ត្រួតលើជង្គង់ នឹងកើតវេទនាឡើងជាប់ជានិច្ច ចិត្តនឹងមិនមានអារម្មណ៍តែមួយ ការដេកមិនសប្បាយ តែកាលដាក់បង្ខិតគ្នា ដោយមិនឲ្យត្រួតលើគ្នា វេទនានឹងមិនកើត ចិត្តមានអារម្មណ៍តែមួយ ការដេកនឹងសប្បាយ ព្រោះដូច្នោះ ទើបដេកយ៉ាងនេះ ។ តែក្នុងទីនេះ ព្រោះទ្រង់ចូលដល់អនុដ្ឋានសេយ្យា លោកទើបមិនពោលថា ទ្រង់មនសិការដល់ឧដ្ឋានសញ្ញា ។ ក៏ក្នុងទីនេះ គប្បីជ្រាបអនុដ្ឋាន ការមិនក្រោកឡើងដោយអំណាចព្រះរាងកាយ ។ តែព្រះមានព្រះភាគ ទ្រង់មិនមានឱកាសនៃកវគ្គចិត្តផ្ងំលក់រហូតដល់អស់រាត្រីនោះឡើយ ពិតមែនក្នុងបឋមយាម ទ្រង់បានមានការសម្តែងធម៌ប្រោសពួកស្តេចមល្លៈ ក្នុងមជ្ឈិមយាម ប្រោសសុភទ្ទៈ ។ ក្នុងបច្ឆិមយាមទ្រង់ប្រទានឱវាទកិក្ខុសង្ឃ ក្នុងវេលាជិតភ្លឺស្តេចបរិនិព្វាន ។

## ៣៧_ការបូជាចំពោះព្រះតថាគត

សម័យនោះឯង សាលព្រឹក្សទាំងគូ ក៏មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងពីគល់ដល់ចុង) ដោយអកាលបុប្ផ (ផ្កាពុំជួកាល) សាលព្រឹក្សទាំងគូនោះ ក៏រោយរាយបាចសាច (នូវផ្កា) លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត សូម្បីមន្ទារវបុស្ស (ផ្កាមន្ទារវៈ) ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស ផ្កាទាំងនោះក៏រោយរាយបាចសាចលើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងលំអិតខ្លឹមច័ន្ទន៍ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស លម្អិតទាំងនោះក៏រោយរាយ បាចសាចលើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងតូរ្យតន្ត្រី ជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទាំងចំរៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ សាលព្រឹក្សទាំងគូ មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងអំពីគល់ដរាបដល់ចុង) ដោយអកាលបុប្ផ រោយរាយ បាចសាចលើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងផ្កាមន្ទារវៈជាទិព្វ ធ្លាក់ចុះអំពីអាកាស ដើម្បីបូជាតថាគត ទាំងលម្អិត

ខ្ទឹមច័ន្ទន៍ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស លម្អិតទាំងនោះ ក៏រោយរាយ បាចសាចលើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ទាំងចំរៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត,

អដ្ឋកថា ៖

បទថា **មានផ្ការីកស្គុះស្គាយ** សេចក្ដីថា ដើមសាលៈទាំងគូរីកស្គុះស្គាយដេរដាសទៅតាំងពីគល់ដល់ចុង មិនមែនមានតែដើមសាលៈទាំងគូតែម្យ៉ាងប៉ុណ្ណោះ ដើមឈើសូម្បីទាំងអស់ក៏បញ្ចេញផ្កាព្រោងព្រាតដូចគ្នាទាំងអស់ ។ មិនមែនតែក្នុងសួននោះតែម្យ៉ាងប៉ុណ្ណោះ សូម្បីក្នុងម៉ឺនចក្រវាឡទាំងអស់ ឈើផ្កាក៏បញ្ចេញផ្កា ឈើផ្លែក៏បញ្ចេញផ្លែ ។ ក្នុងដើមឈើគ្រប់ដើមមានខន្ធបទុមរីកត្រង់ដើម សាខាបទុមរីកត្រង់មែកទាំងឡាយ វល្លិបទុមរីកត្រង់វល្លិ អាកាសបទុមរីកលើអាកាស ទណ្ឌបទុមជ្រែកផ្ទៃផែនដីឡើងមករីក ។ មហាសមុទ្រទាំងអស់ដេរដាសទៅដោយឈូក ៥ ពណ៌ ព្រៃហិមពាន្តទំហំ ៣,០០០ យោជន៍ បានជាទីរីករាយក្រៃលែងណាស់ ដូចកន្ទុយសត្វក្ងោកដែលត្រដាងជាប់គ្នាជាផ្ទាំង ដូច

*ក្នុងនិងចន្លោមផ្កាឈើជាប់គ្នាមិនមានចន្លោះ ដូចផ្កាឈើប្រដាប់សីស: ដែលចងជ្រៀតគ្នាយ៉ាងល្អ និងដូចប្រអប់ដែលមានផ្កាឈើពេញ ។ បទថា* តេ តថាគតស្ស សរីរំ ឱកិរន្តិ *(រោយរាយចុះកាន់សរីរៈព្រះតថាគត) សាលព្រឹក្សទាំងគូនោះ ត្រូវកុម្មទេវតាអង្រួនដើមមែកនិងបង្គាប រោយចុះកាន់ព្រះសរីរៈរបស់ព្រះតថា-គត គឺរោយផ្កាចុះលើព្រះសរីរៈ ។ បទថា* អជ្ឈោកិរន្តិ *(ក៏រោយរាយ) ជ្រុះចុះដូចជារោយគ្រប (សរីរៈ) ។ ពាក្យថា* **បាចសាច** *បានដល់ ជ្រុះចុះញយៗ គឺរឿយៗ ។*

*ពាក្យថា* **ជាទិព្វ** *បានដល់ ដែលកើតក្នុងនន្ទបោក្ខរណីផ្កាមន្ទារវៈទាំងនោះ មានពណ៌ហាក់បីដូចជាមាស មានស្លឹកប្រមាណប៉ុនឆត្រស្លឹកឈើ ។ ជាប់កេសរប្រមាណមួយនាឡិធំមិនមែនផ្កាមន្ទារវៈជាទិព្វតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីផ្កាយ៉ាងដទៃក៏ជាទិព្វ ដូចជាផ្កាបារិឆត្តនិងផ្ការលួសជាដើម បញ្ចុះពេញប្រអប់មាស ដែលទេវតាអ្នកនៅត្រង់កណ្តាប់មាត់ចក្រវាឡក្តី ជាន់ត្រៃទសក្តី ក្នុងព្រហ្មលោកក្តី នាំចូលទៅ រមែងធ្លាក់ចុះអំពីអាកាស ។*

បទថា **កាន់សរីរៈព្រះតថាគត** សេចក្តីថា មិនខ្វាត់ខ្វាយទៅក្នុងចន្លោះមករោយរាយចំពោះព្រះសរីរៈ របស់ព្រះតថាគតដោយត្របកកេសរ និងលំអិត ។

ពាក្យថា **ទាំងលម្អិតខ្លឹមចន្ទន៍ជាទិព្វ** បានដល់ លំអិតចន្ទន៍ដែលសម្រេចរូបរបស់ពួកទេវតា ។ មិនមែនលំអិតចន្ទន៍ដែលសម្រេចរូបរបស់ទេវតាប៉ុណ្ណោះ ជារបស់នាគសុបណ្ណនិងមនុស្សផង ។ មិនមែនលំអិតចន្ទន៍តែម្យ៉ាងប៉ុណ្ណោះ នៅមានកម្ទេចផង់គន្ធ-ជាតដែលជាទិព្វទាំងអស់ដូចជាក្រស្នា និងចន្ទន៍ក្រហមជាដើម ។ កម្ទេចផង់ពណ៌លឿងទុំ ពណ៌ខៀវស្រស់ ប្រាក់និងមាស ប្រភេទដែលអប់ដោយក្លិនទិព្វទាំងអស់ បញ្ចុះពេញហិបប្រាក់ និងមាសជាដើមដែលទេវតានៅក្នុងកណ្តាប់មាត់ចក្រវាឡជាដើម នាំចូលទៅមិនរាត់រាយចេញក្នុងចន្លោះ រោយចុះកាន់ព្រះសរីរៈរបស់ព្រះតថាគតដូចគ្នា ។

បទថា **ទាំងចំរៀងជាទិព្វ** សេចក្តីថា បានឮថា ពួកទេវតាអ្នកមានអាយុវែង ឈ្មោះថា វរុណ វារុណ ទេវតាទាំងនោះ ជ្រាបថា ព្រះមហាបុរសកើតក្នុងដែនដីមនុស្ស នឹងត្រាស់ជាព្រះពុទ្ធ

ហើយផ្តើមក្រងកម្រងផ្កាដោយបំណងថា នឹងកាន់ទៅក្នុងថ្ងៃបដិសន្ធិ ។ ក៏ទេវតានោះ កំពុងក្រងកម្រងផ្កា ជ្រាបថា ព្រះមហាបុរសចាប់បដិសន្ធិក្នុងគភ៌របស់មាតា ត្រូវសួរថា ពួកលោកក្រងកម្រងផ្កា ដើម្បីអ្នកណា ឆ្លើយថា មិនទាន់សម្រេច ហើយប្រាប់ថា ពួកយើងក្រងសម្រេចហើយនឹងយកទៅ ក្នុងថ្ងៃស្តេចប្រសូតចាកព្រះគភ៌ ហើយជ្រាបថា ប្រសូតចាកព្រះគភ៌ហើយ គិតថានឹងទៅក្នុងថ្ងៃស្តេចចេញមហាភិនេស្ក្រមណ៍ ជ្រាបសូម្បីថា ព្រះមហាបុរស ទ្រង់គ្រប់គ្រងផ្ទះ ២៩ វស្សា ហើយថ្ងៃនេះក៏ស្តេចចេញមហាភិនេស្ក្រមណ៍ហើយ គិតថា នឹងទៅក្នុងថ្ងៃត្រាស់ដឹង ក៏ប្រាបថា ទ្រង់ធ្វើសេចក្តីព្យាយាមធំរហូតដល់អស់ ៦ វស្សា ថ្ងៃនេះក៏ត្រាស់ដឹង ហើយគិតថា នឹងទៅក្នុងថ្ងៃប្រកាសធម្មចក្រ ជ្រាបសូម្បីទៀតថា ប្រថាប់ទៀបពោធិមណ្ឌស្ថាន ៧ សប្តាហ៍ ស្តេចទៅកាន់ឥសិបតនមិគទាយវ័ន ប្រកាសព្រះធម្មចក្កហើយ គិតថានឹងទៅថ្ងៃទ្រង់សម្តែងយមកបាដិហារ្យ ក៏ជ្រាបថា ថ្ងៃនេះទ្រង់ធ្វើយមកបាដិហារ្យ រួចហើយគិតថា នឹងទៅក្នុងថ្ងៃស្តេចចុះអំពីទេវលោក ជ្រាបថា ថ្ងៃនេះក៏ស្តេចចុះអំពីទេវលោកហើយ គិតថា

នឹងទៅថ្ងៃទ្រង់ដាក់អាយុសង្ខារ ជ្រាបថា ថ្ងៃនេះក៏ទ្រង់ដាក់អាយុ-សង្ខារហើយ គិតថា នៅធ្វើមិនទាន់សម្រេច ក៏នឹងទៅក្នុងថ្ងៃបរិនិព្វាន ជ្រាបថា ថ្ងៃនេះព្រះមានព្រះភាគ ទ្រង់សម្រេចសីហ-សេយ្យា ផ្អៀងទៅខាងស្តាំ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ មានព្រះសតិសម្បជញ្ញៈ នឹងបរិនិព្វានវេលាជិតភ្លឺ មានសំឡេងសួរថាពួកលោកក្រងកម្រងផ្កាដើម្បីអ្នកណា ពោលថា នេះយ៉ាងណាហ្ន៎ ថ្ងៃនេះឯង ព្រះមហាបុរសទ្រង់ចាប់បដិសន្ធិក្នុងព្រះគភ៌របស់មាតា ថ្ងៃនេះក៏ប្រសូតចាកព្រះគភ៌របស់មាតា ថ្ងៃនេះក៏ស្តេចចេញមហា-ភិនេស្រ្កមណ៍ ថ្ងៃនេះក៏ត្រាស់ជាព្រះពុទ្ធ ថ្ងៃនេះក៏ប្រកាសព្រះ-ធម្មចក្រ ថ្ងៃនេះក៏សម្តែងយមកបាដិហារ្យ ថ្ងៃនេះក៏ស្តេចចុះអំពីទេវលោក ថ្ងៃនេះក៏ទ្រង់ដាក់អាយុសង្ខារ ជ្រាបថា ថ្ងៃនេះក៏នឹងស្តេចបរិនិព្វាន ព្រះអង្គគប្បីទ្រង់តាំងព្រះជន្មនៅ ប្រមាណវេលាហុតយាគូម្តង ក្នុងថ្ងៃទី ២ ឬទេហ្ន៎ ហេតុនេះមិនសមគួរដល់ព្រះអង្គ ដែលទ្រង់បំពេញបារមី ១០ ហើយសម្រេចជាព្រះពុទ្ធចាំបាច់យើងត្រូវតែកាន់យកកម្រងផ្កា ដែលនៅមិនទាន់សម្រេចមក កាលមិនបានឱកាសខាងក្នុងចក្រវាឡ ក៏បានបំពាក់លើ

កណ្តាប់មាត់ចក្រវាឡ ហែទៅតាមកណ្តាប់មាត់ចក្រវាឡ យកដៃផ្គុំនឹងដៃឲ្យក្រពុំ ប្រៀងប្រារព្ធព្រះរតនត្រៃ ប្រារព្ធមហាបុរិសលក្ខណៈ ៣២ ព្រះឆព្វណ្ណរង្សី ទសបារមី ជាតក ៥៥០ ព្រះពុទ្ធញាណ ១៤ ក្នុងទីបំផុតនៃព្រះពុទ្ធគុណនោះៗ ក៏ត្រូវលះបង់ទៅៗ ។ លោកអាស្រ័យសង្គីតៈនោះ ទើបពោលពាក្យនេះថា **ទិព្វានិបិ សង្គីតានិ អន្តលិក្ខេ, វជ្ជន្តិ តថាគតស្ស បូជាយ** (ទាំងចម្រៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត) ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់បន្តទៀតថា ៖

ម្នាលអានន្ទ ព្រះតថាគត មិនបានឈ្មោះថា បរិស័ទ ធ្វើសក្ការៈក្តី គោរពក្តី រាប់អានក្តី បូជាក្តី និងកោតក្រែងក្តី ដោយហេតុមានប្រមាណប៉ុណ្ណោះឡើយ

យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ :

ម្នាលអានន្ទ បុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតដោយគ្រឿងបូជាដ៏ឧត្តម,

តស្មាតិហានន្ទ ធម្មានុធម្មប្បដិបន្នា វិហរិស្សាម សាមីចិប្បដិបន្នា អនុធម្មចារិនោតិ ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វំ ។ ម្នាលអានន្ទ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយនឹងប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

<u>អដ្ឋកថា</u> ៖

ក៏ឯព្រះមានព្រះភាគ ទ្រង់ផ្ទំផ្អៀងខាងស្តាំ ចន្លោះដើមសាលព្រឹក្សទាំងគូ ទ្រង់ឃើញសេចក្តីឧស្សាហ៍យ៉ាងធំ របស់បរិស័ទដែលប្រជុំគ្នាតាំងពីផែនដី ទៅទល់កណ្តាប់មាត់ចក្រវាឡ និងតាំងពីកណ្តាប់មាត់ចក្រវាឡទៅទល់ព្រហ្មលោក ទើបត្រាស់ប្រាប់ព្រះអានន្ទ ។ ដោយហេតុនោះ លោកទើបពោលថា "អថខោ

ភគវា អាយស្មន្តំ អានន្ទំ ។បេ។ តថាគតស្ស បូជាយ" ។ គ្រាទ្រង់សម្តែងមហាសក្ការៈយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងសេចក្តីដែលព្រះអង្គជាអ្នកដែលបរិស័ទ មិនធ្វើសក្ការៈដោយមហាសក្ការៈសូម្បីនោះ ទើបត្រាស់ថា ន ខោ អានន្ទ ឯត្តាវតា (ម្នាលអានន្ទ មិនបានឈ្មោះថា) ជាដើម ។

លោកអធិប្បាយទុកយ៉ាងនេះថា ម្នាលអានន្ទ តថាគតក្រាបនៅទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមថា **ទីបង្ករ** ប្រជុំធម៌ ៨ ប្រការ កាលនឹងធ្វើអភិនីហារ មិនមែនធ្វើអភិនីហារ ដើម្បីប្រយោជន៍ដល់កម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងប្រគំនិងការច្រៀង មិនមែនបំពេញបារមីទាំងឡាយ ដើម្បីប្រយោជន៍ដល់វត្ថុទាំងនោះ ព្រោះដូច្នោះ តថាគតមិនឈ្មោះថា បរិស័ទបូជាហើយដោយការបូជានេះឡើយ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទ្រង់សរសើរវិបាក ដែលសូម្បីព្រះពុទ្ធញាណក៏កំណត់មិនបាននៃការបូជា ដែលបុគ្គលកាន់យកត្រឹមតែផ្កាកប្បាសមួយទង រលឹកដល់ព្រះពុទ្ធគុណបូជាហើយទុកក្នុងទីដទៃ ក្នុងទីនេះត្រឡប់ទ្រង់ជំទាស់ការបូជាធំ

យ៉ាងនេះ ។ ឆ្លើយថា ព្រោះដើម្បីនឹងទ្រង់អនុគ្រោះបរិស័ទ ១ ដើម្បីប្រាថ្នានឹងឲ្យព្រះសាសនាតាំងនៅយឺនយូរ ១ ។

ពិតមែន ព្រះមានព្រះភាគ មិនគប្បីជំទាស់យ៉ាងនោះហើយ តទៅក្នុងអនាគត ពុទ្ធបរិស័ទក៏មិនគប្បីបំពេញសីល ក្នុងឋានៈដែលសីលមកដល់ នឹងមិនឲ្យសមាធិបរិបូរណ៍ ក្នុងឋានៈដែលសមាធិមកដល់ មិនឲ្យកាន់បន្ទប់គឺវិបស្សនា ក្នុងឋានៈដែលវិបស្សនាមកដល់ បបួលហើយបបួលទៀត នូវឧបដ្ឋាកធ្វើការបូជាតែម្យ៉ាង ។ ពិតមែន ឈ្មោះថា អាមិសបូជានោះ មិនអាចនឹងតម្កល់ព្រះសាសនា សូម្បីក្នុងថ្ងៃមួយខ្ទះ សូម្បីវេលាប្រមាណហុតយាគូមួងខ្ទះ ។ ពិតមែន វិហាររាប់ពាន់ដូចជាមហាវិហារ ចេតិយរាប់ពាន់ចេតិយ ដូចជាមហាចេតិយ ក៏តម្កល់ព្រះសាសនាទុកមិនបាន ។ បុណ្យអ្នកណាធ្វើទុក ក៏ជារបស់អ្នកនោះតែម្នាក់ ។ ចំណែកសម្មាបដិបត្តិ ឈ្មោះថា ជាការបូជាដែលសមគួរចំពោះព្រះតថាគត ។ ជាការពិត បដិបត្តិបូជានោះ ឈ្មោះថា តាំងនៅហើយ អាចតម្កល់ព្រះសាសនាទុកបានផង ព្រោះដូច្នោះ ព្រះមាន

ព្រះភាគ កាលនឹងទ្រង់សម្តែងបដិបត្តិបូជានោះ ទើបត្រាស់ថា **យោ ខោ អានន្ទ** (ម្នាលអានន្ទ បុគ្គលណាមួយ) ជាដើម ។

បណ្តាបទទាំងនោះ បទថា ធម្មានុធម្មបដិបន្នោ (ប្រតិបត្តិនូវធម៌តាមធម៌) បានដល់ បដិបត្តិបុព្វភាគបដិបទា ដែលជាធម៌សមគួរដល់លោកុត្តរធម៌ ៩ ប្រការ ។ ក៏បដិបទានុ៎ះឯង លោកហៅថា **សាមីចិ** ប្រពៃក្រៃលែង ព្រោះជាបដិបទាដែលសមគួរ ។ ឈ្មោះថា សាមីចិបដិបន្នោ ប្រតិបត្តិដោយសេចក្តីកោតក្រែង ព្រោះបដិបត្តិធម៌ដ៏ប្រពៃក្រៃលែង ។ ឈ្មោះថា អនុធម្មចារី ប្រព្រឹត្តតាមធម៌ ព្រោះប្រព្រឹត្តបំពេញធម៌ដ៏សមគួរ ពោលគឺបុព្វ-ភាគបដិបទានោះឯង ។ ក៏សីល អាចារៈ បញ្ញត្តិ ការសមាទាន-ធុតង្គ សម្មាបដិបទាដល់គោត្រភូញាណ គប្បីជ្រាបថា បុព្វភាគ-បដិបទា ។ ព្រោះដូច្នោះ ភិក្ខុតាំងនៅក្នុងអគារវៈ ៦ ល្មើសបញ្ញត្តិចិញ្ចឹមជីវិតដោយអនេសនា ភិក្ខុនេះឈ្មោះថា មិនបដិបត្តិសមគួរដល់ធម៌ ចំណែកភិក្ខុណាមិនល្មើសសិក្ខាបទដែលទ្រង់បញ្ញត្តហើយដល់ខ្ទង់ទាំងអស់ ដែលកម្រិតព្រំប្រទល់ និងខ្សែបន្ទាត់របស់ព្រះជិនស្រី សូម្បីមានប្រមាណតិច ភិក្ខុនេះឈ្មោះថា បដិបត្តិធម៌

សមគួរដល់ធម៌ ។ សូម្បីក្នុងភិក្ខុនី ក៏ន័យនេះដូចគ្នា ។ ក៏ឧបាសកណាធ្វើពៀរវេរា ៥ អកុសលកម្មបថ ១០ ប្រព្រឹត្តប្រកាន់មាំ ឧបាសកនោះឈ្មោះថា មិនបដិបត្តិធម៌សមគួរដល់ធម៌ ។ ចំណែកឧបាសកបដិបត្តិឲ្យសម្បូរក្នុងសរណៈ ៣ សីល ៥ សីល ១០ រក្សាឧបោសថមួយខែ ៨ ដង ថ្វាយទាន បូជាដោយរបស់ក្រអូប បូជាដោយមាលា ទំនុកបម្រុងមាតាបិតា ទំនុកបម្រុងសមណ-ព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ឧបាសកនេះ ឈ្មោះថា ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ សូម្បីក្នុងឧបាសិកា ក៏ន័យនេះដូចគ្នា ។

បទថា បរមាយ បូជាយ (ដោយការបូជាក្រៃលែង) បានដល់ ដោយបូជាដ៏ខ្ពង់ខ្ពស់ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងទុកថា ពិតមែន ឈ្មោះថា និរាមិសបូជា អាចតម្កល់ព្រះសាសនារបស់តថាគតទុកបាន ។ ពិតមែន បរិស័ទ ៤ នេះនឹងបូជាតថាគតដោយការបូជានេះត្រឹមណា សាសនារបស់យើងក៏នឹងរុងរឿង ដូចព្រះចន្ទ្រពេញវង់រះឡើងកណ្តាលផ្ទៃអាកាស ដូច្នោះ ។

## ៣៨-រឿងព្រះឧបវាណ

*សម័យនោះឯង ឧបវាណភិក្ខុមានអាយុ ឋិតនៅចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ កំពុងបក់ថ្វាយព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់បណ្តេញឧបវាណៈមានអាយុថា អ្នកចូរចៀសចេញ អ្នកកុំឋិតនៅខាងមុខតថាគតឡើយ ។*

*គ្រានោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះ ដូច្នេះថា ព្រះឧបវាណៈមានអាយុនេះ ជាឧបដ្ឋាកធ្លាប់នៅជិត ដើរជិតព្រះមានព្រះភាគ ជាយូរហើយ ទើបតែបច្ឆិមកាល(នេះ) ព្រះមានព្រះភាគ ទ្រង់បណ្តេញឧបវាណៈមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំឋិតនៅខាងមុខតថាគតឡើយ ដូច្នេះ មានហេតុដូចម្តេច មានបច្ច័យដូចម្តេច បានជាព្រះមានព្រះភាគ ទ្រង់បណ្តេញឧបវាណៈមានអាយុថា អ្នកចូរចៀសចេញ អ្នកកុំឋិតនៅខាងមុខតថាគតឡើយ ។ ទើបព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧបវាណៈមានអាយុនេះ ជាឧបដ្ឋាកធ្លាប់នៅជិត ដើរជិតព្រះមានព្រះភាគ ។បេ។ ដូច្នេះ ។*

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ទេវតាក្នុងលោកធាតុទាំង ១០ ប្រជុំគ្នា ដើម្បីមើលតថាគតដោយច្រើន ម្នាលអានន្ទ សាលវ័នរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុងកុសិនារាមានចំនួន ១២ យោជន៍ដោយជុំវិញ មានកំណត់ត្រឹមណា ប្រទេសនោះ សូម្បីគ្រាន់តែល្មមចាក់ដោយចុងបំផុតនៃសក់ដែលទេវតាមានស័ក្កិធំ មិនបានពាល់ត្រូវ មិនមានឡើយ ម្នាលអានន្ទ ពួកទេវតាពោលទោសថា

"ពួកយើងមកអំពីចម្ងាយ ដើម្បីឃើញព្រះតថាគតៗ ជាព្រះអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកមានម្តងៗ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះឯង បរិនិព្វាននឹងមានដល់ព្រះតថាគត ក៏ភិក្ខុមានស័ក្តិធំនេះ មកឈរវាំងនៅចំព្រះភក្រ្ត នៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះតថាគត ក្នុងបច្ឆិមកាលឡើយ" ។

អដ្ឋកថា ៖

បានឮថា ក្នុងចំណែកដែលជិតព្រះមានព្រះភាគ ទេវតាដែលមានស័ក្តិធំ និម្មិតអត្តភាពដែលល្អិតក្នុងឱកាសប៉ុនចុងរោមទ្រាយ ១០ អង្គៗ ។ ខាងមុខនៃទេវតា ១០ អង្គៗ នោះ

មានទេវតា ២០ អង្គៗ ។ ខាងមុខទេវតា ២០ អង្គៗ មានទេវតា ៣០ អង្គៗ ខាងមុខទេវតា ៣០ អង្គៗ មានទេវតា ៤០ អង្គៗ ខាងមុខទេវតា ៤០ អង្គៗ មានទេវតា ៥០ អង្គៗ ។ ខាងមុខទេវតា ៥០ អង្គ មានទេវតាឈរគាល់នៅ ៦០ អង្គៗ ។ ទេវតាទាំងនោះ ជ្រៀតគ្នានឹងគ្នាដោយដៃជើង ឬសំពត់ ។ មិនមានហេតុដែលនឹងគប្បីពោលថា ចេញទៅកុំច្រៀតបៀតយើង ។ ទេវតាទាំងឡាយ ក៏ដូចគ្នានឹងដែលទ្រង់ត្រាស់ទុកថា “ម្នាលសារីបុត្រ ឯពួកទេវតា ទាំងនោះ មានចំនួន ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះ ៤០ អង្គខ្លះ ៥០ អង្គខ្លះ ៦០ អង្គខ្លះ ឋិតនៅក្នុងទីឱកាសល្មមចាក់ដោយចុងដែកស្រួចបាន តែមិនច្រៀតបៀតដល់គ្នានឹងគ្នាឡើយ” ។

បទថា ឱវារេន្តោ (ឈរបាំង) គឺឈរបាំង ។ បានឮថា ព្រះថេរៈរាងធំដូចនឹងកូនដំរី ដណ្តប់សំពត់បង្សុកូលចីវរ ក៏មើលទៅដូចធំសម្បើមណាស់ ។

បទថា តថាគតំ ទស្សនាយ (បានឃើញព្រះតថាគត) សេចក្តីថា ទេវតាទាំងឡាយ កាលមិនបានឃើញព្រះភក្ត្រព្រះមានព្រះភាគ ទើបតិះដៀលយ៉ាងនេះ ។ សួរថា ក៏ទេវតាទាំងនោះ មិន

អាចមើលធ្លុះព្រះថេរៈឬ ។ ឆ្លើយថា មិនមើលអាចធ្លុះទេ ។ ព្រោះថា ពួកទេវតាអាចមើលធ្លុះ(កាយ)ពួកបុថុជ្ជនបាន តែមើលធ្លុះ(កាយ) ពួកព្រះខីណាស្រពមិនបានទេ ទាំងមិនអាចចូលទៅជិតផង ។ ព្រោះព្រះថេរៈមានអានុភាពច្រើន មានអំណាចច្រើន ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះថេរៈទើបមានអំណាចច្រើន អ្នកដទៃមិនជាព្រះអរហន្តឬ ។ ឆ្លើយថា ព្រោះលោកជាអារក្ខទេវតានៅក្នុងចេតិយរបស់ព្រះពុទ្ធកស្សប ។ បានឮមកថា កាលព្រះវិបស្សី-សម្មាសម្ពុទ្ធ បរិនិព្វានហើយ ជនទាំងឡាយបាននាំគ្នាសាងព្រះ-ចេតិយមួយ បញ្ចុះព្រះសារីរិកធាតុសរីរៈដែលដូចគ្នានឹងដុំមាសតាន់ ។ ពិតមែន ព្រះពុទ្ធដែលមានព្រះជន្មាយុវែង រមែងមានព្រះចេតិយតែមួយប៉ុណ្ណោះ មនុស្សទាំងឡាយប្រើផែនឥដ្ឋមាសបណ្តោយ ១ ហត្ថ ទទឹងមួយចំអាម កម្រាស់ ៨ ធ្នាប់ សាងព្រះ-ចេតិយនោះ ភ្ជាប់ដោយរង់និងមនោសិលាជំនួសដី លាបដោយប្រេងល្ងជំនួសទឹក ហើយស្ថាបនាប្រមាណមួយយោជន៍ ។ តពីនោះ ភុម្មទេវតា ក៏មួយយោជន៍ តពីនោះ ក៏អាកាសដ្ឋកទេវតា តពីនោះ ក៏ឧណ្ហវលាហកទេវតា តពីនោះ ក៏អព្ភវលាហកទេវតា

តពីនោះ ក៏ទេវតា ជាន់ចាតុម្មហារាជ តពីនោះ ទេវតាជាន់តាវត្តិង្ស ស្ថាបនា ១ យោជន៍ ។ ព្រះចេតិយទើបមាន ៧ យោជន៍ ដោយប្រការដូច្នេះ ។

កាលមនុស្សកាន់យកកម្រងផ្កា គ្រឿងក្រអូប និងសំពត់ជាដើមមក អារក្ខទេវតាទាំងឡាយក៏នាំគ្នាកាន់ផ្កាឈើមកបូជាព្រះចេតិយ ទាំងដែលមនុស្សទាំងនោះបានឃើញ ។ គ្រានោះព្រះថេរៈនេះជាព្រាហ្មណ៍មហាសាល កាន់សំពត់លឿងមួយផ្ទាំងទៅ ។ ទេវតាក៏ទទួលសំពត់អំពីដៃព្រាហ្មណ៍នោះទៅបូជាព្រះ-ចេតិយ ។ ព្រាហ្មណ៍ឃើញដូច្នោះ ក៏មានចិត្តជ្រះថ្លាតាំងសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល សូម្បីយើងក៏នឹងជាអារក្ខទេវតាក្នុងព្រះចេតិយរបស់ព្រះពុទ្ធបែបនេះ ដូច្នេះហើយ ចុតិអំពីអត្តភាពនោះក៏ទៅកើតក្នុងទេវលោក ។ កាលព្រាហ្មណ៍នោះត្រាច់អន្ទោលនៅក្នុងមនុស្សលោកនិងទេវលោក ព្រះកស្សបៈមានព្រះភាគ ស្តេចឧប្បត្តិក្នុងលោកហើយបរិនិព្វាន ។ ព្រះធាតុសរីរៈរបស់ព្រះអង្គក៏មានតែមួយកន្ទែងប៉ុណ្ណោះ ។ មនុស្សទាំងឡាយនាំព្រះធាតុសរីរៈនោះ សាងព្រះចេតិយ ១ យោជន៍ ។ ព្រាហ្មណ៍ជាអារក្ខទេវតា

ក្នុងព្រះចេតិយនោះ កាលព្រះសាស្តាអន្តរធានទៅ ។ ក៏កើតក្នុងសួគ៌ក្នុងកាលរបស់ព្រះមានព្រះភាគនៃយើង ចុតិអំពីសួគ៌នោះហើយ កាន់បដិសន្ធិក្នុងត្រកូលធំ ចេញបួសហើយ សម្រេចព្រះ-អរហត្ត ។ គប្បីជ្រាបថា ព្រះថេរៈមានអំណាចច្រើន ព្រោះជាអារក្ខទេវតាក្នុងព្រះចេតិយមកហើយ ដោយប្រការដូច្នេះ ។

ដោយពាក្យថា **ម្នាលអានន្ទ ពួកទេវតាពោលទោស** ព្រះមានព្រះភាគ ទ្រង់សម្តែងថា ម្នាលអានន្ទ ពួកទេវតាតិះដៀល មិនមែនបុត្រយើងមានសេចក្តីខុសអ្វីដទៃ ។

<u>ព្រះអានន្ទ</u> ក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ចុះពួកទេវតាធ្វើទុកក្នុងចិត្តដូចម្តេច ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មានពួកទេវតា (ខ្លះ) **សម្គាល់ផែនដីក្នុងអាកាស** (និម្មិតផែនដីក្នុងអាកាស) រំសាយកេសា កន្ទក់កន្ទេញ ផ្គងនូវកំភួនដៃឡើង កន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះនៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមាន-ព្រះភាគ នឹងបរិនិព្វានឆាប់ម៉្លេះ ព្រះសុគតនឹងបរិនិព្វានឆាប់ម៉្លេះ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោកនឹងសូន្យបាត់ទៅឆាប់ម៉្លេះ,

ម្នាលអានន្ទ មានពួកទេវតា (ខ្លះ) **សម្គាល់ផែនដីក្នុងផែនដី** (និម្មិតផែនដីប្រក្រតីឲ្យជាផែនដីទិព្វ) រំសាយកេសា ។បេ។ នឹងសូន្យបាត់ទៅឆាប់ពេកណាស់, ឯពួកទេវតាណា ដែលមិនមានរាគៈ ពួកទេវតានោះ មានសតិនិងសម្បជញ្ញៈ អត់សង្កត់សេចក្ដីសោកបាន ដោយគិតថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបានសេចក្ដីទៀងទាត់ (ក្នុងខន្ធប្បវត្តិ)នេះ អំពីណា ។

<u>អដ្ឋកថា</u> សុមង្គលវិលាសិនី ពន្យល់ថា ៖

ព្រោះហេតុអ្វី ព្រះអានន្ទ ទើបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ចុះពួកទេវតាធ្វើទុកក្នុងចិត្តដូចម្ដេច" ។ ទូលសួរថា បពិត្រព្រះមានព្រះភាគ ព្រះអង្គត្រាស់ថា ពួកទេវតាតិះដៀល ក៏ពួកទេវតានោះធ្វើទុកក្នុងចិត្តដូចម្ដេច ទើបនឹងព្រមទទួលការបរិនិព្វានរបស់ព្រះអង្គឬ ។ គ្រានោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងការៈដែលពួកទេវតាទាំងនោះ ព្រមទទួលមិនបានថា យើងមិនពោលហេតុនៃការព្រមទទួល ទើបត្រាស់ ថា **សន្តានន្ទ** (ម្នាលអានន្ទ មាន) ជាដើម ។

*បណ្ដាបទទាំងនោះ បទថា* អាកាសេ បថវីសញ្ញិនិយោ *(សម្គាល់ផែនដីក្នុងអាកាស) បានដល់ និម្មិតផែនដីក្នុងអាកាស មានសេចក្ដីសម្គាល់ក្នុងអាកាសនោះថាជាផែនដី ។ បទថា* ***កន្ទក់កន្ទេញ*** *គឺស្រែកយំ ។ បទថា* ***ផ្ដួលខ្លួនបីដូចជាមានជើងដាច់*** *បានដល់ រលំដួលចុះដូចជាដាច់ពាក់កណ្ដាលខ្លួន ។ បទថា* ***បម្រះនទៀលទៅមក*** *បានដល់ ដួលប្រមៀលទៅ ។ ម្យ៉ាងទៀត ដួលប្រមៀលទៅទីខាងមុខ ទីខាងក្រោយ ទីខាងឆ្វេង ទីខាងស្ដាំ ហៅថា* ***បម្រះនទៀល*** *។ បទថា* សន្តានន្ទ ទេវតា បថវិយំ បថវីសញ្ញិនិយោ *(ម្នាលអានន្ទ មានពួកទេវតា សម្គាល់ផែនដីក្នុងផែនដី) សេចក្ដីថា បានឮថា ពួកទេវតាមិនអាចតម្កល់ខ្លួនបាននៅលើផែនដីប្រក្រតី ។ ពួកទេវតា រមែងលិចចុះក្នុងផែនដីនោះដូចហត្ថកព្រហ្ម ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា "ម្នាលហត្ថកៈ អ្នកចូរនិម្មិតនូវអត្តភាពឲ្យធំសម្បើម" ។ ព្រោះដូច្នោះ លោកសំដៅយកពួកទេវតាដែលនិម្មិតផែនដីក្នុងផែនដី ទើបពោលថា ពួកទេវតាមានសេចក្ដីសម្គាល់ក្នុងផែនដីថាជាផែនដី ។ បទថា* វីតរាគា *(មិនមានរាគៈ) បានដល់ ពួកទេវតាដែលជាព្រះអនាគាមី*

និងព្រះឱណាស្រេចដែលមានទោមនស្សលះបង់បានហើយ ដូចគ្នានឹងសសរថ្ម ។

## ៣៩_សំវេជនីយដ្ឋាន ៤ កន្លែង

ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ពួកភិក្ខុនៅចាំវស្សាក្នុងទិសទាំងឡាយ រួចហើយ តែងមកគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គ តែងបានជួបនឹងភិក្ខុអ្នកចម្រើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះអំណើះតតអំពីព្រះមានព្រះភាគទៅ យើងខ្ញុំព្រះអង្គ នឹងលែងបានជួប លែងបានចូលទៅអង្គុយជិតភិក្ខុអ្នកចម្រើនដោយចិត្តហើយ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ **សំវេជនីយដ្ឋាន** (ទីដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្ត អ្នកមានសទ្ធានេះ ៤ កន្លែង ។ សំវេជនីយដ្ឋាន ៤ កន្លែង តើដូចម្តេច ។ ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះដូច្នេះ ១ ម្នាលអានន្ទ

សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយ
រឭកឃើញថា ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ-
ញាណ ក្នុងទីនេះដូច្នេះ ១ ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរ
ឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះ-
តថាគតបានសម្តែងនូវអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះ ១ ម្នាល
អានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្ត អ្នកមានសទ្ធា
ដោយរឭកឃើញថា ព្រះតថាគតបរិនិព្វានដោយអនុបាទិសេស-
និព្វានធាតុ ក្នុងទីនេះដូច្នេះ ១ ម្នាលអានន្ទ នេះឯងសំវេជនីយ-
ដ្ឋានដែលគួរឃើញ ៤ កន្លែងរបស់កុលបុត្តអ្នកមានសទ្ធា,

ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមាន
សទ្ធា នឹងមកដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះ
ដូច្នេះក្តី ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ក្នុង
ទីនេះដូច្នេះក្តី ព្រះតថាគតបានសម្តែងនូវអនុត្តរធម្មចក្ក ក្នុងទីនេះ
ដូច្នេះក្តី ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុង
ទីនេះដូច្នេះក្តី ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមកកាន់ទី
ចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ

ពួកជនទាំងអស់នោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្ស សុគតិ និងឋានសួគ៌ ។

<u>អដ្ឋកថា</u> : បទថា សទ្ធស្ស (អ្នកមានសទ្ធា) សេចក្តីថា វត្ថុទាំងអស់ មានចេតិយង្គណវត្តជាដើម ដែលលោកធ្វើតាំងពីព្រឹក រមែងប្រាកដដល់កុលបុត្រដែលមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធជាដើម អ្នកបរិបូរណ៍ដោយវត្ត ។

បទថា ទស្សនីយានិ បានដល់ គួរឃើញ គឺគួរទៅដើម្បីឃើញ ។ បទថា សំវេជនីយានិ បានដល់ ឲ្យកើតសេចក្តីសង្វេគ ។ បទថា ឋានានិ បានដល់ ហេតុ ឬទីស្ថាន ។ ពាក្យថា យេ ហិ កេចិ នេះ លោកពោលដើម្បីសម្តែងដល់ការចារិកទៅក្នុងចេតិយមានប្រយោជន៍ ។

តត្ថ ចេតិយចារិកំ អាហិណ្ឌន្តាតិ យេ ច តាវ តត្ថ តត្ថ ចេតិយង្គណំ សម្មជ្ជន្តា, អាសនានិ ធោវន្តា ពោធិម្ហិ ឧទកំ សិញ្ចន្តា អាហិណ្ឌន្តិ, តេសុ វត្តពូមេវ

ឆត្តិ អសុកាវិហារេ "ចេតិយំ វន្ទិស្សាមា"តិ និក្ខមិត្វា បសន្នចិត្តា អន្តរា កាលំ ករោន្តាបិ អនន្តរាយេន សគ្គេ បតិដ្ឋហិស្សន្តិ យេវាតិ ឧស្សេតិ ។

បណ្តាបទទាំងនោះ ដោយបទថា ចេតិយចារិកំ អាហិណ្ឌន្តា លោកសម្តែងថា កាលមុនភិក្ខុទាំងឡាយណា បោសលានចេតិយក្នុងទីនោះ សំអាតអាសនៈ ស្រោចទឹកដើមពោធិព្រឹក្សហើយត្រាច់ទៅ ក្នុងភិក្ខុទាំងនោះមិនចាំបាច់ត្រូវពោលឡើយ ។ ពួកភិក្ខុដែលចេញអំពីវត្តទៅ ដោយគិតថា នឹងទៅថ្វាយបង្គំព្រះចេតិយក្នុងវត្តឯណោះ មានចិត្តជ្រះថ្លា សូម្បីធ្វើកាលកិរិយាក្នុងចន្លោះផ្លូវ ក៏នឹងទៅកើតក្នុងឋានសួគ៌ដោយមិនមានអន្តរាយឡើយ ។

## ៤០-ការប្រតិបត្តិក្នុងមាតុគ្រាម

ព្រះអានន្ទក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គទាំងឡាយ ត្រូវប្រដិបត្តិក្នុងមាតុគ្រាមដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ត្រូវកុំមើល ។ បពិត្រព្រះមានព្រះភាគ កាលបើមើលហើយ គប្បីប្រដិបត្តិដូចម្តេច ។ ម្នាលអានន្ទ ត្រូវកុំ

និយាយរក ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើនិយាយរកហើយ គប្បីប្រដិបត្តិដូចម្ដេចទៀត ។ ម្នាលអានន្ទ គប្បីតាំងសតិឲ្យមាំ ។

អដ្ឋកថា សុមង្គលវិលាសនី ពន្យល់ថា ៖

បទថា អទស្សនំ អានន្ទ ទ្រង់សម្ដែងថា ការមិនមើលមាតុគ្រាមនោះឯង ជាការប្រតិបត្តិដ៏ឧត្ដមគួរក្នុងទីនេះ ពិតមែនភិក្ខុបើកទ្វារអង្គុយលើសេនាសនៈ ដរាបណាដែលមិនទាន់មើលមាតុគ្រាមមកឈរត្រង់ខាងមុខទ្វារ ដរាបនោះ ភិក្ខុនោះ រមែងមិនកើតលោភៈ ចិត្តមិនញាប់ញ័រដោយចំណែកមួយប៉ុណ្ណោះ ។ តែកាលមើលហើយ ទាំង ២ យ៉ាងនោះ ក៏គប្បីមាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា អទស្សនំ អានន្ទ ។

បទថា ទស្សនេ ភន្តេ ភគវា សតិ ការិ ព្រះអានន្ទទូលសួរថា កាលឃើញក្នុងទីដែលភិក្ខុចូលទៅទទួលភិក្ខាជាដើម ភិក្ខុនឹងគប្បីបដិបត្តិយ៉ាងណា គ្រានោះ ព្រះមានព្រះភាគ ត្រាស់ថា បុរសឈរកាន់ដាវ ពោលថា បើលោកនិយាយនឹងយើង យើងនឹងកាត់សីសៈលោកឲ្យដាច់ក្នុងទីនេះឯង ឬនាងយក្ខិនីឈរពោលថា បើលោកនិយាយនឹងយើង យើងនឹងពន្ទុះ ស៊ាច់លោកស៊ីក្នុងទីនេះ

យ៉ាងនេះឯងនៅល្អជាង ព្រោះការវិនាស មានហេតុ (នៃការចរចា) នោះជាបច្ច័យ រមែងមានតែក្នុងអត្តភាពមួយប៉ុណ្ណោះ មិនបានទៅសោយទុក្ខ ដែលកំណាត់មិនបានក្នុងអបាយភូមិទាំងឡាយ ចំណែកកាលមានការចរចា ប្រាស្រ័យជាមួយមាតុគ្រាម ការស្គាល់ជិតដិតក៏មាន កាលមានការស្គាល់ជិតដិតបន្ទោះផ្លូវក៏មាន ភិក្ខុដែលមានរាគៈគ្របសង្កត់ ក៏ដល់សេចក្តីវិនាសនៃសីល ត្រូវទៅពេញក្នុងអបាយភូមិ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **អនាលាបោ** ដូច្នេះ ។ សមពិត ដូចដែលព្រះអង្គត្រាស់ទុកថា ៖

"សល្លបេ អសិហត្ថេន បិសាចេនាបិ សល្លបេ
អាសីវិសម្បិ អាសីទេ យេន ទដ្ឋោ ន ជីវតិ
នត្វេវ ឯកោ ឯកាយ មាតុគាមេន សល្លបេ"។

បុគ្គល ចរចាជាមួយនឹងជនដែលមានដាវក្នុងដៃក្តី ចរចាជាមួយនឹងបិសាចក្តី ប៉ះពាល់នឹងអាសិរពិស ហើយត្រូវអាសិរពិសចឹកស្លាប់ក្តី (ប្រសើរជាង) មិនគួរចរចាជាមួយនឹងមាតុគ្រាមតែមួយនឹងមួយឡើយ[១] ។

---

១ អង្គុត្តរនិកាយ បញ្ចកនិបាត លេខ២៤ ទំព័រ១៤០ ។

*បទថា អាលបន្តេ បន សេចក្តីថា បើមាតុគ្រាមសួរក្នុងសីល ប្រាថ្នានឹងស្តាប់ធម៌ សួរបញ្ហា ឬក៏មានកិច្ចកម្ម ដែលបព្វជិតត្រូវធ្វើដល់មាតុគ្រាមនោះ មាតុគ្រាមនោះ ក៏ត្រូវនិយាយនឹងភិក្ខុដែលមិននិយាយក្នុងវេលាយ៉ាងនេះថា ភិក្ខុអង្គនេះឆ្គួតទេដឹង ថ្លង់ទេដឹង ឆាន់រួចហើយអង្គុយបិទមាត់ ព្រោះដូច្នោះ ភិក្ខុគប្បីនិយាយដោយពិត ។*

*ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គ កាលភិក្ខុនិយាយយ៉ាងនេះ គប្បីប្រតិបត្តិយ៉ាងណា ។ លំដាប់នោះ ព្រះមានព្រះ-ភាគ ទ្រង់សំដៅយកព្រះឱវាទដែលទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរតាំងចិត្តឲ្យដូចជាមាតា ក្នុងពួកស្ត្រីល្មមជាមាតា ចូរតាំងចិត្តឲ្យដូចជាបងប្អូនស្រី ក្នុងពួកស្ត្រីល្មមជាបងប្អូនស្រី ចូរតាំងចិត្តឲ្យដូចជាកូនស្រី ក្នុងពួកស្ត្រីល្មមជាកូនស្រី[១] ។ ទើបត្រាស់ថា គប្បីតាំងសតិទុក ។*

---

*១. សំយុត្ត. សឡា. គហបតិវគ្គ. ៣៥. ១៩៤, ២៥៥ ។*

## ៤១-ការប្រតិបត្តិក្នុងព្រះសរីរៈ

ព្រះអានន្ទក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គទាំងឡាយ ត្រូវប្រតិបត្តិក្នុងព្រះសរីរៈព្រះតថាគតដូចម្ដេច ។ (ព្រះអង្គត្រាស់ថា) ម្នាលអានន្ទ អ្នកទាំងឡាយកុំខ្វល់ខ្វាយ ដើម្បីបូជាសរីរៈតថាគតឡើយ ម្នាលអានន្ទ អ្នកទាំងឡាយចូរខំព្យាយាម ក្នុងប្រយោជន៍របស់ខ្លួនចុះ ចូរខ្មីឃ្មាត សង្វាតក្នុងប្រយោជន៍របស់ខ្លួនចុះ កុំប្រមាទក្នុងប្រយោជន៍របស់ខ្លួន ចូរព្យាយាម មានចិត្តបញ្ជូនទៅ (កាន់ព្រះនិព្វាន) ចុះ ម្នាលអានន្ទ គង់តែមានខត្តិយបណ្ឌិតក្ដី ព្រាហ្មណបណ្ឌិតក្ដី គហបតីបណ្ឌិតក្ដី ជ្រះថ្លាក្នុងព្រះតថាគត គេនឹងធ្វើការបូជាសរីរៈតថាគតមិនខាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងឡាយនោះ គប្បីប្រតិបត្តិក្នុងព្រះសរីរៈព្រះតថាគត ដូចម្ដេច ។ ម្នាលអានន្ទ ជនទាំងឡាយតែងប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ យ៉ាងណាមិញ ជនទាំងនោះ គប្បីប្រតិបត្តិក្នុងសរីរៈតថាគតយ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងនោះ ប្រតិបត្តិក្នុងព្រះសរីរៈព្រះចក្រពត្តិរាជ ដូចម្ដេច ។ ម្នាលអានន្ទ ជនទាំងឡាយ រុំសរីរៈព្រះចក្រពត្តិរាជ ដោយសំពត់ថ្មី លុះរុំ

ដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីរួចហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំសរីរៈព្រះចក្រពត្តិរាជ ដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ដោយមឈូសមាស ដែលដាក់ប្រេង ហើយគ្របដោយមឈូសមាសដទៃ រួចធ្វើជើងថ្ករ ហើយថ្វាយព្រះភ្លើង ចំពោះសរីរៈព្រះចក្រពត្តិរាជ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ហើយគេធ្វើស្តូបនៃព្រះចក្រពត្តិរាជ ក្នុងផ្លូវធំបែកជា ៤ ម្នាលអានន្ទ ជនទាំងឡាយ ប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ យ៉ាងណាមិញ ជនទាំងនោះ គប្បីប្រតិបត្តិក្នុងសរីរៈតថាគត គប្បីធ្វើស្តូបរបស់តថាគត ក្នុងផ្លូវធំបែកជា ៤ យ៉ាងនោះចុះ ពួកជនណា នឹងលើកឡើងនូវកម្រងផ្កាក្តី គ្រឿងក្រអូបក្តី គ្រឿងលម្អិតក្តី ឬនឹងថ្វាយបង្គំ ឬធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ អំពើនោះ របស់ជនទាំងនោះ នឹងនាំមកនូវប្រយោជន៍ និងសេចក្តីសុខ អស់កាលយូរ ។

<u>អដ្ឋកថា</u> ពន្យល់ថា ៖

បទថា អព្យាវដា (កុំខ្វល់ខ្វាយ) បានដល់ កុំពាក់ព័ន្ធ កុំរវីរវល់ ។ បទថា ឃដេថ ឃដថ (ចូរខំប្រឹងប្រែងក្នុង

ប្រយោជន៍របស់ខ្លួនចុះ) បានដល់ ព្យាយាមក្នុងព្រះអរហត្ត ដែលជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុត ។ បទថា អនុយុញ្ជថ (ចូរខ្មីឃ្មាតសង្វាត) បានដល់ ចូរប្រកបរឿយៗ ដើម្បីសម្រេចអរហត្តនោះ ។ បទថា អប្បមត្តា (កុំប្រមាទ) បានដល់ មិននៅប្រាសចាកសតិ ។ ឈ្មោះថា **អ្នកមានព្យាយាម** ព្រោះប្រកបដោយធម៌ដែលជាគ្រឿងដុតកិលេស គឺសេចក្ដីព្យាយាម ឈ្មោះថា មានខ្លួនបញ្ជូនទៅ គឺមានចិត្តបញ្ជូនទៅ ព្រោះជាអ្នកមិនមានអាល័យក្នុងកាយនិងជីវិត។ ដោយបទថា កថំ បន ភន្តេ (បពិត្រព្រះអង្គដ៏ចម្រើន ចុះដូចម្ដេច) ព្រះអានន្ទទូលសួរថា ជនទាំងនេះ មានខត្តិយបណ្ឌិតជាដើម នឹងគប្បីបដិបត្តិយ៉ាងណា គេនឹងសាកសួរខ្ញុំព្រះអង្គដោយពិតថា លោកម្ចាស់អានន្ទ យើងខ្ញុំនឹងបដិបត្តិក្នុងសរីរៈរបស់ព្រះតថាគតយ៉ាងណា ខ្ញុំព្រះអង្គគប្បីឆ្លើយប្រាប់ពួកគេយ៉ាងណា ។

## ៤២_ថូបារហបុគ្គល ៤ ពួក

ម្នាលអានន្ទ *ថូបារហបុគ្គល* (បុគ្គលដែលគួរដល់ស្តូប) នេះមាន ៤ ពួក ។ ថូបារហបុគ្គល ៤ ពួក តើដូចម្ដេចខ្លះ ។ គឺ

ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាថូបារហបុគ្គល ១ ព្រះបច្ចេក-ពុទ្ធ ជាថូបារហបុគ្គល ១ សាវ័ករបស់ព្រះតថាគត ជាថូបារហ-បុគ្គល ១ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ១ ។

ម្នាលអានន្ទ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ជាថូបារហ-បុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ លុះបែកធ្លាយរាង កាយទៅខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិឋានសួគ៌ ម្នាលអានន្ទ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលអានន្ទ ព្រះបច្ចេកសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះបច្ចេកពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ ព្រះ

បច្ចេកសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលអានន្ទ សាវ័ករបស់តថាគត ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបនៃសាវ័ករបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិឋានសួគ៌ ម្នាលអានន្ទ សាវ័ករបស់ព្រះតថាគត ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលអានន្ទ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះធម្មរាជ ដែលទ្រង់ធម៌នោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ

ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។

ម្នាលអានន្ទ ថូបារហបុគ្គលមាន ៤ ពួកនេះឯង ។

<u>អដ្ឋកថា</u> ពន្យល់ថា ៖

សួរថា ក្នុងពាក្យថា **ព្រះចក្រពត្តិរាជ** ហេតុអ្វី ទើបព្រះមានព្រះភាគ អនុញ្ញាតការសាងសថូបដល់ព្រះរាជាដែលនៅគ្រប់គ្រងផ្ទះ សោយទីវង្គតហើយ ទ្រង់មិនអនុញ្ញាតសម្រាប់ភិក្ខុដែលមានសីល ? ឆ្លើយថា ព្រោះមិនគួរអស្ចារ្យ ។ ពិតមែន កាលទ្រង់អនុញ្ញាតសថូបសម្រាប់ភិក្ខុបុថុជ្ជន ក៏មិនមានឱកាសសម្រាប់សថូបទាំងឡាយក្នុងកោះសីហឡ: ក្នុងទីដទៃៗក៏ដូចគ្នា ព្រោះដូច្នោះ សថូបនោះ មិនគួរអស្ចារ្យ ព្រោះហេតុនោះ ទើបទ្រង់មិនអនុញ្ញាត ។ ស្ដេចចក្រពត្តិកើតតែមួយព្រះអង្គប៉ុណ្ណោះ ដោយហេតុនោះ សថូបរបស់ព្រះអង្គទើបអស្ចារ្យ ។ ចំណែកសម្រាប់ភិក្ខុបុថុជ្ជនអ្នកមានសីល នឹងធ្វើសក្ការៈសូម្បីយ៉ាងធំ ដូចជាភិក្ខុដែលបរិនិព្វានក៏គួរដូចគ្នា ។

## ទ្រង់ត្រាស់ឲ្យហៅព្រះអានន្ទ

គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅកាន់វិហារ ក៏តោង នូវឈើមានសណ្ឋានដូចក្បាលស្វា (ត្រដោកទ្វារ) ឈរយំរៀបរាប់ថា ឱអាត្មាអញ ជាសេក្ខបុគ្គល មានកិច្ចគួរធ្វើតទៅទៀតនៅឡើយ ក៏ព្រះសាស្តារបស់អាត្មាអញ ដែលជាអ្នកអនុគ្រោះដល់អាត្មាអញ នឹងទ្រង់បរិនិព្វាន ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទទៅណា ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមានអាយុ ចូលទៅកាន់រោងសម្រាប់សម្រាកកាយ តោងត្រដោកទ្វារ ឈរយំរៀបរាប់ឯងណោះថា "ឱអាត្មាអញ នៅជាសេក្ខបុគ្គលមានកិច្ចគួរធ្វើតទៅទៀតនៅឡើយ ក៏ព្រះសាស្តារបស់អាត្មាអញ ដែលជាអ្នកអនុគ្រោះដល់អាត្មាអញ នឹងទ្រង់បរិនិព្វាន" ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ អ្នកចូរទៅហៅអានន្ទ តាមពាក្យតថាគតថា ម្នាលអាវុសោអានន្ទ ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅអ្នក ។ ភិក្ខុនោះទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយ

ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុ ដូច្នេះថា "ម្នាលអាវុសោអានន្ទ ព្រះសាស្តា ទ្រង់ត្រាស់ឲ្យហៅអ្នក" ។ ព្រះអានន្ទមានអាយុ ទទួលពាក្យរបស់ភិក្ខុនោះថា "អើអាវុសោ" ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា "ម្នាលអានន្ទ ណ្ហើយអ្នកកុំសោយសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ តថាគតបានប្រាប់អ្នកជាមុនហើយ យ៉ាងនេះថា សេចក្តីព្រាត់ប្រាស វិនាស ប្រែប្រួល ចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីមិនព្រាត់ប្រាសនោះក្នុង (ខន្ធប្បវត្តិ) នេះ មកអំពីណា ធម្មជាតិណាដែលកើតហើយ ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មានសេចក្តីទ្រុឌ-ទ្រោមទៅជាធម្មតា ធម្មជាតនោះ បុគ្គលនឹងពោលយាត់ថា កុំទ្រុឌទ្រោមទៅដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះ មិនមានឡើយ

ម្នាលអានន្ទ ខ្លួនអ្នកបានបម្រើតថាគត មកជាយូរអង្វែងហើយ ដោយកាយកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍ និងសេចក្ដីសុខ មិនមានចំណែកពីរ ជាកម្មប្រមាណមិនបាន ដោយវចីកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍ និងសេចក្ដីសុខ មិនមានចំណែកពីរ ជាកម្មប្រមាណមិនបាន ដោយមនោកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍ និងសេចក្ដីសុខ មិនមានចំណែកពីរ ជាកម្មប្រមាណមិនបាន ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរប្រកបព្យាយាមឲ្យរឿយៗចុះ នឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់" ។

ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធដែលមានក្នុងអតីតកាល ពួកភិក្ខុជាឧបដ្ឋាករបស់ព្រះមានព្រះភាគទាំងនោះ មានកំណត់ដូច្នេះឯង ដូចអានន្ទរបស់តថាគតដែរ, ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងមានមកក្នុងអនាគតកាល ពួកភិក្ខុជាឧបដ្ឋាករបស់ព្រះមានព្រះភាគទាំងនោះ មានកំណត់ដូច្នេះឯង ដូច

អានន្ទរបស់តថាគតដែរ, ម្នាលភិក្ខុទាំងឡាយ អានន្ទ ជាបណ្ឌិត តែងដឹងដូច្នេះថា “កាលនេះ ជាកាលគួរនឹងចូលទៅគាល់ព្រះតថាគត កាលនេះ ជាកាលគួររបស់ពួកភិក្ខុ កាលនេះ ជាកាលគួររបស់ពួកភិក្ខុនី កាលនេះ ជាកាលគួររបស់ពួកឧបាសក កាលនេះ ជាកាលគួររបស់ពួកឧបាសិកា កាលនេះ ជាកាលគួររបស់ព្រះរាជា និងរាជមហាមាត្រ កាលនេះ ជាកាលគួររបស់ពួកតិរ្ថិយ កាលនេះ ជាកាលគួររបស់ពួកតិត្ថិយសាវក ។

## ៤៣_អច្ឆរិយព្ភូតធម៌មាននៅក្នុងព្រះអានន្ទ

ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ (ធម៌អស្ចារ្យចម្លែក) ទាំងឡាយ ៤ យ៉ាងនេះ មាននៅក្នុងអានន្ទ ។ ធម៌ទាំង ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុបរិស័ទនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិស័ទនោះ ក៏មានសេចក្តីត្រេកអរ ដោយភាសិតនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិស័ទ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ,

ភិក្ខុនីបរិស័ទ... ឧបាសកបរិស័ទ... ឧបាសិកាបរិស័ទ... ។

ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ទាំងឡាយ ៤ យ៉ាង នេះឯង មាននៅក្នុងអានន្ទ ។ល។

អដ្ឋកថា ពន្យល់ថា ៖

ពាក្យថា **បើភិក្ខុបរិស័ទចូលទៅដើម្បីជួបនឹងអានន្ទ** សេចក្ដីថា ជនពួកណា ប្រាថ្នានឹងគាល់ព្រះមានព្រះភាគ ចូលទៅរកព្រះថេរៈ និងជនពួកណាមក បានឮគុណរបស់ព្រះថេរៈថា បានឮថា ព្រះអានន្ទគួរជ្រះថ្លាសព្វទីកន្លែង ល្អគួរសរសើរ ជាពហុស្សូត អ្នកល្អក្នុងសង្ឃ លោកសំដៅយកជនទាំងនោះ ទើបពោលថា ភិក្ខុបរិស័ទចូលទៅជួបព្រះអានន្ទ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា អត្តមនា (ចិត្តរបស់ខ្លួន) ឈ្មោះថា មានចិត្តជារបស់ខ្លួន គឺមានចិត្តត្រេកអរ ព្រោះឃើញ សមដោយការស្ដាប់មក ។ បទថា ធម្មំ (ធម៌) បានដល់ ធម៌គឺបដិសណ្ឋារបែបនេះថា អ្នកមានអាយុ ល្មមអត់ធន់បានទេឬ ល្មមប្រព្រឹត្តទៅបានទេឬ លោកចូរធ្វើកិច្ចក្នុងយោនិសោមនសិការ ចូរបំពេញ

អាចរិយវត្តនិងឧបជ្ឈាយវត្ត ។ ក្នុងធម៌គឺបដិសណ្ឋារនោះ មានការធ្វើផ្សេងគ្នាក្នុងភិក្ខុនីទាំងឡាយ ដូច្នេះថា ភិក្ខុនីទាំងឡាយ ៤ ពួក លោកសមាទានប្រព្រឹត្តគរុធម៌ ៨ ខ្លះទេឬ ។ កាលឧបាសកទាំងឡាយមកមិនធ្វើបដិសណ្ឋារយ៉ាងនេះថា "លោកមិនឈឺ ឈឺចុកចាប់សិរ ឬអវយវៈខ្លះទេឬ បុត្រនិងបងប្អូនរបស់អ្នក មិនមានរោគទេឬ" ។ តែនឹងធ្វើបដិសណ្ឋារយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយ សរណៈ ៣ ជាយ៉ាងណា លោករក្សាសីល ៥ រក្សាឧបោសថសីល មួយខែ ៨ ដង ចូរធ្វើវត្តគឺការទំនុកបម្រុងមាតាបិតា ចូរបដិបត្តិសមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ។ ក្នុងឧបាសិកាទាំងឡាយ ក៏ន័យនេះដូចគ្នា ។

## ៤៤-រាជធានីឈ្មោះកុសាវតី

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ កុំបរិនិព្វាន (ក្នុងនគរកុសិនរា) ជានគរតូច ជានគរទួល ជាសាខានគរនេះឡើយ បពិត្រព្រះអង្គដ៏

ចម្រើន មានមហានគរដទៃ គឺនគរចម្បា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី ពារាណសី សូមព្រះមានព្រះភាគ បរិនិព្វានក្នុងនគរទាំងនុ៎ះ ខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតីមហា-សាល ជាច្រើនក្នុងនគរទាំងនោះ មានសេចក្ដីជ្រះថ្លាក្នុងព្រះ-តថាគត គេនឹងធ្វើការបូជា ព្រះសរីរៈព្រះតថាគត ។ ម្នាលអានន្ទ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំនិយាយថា នគរ-កុសិនារានេះ ជានគរតូច ជានគរទួល ជាសាខានគរយ៉ាងនេះឡើយ ម្នាលអានន្ទ កាលពីដើមមានព្រះចក្រពត្តិរាជ ព្រះនាមមហាសុទស្សនៈ ជាធម្មរាជ ទ្រង់ធម៌ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានជនបទមាំមួន ប្រកបដោយរតនៈទាំង ៧ ប្រការ ម្នាលអានន្ទ ទីក្រុងកុសិនារានេះ ជារាជធានីឈ្មោះកុសាវតីរបស់ព្រះមហាសុទស្សនរាជ មានបណ្ដោយ ១២ យោជន៍ អំពីទិសខាងកើតទៅទិសខាងលិច មានទទឹង ៧ យោជន៍ អំអីទិសខាងជើងទៅទិសខាងត្បូង ម្នាលអានន្ទ កុសាវតីរាជធានីជាក្រុងស្ដុកស្ដម្ភ សម្បូណ៌ ពោរពាស (ដោយទំនិញ) មានជនច្រើន មានមនុស្សដេរដាស ទាំងបរិបូរណ៍ដោយភិក្ខាហារ ម្នាល

អានន្ទ រាជធានីឈ្មោះអាឡកមន្ទា របស់ពួកទេវតាជារាជធានីស្តុកស្តម្ភ សម្បូណ៌ពោរពាស មានជនច្រើន មានយក្ខ ដេរដាស ទាំងបរិបូរណ៍ ដោយកិក្ខាហារយ៉ាងណាមិញ ម្នាលអានន្ទ កុសាវតី រាជធានី ក៏ជាក្រុងស្តុកស្តម្ភ សម្បូណ៌ពោរពាស (ដោយទំនិញ) មានជនច្រើន មានមនុស្សដេរដាស ទាំងបរិបូរណ៍ដោយកិក្ខាហារ យ៉ាងនោះដែរ ម្នាលអានន្ទ កុសាវតីរាជធានី មិនដែលស្ងាត់ ដោយសូរសំឡេង ១០ យ៉ាង ទាំងថ្ងៃទាំងយប់ គឺសូរសំឡេងដំរី សូរសំឡេងសេះ សូរសំឡេងរថ សូរសំឡេងស្គរ សូរសំឡេង សំភោរ សូរសំឡេងពិណ សូរសំឡេងចម្រៀង សូរសំឡេងរគាំង សូរសំឡេងរនោត និងសូរសំឡេងជាគម្រប់ ១០ ថា អ្នកទាំង ឡាយចូរស៊ី ចូរផឹក ចូរទំពា ។

<u>អដ្ឋកថា</u> : បណ្តាមហាសាលទាំងនោះ ដែលឈ្មោះថា **ខត្តិយមហាសាល** បានដល់ ពួកក្សត្រិយ៍ដែលរក្សាទ្រព្យទុក រាប់រយកោដិខ្ទះ រាប់ពាន់កោដិខ្ទះ ចំណាយកហាបណៈប្រចាំថ្ងៃ ចេញទៅមួយថ្ងៃ ១ រទេះ ល្ងាចកហាបណៈទទួលចូលមួយថ្ងៃ ២ រទេះ ។ ដែលឈ្មោះថា **ព្រាហ្មណមហាសាល** បានដល់ ពួក

ព្រាហ្មណ៍ដែលរក្សាទ្រព្យទុក ៨០ កោដិ ចាយវាយកហាបណៈ ទៅមួយថ្ងៃ ១ កុម្ភៈ ល្ងាចទទួលចូលមួយថ្ងៃ ១ រទេះ ។ ដែលឈ្មោះថា **គហបតីមហាសាល** បានដល់ ពួកគហបតីដែលរក្សាទ្រព្យសម្បត្តិទុក ៤០ កោដិ ចាយវាយកហាបណៈប្រចាំថ្ងៃមួយៗ ៥ អម្ពណៈ ល្ងាចទទួលចូលមួយថ្ងៃ ១ កុម្ភៈ ។

បទថា មា ហេវំ អានន្ទ អវច (ម្នាលអានន្ទ អ្នកកុំនិយាយ) បានដល់ អានន្ទអ្នកកុំនិយាយយ៉ាងនោះ ។ ព្រះមានព្រះភាគ ត្រាស់ថា លោកមិនគួរនិយាយថា នេះនគរតូច សេចក្ដីពិត តថាគតមកកាន់នគរនេះ ដោយសេចក្ដីឧស្សាហ៍ដ៏ធំ ដោយសេចក្ដីតស៊ូព្យាយាមយ៉ាងខ្លាំងក្លា ឈរ អង្គុយច្រើនដង ក៏ដើម្បីនឹងពោលដល់សម្បត្តិរបស់នគរនេះដោយពិត ហើយទើបត្រាស់ថា **ភូតបុព្វំ** ជាដើម ។

## ៤៥. ការថ្វាយដំណឹងដល់ពួកមល្លក្សត្រ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៀតថា ៖

ម្នាលអានន្ទ អ្នកចូរទៅក្នុងក្រុងកុសិនារា ហើយថ្វាយដំណឹងដល់មល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះតថាគតនឹងបរិនិព្វាន បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ កុំឲ្យមានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះតថាគតទ្រង់បរិនិព្វាន ក្នុងគាមក្ខេត្តរបស់យើងទាំងឡាយហើយ យើងទាំងឡាយមិនបានឃើញព្រះតថាគត ក្នុងកាលជាទីបំផុតដូច្នេះឡើយ ។ ព្រះអានន្ទ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះកុណាព្រះអង្គ ហើយក៏ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ មិនមានភិក្ខុជាគម្រប់ពីរ ចូលទៅក្នុងក្រុងកុសិនារា ។ សម័យនោះឯង ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារា កំពុងប្រជុំគ្នាក្នុងសណ្ឋាគារដ្ឋាន (សាលាសម្រាប់បង្រៀនវិជ្ជាក្នុងរាជត្រកូល) ដោយកិច្ចនីមួយ ។ ព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់សណ្ឋាគារដ្ឋាន

របស់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ទើបថ្វាយដំណឹងដល់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារាថា "បពិត្រវាសិដ្ឋគោត្រទាំងឡាយ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះតថាគតនឹងបរិនិព្វាន ។ល។ យើងទាំងឡាយមិនបានឃើញព្រះតថាគត ក្នុងកាលជាទីបំផុត ដូច្នេះឡើយ" ។ ពួកមល្លក្សត្រ និងពួកបុត្ររបស់មល្លក្សត្រ និងសុណិសារបស់មល្លក្សត្រ និងភរិយារបស់មល្លក្សត្រ លុះឮពាក្យនេះ របស់ព្រះ-អានន្ទមានអាយុហើយ ក៏កើតទុក្ខតូចព្រះទ័យ ពោរពេញដោយសេចក្តីទុក្ខក្នុងព្រះទ័យ ខ្លះក៏រំសាយកេសាកន្ទក់កន្ទេញ ផ្គងកំភួន-ដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះបម្រះននៀលទៅមក ដូចជាមានជើងដាច់ហើយថា "ព្រះមានព្រះភាគ នឹងបរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក នឹងបាត់ទៅឆាប់ពេកណាស់" ។

លំដាប់នោះ ពួកមល្លក្សត្រ និងពួកបុត្ររបស់មល្លក្សត្រ និងសុណិសារបស់មល្លក្សត្រ និងភរិយារបស់មល្លក្សត្រ កើតទុក្ខតូចព្រះទ័យ ពោរពេញដោយសេចក្តីទុក្ខក្នុងព្រះទ័យ ក៏នាំគ្នាចូល

ទៅរកព្រះអានន្ទមានអាយុ ក្នុងសាលរវែនរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុង ។

លំដាប់នោះ ព្រះអានន្ទមានអាយុ ក៏ឲ្យពួកមល្លក្សត្រ ថ្វាយបង្គំព្រះមានព្រះភាគ តាមវង្សនៃត្រកូលៗ ក្នុងបឋមយាម ។

## ៤៦_រឿងសុភទ្ទបរិព្វាជក

សម័យនោះឯង មានបរិព្វាជកឈ្មោះសុភទ្ទ នៅក្នុងក្រុងកុសិនារា សុភទ្ទបរិព្វាជក បានឮដំណឹងថា ព្រះសមណគោតមនឹងបរិនិព្វានក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ។ គ្រានោះ សុភទ្ទ-បរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យនេះ អាត្មាអញបានឮមក អំពីពួកបរិព្វាជក ជាមនុស្សចាស់ទុំ ជាអាចារ្យតៗ គ្នាមកតែងនិយាយថា ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយដងមួយកាល ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតម នឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះ កើតឡើងដល់អាត្មាអញ ទាំងអាត្មាអញក៏មានសេចក្តីជ្រះថ្លាក្នុងព្រះសមណគោតមដែរ អាត្មាអញគួរលះបង់នូវសេចក្តីសង្ស័យ

នេះបានយ៉ាងណា ព្រះសមណគោតម អាចនឹងសម្តែងធម៌ដល់អាត្មាអញយ៉ាងនោះបាន ។

គ្រានោះ សុភទ្ទបរិព្វាជក ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅទាំងដល់ហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុ អំពីអ្វីដែលខ្លួនបានឮមក និងសេចក្តីប្រាថ្នារបស់ខ្លួន ជាគម្រប់ពីរដងបីដង តែត្រូវព្រះអានន្ទ មានអាយុ និយាយហាមឃាត់ថា "ម្នាលអាវុសោសុភទ្ទ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគទ្រង់លំបាកព្រះអង្គណាស់" ។ ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់កថាសល្លាបៈនេះ របស់ព្រះអានន្ទមានអាយុ ជាមួយនឹងសុភទ្ទបរិព្វាជក ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ កុំឡើយ អ្នកកុំឃាត់សុភទ្ទ ម្នាលអានន្ទ សុភទ្ទចូរបានឃើញតថាគតចុះ សុភទ្ទនឹងសួរនូវសេចក្តីណាមួយនឹងតថាគត គាត់ចង់ដឹងនូវសេចក្តីនោះមែន ទើបគាត់មកសួរតថាគត មិនមែនគាត់សួរចង់បៀតបៀនទេ បើសុភទ្ទនេះសួរហើយ តថាគតសម្តែងធម៌ណា គាត់នឹងបានដឹងធម៌នោះឆាប់ភ្លាម ។

គ្រានោះសុភទ្ទបរិព្វាជក ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាដើមហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ សុភទ្ទបរិព្វាជក ក៏បានសាកសួរព្រះតថាគត ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសុភទ្ទ ណ្ហើយចុះ ពាក្យដែលអ្នកនិយាយថា ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹងដូចជាពាក្យប្តេជ្ញារបស់ខ្លួនមែន ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ ដូច្នេះនេះ ចូរលើកទុកសិនចុះ ម្នាលសុភទ្ទ តថាគតនឹងសម្តែងធម៌ដល់អ្នក អ្នកចូរស្តាប់ធម៌នោះ ចូរតាំងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ សុភទ្ទបរិព្វាជក ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលសុភទ្ទ អរិយមគ្គមានអង្គ ៨ មិនមានក្នុងធម្មវិន័យណា សមណៈទី ១ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ២ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៣ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក្តី មិនមានក្នុងធម្មវិន័យនោះដែរ, ម្នាលសុភទ្ទ លុះតែអរិយមគ្គប្រកបដោយអង្គ ៨ មានក្នុងធម្មវិន័យណា សមណៈ (ទី) ១ ក្តី ទើបមានក្នុងធម្មវិន័យនោះ

សមណៈ (ទី) ២ ក្តី មានក្នុងធម្មវិន័យនោះ សមណៈ (ទី) ៣ ក្តី មានក្នុងធម្មវិន័យនោះ សមណៈ (ទី) ៤ ក្តី ក៏មានក្នុងធម្មវិន័យនោះដែរ, ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈ (ទី) ១ ក៏មានតែក្នុងសាសនានេះ ។ល។ សមណៈ (ទី) ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ(វាទៈនៃគ្រូដទៃ) អំពីសំណាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបានសូន្យចាកពួកអរហន្តឡើយ ។

ម្នាលសុភទ្ទ កាលតថាគតមានវ័យ ២៩ ឆ្នាំ បានបួសហើយ ជាអ្នកស្វែងរកនូវកុសល (សព្វញ្ញុតញ្ញាណ) ម្នាលសុភទ្ទ កាលណាបើតថាគតបួសបានជាង ៥០ ឆ្នាំហើយ ញ៉ាំងប្រទេសគឺវិបស្សនាមគ្គ ឲ្យប្រព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹងគឺអរិយមគ្គ ព្រោះហេតុនោះ សមណៈ (ទី) ១ ខាងក្រៅអំពីសាសនានៃតថាគតនេះមិនមានឡើយ ។

*សមណៈទី ២ ក្តី មិនមាន សមណៈទី ៣ ក្តី មិនមាន សមណៈទី ៤ ក្តី ក៏មិនមានដែរ បរប្បវាទអំពីសំណាក់នៃបុគ្គលដទៃ រមែងសូន្យបាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបានសូន្យបាកពួកអរហន្តឡើយ ។*

*លុះព្រះមានព្រះភាគ មានព្រះពុទ្ធតម្រាស់យ៉ាងនេះហើយ សុភទ្ទបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ ។ល។ សុភទ្ទបរិព្វាជក ក៏សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ និងសូមបព្វជ្ជា និងឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ សុភទ្ទបរិព្វាជក ឧបសម្បទារួចភ្លាម ក៏ចេញទៅតែម្នាក់ឯង មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ក៏បានសម្រេចជាព្រះអរហន្ត ។ ជាបច្ឆិមសក្ខិសាវ័ក ។*

*<u>អដ្ឋកថា</u> : ព្រះមានព្រះភាគ ស្តេចមកដោយព្រះពុទ្ធប្រាថ្នាថា នឹងទ្រង់សម្តែងធម៌ប្រោសពួកស្តេចមល្លក្សត្រ ពេល*

បឋមយាម សម្តែងធម៌ប្រោសសុភទ្ទៈ ពេលមជ្ឈិមយាម ទូន្មានភិក្ខុសង្ឃ ពេលបច្ឆិមយាម ស្តេចបរិនិព្វានក្នុងវេលាជិតភ្លឺ ។

បទថា សមណោបិ តត្ថ ន ឧបលព្ភតិ (សមណៈមិនមានក្នុងធម្មវិន័យនោះ) សេចក្តីថា ក្នុងធម្មវិន័យនោះ មិនមានសូម្បីសមណៈទី ១ គឺព្រះសោតាបន្ន សូម្បីសមណៈទី ២ គឺព្រះសកទាគាមី សូម្បីសមណៈទី ៣ គឺព្រះអនាគាមី សូម្បីសមណៈទី ៤ គឺព្រះអរហន្ត ក៏មិនមានក្នុងធម៌វិន័យនោះ ។ ព្រះមានព្រះភាគត្រាស់ដោយមិនកំណត់ទេសនាខាងដើម ឥឡូវនេះ កាលទ្រង់កំណត់សាសនារបស់ព្រះអង្គ ទើបត្រាស់ថា ឥមស្មឹំ ខោ (មានតែក្នុងធម្មវិន័យនេះឯង) ជាដើម ។ បទថា សុញ្ញា បរប្បវាទា សមណេភិ (វាទៈនៃគ្រូដទៃ រមែងសូន្យចាកពួកសមណៈ) សេចក្តីថា វាទៈរបស់មេលទ្ធិដទៃ សូន្យទទេចាកអំពីសមណៈ ១២ ពួក គឺអ្នកផ្តើមវិបស្សនាដើម្បីប្រយោជន៍ដល់មគ្គ ៤ រួមជា ៤ ពួក អ្នកតាំងនៅក្នុងមគ្គ រួមជា ៤ ពួក អ្នកតាំងនៅក្នុងផល ៤ ។ បទថា ឥមេ ច សុភទ្ទ ភិក្ខូ (ម្នាលសុភទ្ទ មួយទៀត ភិក្ខុ

ទាំងនេះ) សេចក្តីថា ភិក្ខុទាំង ១២ ពួកនេះ ។ ក្នុងពាក្យថា សុញ្ញា វិហារេយ្យុំ (គប្បីនៅដោយប្រពៃ) ព្រះសោតាបន្ន ប្រាប់ឋានៈដែលខ្លួនសម្រេចដល់អ្នកដទៃនោះ ឲ្យជាសោតាបន្ន ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងព្រះសកទាគាមីជាដើម ក៏ន័យនេះ ។ ភិក្ខុតាំងនៅក្នុងសោតាបត្តិមគ្គ ធ្វើសូម្បីអ្នកដទៃឲ្យជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ក៏ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងភិក្ខុតាំងនៅក្នុងមគ្គដ៏សេសក៏ន័យនេះ ។ ភិក្ខុផ្តើមវិបស្សនា ដើម្បីសោតាបត្តិមគ្គ កំណត់កម្មដ្ឋានដែលខ្លួនស្ទាត់ជំនាញ ធ្វើសូម្បីអ្នកដទៃឲ្យជាអ្នកផ្តើមវិបស្សនាដើម្បីសោតាបត្តិមគ្គ ក៏ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងភិក្ខុផ្តើមវិបស្សនាដើម្បីមគ្គដ៏សេសក៏ន័យនេះ ។ ទ្រង់សំដៅយកសេចក្តីនេះ ទើបត្រាស់ថា សុញ្ញា វិហារេយ្យុំ ។ ពាក្យថា **លោកនឹងមិនបានសូន្យចាកពួកអរហន្តឡើយ** សេចក្តីថា គប្បីមិនសាបសូន្យ ដូចជាព្រៃឈើបបុស ព្រៃឈើបន្ទា ។

បទថា សមណោបិ ឥត្ថិ (សមណៈមិនមានឡើយ) គឺ សូម្បីសមណៈអ្នកបំពេញវិបស្សនា អ្នកនៅក្នុងផ្លូវនៃវិបស្សនា

មិនមាន លោកអធិប្បាយថា សមណៈទី ១ សូម្បីដែលជាសោតាបន្ន មិនមាន ។

ពាក្យថា **បានហើយ** គឺបានហើយយ៉ាងណា ។ បានឮថា ព្រះថេរៈនាំសុភទ្ទៈនោះ ទៅក្នុងទីកន្លែងមួយយកទឹកអំពីគណ្ឌិស្រោចសិរ ប្រាប់តចបញ្ចកកម្មដ្ឋាន កោរសក់និងពុកមាត់ ឲ្យគ្រងសំពត់កាសាយៈហើយ ឲ្យសរណៈហើយ នាំទៅកាន់សំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ឲ្យឧបសម្បទាហើយ ត្រាស់ប្រាប់កម្មដ្ឋាន ។ លោកទទួលកម្មដ្ឋានទុកហើយ អធិដ្ឋានទីចង្ក្រមក្នុងចំណែកមួយនៃឧទ្យាន ប្រារព្ធព្យាយាមជម្រះវិបស្សនាសម្រេចអរហត្តព្រមដោយបដិសម្ភិទាហើយ មកថ្វាយបង្គំព្រះ-មានព្រះភាគ អង្គុយចុះ ។ លោកសំដៅយកឧបសម្បទាកម្មនោះ ទើបពោលថា អលត្ថ ឧបសម្បទំ បេ (លុះឧបសម្បទារួចភ្លាម) ជាដើម ។ ក៏ព្រះសុភទ្ទៈនោះ បានជាបច្ឆិមសក្ខីសាវករបស់ព្រះមានព្រះភាគនោះឯង ។

## ៤៧~ទ្រង់ប្រទានព្រះឱវាទដល់ភិក្ខុសង្ឃ

*គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រដៅដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើងឈ្មោះថា មិនមានឡើយ ម្នាលអានន្ទ សេចក្តីនេះអ្នកកុំចូលចិត្តយ៉ាងនេះឡើយ ៖*

យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច

ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។

*ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយដល់អ្នកទាំងឡាយ លុះអំណើះតអំពីតថាគតទៅ ធម៌និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ។*

*ម្នាលអានន្ទ ក៏ក្នុងកាលសព្វថ្ងៃនេះ ពួកភិក្ខុហៅគ្នានឹងគ្នា ដោយពាក្យថា អាវុសោ អំណើះតពីតថាគតទៅ អ្នកទាំងឡាយកុំហៅយ៉ាងនេះទៀតឡើយ ម្នាលអានន្ទ ភិក្ខុចាស់ជាង ត្រូវហៅភិក្ខុខ្ចីជាង ដោយនាមក៏បាន ដោយគោត្រក៏បាន ដោយពាក្យថា* **អាវុសោ** *ក៏បាន ចំណែកភិក្ខុខ្ចីជាង ត្រូវហៅភិក្ខុចាស់ជាងថា* **ភន្តេ**

ក៏បានថា **អាយស្មា** ក៏បាន, ម្នាលអានន្ទ លុះអំណើះតអំពីតថាគតទៅ បើសង្ឃមានប្រាថ្នានឹងដកសិក្ខាបទ ចូរដកសិក្ខាបទដែលតូចនិងតូចដោយលំដាប់ចុះ, ម្នាលអានន្ទ តអំពីតថាគតទៅ សង្ឃត្រូវដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុផងចុះ ។ ព្រះអានន្ទ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មទណ្ឌតើដូចម្តេច ។ ព្រះ-អង្គ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ឆន្នភិក្ខុ ចង់ពោលនូវពាក្យណា ពោលនូវពាក្យនោះចុះ ប៉ុន្តែពួកភិក្ខុ មិនត្រូវនិយាយ មិនត្រូវទូន្មាន មិនត្រូវប្រដៅឆន្នភិក្ខុនោះឡើយ ។

<u>អដ្ឋកថា</u> ពន្យល់ថា : ឥឡូវនេះ ដើម្បីសម្តែងការប្រទានព្រះឱវាទដល់ភិក្ខុសង្ឃ ដែលទ្រង់ផ្តើមទុកនោះ ទើបពោលពាក្យថា អថ ខោ ភគវា (គ្រានោះ ព្រះមានព្រះភាគ) ជាដើម ។ បណ្តាបទទាំងនោះ បទថា ទេសិតោ បញ្ញត្តោ (សម្តែងហើយ បញ្ញត្តហើយ) សេចក្តីថា ទាំងធម៌ក៏ទ្រង់សម្តែងហើយ បញ្ញត្តហើយ ទាំងវិន័យក៏ទ្រង់សម្តែងហើយ បញ្ញត្តហើយ ។ អធិប្បាយថា ឈ្មោះថា **ទ្រង់បញ្ញត្ត** បានដល់ ទ្រង់តែងតាំងហើយ ។ បទថា

សោ វោ មមច្ចយេន បានដល់ ធម៌និងវិន័យនោះ នឹងជាសាស្ដារបស់លោកទាំងឡាយ ដោយអំណើះតពីតថាគតទៅ ។

មែនពិត តថាគតគង់ព្រះជន្មនៅឡើយនេះឯង សម្ដែងឧភតោវិភង្គវិន័យ ព្រមទាំងខន្ធកបរិវារ ដល់អ្នកទាំងឡាយ ក្នុងវត្ថុដែលបាត់ទុកដោយអំណាចកងអាបត្តិទាំង ៧ កង ថា នេះអាបត្តិស្រាល នេះអាបត្តិធ្ងន់ នេះអាបត្តិដែលកែខៃបាន នេះអាបត្តិដែលកែខៃមិនបាន នេះអាបត្តិដែលជាលោកវជ្ជៈ នេះជាបណ្ណត្តិវជ្ជៈ នេះអាបត្តិចេញបានក្នុងសំណាក់បុគ្គល នេះអាបត្តិចេញបានក្នុងសំណាក់គណៈ នេះអាបត្តិចេញបានក្នុងសំណាក់សង្ឃ ។ វិន័យ-បិដក សូម្បីទាំងអស់នោះ កាលតថាគតបរិនិព្វានហើយនឹងធ្វើកិច្ចនៃសាស្ដារបស់អ្នកទាំងឡាយឲ្យសម្រេច ។ មួយទៀត តថាគតគង់ព្រះជន្មនៅឡើយនេះឯង ក៏ចែកចំណែកធម៌ទាំងនេះ សម្ដែងសុត្តន្តបិដក ដោយអាការនោះថា ទាំងនេះសតិប្បដ្ឋាន ៤ សម្មប្ប-ធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ សុត្តន្តបិដកសូម្បីទាំងអស់នោះនឹងធ្វើកិច្ចនៃសាស្ដារបស់អ្នកទាំងឡាយឲ្យសម្រេច ។ មួយទៀត តថាគតឋិតនៅនេះ

៦៩ ចែកចំណែកធម៌ទាំងនេះគឺ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ សច្ចៈ ៤ ឥន្ទ្រិយ ២២ ហេតុ ៩ អាហារ ៤ ផស្សៈ ៧ វេទនា ៧ សញ្ញា ៧ សញ្ចេតនា ៧ ចិត្ត ៧ សូម្បីក្នុងចិត្តនោះ ធម៌ប៉ុណ្ណេះជាកាមាវចរ ប៉ុណ្ណេះជារូបាវចរ ប៉ុណ្ណេះជាអរូបាវចរ ប៉ុណ្ណេះជាធម៌ជាប់ទាក់ទងគ្នា ប៉ុណ្ណេះជាធម៌មិនជាប់ទាក់ទងគ្នា ប៉ុណ្ណេះជាលោកិយៈ ប៉ុណ្ណេះជាលោកុត្តរៈ ហើយសម្តែងអភិធម្មបិដក ជាសមន្តប្បដ្ឋាន ២៤ ប្រដាប់មហាបដ្ឋានអនន្តន័យ អភិធម្មបិដកសូម្បីទាំងអស់ កាលតថាគតបរិនិព្វានហើយ នឹងធ្វើកិច្ចនៃសាស្តារបស់អ្នកទាំងឡាយឲ្យសម្រេច ។

ម្យ៉ាងទៀត ព្រះពុទ្ធវចនៈនេះទាំងអស់ ដែលតថាគតភាសិតហើយ ពោលហើយ តាំងពីត្រាស់ដឹងដរាបដល់បរិនិព្វានមានច្រើនប្រភេទយ៉ាងនេះគឺ បិដក ៣ និកាយ ៥ (សាសនាមាន) អង្គ ៩ (ព្រះធម៌) ប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ ។ ព្រះធម្មក្ខន្ធប្រាំបីម៉ឺនបួនពាន់ទាំងនេះ តាំងនៅដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងហេតុជាច្រើនយ៉ាងនេះថា តថាគតនឹងបរិនិព្វានតែមួយអង្គប៉ុណ្ណោះ មួយទៀត ឥឡូវនេះ តថាគតតែ-

មួយអន្លើប៉ុណ្ណោះ ឲ្យឱវាទប្រៀនប្រដៅ កាលតថាគតបរិនិព្វាន ហើយ ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធទាំងនេះ ក៏នឹងឱវាទ ប្រៀនប្រដៅដល់អ្នកទាំងឡាយ ទ្រង់ប្រទានព្រះឱវាទថា ធម៌វិន័យ នោះនឹងជាសាស្ដារបស់អ្នកទាំងឡាយ អំណើះតអំពីតថាគតទៅ ហើយ កាលទ្រង់សម្ដែងចារិតដដែល ក្នុងអនាគតកាល ទើប ត្រាស់ថា **យថា ខោ បន** (ក៏ក្នុងកាលសព្វថ្ងៃនេះ) ជាដើម ។

## ៤៨.ពោលអំពីសិក្ខាបទតូចនិងតូច

ក្នុងបញ្ចសតិកក្ខន្ធកៈ ព្រះថេរៈទាំងឡាយពួកខ្លះ ពោល យ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ ឈ្មោះថា តូចៗ ដោយលំដាប់ ។ល។

ព្រះថេរៈទាំងឡាយពួកខ្លះ ពោលយ៉ាងនេះថា សិក្ខាបទ ទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយ ៣០ សុទ្ធិកបាចិត្តិយ ៩២ និង បាដិទេសនីយ ៤ ឈ្មោះថាតូចៗ ដោយលំដាប់ ។

គ្រានោះឯង ព្រះមហាកស្សបមានអាយុ ក៏ប្រកាសសង្ឃថា ម្នាលអាវុសោ សង្ឃចូរស្ដាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង ក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយក៏តែងដឹងថា អំពើនេះ គួរដល់លោកទាំងឡាយជាសមណ-សក្យបុត្តិយ៍ អំពើនេះ មិនគួរដល់លោកទាំងឡាយទេ ។ បើយើងទាំងឡាយនឹងដកសិក្ខាបទតូចៗ ដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយ ជាអ្នកពោលតិះដៀល នឹងពោលថា សិក្ខាបទដែលព្រះសមណគោតម បញ្ញត្តហើយដល់សាវកទាំងឡាយ បានត្រឹមតែធូមកាលិក គឺកាលនៃផ្សែងភ្លើង គឺបរិនិព្វានប៉ុណ្ណោះ ព្រះសាស្ដារបស់សាវកទាំងឡាយនេះ ឋិតនៅត្រឹមណា សាវកទាំងឡាយនេះ នាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលណាបើសាស្ដារបស់សាវកទាំងនេះ បរិនិព្វានហើយ ឥឡូវនេះ សាវកទាំងនេះក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃកុំគប្បីបញ្ញត្តថែមនូវសិក្ខាបទដែលព្រះជាគ្រូ មិនបានបញ្ញត្តទេ កុំគប្បីដកចេញនូវសិក្ខាបទដែលព្រះជាគ្រូបញ្ញត្តមកហើយ ត្រូវសមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយដែលព្រះជាគ្រូទ្រង់បញ្ញត្តហើយ ។ នេះជាញត្តិ ។ល។

# ដីកា

ក្នុងគម្ពីរសារត្ថទីបនីដីកាពោលថា <u>សួរថា</u> ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបមិនត្រាស់ដោយចំណែកមួយប៉ុណ្ណោះថា “លោកចូរដក” ទ្រង់តាំងទុកដោយពាក្យជាវិកប្បប៉ុណ្ណោះថា “សង្ឃប្រាថ្នាគប្បីដក” ដូច្នេះសោត ?

<u>ឆ្លើយថា</u> ព្រោះទ្រង់ឃើញកម្លាំងញាណរបស់ព្រះមហាកស្សបៈ មែនពិតព្រះមានព្រះភាគ ទ្រង់ឃើញថា សូម្បីកាលព្រះអង្គត្រាស់ថា “ពួកលោកចូរដក” ដូច្នេះ ព្រះមហាកស្សបៈក៏នឹងមិនដកក្នុងកាលដែលធ្វើសង្គាយនា ព្រោះហេតុនោះ ទើបទ្រង់តាំងទុកដោយពាក្យវិកប្បប៉ុណ្ណោះ ។

<u>សួរថា</u> ក៏ព្រះមានព្រះភាគ ទ្រង់ឃើញការមិនដក និងទ្រង់ប្រាថ្នាការមិនដកនោះ កាលបើដូច្នោះ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបត្រាស់ថា “សង្ឃប្រាថ្នាចូរដក” ដូច្នេះ ?

<u>ឆ្លើយថា</u> បានត្រាស់ដោយអំណាចអធ្យាស្រ័យរបស់បុគ្គលបែបនោះ ។ មែនពិត ភិក្ខុពួកខ្លះ មិនប្រាថ្នាប្រព្រឹត្ត សមាទានសិក្ខាបទតូចៗ កាលព្រះអង្គមិនត្រាស់យ៉ាងនោះ សេចក្តីបង្អៀតចង្អល់ក្នុងព្រះមានព្រះភាគ ក៏គប្បីកើតឡើងដល់ភិក្ខុទាំងនោះបាន

សេចក្ដីនោះ ក៏នឹងប្រព្រឹត្តទៅដើម្បីសេចក្ដីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលយូរដល់ភិក្ខុនោះ ។ តែកាលត្រាស់យ៉ាងនោះហើយ សេចក្ដីចង្អៀតចង្អល់ក៏នឹងមិនគប្បីកើតឡើងដល់ភិក្ខុនោះ ពួកយើងនឹងមានទោសនេះប៉ុណ្ណោះ ព្រោះបណ្ដាពួកយើងនោះឯង ភិក្ខុពួកខ្លះ ក៏មិនប្រាថ្នាការដក ។

អាចារ្យពួកខ្លះពោលថា ក៏ព្រះមានព្រះភាគ ត្រាស់យ៉ាងនោះ ដើម្បីធ្វើសេចក្ដីដែលព្រះសាសនាទាំងមូល ជាព្រះសាសនាជាប់ដោយសង្ឃ សិក្ខាបទណាមួយដែលព្រះសាស្ដា ទ្រង់បញ្ញត្តហើយ ព្រះសមណសក្យបុត្តទាំងឡាយ រមែងទទួលសិក្ខាបទនោះដោយសិរសា រមែងរក្សាទុកដូចជីវិត ។ ពិតយ៉ាងនោះ ព្រះសមណសក្យបុត្តនោះ សូម្បីកាលព្រះមានព្រះភាគត្រាស់ថា “បើសង្ឃមានប្រាថ្នាចូរដកសិក្ខាបទទាំងឡាយតូចនិងតូចបាន” ដូច្នេះ ក៏មិនដក ។ សូម្បីកាលព្រះមានព្រះភាគ ទ្រង់រំលត់ខន្ធបរិនិព្វានទៅ ក៏រក្សានៅដូចចំពោះព្រះភក្ត្រដោយពិត ព្រោះហេតុនោះ គប្បីឃើញថា ព្រះមានព្រះភាគ ត្រាស់យ៉ានោះ ដើម្បីសម្ដែងសេចក្ដីដែលពាក្យទូន្មានរបស់ព្រះសាស្ដា និងព្រះសាសនាជារបស់ដ៏ធំ ។

ពិតយ៉ាងនោះ លោកអាចារ្យ ឬសូម្បីភិក្ខុពួកដទៃក៏មិនបានសួរថា "បពិត្រលោកដ៏ចម្រើន ក៏សិក្ខាបទតូចនិងតូច សិក្ខាបទណាតូច" ព្រោះមិនមានអធ្យាស្រ័យនឹងដកនោះឯង ។ ដោយហេតុនោះឯង ព្រះធម្មសង្គាហកថេរៈទាំងឡាយពោលថា "វៀរអំពីបារាជិក ៤ ចេញ សិក្ខាបទដ៏សេស ឈ្មោះថាតូចៗ ដោយលំដាប់" ដើម្បីនឹងសម្តែងថា សិក្ខាបទទាំងពួងដែលលោកគប្បីរក្សាទុក មិនលះសូម្បីសិក្ខាបទមួយ ។ ក៏ព្រោះសេចក្តីដែលព្រះធម្មសង្គាហកថេរៈទាំងឡាយ ពោលយ៉ាងនេះ មិនបានវិនិច្ឆ័យថា "ឈ្មោះថាធម៌ទាំងនេះ ជាសិក្ខាបទតូច ជាសិក្ខាបទតូចៗ" ដូច្នេះ រមែងជាការសម្តែងថា ដែលលោកគួររក្សាទុកគ្រប់សិក្ខាបទ ។

(សារត្ថទីបនីដីកា ភាគ៣ ទំព័រ៥៣៥-៥៣៦)

## ៤៩-ទ្រង់ឱ្យភិក្ខុសាកសួរ

លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា

គប្បីមានសួម្បីដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសាកសួរ (តថាគតចុះ) កុំឲ្យអ្នកទាំងឡាយ មានសេចក្ដីក្ដៅ-ក្រហាយ ស្ដាយក្នុងកាលជាខាងក្រោយថា ព្រះសាស្ដាមាននៅចំពោះមុខនៃយើងរាល់គ្នាៗ មិនបានជាយកចិត្តទុកដាក់ដើម្បីសាកសួរ ព្រះមានព្រះភាគ ក្នុងទីចំពោះព្រះភក្ត្រសោះ ។ កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ភិក្ខុទាំងនោះក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ជាគម្រប់ពីរដង ។បេ។ ជាគម្រប់បីដង ។បេ។

ភិក្ខុទាំងនោះ ក៏នៅតែស្ងៀម ជាគម្រប់បីដង ។ល។

បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុណា ដែលមានគុណធម៌យ៉ាងទាបបំផុត ភិក្ខុនោះ គង់ជាសោតាបន្នបុគ្គលមានសភាពមិនធ្លាក់ចុះក្នុងអបាយ ជានិយតបុគ្គល មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។

## ៥០-បច្ឆិមវាចារបស់ព្រះមានព្រះភាគ

*គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា* ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ : *ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។*

អយំ តថាគតស្ស បច្ឆិមា វាចា *នេះជាបច្ឆិមវាចារបស់ព្រះតថាគត ។*

*ក្នុងអដ្ឋកថា ឈ្មោះសុមង្គលវិលាសិនី មានពន្យល់ថា*

**អប្បមាទេន សម្បាទេថា**តិ សតិអវិប្បវាសេន សព្វកិច្ចានិ សម្បាទេយ្យាថ ។

*បទថា* អប្បមាទេន សម្បាទេថ *(ចូរឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ) សេចក្តីថា ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រាសចាកសតិ ។*

ឥតិ ភគវា បរិនិព្វានមញ្ចេ និបន្នោ បញ្ចចត្តាលីស វស្សានិ ទិន្នំ ឱវាទំ សព្ពំ ឯកស្មឹ អប្បមាទបទេយេវ បក្ខិបិត្វា អទាសិ ។ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ផ្ទំលើគ្រែ បរិនិព្វាន ប្រទានព្រះឱវាទដែលប្រទានមកហើយ អស់កាល ៤៥ វស្សា រួមចុះក្នុងបទ គឺសេចក្តីមិនប្រមាទតែម៉្យាងប៉ុណ្ណោះ ។

ក៏ពាក្យនេះថា បច្ឆិមា វាចា (ជាព្រះតម្រាស់ចុងក្រោយ) ជាពាក្យរបស់ព្រះសង្គីតិកាចារ្យទាំងឡាយ ។

## ៥១_ការបរិនិព្វាននៃព្រះមានព្រះភាគ

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលកាន់បឋមជ្ឈាន ចេញអំពីបឋមជ្ឈាន ហើយចូលកាន់ទុតិយជ្ឈាន ចេញអំពីទុតិយ-ជ្ឈានហើយ ចូលកាន់តតិយជ្ឈាន ចេញអំពីតតិយជ្ឈានហើយ ចូលកាន់ចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈាន ហើយចូលកាន់អាកាសា-នញ្ចាយតនសមាបត្តិ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិ ហើយចូលកាន់វិញ្ញានញ្ចាយតនសមាបត្តិ ចេញអំពីវិញ្ញាណញ្ចា-យតនសមាបត្តិហើយ ចូលកាន់អាកិញ្ចញ្ញាយតនសមានបត្តិ ចេញ

អំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ចូលកាន់នេវសញ្ញានាសញ្ញា-យតនសមាបត្តិ ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ចូលកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញា និងវេទនា) ។

គ្រានោះ ព្រះអានន្ទមានអាយុ ពោលទៅនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រអនុរុទ្ធដ៏ចម្រើន ព្រះមានព្រះភាគបរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធតបថា ម្នាលអាវុសោអានន្ទ ព្រះ-មានព្រះភាគ មិនទាន់បរិនិព្វានទេ ព្រះអង្គទ្រង់ចូលកាន់សញ្ញា-វេទយិតនិរោធ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសញ្ញាវេទយិត-និរោធសមាបត្តិហើយ ថយមកចូលកាន់នេវសញ្ញានាសញ្ញា-យតនសមាបត្តិវិញ ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ថយមកចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ថយមកចូលកាន់វិញ្ញាណញ្ចា-យតនសមាបត្តិវិញ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិហើយ ថយមកចូលកាន់អាកាសានញ្ចាយតនសមាបត្តិវិញ ចេញអំពី

អាកាសានញ្ចាយតនសមាបត្តិហើយ ថយមកចូលកាន់ចតុត្ថជ្ឈាន
វិញ ចេញអំពីចតុត្ថជ្ឈានហើយ ថយមកចូលកាន់តតិយជ្ឈានវិញ
ចេញអំពីតតិយជ្ឈានហើយ ថយមកចូលកាន់ទុតិយជ្ឈានវិញ
ចេញអំពីទុតិយជ្ឈានហើយ ថយមកចូលកាន់បឋមជ្ឈានវិញ ចេញ
អំពីបឋមជ្ឈានហើយ ក៏ចូលកាន់ទុតិយជ្ឈានទៀត ចេញអំពីទុតិ-
យជ្ឈានហើយ ក៏ចូលកាន់តតិយជ្ឈានទៀត ចេញអំពីតតិយជ្ឈាន
ហើយ ក៏ចូលកាន់ចតុត្ថជ្ឈានទៀត ។ លុះព្រះមានព្រះភាគ ទ្រង់
ចេញចាកចតុត្ថជ្ឈានហើយ ក៏ទ្រង់បរិនិព្វាន ក្នុងចន្លោះនោះ ។

ក្នុងអដ្ឋកថា ឈ្មោះសុមង្គលវិលាសិនី មានពន្យល់ថា ៖

បណ្ដាបទទាំងនោះ បទថា បរិនិព្វុតោ ភន្តេ សេចក្ដីថា
ព្រះអានន្ទ ឃើញព្រះមានព្រះភាគ ចូលនិរោធសមាបត្តិមិនមាន
អស្សាសបស្សាសៈ ទើបសួរថា "បពិត្រអនុរុទ្ធដ៏ចម្រើន ព្រះមាន
ព្រះភាគ បរិនិព្វានហើយឬ" ។ ព្រះអនុរុទ្ធតបថា "ម្នាលអាវុសោ
អានន្ទ ព្រះមានព្រះភាគ មិនទាន់បរិនិព្វានទេ" ។ ព្រះថេរៈជ្រាប
រឿង ។ បានឮថា ព្រះថេរៈចូលសមាបត្តិនោះៗ ព្រមនឹងព្រះ
សាស្ដាទុំះឯង ទើបដឹងថា ព្រះមានព្រះភាគ ចេញចាកនេវសញ្ញា-

នាសញ្ញាយតនៈ ហើយដំណើរទៅ ឥឡូវនេះ ចូលនិរោធសមាបត្តិ ឈ្មោះថា ការធ្វើកាលកិរិយាខាងក្នុងនិរោធសមាបត្តិមិនមាន ។

ក្នុងព្រះបាលីនេះថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកសញ្ញាវេទយិតនិរោធ ចូលនៅសញ្ញានាសញ្ញាយតនៈ ។លៈ។ ចេញចាកតតិយឈាន ចូលចតុត្ថឈាន ព្រះមានព្រះភាគទ្រង់ចូលបឋមឈានក្នុងឋានៈ ២៤ ទុតិយឈានក្នុងឋានៈ ១៣ តតិយឈានក៏ដូចគ្នា ចូលចតុត្ថឈានក្នុងឋានៈ ១៥ ។ ចូលយ៉ាងណា ។ គឺចូលបឋមឈានក្នុងឋានៈ ២៤ ទាំងនេះ មានអសុភៈ ១០ អាការៈ ៣២ កសិណ ៨ មេត្តា ករុណា មុទិតា អានាបានស្សតិ បរិច្ឆេទាកាស ជាដើម ។ តែវៀរអាការៈ ៣២ និងអសុភៈ ១០ ចូលទុតិយឈានក្នុងឋានៈដ៏សេស ១៣ និងចូលតតិយឈានក្នុងឋានៈ ១៣ នោះដូចគ្នា ។ មួយទៀត ចូលចតុត្ថឈាន ក្នុងឋានៈ ១៥ ទាំងនេះគឺ កសិណ ៨ ឧបេក្ខាព្រហ្មវិហារ អានាបានស្សតិ បរិច្ឆេទាកាស អរូប ៤ ។ ពោលដោយសង្ខេបប៉ុណ្ណោះ ។ តែព្រះមានព្រះភាគ ទ្រង់ជាធម្មសាមី ស្តេចចូលព្រះនគរគឺ បរិនិព្វាន ស្តេចចូលសមាបត្តិទាំងអស់រាប់បានម្ភៃបួនសែនកោដិ ហើយចូល

សោយសុខក្នុងសមាបត្តិទាំងអស់ ដូចជាអ្នកទៅកាន់ប្រទេសផ្សេងៗ ប្រមូលជនដែលជាញាតិដូច្នោះ ។

ក្នុងពាក្យនេះថា ព្រះមានព្រះភាគ ស្តេចចេញចាកចតុត្ថ-ឈាន ក្នុងលំដាប់មកស្តេចបរិនិព្វាន គឺក្នុងលំដាប់ទាំង ២ គឺក្នុងលំដាប់នៃឈាន ក្នុងលំដាប់នៃបច្ចវេក្ខណញ្ញាណ ។ ព្រះមានព្រះភាគ ចេញចាកឈានហើយ ចូលកាន់ភវង្គហើយបរិនិព្វានក្នុងចន្លោះនោះ ឈ្មោះថា ចន្លោះឈាន ក្នុងលំដាប់ ២ នោះ ។ ព្រះមានព្រះភាគ ស្តេចចេញចាកឈានហើយពិចារណាអង្គឈានទៀត ចូលកាន់ភវង្គហើយបរិនិព្វានក្នុងចន្លោះនោះឯង ឈ្មោះថា ចន្លោះបច្ចវេក្ខណញ្ញាណ ។ សូម្បីទាំង ២ នេះក៏ឈ្មោះថា ចន្លោះទាំងនោះ ។ ក៏ព្រះមានព្រះភាគ ចូលឈានស្តេចចេញចាកឈានពិចារណាអង្គឈាន ហើយបរិនិព្វានដោយភវង្គចិត្តជាអព្យាកតជាទុក្ខសច្ចះ ។ សត្វពួកណាមួយ មិនថា ព្រះពុទ្ធ ឬព្រះសាវ័កដោយហោចទៅសូម្បីស្រមោចខ្មៅ ស្រមោចក្រហម ត្រូវធ្វើកាល-កិរិយាដោយភវង្គចិត្តដែលជាអព្យាកត ជាទុក្ខសច្ចទាំងនោះឯង ។

## ៥២. ហេតុកើតព្រមនឹងការបរិនិព្វាន

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ការកក្រើកនៃផែនដីធំ គួរស្បើម គួរព្រឺរោម ក៏កើតមាន ទាំងផ្គរក៏លាន់ឮគគ្រឹកគគ្រេង ព្រមនឹងការបរិនិព្វាន ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ សហម្បតិព្រហ្មក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា ៖

សព្វេ វ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា លោកេ អប្បដិបុគ្គលោ
តថាគតោ ពលប្បត្តោ សម្ពុទ្ធោ បរិនិព្វុតោតិ ។

ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ប្រាកដដូច្នេះ ព្រះតថាគតជាសម្ពុទ្ធ បរិបូរណ៍ហើយដោយកម្លាំង ទ្រង់បរិនិព្វានហើយ ក្នុងលោកណា ពួកសត្វទាំងអស់ មុខជានឹងដាក់ចុះនូវរាងកាយក្នុងលោក (នោះ) មិនខានឡើយ ។

កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះឥន្ទជាធំជាងទេវតា ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា ៖

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។

*សង្ខារទាំងឡាយ មិនទៀងហ្ន៎ មានកិរិយាកើតឡើង និង ការសូន្យទៅជាធម្មតា លុះកើតឡើងហើយ ក៏រលត់ទៅវិញ កិរិយារម្ងាប់នូវសង្ខារទាំងឡាយនោះបាន ទើបនាំមកនូវ សេចក្តីសុខ ។*

*<u>អដ្ឋកថា</u> : បទថា* ឧប្បាទវយធម្មិនោ *(មានកិរិយា កើតឡើងនិងសូន្យទៅជាធម្មតា) បានដល់ ដែលមានការកើតឡើង និងរលត់ទៅជាសភាវៈ ។ បទថា* តេសំ វូបសមោ *(កិរិយា រម្ងាប់នូវសង្ខារទាំងនោះបាន) សេចក្តីថា សេចក្តីរម្ងាប់សង្ខារទាំង នោះ ក៏គឺព្រះនិព្វានដែលមិនមានបច្ច័យតាក់តែងនោះឯង ជាសុខ។*

*កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអនុរុទ្ធ មាន អាយុ ក៏ពោលនូវគាថានេះ ព្រមទឹងការបរិនិព្វានថា ៖*

នាហុ អស្សាសបស្សាសោ ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ យំ កាលមករី មុនិ ។

អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហុ ។

*ព្រះមុនីនាថអង្គណា ដែលមិនមានតណ្ហា ទ្រង់ប្រារព្ធនូវអនុបាទិសេសបរិនិព្វានហើយ ទ្រង់ធ្វើមរណកាល អស្សាសបស្សាសនៃព្រះមុនីនាថ ជាតាទិបុគ្គល ដែលមានព្រះទ័យខ្ជាប់ខ្ជួននោះ មិនមានហើយ ។ ព្រះមុនីនាថ ទ្រង់អត់សង្កត់វេទនាបានដោយចិត្តមិនរួញរា សេចក្តីរលត់នៃចិត្តក៏កើតមានបីដូចជាការរលត់នៃប្រទីប ។*

*កាលព្រះមានព្រះភាគ បរិនិព្វានហើយ ព្រះអានន្ទ មានអាយុ ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា ៖*

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេ ។

*កាលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុប្រសើរទាំងពួងទ្រង់បរិនិព្វានហើយ សេចក្តីញាប់ញ័រក្តី សេចក្តីព្រឺរោមក្តីក៏កើតមានប្រាកដ ។*


ព្រះសថូប កន្លែងទ្រង់បរិនិព្វាន





# អចលចេតិយ នៅសង្កស្សនគរ





# II. កាលជាខាងក្រោយពីការបរិនិព្វាន

## ១~ការកន្ទក់កន្ទេញនៃបរិស័ទ

*កាលព្រះមានព្រះភាគ បរិនិព្វានហើយ ភិក្ខុទាំងឡាយណា ដែលមិនទាន់ប្រាសចាករាគៈ មាននៅក្នុងទីនុ៎ះ ភិក្ខុទាំងនោះពួកខ្លះ ក៏ផ្គងឡើងនូវកំភួនដៃហើយកន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះនទៀល ទៅមក ហាក់ដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគត ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុ ក្នុងលោក ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ។ ឯពួកភិក្ខុណា ដែលប្រាសចាករាគៈហើយ ភិក្ខុទាំងនោះ មានសតិ និងសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀងពិត ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុង(ខន្ធប្បវត្តិ) នេះអំពីណា ។*

*អដ្ឋកថាថា : បទថា* អវីតរាគា *(មិនទាន់ប្រាសចាករាគៈ) បានដល់ បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតមែន បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ទាំងនោះលះទោ-*

មនុស្សមិនទាន់បាន ព្រោះដូច្នោះ លោកសូម្បីទាំងនោះ ផ្គងដៃទាំងពីរទួញយំ ដាក់ដៃទាំងពីរទុកលើសិរស្រែកយំ ។

លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ប្រាប់ពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោយសោក កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ សេចក្ដីនេះព្រះមានព្រះភាគទ្រង់បានសម្ដែងមកពីមុនហើយថា សេចក្ដីព្រាត់ប្រាស វិនាសប្រែប្រួលចាកសត្វនិងសង្ខារដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្ដីមិនព្រាត់ប្រាសនោះ ក្នុង (ខន្ធប្បវត្តិ) នេះអំពីណា ធម្មជាតណាដែលកើតហើយ ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មានសេចក្ដីទ្រុឌទ្រោម ជាធម្មតា ធម្មជាតនោះឯង បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ម្នាលអាវុសោទាំងឡាយ ទេវតាទាំងឡាយនឹងពោលទោសមិនខាន ។

ព្រះអានន្ទសួរថា បពិត្រអនុរុទ្ធដ៏ចម្រើន ចុះពួកទេវតា

ធ្វើទុកក្នុងចិត្តដូចម្តេច ។

ព្រះអនុរុទ្ធមានថេរវាចាថា ម្នាលអាវុសោអានន្ទ មានពួកទេវតា (ខ្លះ) ដែលសម្គាល់ គឺនិម្មិតផែនដីក្នុងអាកាស រំសាយសក់កន្ទក់កន្ទេញ ផ្តួលខ្លួនចុះ បម្រះនទៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគត ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់ប្រញាប់បាត់បង់ពេកណាស់, ម្នាលអាវុសោអានន្ទ មានពួកទេវតា(ខ្លះ) ដែលសម្គាល់ នូវនិម្មិតគឺផែនដីលើផែនដី រំសាយសក់ កន្ទក់កន្ទេញ ។បេ។ បាត់ទៅ ។ ពួកទេវតាណា ដែលប្រាសចាករាគៈ ទេវតាទាំងនោះ មានសតិសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ក្នុង(ខន្ធប្បវត្តិ)នេះអំពីណា ។

គ្រានោះ ព្រះអនុរុទ្ធមានអាយុ និងព្រះអានន្ទមានអាយុធ្វើធម្មីកថា អស់រាត្រីដែលនៅសល់នោះ ។ ទើបព្រះអនុរុទ្ធ មានអាយុ ពោលនឹងព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ អ្នក

ចូរចូលទៅកាន់ក្រុងកុសិនារា ហើយថ្វាយដំណឹង ដល់ពួកមល្ល-ក្សត្រិយ៍ អ្នកក្រុងកុសិនារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ព្រះមានព្រះភាគ បរិនិព្វានហើយ ឥឡូវអ្នកទាំងឡាយ ចូរសម្គាល់នូវកាលគួរចុះ ។

ព្រះអានន្ទមានអាយុ ទទួលវាចានៃព្រះអនុរុទ្ធមានអាយុថា អើលោកម្ចាស់ ហើយក៏ស្លៀកស្បង់កាន់យកបាត្រ និងចីវរក្នុងបុព្វណ្ហសម័យ មិនមានភិក្ខុជាគម្រប់ពីរឡើយ ចូរទៅកាន់ក្រុងកុសិនារា ។

## ២. ការថ្វាយដំណឹងបរិនិព្វាន

ក្នុងសម័យនោះឯង ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា កំពុងប្រជុំគ្នាក្នុងសណ្ឋាគារដ្ឋាន ដោយកិច្ចនីមួយ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅកាន់សណ្ឋាគារដ្ឋានរបស់ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ថ្វាយដំណឹងដល់ពួកមល្លក្សត្រិយ៍អ្នកក្រុងកុសិនារាថា បពិត្រវាសិដ្ឋទាំងឡាយ ព្រះមានព្រះភាគ បរិនិព្វានហើយ ឥឡូវនេះ សូមទ្រង់ទាំងឡាយសម្គាល់នូវកាលគួរចុះ ។ ពួកមល្លក្សត្រិយ៍ ពួកបុត្ររបស់មល្ល-

ក្សត្រិយ៍ ព្រះសុណិសារបស់មល្លក្សត្រិយ៍ និងភរិយា របស់មល្ល-ក្សត្រិយ៍ ឮពាក្យនោះ របស់ព្រះអានន្ទមានអាយុហើយ ក៏កើតទុក្ខតូចព្រះទ័យ ផ្អែតដោយសេចក្តីទុក្ខក្នុងចិត្ត ខ្លះរំសាយសក់កន្ទក់កន្ទេញ ផ្គងកំភួនដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះ បម្រះនទៀលទៅមកបីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសុគតទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក បាត់បង់ទៅឆាប់ពេកណាស់ ។

គ្រានោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា បង្គាប់ពួករាជបុរសថា ម្នាលនាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រមូលគ្រឿងក្រអូបនិងកម្រងផ្កា និងគ្រឿងតូរ្យតន្ត្រីទាំងអស់ដែលមានក្នុងក្រុងកុសិនារា ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំយកគ្រឿងក្រអូបនិងកម្រងផ្កា និងគ្រឿងតូរ្យតន្ត្រី និងសំពត់ ៥០០ គូ ចូលទៅគាល់ព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងសាលវ័នរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុង លុះចូលទៅដល់ហើយ ក៏ធ្វើសក្ការៈ គោរពរាប់អានបូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូប

ទាំងឡាយ ហើយធ្វើពិដានសំពត់ តាក់តែងរោងបាំរាំយ៉ាងនេះ ពេញអស់ ១ ថ្ងៃនោះ ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា មានសេចក្តីត្រិះរិះដូច្នេះថា កាលនេះជ្រុលវេលាហើយ នឹងថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងថ្ងៃនេះមិនទាន់ទេ ចាំថ្ងៃស្អែកសឹមយើងនឹងថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំគ្នាធ្វើសក្ការៈ គោរពរាប់អានបូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ហើយធ្វើពិដានសំពត់ តាក់តែងរោងបាំរាំទាំងឡាយ ហើយញ៉ាំងថ្ងៃជាគម្រប់ពីរ ឲ្យកន្លងទៅទៀត ញ៉ាំងថ្ងៃជាគម្រប់បីឲ្យកន្លងទៅទៀត ញ៉ាំងថ្ងៃជាគម្រប់បួនឲ្យកន្លងទៅទៀត ញ៉ាំងថ្ងៃជាគម្រប់ប្រាំ ឲ្យកន្លងទៅទៀត ញ៉ាំងថ្ងៃជាគម្រប់ ៦ ឲ្យកន្លងទៅទៀត លុះថ្ងៃជាគម្រប់ ៧ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរព រាប់អាន បូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ហើយហែទៅតាម

ទិសខាងត្បូងទៅក្រៅក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ អំពីខាងត្បូងនៃក្រុង ។

## ៣.មល្លក្សត្រិយ៍ ៨ អង្គ

ក្នុងសម័យនោះឯង មល្លក្សត្រិយ៍ ៨ អង្គដែលជាប្រធានជម្រះសីសៈហើយ ទ្រង់សំពត់ថ្មី គិតគ្នាថា យើងនឹងលើកព្រះសរីរៈនៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងលើករួចបាន ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា ពោលនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្ដេច មានបច្ច័យដូចម្ដេច បានជាមល្លក្សត្រិយ៍ជាប្រធានទាំង ៨ អង្គនេះ ជម្រះសីសៈហើយ ទ្រង់សំពត់ថ្មី គិតគ្នាថា យើងនឹងលើកព្រះសរីរៈនៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងលើករួចបាន ។

ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ទ្រង់ទាំងឡាយផ្សេង បំណងរបស់ពួកទេវតាផ្សេង ។

ពួកមល្លក្សត្រិយ៍ សួរទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ទេវតាតើដូចម្ដេច ។

ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ទ្រង់ទាំងឡាយថា យើងរាល់គ្នានឹងធ្វើសក្ការៈ គោរពរាប់អាន បូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ហើយហែទៅតាមទិសខាងត្បូងទៅក្រៅក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគអំពីខាងត្បូងនៃក្រុង បពិត្រវាសិដ្ឋទាំងឡាយ ឯបំណងរបស់ពួកទេវតាថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរពរាប់អាន បូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយដែលជាទិព្វ ហើយហែទៅទិសខាងជើងតាមទិសខាងជើងនៃក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើង ហើយហែទៅត្រង់កណ្តាលតាមទីកណ្តាលនៃក្រុង ហើយចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយរបស់មល្លក្សត្រិយ៍ខាងកើតនៃក្រុង ។

ពួកមល្លក្សត្រិយ៍ ទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណងរបស់ពួកទេវតាយ៉ាងណា ការថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាងនោះចុះ ។

*សម័យនោះឯង ក្រុងកុសិនារាពាសពេញដោយផ្កាមន្ទារវៈ ដោយគំនរប្រមាណត្រឹមជង្គង់ រហូតដល់ទីជាចន្លោះនៃផ្ទះ និងទីសម្រាប់បង្ហូរនូវគូថ និងកន្លែងសម្រាប់បោលនូវសម្រាម ។ គ្រានោះ ពួកទេវតានិងពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំគ្នាធ្វើសក្ការៈគោរពរាប់អាន បូជាព្រះសរីរៈនៃព្រះមានព្រះភាគ ដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ ជារបស់ទិព្វខ្លះ របស់មនុស្សខ្លះ ហើយហែទៅខាងជើងតាម**ទិសខាងជើង**នៃក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើង ហើយហែទៅត្រង់កណ្តាល តាមទីកណ្តាលនៃក្រុង ហើយចេញទៅតាមទ្វារខាងជើងនៃក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយរបស់ពួកមល្លក្សត្រិយ៍ ខាងកើតនៃក្រុង ។*

*អដ្ឋកថា : ពាក្យថា **ចេតិយរបស់ពួកស្តេចមល្លៈ** ឈ្មោះថា មកុដពន្ធនៈនេះ ជាឈ្មោះរបស់សាលាមង្គលជាទីតែងព្រះអង្គរបស់ពួកស្តេចមល្លៈ ។ ក៏សាលានេះ លោកហៅថា ចេតិយ ព្រោះអត្ថថា លោកសាងទុកយ៉ាងស្រស់ល្អ ។*

បទថា មជ្ឈេន មជ្ឈំ ឯករស្ស ហារិត្វា (ហែទៅត្រង់កណ្ដាល តាមទីកណ្ដាលនៃក្រុង) សេចក្ដីថា កាលព្រះសរីរៈរបស់ព្រះមានព្រះភាគ ត្រូវគេនាំមកយ៉ាងនេះ ភរិយារបស់ពន្ធុលសេនាបតី ឈ្មោះថា **មល្លិកា** ជ្រាបថា គេនាំព្រះសរីរៈរបស់ព្រះមានព្រះភាគមក ក៏គិតថា យើងនឹងឲ្យគេនាំគ្រឿងប្រដាប់ឈ្មោះមហាលតាបសាធនៈ ដូចគ្នានឹងគ្រឿងប្រដាប់របស់នាងវិសាខា ដែលយើងរក្សាទុកមិនបានប្រើប្រាស់មកតាំងពីស្វាមីរបស់ខ្លួនស្លាប់ទៅ នឹងបូជាព្រះសាស្ដាដោយមហាលតាបសាធនៈនេះ ដូច្នេះហើយ ឲ្យសម្អាតមហាលតាបសាធនៈនោះ ជម្រះដោយទឹកក្រអូបហើយដាក់ទុកជិតទ្វារ ។ បានឮថា គ្រឿងប្រដាប់នោះមាននៅក្នុងស្ថានទី ៣ កន្លែង គឺក្នុងផ្ទះរបស់ស្ត្រីទាំងពីរនោះ (នាងវិសាខា និងនាងមល្លិកា) និងផ្ទះរបស់ចោរឈ្មោះថា ទេវទានិយៈ ។ ក៏នាងមល្លិកានោះ ពោលថា កាលព្រះសរីរៈរបស់ព្រះសាស្ដាមកដល់ទ្វារហើយ អ្នកទាំងឡាយចូរដាក់ព្រះសរីរៈរបស់ព្រះសាស្ដាចុះហើយ ពាក់គ្រឿងប្រដាប់នេះលើព្រះសរីរៈរបស់ព្រះសាស្ដា ។ គ្រឿងប្រដាប់នោះ ពាក់តាំងពីព្រះសិរសាដរាបទល់

នឹងថ្វាយព្រះបាទ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលមានព្រះឆវីវណ្ណដូចមាស ប្រដាប់ដោយមហាលតាបសាធនៈ ដែលធ្វើដោយរតនៈ ៧ ប្រការ ក៏រុងរឿងក្រៃលែងណាស់ ។ នាងមល្លិកានោះឃើញដូច្នោះហើយ ក៏មានចិត្តថាផូរផង់ធ្វើសេចក្ដីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ នឹងត្រាច់ទៅក្នុងវដ្ដសង្សារដរាបណា ដរាបនោះ កិច្ចដោយគ្រឿងប្រដាប់ ចូរកុំបែកអំពីខ្ញុំព្រះអង្គ សូមសរីរៈដូចគ្នានឹងគ្រឿងប្រដាប់ដែលពាក់ដាក់នៅជានិច្ចចុះ ។ គ្រានោះពួកស្ដេចមល្លបាមោក្ខ លើកព្រះមានព្រះភាគព្រមដោយគ្រឿងមហាលតាបសាធនៈ ដែលធ្វើដោយរតនៈ ៧ ប្រការ ចេញតាមទ្វារទិសខាងកើត ដាក់ព្រះសរីរៈរបស់ព្រះមានព្រះភាគ ចុះក្នុងមកុដពន្ធនចេតិយរបស់ពួកស្ដេចមល្លៈ ផ្លូវទិសខាងកើតនៃព្រះនគរ ។

លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា ពោលនឹងព្រះអានន្ទមានអាយុ ដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងទាំងឡាយ នឹងប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះតថាគតដូចម្ដេច ។

ព្រះអានន្ទតបថា បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជយ៉ាងណា ពួកមហាបពិត្រគប្បីប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះតថាគតយ៉ាងនោះចុះ ។

បពិត្រព្រះអានន្ទដ៏ចម្រើន ចុះពួកឥស្សរជនប្រតិបត្តិ ក្នុងសរីរៈនៃព្រះចក្រពត្តិរាជដូចម្តេច ។

បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជន រុំសរីរៈនៃព្រះចក្រ-ពត្តិរាជ ដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) ប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជ រុំសរីរៈនៃព្រះចក្រពត្តិរាជដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងមឈូសមាសដែលដាក់ប្រេង ហើយគ្របដោយមឈូសមាសដទៃ ហើយធ្វើជើងថ្ករទើបថ្វាយព្រះភ្លើង នូវសរីរៈនៃព្រះចក្រពត្តិរាជ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ហើយគេធ្វើព្រះស្តូបនៃព្រះចក្រពត្តិរាជក្នុងផ្លូវធំ បែកជា ៤ បពិត្រវាសិដ្ឋៈទាំងឡាយ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជ យ៉ាងណាមិញ ពួកមហា-បពិត្រគប្បីប្រតិបត្តិ ក្នុងព្រះសរីរៈនៃព្រះតថាគត គប្បីធ្វើស្តូប

របស់ព្រះតថាគត ក្នុងផ្លូវបែកជា ៤ យ៉ាងនោះចុះ ពួកជនណា នឹងលើកឡើងនូវផ្កាកម្រងក្តី គ្រឿងក្រអូបក្តី គ្រឿងលំអិតក្តី ឬនឹងថ្វាយបង្គំ ឬធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ អំពើនោះនឹងនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់ជនទាំងនោះ អស់កាលយូរអង្វែង ។

គ្រានោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា បង្គាប់រាជបុរសថា ម្នាលនាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រមូលសំឡីរបស់ពួកមល្លជនមក ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំគ្នារុំព្រះសរីរៈនៃព្រះមានព្រះភាគ ដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំសរីរៈនៃព្រះមានព្រះភាគដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងព្រះមឈូសមាស ដែលដាក់ប្រេង ហើយគ្របដោយមឈូសមាសដទៃ ហើយធ្វើជើងថ្ករ ទើបថ្វាយព្រះភ្លើងនូវសរីរៈនៃព្រះមានព្រះភាគ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ។

## ៤-រឿងព្រះមហាកស្សប

*សម័យនោះឯង ព្រះមហាកស្សបមានអាយុ និមន្តតាមផ្លូវឆ្ងាយ មកអំពីក្រុងបាវា ទៅកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃជាច្រើន ប្រមាណ ៥០០ រូប ។ លំដាប់នោះ ព្រះមហាកស្សបមានអាយុ ចៀសអំពីផ្លូវទៅគង់ក្រោមម្លប់ឈើ ១ ។ ក៏សម័យនោះឯង មានអាជីវកម្នាក់ កាន់ផ្កាមន្ទារវៈ អំពីក្រុងកុសិនារា ដើរតាមផ្លូវឆ្ងាយ ទៅកាន់ក្រុងបាវា ។ ព្រះមហាកស្សបមានអាយុ បានឃើញអាជីវកនោះ ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទៅនឹងអាជីវកនោះ ដូច្នេះថា ម្នាលអាវុសោ អ្នកបានដឹងដំណឹងព្រះសាស្តា របស់យើងខ្លះដែរឬ ។ អាជីវកតបថា អើអាវុសោ ខ្ញុំដឹងដែរ ព្រះសមណគោតមបរិនិព្វានទៅ ៧ ថ្ងៃ គម្រប់នឹងថ្ងៃនេះហើយ ផ្កាមន្ទារវៈនេះ ខ្ញុំយកមកអំពីទីបរិនិព្វានរបស់ព្រះសមណៈគោតមនោះ ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណា ដែលមិនទាន់ប្រាសចាករាគៈ ពួកភិក្ខុទាំងនោះ ខ្លះក៏ផ្គងកំភួនដៃ កន្ទក់កន្ទេញ ដួលបម្រះននៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសុគត ទ្រង់*

បរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់បាត់ទៅឆាប់ពេកណាស់ ។ ឯពួកភិក្ខុណា ដែលប្រាសចាករាគៈហើយ ពួកភិក្ខុនោះ ក៏មានសតិសម្បជញ្ញៈ អត់សង្កត់ថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុងខន្ធប្បវត្តិនេះមកអំពីណា ។

អដ្ឋកថាថា : ពាក្យថា **មកអំពីក្រុងបាវា ទៅកាន់ក្រុងកុសិនារា** សេចក្តីថា ព្រះមហាកស្សបៈ និមន្តផ្លូវឆ្ងាយដោយប្រាថ្នាថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងនគរបាវាហើយ នឹងទៅកាន់នគរកុសិនារា ។ ក្នុងពាក្យថា **គង់ក្រោមម្លប់ឈើ ១** នេះ តើហេតុណា ទើបលោកមិនពោលថា សម្រាកពេលថ្ងៃ ។ ព្រោះលោកមិនអង្គុយដើម្បីត្រូវការសម្រាកពេលថ្ងៃ ។ សេចក្តីពិត ពួកភិក្ខុបរិវាររបស់ព្រះថេរៈសុទ្ធតែចម្រើនសុខ មានបុណ្យច្រើន លោកធ្វើដំណើរដោយជើងលើផែនដីដែលដូចជាផ្ទាំងថ្មដ៏ក្តៅ ក្នុងវេលាថ្ងៃត្រង់បានលំបាក ។ ព្រះថេរៈឃើញភិក្ខុទាំងនោះ ក៏គិតថា ភិក្ខុទាំងឡាយលំបាក ទាំងស្ថានទីដែលត្រូវទៅក៏នៅឆ្ងាយ នឹងសម្រាកបន្តិចបន្តួចរម្ងាប់សេចក្តីលំបាក ពេលល្ងាចដល់នគរកុសិនារា

នឹងចូលគាល់ព្រះទសពល ទើបឆៀងចុះអំពីផ្លូវ ក្រោលសង្ឃាដិ ទៀបគល់ឈើមួយកន្លែង ហើយយកទឹកអំពីតុម្ពលាបដៃនិងជើង ឲ្យត្រជាក់ហើយគង់ចុះ ។ សូម្បីពួកភិក្ខុបរិវាររបស់លោក ក៏គង់ ទៀបគល់ឈើ ធ្វើយោនិសោមនសិការកម្មដ្ឋាន អង្គុយសរសើរ គុណព្រះរតនត្រ័យ ។ ដូច្នោះ លោកទើបមិនពោលថា សម្រាក ពេលថ្ងៃ ។ ព្រោះអង្គុយដើម្បីត្រូវការបន្ទោបង់សេចក្ដីនឿយ លំបាក ។

ពាក្យថា **កាន់ផ្កាមន្ទារវៈ** បានដល់ យកឈើដោតផ្កា មន្ទារវៈប៉ុនថាសធំ កាន់មកដូចឆត្រ ។ ពាក្យថា **បានឃើញនោះ** បានដល់ ឃើញអាជីវកដើរមកពីចម្ងាយ ។ ក៏ឯគ្រាឃើញហើយ ព្រះថេរៈគិតថា នោះផ្កាមន្ទារវៈប្រាកដនៅក្នុងដៃរបស់អាជីវកនេះ ក៏ផ្កាមន្ទារវៈនោះ មិនប្រាកដក្នុងលំនៅរបស់មនុស្សរឿយៗ និង មានក៏ចំពោះកាលអ្នកមានឫទ្ធិខ្លះ លោកប្តែងឫទ្ធិ និងចំពោះកាល ព្រះសព្វញ្ញូពោធិសត្វ ស្ដេចចុះកាន់ព្រះគភ៌របស់ព្រះមាតាជាដើម តែថ្ងៃនេះ អ្នកមានឫទ្ធិណាមួយ ក៏មិនបានសម្ដែងឫទ្ធិនេះ ព្រះ-សាស្ដារបស់យើងក៏ស្ដេចមិនចុះកាន់ព្រះគភ៌របស់ព្រះមាតា ស្ដេច

មិនបានចេញចាកព្រះគកិ ទាំងថ្ងៃនេះព្រះអង្គក៏មិនបានត្រាស់ដឹង មិនបានប្រកាសព្រះធម្មចក្រ មិនបានសម្តែងយមកបាដិហារ្យ ស្តេចមិនបានចុះអំពីទេវលោក ទ្រង់មិនបានដាក់អាយុសង្ខារ តែព្រះសាស្តារបស់យើងទ្រង់ព្រះជរា នឹងស្តេចបរិនិព្វានដោយពិតហើយ ។ លំដាប់នោះ ព្រះថេរៈកើតចិត្តគិតថា នឹងសួរគេ ទើបត្រិះរិះថា ក៏បើយើងអង្គុយសួរ ក៏នឹងជាការធ្វើសេចក្តីមិនគោរពក្នុងព្រះសាស្តា ដូច្នេះហើយទើបក្រោកឡើង ដណ្តប់បង្សុកូលចីវរពណ៌ផ្ទៃមេឃដែលព្រះទសពលប្រទាន ប្រៀបដូចស្តេចដំរីឆទ្ទន្តជៀសចេញចាកទីឈរ ដណ្តប់ស្បែកកែវមណីដូច្នោះ លើកអញ្ជលីដែលរុងរឿងដោយទសនខសមោធានទុកលើសិរសា បែរមុខត្រង់ចំពោះអាជីវកដោយគារវៈដែលធ្វើក្នុងព្រះសាស្តា ពោលសួរថា អ្នកមានអាយុ លោកជ្រាបដំណឹងព្រះសាស្តារបស់យើងដែរទេ ។

សួរថា ក៏ព្រះមហាកស្សបៈ ដឹងការបរិព្វានរបស់ព្រះសាស្តា ឬមិនដឹងទេ ទើបសួរ ។ អាចារ្យពួកមួយពោលថា ការដឹងរបស់ព្រះខីណាស្រពទាំងឡាយ ត្រូវជាប់ដោយអាវជ្ជនៈ ការនឹក ក៏ព្រះ

មហាកស្សបៈនេះមិនដឹង ទើបសួរ ព្រោះលោកមិនបានទឹកទុក ។ ព្រះថេរៈច្រើនដោយសមាបត្តិ ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដោយការច្រើនទៅដោយសមាបត្តិជានិច្ច ក្នុងទីនៅពេលយប់ ទីសម្រាកពេលថ្ងៃ ទីពួនសម្ងំនិងទីមណ្ឌបជាដើម ចូលស្រុករបស់ត្រកូលក៏ចូលសមាបត្តិគ្រប់ទ្វារផ្ទះ ចេញចាកសមាបត្តិហើយទើបទទួលភិក្ខា បានឮថា ព្រះថេរៈ ធ្វើសេចក្ដីតាំងចិត្តយ៉ាងនេះថា ដោយអត្តភាពចុងបង្អស់នេះ យើងនឹងអនុគ្រោះមហាជន ជនពួកណាថ្វាយភិក្ខា ឬធ្វើសក្ការៈដោយគ្រឿងក្រអូប និងផ្កាឈើជាដើមដល់យើង ទាននោះរបស់ជនទាំងនោះ ចូរមានផលច្រើន ដូច្នេះ ព្រោះដូច្នោះ លោកទើបមិនដឹង ព្រោះច្រើនទៅដោយសមាបត្តិ ។ ដូច្នោះ អាចារ្យពួកមួយទើបពោលថា លោកមិនដឹងទើបសួរ ។ ពាក្យនោះមិនគួរកាន់យក ។ ព្រោះថា មិនមានហេតុដែលនឹងមិនដឹងក្នុងសេចក្ដីនោះ ។ ការបរិនិព្វានរបស់ព្រះសាស្ដា បានជាការកំណត់ទុកច្បាស់ហើយដោយនិមិត្តទាំងឡាយ មានម៉ឺនលោក-ធាតុញាប់ញ័រជាដើម ព្រះថេរៈដឹង ទើបសួរដើម្បីឲ្យកើតសតិដល់ភិក្ខុទាំងឡាយ ដោយគិតថា ក៏ក្នុងបរិស័ទរបស់ព្រះថេរៈ ភិក្ខុពួក

ខ្លះក៏ធ្លាប់ឃើញព្រះមានព្រះភាគ ពួកខ្លះក៏មិនធ្លាប់ឃើញ បណ្ដាភិក្ខុទាំងនោះ សូម្បីភិក្ខុពួកណាធ្លាប់ឃើញហើយភិក្ខុសូម្បីទាំងនោះក៏នៅតែចង់ឃើញ សូម្បីភិក្ខុពួកណាមិនធ្លាប់ឃើញ សូម្បីភិក្ខុទាំងនោះក៏ចង់ឃើញដូចគ្នា បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកណា មិនធ្លាប់ឃើញ ភិក្ខុទាំងនោះក៏ទៅព្រោះអន្ទះអន្ទែងចង់ឃើញក្រៃលែងណាស់ សួរថា ព្រះមានព្រះភាគ នៅទីណា ជ្រាបថា បរិនិព្វានទៅហើយ ក៏នឹងមិនអាចនឹងតម្កល់ខ្លួននៅបាន បោលបាត្រចីវរ ស្លៀកសំពត់តែមួយផ្ទាំងខ្លះ ស្លៀកមិនល្អខ្លះ ដណ្ដប់មិនល្អខ្លះ គត់ទ្រូងស្រែកទ្រហោយំ ក្នុងទីនោះ មនុស្សទាំងឡាយនឹងសម្ដែងទោសរបស់យើងថា ពួកភិក្ខុដែលកាន់បង្សុកូលចីវរិកង្គធុតង្គដែលមកជាមួយព្រះមហាកស្សបៈ ស្រែកយំដោយខ្លួនឯងដូចស្ត្រី ភិក្ខុទាំងនោះនឹងលួងលោមពួកយើងបានយ៉ាងណា ក៏ព្រៃធំនេះគង់និងសូន្យទទេ កាលភិក្ខុទាំងឡាយស្រែកយំខ្លាំងក្នុងទីនេះ ដែលឈ្មោះថា ទោសគង់នឹងមិនមាន ព្រោះដឹងរឿងជាមុន សូម្បីមានសោកសៅក៏គង់នឹងស្រាលខ្លះ ដូច្នេះ ។

បទថា **ព្រះសមណគោតម បរិនិព្វានទៅ ៧ ថ្ងៃ គម្រប់នឹងថ្ងៃនេះហើយ** គឺថា រាប់មកដល់ថ្ងៃនេះ ព្រះសមណគោតម បរិនិព្វាន បាន ៧ ថ្ងៃហើយ ។ បទថា **នេះខ្ញុំយកពីទីនោះ** សេចក្តីថា ផ្កាមន្ទារវៈនេះ ខ្ញុំរើសមកហើយពីស្ថានទីបរិនិព្វានរបស់ព្រះសមណគោតមនោះ ។

សម័យនោះឯង ភិក្ខុបួសចាស់ឈ្មោះសុភទ្ទ អង្គុយក្នុងកណ្តាលបរិស័ទនោះ ។ លំដាប់នោះ ភិក្ខុបួសចាស់ឈ្មោះសុភទ្ទ ពោលទៅនឹងពួកភិក្ខុទាំងនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោកសៅកុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថាពួកយើង មហាសមណៈនោះតែងបៀតបៀនថា អំពើនេះគួរដល់អ្នក អំពើនេះមិនគួរដល់អ្នកឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើអំពើណា នឹងធ្វើអំពើនោះបាន មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន ។ គ្រានោះ ព្រះមហាកស្សប ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ពាក្យនេះព្រះមានព្រះភាគ បានសម្តែងជាមុនហើយថា សេចក្តី

ព្រាត់ប្រាសវិនាស ប្រែប្រួលចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីមិនព្រាត់ប្រាសនោះ ក្នុងខន្ធប្បវត្តិនេះមកអំពីណា ធម្មជាតណាដែលកើតហើយ មានហើយ ដែលបច្ច័យតាក់តែងហើយ សឹងមានសេចក្តីទ្រុឌទ្រោមទៅជាធម្មតា ធម្មជាតនោះ បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ (ដោយហេតុណា) ហេតុនេះមិនមានឡើយ ។

អដ្ឋកថាថា : ព្រះថេរៈស្តាប់ពាក្យនោះហើយ មិនបានសម្គាល់ថា ដូចជាត្រូវប្រហារត្រង់ហទយៈ ដូចជារន្ទះបាញ់ធ្លាក់ចុះលើអម្បែងក្បាល ។ តែព្រះថេរៈកើតធម៌សង្វេគ ។ ព្រះមានព្រះភាគ បរិនិព្វានបានត្រឹមតែ ៧ ថ្ងៃ សូម្បីថ្ងៃនេះព្រះសរីរៈរបស់ព្រះអង្គ មានព្រះឆវីវណ្ណដូចមាសក៏តាំងនៅនោះឯង ។ ការចម្រូងចម្រាស់ដ៏ធំកើតឡើងរហ័សយ៉ាងនេះ ក្នុងព្រះសាសនា ដែលព្រះមានព្រះភាគ ទ្រង់នាំមកដោយទុក្ខលំបាក ក៏បុគ្គលបាបនេះកាលធំធាត់ បានអ្នកដទៃឃើញបុគ្គលបាបនោះជាបក្ខពួក ក៏អាចនឹងធ្វើព្រះសាសនាឲ្យសាបសូន្យអន់ថយបាន ។

លំដាប់នោះ ព្រះថេរៈគិតថា ក៏បើយើងនឹងឲ្យភិក្ខុបួសឯចាស់នេះស្លៀកសំពត់ចាស់ យកកម្មេចផេះរោយសិរ បណ្តេញទៅ ។ មនុស្សទាំងឡាយក៏នឹងនាំគ្នាលើកទោសពួកយើងថា កាលព្រះសរីរៈរបស់ព្រះសមណគោតមនៅធរមាននៅឡើយ ពួកសាវកក៏វិវាទគ្នា ព្រោះដូច្នោះ យើងទើបអត់ទ្រាំទុកសិន ក៏ធម៌ដែលទ្រង់សម្តែងហើយនោះ ប្រៀបដូចផ្កាឈើទាំងឡាយដែលត្រូវខ្យល់រមែងខ្ចាត់ខ្ចាយទៅ យ៉ាងណា សិក្ខាបទ ១-២ សិក្ខាបទក្នុងវិន័យក៏នឹងវិនាសបញ្ហាវារៈ ១-២ វារៈ ក្នុងសូត្រក៏នឹងវិនាស ភូមិដទៃ ១-២ ភូមិ ក្នុងអភិធម្មក៏នឹងវិនាស ក្នុងកាលវេលាកន្លងទៅៗដោយអំណាចបុគ្គលអាក្រក់មានសភាពបែបនេះ ក៏ដូច្នោះដែរ ។ កាលឫសគល់វិនាសទៅយ៉ាងនេះ ពួកយើងក៏នឹងដូចជាបីសាច ។ ព្រោះដូច្នោះ យើងនឹងធ្វើសង្គាយនាធម្មវិន័យ កាលជាដូច្នេះ ធម៌នេះ វិន័យនេះ ក៏នឹងរឹងមាំដូចផ្កាឈើដែលយុំគ្រងទុកដោយអំបោះដ៏ស្វិត ក៏ដើម្បីប្រយោជន៍យ៉ាងនេះ ព្រះមានព្រះភាគ ទើបស្តេចទទួលយើងរហូតដល់អស់ផ្លូវចម្ងាយ ៣ គាវុត ប្រទានឧបសម្បទាដោយឱវាទ ៣ ប្រការ ទ្រង់ផ្លាស់ចីវរអំពីព្រះវរកាយ ត្រាស់

បដិបទាប្រៀបដោយព្រះចន្ទ្រ ដូចជាគ្រវីដៃក្នុងអាកាស ទ្រង់លើកតម្កើងយើងជាកាយសក្ខី (មានវិហារធម៌ស្មើដោយព្រះអង្គ) ទ្រង់ប្រគល់ភាពជាសកលសាសនទាយាទ ៣ ដងថា កាលភិក្ខុដូចជាយើងតាំងនៅ ភិក្ខុអាក្រក់នេះនឹងមិនបានសេចក្ដីចម្រើនក្នុងព្រះសាសនា ។ អធម៌មិនទាន់រុងរឿង ធម៌ក៏នឹងមិនសាបសូន្យអន់ថយ អវិន័យមិនទាន់រុងរឿង វិន័យក៏នឹងមិនសាបសូន្យ អន់-ថយ ចំណែកអធម្មវាទីមិនទាន់មានកម្លាំង ចំណែកធម្មវាទី ក៏នឹងមិនខ្សោយកម្លាំង ចំណែកអវិនយវាទីមិនទាន់មានកម្លាំង ចំណែកវិនយវាទីក៏នឹងមិនខ្សោយកម្លាំងត្រឹមណា យើងក៏នឹងសង្គាយនាធម៌និងវិន័យត្រឹមនោះ ។ តពីនោះ ពួកភិក្ខុរបររមភិក្ខុ ដែលជាសភាគគ្នា ល្មមដល់ខ្លួនៗ ក៏នឹងពោលវត្ថុដែលគួរ និងមិនគួរបានកាលជាដូច្នេះ ភិក្ខុអាក្រក់នេះឯងក៏ប្រសព្វនិគ្គហ: មិនអាចងើបសិរបានទៀត ព្រះសាសនាក៏នឹងមាំមួននិងផ្សាយទៅច្រើន ។ ព្រះថេរៈគិតថា យើងកើតចិត្តគិតយ៉ាងនេះហើយ **អថខោ មហាកស្សបោ ។បេ។ នេតំ ឋានំ វិជ្ជតិ** (គ្រានោះព្រះមហាកស្សបៈ ។ល។ ហេតុនេះមិនមានឡើយ) ដូច្នេះ ។

*សម័យនោះឯង ពួកមល្លក្សត្រិយ៍ ៤ អង្គ ដែលជាប្រធាន ទ្រង់ជម្រះសីសៈ ហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឈ្មួលនូវជើងថ្ករនៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងឈ្មួលឲ្យឆេះបាន ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា បានពោលទៅនឹងព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្ដេច មានបច្ច័យដូចម្ដេច បានជាពួកមល្លក្សត្រិយ៍ជាប្រធានទាំង ៤ អង្គនេះ ជម្រះសីសៈហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឈ្មួលនូវជើងថ្ករនៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងឈ្មួលឲ្យឆេះបាន ។*

*ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ពួកទេវតាផ្សេងគ្នា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ពួកទេវតាដូចម្ដេច ។ បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ពួកទេវតាថា ព្រះមហាកស្សបមានអាយុ កំពុងនិមន្តតាមផ្លូវឆ្ងាយចេញអំពីក្រុងបាវា មកកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឃជាច្រើនប្រមាណ ៥០០ រូប ព្រះមហាកស្សបមានអាយុ មិនទាន់បានថ្វាយបង្គំនូវបាទានៃព្រះមានព្រះភាគ ដោយដៃរបស់ខ្លួនដរាប*

ណា ជើងថ្ករព្រះមានព្រះភាគ ក៏មិនទាន់ឆេះដរាបនោះ ។

ពួកមល្លក្សត្រិយ៍តបថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណង របស់ពួកទេវតាយ៉ាងណា ការថ្វាយព្រះភ្លើងនូវព្រះសរីរៈនៃព្រះ-មានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាងនោះចុះ ។

គ្រានោះ ព្រះមហាកស្សបមានអាយុ ចូលទៅកាន់ជើងថ្ករ នៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយរបស់ពួកមល្លក្សត្រិយ៍ ទៀបក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ក៏ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ធ្វើប្រទក្សិណជើងថ្ករ ៣ ជុំហើយ បើកអំពីខាងព្រះបាទ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ ។ ឯភិក្ខុទាំង ៥០០ រូបនោះ ក៏ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យ-អញ្ជលី ធ្វើបទក្សិណជើងថ្ករ ៣ ជុំហើយ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគដោយសិរ្សៈ ។ កាលដែលព្រះមហាកស្សបមាន-អាយុ និងពួកភិក្ខុ ៥០០ រូបនោះ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគរួចហើយ ជើងថ្ករព្រះមានព្រះភាគ ក៏ឆេះឯង ។

អដ្ឋកថា : បានឮថា ទេវតាទាំងនោះ ជាទេវតាឧបដ្ឋាក របស់ព្រះថេរៈនុ៎ះឯង ។ សេចក្ដីពិត ព្រោះចិត្តជ្រះថ្លាព្រះអសីតិ-

មហាសាវ័ក ឧបដ្ឋាក ៨០,០០០ ត្រកូល របស់ព្រះមហាសាវ័កទាំងនោះ ក៏ទៅកើតក្នុងសួគ៌ ។ លំដាប់នោះ ពួកទេវតាដែលមានចិត្តជ្រះថ្លាក្នុងព្រះថេរៈហើយកើតក្នុងសួគ៌ មិនឃើញព្រះថេរៈក្នុងសមាគមនោះ គិតថា ព្រះថេរៈប្រចាំត្រកូលរបស់ពួកយើងចេញទៅទីណាហ្ន៎ ក៏ឃើញលោកដើរនៅក្នុងចន្លោះផ្លូវ ទើបនាំគ្នាអធិដ្ឋានថា កាលព្រះថេរៈប្រចាំត្រកូលរបស់ពួកយើងមិនទាន់បានថ្វាយបង្គំព្រះសរីរៈរបស់ព្រះមានព្រះភាគ សូមជើងថ្ករកុំឆេះឡើយដូច្នេះ ។ ពួកមនុស្សស្តាប់រឿងនោះហើយគិតថា បានឮថា ភិក្ខុឈ្មោះថា ព្រះមហាកស្សបៈដ៏ចម្រើន នឹងថ្វាយបង្គំព្រះបាទរបស់ព្រះទសពល ព្រមនឹងភិក្ខុ ៥០០ រូប ដូច្នេះហើយទើបមក កាលភិក្ខុនោះនៅមិនទាន់មកដល់ជើងថ្ករក៏នឹងមិនឆេះ ។ អ្នកដ៏ចម្រើនភិក្ខុនោះជាប្រភេទណា ខ្មៅ ស ខ្ពស់ ទាប កាលភិក្ខុដូច្នេះតាំងនៅហេតុដូចម្តេចព្រះទសពលទើបបរិនិព្វាន ដូច្នេះហើយ ពួកខ្លះកាន់របស់ក្រអូបនិងផ្កាឈើជាដើមដើរតាមផ្លូវ ពួកខ្លះធ្វើថ្នល់ឲ្យស្អាតល្អ ឈរចាំមើលផ្លូវដែលនឹងមក ។

ពាក្យថា គ្រានោះឯង ព្រះមហាកស្សបមានអាយុ ចូលទៅ

*កាន់ជើងថ្ករ ។លៈ។ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសីសៈ សេចក្ដីថា បានឮថា ព្រះថេរៈធ្វើប្រទក្សិណចិត្តកាធារបណ្ដើរវំលឹកកំណត់ថា ត្រង់នេះព្រះសិរសា ត្រង់នេះព្រះបាទ ។ តពីនោះ ព្រះថេរៈក៏ឈរជិតព្រះបាទទាំងពីរ ចូលចតុត្ថឈានដែលជាបាទនៃអភិញ្ញា ចេញចាកឈានហើយអធិដ្ឋានថា សូមព្រះយុគលបាទរបស់ព្រះទសពល ដែលមានលក្ខណៈចក្រដែលប្រកបដោយកាំ ១,០០០ ប្រតិស្ឋានហើយ ចូរញែកគូនៃសំពត់ ៥០០ គូ ព្រមនឹងជាន់សាឡី មឈូសមាស និងចិត្តកាធារឈើចន្ទន៍ចេញជា ២ ប្រហោង ប្រតិស្ឋានលើសិរសារបស់ខ្ញុំព្រះអង្គចុះ ។ ព្រមដោយចិត្តអធិដ្ឋាន ព្រះយុគលបាទ ក៏ញែកគូសំពត់ ៥០០ គូជាដើមទាំងនោះ ផុសឡើងចេញមក ដូចជាព្រះចន្ទ្រពេញវង់ ចេញចាកចន្លោះវលាហក (ពពក) ដូច្នោះ ។ ព្រះថេរៈលាដៃទាំង ២ ដូចផ្កាបទុមក្រហមដែលរីកហើយ ចាប់ព្រះយុគលបាទរបស់ព្រះសាស្ដា ដែលមានព្រះឆវីវណ្ណដូចមាសជរាបដល់កព្រះបាទទុកមាំហើយ ប្រតិស្ឋានទុកលើសិរសាដ៏ប្រសើររបស់ខ្លួន។*

ដោយហេតុនោះ លោកទើបពោលថា "បើកអំពីខាងព្រះបាទ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្ស:" ។

មហាជន ឃើញសេចក្តីអស្ចារ្យដូច្នោះហើយ បន្លឺសីហនាទ ដ៏ទ្រហឹងឡើងព្រមគ្នា បូជាដោយរបស់ក្រអូបនិងផ្កាឈើជាដើម ហើយថ្វាយបង្គំតាមសេចក្តីពេញចិត្ត ។ ក៏ឯល្មមព្រះថេរៈ មហាជន និងភិក្ខុ ៥០០ រូបទាំងនោះ ថ្វាយបង្គំហើយ ក៏មិនមានកិច្ចដែលនិងត្រូវអធិដ្ឋានទៀត ។ ដោយអំណាចការអធិដ្ឋានតាមប្រក្រតីប៉ុណ្ណោះ ផ្ទៃព្រះយុគលបាទរបស់ព្រះមានព្រះភាគ មានវណ្ណៈដូចទឹកលក្ត ផុតពីដៃរបស់ព្រះថេរៈហើយមិនធ្វើឈើចន្ទន៍ជាដើមអ្វីឲ្យញ័រ ប្រតិស្ឋានទៅក្នុងទីដើម ។ ពិតមែន កាលព្រះយុគលបាទរបស់ព្រះមានព្រះភាគ ចេញមកឬចូលទៅ សរសៃសំលីក្តី សរសៃសំពត់ក្តី តំណក់ប្រេងក្តី ចម្រៀកឈើក្តី មិនឃ្លាតចាកទីឡើយ ទាំងអស់តាំងនៅដូចដើមនុ៎ះឯង ។ តែកាលព្រះយុគលបាទរបស់ព្រះតថាគតតាំងឡើងហើយ ក៏បាត់ក្លាមទៅដូចព្រះចន្ទ្រនិងព្រះអាទិត្យអស្តង្គត មហាជននាំគ្នាស្រែកយំខ្លាំងយ៉ាងសម្បើម ។ គួរករុណាក្រៃលែងជាងគ្រាបរិនិព្វានទៅទៀត ។

*ក៏ពាក្យថា ជើងថ្ករព្រះមានព្រះភាគ ក៏ឆេះដោយខ្លួនឯងនេះ លោកពោលដោយអំណាចមើលមិនឃើញ ដែលអ្នកណាមួយព្យាយាមឲ្យឆេះភ្លើង ។ ក៏ចិត្តកាធារនោះឆេះព្រឹបតែម្តង ដោយជុំវិញ ដោយអានុភាពរបស់ទេវតា ។*

## ៥~ព្រះសរីរធាតុរបស់ព្រះមានព្រះភាគ

*ព្រះសរីរធាតុរបស់ព្រះមានព្រះភាគ ដែលភ្លើងឆេះហើយអាការណា ទោះព្រះឆវីក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការៈនោះក៏ឆេះអស់ មិនមានផេះ មិនមានកំទេចធ្យូងឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ ។ សប្បិ ឬប្រេង ដែលភ្លើងឆេះ ក៏មិនមានកំទេចយ៉ាងណាមិញ ព្រះសរីរធាតុរបស់ព្រះមានព្រះភាគ ។បេ។ សល់នៅតែព្រះសរីរធាតុសុទ្ធ ក៏យ៉ាងនោះដែរ ។*

*បណ្តាសំពត់ទាំង ៥០០ គូនោះ សំពត់ពីរ គឺសំពត់ជាន់ក្នុងបំផុត ១ សំពត់ជាន់ក្រៅបំផុត ១ ក៏ឆេះអស់ ។*

## ៦_ពណ៌ព្រះបរមធាតុ

*អដ្ឋកថា : ពាក្យថា នៅសល់តែព្រះធាតុសុទ្ធ សេចក្ដីថា កាលមុនបានឈ្មោះថា សរីរៈ ក៏ព្រោះតាំងនៅដោយគ្រោងឆ្អឹងតែមួយ ឥឡូវនេះ លោកពោលថា សរីរៈទាំងអស់ខ្ចាត់ខ្ចាយទៅហើយ ។ អធិប្បាយថា ព្រះធាតុទាំងឡាយ ក៏ដូចផ្កាម្លិះក្រពុំ ដូចកែវមុក្ដាដែលច្នៃហើយ និងដូចកម្ទេចមាសនៅសល់ ។ ពិតមែនសរីរៈរបស់ព្រះពុទ្ធដែលមានព្រះជន្មវែងទាំងឡាយ រមែងជាប់គ្នាជាដុំដូចជាដុំមាស ។ ចំណែកព្រះមានព្រះភាគ ទ្រង់អធិដ្ឋាន ព្រះ-ធាតុឲ្យបែកជាបំណែកថា តថាគតនៅមិនបានយូរក៏នឹងបរិនិព្វាន សាសនារបស់តថាគតមិនទាន់បែកខ្ញែកច្រើន ទៅក្នុងទីទាំងពួងទេ ព្រោះដូច្នោះ កាលតថាគតសូម្បីបរិនិព្វានហើយ មហាជនកាន់យកព្រះធាតុសូម្បីខ្នាតប៉ុនគ្រាប់ស្ពៃ ធ្វើចេតិយក្នុងទីលំនៅរបស់ខ្លួនៗ ប្រតិបត្តិ ចូរមានសួគ៌ជាទីទៅក្នុងខាងមុខ ។*

## ៧_ខ្នាតព្រះបរមធាតុ

កតិ, ភន្តេ ធាតុយោ វិប្បកិណ្ណា, កតិ ន វិប្បកិណ្ណាតិ ។ ចតស្សោ ទាឋា, ទ្វេ អក្ខកា, ឧណ្ហីសន្តិ ឥមា សត្ត ធាតុយោ ន វិប្បកិរីសុ, សេសា វិប្បកិរីសូតិ ។ *សួរថា ព្រះធាតុយ៉ាងណារបស់ព្រះអង្គបែកជាបំណែក យ៉ាងណាមិនបែកជាបំណែក ។ ឆ្លើយថា ព្រះធាតុ ៧ ទាំងនេះគឺ ទាឋធាតុ (ព្រះចង្កូមកែវ) ៤ ព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត) ២ ព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១ មិនបែកជាបំណែក ក្រៅនោះបែកជាបំណែក ។*

តត្ថ សព្វខុទ្ទកា ធាតុ សាសបពីជមត្តា អហោសិ, មហាធាតុ មជ្ឈេ ភិន្នតណ្ឌុលមត្តា, អតិមហាតី មជ្ឈេ ភិន្នមុគ្គមត្តាតិ ។

*បណ្តាព្រះធាតុទាំងនោះ ព្រះធាតុខ្នាតតូចៗ ទាំងអស់ មានខ្នាតប៉ុនគ្រាប់ស្ពៃ ។ ព្រះធាតុខ្នាតធំ មានខ្នាតប៉ុនគ្រាប់អង្ករបាក់-*

ពាក់កណ្តាល, ព្រះធាតុខ្នាតធំក្រៃលែង មានខ្នាតប៉ុនគ្រាប់សណ្តែកបាយបាក់ពាក់កណ្តាល ។ (អដ្ឋកថា ពហុធាតុកសូត្រ)

## ៨.ការរំលត់ជើងថ្ករជាដើម

លុះព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលត្រូវភ្លើងឆេះហើយ ធារទឹកក៏បង្អុរអំពីអាកាស រំលត់ជើងថ្ករនៃព្រះមានព្រះភាគ ។ ទាំងមានទឹកខ្ទុរចេញអំពីដើមសាលព្រឹក្ស រំលត់ជើងថ្ករនៃព្រះមានព្រះភាគ ។ ទើបពួកមល្លក្សត្រ អ្នកក្រុងកុសិនារារំលត់ជើងថ្ករនៃព្រះមានព្រះភាគ ដោយទឹកក្រអូបទាំងពួង ។

គ្រានោះ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ក៏ធ្វើនូវការបញ្ជរលំពែង រួបព័ទ្ធដោយកំពែងធ្នូ ហើយធ្វើសក្ការៈគោរពរាប់អាន បូជាព្រះសរីរធាតុរបស់ព្រះមានព្រះភាគ ដោយរបាំចម្រៀង ភ្លេងប្រគំ ផ្កាកម្រងនិងគ្រឿងក្រអូបទាំងឡាយ អស់ ៧ ថ្ងៃ ក្នុងសណ្ឋាគារដ្ឋាន ។

អដ្ឋកថា : បទថា និព្វាបេសុំ (រំលត់) សេចក្តីថា ពួកស្តេចមល្លៈរំលត់ចន្ទនចិតកៈ (ជើងថ្ករខ្លឹមចន្ទន៍) ឆាយដោយ

ដំបង ៨ កំណាត់ ដែលធ្វើដោយមាសនិងប្រាក់ ហើយញ៉ាំង ជើងថ្ករខ្ទឹមចន្ទន៍ឲ្យរលត់ ។ ក៏កាលភ្លើងកំពុងឆេះជើងថ្ករនោះ អណ្តាតភ្លើងក៏បាញ់ឡើងអំពីចន្លោះមែក បង្កាប និងស្លឹករបស់ ដើមសាលៈដែលឋិតនៅលោមព័ទ្ធ ។ ស្លឹក មែក ឬ ផ្កាមិនឆេះ ឡើយ ។ ទាំងស្រមោចក្រហម ទាំងស្វា ទាំងសត្វតូចៗ ត្រាច់ទៅ ដោយចន្លោះអណ្តាតភ្លើង ។ ធម្មតាក្នុងធារទឹកដែលធ្លាក់ អំពី អាកាសក្តី ក្នុងធារទឹកដែលចេញចាកដើមសាលៈក្តី ក្នុងធារ ទឹកដែលញែកផែនដីចេញទៅក្តី គួរកាន់យកជាប្រមាណ ។

ក៏ឯគ្រារលត់ជើងថ្ករយ៉ាងនេះហើយ ពួកស្តេចមល្លៈក៏ឲ្យ ប្រោះព្រំដោយគន្ធជាត ៤ ប្រភេទ ឯសណ្ឋាគារ រោយផ្កាឈើ មានលាជជាគម្រប់ ៥ ប្រក់ពិតានសំពត់ទុកខាងលើ វិចិត្រដោយ ផ្កាយមាសជាដើម ព្យួរក្បួងរបស់ក្រអូប ក្បួងកម្រងផ្កា និងក្បួងកែវ ឲ្យព័ទ្ធវាំងននទនិងកន្ទេលផែងទុកទាំងពីរខាង តាំងពីសណ្ឋាគារ ដរាបដល់មណ្ឌលសាលា ដែលប្រដាប់សិរ ពោលគឺមកុដពន្ធនៈ ហើយប្រក់ពិតានសំពត់ទុកខាងលើ វិចិត្រដោយផ្កាយមាសជាដើម ព្យួរក្បួងរបស់ក្រអូប ក្បួងកម្រងផ្កា និងក្បួងកែវ សូម្បីក្នុងទីនោះ

ឲ្យលើកទង់ ៥ ពណ៌ ដោយពណ៌មណីនិងឫស្សី លោមព័ទ្ធទង់ជ័យនិងទង់បដាកទុកដោយជុំវិញ តាំងដើមចេកនិងឆ្នាំងដែលពេញដោយទឹកទុកត្រង់ថ្នល់ទាំងឡាយ ដែលស្រោចទឹក និងរលើបរលោងក៏អុជប្រទីបមានជង ដាក់មឈូសមាសព្រមដោយព្រះធាតុទាំងឡាយទុកលើកដំរីដែលប្រដាប់ហើយ បូជាដោយកម្រងផ្កា និងគ្រឿងក្រអូបជាដើម លេងសាធុកីឡា នាំចូលទៅខាងក្នុងព្រះនគរ ដាក់លើបល្ល័ង្កដែលធ្វើដោយរតនៈ ៧ ប្រការក្នុងសណ្ឋាគារ បាំងស្វេតឆត្រទុកខាងលើ ។ គ្រាធ្វើដូច្នេះហើយគ្រានោះ ពួកស្តេចមល្លៈអ្នកនគរកុសិនារាឲ្យទាហានកាន់លំពែងជារបងការពារ ឲ្យទាហានកាន់ធ្នូជាកំពែងព័ទ្ធទីសណ្ឋាគារ បូជាព្រះសរីរៈរបស់ព្រះមានព្រះភាគ ដោយការលេងរបាំ ការច្រៀង ការប្រគំដោយកម្រងផ្កា របស់ក្រអូប រហូតដល់អស់ ៧ ថ្ងៃ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា សត្តិបញ្ជរំ ករិត្វា (ធ្វើការបញ្ជរលំពែង) បានដល់ ចាត់ពួកបុរសកាន់លំពែងលោមព័ទ្ធ ។ បទថា ធនុបាការំ (ដោយកំពែងធ្នូ) បានដល់ ចាត់ពួកដំរីរៀង

លំដាប់ពោធទល់គ្នាលោមព័ទ្ធទុកជាមុន តពីនោះ ចាត់ពួកសេះរៀងលំដាប់កទល់គ្នា តពីនោះ ចាត់ពួករថរៀងលំដាប់ចុងស្នៀតកង់រថទល់គ្នា ចាត់ពួកធ្នូរៀងលំដាប់តគ្នាលោមព័ទ្ធ ។ ពួកស្ដេចមល្លៈចាត់រក្សារហូតដល់អស់ទីប្រមាណមួយយោជន៍ ដោយជុំវិញ ៧ ថ្ងៃ ធ្វើដូចជាកូនគោពាក់ក្រោះ ដោយប្រការដូច្នេះ ។

លោកសំដៅយកសេចក្ដីនោះទើបពោលថា ធនុចាការំ បរិក្ខិបាបេត្វា (រួចព័ទ្ធដោយកំពែងធ្នូ) ដូច្នេះ ។ សួរថា ក៏ព្រោះហេតុអ្វី ពួកស្ដេចមល្លៈទាំងនោះ ទើបបានធ្វើដូច្នោះ ។ ឆ្លើយថា ក្នុង ២ សប្ដាហ៍ដំបូងអំពីនេះ ស្ដេចមល្លៈទាំងនោះ ធ្វើឱកាសទីឈរនិងអង្គុយសម្រាប់ភិក្ខុសង្ឃ ចាត់ចែងរបស់ទំពាររបស់ឆាន់ប្រគេន មិនបានឱកាសដែលនិងលេងសាធុកីឡា ។ តពីនោះ ស្ដេចមល្លៈទាំងនោះត្រិះរិះគ្នាថា ពួកយើងនឹងលេងសាធុកីឡា រហូតអស់ ១ សប្ដាហ៍នេះ ។ សេចក្ដីដែលអ្នកណាមួយដឹងថា ពួកយើងប្រមាទ ហើយមកកាន់យកព្រះធាតុទាំងឡាយចេញទៅ មានឋានៈដែលនឹងប្រព្រឹត្តទៅបាន ព្រោះដូច្នោះ ពួកយើងនឹងត្រូវតាំងកង-

រក្សាការណ៍ទុកហើយលេងកីឡា ។ ដោយហេតុនោះ ស្តេចមល្ល: ទាំងនោះ ទើបបានធ្វើដូច្នោះ ។

## ៩. រឿងព្រះបាទអជាតសត្តុជាដើម

ព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកនៃព្រះសរីរធាតុនៃព្រះមានព្រះភាគដែរ យើងនឹងធ្វើស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ឯពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី, ពួកក្សត្រសក្យ: អ្នកក្រុងកបិលវត្ថុ បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាញាតិផ្ទាល់របស់ពួកយើង យើងគួរបានចំណែកនៃព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្ប:, ពួកក្សត្រកោឡិយ: អ្នករាមគ្រាម ។ ឯព្រាហ្មណ៍ដែលនៅក្នុងដែនវេដ្ឋទីប:

ក្នុងដែនវេដ្ឋទីបៈ បញ្ជូនទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាព្រាហ្មណ៍ យើងគួរបានចំណែកនៃព្រះសរីរធាតុនៃព្រះមានព្រះភាគដែរ យើងនឹងធ្វើស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ពួកមល្លក្សត្រអ្នកក្រុងបាវា ក៏បានបញ្ជូនរាជទូតទៅដូចគ្នា ។

លុះពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ពោលពាក្យយ៉ាងនេះហើយ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា បានពោលទៅនឹងពួកគណៈទូតទាំងនោះ ដូច្នេះថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយក្នុងគាមក្ខេត្តរបស់យើង យើងនឹងមិនឲ្យនូវចំណែកព្រះសរីរធាតុនៃព្រះមានព្រះភាគឡើយ ។

អដ្ឋកថា : បទថា អស្សោសិ ខោ រាជា (ទ្រង់បានឮដំណឹង) សេចក្តីថា ព្រះបាទអជាសត្រូវទ្រង់ជ្រាបរឿងហើយ ។ បានឮថា ពួកអមាត្យរបស់ស្តេចគិតតាំងពីដំបូងតែម្តងថា ធម្មតាថាព្រះសាស្តាបរិនិព្វានហើយ អ្នកណាៗ ក៏មិនអាចនាំព្រះអង្គមកបានវិញ តែមិនមានអ្នកស្មើដូចព្រះរាជារបស់យើង ដោយសទ្ធា

របស់បុប្ផជន បើព្រះរាជាអង្គនេះនឹងទ្រង់ស្តាប់ដោយទំនងនេះ ហឫទ័យរបស់ទ្រង់នឹងត្រូវបែក តែពួកយើងគួរប្រុងប្រយ័ត្នរក្សាព្រះរាជាទុកដូច្នេះ ។ អមាត្យទាំងនោះ ទើបនាំមឈូសមាស ៣ បញ្ចុះរបស់ឆ្ងាញ់ៗ ទុកពេញនាំទៅកាន់រាជសំណាក់ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គយល់សប្តិឃើញ ព្រះអង្គគួរទ្រទ្រង់សំពត់សំបកឈើពីរជាន់ ហើយផ្ទំក្នុងមឈូសដែលពេញដោយរបស់ឆ្ងាញ់ៗ ៤ យ៉ាង ល្មមពេលប្រហោងព្រះនាសិកផុសឡើង ដើម្បីកម្ចាត់សេចក្តីយល់សប្តិនោះចេញ ព្រះរាជាស្តាប់ពាក្យរបស់ពួកអមាត្យអ្នកប្រាថ្នាប្រយោជន៍ ទ្រង់ត្រាស់ថា យើងធ្វើបានហើយ បានទ្រង់ធ្វើយ៉ាងនោះ ។ លំដាប់នោះ អមាត្យមួយនាក់ដោះគ្រឿងប្រដាប់ហើយរំសាយសក់ បែរមុខទៅកាន់ទិសដែលព្រះសាស្តាបរិនិព្វាន ។ ផ្គងអញ្ជលីទូលព្រះរាជាថា ព្រះអង្គដែលឈ្មោះថាសត្វរួចផុតអំពីសេចក្តីស្លាប់មិនមានទេ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអ្នកចម្រើនជន្មាយុ ជាចេតិយស្ថាន ជាបុញ្ញខេត្ត ជាព្រះទេនអភិសេក ជាសាស្តារបស់យើងទាំងឡាយ បរិនិព្វានហើយក្នុងនគរកុសិនារា ព្រះរាជាទ្រង់ស្តាប់ហើយ ក៏ដល់វិសញ្ញី-

កាព (សន្ទប់) បញ្ចេញចំហាយក្តៅក្នុងមឈូសដែលពេញដោយរបស់ឆ្ងាញ់ ៤ យ៉ាង លំដាប់នោះ ពួកអមាត្យក៏លើកព្រះអង្គឡើងអំពីមឈូសទី ១ នោះ ឲ្យផ្ទំក្នុងមឈូសទី ២ ។ ស្តេចត្រឡប់ភ្ញាក់ឡើង មកត្រាស់សួរថា បាអើយ ពួកអ្នកនិយាយអ្វីហ្ន៎ ។ ក្រាបទូលថា ព្រះមហារាជ ព្រះសាស្តាបរិនិព្វានហើយព្រះអង្គ ។ ព្រះរាជា ក៏ត្រឡប់ទ្រង់វិសញ្ញីភាពទៀត បញ្ចេញចំហាយក្តៅចុះក្នុងមឈូសរបស់ឆ្ងាញ់ ៤ យ៉ាង ។ លំដាប់នោះ ពួកអមាត្យជួយគ្នាលើកស្តេចឡើងអំពីមឈូសទី ២ នោះហើយ ឲ្យផ្ទំក្នុងមឈូសទី ៣ ។ ស្តេចទ្រង់ត្រឡប់បានស្មារតីឡើងមកត្រាស់សួរថា បាអើយ ពួកអ្នកនិយាយ អ្វីហ្ន៎ ។ ក្រាបទូលថា ព្រះសាស្តាបរិនិព្វានហើយព្រះអង្គ ។ ព្រះរាជាក៏ទ្រង់វិសញ្ញីភាពទៀត ។ គ្រានោះ ពួកអមាត្យជួយគ្នា លើកព្រះអង្គឡើង ឲ្យស្រង់ទឹកយកផ្កាំងទឹកស្រោចទឹកចុះលើព្រះសិរសា ។

ព្រះរាជាទ្រង់ចាំបានហើយ ក្រោកចាកទីប្រថាប់រំសាយព្រះកេសា ដែលមានវណ្ណៈហាក់បីដូចកែវមណីអប់ដោយគ្រឿងក្រអូប សណ្តូកព្រះបិដ្ឋិ (ខ្នង) ដែលមានវណ្ណៈដូចផែនមាស យក

ព្រះហស្ដគក់ព្រះឱរៈ ចាប់ព្រះឱរៈដែលមានវណ្ណៈដូចផែនក្ដារមាស ដូចជាថា នឹងសិកដោយម្រាមព្រះហស្ដដ៏មូលក្រឡឹង ដែលមានវណ្ណៈដូចពន្លកកែវប្រវាឡ ទ្រង់ទួញយំ ស្ដេចចុះទៅក្នុងចន្លោះថ្នល់ដោយភេទរបស់អ្នកវិកលចរិត ស្ដេចមានស្រីរបាំដែលតែងខ្លួនហើយជាបរិវារ ស្ដេចចេញចាកព្រះនគរទៅកាន់សួនស្វាយរបស់ហ្មជីវក ទតព្រះនេត្រស្ថានទីដែលព្រះមានព្រះភាគ ប្រថាប់សម្ដែងធម៌ បរិទេវនាការត្អូញត្អែររៀបរាប់ដដែលៗ ថា ព្រះមានព្រះភាគទ្រង់ជាសព្វញ្ញូប្រថាប់សម្ដែងធម៌ទីនេះ មិនមែនឬ ? ទ្រង់បន្ទោបង់សេចក្ដីសោកស្ដាយរបស់ខ្ញុំព្រះអង្គ ព្រះអង្គទ្រង់នាំសេចក្ដីសោកស្ដាយរបស់ខ្ញុំព្រះអង្គចេញទៅ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមកកាន់សំណាក់របស់ព្រះអង្គហើយ តែឥឡូវនេះ ព្រះអង្គមិនប្រទានសូម្បីពាក្យឆ្លើយឆ្លងដល់ខ្ញុំព្រះអង្គ និងត្រាស់ពាក្យជាដើមយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គស្ដាប់មកក្នុងវេលាដទៃ មិនមែនឬ ? ថា ក្នុងវេលាបែបនោះ ព្រះអង្គមានភិក្ខុសង្ឃពួកធំជាបរិវារ ស្ដេចចារិកទៅលើផែនដីជម្ពូទ្វីប តែឥឡូវនេះខ្ញុំព្រះអង្គក៏បានតែស្ដាប់រឿងដែលមិនសមគួរ មិនគួរដល់ព្រះអង្គ

ឡើយ ហើយទ្រង់រំលឹកព្រះគុណរបស់ព្រះមានព្រះភាគ ដោយគាថាប្រមាណ ៦០ គាថា ទ្រង់ព្រះតម្រិះថា អ្វីៗ រមែងមិនសម្រេចបានដោយបរិទេវនាការរបស់យើង ចាំបាច់យើងនឹងឲ្យនាំព្រះ-បរមធាតុរបស់ព្រះទសពលមក ។ ទ្រង់ស្តាប់មកយ៉ាងនេះហើយរួចហើយ កាលទ្រង់បាត់វិសញ្ញីភាពជាដើមហើយ ក៏បញ្ជូនរាជទូតទៅ ។ លោកសំដៅយករឿងនោះ ទើបពោលថា អថ ខោ រាជា ជាដើម ។

បណ្តាបទទាំងនោះ បទថា ទូតំ ចាហេសិ (បញ្ជូនរាជ-ទូត) បានដល់ ទ្រង់បញ្ជូនរាជទូតនិងបណ្ណាការទៅ ។ ព្រះបាទអជាតសត្តុ ទ្រង់ព្រះតម្រិះថា បើពួកស្តេចមល្លៈនឹងឲ្យ ក៏ជាការល្អ បើមិនឲ្យ យើងនឹងត្រូវនាំមកដោយឧបាយ នាំមកឲ្យបានដូច្នេះហើយ ។ ទ្រង់ចាត់កងទ័ព ៤ ពួក ស្តេចចេញទៅដោយព្រះអង្គឯង ។ សូម្បីពួកស្តេចលិច្ឆវីជាដើម ក៏បញ្ជូនទូតទៅ ស្តេចចេញទៅដោយព្រះអង្គឯង ព្រមដោយកងទ័ព ៤ ពួកដូចព្រះបាទអជាតសត្តុ ដូច្នោះ ។ បើមានពាក្យសួរថា បណ្តាស្តេចទាំងនោះ ស្តេចមល្លៈអ្នកនគរបាវា មានចម្ងាយជិតជាងគេទាំងអស់ នៅក្នុង

នគរបាវាចម្ងាយ ៣ គាវុត អំពីនគរកុសិនារា សូម្បីព្រះមានព្រះភាគ ស្តេចចូលនគរបាវាហើយ ទើបស្តេចទៅនគរកុសិនារាកាលជាដូច្នោះ ព្រោះហេតុអ្វី ពួកស្តេចមល្លៈនគរបាវា ទើបស្តេចមិនមកជាមុន ។ ឆ្លើយថា ព្រោះថា ពួកស្តេចទាំងនោះ មានបរិវារច្រើន កាលធ្វើកិច្ចចំពោះបរិវារដ៏ច្រើនទើបមកខាងក្រោយ ។

បទថា តេ សង្ឃេ គណេ ឯតទវោចុំ (បានពោលទៅពួកគណៈទូតទាំងនោះ) សេចក្តីថា ពួកស្តេចលះបង់ព្រាហ្មណ៍ទាំងអស់នោះ រួមជាអ្នកនគរ ៧ នគរ នាំគ្នាមកហើយ ពោលពាក្យដាច់ខាតថា ពួកស្តេចមល្លៈនឹងឲ្យព្រះបរមធាតុដល់ពួកយើងឬនឹងច្បាំង ។ ហើយតាំងទ័ពឡោមព័ទ្ធនគរកុសិនារាទុក ពួកស្តេចមល្លក្សត្រ ក៏បានពោលពាក្យឆ្លើយឆ្លងទៅថា ព្រះមានព្រះភាគស្តេចបរិនិព្វានក្នុងគាមខេត្តរបស់ពួកយើងនេះ ។

បានឮថា ស្តេចទាំងនោះ ត្រាស់យ៉ាងនេះថា ពួកយើងមិនបានបញ្ជូនដំណឹងរបស់ព្រះសាស្តា ពួកយើងទៅក៏មិនបាននាំដំណឹងមក តែព្រះសាស្តាស្តេចមកដោយព្រះអង្គឯង ទ្រង់បញ្ជូនដំណឹងទៅបង្គាប់ឲ្យហៅពួកយើង សូម្បីតែពួកលោកមិនឲ្យព្រះ-

រតនៈ ដែលកើតក្នុងគាមខេត្តរបស់ពួកលោកដល់ពួកយើង ធម្មតាថា ព្រះរតនៈដែលស្មើដោយព្រះពុទ្ធរតនៈមិនមានក្នុងលោក ព្រមទាំងទេវលោក ពួកយើងបានព្រះរតនៈដែលខ្ពង់ខ្ពស់បំផុតបែបនេះ នឹងមិនព្រមឲ្យ ក៏ពួកលោកប៉ុណ្ណោះផឹកទឹកដោះអំពីដោះរបស់មាតា ពួកយើងមិនបានផឹកក៏ទេ ។ ពួកលោកប៉ុណ្ណោះជាកូនប្រុស ពួកយើងមិនមែនជាកូនប្រុសឬ ជាអ្វីក៏ដោយ ក៏ធ្វើអហំការ បញ្ជូនសំបុត្រឆ្លើយឆ្លងគ្នា ប្រើមានះគម្រាមដល់គ្នានឹងគ្នា ។ ក៏កាលមានការច្បាំងគ្នា ចំណែកពួកស្តេចមល្លក្សត្រ ក្រុងកុសិនារា គួរបានជ័យជំនះ ។ ព្រោះហេតុអ្វី ? ព្រោះពួកទេវតាដែលនាំគ្នាមកដើម្បីបូជាព្រះបរមធាតុ ត្រូវជាបក្ខពួករបស់ស្តេចមល្លក្សត្រ ក្រុងកុសិនារាទាំងនោះពិត ។ តែក្នុងព្រះបាលីមកត្រឹមតែប៉ុណ្ណោះថា ស្តេចមល្លក្សត្រ ក្រុងកុសិនារាពោលថា ព្រះមានព្រះភាគ បរិនិព្វានក្នុងគាមខេត្តរបស់ពួកយើង ពួកយើងនឹងមិនព្រមឲ្យចំណែកនៃព្រះសរីរធាតុនៃព្រះមានព្រះភាគ ដូច្នេះ ។

កាលបើពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះហើយ ទើបទោណព្រាហ្មណ៍ និយាយទៅនឹងពួកគណៈទូតទាំងនោះដូច្នេះថា

លោកទាំងឡាយដ៏ចម្រើន សូមស្តាប់ពាក្យរបស់ខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ (អ្នកពោលសរសើរគុណនៃខន្តី) មែនពិត ការប្រហារគ្នា (ច្បាំងគ្នា) ព្រោះតែចំណែកនៃព្រះសរីរធាតុ របស់ឧត្តមបុគ្គលនេះ មិនប្រពៃឡើយ ។ បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នា (គួរតែ) ស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសរីរធាតុ ឲ្យជា ៨ ចំណែក ព្រះស្តូបទាំងឡាយសូមផ្សាយទៅកាន់ទិសទាំងឡាយចុះ ពួកជនជាច្រើន គង់ជ្រះថ្លាចំពោះព្រះសម្ពុទ្ធមានចក្ខុ មិនលែង ។

អដ្ឋកថា : បទថា **កាលបើពោលយ៉ាងនេះហើយ ទើបទោណព្រាហ្មណ៍** សេចក្តីថា ទោណព្រាហ្មណ៍ស្តាប់រឿងការវិវាទ (ទាស់ទែងគ្នា) របស់ក្សត្រ និងព្រាហ្មណ៍ទាំងនោះហើយ ត្រិះរិះថា ពួកស្តេចទាំងនេះ បង្ករទាស់ទែងគ្នា ក្នុងស្ថានទីព្រះមានព្រះភាគ

បរិនិព្វាន ។ ជាការមិនសមគួរទេ ។ ការឈ្លោះទាស់ទែងគ្នានេះ គួរនឹងល្អមប៉ុណ្ណឹងហើយ យើងចាំបាច់ត្រូវតែរម្ងាប់ការទាស់ទែងគ្នានោះចេញ ដូច្នេះហើយ ក៏ទៅពោលសេចក្ដីនេះ ដល់ពួកគណៈស្ដេចទាំងនោះ ។ ពោលថា យ៉ាងណា ? ទោណព្រាហ្មណ៍ឈរក្នុងទីទួល (ខ្ពស់) បានពោលគាថា ដែលឈ្មោះថា **ទោណគ្គជិត** (ការបន្ទឺរបស់ទោណព្រាហ្មណ៍) ប្រមាណ ២ ភាណវារ ។ បណ្ដាភាណវារទាំង ២ នោះ ភាណវារមុន ពួកស្ដេចទាំងនោះមិនដឹងសូម្បីតែមួយបទ ។ ចប់ភាណវារទី ២ ពួកស្ដេចទាំងអស់និយាយគ្នាថា អ្នកដ៏ចម្រើន នោះមើលទៅដូចជាសំឡេងរបស់លោកអាចារ្យនេះៗ ហើយក៏នាំគ្នាស្ងាត់សំឡេង ។ បានឮថា ក្នុងផែនដីជម្ពូទ្វីប អ្នកដែលកើតក្នុងផ្ទះនៃត្រកូលដោយច្រើន ឈ្មោះថាមិនជាសិស្សរបស់ទោណព្រាហ្មណ៍នោះ មិនមានឡើយ ។ គ្រានោះ ទោណព្រាហ្មណ៍ដឹងថា ស្ដេចទាំងនោះ ស្ដាប់ពាក្យរបស់ខ្លួនហើយស្ងាត់សំឡេង នៅស្ងៀម ទើបបានពោលដដែល បានពោល ២ គាថានេះថា សុណន្តុ ភោន្តោ (លោកដ៏ចម្រើនទាំងឡាយ ចូរស្ដាប់ខ្ញុំ) ជាដើម ។

បណ្ដាបទទាំងនោះ បទថា អម្ហាកំ ពុទ្ធោ (ព្រះពុទ្ធជាម្ចាស់នៃយើង) ឬព្រះពុទ្ធរបស់ពួកយើង ។ បទថា អហុ ខន្តិវាទោ (ព្រះអង្គជាខន្តិវាទ) សេចក្ដីថា ព្រះអង្គសូម្បីមិនទាន់សម្រេចពុទ្ធភូមិ ទ្រង់បំពេញបារមីទាំងឡាយ ទ្រង់មិនធ្វើសេចក្ដីក្រោធក្នុងអ្នកដទៃៗ បានធ្វើតែខន្តិតែម្យ៉ាង ទ្រង់សរសើរខន្តិតែម្យ៉ាង កាលសោយព្រះជាតិជាខន្តិវាទិតាបស កាលជាធម្មបាលកុមារ កាលជាស្ដេចដំរីឆទ្ទន្ត កាលជាស្ដេចនាគឈ្មោះភូរិទត្តៈ កាលជាស្ដេចនាគឈ្មោះចម្បេយ្យកៈ កាលជាស្ដេចនាគឈ្មោះសង្ខបាលៈ កាលជាស្វាធំ និងក្នុងជាតកដទៃៗ ជាច្រើន ។ នឹងបាច់ពោលទៅថ្វី ឥឡូវនេះ ព្រះពុទ្ធរបស់ពួកយើង ទ្រង់សម្រេចលក្ខណៈភាពជាអ្នករឹងមាំក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ បានមានព្រះវាទៈរឿងខន្តិ ។ ការដែលពួកយើងនឹងមកប្រហារគ្នា ក្នុងរឿងហេតុចែកចំណែកព្រះសរីរៈរបស់ព្រះអង្គ ដែលជាបុគ្គលខ្ពង់ខ្ពស់បំផុត ដូចដែលពោលមកនេះ មិនល្អឡើយ ។ ពាក្យថា ន ហិ សាធុយំ កាត់បទថា ន ហិ សាធុ អយំ (នេះមិនជា

ការប្រព្រៃឡើយ) ។ បទថា សរីរភាគេ ប្រែថា និមិត្តនៃចំណែក របស់ព្រះសេរីរៈ អធិប្បាយថា ហេតុចំណែកនៃព្រះបរមធាតុ ។ បទថា សិយា សម្បហារោ (ការប្រហារគ្នា) លោកអធិប្បាយថា ការប្រហារគ្នាដោយអាវុធមិនល្អឡើយ ។ បទថា សព្វេវ ភោន្តោ សហិតា (បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នា ស្រុះស្រួលគ្នា) សេចក្ដីថា បពិត្រលោកទាំងឡាយដ៏ចម្រើន ពួក លោកទាំងអស់ ចូររួបរួមគ្នា កុំបែកគ្នាឡើយ ។ បទថា សមគ្គា (ព្រមព្រៀងគ្នា) បានដល់ ចូរជាអ្នកប្រជុំព្រមគ្នា និយាយពាក្យ ជាមួយគ្នា សាមគ្គីគ្នា ផ្សំកាយនិងផ្សំវាចាចុះ ។ បទថា សម្មោ-ទមានា (រីករាយរកគ្នា) បានដល់ ចូរជាអ្នករីករាយរកគ្នានឹងគ្នា សូម្បីផ្សំចិត្តចុះ ។ បទថា កពោមដ្ឋភាគេ (បែកព្រះសរីរធាតុ ឲ្យជា ៨ ចំណែក) សេចក្ដីថា ចូរបែកព្រះសរីរៈរបស់ព្រះមានព្រះ ភាគ ជា ៨ ចំណែក ។ បទថា ចក្ខុមតោ (មានចក្ខុ) បានដល់ ព្រះពុទ្ធទ្រង់មានចក្ខុដោយចក្ខុ ៥ ។ ទោណព្រាហ្មណ៍បានពោល ហេតុជាច្រើនឲ្យយល់គ្នាថា មិនមែនពួកលោកតែមួយពួកទេ ដែល

ជ្រះថ្លា សូម្បីមហាជនក៏ជ្រះថ្លា ជនទាំងនោះដែលឈ្មោះថា មិនគួរបានចំណែកព្រះសរីរធាតុមិនមាន សូម្បីតែមួយនាក់ ។



## ១០.ការចែកព្រះសរីរធាតុនៃព្រះមានព្រះភាគ

*ពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ទទួលពាក្យថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចែកព្រះសរីរធាតុនៃព្រះមានព្រះភាគឲ្យជា ៨ ចំណែកស្មើគ្នាចុះ ។*

*ទោណព្រាហ្មណ៍ ក៏ទទួលពាក្យរបស់ពួកគណៈទូតទាំងនោះ ដោយពាក្យថា អើអ្នកដ៏ចម្រើន អើអ្នកដ៏ចម្រើន ហើយក៏ចែកព្រះសរីរធាតុនៃព្រះមានព្រះភាគឲ្យជា ៨ ចំណែកស្មើគ្នា ហើយនិយាយនឹងពួកគណៈទូតទាំងនោះ ដូច្នេះថា លោកទាំងឡាយដ៏ចម្រើន សូមលោកទាំងឡាយដ៏ចម្រើន ឲ្យតុម្ពនេះដល់ខ្ញុំចុះ ខ្ញុំនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះតុម្ព ។ ពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ក៏បានឲ្យតុម្ពដល់ទោណព្រាហ្មណ៍ ។*

*អដ្ឋកថាថា : ពាក្យថា **ក៏ទទួលពាក្យរបស់ពួកគណៈទូតទាំងនោះ** សេចក្តីថា ព្រោះពួកគណៈដែលមកប្រជុំគ្នាអំពីទីនោះៗ ទាំងនោះ ទទួលស្តាប់ (យល់ព្រម) ទោណព្រាហ្មណ៍ទើបបែងចែកព្រះសរីរធាតុរបស់ព្រះមានព្រះភាគ ជា ៨ ចំណែកស្មើៗ គ្នា ។ លំដាប់សេចក្តីក្នុងរឿងនោះ មានដូច្នេះ ។*

បានឮមកថា ព្រោះស្តេចទាំងនោះយល់ព្រម ទោណ-ព្រាហ្មណ៍ ទើបបង្គាប់ឲ្យបើកមឈូសមាស ។ ស្តេចទាំងឡាយក៏មកឈរជិតមឈូសមាសនុ៎ះឯង ទតឃើញព្រះបរមធាតុទាំងឡាយ មានពណ៌ដូចជាពណ៌នៃមាស នាំគ្នាយំរៀបរាប់ថា បពិត្រព្រះមានព្រះភាគជាសព្វញ្ញូ ពីមុនខ្ញុំព្រះអង្គទាំងឡាយ បានឃើញព្រះសរីរៈរបស់ព្រះអង្គមានពណ៌ដូចមាស ប្រដាប់ដោយព្រះ-មហាបុរិសលក្ខណៈ ៣២ ប្រការ វិចិត្រដោយព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ ល្អរុងរឿងដោយព្រះអនុព្យញ្ជនៈ ៨០ ប្រការតែឥឡូវនេះ ក៏នៅសល់តែព្រះបរមធាតុ មានពណ៌ដូចជាពណ៌នៃមាស បពិត្រព្រះមានព្រះភាគ ការណ៍នេះមិនសមគួរដល់ព្រះ-អង្គឡើយ ។ សម័យនោះ សូម្បីទោណព្រាហ្មណ៍ដឹងថា ស្តេចទាំងនោះធ្វេសប្រហែស ក៏ឆក់យកព្រះចង្កូមកែវខាងស្តាំ រក្សាទុកក្នុងសំពត់ជួតក្បាល ។ តមក ខាងក្រោយទើបបែងចែកជា ៨ ចំណែកស្មើៗ គ្នា ព្រះបរមធាតុទាំងអស់ រួមបាន ១៦ នាឡិដោយនាឡិតាមប្រក្រតី ស្តេចមួយនគរៗបាន ២ នាឡិគ្រប់ល្មម ។

កាលទោណព្រាហ្មណ៍កំពុងបែងចែកព្រះបរមធាតុទាំងឯង ៗ សក្កទេវរាជ ជាស្តេចទេវតាត្រួតមើលថា អ្នកណាហ្ន៎ឆក់យកព្រះចង្កូមកែវខាងស្តាំរបស់ព្រះមានព្រះភាគ ដែលជាបច្ច័យនៃការត្រាស់រឿងសច្ចៈ ៤ ដើម្បីទ្រង់ប្រាថ្នាកាត់សេចក្តីសង្ស័យរបស់លោក ព្រមទាំងទេវលោកទៅ ក៏ទ្រង់ឃើញថា ព្រាហ្មណ៍ឆក់យកទៅ ។ ទ្រង់ត្រិះរិះថា សូម្បីព្រាហ្មណ៍ក៏មិនអាចធ្វើសក្ការៈដ៏គួរដល់ព្រះចង្កូមកែវបាន ចាំបាច់យើងនឹងកាន់យកព្រះចង្កូមកែវនោះទៅ ហើយទ្រង់កាន់យកអំពីចន្ទោះសំពត់ជួត បញ្ចុះទុកក្នុងប្រអប់មាស នាំទៅកាន់ទេវលោកប្រតិស្ឋានទុកក្នុងព្រះចូឡាមណីចេតិយ ។ ចំណែកព្រាហ្មណ៍ គ្រាបែងចែកព្រះបរមធាតុហើយ មិនឃើញព្រះចង្កូមកែវ តែព្រោះខ្លួនឆក់យកដោយកិរិយារបស់ចោរ ទើបមិនអាចសូម្បីតែនឹងសួរថា អ្នកណាឆក់យកព្រះចង្កូមកែវរបស់យើងទៅ ។ ឃើញតែការលើកទោសក្នុងខ្លួនឯងថា អ្នកឯងប៉ុណ្ណោះបែងចែកព្រះបរមធាតុមិនមែនឬ ហេតុដូចម្តេចអ្នកឯងមិនដឹងថា ព្រះបរមធាតុរបស់ខ្លួនមានអំពីមុនហ្ន៎ ។ លំដាប់នោះព្រាហ្មណ៍គិតថា នាឡិមាសនេះ ក៏មានគតិដូចព្រះបរមធាតុ យើង

នឹងធ្វើនាឡិមាសដែលវាល់ព្រះបរមធាតុរបស់ព្រះតថាគត ជាសថូប ហើយទើបទូលថា លោកទាំងឡាយដ៏ចម្រើន សូមមេត្តាប្រទាននាឡិនេះ ដល់ខ្ញុំចុះ ។

ឯពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ក៏បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាក្សត្រយើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុនៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុព្រះមានព្រះភាគ ។

ពួកមល្លក្សត្រតបថា ចំណែកព្រះសរីរធាតុរបស់ព្រះមានព្រះភាគ មិនមានទេ ព្រះសរីរធាតុទាំងឡាយរបស់ព្រះមានព្រះភាគ យើងចែកគ្នាអស់ហើយ ចូរអ្នកទាំងឡាយនាំយកព្រះអង្គារ (ធ្យូង) អំពីកន្លែងដែលថ្វាយព្រះភ្លើងនេះទៅចុះ ។

ពួកក្សត្រមោរិយៈទាំងនោះ ក៏នាំយកព្រះអង្គារអំពីកន្លែងដែលថ្វាយព្រះភ្លើងនោះទៅ ។

## ១១-ព្រះស្តូប ១០ ស្ថាន

គ្រានោះ ព្រះបាទមាគធអជាតសត្តុវេទេហិបុត្ត ទ្រង់បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងរាជគ្រឹះ ។

ឯពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងវេសាលី ។

ពួកក្សត្រ អ្នកក្រុងកបិលវត្ថុ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងកបិលវត្ថុ ។

ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្បៈ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងអល្លកប្បៈ ។

ពួកក្សត្រកោឡិយៈ អ្នករាមគ្រាម ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងរាមគ្រាម ។

ព្រាហ្មណ៍អ្នកវេដ្ឋទីបៈ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងដែនវេដ្ឋទីបៈ ។

ពួកមល្លក្សត្រអ្នកក្រុងបាវា ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងបាវា ។

ពួកមល្លក្សត្រ ក្នុងក្រុងកុសិនារា ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងកុសិនារា ។

ទោណព្រាហ្មណ៍ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះតុម្ព ។

ពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះអង្គារ ក្នុងក្រុងបិប្ផលិវ័ន ។

រួមព្រះស្តូបតម្កល់ព្រះសរីរធាតុទាំងអស់មាន ៨
ជាគម្រប់ ៩ នឹងព្រះស្តូបដែលតម្កល់ព្រះតុម្ព,
ជាគម្រប់ ១០ នឹងព្រះស្តូបដែលតម្កល់ព្រះអង្គារ,

ឯធាតុនិធាន (ទីបញ្ចុះព្រះធាតុ) នេះ ធ្លាប់មានមកហើយយ៉ាងនេះ ។

## ១២_ព្រះសរីរធាតុ

ព្រះសរីរធាតុរបស់ព្រះសម្ពុទ្ធមានចក្ខុ មានចំនួន ៨ ទោណៈ ព្រះសរីរធាតុ ៧ ទោណៈ ជនទាំងឡាយធ្វើសក្ការបូជាក្នុងជម្ពូទ្វីប ព្រះសរីរធាតុរបស់ព្រះសម្ពុទ្ធ ជាបុរសប្រសើរខ្ពង់ខ្ពស់ ១ ទោណៈទៀត ពួកនាគរាជ ធ្វើសក្ការបូជាក្នុងរាមគ្រាម ។

ព្រះទាឋា (ព្រះចង្កូម) ១ ពួកទេវតានាំយកទៅបូជា ព្រះទាឋា ១ ទៀត ពួកជនធ្វើសក្ការបូជាក្នុងគន្ធារបុរី ព្រះទាឋា ១ ទៀត ពួកជនធ្វើសក្ការបូជាក្នុងដែនរបស់ស្តេចកលិង្គ ព្រះទាឋា ១ ទៀត ពួកនាគនាំយកទៅធ្វើសក្ការបូជា ។

ហេតុតែតេជះ នៃព្រះសរីរធាតុរបស់ព្រះមានព្រះភាគនោះឯង មហាប្រឹថពីនេះ ក៏បានប្រដាប់ដោយគ្រឿងបូជាវិសេស ឯព្រះសរីរធាតុរបស់ព្រះសម្ពុទ្ធ មានចក្ខុនេះ គឺពួកសត្វដែលធ្លាប់ធ្វើនូវគ្រឿងសក្ការៈដ៏លើសលប់ទាំងឡាយ បានធ្វើសក្ការៈដោយល្អហើយយ៉ាងនេះ ។ ស្តេចទេវតា ស្តេចនាគ និងស្តេចមនុស្ស បានបូជាហើយចំពោះព្រះសម្ពុទ្ធជាម្ចាស់ ទាំងពួកមនុស្សអ្នកប្រសើរ ក៏បានធ្វើសក្ការបូជា ហើយដូច្នោះដែរ ព្រោះហេតុនោះ អ្នកទាំងឡាយបូរផ្គង

អញ្ជលីឡើង ថ្វាយបង្គំព្រះសម្ពុទ្ធជាម្ចាស់នោះចុះ ព្រោះថា ព្រះសម្ពុទ្ធជាម្ចាស់ទាំងឡាយ ជាបុគ្គលរកបានក្រ ដោយរយនៃកប្បទាំងឡាយ (**ពុទ្ធា ហវេ កប្បសតេហិ ទុល្លភាតិ**) ។

ព្រះទន្តទាំង ៤០ គត់ក្តី កេសាក្តី ព្រះលោមាក្តី ទាំងអស់ពួកទេវតាដែលនៅក្នុងចក្រវាឡតៗ គ្នានាំយកទៅមួយៗ ម្នាក់ ។

បាត្រ ឈើប្រត់ និងចីវររបស់ព្រះមានព្រះភាគ តម្កល់ទុកក្នុងដែនវជិរ, ស្បង់តម្កល់ទុកក្នុងផ្ទះនៃត្រកូល, គ្រឿងកម្រាលតម្កល់ទុកក្នុងក្រុងឈ្មោះសីលៈ ។

ធម្មក្រកនិងកាយពន្ធ (វត្ថពន្ធចង្កេះ) តម្កល់ទុកនៅក្នុងក្រុងបាដលីបុត្ត ឧទកសាដក តម្កល់ទុកនៅក្រុងចម្បា ព្រះឧណ្ណាលោម (រោមចញ្ចើម) តម្កល់ទុកក្នុងដែនកោសល ។

សំពត់កាសាវៈ តម្កល់ទុកក្នុងព្រហ្មលោក ឈ្នួតតម្កល់ទុកក្នុងឋានត្រៃត្រឹង្ស ស្នាមព្រះបាទដ៏ប្រសើរ ដែលមិនបាត់ទៅ តម្កល់ទុកលើថ្ម សំពត់និសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ គ្រឿងកម្រាលតម្កល់ទុកក្នុងដែនឈ្មោះទេវៈ ក្នុងកាលនោះ ។

កាលនោះ ដែកភ្លើង តម្កល់ទុកក្នុងក្រុងមិថិលា តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ កាំបិតកោរនិងបំពង់ម្ជុល តម្កល់ទុកក្នុងឥន្ទបត្តបុរី ។

កាលនោះ គ្រឿងបរិក្ខារដ៏សេសទាំងឡាយតម្កល់ទុក ក្នុងជនបទជាទីបំផុត ពួកមនុស្សតែងបូជាចំពោះគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះមុនីតែងប្រើប្រាស់ ។

ការផ្សាយទៅនៃព្រះធាតុ របស់ព្រះមហេសី ព្រះនាមគោតម ក្នុងកាលនោះ ជាប្រពៃណីពីបូរាណ (នៃព្រះពុទ្ធទាំងឡាយ) សម្រាប់ទុកអនុគ្រោះ ស្រោចស្រង់សត្វទាំងឡាយជាខាងក្រោយ ។

## ១៣_ការបូជារបស់ព្រះបាទអជាតសត្តុ

ក្នុងអដ្ឋកថា ពោលទុកថា ៖

ព្រះបាទអជាតសត្តុ បានទ្រង់សាងព្រះសថូបបញ្ចុះព្រះសរីរធាតុ របស់ព្រះមានព្រះភាគ និងការធ្វើមហកម្មក្នុងក្រុងរាជគ្រឹះ ។ សួរថា ទ្រង់បានធ្វើយ៉ាងណា ? ឆ្លើយថា ទ្រង់បានធ្វើការមហកម្មតាំងពីក្រុងកុសិនារាដរាបដល់ក្រុងរាជគ្រឹះអស់រយៈផ្លូវ

២៥ យោជន៍ ។ ក្នុងចន្លោះនោះ ទ្រង់ឲ្យធ្វើផ្លូវទទឹង ៨ ឧសភៈ ពង្រាបផែនដីរាបស្មើបន្ទាប់ឲ្យធ្វើការបូជាក្នុងផ្លូវស្ទួន ២៥ យោជន៍ ដូចដែលពួកស្តេចមល្លៈ បន្ទាប់ឲ្យធ្វើការបូជាចន្លោះមកុដពន្ធនចេតិយ និងសណ្ឋាគារ ទ្រង់ពង្រីកទៅក្នុងចន្លោះផ្សារ ក្នុងទីគ្រប់កន្លែង ដើម្បីអនុគ្រោះដល់មនុស្សលោក ទ្រង់ឲ្យឡោមព័ទ្ធព្រះបរមធាតុដែលបញ្ចុះទុកក្នុងមឈូសមាស ដោយរបងលំពែង ឲ្យមនុស្សប្រជុំគ្នាជាបរិមណ្ឌល ៥០០ យោជន៍ ក្នុងដែនរបស់ព្រះអង្គ ។ មនុស្សទាំងនោះទទួលព្រះបរមធាតុ លេងសាធុកីឡាចេញចាកក្រុងកុសិនារា ជួបឃើញផ្កាឈើមានពណ៌ហាក់បីដូចជាមាសក្នុងទីណាៗ ក៏បេះផ្កាឈើទាំងនោះក្នុងទីនោះៗ បូជាព្រះបរមធាតុក្នុងចន្លោះលំពែង វេលាផ្កាឈើទាំងនោះអស់ហើយក៏ដើរតទៅ កាលដល់ហានទីមនៃរថក្នុងទីបំផុត ក៏នាំគ្នាលេងសាធុកីឡាមួយកន្លែងៗ ៧ ថ្ងៃ កាលមនុស្សទទួលព្រះបរមធាតុនាំគ្នាមកដោយអាការយ៉ាងនេះ វេលាក៏កន្លងទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ពួកមិច្ឆាទិដ្ឋិនាំគ្នាតិះដៀលថា តាំងពីព្រះសមណគោតមបរិនិព្វាន ពួកយើងក៏ក្រវល់ក្រវាយ ដោយការលេងសាធុកីឡា

ដោយពលការ ការងាររបស់ពួកយើងវិនាសទៅអស់ហើយ ក៏មានចិត្តប្រទូស ទៅកើតក្នុងអបាយប្រមាណ ៨៦,០០០ នាក់ ។

ពួកព្រះខីណាស្រព រលឹកហើយឃើញថា មហាជនក្តៅក្រហាយចិត្ត នាំគ្នាកើតក្នុងអបាយ ហើយត្រិះរិះថា ពួកស្តេចនឹងឲ្យស្តេចសក្កទេវរាជ ទ្រង់ធ្វើឧបាយនាំព្រះបរមធាតុមក ដូច្នេះទើបនាំគ្នាទៅកាន់សំណាក់ស្តេចសក្កទេវរាជនោះ ទូលប្រាប់រឿងនោះ ហើយទូលថា ព្រះមហារាជ សូមទ្រង់មេត្តាធ្វើឧបាយនាំព្រះបរមធាតុមកចុះ ។ ស្តេចសក្កៈ ត្រាស់ថា លោកម្ចាស់ ដែលឈ្មោះថា បុថុជ្ជនដែលមានសទ្ធាស្មើដោយព្រះបាទអជាតសត្តុមិនមានទេ ព្រះអង្គទ្រង់មិនជឿយើងទេ ក៏ប៉ុន្តែថា ខ្ញុំនឹងសម្តែងវត្ថុដែលគួរភ័យខ្លាច ។ ដូចមារដែលគួរភ័យខ្លាច នឹងប្រកាសឲ្យលាន់ឮ នឹងធ្វើជាអ្នកជម្ងឺញ័រទទ្រើក ដូចអ្នកខ្មោចចូល សូមលោកម្ចាស់ទូលថា មហាបពិត្រ ពួកអមនុស្សគេក្រោធខឹង មេត្តាឲ្យនាំព្រះបរមធាតុទៅដោយរហ័ស ដោយឧបាយយ៉ាងនេះ ស្តេចលោកក៏នឹងទ្រង់ឲ្យនាំព្រះបរមធាតុទៅ ។ គ្រានោះឯង ស្តេចសក្កៈក៏បានទ្រង់ធ្វើគ្រប់វត្ថុ គ្រប់យ៉ាងដូចពោលនោះ ចំណែកព្រះថេរៈ

ទាំងឡាយក៏ចូលទៅគាល់ព្រះរាជា ទូលថា ថ្វាយព្រះពរ ពួកអមនុស្សគេក្រោធខឹង មេត្តាឲ្យនាំព្រះបរមធាតុទៅចុះ ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ ចិត្តរបស់ញោមមិនទាន់ត្រេកអរមុនទេ តែកាលជាដូច្នោះ ក៏នឹងឲ្យគេនាំព្រះបរមធាតុទៅ ។ ក្នុងថ្ងៃទី ៧ មនុស្សទាំងឡាយក៏នាំព្រះបរមធាតុមកដល់ ។ ស្ដេចទ្រង់ទទួលព្រះបរមធាតុដែលមកដោយអាការយ៉ាងនោះ ទ្រង់សាងព្រះសថូបទុកក្នុងក្រុងរាជគ្រឹះ និងទ្រង់ធ្វើមហកម្ម សូម្បីពួកស្ដេចទាំងឡាយដទៃៗ ក៏នាំទៅតាមសមគួរដល់កម្លាំងរបស់ខ្លួនៗ សាងព្រះសថូបទុកក្នុងស្ថានរបស់ខ្លួនៗ ហើយធ្វើមហកម្ម ។

បទថា ឯវមេតំ ភូតបុព្វំ (ធ្លាប់មានមកហើយយ៉ាងនេះ) សេចក្ដីថា ការបែងចែកព្រះបរមធាតុ និងការសាងព្រះសថូប ១០ កន្លែងនេះ ធ្លាប់មានមកហើយក្នុងជម្ពូទ្វីបដោយប្រការដូច្នេះ ។ ខាងក្រោយព្រះសង្គីតិកាចារ្យទាំងឡាយទើបពោលទុក ។


ទីព្រះគន្ធកុដិ  លើភ្នំគិជ្ឈកូដ


ទីតាំងព្រះចេតីយ៍  នៅក្រុងរាជគ្រឹះ

## កូដាគារសាលា នាព្រៃមហាវ័ន



## គយាសីសប្រទេស



# III. វេមត្តកថា

## ១.វេមត្តៈ ៨ ប្រការ

*ព្រះពុទ្ធ ២៥ ព្រះអង្គ ដែលចង្អុលបង្ហាញទុកក្នុងពុទ្ធវង្ស ទាំងអស់នេះ គប្បីជ្រាបថា មានវេមត្តៈ គឺសេចក្តីផ្សេងគ្នា ៨ យ៉ាង គឺ អាយុវេមត្តៈ បមាណវេមត្តៈ កុលវេមត្តៈ បធានវេមត្តៈ រស្មីវេមត្តៈ យានវេមត្តៈ ពោធិរុក្ខវេមត្តៈ បល្លង្កវេមត្តៈ ។*

### ១.១ អាយុវេមត្តៈ

*បណ្តាវេមត្តៈទាំងនោះ ឈ្មោះថា អាយុវេមត្តៈ សេចក្តីផ្សេងគ្នានៃព្រះជន្ម បានដល់ ព្រះពុទ្ធអង្គខ្លះ ព្រះអង្គមានព្រះជន្មវែង ព្រះពុទ្ធអង្គខ្លះមានព្រះជន្មខ្លី ។*

*ពិតយ៉ាងនោះ ព្រះពុទ្ធ ៩ ព្រះអង្គទាំងនេះ គឺ ព្រះទីបង្ករ ព្រះកោណ្ឌញ្ញៈ ព្រះអនោមទស្សី ព្រះបទុមៈ ព្រះបទុមុត្តរៈ ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថៈ ព្រះតិស្សៈ មានព្រះជន្មាយុ ១ សែនឆ្នាំ ។*

ព្រះពុទ្ធ ៨ ព្រះអង្គទាំងនេះ គឺ ព្រះមង្គលៈ ព្រះសុមនៈ ព្រះសោភិតៈ ព្រះនារទៈ ព្រះសុមេធៈ ព្រះសុជាតៈ ព្រះបិយទស្សី ព្រះបុស្សៈ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះរេវតៈ ព្រះវេស្សភូ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ។

ព្រះមានព្រះភាគវិបស្សី មានព្រះជន្មាយុ ៨ ម៉ឺន ឆ្នាំ ។

ព្រះពុទ្ធ ៤ ព្រះអង្គទាំងនេះគឺ ព្រះសិខី ព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ, បួនម៉ឺនឆ្នាំ, បីម៉ឺនឆ្នាំ, ពីរម៉ឺនឆ្នាំ តាមលំដាប់ ។

ចំណែកព្រះមានព្រះភាគរបស់យើង មានព្រះជន្មាយុ ១០០ ឆ្នាំ ។

ប្រមាណអាយុ មិនមានប្រមាណ ដោយយុគរបស់ព្រះពុទ្ធទាំងឡាយ អ្នកប្រកបដោយកម្មដែលធ្វើឲ្យអាយុវែង នេះឈ្មោះថា អាយុវេមត្តៈ របស់ព្រះពុទ្ធ ២៥ ព្រះអង្គ ។

## ១.២ បមាណវេមត្តៈ

*ដែលឈ្មោះថា បមាណវេមត្តៈ សេចក្តីផ្សេងគ្នានៃប្រមាណ បានដល់ ព្រះពុទ្ធអង្គខ្លះខ្ពស់ ព្រះពុទ្ធអង្គខ្លះទាប ។ ពិតយ៉ាងនោះ ព្រះពុទ្ធ គឺ ព្រះទីបង្ករ ព្រះរេវតៈ ព្រះបិយទស្សី ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះវិបស្សី មានព្រះសរីរៈកម្ពស់ ៨០ ហត្ថ ។*

*ព្រះពុទ្ធ គឺ ព្រះកោណ្ឌញ្ញៈ ព្រះមង្គលៈ ព្រះនារទៈ ព្រះសុមេធៈ មានព្រះវរកាយកម្ពស់ ៨៨ ហត្ថ ។*

*ព្រះសុមនសម្ពុទ្ធ មានព្រះសរីរៈកម្ពស់៩០ ហត្ថ ។*

*ព្រះពុទ្ធ គឺ ព្រះសោភិតៈ ព្រះអនោមទស្សី ព្រះបទុមៈ ព្រះបទុមុត្តរៈ ព្រះបុស្សៈ មានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ។*

*ព្រះសុជាតសម្ពុទ្ធ មានព្រះសរីរៈកម្ពស់ ៥០ ហត្ថ ។*

*ព្រះពុទ្ធ គឺ ព្រះសិទ្ធត្ថៈ ព្រះតិស្សៈ និង ព្រះវេស្សភូ មានព្រះវរកាយកម្ពស់ ៦០ ហត្ថ ។*

*ព្រះសិខីសម្ពុទ្ធ មានព្រះសរីរៈកម្ពស់ ៧០ ហត្ថ ។*

*ព្រះពុទ្ធគឺ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និង ព្រះកស្សបៈ ព្រះវរកាយកម្ពស់ ៤០ ហត្ថ ៣០ ហត្ថ ២០ ហត្ថ តាមលំដាប់ ។*

អម្ហាកំ ភគវា អដ្ឋារសហត្ថុព្វេធោ អហោសិ : ចំណែកព្រះមានព្រះភាគរបស់យើងកម្ពស់ ១៨ ហត្ថ ។

នេះឈ្មោះថា បមាណវេមត្តៈ របស់ព្រះពុទ្ធ ២៥ ព្រះអង្គ ។

## ១.៣ កុលវេមត្តៈ

ដែលឈ្មោះថា កុលវេមត្តៈ សេចក្ដីផ្សេងគ្នានៃត្រកូល បានដល់ ព្រះពុទ្ធអង្គខ្លះ ព្រះអង្គកើតក្នុងត្រកូលក្សត្រិយ៍ ព្រះពុទ្ធអង្គខ្លះកើតក្នុងត្រកូលព្រាហ្មណ៍ ពិតយ៉ាងនោះ ព្រះសម្មាសម្ពុទ្ធ គឺ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និង ព្រះកស្សបៈ កើតក្នុងត្រកូលព្រាហ្មណ៍ ។

ព្រះពុទ្ធ ២២ ព្រះអង្គដ៏សេស មានព្រះពុទ្ធទីបង្ករជាដើម មានព្រះពុទ្ធគោតមជាទីបំផុត កើតក្នុងត្រកូលក្សត្រិយ៍ ទាំងនោះ ។

នេះឈ្មោះថា កុលវេមត្តៈរបស់ព្រះពុទ្ធ ២៥ ព្រះអង្គ ។

## ១.៤ បធានវេមត្តៈ

ដែលឈ្មោះថា **បធានវេមត្តៈ** សេចក្ដីផ្សេងគ្នានៃការតាំងសេចក្ដីព្យាយាម បានដល់ ព្រះពុទ្ធ គឺ ព្រះទីបង្ករ ព្រះកោណ្ឌញ្ញៈ

ព្រះសុមនៈ ព្រះអនោមទស្សី ។ ព្រះសុជាតៈ ព្រះសិទ្ធត្ថៈ និង ព្រះកកុសន្ធៈ ទ្រង់បំពេញព្យាយាម ១០ ខែ ។

មង្គលសុមេធតិស្សសិខីធំ អដ្ឋមាសិកា ។

ព្រះពុទ្ធ គឺ ព្រះមង្គលៈ ព្រះសុមេធៈ ព្រះតិស្សៈ និង ព្រះសិខី ទ្រង់បំពេញព្យាយាម ៨ ខែ ។

ព្រះរេវតសម្ពុទ្ធ ៧ ខែ ។ ព្រះសោភិតសម្ពុទ្ធ ៤ ខែ ។

ព្រះពុទ្ធ គឺ ព្រះបទុមៈ ព្រះអត្ថទស្សី និង ព្រះវិបស្សី កន្លះខែ ។

ព្រះពុទ្ធ គឺ ព្រះនារទៈ ព្រះបទុមុត្តរៈ ព្រះធម្មទស្សី និង ព្រះកស្សបៈ ៧ ថ្ងៃ ។

ព្រះពុទ្ធ គឺ ព្រះបិយទស្សី ព្រះបុស្សៈ ព្រះវេស្សភូ និង ព្រះកោនាគមនៈ ៦ ខែ ។

ព្រះពុទ្ធរបស់យើងទ្រង់បំពេញព្យាយាម ៦ ឆ្នាំ ។

នេះឈ្មោះថា បធានវេមត្តៈ ។

## ១.៥ រស្មីវេមត្តៈ

*ដែលឈ្មោះថា **រស្មីវេមត្តៈ** សេចក្ដីផ្សេងគ្នានៃព្រះរស្មី បានឮថា ព្រះមង្គលសម្មាសម្ពុទ្ធ មានព្រះរស្មីនៃព្រះសរីរៈផ្សាយទៅក្នុងមួយម៉ឺនលោកធាតុ ។*

*ព្រះបទុមុត្តរសម្ពុទ្ធ ផ្សាយទៅ ១២ យោជន៍ ។*

*ព្រះវិបស្សី ផ្សាយទៅ ៧ យោជន៍ ។*

*ព្រះសិខីសម្ពុទ្ធ ផ្សាយទៅ ៣ យោជន៍ ។*

*ព្រះកកុសន្ធសម្ពុទ្ធ ផ្សាយទៅ ១០ យោជន៍ ។*

*ព្រះមានព្រះភាគ របស់យើង ប្រមាណមួយព្យាមដោយជុំវិញ ។*

*ព្រះពុទ្ធក្រៅនោះ មិនប្រាកដ ។*

*នេះឈ្មោះថា រស្មីវេមត្តៈ ។*

## ១.៦ យានវេមត្តៈ

*ដែលឈ្មោះថា **យានវេមត្តៈ** សេចក្ដីផ្សេងគ្នានៃយាន បានដល់ ព្រះពុទ្ធអង្គខ្លះ ព្រះអង្គចេញអភិនេស្រ្កមណ៍ ដោយ*

យានគឺដំរី ព្រះអង្គខ្លះ ដោយយានគឺសេះ ព្រះអង្គខ្លះ ដោយយានគឺរថ ដំណើរដោយព្រះបាទ ប្រាសាទ និង គ្រែស្នែងជាដើម យ៉ាងណាមួយ ។

ពិតមែន ព្រះពុទ្ធ គឺ ព្រះទីបង្ករ ព្រះសុមនៈ ព្រះសុមេធៈ ព្រះបុស្សៈ ព្រះសិខី និងព្រះកោនាគមនៈ ចេញអភិនេស្ក្រមណ៍ ដោយយាន គឺ ដំរី ។

ព្រះកោណ្ឌញ្ញៈ ព្រះរេវតៈ ព្រះបទុមៈ ព្រះបិយទស្សី ព្រះវិបស្សី និង ព្រះកកុសន្ធៈ ដោយយានគឺរថ ។

ព្រះមង្គលៈ ព្រះសុជាតៈ ព្រះអត្ថទស្សី ព្រះតិស្សៈ និង ព្រះគោតមៈ ដោយយានគឺសេះ ។

ព្រះអនោមទស្សី ព្រះសិទ្ធត្ថៈ ព្រះវេស្សភូ ដោយយានគឺគ្រែស្នែង ។

ព្រះនារទៈ ស្តេចយាងចេញអភិនេស្ក្រមណ៍ ដោយព្រះបាទ។

ព្រះសោភិតៈ ព្រះបទុមុត្តរៈ ព្រះធម្មទស្សី និងព្រះកស្សបៈ យាងចេញអភិនេស្ក្រមណ៍ដោយប្រាសាទ ។

នេះឈ្មោះថា យានវេមត្តៈ ។

## ១.៧ ពោធិរុក្ខវេមត្តៈ

*ដែលឈ្មោះថា ពោធិរុក្ខវេមត្តៈ សេចក្ដីផ្សេងគ្នានៃពោធិព្រឹក្ស បានដល់ ព្រះមានព្រះភាគ ទីបង្ករ មានពោធិព្រឹក្ស ឈ្មោះដើម* ***កបិតន***[១] *(ល្មៀប) ។*

*ព្រះមានព្រះភាគ កោណ្ឌញ្ញៈ មានពោធិព្រឹក្ស ឈ្មោះដើម* ***សាលកល្យាណី*** *។*

*ព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈ មានពោធិព្រឹក្ស ឈ្មោះដើម**នាគៈ** (ដើមខ្ទឹង) ។*

*ព្រះអនោមទស្សី មានពោធិព្រឹក្សឈ្មោះដើម**អជ្ជុនៈ**(អង្គ្រង)។*

*ព្រះបទុមៈ និង ព្រះនារទៈ មានពោធិព្រឹក្ស ឈ្មោះដើម មហាសោណៈ (ម្រុំ) ។*

*ព្រះបទុមុត្តរៈ មានពោធិព្រឹក្ស ឈ្មោះដើម**សលឡ**(ស្រល់)។*

*ព្រះសុមេធៈ មានពោធិព្រឹក្ស ឈ្មោះដើម**នីប** (ស្ដៅ) ។*

*ព្រះសុជាតៈ មានពោធិព្រឹក្ស ឈ្មោះដើមវេឡុ (ដើមឫស្សី) ។*

*ព្រះបិយទស្សី មានពោធិព្រឹក្សឈ្មោះដើមកកុធៈ (ថ្ងាន់) ។*

---

*១- បិប្ផលីតិ បិលក្ខកបីតនរុក្ខោ ពោធិ ។ អដ្ឋកថាពុទ្ធវង្ស ។*

ព្រះអត្ថទស្សី ពោធិព្រឹក្ស ឈ្មោះដើមចម្បកៈ (ចំប៉ា) ។

ព្រះធម្មទស្សី ពោធិព្រឹក្ស ឈ្មោះដើមរត្តកុរវក (ទន្ទាប់) ។

ព្រះសិទ្ធត្ថៈ ពោធិព្រឹក្ស ឈ្មោះដើមកណ្ណិការៈ (ដើមកណ្ណិការ) ។

ព្រះតិស្សៈ ពោធិព្រឹក្ស ឈ្មោះដើមអសន (ដើមធ្នង់) ។

ព្រះបុស្សៈ ពោធិព្រឹក្ស ឈ្មោះដើមអាលមក (ដើមកន្ទួតព្រៃ) ។

ព្រះវិបស្សី ពោធិព្រឹក្ស ឈ្មោះដើមបាដលី (ដើមសង្កែ) ។

ព្រះសិខី ពោធិព្រឹក្ស ឈ្មោះដើមបុណ្ឌរីកៈ (ដើមស្វាយស) ។

ព្រះវេស្សភូ ពោធិព្រឹក្ស ឈ្មោះដើមសាលៈ (ដើមរាំង) ។

ព្រះកកុសន្ធៈ ពោធិព្រឹក្ស ឈ្មោះដើមសិរីសៈ (ច្រេស) ។

ព្រះកោនាគមនៈ ពោធិព្រឹក្ស ឈ្មោះដើមឧទុម្ពរ (ល្វា) ។

ព្រះកស្សបៈ ពោធិព្រឹក្ស ឈ្មោះដើមនិគ្រោធ (ជ្រៃ) ។

ព្រះគោតមៈ ពោធិព្រឹក្ស ឈ្មោះដើមអស្សត្ថៈ ។

នេះឈ្មោះថា ពោធិវេមត្តៈ ។

## ១.៨ បល្លង្កវេមត្តៈ

ដែលឈ្មោះថា បល្ល័ង្កវេមត្តៈ សេចក្តីផ្សេងគ្នានៃបល្ល័ង្ក បានដល់ ព្រះពុទ្ធ គឺ ព្រះទីបង្ករ ព្រះរេវតៈ ព្រះបិយទស្សី ព្រះអត្ថទស្សី ព្រះធម្មទស្សីនិងព្រះវិបស្សី មានបល្ល័ង្កកម្ពស់ ៥៣ ហត្ថ ។ ព្រះកោណ្ឌញ្ញៈ ព្រះមង្គលៈ ព្រះនារទៈ និង ព្រះសុមេធៈ មានបល្ល័ង្កកម្ពស់ ៥៧ ហត្ថ ។ ព្រះសុមនៈ មានបល្ល័ង្កកម្ពស់ ៦០ ហត្ថ ។ ព្រះសោភិតៈ ព្រះអនោមទស្សី ព្រះបទុមៈ ព្រះបទុមុត្តរៈ និងព្រះបុស្សៈមានបល្ល័ង្កកម្ពស់ ៣៨ ហត្ថ ។ ព្រះសុជាតៈ មានបល្ល័ង្កកម្ពស់ ៣២ ហត្ថ ។ ព្រះសិទ្ធត្ថៈ ព្រះតិស្សៈ និងព្រះវេស្សភូ មានបល្ល័ង្កកម្ពស់ ៤០ ហត្ថ ។ ព្រះសិខី មានបល្ល័ង្កកម្ពស់ ៣២ ហត្ថ ។ ព្រះកកុសន្ធៈ មានបល្ល័ង្កកម្ពស់ ២៦ ហត្ថ ។ ព្រះកោនាគមនៈ មានបល្ល័ង្កកម្ពស់ ២០ ហត្ថ ។ ព្រះកស្សបៈ មានបល្ល័ង្ក ១៥ ហត្ថ ។

ព្រះគោតមៈ មានបល្ល័ង្ក ១៤ ហត្ថ ។

នេះឈ្មោះថា បល្ល័ង្កវេមត្តៈ ។

ទាំងនេះឈ្មោះថា វេមត្តៈ ៨ ។

# IV. ផ្សេងៗ

## ១-ស្ថានទីព្រះពុទ្ធទ្រង់មិនលះ

ក៏ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនលះស្ថានទី ៤ កន្លែង ។ ពិតមែន ពោធិបល្ល័ង្ក ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនលះ ជាស្ថានទីតែមួយនុ៎ះឯង ។ ទ្រង់មិនលះការប្រកាសព្រះធម្មចក្ក ក្នុងឥសិបតនមិគទាយវ័ន, ទ្រង់មិនលះស្ថានទីជាន់ព្រះបាទជាដំបូង ជិតទ្វារសង្កស្សនគរ កាលស្ដេចចុះចាកទេវលោក, ទ្រង់មិនលះស្ថានទីដាក់ជើងគ្រែ ៤ នៃព្រះគន្ធកុដិ ក្នុងព្រះវិហារជេតពន, ព្រះវិហារតូចក៏មាន ធំក៏មាន ទាំងព្រះវិហារ ក៏មិនលះ ទាំងព្រះនគរក៏មិនលះ ។

## ២-ការកំណត់សហជាតនិងកំណត់នក្ខត្តឫក្ស

នៅមានប្រការមួយទៀត ព្រះសង្គីតិកាចារ្យទាំងឡាយ សម្ដែងកំណត់សហជាត និងកំណត់នក្ខត្តឫក្សរបស់ព្រះមានព្រះភាគនៃយើងប៉ុណ្ណោះ ។

វត្ថុដែលកើតរួមគ្នានឹងព្រះសព្វញ្ញូពោធិសត្វ របស់យើង មាន ៧ ទាំងនេះ គឺ ព្រះមាតាព្រះរាហុល ១ ព្រះអានន្ទត្ថេរ: ១ ព្រះឆន្ន: ១ សេះកណ្ឋក: ១ រណ្តៅកំណប់ទ្រព្យ ១ ព្រះមហាពោធិព្រឹក្ស ១ ព្រះកាឡុទាយី ១ នេះឈ្មោះថា កំណត់សហជាត ។

ដោយនក្ខត្តប្ញក្ស គឺ ផ្កាយនក្ខត្តប្ញក្សក្នុងខែឧត្តរាសាឡ្ហ (ខែអាសាឍ) ព្រះមហាបុរសយាងចុះកាន់ព្រះគភ៌ ព្រះជននី ស្តេចចេញមហាភិនិស្រ្កម ទ្រង់ប្រកាសព្រះធម្មចក្ក ទ្រង់សម្តែងយមកបាដិហារ្យ ។

ដោយនក្ខត្តប្ញក្ស គឺ ផ្កាយនក្ខត្តប្ញក្ស ក្នុងខែវិសាខ ទ្រង់ប្រសូត ត្រាស់ដឹង និង បរិនិព្វាន ។

ដោយនក្ខត្តប្ញក្ស គឺ ផ្កាយនក្ខត្តប្ញក្សខែមាឃ ព្រះអង្គទ្រង់ប្រជុំព្រះសាវក និង ទ្រង់ដាក់អាយុសង្ខារ,

ដោយនក្ខត្តប្ញក្ស គឺ ផ្កាយនក្ខត្តប្ញក្សខែអស្សុជ ស្តេចចុះចាកទេវលោក នេះឈ្មោះថា កំណត់នក្ខត្តប្ញក្ស ។

## ៣-រឿងធម្មតារបស់ព្រះពុទ្ធ

ឥឡូវនេះ យើងនឹងប្រកាសធម្មតាទូទៅរបស់ព្រះពុទ្ធ គ្រប់ព្រះអង្គ ធម្មតារបស់ព្រះពុទ្ធគ្រប់ព្រះអង្គមាន ៣០ គត់ គឺ

១-ព្រះពោធិសត្វមានភពទីបំផុត មានសម្បជញ្ញៈ ដឹងខ្លួន ចុះកាន់ព្រះគភ៌របស់ព្រះជននី

២-ព្រះពោធិសត្វគង់ចម្រើនសមាធិ ក្នុងព្រះគភ៌របស់ជននី បែរព្រះភ័ក្ត្រចេញទៅខាងក្រៅ

៣-ព្រះជននីរបស់ព្រះពោធិសត្វឈរប្រសូត

៤-ព្រះពោធិសត្វចេញចាកព្រះគភ៌ព្រះជននី ក្នុងព្រៃប៉ុណ្ណោះ

៥-ព្រះពោធិសត្វដាក់ព្រះបាទចុះលើផែនមាស បែរព្រះ-ភក្ត្រទៅទិសឧត្តរ ឈានព្រះបាទ ៧ ជំហាន ទ្រង់ក្រឡេកមើលទិសទាំង ៤ ទើបបញ្ចេញសីហនាទ (ថា អាត្មាអញ ជាកំពូលរបស់លោក អាត្មាអញជាបុគ្គលចម្បងជាងលោក អាត្មាអញជាបុគ្គលប្រសើរជាងសត្វលោក ជាតិនេះ ជាជាតិទីបំផុត ឥឡូវនេះ មិនមានភពថ្មីទៀតឡើយ)

៦-ព្រះមហាសត្វ ក៏ទ្រង់ឃើញនិមិត្ត ៤ ហើយចេញមហាភិនិក្រ្ខម ពេលព្រះឱរសប្រសូត

៧-ព្រះមហាសត្វ ទ្រង់កាន់សំពត់ទង់ជ័យនៃព្រះអរហន្ត ទ្រង់ព្រះផ្នួស ទ្រង់បំពេញព្យាយាមកំណត់យ៉ាងតិច បំផុត ៧ ថ្ងៃ

៨-សោយបាយមធុបាយាស ក្នុងថ្ងៃដែលទ្រង់សម្រេចព្រះសម្ពោធិញាណ

៩-ប្រថាប់គង់លើសន្ថ័តស្មៅ សម្រេចព្រះសព្វញ្ញុតញ្ញាណ

១០-ទ្រង់បរិកម្មអានាបានស្សតិកម្មដ្ឋាន

១១-ទ្រង់កម្ចាត់កងកម្លាំងរបស់មារ

១២-ទ្រង់គង់លើពោធិបល្ល័ង្កទ្ទុំះឯង សម្រេចនូវវិជ្ជា ៣ ជាដើម ទ្រង់បានគុណមានអសាធារណញាណ

១៣-ទ្រង់គង់នៅជិតពោធិព្រឹក្ស ៧ សប្តាហ៍

១៤-ស្តេចមហាព្រហ្មទូលអារាធនា ដើម្បីឲ្យទ្រង់សម្តែងធម៌

១៥-ទ្រង់ប្រកាសព្រះធម្មចក្ក ក្នុងព្រៃឥសិបតនមិគទាយវ័ន

១៦-ក្នុងថ្ងៃមាឃបុណ្ណមី ទ្រង់លើកបាតិមោក្ខឡើងសម្តែងក្នុងទីប្រជុំសាវកប្រកបដោយអង្គ ៤

១៧-ទ្រង់គង់នៅប្រចាំក្នុងព្រះវិហារជេតពន

១៨-ទ្រង់ធ្វើយមកបាដិហារ្យ ជិតទ្វារក្រុងសាវត្ថី

១៩-ទ្រង់សម្តែងព្រះអភិធម្មក្នុងឋានតាវត្តិង្ស

២០-ស្តេចចុះចាកទេវលោក ជិតទ្វារសង្កស្សនគរ

២១-ទ្រង់ចូលផលសមាបត្តិជាប់តគ្នា

២២-ទ្រង់ត្រួតមើលវេនេយ្យជន ២ វារៈ

២៣-កាលរឿងកើតឡើង ទើបទ្រង់បញ្ញត្តសិក្ខាបទ

២៤-កាលហេតុដើមនៃរឿងកើតឡើង ទើបត្រាស់ជាតក

២៥-ត្រាស់ពុទ្ធវង្សក្នុងសមាគមព្រះញាតិ

២៦-ទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងភិក្ខុអាគន្តុកៈ

២៧-ទ្រង់ចាំវស្សាហើយ ដែលត្រូវគេនិមន្ត មិនប្រាប់លាជាមុន មិនស្តេចទៅ

២៨-ទ្រង់ធ្វើកិច្ចមុនភត្ត និងក្រោយភត្ត បឋមយាម មជ្ឈិមយាម និងបច្ឆិមយាម រាល់ៗ ថ្ងៃ

២៩-សោយរសេមំសៈ ក្នុងថ្ងៃបរិនិព្វាន

៣០-ទ្រង់ចូលសមាបត្តិ ២៤ សែនកោដិសមាបត្តិ ហើយទើបបរិនិព្វាន ។

ធម្មតារបស់ព្រះពុទ្ធគ្រប់ព្រះអង្គមាន ៣០ គត់ ដូចដែលពោលមកដូច្នេះ ។

## ៤~រឿងអនន្តរាយិកធម៌

ព្រះពុទ្ធគ្រប់ព្រះអង្គ មានអនន្តរាយិកធម៌ (គឺមិនមានអន្តរាយជាធម្មតា) ៤ ប្រការ គឺ

១-អ្នកណាៗ មិនអាចធ្វើអន្តរាយដល់បច្ច័យ ៤ ដែលមានចំពោះព្រះពុទ្ធទាំងឡាយ

២-អ្នកណាៗ មិនអាចធ្វើអន្តរាយដល់ព្រះជន្មាយុរបស់ព្រះពុទ្ធទាំងឡាយ, សមពិតដូចទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស (គួរធ្វើបាន

ទេ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ” ។

៣-អ្នកណាៗ មិនអាចធ្វើអន្តរាយដល់ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងដល់ព្រះអនុព្យញ្ជនៈ ៨០ ប្រការ

៤-អ្នកណាៗ មិនអាចធ្វើអន្តរាយដល់ព្រះពុទ្ធរស្មីបាន, ទាំងនេះឈ្មោះថា អនន្តរាយិកធម៌ ៤ ប្រការ ៕

(ចាកអដ្ឋកថា មធុរត្ថវិលាសនី)

## ៥.ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ

១-មានព្រះបាទាប្រតិស្ឋានលើផែនដីស្មើបល្អ នេះជាមហាបុរិសលក្ខណៈនៃមហាបុរស របស់ព្រះមានព្រះភាគដ៏ចម្រើននោះ ។

២-មានកង់ចក្រ កើតនៅត្រង់ផ្ទៃនៃព្រះបាទខាងក្រោម មានកាំ ១.០០០ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ ដ៏បរិបូរណ៍ដោយអាការទាំងពួង

៣- មានព្រះបណ្ហិ (កែងជើង) វែង

៤-មានម្រាមព្រះហស្ថ និងម្រាមព្រះបាទវែង

៥-មានព្រះហស្ត និង ព្រះបាទទន់ខ្ចី

៦-មានព្រះហស្ត និង ព្រះបាទដូចជាសំណាញ់

៧-មានកព្រះបាទដូចជាអណ្តែតឡើង

៨-មានព្រះជង្ឃាដូចជាស្មងនៃសត្វទ្រាយ

៩-បើទ្រង់ឈរជាប្រក្រតី មិនបានឱនចុះ ហើយយកផ្ទៃព្រះហស្តទាំងពីរស្ទាបពាល់នូវព្រះជានុបាន

១០-មានព្រះអវយវៈ ដែលត្រូវលាក់ក្នុងសំពត់ ឋិតនៅក្នុងស្រោម

១១-មានសម្បុរព្រះកាយល្អ ដូចជាសម្បុរនៃមាស មានព្រះតចៈភ្លឺ ប្រហែលដោយមាស

១២-មានព្រះឆវីល្អិតម៉ត់ ព្រោះព្រះឆវីល្អិតម៉ត់ (នោះ) ទើបធូលី និងក្អែលមិនបានជិតជាប់ព្រះកាយឡើយ

១៣-មានព្រះរោមតែមួយៗ គឺព្រះរោមទាំងឡាយ តែមួយសរសៃៗ ដុះឡើងក្នុងរណ្តៅនៃរោមទាំងឡាយ

១៤-មានចុងព្រះរោមកួចឡើងលើ គឺព្រះរោមទាំងឡាយមានចុងងឡើង មានពណ៌ខៀវដូចជាពណ៌នៃផ្កាអញ្ចាន វិលទៅខាងស្តាំដូចជារង្វង់នៃកុណ្ឌល

១៥-មានជង្ឃព្រះអង្គត្រង់ដូចជាកាយមហាព្រហ្ម

១៦-មានព្រះមំសៈដ៏ពេញកំពុងល្អ ក្នុងសរីរៈប្រទេស ៧ អន្លើ (ត្រង់ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទាទាំងពីរ ចង្កូយស្មាទាំងពីរ និងព្រះសុរង)

១៧-មានព្រះកាយដូចជាកាយពាក់កណ្តាលខាងមុខនៃសត្វសីហៈ

១៨-មានចន្លោះព្រះអង្សា (សាច់ជាចន្លោះនៃស្មាប្រជៀវទាំងពីរ) ពេញស្មើល្អ

១៩-មានបរិមណ្ឌលនៃព្រះកាយស្មើគ្នា ដូចជាបរិមណ្ឌលនៃដើមជ្រៃ គឺព្រះកាយរបស់ព្រះអង្គប្រវែងប៉ុន្មាន ព្យាមរបស់ព្រះអង្គប្រវែងប៉ុណ្ណោះដែរ ព្យាមរបស់ព្រះអង្គប្រវែងប៉ុន្មាន ព្រះ-កាយរបស់ព្រះអង្គក៏ប្រវែងប៉ុណ្ណោះដែរ

២០-មានព្រះសុរងមូលស្មើ

២១-មានសរសៃល្អសម្រាប់នាំនូវរស

២២-មានព្រះហនុ (ចង្កា) ដូចជាចង្កានៃសត្វសីហៈ

២៣-មានព្រះទន្ត ៤០ គត់

២៤-មានព្រះទន្តត្រឹមស្មើ

២៥-មានព្រះទន្តមិនរង្វើល

២៦-មានព្រះចង្កូមសស្អាត

២៧-មានព្រះជិវ្ហាដ៏ល្មម

២៨-មានព្រះសូរស័ព្ទ ដូចជាសំឡេងនៃព្រហ្ម មានព្រះ-វាចាពីរោះ ដូចជាសំឡេងនៃសត្វករវិក

២៩-មានព្រះនេត្រខ្មៅយង់

៣០-មានរោមព្រះនេត្រដូចជារោមភ្នែកនៃកូនគោ

៣១-ព្រះឧណ្ណាលោមរបស់ព្រះមានព្រះភាគដ៏ចម្រើននោះ ដុះក្នុងចន្លោះនៃព្រះភមូ (ចិញ្ចើម) មានពណ៌ស ទន់ល្មន់ ដូចជាសំឡី

៣២-មានព្រះឧណ្ហីសៈ (ថ្ងាស ឬក្បាំង) និងព្រះសិរ្ស ដ៏បរិបូណ៌, នេះជាមហាបុរិសលក្ខណៈ នៃមហាបុរសរបស់ព្រះមានព្រះភាគដ៏ចម្រើននោះ ។

(សុត្តន្តបិដក ភាគ២៥ ទំព័រ៨)

✍ 📖 📖 📖 ✍

# V. អត្ថបទកំណាព្យ

## (១) ដំណើរយាត្រានមស្ការពុទ្ធស្ថាន

-សទ្ធានាំមុខចេញចរយាត្រា ទៅនមស្ការតាមទីពុទ្ធស្ថាន
កត្តិក៣ កើតណាមិត្រកល្យាណ ឥតមានខកខានដល់ក្រុងដៃល្លី។
-ជាដែនកុរុពីសម័យមុន ស្រស់ល្អពេកពន់អង្គព្រះមុនី
សម្ដែងសតិប្បដ្ឋានព្រះធម្មី ផ្លូវល្អគ្មានពីរនាំរួចចាកទុក្ខ ។
-រាត្រីទៀបភ្លឺពេលព្រឹកព្រលឹម ញញឹមសង្ឃឹមដំណើរទៅមុខ
ក្រុងសាវត្ថីតាមការគ្រោងទុក ព្រះសង្ឃម៉ែពុកមានចិត្តស្រស់ថ្លា។
-គណ្ឌាម្ពព្រឹក្សស្វាយលាស់ស្រស់ខ្ចី អង្គព្រះជិនស្រីធ្វើបាដិហារ្យ
អាសាឍ១៥ កើតដ៏អស្ចារ្យ ផ្ចាញ់ពួកមិច្ឆាទិដ្ឋិទាំងឡាយ ។
-វត្តបុព្វារាមនៅខាងកើតក្រុង ជាទីបម្រុងគួរឲ្យសប្បាយ
ដែលវិសាខានាងបានចំណាយ ទ្រព្យសាងថ្វាយកប់ក្នុងពុទ្ធសាសន៍។
-ជាទីគង់នៅនៃព្រះសាស្ដា ប្រាំមួយវស្សាពិតប្រាដកណាស់
លោហប្រាសាទវិចិត្រល្អល្អះ មានសព្វមិនខ្វះបរិក្ខារទាំងឡាយ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (២) វត្តជេតពនជាទីរីករាយ

-វត្តជេតពនជាទីមនោរម្យ ជាទីប្រជុំសាវ័កទាំងឡាយ
ព្រះពុទ្ធមិនលះទោះស្ដេចទៅឆ្ងាយ បរិស័ទថ្វាត់ថ្វាយបង្គំបូជា ។

-អានន្ទពោធិ៍ព្រះគន្ធកុដិ ឋិតនៅប្រាកដនៃព្រះភគវា
បរិស័ទមានចិត្តជិតដោយសទ្ធា តែងទៅវន្ទាដោយចិត្តជ្រះថ្លា ។
-នៅវេលាល្ងាចបរិស័ទទាំងឡាយ មានចិត្តសប្បាយចូលនមស្ការ
បូជាប្រទីបព្រមទាំងភ្ញីផ្កា ស្តាប់ធម៌ទេសនាតាំងអធិដ្ឋាន ។
-សូមបុណ្យកុសលបានជាបច្ច័យ ឧបនិស្ស័យដាក់ដល់ភូមិឋាន
ទីបរមសុខប្រសើរថ្កើងថ្កាន បានសុខក្សេមក្សាន្តរួចចាកទុក្ខា ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៣) ទីក្រុងកបិលពស្តុ

-មកដល់ទីក្រុងកបិលពស្តុថ្មី វន្ទាចេតីយ៍នៃព្រះសាស្តា
តម្កល់ព្រះធាតុ២នាឡិនោះណា ស្តាប់ធម៌ទេសនាដោយចិត្តស្ងប់ស្ងាត់។
-អរុណបានរះចាំងជះរស្មី មកលើផែនដីបំភ្លឺសព្វសត្វ
ញុំាងដួងហឫទ័យនៃពុទ្ធបរិស័ទ ចូលទៅប្រតិបត្តិដល់ទីពុទ្ធស្ថាន។
-ឧទ្យានសាលវ័នឈ្មោះលុម្ពិនី អង្គព្រះមុនីកាលនោះទ្រង់បាន
ប្រសូតចាកភគិមាតាកល្យាណ ថ្ងៃនេះខ្ញុំបានចូលនមស្ការ ។
-ក្រុងកបិលពស្តុទ្រង់ធ្លាប់គង់នៅ ប៉ុន្តែឥឡូវសល់តែសិលា
ស្មៅដុះជុំជិតមានអ្វីអស្ចារ្យ នេះហើយសង្ខារទាំងឡាយមិនទៀង។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៤) និគ្រោធារាម

-និគ្រោធារាមពួកញាតិសាងថ្វាយ ក៏បានប្រែក្លាយសល់តែរូបរាង
គ្រឹះស្ថានអារាមសំឡេងស្ងួរសៀង ដីកាសំនៀងសូន្យស្ងាត់ពេកណាស់។
-ជាទីគង់នៅនៃព្រះសម្ពុទ្ធ សាវ័កសុគតប្រសើរល្អល្អះ
២ម៉ឺនព្រះអង្គគួរជ្រះថ្លាណាស់ ឱព្រះគុណម្ចាស់បាត់ទៅណាហើយ។
-ទេវទហានគរមាតា រាមគ្រាមអស្ចារ្យនៅមិនឆ្ងាយឡើយ
ទួលព្រះចេតីយ៍ស្រស់ល្អមែនហើយ ឥតមានកន្តើយគោរពបូជា ។
-ស្តាប់ធម៌ទេសនាប្រវត្តិព្រះធាតុ បញ្ជាក់ថែមទៀតចម្រើនសទ្ធា
រលឹកដល់គុណនៃព្រះភគវា ក្រាបថ្វាយវន្ទាគោរពដោយស្មោះ។
និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៥) កុសិនារាគួរឲ្យអាឡោះ

-ថ្ងៃប្រាំបីកើតដំណើរយាត្រា កុសិនារាគួរឲ្យអាឡោះ
អាល័យនឹកដល់ពុទ្ធអង្គកាលណោះ ទ្រង់ល្វិតល្វៃខ្សោះកម្លាំងព្រះកាយ។
-ចូលកាន់សាលវ័ននៃពួកមល្លក្សត្រ មិនសូន្យមិនស្ងាត់ភិក្ខុទាំងឡាយ
ដ៏ច្រើនរូបណាស់ជាប់តាមមិនឆ្ងាយ នៅជិតព្រះកាយនៃព្រះសាស្តា។
-បង្គាប់អានន្ទឲ្យឆាប់រួសរាន់ ប្រញាប់បន្ទាន់រៀបគ្រែអាសនា
ឱ្យមានសីសៈទៅទៅទិសឧត្តរា អនុដ្ឋានសេយ្យាមិនក្រោកវិញទេ។

-ថ្ងៃពេញបូណ៌មីជាថ្ងៃចុងក្រោយ ព្រះជន្ម៨០ហើយរសៀលជ្រាលជ្រេ
ទ្រង់មានស្មារតីមិនតក់ស្លុតទេ ព្រទ័យរិះរេប្រទានឱវាទ ។
-បណ្តាំចុងក្រោយល្អវិសេសណាស់ បរិស័ទក្មេងចាស់ត្រូវខំសង្វាត
ចម្រើនកុសលកុំបីប្រមាទ ពិតជាឱវាទដ៏ប្រសើរក្រៃ ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៦) មកុដពន្ធនចេតីយ៍

-ចូលមកុដពន្ធនចេតីយ៍ ហាក់ដូចថ្មីៗគិតនឹកស្រមៃ
បូជាព្រះសពព្រះចមក្សត្រថ្លៃ ជាគម្រប់ថ្ងៃទីប្រាំពីរហើយ ។
-បរិស័ទទាំងឡាយចូលមកបូជា នូវព្រះភគវាឥតមានកន្តើយ
មានមនុស្សទេវតាមិនតិចតួចឡើយ កន្លែងនេះហើយមកុដពន្ធនៈ។
-នៅក្នុងគ្រានោះហេតុអស្ចារ្យណាស់ មែនពិតយ៉ាងច្បាស់ច្រើនប្រាកដជាក់
ជុំដោយគ្រហស្ថនិងសង្ឃសាវ័ក មានការជឿជាក់អង្គព្រះជិនស្រី។
-ប្រទក្សិណបីជុំរួចក៏បន្ត ដំណើរត្រាច់ចរតាមដងវិថី
ចូលទៅទៀបស្ទឹងហិរញ្ញវតី ដែលព្រះជិនស្រីទ្រង់បានឆ្លងកាត់។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៧) ក្រុងវេសាលី

-ក្រុងវេសាលីនៃស្តេចលិច្ឆវី អង្គព្រះមុនីទ្រង់បានកំចាត់
ភ័យបីប្រការឲ្យវិនាសបាត់ ញុំាងរាស្ត្រនិងក្សត្របានសុខសួស្តី ។

-កូដាគារសាលាព្រៃមហាវ៍ន មានរឿងពាក់ព័ន្ធនឹងភិក្ខុនី
បួសក្នុងសាសនានៃព្រះជិនស្រី ស្មោះស្ម័គ្រភក្តីក្នុងព្រហ្មចារ្យ ។
-លះបង់ពួកញាតិដែលធ្លាប់ជួបជុំ និងភាពជាធំព្រមទាំងបរិវារ
លះកាមលោកីយ៍ឥតស្តាយទេណា មានចិត្តប្រាថ្នាតែក្នុងបព្វជ្ជា។
-ឯព្រះអានន្ទក៏ជួយអង្វរ ដោយចិត្តស្មោះសឥតមានរួញរា
ក្រាបបង្គំទូលដល់ព្រះភគវា រហូតដល់គ្រាទ្រង់អនុញ្ញាតឲ្យ។
-ស្ត្រីបួសក្នុងព្រះពុទ្ធសាសនា នៅនាកូដាសាលានេះហើយ
មាន៥០០រូបពិតមិនតិចឡើយ កាលនោះឯងហើយគួរឲ្យជ្រះថ្លា។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៨) ទ្រង់ប្រាប់ការបរិនិព្វាន

-ថ្ងៃ១៥ កើត បិតក្នុងខែមាឃ ព្រះមានព្រះភាគទ្រង់បង្គាប់ថា
ឲ្យប្រជុំសង្ឃនៅក្នុងសាលា រួចទ្រង់ប្រាប់ការបរិនិព្វាន ។
-ទ្រង់ផ្តល់ឱវាទដល់ភិក្ខុសង្ឃ ជាច្រើនព្រះអង្គឥតមានលាក់លៀម
កុំឲ្យប្រមាទមានចិត្តអាចហាន ប្រព្រឹត្តសមាទានព្រហ្មចរិយៈ ។
-អម្ពបាលិវ៍នក្រុងវេសាលី ទីតាំងចេតីយ៍ធាតុ២នាឡិជាក់
សទ្ធានាំមុខចិត្តឥតស្ទើរស្ទាក់ ឈានជើងបែរភក្ត្រចូលក្រាបវន្ទា។
-ក្រុងវេសាលីនៃស្តេចលិច្ឆវី អង្គព្រះមុនីនិងព្រះសង្ឃា

ទ្រង់ត្រាស់ព្រះសូត្ររម្ងាប់រោគា អមនុស្សនានាក៏បានចៀសឆ្ងាយ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៩) បាតលិបុត្តអសោការាម

-បាតលិបុត្តអសោការាម ទីនេះបើតាមក្បួនច្បាប់ទាំងឡាយ
ជាទីមនោរម្យគួរឲ្យសប្បាយ ភិក្ខុទាំងឡាយធ្វើសង្គាយនា ។
-រួបរួមព្រះធម៌និងព្រះវិន័យ ដ៏ល្អប្រពៃនៃព្រះភគវា
ភិក្ខុមួយពាន់រូបសុទ្ធសឹងជា បដិសម្ភិទាញាណដ៏វិសេស។
-ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ គឺជាព្រះថេរដែលមានចំណេះ
ជាអធិបតីនាំដ៏ពិសេស លោកមានតម្រិះល្អប្រសើរណាស់។
-សង្គាយនានេះជាលើកទី៣ វេលានោះក្តី ៩ ខែឥតខ្វះ
សូម្បីផែនដីដ៏មានកម្រាស់ ញ័ររំព្រៃលែងណាស់ឲ្យសាធុការ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១០) ទីក្រុងរាជគ្រឹះ

-ទីក្រុងរាជគ្រឹះបញ្ចគិរី ក្រុងនេះជាទីព្រះពុទ្ធសាស្តា
ទ្រង់យាងចូលមកនិងអរហន្តា ស្តេចពិម្ពិសារមានចិត្តត្រេកអរ ។
-ភ្នំគិជ្ឈកូដមានព្រះគន្ធកុដិ ឋិតនៅប្រាកដគ្រឹះស្ថានបវរ
បរិស័ទក្មេងចាស់មានចិត្តស្មោះស រីករាយត្រេកអរឡើងនមស្ការ។

-សូករខាតាគឺជាគុហា ដែលព្រះភគវាវិសុទ្ធអស្ចារ្យ
ទ្រង់ធ្លាប់គង់នៅត្រាស់ធម៌ទេសនា ញ៉ាំងសព្វសត្តាត្រាស់ដឹងធម៌ថ្លៃ។
-ម្យ៉ាងទៀតជាទីគង់នៅប្រចាំ ព្រះសាវ័កស្គាំអ្នកមានគុណក្រៃ
បរិស័ទចូលដល់បត់ជើងលើកដៃ ចិត្តនឹកស្រមៃថ្វាត់ថ្វាយបង្គំ ។
-ល្អាងព្រះមោគ្គលានបិតនៅទីជិត ក្បែរនោះមែនពិតខាងក្រោមញកភ្នំ
ចូលនមស្ការក្រាបថ្វាយបង្គំ រួចហើយជួបជុំស្តាប់ធម៌វិន័យ ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១១) វត្តអម្ពវ័នជាដើម

-វត្តអម្ពវ័នពេទ្យជីវកៈ មានចិត្តស្មោះស្ម័គ្រនៅក្នុងហឫទ័យ
វេរថ្វាយព្រះសង្ឃបវរប្រពៃ ក្នុងធម៌វិន័យតាមចិត្តសទ្ធា ។
-សត្តបណ្ណល្អាងដ៏ស្ងប់ស្ងាត់ ភិក្ខុបរិស័ទមកជួបជុំគ្នា
រួមពុទ្ធវចនៈនៃព្រះភគវា ធ្វើសង្គាយនាព្រះធម៌វិន័យ ។
-សុទ្ធសឹងអរហន្តបានអភិញ្ញា បដិសម្ភិទាញាណដ៏ប្រពៃ
៥០០ព្រះអង្គគិតគូរលកលៃ ស្ងួម្បីផែនដីក៏បានញាប់ញ័រ ។
-វត្តវេឡុវ័នជាទីរីករាយ ដ៏ស្រស់ពណ្ណរាយទៅដោយព្រះធម៌
ភិក្ខុសាវ័កក៏មិនញាប់ញ័រ ព្រោះបានឃើញធម៌ត្រាស់ដឹងសច្ចៈ។
-ជាទីកន្លែងប្រជុំសាវ័ក សន្និបាតជាក់ពិតយ៉ាងប្រចក្ស
ព្រះខីណាស្រពមានគុណសមស័ក្តិ ត្រាស់ដឹងសច្ចៈអភិញ្ញា ៦ ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១២) ឥន្ទសាលគុហាជាដើម

-ឥន្ទសាលគុហានៅឆ្ងាយ តែចិត្តសប្បាយឥតមានភ័យព្រួយ
ដើរដោយថ្មើរជើងឈានទៅមួយៗ ផលបុណ្យតាមជួយបានដល់ពុទ្ធស្ថាន។
-ទ្រង់ធ្លាប់គង់នៅដោះស្រាយបញ្ហា សក្កៈទេវតាទ្រង់ក៏ប្រោសប្រាណ
សាកសួរព្រះធម៌បវរកល្យាណ ចប់ស្រេចក៏បានត្រាស់ដឹងធម៌ថ្លៃ។
-មហាវិទ្យាល័យនាលន្ទា សាលាធម្មាដ៏ប្រសើរក្រៃ
តែត្រូវមនុស្សបាបមានចិត្តព្រៃផ្សៃ ដុតគ្មានសំចៃយនៅសល់តែគ្រឹះ។
-ឃ្លាំងទ្រព្យវាំងចាស់នៃព្រះរាជា សម្បូរហូរហៀរក្នុងក្រុងរាជគ្រឹះ
តែឥឡូវនេះមើលទៅគ្រប់ទិស សត្វស្វារពឹសរស់នៅពាសពេញ។
-សង្ខារទាំងឡាយមិនទៀងមែនពិត តែងតែវិបរិតកុំបីម្នោម្នេញ
អ្វីដែលកើតហើយតែងវិនាសវិញ គប្បីបំពេញតែសេចក្តីល្អ ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១៣) ភ្នំបណ្ឌវៈ

-ភ្នំបណ្ឌវៈព្រះពោធិសត្វ ទ្រង់បានជួបក្សត្ររាជាបវរ
ស្តេចពិម្ពិសារទ្រង់ទូលអង្វរ មានចិត្តត្រេកអរចែករាជ្យឲ្យសោយ។
-ព្រះពោធិសត្វមហាបុរស ទ្រង់មិនអាឡោះអាល័យសោះឡើយ
លះរាជ្យសម្បត្តិគ្រប់យ៉ាងនោះហើយ ឥតមានកន្តើយរកពោធិញ្ញាណ។
-លដ្ឋិវនឧទ្យានសួនច្បារត្នោត ក៏ទីនេះសោតព្រះពុទ្ធទ្រង់ញាណ

ស្តេចយាងចូលដល់កាលគង់ធរមាន ទ្រង់ត្រាស់ទូន្មានដល់ពួកបរិស័ទ។
-អនុបុព្វីកថាសច្ចៈ ពិតយ៉ាងប្រចក្សដោយប្រុងប្រយ័ត្ន
ធម៌មានលម្អដើម្បីកំចាត់ កិលេសឲ្យបាត់ពីខន្ធសន្តាន ។
និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១៤) ទុក្ករកិរិយាជាផ្លូវអម

-ទុក្ករកិរិយាជាផ្លូវអម កម្មជាដើមចមចេះតែរុញច្រាន
ឲ្យខំព្យាយាមនាំលំបាកប្រាណ ក្រោយមកទ្រង់បានរកឃើញផ្លូវត្រង់។
-អរិយមគ្គមានអង្គប្រាំបី ញុំាំងព្រះជិនស្រីឲ្យបានផ្ទូរផង់
ប្រតិបត្តិល្អដោយការផ្ចិតផ្ចង់ ដើរតាមផ្លូវត្រង់ទើបបានត្រាស់ដឹង។
-ថ្ងៃ ១៥ កើតវិសាខបុណ្ណមី ជាផលបារមី ៣០ ប៉ុណ្ណឹង
ជាគុណដ៏លើសនោះឯងសុទ្ធសឹង ទ្រង់បានត្រាស់ដឹងសម្ពោធិញ្ញាណ។
-វិសាខទៀបភ្លឺអរុណជិតរះ រស្មីចាំងជះមគ្គផលកើតមាន
ទ្រង់បានត្រាស់ដឹងសម្ពោធិញ្ញាណ ហេតុចំឡែកមានកើតប្រាកដច្បាស់។
-កក្រើកផែនដីពន្លឺភ្លឺស្វាង មិនមែនតែម្យ៉ាងដ៏ក្រៃលែងណាស់
ជាគុណតេជះព្រះពុទ្ធជាម្ចាស់ ពោរពេញមិនខ្វះបន្តិចឡើយណា។
-បរិស័ទទាំងឡាយមានចិត្តសទ្ធា គោរពវន្ទាថ្វាយនូវភ្ញីផ្កា
បាត្រពេជ្រចីវរនិងគ្រឿងបរិក្ខារ ដល់ព្រះសាស្តាឥតមានស្ទាក់ស្ទើរ។
និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# (១៥) ៧ សប្តាហ៍ក្រោយការត្រាស់ដឹង

-ស្ថានទីត្រាស់ដឹងពុទ្ធគយា បល្ល័ង្កភគវាក្រោមដើមឈើ
គួរអ្នកព្យាយាមដោយអើពើ ម៉ីម្នាប្រឹងធ្វើការបូជា ។
-អនិម្មិសរតនចង្រ្កម ប្រសើរឧត្តមទីជិតគ្នា
បរិស័ទទាំងឡាយចូលវន្ទា ស្តាប់ព្រះធម្មាកើតជ្រះថ្លា ។
-ឯរតនឃរចេតីយ៍ អង្គព្រះជិនស្រីពិចារណា
ធម៌អភិធម្មជ្រៅអស្ចារ្យ ពន្លឺភ្លឺថ្លាចេញពីកាយ ។
-សប្តាហ៍ទី៥ ជាបន្ត ទ្រង់យាងដោយល្អទៅមិនឆ្ងាយ
អជបាលនិគ្រោធទីសប្បាយ គង់សម្រាកកាយសោយវិមុត្តិ ។
-សប្តាទី៦ ស្រះមុចលិន្ទ អង្គព្រះមុនិន្ទទ្រង់បានផ្គត់-
ភ្នែនក្រោមដើមរាំងសោយវិមុត្តិ អង្គព្រះសុគតគង់ស្ងប់ស្ងាត់ ។
-ភ្លៀងពុំជូកាលបានធ្លាក់ចុះ នៅក្នុងកាលណោះបានបក់ផាត់
នាគបានពែនព័ទ្ធព្រះចមក្សត្រ ដោយប្រុងប្រយ័ត្នពីខាងក្រៅ ។
-ឯរាជាយតនចេតីយ៍ អង្គព្រះជិនស្រីទ្រង់សំដៅ
សប្តាហ៍ទី៧ គង់ខាងក្រៅ ដែលលោកសំដៅទីសប្បាយ ។
-យើងខ្ញុំគ្រប់គ្នាសូមគោរព មិនថាថ្ងៃយប់ឥតនឿយណាយ
សូមជ្រកក្រោមម្លប់ព្រះធម្មកាយ បង្គំថ្វាត់ថ្វាយត្រៃរតនា ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១៦) ស្ថានទីត្រាស់ដឹងពោធិព្រឹក្ស

( បទពាក្យ ៧ )

*ស្ថានទីត្រាស់ដឹងពោធិព្រឹក្ស តាំងពីពេលព្រឹករហូតយប់
បរិស័ទទាំងឡាយមកមិនឈប់ ចូលមកគោរពព្រះភគវា ។
*មានទាំងគ្រហស្ថទាំងបព្វជិត ច្រើនណាស់មែនពិតខំម៉្ទីម្ទា
ខ្លះមានបុប្ផាគ្រឿងបូជា ប្រទីបផ្កាលាត្រៃចីវរ ។
*សង្រួមកាយចិត្តពោលវាចា សូធ្យនមស្ការចិត្តត្រេកអរ
សូធ្យហើយសូធ្យទៀតជាប់បន្ត ដោយចិត្តស្មោះសក្នុងត្រៃរ័ត្ន ។
*សូរស័ព្ទព្រះធម៌ពេញពុទ្ធស្ថាន ណាមិត្តកល្យាណជាក់ប្រាកដ
សូធ្យធម៌នមស្ការនិងធម៌បទ ឥតមានកំណត់អធ្យាស្រ័យ ។
*ខ្លះក៏សមាធិធ្វើកម្មដ្ឋាន ទូន្មានសន្តានលះអាល័យ
រលឹកដល់គុណចមក្សត្រថ្លៃ សន្សំនិស្ស័យបុណ្យបារមី ។
*សំឡេងគោះជួងនិងកូតទ្រ ព្រមទាំងវាយស្គរគ្មានប្រណី
ក៏បានលាន់ឮក្នុងទឹកដី វាយដើម្បីអ្វីឬបូជា ។
*ចំរុះជាតិសាសន៍មកជួបជុំ ថ្វាត់ថ្វាយបង្គំដោយសទ្ធា
រលឹកដល់គុណព្រះភគវា ដែលទ្រង់ឈ្នះមារទីនេះឯង ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# (១៧) សួនធម្មចក្ក

( បទពាក្យ ៧ )

* ឥសិបតនមិគទាយវ៍ន មានរឿងពាក់ព័ន្ធព្រះជិនស្រី
ស្តេចយាងមកដល់ពារាណសី ជួបពួកឥសីបញ្ចវគ្គីយ៍ ។
* ទ្រង់បានពន្យល់ឲ្យជឿជាក់ ឥសីប្រាំនាក់ស្តាប់ធម្មី
ព្រះពុទ្ធដីកាព្រះមុនី ត្រាស់ព្រះធម្មីអរិយសច្ច ។
* ព្រះកោណ្ឌញ្ញៈជាបឋម ឃើញធម៌ឧត្តមបានសម្រេច
ព្រមទាំងពួកព្រហ្មឃើញអរិយសច្ច រួចហើយទើបស្តេចចប់ទេសនា។
* បរិស័ទទាំងឡាយមានសទ្ធា បានចូលវន្ទានមស្ការ
ឆព្វណ្ណរង្សីទង់សាសនា បូជាសាស្តាដោយគោរព ។
* ស្វាធ្យាយព្រះធម៌ព្រះធម្មចក្ក មានចិត្តស្មោះស្ម័គ្រជ្រកក្រោមម្លប់
ទទួលធម្មទានទល់ព្រលប់ រួចហើយក៏ឈប់ឧទ្ទិសផល ។
* សូមឲ្យសព្វសត្វអនុមោទនា ដោយចិត្តសទ្ធាក្នុងកុសល
សន្សំយកបុណ្យយកមគ្គផល សូមឲ្យបានដល់ក្តីសុខា ។
* ម្យ៉ាងសូមឲ្យយើងខ្ញុំទាំងឡាយ ផុតពីអបាយចិត្តស្រស់ថ្លា
មានការយល់ត្រូវជាសម្មា ស្តាប់ធម៌ទេសនារួចចាកទុក្ខ ។

ថ្ងៃ ២ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១៨) ហែព្រះបរមសារីរិកធាតុនៅពារាណសី

* កត្តិក១៥កើតពេញបូណ៌មី ពារាណសីហែសាស្តា
ព្រះបរមធាតុដ៏អស្ចារ្យ បរិស័ទជ្រះថ្លាមិនកន្តើយ ។
* ឈានទៅមួយៗដោយសទ្ធា ក្នុងព្រះភគវាអែបពីក្រោយ
កាត់សួនធម្មចក្កណាអ្នកអើយ ឥតបង្អង់ឡើយដល់ចេតីយ៍ ។
* ក្រោមកំដៅថ្ងៃពេលរសៀល តែមិនរួញរាទាំងប្រុសស្រី
ព្រះសង្ឃសាវ័កចិត្តមេត្រី ស្មោះស្ម័គ្រភក្តីពុទ្ធបិតា ។
* សូមកុសលកម្មទាំងឡាយនេះ បានជាជំនិះឆ្លងសង្សារ
បានសោយសុខស្ងប់ជាអមតា ផុតចាកទុក្ខាទាំងពួងហោង ។

កត្តិក ១៥ កើត ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## (១៩) អាទិត្តបរិយាយសូត្រ

-ឧរុវេលាសេនានិគម នៅលើខ្នងភ្នំឈ្មោះគយា
ទ្រង់ត្រាស់ទេសនាព្រះធម្មា ដល់ពួកសង្ឃាមួយពាន់អង្គ ។
-អាទិត្តបរិយាយសូត្រ គឺជាព្រះសូត្រដ៏ផូរផង់
ទ្រង់បានសម្តែងដោយផ្ចិតផ្ចង់ ដល់ភិក្ខុសង្ឃកំពុងស្តាប់ ។
-ចក្ខុសោតៈនិងឃានៈ ជិវ្ហាកាយៈទ្រង់បានប្រាប់
ថារបស់ក្តៅអ្នកកុំចាប់ លះវៀរឲ្យឆាប់កុំប៉ះពាល់ ។

-ភិក្ខុទាំងឡាយបានយល់ច្បាស់ តាមពុទ្ធតម្រាស់ជាបន្ទាល់
លះការប្រកាន់មិនប៉ះពាល់ ក៏បានដឹងស្គាល់ឃើញអរិយសច្ច ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (២០) ឥន្ទសាលគុហា

<ឥន្ទសាលគុហា> ជិតភ្នំវេទិយកៈ តាំងនៅជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ។ ជាទីកន្លែងព្រះអង្គគង់ដោះស្រាយបញ្ហាដែលសក្កទេវរាជសួរ, ព្រះអង្គដោះស្រាយព្រះធម៌ដែលមានសេចក្ដីពីរោះណាស់ ។ សក្កទេវរាជ ស្ដាប់ហើយក៏បានធម្មចក្ខុ ( សោតាបត្តិមគ្គ ) និងដល់ទេវតា ៨ ហ្មឺនឯទៀងផង ។

## ឥន្ទសាលគុហា (កំណាព្យ)

-ឥន្ទសាលគុហានៅឆ្ងាយ តែចិត្តសប្បាយឥតមានភ័យព្រួយ
ដើរដោយថ្មើរជើងឈានទៅមួយៗ ផលបុណ្យតាមជួយបានដល់ពុទ្ធស្ថាន។

-ឡើងថ្វាយបង្គំដល់ទីកន្លែង ព្រះពុទ្ធសម្ដែងព្រះធម៌កល្យាណ
ដោះស្រាយបញ្ហាដ៏ប្រសើរថ្កាន ដែលសក្កៈបានក្រាបទូលសាកសួរ។

-គឺជាព្រះធម៌ជ្រាលជ្រៅមែនពិត ញ៉ាំងអ្នកប្រព្រឹត្តតាមកាលសមគួរ

និងញ៉ាំងព្រះឥន្ទដែលទ្រង់សាកសួរ ប្រព្រឹត្តសមគួរត្រាស់ដឹងសច្ច។
-ដល់ទេវតា ៨ ហ្មឺនទៀងផង បានឆ្លងកន្លងឃើញយ៉ាងប្រចក្ស
ធម្មចក្ខុត្រាស់ដឹងសច្ច ឃើញយ៉ាងប្រចក្សអស់ក្តីសង្ស័យ ។
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## (២១) សេនាបតីសារីបុត្ត

-ទីកន្លែងកើតបរិនិព្វាន រឿងនេះកើតមានដល់ព្រះសាវ័ក
សេនាបតីសារីបុត្តជាក់ ច្បាប់បានបញ្ជាក់ខ្ញុំសូមវន្ទា ។
-រលឹកដល់គុណដ៏អស្ចារ្យ សាវ័កសាស្តាព្រះភគវា
មានគុណតេជះសីលភាវនា និងគុណធម្មាប្រសើរក្រៃ ។
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (២២) អង្គុលិមាល

-អង្គុលិមាលចិត្តអង់អាច ឃោរឃៅកំណាចកាប់ប្រហារ
តែត្រូវព្រះពុទ្ធសាស្តាចារ្យ ឲ្យលះហិង្សាចូលបព្វជ្ជា ។
-មិនយូរប៉ុន្មានបានសម្រេច ប្រហារកាត់ផ្តាច់កិលេសមារ
កាច់សង្សារចក្កអវិជ្ជា គួរឲ្យបូជាយ៉ាងក្រៃលែង ។
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (២៣) ក្រុងកោសម្ពីឃោសិតារាម

-ក្រុងកោសម្ពីឃោសិតារាម វត្តនេះបើតាមសិក្សាមក
ឃោសកសេដ្ឋីបានលៃលក កសាងទុកមកដោយសទ្ធា ។
-ថ្វាយព្រះសាស្តានិងព្រះសង្ឃ ប្រណិតផ្ចិតផ្ចង់អារាធនា
ព្រះសង្ឃសាវ័កព្រះភគវា យាងមកក្នុងគ្រាសាងរួចស្រេច ។
-ចូលកាន់អារាមសសរស្តម្ភ រាជូបត្ថម្ភកាលនោះស្តេច
ព្រះធម្មាសោកឲ្យសម្រេច រួចហើយក៏ស្តេចប្រតិស្ឋាន ។
-បរិស័ទទាំងឡាយមានសទ្ធា គោរពវន្ទាត្រង់ទីឋាន
ទ្រង់ធ្លាប់គង់នៅទាំងប៉ុន្មាន ហាទ័យប្រោសប្រាណដល់សព្វសត្វ។

ថ្ងៃ ៣ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (២៤) វាំងចាស់របស់ស្តេចឧទេន

-វាំងចាស់របស់ស្តេចឧទេន ឥឡូវមែនទែនវិនាសខ្ទាត់
សល់តែទីឋានស្តេចសូន្យបាត់ បរិស័ទខំស្កាត់ចូលទស្សនា ។
-ពេលដែលចូលដល់សៃនរលឹក ហាទ័យគិតនឹកព្រះសាស្តា
ទ្រង់ធ្លាប់គង់នៅលើអាសនា ត្រាស់ធម៌ទេសនាអនុមោទនា ។
-ព្រះសង្ឃក៏គង់ដោយប្រើប្រាស់ ជាច្រើនរូបណាស់តាមវេលា
តាមការនិមន្តនៃរាជា ឆាន់នូវភោជនាដោយបញ្ញា ។

-យើងខ្ញុំទាំងឡាយនឹកខ្លាំងណាស់ ដល់ព្រះពុទ្ធម្ចាស់ទីនេះណា
សូមក្រាបបង្គំនមស្ការ ដោយចិត្តជ្រះថ្លាក្នុងត្រៃរ័ត្ន ។

ថ្ងៃ ៤ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

* ព្រះពាកុលៈ ប្រសូតមក បាន ៥ ថ្ងៃ ត្រូវត្រីលេប នៅស្ទឹងយមុនា អណ្តែតទៅដល់ពារាណសី, ភិរិយាសេដ្ឋីនៅពារាណសីចិញ្ចឹមរក្សា ។ អាយុ ៨០ ឆ្នាំ ក៏បានចេញបួស ។ បួសបាន ៨ ថ្ងៃ បានសម្រេចព្រះអរហត្ត ។

(២៥) ព្រះពាកុលៈ

-ស្ទឹងយមុនាដ៏វែងឆ្ងាយ មានរឿងទាំងឡាយគួរសិក្សា
ព្រះពាកុលៈនៅកុមារ ត្រូវសត្វមច្ឆាលេបយកទៅ ។
-អណ្តែតចុះដល់ពារាណសី ត្រូវអ្នកចាប់ត្រីចាប់លក់នៅ
មុខផ្ទះសេដ្ឋី ភរិយាទៅ- ទិញមកលំនៅវះឃើញកូន ។
-ចិញ្ចឹមរក្សាដោយត្រេកអរ ប្រសើរបវរលើសបងប្អូន
ស្រឡាញ់ដោយស្មោះដូចជាកូន ខ្លាចតែបាត់សូន្យមិនចង់ឃ្លាត ។
-ក្រោយមកទៅបួសក្នុងសាសនា ព្រះពុទ្ធបិតាឥតរវាត
ព្យាយាមប្រឹងប្រែងបន្ថែមទៀត ក៏មិនឃ្លៀងឃ្លាតចាកមគ្គផល។

ថ្ងៃ ៤ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## (២៦) ដែនសង្កស្សអចលចេតីយ៍

* ដែនសង្កស្សអចលចេតីយ៍ ព្រះពុទ្ធជិនស្រីទ្រង់ចាកឋាន
ទេវលោកតាវត្តិង្សប្រសើរថ្កាន បរិស័ទគ្រប់ប្រាណចាំទទួល ។
* អស្សុជ ១៥ ពេញបូណ៌មី ទាំងប្រុសទាំងស្រីបានស្រុះស្រួល
មានចិត្តជ្រះថ្លាឥតប្រែប្រួល រង់ចាំទទួលព្រះសាស្តា ។
* ព្រះពុទ្ធទាំងឡាយមិនលះបង់ ទ្រង់តែងចុះត្រង់ទីនេះណា
អចលចេតីយ៍ដ៏អស្ចារ្យ ទាំងមនុស្សទេវតាមកបូជា ។
* ថ្ងៃនេះយើងខ្ញុំមកដល់ហើយ ឥតបង្អង់ឡើយចូលវន្ទា
ទីឋានចេតីយ៍ព្រះភគវា ដោយចិត្តសទ្ធាដ៏ឧឡារ ។
* សូមឲ្យធម៌រំលឹកដល់ព្រះគុណ ដ៏ល្អលើសលន់សាស្តាចារ្យ
សូមបុណ្យកុសលដ៏ថ្លៃថ្លា រួចចាកទុក្ខាទាំងពួងហោង ។

ថ្ងៃ ៤ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (២៧) សតិប្បដ្ឋានព្រះធម្មី

( បទពាក្យ ៧ )

-សទ្ធានាំមុខចរយាត្រា ទៅនមស្ការដល់ពុទ្ធស្ថាន
ព្រះសង្ឃបរិស័ទមិត្តកល្យាណ ឥតមានខកខានក្រុងដែល្លី ។
-ជាដែនកុរុសម័យមុន ស្រស់ល្អពេកពន់ព្រះមុនី

សម្តែងសតិប្បដ្ឋានព្រះធម្មី បរិស័ទសម្ពីស្តាប់ទេសនា ។
-ជាផ្លូវបរិសុទ្ធិនៃសព្វសត្វ ប្រតិបត្តិកម្ចាត់នូវមោហា
លះបង់ទិដ្ឋិនិងតណ្ហា មិនមានសត្តាត្រឹមធម្មៈ ។
-កាយក្នុងកាយវេទនាក្នុងវេទនា ដែលព្រះភគវាទ្រង់បញ្ជាក់
ចិត្តក្នុងចិត្តធម៌ក្នុងធម្មៈ នេះប្រាកដជាក់ឥតមានសត្វ ។
-ភិក្ខុពិចារណាឃើញប្រក្រតី ទាំងមានស្មារតីគ្រឿងកម្ចាត់
អភិជ្ឈាទោមនស្សឲ្យស្ងន្សបាត់ ឥតមានឃើញសត្វបុគ្គលឡើយ។
-សតិប្បដ្ឋានជាផ្លូវតែមួយពិត គប្បីប្រព្រឹត្តកុំកន្តើយ
ឯកាយនៈណាអ្នកអ្ហើយ សត្វណាដើរហើយនាំផុតទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (២៨) ស្ថានទីព្រះពុទ្ធមិនលះបង់

* ស្ថានទីព្រះពុទ្ធមិនលះបង់ ប្រសើរផូរផង់ទាំង ៤ ឋាន
ពោធិបល្ល័ង្កប្រសើរថ្កាន ទីដែលទ្រង់បានពោធិញ្ញាណ ។
* អចលបល្ល័ង្កសួនធម្មចក្ក បិននៅប្រចក្សទ្រង់ទូន្មាន
ដល់បញ្ចវគ្គីយ៍ឲ្យអាចហាន រួចទ្រង់ទូន្មានធម៌ធម្មចក្ក ។
* ទ្រង់ចាកទេវលោកតាវត្តិង្ស នេះអ្នកត្រូវដឹងសង្កស្សៈ
អចលចេតីយ៍នៅប្រចក្ស បរិស័ទស្មោះស្ម័គ្រចូលបូជា ។

* ទីដាក់ចុះជើងគ្រែទាំង៤ ចិតថេរមាំមួនក្នុងវិហារ
ជេតពនអារាមព្រះភគវា ត្រាស់ព្រះធម្មាដោយករុណា ។
* ខ្ញុំសូមគោរពដល់ទីស្ថាន នេះទាំងប៉ុន្មានដោយជ្រះថ្លា
រលឹកដល់គុណព្រះសម្មា- សម្ពុទ្ធនោះណាគ្រប់ព្រះអង្គ ។
* សូមបុណ្យកុសលជាបច្ច័យ ឧបនិស្ស័យដ៏ផូរផង់
បានជួបសប្បុរសចិត្តស្មោះត្រង់ ស្ដាប់ធម៌ពុទ្ធអង្គរួចចាកទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (២៩) ព្រះធាតុព្រះសម្មាសម្ពុទ្ធ

* មកដល់ទីក្រុងញូដេលី សារមន្ទីរនៃសាសនា
តម្កល់ព្រះធាតុព្រះសម្មា- សម្ពុទ្ធអស្ចារ្យពេកកន្លង ។
* បរិស័ទទាំងឡាយមានសទ្ធា បានចូលវន្ទាឥតមានហ្មង
ថ្វាត់ថ្វាយបង្គំភ្លាមតែម្ដង ទៅតាមបំណងដោយជ្រះថ្លា ។
* ព្រះធាតុហែមកពីចេតីយ៍ កបិលពស្តុថ្មីនោះឯងណា
បានតម្កល់ទុកថែរក្សា មន្ទីរនេះណាដោយផ្ចិតផ្ចង់ ។
* ខ្ញុំសូមកម្បង់ផ្គងអញ្ជលី លើកហត្ថទាំងពីរដ៏ផូរផង់
គោរពនឹកដល់ព្រះពុទ្ធអង្គ ដោយចិត្តស្មោះត្រង់ពុទ្ធបិតា ។
* សូមជ្រកក្រោមម្លប់ធម៌វិន័យ ដ៏ល្អប្រពៃព្រះសាស្ដា

សូមមានទិដ្ឋិជាសម្មា ស្តាប់ធម៌ទេសនារួចចាកទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៣០) បូជាព្រះបរមសារីរិកធាតុ

* ខ្ញុំសែនមានចិត្តសោមនស្សា បូជាបុប្ផានិងចីវរ
ថ្វាយព្រះបរមធាតុចិត្តស្មោះស ប្រសើរបវរក្នុងមន្ទីរ ។
* ព្រះធាតុហែពីកបិលពស្តុថ្មី ចាកព្រះចេតីយ៍ព្រះមុនី
បរិស័ទទាំងឡាយខំសម្តី ចូលកាន់មន្ទីរដោយរីករាយ ។
* ក្រាបថ្វាយបង្គំនមស្ការ ស្តាប់ព្រះធម៌អាចិឥតនិយាយ
ភាវនាស្ងប់ស្ងៀមមិនរាយមាយ មានចិត្តរីរាយដោយសទ្ធា ។
* ហាប្ញទ័យស្មោះស្ម័គ្រនិងមេត្រី ក្នុងព្រះជិនស្រីព្រះភគវា
រួចឧទ្ទិសបុណ្យទាំងអស់គ្នា អនុមោទនារួចចាកទុក្ខ ។

ថ្ងៃ០៧រោចខែកត្តិកពុទ្ធសករាជ២៥៥៩

ដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៣១) សាធុសាធុ ចិត្តត្រេកអរ

* សាធុសាធុចិត្តត្រេកអរ ដំណើរបវរតទៅមុខ
សាធុសាធុសន្សំទុក អាចរួចចាកទុក្ខព្រោះបុណ្យជួយ ។

* សាធុសាធុដោយរីករាយ ស្រស់ល្អពណ្ណរាយបំបាត់ព្រួយ
សាធុសាធុមិនតែមួយ បានជាជំនួយស្រីសួស្តី ។
* សាធុសាធុមិនអល់អែក គឺថាសូមចែកដោយមេត្រី
សាធុសាធុចិត្តភក្តី សូមបានសិរីពីបុញ្ញា ។
* សាធុសាធុយកកុសល សង្ឃឹមបានផលដូចប្រាថ្នា
សាធុសាធុឆ្លងសង្សារ រួចចាកទុក្ខាដល់និព្វាន ។

ថ្ងៃ ៧ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៣២) ព្រះពុទ្ធសម្តែងជយបរិត្ត

* ព្រះពុទ្ធសម្តែងជយបរិត្ត យើងខ្ញុំមានចិត្តសោមនស្សា
ព្យាយាមចូលទៅនមស្ការ កាត់តាមសួនច្បារក៏បានដល់ ។
* ទ្រង់ត្រាស់ពីនក្ខត្តឫក្សល្អ ប្រសើរបវរត្រង់តម្កល់
កាយកម្មជាដើមក្នុងកុសល នោះអ្នកនឹងដល់សុខសួស្តី ។
* មិនថាគ្រហស្ថឬបព្វជិត បើបានប្រព្រឹត្តធ្វើការអ្វី
បានពិចារណាដឹងសេចក្តី ធ្វើដោយឃ្មាតខ្មីនឹងចម្រើន ។
* សុខក្នុងបច្ចុប្បន្ននិងបរលោក មានជ័យមានជោគកាន់តែច្រើន
ការងារត្រឹមត្រូវនាំកើតកើន ឲ្យសុខចម្រើនរួចចាកទុក្ខ ។

និពន្ធដោយ ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៣) វិហារផ្កាឈូក

-វិហារផ្កាឈូកសាសនាបាហាយ បរិស័ទទាំងឡាយក៏បានចូលដល់
អង្គុយសមាធិលើកចិត្តតម្កល់ ឋិតក្នុងកុសលចម្រើនភាវនា។
-ឥតមានប្រកាន់ជាតិសាសនាណា បើអ្នកប្រាថ្នាទៅតាមសទ្ធា
ចូលទៅអង្គុយចម្រើនភាវនា តាមពេលវេលាដែលបានកំណត់។
-រលឹកដល់គុណពុទ្ធានុស្សតិ ធម្មានុស្សតិឲ្យបានប្រាកដ
សង្ឃានុស្សតិក៏ឲ្យហ្មត់ចត់ តាមទៅកំណត់គុណដ៏ថ្លៃថ្លា។
-កាយស្ងប់ចិត្តស្ងប់ឆ្ងាយចាកបាបធម៌ កុំឲ្យញាប់ញ័រតាមតែតណ្ហា
អប់រំទូន្មានចិត្តឲ្យស្រស់ថ្លា ឋិតក្នុងកុសលានឹងបានសុខពិត។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៤) ឯករាជ្យសព្វសត្វតែងប្រាថ្នា

* ឯករាជ្យសព្វសត្វតែងប្រាថ្នា គឺតែងត្រូវការភាពជាធំ
មានសិទ្ធិសម្រេចក្នុងសង្គម រាល់កិច្ចតូចធំដោយខ្លួនឯង។
* ទោះក្នុងប្រទេសឬគ្រួសារ នេះជាធម្មតាពិតជាក់ស្ដែង
ចង់ជាឥស្សរដោយខ្លួនឯង កែខៃតាក់តែងគ្រឿងការពារ។
* តែត្រូវដឹងចុះណាមាសស្ងួន ស្ងួនម្បីតែខ្លួនណាពុំងា
តែងចាស់ទ្រុឌទ្រោមមានរោគា ថាតើគ្រប់គ្នាធំលើអ្វី។

* កុំចង់គ្រប់គ្រងលើលោកនេះ  គួរតែត្រិះរិះដោយស្មារតី
ឃើញនូវទុក្ខទោសកាមលោកីយ៍ ចេញចាកភពបីទើបសុខស្ងប់។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៥) ចូលវិហារ

-ពេលព្រឹកឬល្ងាចចូលវិហារ  បង្គំវន្ទាត្រៃរតនា
អង្គុយសមាធិផ្សាយមេត្តា  សូមសព្វសត្តាបានសុខស្ងប់។
-កុំឲ្យមានពៀរកុំព្យាបាទ  បៀតបៀនប្រមាថប្រទូសស្អប់
គំនុំក្នុងចិត្តសូមបញ្ចប់  សូមបានប្រសព្វសុខឥតទុក្ខ។
-គប្បីមានខ្លួនជាឧបមា  ផ្សព្វផ្សាយមេត្តាជាប្រមុខ
ទិសតូចទិសធំតម្កល់ទុក  ផ្សាយឥតរើសមុខជាធម្មតា។
-ព្រហ្មវិហារធម៌ប្រសើរពិត  បើបានប្រព្រឹត្តចិត្តស្រស់ថ្លា
មេត្តាករុណាមុទិតា  និងឧបេក្ខាមួយទៀតផង។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៦) វដ្តសង្សារជាផ្លូវឆ្ងាយ

-វដ្តសង្សារជាផ្លូវឆ្ងាយ  ដែលសត្វទាំងឡាយតែងត្រាច់ចរ
អាស្រ័យតណ្ហានៅបន្ត  ឲ្យល្អក់កករមិនប្រសើរ។

-ឯអវិជ្ជាក៏រារាំង ប្រៀបដូចរនាំងស្ទាក់ដំណើរ
មិនឲ្យឃើញមគ្គដ៏ប្រសើរ ក៏ចេះតែដើរក្នុងផ្លូវឆ្ងាយ។
-មគ្គអង្គប្រាំបីជាផ្លូវត្រង់ ដែលព្រះពុទ្ធអង្គទ្រង់បរិយាយ
ឲ្យឃើញនិព្វានផុតអបាយ រីឯផ្លូវឆ្ងាយក៏បានដល់។
-ហេតុនេះប្រសិនអ្នកប្រាថ្នា កាត់វដ្តសង្សារត្រូវតម្កល់
សម្មាទិដ្ឋិក្នុងកុសល នឹងសម្រេចផលព្រះនិព្វាន។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៧) មគ្គអង្គប្រាំបីដ៏ប្រពៃ

-មគ្គអង្គប្រាំបីដ៏ប្រពៃ គប្បីលកលៃចិត្តអាចហាន
អប់រំកុសលខំសមាទាន ផ្លូវទៅនិព្វានផុតទុក្ខា។
-កាមគុណមានអ្វីគួរត្រេកអរ ពិតមិនបវរសោះឡើយណា
ញាំងសត្វឲ្យជាប់ក្នុងសង្សារ មិនដឹងថ្ងៃណាបានរួចខ្លួន។
-បើមិនសេពគប់នូវសប្បុរស នៅតែឡេះឡោះឱមាសស្ងួន
នឹងទទួលរងទុក្ខផ្ទួនៗ មិនអាចរួចខ្លួនបានសុខស្ងប់។
-ដូច្នេះគប្បីមានស្មារតី តាមព្រះជិនស្រីអាចបញ្ចប់
ព្រោះឃើញនិព្វានទីសុខស្ងប់ ពិតមិនត្រឡប់ជាអមត។

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៨) ឆ្លងសង្សារ

-វដ្តសង្សារដ៏ធំធេង សត្វតែងវង្វេងដោយមោហា
ជំពាក់នៅក្នុងកាមតណ្ហា មិនដឹងថ្ងៃណាអាចស្រាយរួច។
-រឹងរឹតប្រាថ្នាក្រៃលែងណាស់ មិនបានដឹងច្បាស់អ្វីតិចតួច
ជាប់ចិត្តនឹងកាមចៀសមិនរួច កិលេសតែងផ្តួចផ្តើមជានិច្ច។
-ងងឹតងងល់មិនភ្លឺថ្លា រស់ឥតបញ្ញាវង្វេងភ្លេច
កំដៅកាមគុណដុតជានិច្ច បានសុខបន្តិចមិនទៅណា។
-ហេតុនេះដឹងចុះមិត្តកល្យាណ បើអ្នកចង់បានឆ្លងសង្សារ
ត្រូវតែលះបង់នូវកាមា ប្រព្រឹត្តធម៌អាចិទើបឆ្លងរួច។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៣៩) បុណ្យបូកនិងបុណ្យ

* សម្រាប់អ្នកឆ្លាតពិតអាចហាន ប្រព្រឹត្តសមាទាននូវកុសលា
ធ្វើដោយខ្លួនឯងឬជ្រះថ្លា នូវបុញ្ញកិរិយាដែលគេឲ្យ។
* បុណ្យពិតមានគុណប្រសើរក្រៃ គឺមានតម្លៃមិនតិចឡើយ
ព្រោះហេតុដូច្នោះកុំកន្តើយ បើគេចែកឲ្យអនុមោទនា។
* កុំគិតថាវាមិនសំណំ ត្រូវចេះផ្សំផ្សំដោយសទ្ធា
បុណ្យបូកនិងបុណ្យផ្តុំចូលគ្នា បានពេញហូរហៀរប្រាកដណាស់។

* បុណ្យជួយឲ្យសុខឲ្យសប្បាយ ផុតចាកអបាយរួចស្រឡះ
ស្រស់ថ្លារុងរឿងភ្លឺត្រចះ នឹងបានជាក់ច្បាស់សច្ចធម៌។

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៤០) មានទ្រព្យត្រូវប្រើដោយបញ្ញា

-មានទ្រព្យត្រូវប្រើដោយបញ្ញា កាន់យកខ្លឹមសារដោយប្រពៃ
ឲ្យទានបរិច្ចាគគិតលកលៃ តាមធម៌វិន័យដ៏បវរ។
-ទំនុកបម្រុងពុទ្ធសាសនា មាតាបិតាឲ្យបានល្អ
សង្គ្រោះញាតិមិត្តអ្នកទ័លក្រ អស់ទៅដោយល្អមានប្រយោជន៍។
-ចិញ្ចឹមខ្លួនឯងនិងគ្រួសារ និងពួកទាសានោះដោយហោច
ធ្វើពលីកម្មកុំលេងសើច ឃុំគ្រងប្រយោជន៍បានសុខជា។
-ព្រោះហេតុដូច្នោះត្រូវកែច្នៃ ឲ្យមានតម្លៃក្នុងទ្រព្យា
សម្រាប់ខ្លួនឯងនិងជនា សុខទាំងអស់គ្នាគ្រប់សន្តាន។

ថ្ងៃ ៩ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៤៣) សូមជូនបុណ្យ

*ធម្មទានក្ដីការគោរពក្ដី បូជាជិនស្រីដោយចិត្តសទ្ធា
រលឹកដល់គុណនៃព្រះភគវា តាមទីនានាដែលជាពុទ្ធស្ថាន។
*សូមបុណ្យកុសលបានជាបច្ច័យ ឧបនិស្ស័យដាក់ដល់ភូមិឋាន

ទីបរមសុខប្រសើរថ្កើងថ្កាន បានសុខក្សេមក្សាន្តរួចចាកទុក្ខហោង។
*ម្យ៉ាងទៀតសូមឲ្យមនុស្សទេវតា និងញាតិវង្សាមិត្តសម្លាញ់ផង
សាធុទទួលដោយចិត្តហ្មត់ហ្មង បានឆ្លងកន្លងផុតចាកទុក្ខដែរ។
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## (៩៩) ប្រពៃណាស់

*ញញឹមរីករាយធ្វើធម្មទាន ញញឹមអាចហានមិននឿយណាយ
ញញឹមធ្វើទៅទាំងសប្បាយ ញញឹមខ្វល់ខ្វាយក្នុងកុសល ។
*ញញឹមគោរពត្រៃរតនា ញញឹមជ្រះថ្លាចិត្តតម្កល់
ញញឹមព្យាយាមឲ្យបានដល់ ញញឹមបានផលសុខក្សេមក្សាន្ត ។
*ញញឹមជូនបុណ្យដោយគោរព ញញឹមបានគប់មិត្តកល្យាណ
ញញឹមសន្តោសចិត្តប្រោសប្រាណ ញញឹមសូមបានក្តីសុខា ។
*ញញឹមសាធុដោយត្រេកអរ ញញឹមបវរចិត្តជ្រះថ្លា
ញញឹមទទួលសាធុការ ញញឹមប្រាប់ថាប្រពៃណាស់ ។
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ៥៥_ថ្ងៃទ្រង់បរិនិព្វាន

-ថ្ងៃ ១៥ កើតវិសាខបុណ្ណមី ឆ្នាំម្សាញ់ប្រុសស្រីគួរឱ្យសង្វេគ
បរិស័ទត្រៀបត្រាច្រើនអនេក ទោមនស្សពេកស្តាយព្រះសាស្តា ។

-ព្រោះថាជាថ្ងៃដែលព្រះទ្រង់ញាណ បរិនិព្វាន ក្រុងកុសិនារា
នៅក្នុងសាលវ័នរបស់ក្សត្រា គ្រប់គ្រងរក្សាដោយស្តេចមល្លក្សត្រ ។
-ព្រះសាស្តាទ្រង់អស់កម្លាំង សែនល្ហិតល្ហៃខ្លាំង ស្ទើរតែសូន្យបាត់
ទ្រង់បានចូលកាន់សាលវ័នមល្លក្សត្រ មិនសូន្យមិនស្ងាត់ភិក្ខុភិក្ខុនី ។
-ព្រះមានព្រះភាគព្រះអង្គទ្រង់ផ្ទំ លើគ្រែឧត្តមទ្រង់បានសម្អី
នៅក្នុងចន្លោះសាលព្រឹក្សទាំងពីរ ទេព្តាមូលមីរបូជាសរីរៈ ។
-ដើម្បីបូជាដល់ព្រះសម្ពុទ្ធ ប្រសើរបំផុត ផ្កាមន្ទារវៈ
លំអិតខ្លឹមចន្ទន៍ ជាដើមបានធ្លាក់ លើព្រះសរីរៈព្រះតថាគត ។
-រីគ្រឿងបូជាហួសពីរៀបរាប់ ប្រសើរគួរគាប់ដ៏ច្រើនបំផុត
បូជាសាស្តាសម្មាសម្ពុទ្ធ ទ្រង់ស្អាតបរិសុទ្ធជាព្រះមុនី ។
-ភិក្ខុជាព្រះអរហន្តា និងសាវិកា ជួបជុំមូលមីរ
ខ្លះជាសេក្ខៈ អនាគាមី មកពីគ្រប់ទីតំបន់ផ្សេងៗ ។
-សកទាគាមី សោតាបន្នៈ សទ្ធាស្មោះស្ម័គ្រមិនបានវង្វេង
នៅក្នុងភពនេះ ឬក្នុងភពផ្សេង មិនបានវង្វេងក្នុងវដ្តសង្សារ ។
-ទោះបុថុជ្ជនអ្នកមានកិលេស ស្មុកស្មាញចាក់ស្រេះនៅក្នុងអាត្មា

មិនថាជាមនុស្ស ឬជាទេវតា ដោយចិត្តជ្រះថ្លា ក្នុងព្រះសម្ពុទ្ធ ។
-ខ្លះសោកខ្សឹកខ្សួលរំជួលហឫទ័យ គួរសង្វេគក្រៃ ចិត្តសែនរន្ធត់
ព្រោះតែព្រាត់ចាកព្រះតថាគត ប្រសើរបំផុតជាងមនុស្សទេវតា ។
-ក្នុងកាលនោះឯងព្រះដ៏មានបុណ្យ ប្រសើរដោយគុណធ្ងន់ក្រៃពេកណា
ទ្រង់បានត្រាស់នូវបច្ឆិមវាចា ដែលមានពាក្យថា ចូរកុំប្រមាទ ។
-ទ្រង់ត្រាស់ប៉ុណ្ណេះជាការបញ្ជាក់ ដល់ពួកសាវ័កចូរខំសង្វាត
ចម្រើនដោយគុណតាមពុទ្ធោវាទ ចូរកុំប្រមាទក្នុងកិច្ចទាំងឡាយ ។
-មុននឹងនិព្វានទ្រង់បានចូលឈាន ចំនួនពីរលានបួនសែនកោដិផ្លាយ
ទ្រង់មិនស្រណោះមិនបានសោកស្ដាយ បរិស័ទទាំងឡាយធ្វើការបូជា ។
-ព្រះមានព្រះភាគបរិនិព្វាន ហេតុចំឡែកមានពេលដំណាលគ្នា
កក្រើកញាប់ញ័រផ្ទៃពសុធា មនុស្សសត្វគ្រប់គ្នាមានចិត្តសង្វេគ ។
-សាវ័កទាំងឡាយគប្បីញ៉ាំងគុណ ប្រសើរពេកពន់ជាច្រើនអនេក
ដើរតាមផ្លូវមគ្គកុំនៅរារែក ញ៉ាំងគុណប្លែកៗឱ្យសម្រេចហោង ។

វត្តនិគ្រោធវ័ន ថ្ងៃ ១៥ កើត ខែវិសាខ ព.ស.២៥៥២

ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅ

-បច្ច័យនៅសល់ពីផ្សាយព្រះធម៌នៅកំពង់សោម

ក្រុមឧបាសិកា តាំង អៀងស៊ុយ ៧០០ ដុល្លា

-បច្ច័យផ្នែកសិក្សាអប់រំ ៣០០ ដុល្លា

-ឧបាសិកា តាត់ យូ ព្រមទាំងកូនចៅ ៣១០ ដុល្លា

-លោក គួច គួងឡេង ឧ.សិ. តាំង យូគាង និងកូនចៅ ២០០ ដ

-លោក ជាម ហួរហុង ឧ.សិ. សុខ គាង និងកូនចៅ ២០០ ដ

-លោក រស់ ថារិទ្ធ និងអ្នកស្រី សេង សុខពិសី ហៅ បងពេជ្យ

ព្រមទាំងកូន ២០០ ដុល្លា

-ឧ.ស. អ៊ុក ចិត្រា ឧ.សិ. វ៉ិន ចិន្តា និងបុត្រ ១១៥ ដុល្លា និង ៥០ ដុល្លា

-ឧបាសិកា ហេ ហ្គេចឆៃ ព្រមទាំងបុត្រ ១០០ ដុល្លា

-ឧបាសិកា អោក បូរ៉ា និងភារិយា ព្រមទាំងបុត្រ ១០០ ដុល្លា

-លោក ឡុង ប៊ុនយ៉េន និងលោកស្រី សួង ខាងឹម

ព្រមទាំងកូនចៅ ៥០ ដុល្លា -ឧ.សិ. ងួន ស៊ីលាង និងបុត្ត ៥០ ដុល្លា

-ឧ.សិ. ផាង ស្រួយ និងកូនចៅ ៥០ ដុល្លា -ឧ.សិ. ម៉ៅ ៣០ ដុល្លា

-ឧ.សិ. លោកស្រី ដាណា ៣០ ដុល្លា -ឧ.សិ. ចេង គាង ១០០,០០០ រ

-ឧ.ស. ហ៊ូ សៅ និងភរិយា តេង សុខណា និងបុត្រ និងញាតិព្រះធម៌ ២៥ ដុល្លា

-ឧ.សិ. ពៅ នារី និងស្វាមី និងកូនចៅ ២០ ដុល្លា

-ឧ.សិ. ស្រី ថា និងស្វាមី និងកូន ២០ ដុល្លា -ឧ.សិ. ហួរ អ៊ី ២០ដុល្លា

-ឧ.សិ. នាក់ សុខា (សុជាតា) ២០ ដុល្លា -ឧ.សិ. សេង ចម្រើន ២០ដុល្លា

-លោក មៀច វណ្ណា និងភរិយា និងកូនចៅ ២០ ដុល្លា

-លោក ឌៀប រុណ ព្រមទាំងកូនចៅ ២០ ដុល្លា

-ឧ.សិ. ប្រាក់ សាអឿន នៅភូមិ៦ ៦០,០០០ រ

-ឧ.សិ. មួង សារឿន ៥០,០០០ រ -ឧ.សិ. វ៉ាន់ សយ ៥០,០០០ រ

-ឧ.សិ. ម៉ូវ ផល្លា ៤០,០០០ រ -ឧ.សិ. ម៉ែន សាន ៤០,០០០ រ

-ឧ.សិ. ប៊ុត ស៊ីមមន្ថា ៤០,០០០ រ -ឧ.សិ. មុំ រឿន ៤០,០០០រ

-ឧ.ស. ហួន វុឌ្ឍី ឧ.សិ. ឯក វ៉ាន់នី ៤០,០០០រ

-ឧ.សិ. ផៃ សុខហេង ៤០,០០០រ -ឧ.សិ. ចាន់ មុំ ៤០,០០០រ

-ឧ.ស. សុខ ផល្លា ឧ.សិ. នាក់ សុខុម ៤០,០០០រ

-ឧ.សិ. សំ ស្រីទូច ៤០,០០០រ

-ឧ.សិ. សួន ឈន និងលោក ផល អ្នកស្រី ហួក ៤០,០០០រ

-ពុទ្ធបរិស័ទ ភូមិត្នោតញី ខ្ពប ស្អាង ខេត្តកណ្ដាល ៤០០០០ រ

-លោក ជា យាម និងអ្នកស្រី ឆ្វយ ណារី ១០ ដុល្លា

-ឧ.សិ. ទឹម រឿន និងកូនចៅ ១០ ដុល្លា

-អ្នកស្រី ជា ហ៊ុយជ័ង និងលោក ប៊ូ នី ១០ ដុល្លា

-ឧ.ស. ធន ច័ន្ទសុជាតិ ១០ ដុល្លា -ឧ.សិ. ជា សារ៉េត ១០ ដុល្លា

-ឧ.ស. អោក អ៊ុម, ឧ.សិ. យឹម សុផានី ព្រមទាំងកូនចៅ,

ឧ.សិ. ទឹម វ៉ាន់ឆៃ ព្រមទាំងកូនចៅ ១០ ដុល្លា

-ឧ.សិ. ទូច គីមហួយ និងស្វាមី និងបុត្ត ១០ ដុល្លា

-ឧ.សិ. ប៉ាវ សេងហួ និងស្វាមី និងបុត្ត ១០ ដុល្លា

-ឧ.សិ. ហែម ណារី និងបុត្ត ១០ ដុល្លា

-លោក សាត សុធី និងអ្នកស្រី ទូច  និងកូនចៅ ១០ ដុល្លា

-ឧ.សិ. ឈរ ហុកលីវ និងបុត្រ ១០ ដុល្លា

-ឧ.សិ. មៀច ទូច  ឧ.សិ. មៀច នាង ១០ ដុល្លា

-ឧ.ស. ស៊ីយ ប៉ុណ្ណរតន៍ និងឧ.សិ. សួស សោភា និងបុត្ត ១០ ដ

-ឧ.ស. ជ្រា បេង គ្រិច គីម ១០ ដុល្លា

-ឧ.ស. ទ្រី ប៉ាវ  ឧ.សិ. តាត់ ណៃជា ១០ ដុល្លា

-ឧ.សិ. ថ្លាង តាំងគាង និងកូនចៅ ១០ ដុល្លា

-ឧ.សិ. វិន សុខា និងកូន ៣០០០០ ៛  -ឧ.សិ. ខៀវ អៀម ៣០,០០០ ៛

-ឧ.សិ. ស៊ុប គឹម និងក្រុមញាតិ ៣០,០០០៛

-ឧ.សិ. ទុយ មុំ និងស្វាមី និងបុត្ត ២០,០០០ ៛

-ឧ.សិ. ឈរ ហុកលីវ និងបុត្ត ២០,០០០ ៛

-ឧ.សិ. ហេង ណឹម និងកូនចៅ ២០,០០០ ៛

-ឧ.សិ. អ៊ុន អាត  និងកូនចៅ ២០,០០០៛

-ឧ.ស. នៅ វិន  ឧ.សិ. សូរ សាម៉ុល និងកូន ២០,០០០៛

-ឧ.សិ. អ៊ុន អាត  និងកូនចៅ ២០,០០០៛  -ឧ.សិ. ចន្ថា ២០,០០០ ៛

-ឧ.សិ. វីរៈ ម៉ាឡា ២០,០០០ ៛  -ឧ.សិ. ពិន សំបូរ ០៥ដុល្លា

-ឧ.សិ. សុខ ខេង ២០,០០០៛  -ឧ.សិ. កេង ណៃ ២០,០០០ ៛

-សីលវតី ប្រាក់ សាអូន វត្តរោងដំរី ២០,០០០ ៛

-សីលវតី អួន សុថុន វត្តរោងដំរី ២០,០០០ ៛

-សីលវតី ហោ អៀន វត្តពោងដំរី ២០,០០០ ៛

-សីលវតី ស៊ិន ឡេក វត្តពោងដំរី ២០,០០០ ៛

-ឧ.សិ. ប្រាក់ សារុន ភូមិ៦ ២០,០០០ ៛

-ឧ.សិ. ហ៊្វ ប៉ៀន និងស្វាមី ភូមិ៦ ២០,០០០ ៛

-ឧ.សិ. ជុន សារុំ និងកូនចៅ ភូមិ៦ ២០,០០០ ៛

-លោក ផល អ្នកស្រី ហួត និងកូន ភូមិ៦ ២០,០០០ ៛

-ឧ.សិ. សួន ឈន និងកូនចៅ ភូមិ៦ ២០,០០០ ៛

-ឧ.សិ. ហេង ស៊ីវ ខេង ២០,០០០ ៛ -ឧ.សិ. សំណាង ទ្រព្យ ២០,០០០ ៛

-ឧ.ស. ឡៅ ប៊ុនសារ៉ាក់ ២០,០០០៛ -ឧ.សិ. រ័ត ម៉េង ២០០០០ ៛

-ឧ.សិ. អ៊ឹង សៀកមួយ ២០០០០ ៛ -ឧ.សិ. ម៉ុញ សុគត ២០០០០ ៛

-ឧ.សិ. ម៉ៅ ផល្លី ២០០០០ ៛ -ឧ.សិ. កាន ២០,០០០ ៛

-ឧ.ស. ជា តុងអាន និង ឧ.ស. ខាត់ សារ៉េត ២០,០០០ ៛

-ឧ.សិ. លីម ផិចហៀង និងកូមចៅ ២០,០០០ ៛

-ឧ.សិ. ជីវ ធឿង និងកូនចៅ ២០,០០០ ៛

-ឧ.ស. នៅ វិន ឧ.សិ. សូរ សាម៉ុល និងកូន២០០០០៛

-ឧ.សិ. អ៊ុន អាត និងកូន ២០០០០៛ -ឧ.សិ. អុន អាន (បុត្ត) ២០០០០ ៛

-ឧ.សិ. រួន រិន ឧ.សិ. សុភ័ណ ២០០០០ ៛

-ឧ.ស. ឡាង ផល ឧ.សិ. ផៃគុយលាង ២០០០០ ៛

-ឧ.សិ. ង៉ូវ ខាគារ និងកូនក្មួយ ៥ ដុល្លា -ឧ.សិ. ជា សុភាព ៥ ដុល្លា

-ឧ.សិ. ចេង ហុង ០៥ ដុល្លា -ឧ.សិ. ទូន សីណា ៣ ដុល្លា

-ពុទ្ធបរិស័ទត្រពាំងថ្លឹង ១៥,០០០ ៛ -ឧ.សិ. មាស ប៊ិន ១៥០០០ ៛

-ទាយិកា គួយ និងស្វាមី ១០,០០០ ៛ -ឧ.សិ. ចាន់ លីណា ១០,០០០ ៛

## នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅ

-ឧ.សិ. អ៊ុង វឌ្ឍនា ១០,០០០ ៛ -ឧ.សិ. ស្រេង ឃីម ១០,០០០ ៛
-ឧ.សិ. គឹម ឆេន ១០,០០០ ៛ -ឧ.សិ. ចាន់ សុខានី ១០,០០០ ៛
-ទាយិកា អ៊ាន ដូរ៉ា ព្រមទាំងបុត្រ ១០,០០០ ៛
-ឧ.សិ. សុខ ណៃ ១០,០០០ ៛ -ឧ.សិ. ហុង វ៉ាន់ស៊ី ១០០០០ ៛
-ឧ.សិ. មាន លីណា ១០០០០៛ -ឧ.សិ. នូ សុខុម ១០,០០០ ៛
-ឧ.សិ. ឈុន យូហួង ១០០០០ ៛ -ឧ.សិ. ង៉ែត សុមាលី ១០,០០០៛
- បង ថេន ១០,០០០ ៛ -ឧ.សិ. សៀង សេង ១០,០០០ ៛
-លោក ជីម ឡុង និងលោកស្រី មួយ ហៀង
ព្រមទាំងកូនចៅ ១០,០០០ ៛ -ឧ.ស. ហួន វុឌ្ឍិន ១០០០០ ៛
-ឧ.សិ. ផេង លិន ១០,០០០ ៛ -ឧ.សិ. យ៉ឺ បួយ ៥០០០ ៛
-លោក ឆេង ផាង និងភរិយា និងបុត្ត ១០០០០ ៛
-ឧ.ស. ហួន ច័ន្ទថូ ឧ.សិ. នុត សុខា ១០០០០ ៛
-ឧ.សិ. ហួន វុឌ្ឍថាន់ ឧ.សិ. រិនសុភាព ១០០០០ ៛
-សិស្ស ហួន ធនរ័ត្ន ១០០០០ ៛ -ឧ.សិ. រិន សុភា ១០០០០ ៛
-ឧ.សិ. ហេង លួន ៥,០០០ ៛ -ឧ.សិ. នី ៥,០០០ ៛
-ឧ.សិ. អុន លឹមស្រ៊ុន ៥០០០ ៛ -ឧ.សិ. សាំង ធី ៥០០០ ៛
-ឧ.សិ. ប៉ាង ស្រីអូន ៥០០០ ៛ -ឧ.សិ. ទ្រី គន្ធី ៥០០០ ៛
-ឧ.សិ. ប៉ា ស៊ីណាត ៥០០០៛ -ឧ.សិ. ប៉ោ ស៊ុនសុខ ៥,០០០ ៛
-ឧ.សិ. ស៊ី ចាន់ ៥,០០០ ៛ -ឧ.សិ. ណា គឹមលី ២,០០០ ៛

សូមអនុមោទនា កុសលធម្មទានរបស់ពុទ្ធបរិស័ទ !